

# ព្រះ
# ត្រៃបិដកបាឡី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# វិនយបិដក
# មហាវិភង្គ តតិយភាគ
# ៣

*និស្សគ្គិយកណ្ឌ និង បាចិត្តិយកណ្ឌ*



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# Vinayapiṭaka

## Mahāvibhaṅga tatiyabhāga

## 3

## Nissaggiyakaṇḍa

## &

## Pācittiyakaṇḍa

**សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី**
**សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្វាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

**វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩**

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

# សេចក្តីណែនាំក្នុងការអាន

១ ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២ ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣ ចំពោះ **សន្លឹកច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# វិនយបិដក មហាវិភង្គ

## តតិយភាគ

## ៣

## និស្សគ្គិយកណ្ឌ និង ចាចិត្តិយកណ្ឌ

# តតិយោ ភាគោ

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## និស្សគ្គិយកណ្ឌំ

## ឥមេ ខោ បនាយស្មន្តោ តឹស និស្សគ្គិយា

## ចាចិត្តិយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

## ចីវរវគ្គស្ស បឋមសិក្ខាបទំ

[១] តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ គោតមកេ ចេតិយេ ។ តេន ខោ បន សមយេន ភគវតា ភិក្ខូនំ តិចីវរំ អនុញ្ញាតំ ហោតិ ។ ឆព្វគ្គិយា ភិក្ខូ ភគវតា តិចីវរំ អនុញ្ញាតន្តិ អញ្ញេនេវ តិចីវរេន គាមំ បវិសន្តិ អញ្ញេនេវ តិចីវរេន អារាមេ អច្ឆន្តិ

វិនយបិដក មហាវិភង្គ

# ភាគទី ៣

*ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ*
*ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

*និស្សគ្គិយកណ្ឌ*

*បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិនិស្សគ្គិយបាចិត្តិយ*
*ទាំង ៣០ នេះឯង មកកាន់ឧទ្ទេស*
*(គឺព្រះបាតិមោក្ខដែលសង្ឃត្រូវសំដែងរាល់កន្ទះខែ) ។*

## ចីវរវគ្គ សិក្ខាបទទី ១

[១] *សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងគោតមកចេតិយ ទៀបក្រុងវេសាលី ។ វេលានោះឯង ត្រៃចីវរដែលព្រះដ៏មានព្រះភាគ ទ្រង់បានអនុញ្ញាតដល់ភិក្ខុទាំងឡាយ រួចស្រេចហើយ ។ ពួកឆព្វគ្គិយភិក្ខុ (ភិក្ខុមានពួក ៦) បានដឹងថា ត្រៃចីវរព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតហើយ (ក៏ប្រើប្រាស់ចីវរហួសពុទ្ធានុញ្ញាត គឺប្រើប្រាស់ចីវរបីត្រៃ) ចូលទៅកាន់ស្រុក (ស្លៀកដណ្តប់) ចីវរមួយត្រៃ នៅក្នុងអារាម (ស្លៀកដណ្តប់) ចីវរមួយត្រៃ*

អញ្ញេនេវ តិចីវរេន នហានំ ឱតរន្តិ ។ យេ តេ ភិក្ខូ
អប្បិច្ឆា សន្តុដ្ឋា លជ្ជិនោ កុក្កុច្ចកា សិក្ខាកាមា
តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម
ឆព្វគ្គិយា ភិក្ខូ អតិរេកចីវរំ ធារេស្សន្តីតិ ។ អថខោ
តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ
ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ
សន្និបាតាបេត្វា ឆព្វគ្គិយេ ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ
តុម្ហេ ភិក្ខវេ អតិរេកចីវរំ ធារេថាតិ ។ សច្ចំ ភគវាតិ ។
វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ មោឃបុរិសា អ-
ននុលោមិកំ អប្បដិរូបំ អស្សាមណកំ អកប្បិយំ
អករណីយំ កថំ ហិ នាម តុម្ហេ មោឃបុរិសា
អតិរេកចីវរំ ធារេស្សថ នេតំ មោឃបុរិសា អប្បសន្នា-
នំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ

ចុះកាន់កំពង់ងូតទឹក (ស្លៀកដណ្តប់) ចីវរមួយត្រៃ ។ ភិក្ខុទាំងឡាយណា ដែលជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកមានសេចក្តីអៀនខ្មាស ជាអ្នកក្តៅក្រហាយនឹងបាប ជាអ្នកពេញចិត្តខាងការរៀនសូត្រ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបីបើនឹងប្រើប្រាស់អតិរេកចីវរ (ចីវរច្រើន) លើសកំណត់ ។ លំដាប់នោះ ភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ រួចត្រាស់សួរបញ្ជាក់ទៅពួកឆព្វគ្គិយភិក្ខុក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានប្រើប្រាស់អតិរេកចីវរ មែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការណ៍នោះ ពិតមែន ។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងរាល់គ្នាធ្វើនេះ មិនទំនង មិនសមបែប មិនសមគួរ មិនមែនជារបស់សមណៈ ជាការមិនគប្បី មិនគួរបើនឹងធ្វើសោះ ម្នាលមោឃបុរសទាំងឡាយ គួរបើដែរ អ្នកឯងរាល់គ្នានឹងប្រើប្រាស់អតិរេកចីវរ (យ៉ាងនេះ) ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងរាល់គ្នាធ្វើនេះ នឹងបាននាំមនុស្សដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬមនុស្សដែលបានជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លា

និស្សគ្គិយកណ្ឌោ ចីវរវគ្គស្ស បឋមសិក្ខាបទស្ស បញ្ញត្តិនិទានំ

។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អតិរេកចីវរំ ធារេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[២] តេន ខោ បន សមយេន អាយស្មតោ អានន្ទស្ស អតិរេកចីវរំ ឧប្បន្នំ ហោតិ ។ អាយស្មា ច អានន្ទោ តំ ចីវរំ អាយស្មតោ សារីបុត្តស្ស ទាតុកាមោ ហោតិ ។ អាយស្មា ច សារីបុត្តោ សាកេតេ វិហរតិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ ភគវតា សិក្ខាបទំ បញ្ញត្តំ ន អតិរេកចីវរំ ធារេតព្វន្តិ ឥទញ្ច មេ អតិរេកចីវរំ ឧប្បន្នំ អហញ្ចិមំ ចីវរំ អាយស្មតោ សារីបុត្តស្ស ទាតុកាមោ អាយស្មា ច សារីបុត្តោ សាកេតេ វិហរតិ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ កីវចិរំ បនានន្ទ សារីបុត្តោ អាគច្ឆិស្សតីតិ ។ នវមំ វា ភគវា ទិវសំ ទសមំ វាតិ ។

ឡើងទៀត (នោះ) ក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ប្រើប្រាស់អតិ-រេកចីវរ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ[១] ។ ឯសិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ ។

[២] គ្រានោះ អតិរេកចីវរ កើតឡើងដល់ព្រះអានន្ទដ៏មានអាយុ ។ ព្រះអានន្ទដ៏មានអាយុ ចង់ប្រគេនចីវរនោះទៅព្រះសារីបុត្តដ៏មានអាយុ ។ តែព្រះសារីបុត្តដ៏មានអាយុ លោកគង់នៅឯនគរសាកេត (មិនទាន់និមន្តមកដល់) ។ វេលានោះ ព្រះអានន្ទដ៏មានអាយុ ត្រិះរិះគិតថា ព្រះដ៏មានព្រះភាគបានបញ្ញត្តសិក្ខាបទថា ភិក្ខុមិនត្រូវទ្រទ្រង់អតិរេកចីវរឡើយ ឥឡូវ អតិរេកចីវរ កើតឡើងដល់អញហើយ អញមានបំណងនឹងប្រគេនចីវរនេះ ទៅព្រះសារីបុត្តដ៏មានអាយុ តែព្រះសារីបុត្តដ៏មានអាយុ លោកគង់នៅឯនគរសាកេត តើអញត្រូវប្រតិបត្តិដូចម្ដេចអេះ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ បានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលអានន្ទ ចុះសារីបុត្តនៅយូរប៉ុន្មានថ្ងៃទៀតនឹងមកដល់ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ ប្រហែលជាប្រាំបួនថ្ងៃ ឬដប់ថ្ងៃទៀត

---
១ គឺអតិរេកចីវរនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ទសា-ហបរមំ អតិរេកចីវរំ ធារេតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ និដ្ឋិតចីវរស្មឹ ភិក្ខុនា ឧព្ភតស្មឹ កឋិនេ ទសាហបរមំ អតិរេកចីវរំ ធារេតព្វំ តំ អតិក្កាមយតោ និស្សគ្គិយំ ចាចិត្តិយន្តិ ។

[៣] និដ្ឋិតចីវរស្មិន្តិ ភិក្ខុនោ ចីវរំ កតំ វា ហោតិ នដ្ឋំ វា វិនដ្ឋំ វា ទឌ្ឍំ វា ចីវរាសា វា ឧបច្ឆិន្នា ។ ឧព្ភតស្មឹ កឋិនេតិ អដ្ឋន្នំ មាតិកានំ អញ្ញតរាយ មាតិកាយ ឧព្ភតំ ហោតិ សង្ឃេន វា អន្តរា ឧព្ភតំ ហោតិ ។ ទសាហបរមន្តិ ទសាហបរមតា ធារេ-តព្វំ ។ អតិរេកចីវរំ នាម អនធិដ្ឋិតំ អវិកប្បិតំ ។

(ទើបលោកនឹងនិមន្តមកដល់) ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យអ្នករាល់គ្នាទុកអតិរេកចីវរ កំណត់ត្រឹមដប់ថ្ងៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើចីវរសម្រេចហើយ (ក្តី) កឋិនដោះហើយ (ក្តី) ភិក្ខុត្រូវទុកអតិរេកចីវរ បានតែត្រឹមដប់ថ្ងៃ បើឲ្យកន្លងហួសពីដប់ថ្ងៃនោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[៣] ត្រង់ពាក្យថា ចីវរសម្រេចហើយ អធិប្បាយថា ចីវរដែលភិក្ខុបានធ្វើរួចហើយក្តី ចីវរដែលបាត់ដោយចោរជាដើមលួចយកទៅក្តី ចីវរវិនាសដោយសត្វកណ្តៀរជាដើមកាត់ក្តី ចីវរដែលភ្លើងឆេះក្តី សេចក្តីប្រាថ្នាក្នុងចីវរ (របស់ភិក្ខុនោះ) ដាច់ស្រឡះក្តី ។ ពាក្យថា កឋិនដោះហើយ គឺកឋិនដែលដោះដោយបណ្តាមាតិកា ៨ យ៉ាង មាតិកាណាមួយ ឬសង្ឃបានប្រជុំគ្នាសូត្រដោះក្នុងកាលជាចន្លោះ ។ ពាក្យថា កំណត់ត្រឹមដប់ថ្ងៃ គឺភិក្ខុត្រូវទុក (អតិរេកចីវរ) កំណត់យ៉ាងយូរបានត្រឹមតែដប់ថ្ងៃ ។ ចីវរដែលភិក្ខុមិនបានអធិដ្ឋាន មិនបានវិកប្ប

ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនូបគំ បច្ឆិមំ[1] ។ តំ អតិក្កាមយតោ និស្សគ្គិយំ ហោតីតិ[2] ឯកាទសេ អរុណុគ្គមនេ និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។

[៤] តេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ ឥទំ មេ ភន្តេ ចីវរំ ទសាហាតិក្កន្តំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន អាបត្តិ បដិគ្គហេតព្វា និស្សដ្ឋចីវរំ ទាតព្វំ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ ចីវរំ ឥត្ថន្នាមស្ស ភិក្ខុនោ និស្សគ្គិយំ សង្ឃស្ស និស្សដ្ឋំ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ ចីវរំ ឥត្ថន្នាមស្ស ភិក្ខុនោ ទទេយ្យាតិ ។

---

១ ឱ. វិកប្បនុបគបច្ឆិមំ ។ ២ និស្សគ្គិយំ ហោតីតិ ឯត្ថ ហោតិសទ្ទោ អតិរេកបាឋោ ភវេយ្យ សុត្តេ អនាគតត្តា ។ ឥតរថា សុត្តំ ឩនំ សិយា ឯវំ និស្សគ្គិយំ ហោតិ បាចិត្តិយន្តិ ភវេយ្យ ។ វិចារេត្វា គហេតព្វំ ។

ឈ្មោះថា អតិរេកចីវរ ។ បណ្ដាចីវរទាំង ៦ ចីវរណាមួយដែលតូចបំផុត គួរល្មមភិក្ខុវិកប្បបាន ឈ្មោះថា ចីវរ ។ ពាក្យថា បើទុកឲ្យកន្លងហួសពីដប់ថ្ងៃនោះទៅ ត្រូវនិស្សគ្គិយ អធិប្បាយថា ចីវរ កាលបើអរុណរះឡើងក្នុងថ្ងៃទី ១១ (ឡើងទៅ) ភិក្ខុត្រូវលះចេញ គឺត្រូវលះដល់ជំនុំសង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះ (ចីវរដល់ជំនុំសង្ឃ) បែបយ៉ាងនេះ ។

[៤] ភិក្ខុនោះឯង ត្រូវ (យកចីវរដែលជានិស្សគ្គិយនោះ) ចូលទៅរកជំនុំសង្ឃ ហើយធ្វើឧត្តរាសង្គ (ចីពរ) ឆៀងស្មាម្ខាងរួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងប្រណម្យអញ្ជលីឡើង ពោលនឹងសង្ឃយ៉ាងនេះថា បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន នេះចីវររបស់ខ្ញុំកន្លងដប់ថ្ងៃ ត្រូវនិស្សគ្គិយហើយ ឥឡូវ ខ្ញុំសូមលះចីវរនេះដល់ជំនុំសង្ឃ ។ លុះ (ភិក្ខុនោះ) លះរួចហើយ ត្រូវសំដែងអាបត្តិចេញ ។ ភិក្ខុអ្នកឆ្លាសអង់អាចត្រូវទទួលអាបត្តិ ត្រូវប្រគល់ចីវរដែលលះបង់ឲ្យដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ ដ្បិតភិក្ខុឈ្មោះនេះ[១] បានលះចីវរនេះដែលត្រូវនិស្សគ្គិយដល់ជំនុំសង្ឃហើយ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវប្រគល់ចីវរនេះ ឲ្យទៅភិក្ខុឈ្មោះនេះ[២]វិញចុះ ។

១-២ ត្រង់នេះ ត្រូវដាក់ឈ្មោះបញ្ចូលមក គឺបើភិក្ខុនោះឈ្មោះអ្វី ត្រូវចេញឈ្មោះនោះ ដូចឈ្មោះថា ពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត ជាដើម ។

[៥] តេន ភិក្ខុនា សម្ពហុលេ ភិក្ខូ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ ឥទំ មេ ភន្តេ ចីវរំ ទសាហាតិក្កន្តំ និស្សគ្គិយំ ឥមាហំ អាយស្មន្តានំ និស្សជ្ជាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន អាបត្តិ បដិគ្គហេតព្វា និស្សដ្ឋចីវរំ ទាតព្វំ សុណន្តុ មេ អាយស្មន្តា ឥទំ ចីវរំ ឥត្ថន្នាមស្ស ភិក្ខុនោ និស្សគ្គិយំ អាយស្មន្តានំ និស្សដ្ឋំ ។ យទាយស្មន្តានំ បត្តកល្លំ អាយស្មន្តា ឥមំ ចីវរំ ឥត្ថន្នាមស្ស ភិក្ខុនោ ទទេយ្យុន្តិ ។

[៦] តេន ភិក្ខុនា ឯកំ ភិក្ខុំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ ឥទំ មេ អាវុសោ ចីវរំ ទសាហាតិក្កន្តំ និស្សគ្គិយំ ឥមាហំ អាយស្មតោ

[៥] (បើលះចីវរដល់គណៈ) ភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុច្រើនអង្គ (គឺភិក្ខុបីរូប ឬ ពីររូប) ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាងសំពះទៀបបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងប្រណម្យអញ្ជលីឡើង ពោលនឹងភិក្ខុទាំងនោះយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន នេះចីវររបស់ខ្ញុំ កន្លងដប់ថ្ងៃ ត្រូវនិស្សគ្គិយហើយ ឥឡូវ ខ្ញុំសូមលះចីវរនេះដល់លោកដ៏មានអាយុទាំងឡាយ ។ ភិក្ខុនោះលះរួចហើយ ត្រូវសំដែងអាបត្តិចេញ ។ ភិក្ខុអ្នកឆ្លាសអង់អាចត្រូវទទួលអាបត្តិ រួចត្រូវឲ្យចីវរដែលភិក្ខុលះនោះ ដោយពាក្យថា សូមលោកដ៏មានអាយុទាំងឡាយ ស្តាប់ពាក្យខ្ញុំ ចីវរនេះរបស់ភិក្ខុឈ្មោះនេះ ជានិស្សគ្គិយ លោកបានលះបង់ ដល់លោកដ៏មានអាយុទាំងឡាយហើយ ។ បើកម្មមានកាលដ៏សមគួរដល់លោកដ៏មានអាយុទាំងឡាយហើយ អស់លោកដ៏មានអាយុ ត្រូវប្រគល់ចីវរនេះ ឲ្យទៅភិក្ខុឈ្មោះនេះវិញចុះ ។

[៦] (បើលះដល់បុគ្គល) ភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុមួយរូប ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង រួចអង្គុយច្រហោង ប្រណម្យអញ្ជលីឡើង ហើយពោលនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ នេះចីវររបស់ខ្ញុំ កន្លងដប់ថ្ងៃហើយត្រូវតែលះបង់ ឥឡូវ ខ្ញុំសូមលះចីវរនេះដល់លោក

៧

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស បឋមសិក្ខាបទស្ស អាបត្តិវារោ

និស្សដ្ឋាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា ។ តេន ភិក្ខុនា អាបត្តិ បដិគ្គហេតព្វា និស្សដ្ឋចីវរំ ទាតព្វំ ឥមំ ចីវរំ អាយស្មតោ ទម្មីតិ ។

[៧] ទសាហាតិក្កន្តេ អតិក្កន្តសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ ទសាហាតិក្កន្តេ វេមតិកោ និស្សគ្គិយំ បាចិត្តិយំ ។ ទសាហាតិក្កន្តេ អនតិក្កន្តសញ្ញី និស្ស-គ្គិយំ បាចិត្តិយំ ។ អនធិដ្ឋិតេ អធិដ្ឋិតសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ អវិកប្បិតេ វិកប្បិតសញ្ញី និស្សគ្គិយំ បា-ចិត្តិយំ ។ អវិស្សជ្ជិតេ វិស្សជ្ជិតសញ្ញី និស្សគ្គិយំ បាចិត្តិ-យំ ។ អនដ្ឋេ នដ្ឋសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ អវិនដ្ឋេ វិនដ្ឋសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ អទឌ្ឍេ ទឌ្ឍសញ្ញី

ដ៏មានអាយុ ។ ភិក្ខុនោះ លុះលះរួចហើយត្រូវសំដែងអាបត្តិចេញ ។ ភិក្ខុនោះ ត្រូវទទួលអាបត្តិ ហើយត្រូវប្រគល់ចីវរដែលលះបង់ ដោយពាក្យថា ខ្ញុំឲ្យចីវរនេះ ទៅលោកដ៏មានអាយុវិញ ។

[៧] (កាលបើចីវរ) កន្ទង់ហួសដប់ថ្ងៃហើយ ភិក្ខុដឹងច្បាស់ថា កន្ទង់ ត្រូវនិស្សគ្គិយបាចិត្តិយ ។ (កាលបើចីវរ) កន្ទង់ហួសដប់ថ្ងៃហើយ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវនិស្សគ្គិយបាចិត្តិយ ។ (កាលបើចីវរ) ដែលកន្ទង់ហួសដប់ថ្ងៃហើយ ភិក្ខុសំគាល់ថា មិនទាន់កន្ទង់ទេ ត្រូវនិស្សគ្គិយបាចិត្តិយ ។ (កាលបើចីវរ) ដែលមិនទាន់បានអធិដ្ឋានហើយភិក្ខុសំគាល់ថា បានអធិដ្ឋានហើយ ត្រូវនិស្សគ្គិយបាចិត្តិយ ។ (កាលបើចីវរ) ដែលភិក្ខុមិនទាន់បានវិកប្ប ហើយភិក្ខុសំគាល់ថា បានវិកប្ប ត្រូវនិស្សគ្គិយបាចិត្តិយ ។ (កាលបើចីវរ) ដែលភិក្ខុមិនទាន់បានលះហើយភិក្ខុដឹងច្បាស់ថា បានលះ ត្រូវនិស្សគ្គិយបាចិត្តិយ ។ (កាលបើចីវរ) មិនបាត់ទេ ហើយភិក្ខុសំគាល់ថា បាត់ ត្រូវនិស្សគ្គិយបាចិត្តិយ ។ (កាលបើចីវរ) មិនខូចទេ ហើយភិក្ខុសំគាល់ថា ខូច ត្រូវនិស្សគ្គិយបាចិត្តិយ ។ (កាលបើចីវរ) ភ្លើងមិនឆេះទេ ហើយភិក្ខុសំគាល់ថា ភ្លើងឆេះ

និស្សគ្គិយំ ចាចិត្តិយំ ។ អវិលុត្តេ វិលុត្តសញ្ញី និស្សគ្គិយំ ចាចិត្តិយំ ។ និស្សគ្គិយំ ចីវរំ អនិស្សជ្ជិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។ ទសាហានតិក្កន្តេ អតិក្កន្តសញ្ញី អាបត្តិ ទុក្កដស្ស ។ ទសាហានតិក្កន្តេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ទសាហានតិក្កន្តេ អនតិក្កន្តសញ្ញី អនាបត្តិ ។

[៨] អនាបត្តិ អន្តោទសាហំ អធិដ្ឋេតិ វិកប្បេតិ វិស្សជ្ជេតិ នស្សតិ វិនស្សតិ ឌយ្ហតិ អច្ឆិន្ទិត្វា គណ្ហាតិ[១] វិស្សាសំ គណ្ហាតិ[២] ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៩] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ និស្សដ្ឋចីវរំ ន ទេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ

---

១-២ ឱ. ម. គណ្ហន្តិ ។

ត្រូវនិស្សគ្គិយបាចិត្តិយ ។ (កាលបើចីវរ) ចោរឥតបានប្លន់យកទេ តែភិក្ខុសំគាល់ថា ចោរប្លន់យក ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមិនបានលះចីវរដែលត្រូវនិស្សគ្គិយ ហើយយកមកប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ (កាលបើចីវរ) មិនទាន់កន្លងហួសដប់ថ្ងៃទេ ភិក្ខុសំគាល់ថា កន្លងហើយ ត្រូវអាបត្តិទុក្កដ ។ (កាលបើចីវរ) មិនទាន់កន្លងហួសដប់ថ្ងៃទេ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ (កាលបើចីវរ) មិនទាន់កន្លងហួសដប់ថ្ងៃ ហើយភិក្ខុក៏សំគាល់ថា មិនទាន់កន្លងទេ មិនត្រូវអាបត្តិឡើយ ។

[៨] វារៈដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុបានអធិដ្ឋាន បានវិកប្បក្នុងខាងក្នុងដប់ថ្ងៃ ១ ភិក្ខុបានលះ ១ ចីវរបាត់ ១ ចីវរខូច ១ ចីវរភ្លើងឆេះ ១ ចីវរចោរដណ្តើមយក ១ ចីវរដែលភិក្ខុយកដោយសេចក្តីស្និទ្ធស្នាល ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៩] ក្នុងសម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនប្រគល់ចីវរ ដែលលះឲ្យទៅភិក្ខុ (ម្ចាស់ចីវរ) នោះវិញ ។ ភិក្ខុទាំងឡាយណា ដែលជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏លើកទោស

៩

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស បឋមសិក្ខាបទស្ស ទុក្កដប្បញ្ញត្តិ

ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ និស្សដ្ឋចីវរំ ន ទស្សន្តីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឆព្វគ្គិយេ ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ តុម្ហេ ភិក្ខវេ និស្សដ្ឋចីវរំ ន ទេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា ។ បេ ។ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ និស្សដ្ឋចីវរំ ន ទាតព្វំ យោ ន ទទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។

តិះដៀល បន្ទោសថា គួរបើដែរ ពួកឆព្វគ្គិយភិក្ខុមិនឲ្យចីវរដែលលះ (ទៅភិក្ខុម្ចាស់ចីវរ) វិញ ។ ភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូលសេចក្តីនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរទៅពួកឆព្វគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយមិនបានឲ្យចីវរដែលលះ (ទៅភិក្ខុម្ចាស់ចីវរ) វិញ មែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា មែន ព្រះអង្គ ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោស ។ បេ ។ រួចទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយ ដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំមិនឲ្យចីវរដែលលះ (ទៅភិក្ខុម្ចាស់ចីវរ) វិញ ភិក្ខុណាមិនឲ្យ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

សិក្ខាបទទី ១ ចប់ ។

# ទុតិយសិក្ខាបទំ

[១០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខូ ភិក្ខូនំ ហត្ថេ ចីវរំ និក្ខិបិត្វា សន្តរុត្តរេន ជនបទចារិកំ បក្កមន្តិ ។ តានិ ចីវរានិ ចិរំ(១) និក្ខិត្តានិ កណ្ណកិតានិ ហោន្តិ ។ តានិ ចីវរានិ(២) ភិក្ខូ ឱតាបេន្តិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ សេនាសនចារិកំ អាហិណ្ឌន្តោ តេ ភិក្ខូ តានិ ចីវរានិ ឱតាបេន្តេ ទិស្វាន យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច កស្សិមានិ អាវុសោ ចីវរានិ កណ្ណកិតានីតិ ។ អថខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស ឯតមត្ថំ អារោចេសុំ ។ អាយស្មា អានន្ទោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខូ ភិក្ខូនំ ហត្ថេ ចីវរំ និក្ខិបិត្វា សន្តរុត្តរេន ជនបទចារិកំ បក្កមិស្សន្តីតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ អថខោ ភគវា តេ ភិក្ខូ បដិបុច្ឆិ

---

១ ចីវររំសេតិបិ បាឋោ ។ ២ ឱរោបិយមរម្មបោត្ថកេសុ ន ហោតិ ។

# សិក្ខាបទទី ២

[១០] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង មានភិក្ខុច្រើនរូបបានផ្ញើចីវរទុកនៅដៃភិក្ខុទាំងឡាយ (រួចស្លៀកដណ្តប់) តែស្បង់និងចីពរចេញទៅកាន់ជនបទចារិកទៅ ។ ឯចីវរដែលភិក្ខុផ្ញើទុកនោះយូរពេកក៏ជាមធ្វុកជាំអស់ ។ ភិក្ខុទាំងឡាយ ក៏យកចីវរទាំងអម្បាលនោះទៅហាលសំដិល ។ ព្រះអានន្ទដ៏មានអាយុបាននិមន្តទៅកាន់សេនាសនចារិកក្រឡេកទៅឃើញភិក្ខុទាំងនោះ កំពុងហាលសំដិលចីវរទាំងនោះ ក៏ដើរចូលទៅជិតភិក្ខុទាំងឡាយនោះ លុះចូលទៅជិតហើយ សួរទៅភិក្ខុទាំងនោះថា ម្នាលអាវុសោទាំងឡាយ ចីវរទាំងនេះ ជាមធ្វុកជាំអស់ តើជារបស់លោកណា ។ គ្រានោះឯង ភិក្ខុទាំងអម្បាលនោះ ក៏បានប្រាប់សេចក្តីនុ៎ះដល់ព្រះអា-នន្ទដ៏មានអាយុ ។ ព្រះអានន្ទដ៏មានអាយុក៏លើកទោស តិះដៀល បន្ទោសថា ភិក្ខុទាំងឡាយមិនគួរបើនឹងផ្ញើចីវរទុកដាក់ដៃរបស់ភិក្ខុទាំងឡាយ ហើយ (ស្លៀកដណ្តប់) តែស្បង់និងចីពរចេញដើរទៅកាន់ជនបទចារិកសោះ ។ ទើបព្រះអានន្ទដ៏មានអាយុ ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សួរតប

១១

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស ទុតិយសិក្ខាបទស្ស គិលានភិក្ខុវត្ថុ

សច្ចំ កិរ ភិក្ខវេ ភិក្ខូ ភិក្ខូនំ ហត្ថេ ចីវរំ និក្ខិបិត្វា សន្តរុត្តរេន ជនបទចារិកំ បក្កមន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា ភិក្ខូនំ ហត្ថេ ចីវរំ និក្ខិបិត្វា សន្តរុត្តរេន ជនបទចារិកំ បក្កមិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភា-វាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ និដ្ឋិតចីវរស្មឹ ភិក្ខុនា ឧព្ភតស្មឹ កឋិនេ ឯករត្តម្បិ ចេ ភិក្ខុ តិចីវរេន វិប្បវសេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១១] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ កោសម្ពិយំ គិលានោ ហោតិ ។ ញាតកា តស្ស ភិក្ខុនោ សន្តិកេ ទូតំ បាហេសុំ អាគច្ឆតុ ភទន្តោ មយំ ឧបដ្ឋហិស្សាមាតិ ។ ភិក្ខូបិ ឯវមាហំសុ គច្ឆ អាវុសោ

ទៅពួកភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយបានផ្ញើចីវរទុកនៅដៃភិក្ខុទាំងឡាយ ហើយ (ស្លៀកដណ្តប់) តែស្បង់និងចីពរចេញដើរទៅកាន់ជនបទចារិក មែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ហេតុនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ គួរបើដែរ មោឃបុរសទាំងនោះហ៊ានផ្ញើចីវរទុកនៅដៃភិក្ខុទាំងឡាយ (ហើយស្លៀកដណ្តប់) តែស្បង់និងចីពរចេញដើរទៅកាន់ជនបទចារិក ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកធ្វើនេះ នឹងបាននាំមនុស្សដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើង ឬមនុស្សដែលបានជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង (នោះ) ក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ កឋិនដោះហើយ បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ញត្តដល់ពួកភិក្ខុយ៉ាងនេះហើយ ។

[១១] គ្រានោះឯង ក្នុងក្រុងកោសម្ពី មានភិក្ខុមួយរូបមានជំងឺ ។ ពួកជនជាញាតិក៏បានចាត់ប្រើបម្រើទៅក្នុងសំណាក់ភិក្ខុនោះថា សូមឲ្យលោកម្ចាស់និមន្តមក យើងនឹងផ្គត់ផ្គង់បម្រើ ។ ទាំងភិក្ខុទាំងឡាយ

ញាតកា តំ ឧបដ្ឋហិស្សន្តីតិ ។ សោ ឯវមាហ ភគវតា អាវុសោ ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ន តិចីវរេន វិប្បវសិតព្វន្តិ អហញ្ចម្ហិ គិលានោ ន សក្កោមិ តិចីវរមាទាយ បក្កមិតុំ នាហំ គមិស្សាមីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គិលានស្ស ភិក្ខុនោ តិចីវរេន អវិប្បវាសសម្មុតឹ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ តេន គិលានេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ គិលានោ ន សក្កោមិ តិចីវរមាទាយ បក្កមិតុំ សោហំ ភន្តេ សង្ឃំ តិចីវរេន អវិប្បវាសសម្មុតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ

ក៏ជួយនិយាយថា ម្នាលអាវុសោ លោកចូរនិមន្តទៅចុះ ពួកញាតិគេនឹងបានផ្គត់ផ្គង់បម្រើលោក ។ ភិក្ខុនោះនិយាយតបយ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ ព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយរួចហើយថា ភិក្ខុមិនត្រូវនៅប្រាសចាកត្រៃចីវរទេ ក៏ឥឡូវ ខ្លួនខ្ញុំមានជំងឺមិនអាចនឹងយកត្រៃចីវរចេញដើរទៅបានឡើយ ខ្ញុំនឹងទៅមិនកើតទេ ។ ភិក្ខុទាំងឡាយ ក៏បានទូលសេចក្តីនុ៎ះ ដល់ព្រះដ៏មាន ព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ក៏ធ្វើធម្មីកថាក្នុងវេលានោះ ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យជំនុំសង្ឃឲ្យនូវសម្មតិ ដើម្បីឲ្យនៅប្រាសចាកត្រៃ-ចីវរដល់ភិក្ខុដែលមានជំងឺ ។ ម្នាលភិក្ខុទាំងឡាយ (សង្ឃ) ត្រូវឲ្យសម្មតិយ៉ាងនេះ ។ ភិក្ខុដែលមានជំងឺនោះត្រូវចូលទៅកាន់ជំនុំសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយប្រហោងផ្គងអញ្ជលីឡើង ពោលនឹងសង្ឃយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចម្រើន ឥឡូវ ខ្ញុំមានជំងឺ មិនអាចនឹងយកត្រៃចីវរចេញដើរទៅបានទេ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំនោះសូមសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរនឹងសង្ឃ ។ ភិក្ខុត្រូវសូមគម្រប់ពីរដងផង ត្រូវសូមគម្រប់បីដងផង ។ ភិក្ខុអ្នកឆ្លាសអង់អាចត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន

១៣

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស ទុតិយសិក្ខាបទស្ស អវិប្បវាសសម្មុតិ

សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ គិលានោ ន សក្កោតិ តិចីវរមាទាយ បក្កមិតុំ ។ សោ សង្ឃំ តិចីវរេន អវិប្បវាសសម្មុតឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ តិចីវរេន អវិប្បវាសសម្មុតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ គិលានោ ន សក្កោតិ តិចី-វរមាទាយ បក្កមិតុំ ។ សោ សង្ឃំ តិចីវរេន អវិប្បវាស-សម្មុតឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ តិចីវរេន អវិប្បវាសសម្មុតឹ ទេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ តិចីវរេន អវិប្បវាសសម្មុតិយា ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ តិចីវរេន អវិប្បវាសសម្មុតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ

សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ដ្បិត) ភិក្ខុនេះឈ្មោះនេះមានជំងឺ មិនអាចនឹងយកត្រៃចីវរចេញដើរទៅបានទេ ។ ភិក្ខុនោះមកសូមសម្មតិ ដើម្បីនៅប្រាសចាកត្រៃចីវរនឹងជំនុំសង្ឃ ។ បើកម្មមានកាលល្មមសមគួរដល់សង្ឃហើយ សង្ឃត្រូវឲ្យសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរ ដល់ភិក្ខុឈ្មោះនេះចុះ ។ វាចានេះ (ជាពាក្យផ្តើម) ញ៉ាំងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុនេះឈ្មោះនេះមានជំងឺ មិនអាចនឹងយកត្រៃចីវរចេញដើរទៅបាន ។ ភិក្ខុនោះ សូមសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរនឹងសង្ឃ ។ សង្ឃឲ្យនូវសម្មតិ ដើម្បីនៅប្រាសចាកត្រៃចីវរដល់ភិក្ខុឈ្មោះនេះ ។ ការឲ្យនូវសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា សូមឲ្យលោកដ៏មានអាយុអង្គនោះស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា សូមឲ្យលោកដ៏មានអាយុអង្គនោះ និយាយឡើង ។ ការសម្មតដើម្បីនៅប្រាសចាកត្រៃចីវរសង្ឃបានឲ្យដល់ភិក្ខុឈ្មោះនេះហើយ ។ ការឲ្យសម្មតិគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ។ ខ្ញុំចាំទុកនូវហេតុនេះដោយកិរិយាស្ងៀមយ៉ាងនេះ (ទុកជាការស្រេច) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ

ឧទ្ទិសេយ្យាថ និដ្ឋិតចីវរស្មឹ ភិក្ខុនា ឧព្ភតស្មឹ កឋិនេ ឯករត្តម្បិ ចេ ភិក្ខុ តិចីវរេន វិប្បវសេយ្យ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយន្តិ ។

[១២] និដ្ឋិតចីវរស្មិន្តិ ភិក្ខុនោ ចីវរំ កតំ វា ហោតិ នដ្ឋំ វា វិនដ្ឋំ វា ទឌ្ឍំ វា ចីវរាសា វា ឧបច្ឆិន្នា ។ ឧព្ភតស្មឹ កឋិនេតិ អដ្ឋន្នំ មាតិកានំ អញ្ញតរាយ មាតិកាយ ឧព្ភតំ ហោតិ សង្ឃេន វា អន្តរា ឧព្ភតំ ហោតិ ។ ឯករត្តម្បិ ចេ ភិក្ខុ តិចីវរេន វិប្បវសេយ្យាតិ សង្ឃាដិយា វា ឧត្តរាសង្គេន វា អន្តរវាសកេន វា ឯករត្តម្បិ ចេ វិប្បវុត្ថំ ហោតិ[១] ។ អញ្ញត្រ ភិក្ខុសម្មតិយាតិ ឋបេត្វា ភិក្ខុសម្មតឹ ។ និស្សគ្គិយំ ហោតីតិ សហ អរុណុគ្គមនេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ តេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ។ បេ ។ ឯវមស្ស វចនីយោ

---

១ ឯករត្តម្បិ ចេ វិប្បវុត្ថំ ហោតីត្យាទិ ឱរោបិយមរម្មបោត្ថកេសុ ន ទិស្សតិ ។

កឋិនដោះហើយ បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ ។

[១២] ត្រង់ពាក្យថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ អធិប្បាយថា ចីវរដែលភិក្ខុបានធ្វើរួចជាស្រេចហើយក្តី ចីវរបាត់ក្តី ចីវរដែលខូចក្តី ចីវរភ្លើងឆេះក្តី បំណង៍ក្នុងចីវរដាច់ស្រឡះក្តី ។ ពាក្យថា កឋិនដោះហើយ អធិប្បាយថា កឋិនដោះហើយ បណ្តាមាតិកាទាំង ៨ យ៉ាង ដោយមាតិកាណាមួយ ម្យ៉ាងទៀត កឋិនដែលសង្ឃបានដោះក្នុងចន្លោះ ។ ពាក្យថា បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់ អធិប្បាយថា បើភិក្ខុនៅប្រាសចាកសង្ឃាដិក្តី ឧត្តរាសង្គៈក្តី ស្បង់ក្តីសូម្បីតែមួយយប់ ។ ពាក្យថា វៀរលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ អធិប្បាយថា លើកលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ ។ ពាក្យថា និស្សគ្គិយ អធិប្បាយថា ចីវរជានិស្សគ្គិយដំណាលនឹងពេលដែលអរុណរះឡើង ភិក្ខុនោះឯង ត្រូវលះ (ចីវរនោះ) ដល់សង្ឃ ឬគណៈ ឬ បុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះ ភិក្ខុត្រូវលះបង់យ៉ាងនេះ ។ ភិក្ខុនោះត្រូវចូលទៅកាន់ជំនុំសង្ឃ ។ បេ ។ ហើយពោលនឹងសង្ឃយ៉ាងនេះថា

ឥធំ មេ ភន្តេ ចីវរំ[១] រត្តិវិប្បវុត្ថំ[២] អញ្ញត្រ ភិក្ខុសម្មុតិយា និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[១៣] គាមោ ឯកូបចារោ នានូបចារោ និវេសនំ ឯកូបចារំ នានូបចារំ ឧទោសិតោ ឯកូបចារោ នានូបចារោ អដ្ដោ ឯកូបចារោ នានូបចារោ មាឡោ ឯកូបចារោ នានូបចារោ បាសាទោ ឯកូបចារោ នានូបចារោ ហម្មិយំ ឯកូបចារំ នានូបចារំ នាវា ឯកូបចារា នានូបចារា សត្ថោ ឯកូបចារោ នានូបចារោ ខេត្តំ ឯកូបចារំ នានូបចារំ ធញ្ញករណំ ឯកូបចារំ នានូបចារំ អារាមោ ឯកូបចារោ នានូបចារោ វិហារោ ឯកូបចារោ នានូបចារោ រុក្ខមូលំ ឯកូបចារំ នានូបចារំ អជ្ឈោកាសោ ឯកូបចារោ នានូបចារោ ។

---

១ ឱ. ឝ. តិចីវរំ ។ ២ ឱ. រត្តឹ វិប្បវុត្ថំ ។ ឝ. ឯករត្តំ វិប្បវុត្ថំ ។

បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះ ខ្ញុំនៅប្រាសយាតមួយរាត្រីហើយ ជានិស្សគ្គិយ ព្រោះឥតមានភិក្ខុសម្មតិទេ ខ្ញុំសូមលះចីវរនេះ ដល់សង្ឃ ។ បេ ។ (ត្រង់បេយ្យាលទាំងបី មានអធិប្បាយត្រង់សិក្ខាបទទី ១ ក្នុងវគ្គជាមួយគ្នានេះរួចហើយ) ។

[១៣] ស្រុកមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ផ្ទះមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ឃ្លាំងមានឧបចារតែមួយ មានឧបចារផ្សេងគ្នា បញ្ចាមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ពាងមានជ្រុងបួនមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ប្រាសាទមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ប្រាសាទមានដំបូលត្រងិល មានឧបចារតែមួយ មានឧបចារផ្សេងគ្នា នាវាមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ពួកឈ្មួញរទេះមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ស្រែមានឧបចារតែមួយ មានឧបចារផ្សេងគ្នា លានស្រូវមានឧបចារតែមួយ មានឧបចារផ្សេងគ្នា សួនច្បារមានឧបចារតែមួយ មានឧបចារផ្សេងគ្នា វិហារមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ទីជិតដើមឈើមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ទីវាលមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ។

[១៤] តាមោ ឯកុបចារោ ឯាម ឯកកុលស្ស តាមោ ហោតិ បរិក្ខិត្តោ ច អន្តោតាមេ ចីវរំ និក្ខិបិត្វា អន្តោតាមេ វត្ថព្វំ ។ អបរិក្ខិត្តោ ហោតិ យស្មឹ ឃរេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ ឃរេ វត្ថព្វំ ហត្ថបាសា វា ន វិជហិតព្វំ ។ ឯានូបចារោ ឯាម[១] ឯាឯាកុល-ស្ស តាមោ ហោតិ បរិក្ខិត្តោ ច យស្មឹ ឃរេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ ឃរេ វត្ថព្វំ សភាយេ វា ទ្វារមូ-លេ វា ហត្ថបាសា វា ន វិជហិតព្វំ ។ សភាយំ គច្ឆន្តេ ហត្ថបាសេ ចីវរំ និក្ខិបិត្វា សភាយេ វត្ថព្វំ ទ្វារមូលេ វា ហត្ថបាសា វា ន វិជហិតព្វំ ។ សភាយេ ចីវរំ និក្ខិបិត្វា សភាយេ វត្ថព្វំ ទ្វារមូលេ វា ហត្ថបាសា វា ន វិជហិតព្វំ ។ អបរិក្ខិត្តោ ហោតិ យស្មឹ ឃរេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ ឃរេ វត្ថព្វំ ហត្ថបាសា វា ន វិជហិតព្វំ ។

[១៥] ឯកកុលស្ស និវេសនំ ហោតិ បរិក្ខិត្តញ្ច ឯាឯាគព្ភា ឯាឯាឱវរកា អន្តោនិវេសនេ ចីវរំ និក្ខិបិត្វា

---

១ ឱរោបិយមរម្មបោត្ថកេសុ ឥទំ បាឋទ្វយំ ន ហោតិ ។

[១៨] ស្រុកដែលឈ្មោះថា មានឧបចារតែមួយ (នោះសំដៅយក) ស្រុករបស់ត្រកូលតែមួយ ដែលគេរាំងព័ទ្ធ (របង) ជុំវិញ ភិក្ខុត្រូវទុកចីវរក្នុងខាងក្នុងស្រុក ហើយនៅក្នុងខាងក្នុងស្រុក ។ ស្រុកដែលគេមិនបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងផ្ទះណា ត្រូវនៅក្នុងផ្ទះនោះ ម្យ៉ាងទៀតមិនត្រូវលះហត្ថបាសឡើយ ។ ស្រុកដែលឈ្មោះថា មានឧបចារផ្សេងគ្នា គឺស្រុករបស់ត្រកូលផ្សេងគ្នា គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងផ្ទះណា ត្រូវនៅក្នុងផ្ទះនោះ ឬនៅក្នុងរោងជាទីប្រជុំ ឬទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ កាលបើភិក្ខុទៅក្នុងរោងជាទីប្រជុំ ត្រូវទុកចីវរក្នុងហត្ថបាស ហើយនៅក្នុងរោងជាទីប្រជុំ ឬទៀបទ្វារ មិនត្រូវលះហត្ថបាសឡើយ ។ បើភិក្ខុទុកចីវរក្នុងរោងជាទីប្រជុំ ត្រូវឲ្យនៅក្នុងរោងជាទីប្រជុំ ឬទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ បើស្រុកដែលគេមិនបានរាំងព័ទ្ធទេ ភិក្ខុទុកចីវរក្នុងផ្ទះណា ត្រូវនៅក្នុងផ្ទះនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[១៩] បើផ្ទះរបស់ត្រកូលតែមួយ ដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេង ៗ គ្នា មានបន្ទប់ផ្សេង ៗ គ្នា ភិក្ខុត្រូវទុកចីវរខាងក្នុងផ្ទះ

អន្តោ និវេសនេ វត្ថព្វំ ។ អបរិក្ខិត្តំ ហោតិ យស្មឹ ឃរេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ ឃរេ វត្ថព្វំ ហត្ថបាសា វា ន វិជហិតព្វំ ។ នានាកុលស្ស និវេសនំ ហោតិ បរិក្ខិត្តញ្ច នានាគព្ភា នានាឱវរកា យស្មឹ ឃរេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ ឃរេ វត្ថព្វំ ទ្វារមូលេ វា ហត្ថបាសា វា ន វិជ-ហិតព្វំ ។ អបរិក្ខិត្តំ ហោតិ យស្មឹ ឃរេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ ឃរេ វត្ថព្វំ ហត្ថបាសា វា ន វិជហិតព្វំ ។

[០៦] ឯកកុលស្ស ឧទ្ទោសិតោ ហោតិ បរិក្ខិត្តោ ច នានាគព្ភា នានាឱវរកា អន្តោឧទ្ទោសិតេ ចីវរំ និ-ក្ខិបិត្វា អន្តោឧទ្ទោសិតេ វត្ថព្វំ ។ អបរិក្ខិត្តោ ហោតិ យស្មឹ ឃរេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ ឃរេ វត្ថព្វំ ហត្ថបាសា វា ន វិជហិតព្វំ ។ នានាកុលស្ស ឧទ្ទោ-សិតោ ហោតិ បរិក្ខិត្តោ ច នានាគព្ភា នានាឱវរកា យស្មឹ ឃរេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ ឃរេ វត្ថព្វំ ទ្វារមូលេ វា ហត្ថបាសា វា ន វិជហិតព្វំ ។ អបរិក្ខិត្តោ ហោតិ យស្មឹ ឃរេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ ឃរេ វត្ថព្វំ ហត្ថបាសា វា ន វិជហិតព្វំ ។

ហើយត្រូវនៅខាងក្នុងផ្ទះ ។ ផ្ទះដែលគេមិនបានរាំងព័ទ្ធជុំវិញទេ (ភិក្ខុ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។ម្យ៉ាងទៀត ផ្ទះរបស់ត្រកូលផ្សេង ៗ គ្នា ដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេង ៗ គ្នា មានបន្ទប់ផ្សេង ៗ គ្នា (ភិក្ខុ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ ផ្ទះដែលគេមិនបានរាំងព័ទ្ធជុំវិញទេ (ភិក្ខុ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[១៦] ឃ្លាំងរបស់ត្រកូលតែមួយ ដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេង ៗ គ្នា មានបន្ទប់ផ្សេង ៗ គ្នា (ភិក្ខុ) ត្រូវទុកចីវរខាងក្នុងឃ្លាំង ហើយត្រូវនៅខាងក្នុងឃ្លាំង ។ ឃ្លាំងដែលគេមិនបានរាំងព័ទ្ធជុំវិញទេ (ភិក្ខុ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។ ម្យ៉ាងទៀតឃ្លាំងរបស់ត្រកូលផ្សេង ៗ គ្នា ដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេង ៗ គ្នា មានបន្ទប់ផ្សេង ៗ គ្នា (ភិក្ខុ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ ឃ្លាំងដែលគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[១៧] ឯកកុលស្ស អង្គោ ហោតិ អង្គោអង្គេ ចីវរំ និក្ខិបិត្វា អង្គោ អង្គេ វត្ថព្វំ ។ នានាកុលស្ស អង្គោ ហោតិ នានាគព្ភា នានាឱវរកា យស្មឹ គព្ភេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ គព្ភេ វត្ថព្វំ ទ្វារមូលេ វា ហត្ថបាសា វា ន វិជហិតព្វំ ។

[១៨] ឯកកុលស្ស មាលោ ហោតិ អង្គោមាលេ ចីវរំ និក្ខិបិត្វា អង្គោមាលេ វត្ថព្វំ ។ នានាកុលស្ស មាលោ ហោតិ នានាគព្ភា នានាឱវរកា យស្មឹ គព្ភេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ គព្ភេ វត្ថព្វំ ទ្វារមូលេ វា ហត្ថបាសា វា ន វិជហិតព្វំ ។

[១៩] ឯកកុលស្ស បាសាទោ ហោតិ អង្គោបាសាទេ ចីវរំ និក្ខិបិត្វា អង្គោបាសាទេ វត្ថព្វំ ។ នានាកុលស្ស បាសាទោ ហោតិ នានាគព្ភា នានាឱវរកា យស្មឹ គព្ភេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ គព្ភេ វត្ថព្វំ ទ្វារមូលេ វា ហត្ថបាសា វា ន វិជហិតព្វំ ។

[២០] ឯកកុលស្ស ហម្មិយំ ហោតិ អង្គោហម្មិយេ ចីវរំ និក្ខិបិត្វា អង្គោហម្មិយេ វត្ថព្វំ ។ នានាកុលស្ស

[១៧] បញ្ជររបស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងបញ្ជរហើយ ត្រូវនៅខាងក្នុងបញ្ជរ ។ បញ្ជររបស់ត្រកូលផ្សេង ៗ គ្នា មានល្វែងក៏ផ្សេង ៗ គ្នា មានបន្ទប់ក៏ផ្សេង ៗ គ្នា ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[១៨] ប្រាសាទមានជ្រុង ៤ របស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងប្រាសាទមានជ្រុង ៤ ហើយត្រូវនៅក្នុងខាងក្នុងនៃប្រាសាទ មានជ្រុង ៤ ។ ប្រាសាទមានជ្រុង ៤ របស់ត្រកូលផ្សេង ៗ គ្នា មានល្វែងផ្សេង ៗ គ្នាមានបន្ទប់ផ្សេង ៗ គ្នា ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ មួយទៀតមិនត្រូវលះហត្ថបាសឡើយ ។

[១៩] ប្រាសាទវែងរបស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងប្រាសាទវែង ហើយត្រូវនៅខាងក្នុងប្រាសាទវែង ។ ប្រាសាទវែងរបស់ត្រកូលផ្សេង ៗ គ្នា មានល្វែងផ្សេង ៗ គ្នា មានបន្ទប់ផ្សេង ៗ គ្នា ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[២០] ប្រាសាទមានដំបូលត្រងិល របស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងប្រាសាទត្រងិល ហើយត្រូវនៅខាងក្នុងប្រាសាទត្រងិល ។ ប្រាសាទមានដំបូលត្រងិលរបស់ត្រកូលផ្សេង ៗ គ្នា មានល្វែងផ្សេង ៗ គ្នា

ហាម្មិយំ ហោតិ នានាគព្ភា នានាឱវរកា យស្មឹ គព្ភេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ គព្ភេ វត្ថព្វំ ហត្ថបាសា វា ន វិជហិតព្វំ ។

[២១] ឯកកុលស្ស នាវា ហោតិ អន្តោនាវាយ ចីវរំ និក្ខិបិត្វា អន្តោនាវាយ វត្ថព្វំ ។ នានាកុលស្ស នាវា ហោតិ នានាគព្ភា នានាឱវរកា យស្មឹ ឱវរកេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ ឱវរកេ វត្ថព្វំ ហត្ថបាសា វា(១) ហត្ថបាសា វា ន វិជហិតព្វំ ។

[២២] ឯកកុលស្ស សត្ថោ ហោតិ សត្ថេ ចីវរំ និក្ខិបិត្វា បុរតោ វា បច្ឆតោ វា សត្តព្ភន្តរា ន វិជហិតព្វា បស្សតោ អព្ភន្តរំ ន វិជហិតព្វំ ។ នានាកុលស្ស សត្ថោ ហោតិ សត្ថេ ចីវរំ និក្ខិបិត្វា ហត្ថបាសា ន វិជហិតព្វំ ។

[២៣] ឯកកុលស្ស ខេត្តំ ហោតិ បរិក្ខិត្តញ្ច អន្តោខេត្តេ ចីវរំ និក្ខិបិត្វា អន្តោខេត្តេ វត្ថព្វំ ។ អបរិក្ខិត្តំ ហោតិ ហត្ថបាសា ន វិជហិតព្វំ ។

---

១ ឱ. ម. បោត្ថកេសុ ឥទំ បាឋទ្វយំ ន ហោតិ ។

មានបន្ទប់ផ្សេង ៗ គ្នា ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[២១] នាវារបស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងនាវា ហើយត្រូវនៅខាងក្នុងនាវា ។ នាវារបស់ត្រកូលផ្សេង ៗ គ្នា មានល្វែងផ្សេង ៗ គ្នា មានបន្ទប់ផ្សេង ៗ គ្នា ភិក្ខុទុកចីវរក្នុងបន្ទប់ណា ត្រូវនៅក្នុងបន្ទប់នោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[២២] ពួកឈ្មួញរទេះរបស់ត្រកូលតែមួយ ភិក្ខុផ្ញើចីវរទុកនឹងពួកឈ្មួញរទេះ (នោះ) ទោះបីដើរ ខាងមុខរទេះក្តី ខាងក្រោយរទេះក្តី មិនត្រូវលះបង់ចម្ងាយ ៧ អព្ភន្តរ[១]ឡើយ (ដើរឲ្យល្មមតែ) ក្រឡេកមើលទៅឃើញ (រទេះ) ទើបមិនត្រូវលះបង់អព្ភន្តរ ។ ពួកឈ្មួញរទេះរបស់ត្រកូលផ្សេង ៗ គ្នា ភិក្ខុផ្ញើចីវរទុកនឹងពួកឈ្មួញរទេះហើយ មិនត្រូវលះហត្ថបាសឡើយ ។

[២៣] ស្រែរបស់ត្រកូលតែមួយ គេបានបិទរាំងជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃស្រែ (នោះ) ត្រូវនៅក្នុងខាងក្នុងនៃស្រែ (នោះ) ។ (បើស្រែ) គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។

១ អដ្ឋកថា ពន្យល់សេចក្តីថា ២៨ ហត្ថ ហៅថា មួយអព្ភន្តរ (ចម្ងាយ ៧ អព្ភន្តរត្រូវជា ១៩៦ ហត្ថ) ។

ញាតកស្ស ខេត្តំ ហោតិ បរិក្ខិត្តញ្ច អន្តោខេត្តេ ចីវរំ និក្ខិបិត្វា អន្តោខេត្តេ វត្ថព្វំ ទ្វារមូលេ វា ហត្ថ-បាសា វា ន វិជហិតព្វំ ។ អបរិក្ខិត្តំ ហោតិ ហត្ថបាសា ន វិជហិតព្វំ ។

[២៤] ឯកកុលស្ស ធញ្ញករណំ ហោតិ បរិក្ខិ-ត្តញ្ច អន្តោធញ្ញករណេ ចីវរំ និក្ខិបិត្វា អន្តោធញ្ញករណេ វត្ថព្វំ ។ អបរិក្ខិត្តំ ហោតិ ហត្ថបាសា ន វិជហិតព្វំ ។ ញាតកស្ស ធញ្ញករណំ ហោតិ បរិក្ខិត្តញ្ច អន្តោ-ធញ្ញករណេ ចីវរំ និក្ខិបិត្វា ទ្វារមូលេ វា វត្ថព្វំ ហត្ថបាសា វា ន វិជហិតព្វំ ។ អបរិក្ខិត្តំ ហោតិ ហត្ថបាសា ន វិជហិតព្វំ ។

[២៥] ឯកកុលស្ស អារាមោ ហោតិ បរិក្ខិត្តោ ច អន្តោអារាមេ ចីវរំ និក្ខិបិត្វា អន្តោអារាមេ វត្ថព្វំ ។ អប-រិក្ខិត្តោ ហោតិ ហត្ថបាសា ន វិជហិតព្វំ ។ ញាតកស្ស អារាមោ ហោតិ បរិក្ខិត្តោ ច អន្តោអារាមេ ចីវរំ និក្ខិបិត្វា ទ្វារមូលេ វា វត្ថព្វំ ហត្ថបាសា វា ន វិជហិតព្វំ ។ អបរិក្ខិត្តោ ហោតិ ហត្ថបាសា ន វិជហិតព្វំ ។

បើស្រែរបស់ត្រកូលផ្សេង ៗ គ្នា គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃស្រែ (នោះ) ហើយត្រូវនៅក្នុងខាងក្នុងនៃស្រែ (នោះ) ឬ (ត្រូវនៅ) ទៀបទ្វារ មិនត្រូវលះហត្ថបាសឡើយ ។ (បើស្រែ) គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។

[២៤] លានស្រូវរបស់ត្រកូលតែមួយ គេរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃលានហើយ ត្រូវនៅក្នុងខាងក្នុងនៃលាន (នោះ) ។ (បើលានស្រូវ) គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។ លានស្រូវរបស់ត្រកូលផ្សេង ៗ គ្នា គេបិទរាំងជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃលានហើយ ត្រូវនៅទៀបទ្វារ មិនត្រូវលះហត្ថបាសឡើយ ។ (បើលានស្រូវ) គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។

[២៥] សួនច្បាររបស់ត្រកូលតែមួយ គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរខាងក្នុងសួនច្បារហើយ ត្រូវនៅខាងក្នុងនៃសួនច្បារ ។ សួនច្បារគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។ សួនច្បាររបស់ត្រកូលផ្សេង ៗ គ្នា គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃសួនច្បារហើយ ត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ សួនច្បារគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។

## ២១

### និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស ទុតិយសិក្ខាបទស្ស បទភាជនីយំ

[២៦] ឯកកុលស្ស វិហារោ ហោតិ បរិក្ខិត្តោ ច អន្តោវិហារេ ចីវរំ និក្ខិបិត្វា អន្តោវិហារេ វត្ថព្វំ ។ អបរិក្ខិត្តោ ហោតិ យស្មឹ វិហារេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ វិហារេ វត្ថព្វំ ហត្ថចាសា វា ន វិជហិតព្វំ ។ នានាកុលស្ស វិហារោ ហោតិ បរិក្ខិត្តោ ច យស្មឹ វិហារេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ វិហារេ វត្ថព្វំ ទ្វារមូលេ វា ហត្ថចាសា វា ន វិជហិតព្វំ ។ អបរិក្ខិត្តោ ហោតិ យស្មឹ វិហារេ ចីវរំ និក្ខិត្តំ ហោតិ តស្មឹ វិហារេ វត្ថព្វំ ហត្ថចាសា វា ន វិជហិតព្វំ ។

[២៧] ឯកកុលស្ស រុក្ខមូលំ ហោតិ យំ មជ្ឈន្តិកេ កាលេ សមន្តា ឆាយា ផរតិ អន្តោឆាយាយ ចីវរំ និក្ខិបិត្វា អន្តោឆាយាយ វត្ថព្វំ ។ នានាកុលស្ស រុក្ខមូលំ ហោតិ ហត្ថចាសា ន វិជហិតព្វំ ។

[២៨] អជ្ឈោកាសោ ឯកុបចារោ នានូបចារោ នាម[១] អគាមកេ អរញ្ញេ សមន្តា សត្តព្ភន្តរា ឯកុបចារោ តតោ បរំ នានូបចារោ ។

---

១ ឱ. ម. បោត្ថកេសុ ឥទំ បាឋទ្វយំ ន ហោតិ ។

និស្សគ្គិយកណ្ឌ ចីវរវគ្គ សិក្ខាបទទី ២ បទភាជនីយ

[២៦] លំនៅរបស់ត្រកូលតែមួយ គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងលំនៅហើយ ត្រូវនៅខាងក្នុងលំនៅ ។ លំនៅដែលគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុទុកចីវរក្នុងលំនៅណា ត្រូវនៅក្នុងលំនៅនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។ លំនៅរបស់ត្រកូលផ្សេង ៗ គ្នា គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងលំនៅណា ត្រូវនៅក្នុងលំនៅនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ ។ លំនៅ ដែលគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុទុកចីវរក្នុងលំនៅណា ត្រូវនៅក្នុងលំនៅនោះ ហើយមិនត្រូវលះហត្ថបាសឡើយ ។

[២៧] ម្លប់ឈើរបស់ត្រកូលតែមួយ ក្នុងពេលថ្ងៃត្រង់ ម្លប់ឈើនោះផ្សាយទៅជុំវិញត្រឹមណា ភិក្ខុទុកចីវរក្នុងខាងក្នុងម្លប់ ហើយត្រូវនៅត្រឹមតែខាងក្នុងម្លប់ (នោះ) ។ ម្លប់ឈើរបស់ត្រកូលផ្សេង ៗ គ្នា ភិក្ខុមិនត្រូវលះហត្ថបាសឡើយ ។

[២៨] ដែលហៅថា ទីវាល មានឧបចារតែមួយ មានឧបចារផ្សេង ៗ គ្នា គឺទីក្នុងព្រៃដែលឥតមានស្រុក ចំនួន ៧ អព្ភន្តរ ដោយជុំវិញ (ទីវាលនោះ) ហៅថា មានឧបចារតែមួយ លំដាប់តអំពីអព្ភន្តរនោះទៅ ហៅថា មានឧបចារផ្សេង ៗ គ្នា ។

[២៩] វិប្បវុត្ថេ វិប្បវុត្ថសញ្ញី អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ វិប្បវុត្ថេ វេមតិកោ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ វិប្បវុត្ថេ អវិប្បវុត្ថសញ្ញី អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ អប្បច្ចុទ្ធដេ បច្ចុទ្ធដសញ្ញី អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ អវិស្សជ្ជិតេ វិស្សជ្ជិតសញ្ញី អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ អនដ្ឋេ នដ្ឋសញ្ញី អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ អវិនដ្ឋេ វិនដ្ឋសញ្ញី អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ អទឌ្ឍេ ទឌ្ឍសញ្ញី អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ អវិលុត្តេ វិលុត្តសញ្ញី អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។

[២៩] ភិក្ខុមានសេចក្តីដឹងច្បាស់ថា ចីវរដែលខ្លួននៅប្រាស ត្រង់ចីវរដែលខ្លួននៅប្រាសហើយ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុមានសេចក្តីសង្ស័យ ត្រង់ចីវរដែលខ្លួននៅប្រាស ត្រូវនិស្សគ្គិយ-បាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសំគាល់ថា ចីវរគឺខ្លួនមិនបាននៅប្រាសទេ ត្រង់ចីវរដែលខ្លួននៅប្រាសហើយ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសំគាល់ថា ចីវរគឺខ្លួនបានដកអធិដ្ឋានហើយ ត្រង់ចីវរដែលខ្លួនមិនបានដកអធិដ្ឋានទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសំគាល់ថា ចីវរគឺខ្លួនបានលះបង់ហើយ ត្រង់ចីវរដែលខ្លួនមិនទាន់បានលះបង់ទេ ត្រូវនិស្សគ្គិយ-បាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសំគាល់ថា ចីវរបាត់ ត្រង់ចីវរដែលមិនមែនបាត់ទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសំគាល់ថា ចីវរវិនាស ត្រង់ចីវរដែលមិនមែនវិនាសទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសំគាល់ថា ចីវរភ្លើងឆេះ ត្រង់ចីវរដែលភ្លើងមិនមែនឆេះទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ ។ ភិក្ខុសំគាល់ថា ចីវរចោរប្លន់យក ត្រង់ចីវរដែលចោរមិនមែនប្លន់យកទេ ត្រូវនិស្សគ្គិយ-បាចិត្តយ វៀរលែងតែបានភិក្ខុសម្មតិ ។

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស ទុតិសិក្ខាបទស្ស អនាបត្តិវារោ

[៣០] និស្សគ្គិយំ ចីវរំ អនិស្សជ្ជិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។ អវិប្បវុត្ថេ វិប្បវុត្ថសញ្ញី អាបត្តិ ទុក្កដស្ស ។ អវិប្បវុត្ថេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អវិប្បវុត្ថេ អវិប្បវុត្ថសញ្ញី អនាបត្តិ ។

[៣១] អនាបត្តិ អន្តោអរុណេ បច្ចុទ្ធរតិ វិស្សជ្ជេតិ នស្សតិ វិនស្សតិ ឌយ្ហតិ អច្ឆិន្ទិត្វា គណ្ហាតិ[១] វិស្សាសំ គណ្ហាតិ[២] ភិក្ខុសម្មតិយា ឧម្មត្តកស្ស អាទិកម្មិ-កស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។

១-២ ឱ. ម. គណ្ហន្តិ ។

[៣០] ភិក្ខុមិនបានលះចីវរដែលជានិស្សគ្គិយ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ថា ចីវរគឺខ្លួននៅប្រាសហើយ ត្រង់ចីវរដែលខ្លួនមិនមែននៅប្រាសទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងចីវរដែលមិនបាននៅប្រាស ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ថា ចីវរគឺខ្លួនមិនមែននៅប្រាសទេ ត្រង់ចីវរដែលខ្លួនមិនមែននៅប្រាសពិត មិនត្រូវអាបត្តិឡើយ ។

[៣១] ហេតុដែលមិនត្រូវអាបត្តិនោះគឺ ភិក្ខុបានដកអធិដ្ឋាន ក្នុងខាងក្នុងនៃអរុណ ១ ភិក្ខុបានលះចីវរ ១ ចីវរបាត់ ១ ចីវរវិនាស ១ ចីវរភ្លើងឆេះ ១ ចីវរចោរដណ្តើមយក ១ អ្នកដទៃយកដោយស្និទ្ធស្នាល ១ ភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ២ ចប់ ។

# តតិយសិក្ខាបទំ

[៣២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ អកាលចីវរំ ឧប្បន្នំ ហោតិ តស្ស តំ ចីវរំ កយិរមានំ នប្បហោតិ ។ អថខោ សោ ភិក្ខុ តំ ចីវរំ ឧស្សាបេត្វា បុនប្បុនំ វិមជ្ជ-តិ ។ អទ្ទសា ខោ ភគវា សេនាសនចារិកំ អាហិណ្ឌន្តោ តំ ភិក្ខុំ តំ ចីវរំ ឧស្សាបេត្វា បុនប្បុនំ វិមជ្ជន្តំ ទិស្វាន យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច កិស្ស ត្វំ ភិក្ខុ ឥមំ ចីវរំ ឧស្សាបេត្វា បុនប្បុ-នំ វិមជ្ជសីតិ ។ ឥទំ មេ ភន្តេ អកាលចីវរំ ឧប្បន្នំ

# សិក្ខាបទទី ៣

[៣២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅនាវត្តព្រះជេតពន ជាអារាមរបស់អនាថបិណ្ឌិកមហាសេដ្ឋី ជិតក្រុងសាវត្ថី ។ កាលនោះឯង អកាលចីវរ[១] កើតឡើងដល់ភិក្ខុ ១ រូបមានឈ្មោះមិនប្រាកដ លុះភិក្ខុនោះ ធ្វើចីវរនោះទៅមិនល្មមគ្រាន់ ។ គ្រានោះ ភិក្ខុនោះក៏លើកចីវរនោះឡើង ហើយទាញឲ្យតឹងធ្វើឲ្យយឺតសាច់សំពត់នោះរឿយ ៗ ។ ព្រះដ៏មានព្រះភាគ បានយាងទៅកាន់សេនាសនចារិក ទ្រង់ទតទៅឃើញភិក្ខុនោះ កំពុងតែលើកចីវរឡើងទាញរឿយ ៗ លុះទ្រង់ទតឃើញហើយ ទ្រង់យាងចូលទៅជិត ហើយត្រាស់សួរទៅភិក្ខុនោះថា ម្នាលភិក្ខុ បានជាអ្នកលើកចីវរឡើងហើយទាញរឿយ ៗ នេះតើព្រោះហេតុអ្វី ។ ភិក្ខុនោះ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន នេះជាអកាលចីវរដែលកើតឡើងដល់ខ្ញុំព្រះអង្គ ៗ ធ្វើទៅមិនគ្រាន់

---

១ គឺចីវរដែលកើតឡើងក្នុងឱកាស ១១ ខែ គឺតាំងពីត្រឹមថ្ងៃ ១ រោចខែកត្តិក ទៅដល់ថ្ងៃ ១៥ កើតខែអស្សុជ នេះជាអកាលចីវររបស់ភិក្ខុដែលឥតបានក្រាលកឋិន ។ ឯភិក្ខុដែលបានក្រាលកឋិន អកាលចីវរមានកំណត់ ៧ ខែ គឺតាំងពីត្រឹមថ្ងៃ ១ រោចខែផល្គុណទៅដល់ថ្ងៃ ១៥ កើតខែអស្សុជ ។

កយិរមានំ នប្បហោតិ តេនាហំ ឥមំ ចីវរំ ឧស្សាបេត្វា បុនប្បុនំ វិមជ្ជាមីតិ ។ អត្ថិ បន តេ ភិក្ខុ ចីវរប្បច្ចាសាតិ ។ អត្ថិ ភគវាតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អកាលចីវរំ បដិគ្គហេត្វា ចីវរប្បច្ចាសាយ[១] និក្ខិបិតុន្តិ ។

[៣៣] តេន ខោ បន សមយេន ភិក្ខូ ភគវតា អនុញ្ញាតំ អកាលចីវរំ បដិគ្គហេត្វា ចីវរប្បច្ចាសាយ[២] និក្ខិបិតុន្តិ[៣] អកាលចីវរំ[៤] បដិគ្គហេត្វា អតិរេកមាសំ និក្ខិបន្តិ ។ តានិ ចីវរានិ ចិវរវំសេ ភណ្ឌិកាពទ្ធានិ តិដ្ឋន្តិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ សេនាសនចារិកំ អាហិណ្ឌន្តោ តានិ ចីវរានិ ចីវរវំសេ ភណ្ឌិកាពទ្ធានិ ឋិតានិ[៥] ទិស្វាន ភិក្ខូ អាមន្តេសិ កស្សិមានិ អាវុសោ ចីវរានិ ចីវរវំសេ ភណ្ឌិកាពទ្ធានិ តិដ្ឋន្តីតិ ។ អម្ហាកំ អាវុសោ ឥមានិ

១ ឱ. ម. ចីវរប្បច្ចាសា ។ ២ ឱ. ម. ចីវរប្បច្ចាសា ។ ៣ ឥតោ បរំ ឱ. ម. បោត្ថកេសុ តេសទ្ទោ ទិស្សតិ ។ ៤ ឱ. ម. អកាលចីវរានិ ។ ៥ ឱ. ម. តិដ្ឋន្តេ ។

ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គលើកចីវរនេះឡើងហើយទាញរឿយ ៗ ដើម្បីឲ្យយឺតសាច់ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមានបំណង នឹងរកចីវរថែមទៀតដែរឬទេ ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មានបំណងដែរ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមក ក្នុងកាលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យអ្នកទាំងឡាយទទួលនូវអកាលចីវរហើយទុកដាក់បាន ព្រោះមានសង្ឃឹមថា នឹងបានចីវរថែមទៀត ។

[៣៣] សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគបានអនុញ្ញាតឲ្យទទួលអកាលចីវរទុកដាក់បាន ព្រោះមានសង្ឃឹមថា នឹងបានចីវរថែមទៀត ហើយក៏ទទួលអកាលចីវរទុកដាក់ឲ្យលើសជាង ១ ខែឡើងទៅ ។ ចីវរទាំងនោះ ក៏ជាប់គ្នាដូចជាបង្វេចនៅលើឈើស្នៀង ។ ព្រះអានន្ទដ៏មានអាយុនិមន្តទៅកាន់សេនាសនចារិក ជួនជាក្រឡេកមើលទៅឃើញចីវរទាំងឡាយនោះជាប់គ្នាដូចជាបង្វេចនៅលើឈើស្នៀង លុះឃើញហើយក៏ហៅភិក្ខុតាំងឡាយ (នោះ) មកសួរថា ម្នាលអាវុសោទាំងឡាយ នេះចីវររបស់លោកណា ក៏ជាប់គ្នាដូចជាបង្វេចនៅលើឈើស្នៀង (ដូច្នេះ) ។ ភិក្ខុទាំងឡាយប្រាប់ថា ម្នាលអាវុសោ នេះអកាលចីវររបស់យើង យើងទុក

អកាលចីវរានិ ចីវរប្បច្ចាសាយ[១] និក្ខិត្តានីតិ ។ កីវចិរំ បនាវុសោ ឥមានិ ចីវរានិ និក្ខិត្តានីតិ ។ អតិរេកមាសំ អាវុសោតិ ។ អាយស្មា អានន្ទោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខូ អកាលចីវរំ បដិគ្គហេត្វា អតិរេកមាសំ និក្ខិបិស្សន្តីតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ភិក្ខូ អកាលចីវរំ បដិគ្គហេត្វា អតិរេកមាសំ និក្ខិបន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា អកាលចីវរំ បដិគ្គហេត្វា អតិរេកមាសំ និក្ខិបិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ និដ្ឋិតចីវរស្មឹ ភិក្ខុនា ឧព្ភតស្មឹ កឋិនេ ភិក្ខុនោ

---

១ ឱ. ម. ចីវរប្បច្ចាសា ។

ដោយមានបំណងនឹងរកចីវរថែមទៀត ។ ព្រះអានន្ទសួរថា ម្នាលអាវុសោទាំងឡាយ ចុះចីវរទាំងនេះ លោកទុកយូរប៉ុន្មានថ្ងៃហើយ ។ ភិក្ខុទាំងឡាយប្រាប់ថា ចីវរទាំងនេះ យើងទុកជាង ១ ខែហើយ ។ ព្រះអានន្ទដ៏មានអាយុក៏បន្ទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ ពួកភិក្ខុ ហ៊ានទទួលអកាលចីវរយកមកទុកឲ្យលើសជាង ១ ខែឡើងទៅសោះ ។ គ្រានោះព្រះអានន្ទដ៏មានអាយុ បានក្រាបទូលសេចក្ដីនុ៎ះ ដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃក្នុងកាលនោះ ហើយត្រាស់សួរទៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកភិក្ខុបានទទួលអកាលចីវរទុកឲ្យលើសជាង ១ ខែមែន ។ ភិក្ខុទាំងនោះ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោសមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ គួរបើដែរ ពួកមោឃបុរសទាំងនោះ ហ៊ានទទួលអកាលចីវរហើយទុកឲ្យលើសជាង ១ ខែ (ដូច្នេះ) ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ នឹងបានដឹកនាំមនុស្សដែលមិនទាន់បានជ្រះថ្លា ឲ្យជ្រះថ្លាឡើង ឬនាំមនុស្សដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ កឋិនដោះហើយ

๒๗



បនេវ អកាលចីវរំ ឧប្បជ្ជេយ្យ អាកង្ខមានេន ភិក្ខុនា បដិគ្គហេតព្វំ បដិគ្គហេត្វា ខិប្បមេវ ការេតព្វំ នោ ចស្ស បារិបូរិ មាសបរមន្តេន ភិក្ខុនា តំ ចីវរំ និក្ខិបិតព្វំ ឩនស្ស បារិបូរិយា សតិយា បច្ចាសាយ តតោ ចេ ឧត្តរឹ និក្ខិបេយ្យ សតិយាបិ បច្ចាសាយ និស្សគ្គិយំ បាចិត្តិយន្តិ ។

[៣៤] និដ្ឋិតចីវរស្មឹ ភិក្ខុនាតិ ភិក្ខុនោ ចីវរំ កតំ វា ហោតិ នដ្ឋំ វា វិនដ្ឋំ វា ទឌ្ឍំ វា ចីវរាសា វា ឧបច្ឆិន្នា ។ ឧព្ភតស្មឹ កឋិនេតិ អដ្ឋន្នំ មាតិកានំ អញ្ញតរាយ មាតិកាយ ឧព្ភតំ ហោតិ សង្ឃេន វា អន្តរា ឧព្ភតំ ហោតិ ។ អកាលចីវរំ នាម អនត្ថតេ កឋិនេ ឯកាទសមាសេ ឧប្បន្នំ អត្ថតេ កឋិនេ សត្តមាសេ ឧប្បន្នំ កាលេបិ អាទិស្ស ទិន្នំ ឯតំ អកាលចីវរំ នាម ។

បើអកាលចីវរកើតឡើងចំពោះភិក្ខុ ទាំងភិក្ខុសោតក៏ត្រូវការ (អកាលចីវរនោះ) ត្រូវទទួលចុះ លុះទទួលរួចហើយ ត្រូវរៀសរវៃធ្វើឲ្យឆាប់ បើចីវរនោះខ្វះធ្វើមិនគ្រាន់ទេ ភិក្ខុនោះមានបំណងថា នឹងរកចីវរមកបំពេញនូវចីវរដែលខ្វះ (នោះ) ត្រូវទុកចីវរនោះបាន យ៉ាងយូរបំផុតត្រឹម ១ ខែ បើទុកឲ្យលើសពី ១ ខែនោះទៅ បើទុកជាមានបំណងថា នឹងរកចីវរមកបំពេញទៀតក៏ដោយ គង់ត្រូវនិស្សគ្គិយបាចិត្តិយ ។

[៣៤] ត្រង់ពាក្យថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ អធិប្បាយថា ចីវរដែលភិក្ខុធ្វើរួចហើយក្តី ចីវរបាត់ក្តី ចីវរខូចក្តី ចីវរភ្លើងឆេះក្តី សេចក្តីចង់បានចីវរដាច់ស្រលះហើយក្តី ។ ពាក្យថា កឋិនដោះហើយ អធិប្បាយថា កឋិនដែលដោះហើយ បណ្តាមាតិកាទាំង ៨ យ៉ាង ដោយមាតិកាណាមួយ ឬពុំនោះជំនុំសង្ឃបានដោះហើយក្នុងចន្លោះ (ខេត្តកឋិន) ។ (បើ) ភិក្ខុមិនបានក្រាលគ្រងកឋិនទេ ចីវរដែលកើតឡើងក្នុងឱកាស ១១ ខែហៅថា អកាលចីវរ (បើ) ភិក្ខុបានក្រាលគ្រងកឋិន ចីវរដែលកើតឡើងក្នុងឱកាស ៧ ខែ ហៅថា អកាលចីវរ បើទុកជាគេពោលថា ជាកាលចីវរហើយឲ្យក៏ដោយ គង់ហៅថា អកាលចីវរដូចគ្នា ។

ឧប្បជ្ជេយ្យាតិ ឧប្បជ្ជេយ្យ សង្ឃតោ វា គណតោ វា ញាតិតោ វា មិត្តតោ វា បំសុកូលតោ[១] វា អត្តនោ វា ធនេន ។

[៣៥] អាកង្ខមានេនាតិ ឥច្ឆមានេន បដិគ្គ-ហេតព្វំ ។ បដិគ្គហេត្វា ខិប្បមេវ ការេតព្វន្តិ ទសាហា ការេតព្វំ ។

[៣៦] នោ ចស្ស បារិបូរីតិ ការិយមានំ នប្បហោតិ ។ មាសបរមន្តេន ភិក្ខុនា តំ ចីវរំ និក្ខិបិតព្វន្តិ មាសបរ-មតា និក្ខិបិតព្វំ ។ ឩនស្ស បារិបូរិយាតិ ឩនស្ស បារិបូរត្ថាយ ។ សតិយា បច្ចាសាយាតិ បច្ចាសា ហោតិ សង្ឃតោ វា គណតោ វា ញាតិតោ វា មិត្តតោ វា បំសុកូលតោ[២] វា អត្តនោ វា ធនេន ។

[៣៧] តតោ ចេ ឧត្តរឹ និក្ខិបេយ្យ សតិយាបិ បច្ចាសាយាតិ តទហុប្បន្នេ មូលចីវរេ បច្ចាសាចីវរំ ឧប្បជ្ជតិ

១ ឱ. ម. បំសុកុលំ ។ ២ ឱ. ម. បំសុកុលំ ។

ពាក្យថា កើតឡើង អធិប្បាយថា គប្បីកើតឡើងអំពីសង្ឃក្តី អំពីគណៈក្តី អំពីញាតិក្តី អំពីមិត្តក្តី អំពីបំសុកូលក្តី អំពីទ្រព្យរបស់ខ្លួនក្តី ។

[៣៥] ពាក្យថា ត្រូវការ អធិប្បាយថា កាលបើចង់បាន ត្រូវទទួលចុះ ។ ពាក្យថា លុះទទួលរួចហើយ ត្រូវរៀសរវៃធ្វើឲ្យឆាប់ អធិប្បាយថា ត្រូវធ្វើឲ្យទាន់ក្នុងរវាង ១០ ថ្ងៃ ។

[៣៦] ពាក្យថា បើចីវរនោះខ្វះ ធ្វើមិនគ្រាន់ទេ អធិប្បាយថា ចីវរដែលភិក្ខុធ្វើទៅហើយមិនគ្រាន់ ។ ពាក្យថា ភិក្ខុនោះត្រូវទុកចីវរនោះ បានយ៉ាងយូរបំផុតត្រឹម ១ ខែ អធិប្បាយថា ភិក្ខុត្រូវទុក (ចីវរ) ជាយូរបំផុតត្រឹមតែ ១ ខែ ។ ពាក្យថា ដើម្បីនឹងបំពេញនូវចីវរដែលខ្វះ អធិប្បាយថា ដើម្បីសេចក្តីត្រូវការនឹងបំពេញនូវចីវរដែលខ្វះ ។ ពាក្យថា បើទុកជាមានបំណង អធិប្បាយថា មានសេចក្តីសង្ឃឹមថា នឹងបានអំពីសង្ឃក្តី អំពីគណៈក្តី អំពីញាតិក្តី អំពីមិត្តក្តី អំពីបង្សុកូលក្តី អំពីទ្រព្យរបស់ខ្លួនក្តី ។

[៣៧] ពាក្យថា បើទុកឲ្យលើសពី ១ ខែនោះទៅ ទុកជាមានបំណងថា នឹងរកចីវរមកបំពេញទៀតក៏ដោយ អធិប្បាយថា កាលបើមូលចីវរ[១] កើតឡើងក្នុងថ្ងៃនោះហើយ បច្ចាសាចីវរ[២] ក៏កើតឡើង

១ ចីវរដើម ។ ២ ចីវរដែលកើតឡើងដោយសេចក្តីចង់បានជាខាងក្រោយ ។

២៩



ទសាហា ការេតព្វំ ។ ទ្វីហុប្បន្នេ មូលចីវរេ... តីហុប្បន្នេ មូលចីវរេ... ចតូហុប្បន្នេ មូលចីវរេ... បញ្ចាហុប្បន្នេ មូលចីវរេ... ឆាហុប្បន្នេ មូលចីវរេ... សត្តាហុប្បន្នេ មូលចីវរេ... អដ្ឋាហុប្បន្នេ មូលចីវរេ... នវាហុប្បន្នេ មូលចីវរេ... ទសាហុប្បន្នេ មូលចីវរេ... បច្ចាសាចីវរំ ឧប្បជ្ជតិ ទសាហា ការេតព្វំ ។ ឯកាទសេ ឧប្បន្នេ មូលចីវរេ... ទ្វាទសេ ឧប្បន្នេ មូលចីវរេ... តេរសេ ឧប្បន្នេ មូលចីវរេ... ចុទ្ទសេ ឧប្បន្នេ មូលចីវរេ... បណ្ណរសេ ឧប្បន្នេ មូលចីវរេ... សោឡសេ ឧប្បន្នេ មូលចីវរេ... សត្តរសេ ឧប្បន្នេ មូលចីវរេ... អដ្ឋារសេ ឧប្បន្នេ មូលចីវរេ... ឯកូនវីសេ ឧប្បន្នេ មូលចីវរេ... វីសេ ឧប្បន្នេ មូលចីវរេ បច្ចាសាចីវរំ ឧប្បជ្ជតិ ទសាហា ការេតព្វំ ។ ឯកវីសេ ឧប្បន្នេ មូលចីវរេ បច្ចាសាចីវរំ ឧប្បជ្ជតិ នវាហា ការេតព្វំ ។ ទ្វាវីសេ ឧប្បន្នេ មូលចីវរេ បច្ចាសាចីវរំ ឧប្បជ្ជតិ អដ្ឋាហា ការេតព្វំ ។ តេវីសេ ឧប្បន្នេ មូលចីវរេ... សត្តាហា ការេតព្វំ ។

(ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ១០ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២ ថ្ងៃ... ៣ ថ្ងៃ... ៤ ថ្ងៃ... ៥ ថ្ងៃ... ៦ ថ្ងៃ... ៧ ថ្ងៃ... ៨ ថ្ងៃ... ៩ ថ្ងៃ... ១០ ថ្ងៃ... បច្ចាសាចីវរក៏កើតឡើងក្នុងថ្ងៃទី ១០ ភិក្ខុគប្បីធ្វើចីវរឲ្យហើយ ក្នុងរវាង ១០ ថ្ងៃ ។ កាលបើមូលចីវរ កើតឡើងបាន ១១ ថ្ងៃ... ១២ ថ្ងៃ... ១៣ ថ្ងៃ... ១៤ ថ្ងៃ... ១៥ ថ្ងៃ... ១៦ ថ្ងៃ... ១៧ ថ្ងៃ... ១៨ ថ្ងៃ... ១៩ ថ្ងៃ... ២០ ថ្ងៃ បច្ចាសាចីវរក៏កើតឡើងក្នុងថ្ងៃទី ២០ ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ១០ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២១ ថ្ងៃ បច្ចាសាចីវរក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៩ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២២ ថ្ងៃ បច្ចាសាចីវរ ក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៨ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៣ ថ្ងៃ បច្ចាសាចីវរ ក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៧ ថ្ងៃ ។

ចតុព្វីសេ ឧប្បន្នេ មូលចីវរេ... ឆាហា ការេតព្វំ ។

បញ្ចវីសេ ឧប្បន្នេ មូលចីវរេ... បញ្ចាហា ការេតព្វំ ។

ឆព្វីសេ ឧប្បន្នេ មូលចីវរេ... ចតូហា ការេតព្វំ ។

សត្តវីសេ ឧប្បន្នេ មូលចីវរេ... តីហា ការេតព្វំ ។

អដ្ឋវីសេ ឧប្បន្នេ មូលចីវរេ... ទ្វីហា ការេតព្វំ ។

ឯកូនត្តឹសេ ឧប្បន្នេ មូលចីវរេ បច្ចាសាចីវរំ ឧប្បជ្ជតិ ឯកាហំ ការេតព្វំ ។ តឹសេ ឧប្បន្នេ មូលចីវរេ បច្ចាសាចីវរំ ឧប្បជ្ជតិ តទហេវ អធិដ្ឋាតព្វំ វិកប្បេតព្វំ វិស្សជ្ជេតព្វំ ។ នោ ចេ អធិដ្ឋហេយ្យ វា វិកប្បេយ្យ វា វិស្សជ្ជេយ្យ វា ឯកតឹសេ អរុណុគ្គមនេ និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ អកាលចីវរំ មាសាតិក្កន្តំ និស្សគ្គិយំ ឥមាហំ

កាលបើមូលចីវរកើតឡើងបាន ២៤ ថ្ងៃ បច្ចាសាចីវរ ក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៦ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៥ ថ្ងៃ បច្ចាសាចីវរ ក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៥ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៦ ថ្ងៃ បច្ចាសាចីវរ ក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៤ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៧ ថ្ងៃ បច្ចាសាចីវរ ក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ៣ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៨ ថ្ងៃ បច្ចាសាចីវរ ក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ២ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ២៩ ថ្ងៃ បច្ចាសាចីវរ ក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឲ្យទាន់ក្នុងរវាង ១ ថ្ងៃ ។ កាលបើមូលចីវរកើតឡើងបាន ៣០ ថ្ងៃ បច្ចាសាចីវរ ក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុនោះ ត្រូវអធិដ្ឋាន ត្រូវវិកប្ប ត្រូវលះបង់ក្នុងថ្ងៃនោះឯង ។ បើភិក្ខុមិនបានអធិដ្ឋានក្តី មិនបានវិកប្បក្តី មិនបានលះបង់ក្តី តែអរុណរះឡើងក្នុងថ្ងៃទី ៣១ (ចីវរនោះ) ត្រូវនិស្សគ្គិយ ភិក្ខុត្រូវលះបង់ដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះយ៉ាងនេះ ។ បេ ។ ថា បពិត្រព្រះសង្ឃដ៏ចម្រើន នេះជាអកាលចីវររបស់ខ្ញុំ ទុកកន្លងហួស ១ ខែ

សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[៣៨] វិសភាគេ ឧប្បន្នេ មូលចីវរេ បច្ចាសាចីវរំ ឧប្បជ្ជតិ រត្តិយោ ច សេសា ហោន្តិ ន អកាមា ការេតព្វំ ។

[៣៩] មាសាតិក្កន្តេ អតិក្កន្តសញ្ញី និស្សគ្គិយំ ចាចិត្តិយំ ។ មាសាតិក្កន្តេ វេមតិកោ និស្សគ្គិយំ ចាចិត្តិយំ ។ មាសាតិក្កន្តេ អនតិក្កន្តសញ្ញី និស្សគ្គិយំ ចាចិត្តិយំ ។ អនធិដ្ឋិតេ អធិដ្ឋិតសញ្ញី អវិកប្បិតេ វិកប្បិតសញ្ញី អវិស្សជ្ជិតេ វិស្សជ្ជិតសញ្ញី អនដ្ឋេ នដ្ឋសញ្ញី អវិនដ្ឋេ វិនដ្ឋសញ្ញី អទឌ្ឍេ ទឌ្ឍសញ្ញី អវិលុត្តេ វិលុត្តសញ្ញី និស្សគ្គិយំ ចាចិត្តិយំ ។

ត្រូវនិស្សគ្គិយហើយ ឥឡូវ ខ្ញុំសូមលះចីវរនេះដល់សង្ឃ ។ (ត្រង់បេយ្យាល ទាំងបី មានសេចក្ដីដូចគ្នានឹងសិក្ខាបទ ទី ១ ក្នុងវគ្គជាមួយគ្នានេះ) ។

[៣៨] កាលបើមូលចីវរ ដែលមានចំណែកមិនស្មើគ្នា[១] កើតឡើងហើយ បច្ចាសាចីវរក៏កើតឡើងដែរ តែរាត្រីសល់នៅច្រើន (បើ) ភិក្ខុមិនចង់ធ្វើទេ ក៏មិនត្រូវធ្វើ (ចីវរនោះឡើយ) ។

[៣៩] ចីវរកន្លងទៅ ១ ខែហើយ ភិក្ខុសំគាល់ថា កន្លងទៅមែន ត្រូវនិស្សគ្គិយបាចិត្តិយ ។ ចីវរកន្លងទៅ ១ ខែហើយ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ចីវរកន្លងទៅ ១ ខែហើយ ភិក្ខុសំគាល់ថា មិនទាន់កន្លងទេ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ចីវរដែលមិនបានអធិដ្ឋាន ភិក្ខុសំគាល់ថា បានអធិដ្ឋានហើយ (ក្ដី) ចីវរដែលមិនបានវិកប្ប ភិក្ខុសំគាល់ថា បានវិកប្បហើយ (ក្ដី) ចីវរដែលមិនបានលះបង់ ភិក្ខុសំគាល់ថា បានលះបង់ហើយ (ក្ដី) ចីវរដែលមិនបាត់ ភិក្ខុសំគាល់ថា បាត់ (ក្ដី) ចីវរដែលមិនខូចទេ ភិក្ខុសំគាល់ ថាខូច (ក្ដី) ចីវរភ្លើងមិនឆេះ ភិក្ខុសំគាល់ថា ភ្លើងឆេះ (ក្ដី) ចីវរចោរឥតបានយកទេ ភិក្ខុសំគាល់ថា ចោរយក (ក្ដី) ត្រូវនិស្សគ្គិយបាចិត្តិយ (ដូចគ្នាទាំងអស់) ។

---

១ មូលចីវរឬបច្ចាសាចីវរ ដែលមានសាច់ក្រាស់ស្ដើងមិនស្មើគ្នា ភិក្ខុមិនអាចនឹងដេរជាមួយគ្នាបាន ហៅថា មានចំណែកមិនស្មើគ្នា ។

[៤០] និស្សគ្គិយំ ចីវរំ អនិស្សជ្ជិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។ មាសាតិក្កន្តេ អតិក្កន្តសញ្ញី អាបត្តិ ទុក្កដស្ស ។ មាសាតិក្កន្តេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ មាសាតិក្កន្តេ អនតិក្កន្តសញ្ញី អនាបត្តិ ។

[៤១] អនាបត្តិ អន្តោមាសេ អធិដ្ឋេតិ វិកប្បេតិ វិស្សជ្ជេតិ នស្សតិ វិនស្សតិ ឌយ្ហតិ អច្ឆិន្ទិត្វា គណ្ហាតិ[១] វិស្សាសំ គណ្ហាតិ[២] ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។

---

១-២ ឱ. ម. គណ្ហន្តិ ។

[៤០] ភិក្ខុមិនបានលះចីវរ ដែលជានិស្សគ្គិយ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់កន្លងទៅ ១ ខែទេ ហើយភិក្ខុសំគាល់ថា កន្លងទៅហើយ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់កន្លង ១ ខែទេ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់កន្លង ១ ខែទេ ភិក្ខុសំគាល់ថា មិនទាន់កន្លងមែន មិនត្រូវអាបត្តិឡើយ ។

[៤១] វារៈសំដែងអំពីមិនមានអាបត្តិ គឺ ភិក្ខុបានអធិដ្ឋានចីវរនោះក្នុងរវាងមួយខែ ១ បានវិកប្បចីវរ ១ បានលះ ១ ចីវរបាត់ ១ ចីវរខូច ១ ចីវរភ្លើងឆេះ ១ ចីវរដែលចោរដណ្ដើមយកទៅ ១ គេយកចីវរដោយសេចក្ដីស្និទ្ធស្នាល ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៣ ចប់ ។

# ចតុត្ថសិក្ខាបទំ

[៤២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មតោ ឧទាយិស្ស បុរាណ-ទុតិយិកា ភិក្ខុនីសុ បព្វជិតា ហោតិ ។ សា ភិក្ខុនី[១] អាយស្មតោ ឧទាយិស្ស សន្តិកេ អភិក្ខណំ អាគច្ឆតិ ។ អាយស្មាបិ ឧទាយិ តស្សា ភិក្ខុនិយា សន្និកេ អភិក្ខណំ គច្ឆតិ ។ តេន ខោ បន សមយេន អាយស្មា ឧទាយិ តស្សា ភិក្ខុនិយា សន្តិកេ ភត្តវិស្សគ្គំ ករោតិ ។ អថខោ អាយស្មា ឧទាយិ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន សា ភិក្ខុនី តេនុប-សង្កមិ ឧបសង្កមិត្វា តស្សា ភិក្ខុនិយា បុរតោ អង្គជាតំ វិវរិត្វា អាសនេ និសីទិ ។ សាបិ ខោ ភិក្ខុនី អាយ-ស្មតោ ឧទាយិស្ស បុរតោ អង្គជាតំ វិវរិត្វា អាសនេ និសីទិ ។ អថខោ អាយស្មា ឧទាយិ សារត្តោ រ[២]

១ ឱ. ម. បោត្ថកេសុ ន ទិស្សតិ ។ ២ ឱ. ម. សារត្តោ ។

# សិក្ខាបទទី ៤

[៤២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានស្រីជាបុរាណទុតិយិកា របស់ឧទាយិភិក្ខុដ៏មានអាយុ បួសក្នុងសំណាក់នាងភិក្ខុនី ។ នាងភិក្ខុនីនោះ តែងមកកាន់សំណាក់ឧទាយិភិក្ខុដ៏មានអាយុជារឿយ ៗ ។ ចំណែកខាងឧទាយិភិក្ខុដ៏មានអាយុ ក៏តែងទៅកាន់សំណាក់នាងភិក្ខុនីនោះជារឿយ ៗ ដែរ ។ វេលានោះឯង ឧទាយិភិក្ខុដ៏មានអាយុបរិភោគភត្តក្នុងសំណាក់នាងភិក្ខុនីនោះ ។ លំដាប់នោះ ឧទាយិភិក្ខុដ៏មានអាយុ ក៏ស្លៀកដណ្តប់រួចយកបាត្រនិងចីវរ ចូលសំដៅទៅរកទីដែលនាងភិក្ខុនីនោះនៅ ក្នុងវេលាព្រឹកព្រហាម លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈខាងមុខនាងភិក្ខុនីនោះ បើកអង្គជាតបង្ហាញ ។ ឯនាងភិក្ខុនីនោះ ក៏អង្គុយលើអាសនៈខាងមុខឧទាយិដ៏មានអាយុបើកអង្គជាតបង្ហាញដែរ ។ វេលានោះ ឧទាយិភិក្ខុដ៏មានអាយុមានតម្រេក

តស្សា ភិក្ខុនិយា អង្គជាតំ ឧបជិជ្ឈាយិ ។ តស្ស អង្គជាតតោ[១] អសុចិ មុច្ចិ ។ អថខោ អាយស្មា ឧទាយិ តំ ភិក្ខុនឹ ឯតទវោច គច្ឆ ភគិនិ ឧទកំ អាហរ អន្តរវាសកំ ធោវិស្សាមីតិ ។ អាហរយ្យ អហមេវ ធោវិស្សាមីតិ ។ អថខោ[២] សា[៣] ភិក្ខុនី[៤] តស្ស[៥] តំ អសុចឹ ឯកទេសំ មុខេន អគ្គហេសិ ឯកទេសំ អង្គជាតេ បក្ខិបិ ។ សា តេន គព្ភំ គណ្ហិ ។ ភិក្ខុនិយោ ឯវមាហំសុ អយំ ភិក្ខុនី អព្រហ្មចារិនី អយំ គព្ភិនីតិ[៦] ។ នាហំ អយ្យេ អព្រហ្មចារិនីតិ ។ អថខោ[៧] សា[៨] ភិក្ខុនី[៩] ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខុនិយោ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យោ ឧទាយិ ភិក្ខុនិយា បុរាណចីវរំ ធោវាបេស្សតីតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧទាយិ ភិក្ខុនិយា បុរាណចីវរំ ធោវាបេស្សតីតិ ។

---

១ តេសុ ន បញ្ញាយតិ ។ ២-៣-៤-៥ តេសុ ន ទិស្សន្តិ ។ ៦ ឱ. ម. អព្រហ្មចារិនី អយំ ភិក្ខុនី គព្ភិនីតិ ។ ៧-៨-៩ តេសុ ន បញ្ញាយន្តិ ។

ក៏សំឡឹងមើលទៅអង្គជាតនាងភិក្ខុនីនោះ ។ ទឹកអសុចិ ក៏ហូរធ្លាក់ពីអង្គជាតរបស់ឧទាយិភិក្ខុនោះ ។ លំដាប់នោះ ឧទាយិភិក្ខុដ៏មានអាយុ ក៏និយាយទៅនឹងភិក្ខុនីនោះថា នែប្អូនស្រី ឯងចូរទៅនាំយកទឹកមក អញនឹងលាងស្បង់ ។ នាងភិក្ខុនីនោះតបវិញថា លោកម្ចាស់ សូមលោកម្ចាស់ឲ្យស្បង់មកខ្ញុំវិញ ខ្ញុំនឹងលាងប្រគេន ។ វេលានោះឯង នាងភិក្ខុនីនោះ ក៏បានយកទឹកអសុចិរបស់ឧទាយិភិក្ខុនោះ បន្តិចដាក់ក្នុងម៉ាត់ យកបន្តិចដាក់ក្នុងអង្គជាត ។ នាងភិក្ខុនីនោះ ក៏មានគភ៌ដោយសារទឹកអសុចិនោះ ។ ពួកនាងភិក្ខុនី ក៏និយាយយ៉ាងនេះថា នាងភិក្ខុនីនេះ មិនមែនប្រព្រឹត្តធម៌ដ៏ប្រសើរទេ ទើបបាននាងភិក្ខុនីនេះមានគភ៌ ។ នាងភិក្ខុនីនោះ តបវិញថា ម្នាលនាងទាំងឡាយ ខ្លួនខ្ញុំមិនបានប្រព្រឹត្តធម៌ដ៏ប្រសើរទេ ។ វេលានោះ នាងភិក្ខុនីនោះ បានប្រាប់សេចក្តីនុ៎ះ ដល់នាងភិក្ខុនីផងគ្នា ។ នាងភិក្ខុនីទាំងឡាយ ក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើលោកម្ចាស់ឧទាយិ ប្រើនាងភិក្ខុនីឲ្យលាងចីវរចាស់ (របស់ខ្លួនសោះ) ។ លំដាប់នោះ ពួកនាងភិក្ខុនីទាំងនោះ បានប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណា ដែលមានប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះ ក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា គួរបើដែរ ឧទាយិដ៏មានអាយុប្រើនាងភិក្ខុនីឲ្យលាងចីវរចាស់ ។

៣៤

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស ចតុត្ថសិក្ខាបទស្ស បញ្ញត្តិ

អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ។ បេ ។ អាយស្មន្តំ ឧទាយឹ បដិបុច្ឆិ សច្ចំ កិរ ត្វំ ឧទាយិ ភិក្ខុនិយា បុរាណចីវរំ ធោវាបេសីតិ ។ សច្ចំ ភគវាតិ ។ ញាតិកា តេ ឧទាយិ អញ្ញាតិ កាតិ ។ អញ្ញាតិកា ភគវាតិ ។ អញ្ញាតកោ មោឃបុរិស អញ្ញាតិកាយ ន ជានាតិ បដិរូបំ វា អប្បដិរូបំ វា ចាសាទិកំ វា អប្បាសាទិកំ វា តត្ថ ហិ នាម ត្វំ មោឃបុរិស អញ្ញាតិកាយ ភិក្ខុនិយា បុរាណចីវរំ ធោវាបេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា បុរាណចីវរំ ធោវាបេយ្យ វា រជាបេយ្យ វា អាកោដាបេយ្យ វា និស្សគ្គិយំ ចាចិត្តិយន្តិ ។

គ្រានោះ ពួកភិក្ខុទាំងនោះ បានក្រាបទូលសេចក្ដីនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ។ បេ ។ ទ្រង់សួរឧទាយិភិក្ខុដ៏មានអាយុថា ម្នាលឧទាយិ ឮថាអ្នកបានប្រើនាងភិក្ខុនី ឲ្យលាងចីវរចាស់ មែនឬ ។ ឧទាយិក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មែន ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរថា ម្នាលឧទាយិ នាងភិក្ខុនីនោះ ត្រូវជាញាតិ ឬមិនមែនជាញាតិនឹងអ្នកទេ ។ ឧទាយិក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស (នាងភិក្ខុនីនោះ) មិនត្រូវជាញាតិនឹងខ្ញុំព្រះអង្គទេ ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា នៃមោឃបុរស ជនមិនមែនជាញាតិ មិនស្គាល់អំពើសមគួរ ឬមិនសមគួរ អំពើនាំមកនូវសេចក្ដីជ្រះថ្លា ឬ មិននាំមកនូវសេចក្ដីជ្រះថ្លា របស់នាងភិក្ខុនីដែលមិនមែនជាញាតិ (នោះទេ) នៃមោឃបុរស មិនសមបើអ្នកទៅប្រើនាងភិក្ខុនីដែលមិនមែនជាញាតិ ឲ្យលាងចីវរចាស់សោះ នៃមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំពួកមនុស្សដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើង ឬមនុស្សដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀត (នោះ) ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ប្រើនាងភិក្ខុនីដែលមិនមែនជាញាតិ ឲ្យលាងក្ដី ឲ្យជ្រលក់ក្ដី ឲ្យគក់ឬបោកក្ដី នូវចីវរចាស់ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[៤៣] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អញ្ញាតិកា នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុគា អសម្ពទ្ធា ។ ភិក្ខុនី នាម ឧភតោ សង្ឃេ ឧបសម្បន្នា ។ បុរាណចីវរំ នាម សកឹ និវត្ថំបិ សកឹ បារុតំបិ ។ ធោវាតិ(១) អាបត្តិ ទុក្កដស្ស ។ ធោតំ(២) និស្សគ្គិយំ ហោតិ ។ រជាតិ អាណាបេតិ(៣) អាបត្តិ ទុក្កដស្ស ។ រត្តំ(៤) និស្សគ្គិយំ ហោតិ ។ អាកោដេហីតិ អាណាបេតិ(៥) អាបត្តិ ទុក្កដស្ស ។ សកឹ បាណិប្បហារំ(៦) វា មុគ្គរប្បហារំ(៧) វា ទិន្នេ និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ បុរាណចីវរំ

---

១ ឱ. ធោវាបេយ្យាតិ ធោវាហីតិ អាណាបេតិ ។ ២ ឱ. ធោវាបិតំ ។ ៣ ឱ. រជាបេយ្យាតិ រជាហីតិ អាណាបេតិ ។ ៤ ឱ. រជ្ជិតំ ។ ៥ ឱ. អាកោដាបេយ្យាតិ អាកោដេហីតិ អាណាបេតិ ។ ៦ បាណិប្បហារេតិបិ បាឋោ ។ ៧ មុគ្គរប្បហារេតិបិ បាឋោ ។

[៤៣] ត្រង់ពាក្យថា ភិក្ខុណាមួយ (ត្រង់បេយ្យាលទាំងពីរ) មាន អធិប្បាយត្រង់សិក្ខាបទទី ១ ក្នុងបារាជិកកណ្ឌរួចហើយ ។ នាងភិក្ខុនី ដែលឥតមានជាប់ទងគន្ធងអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាជាគម្រប់ ៧ ហៅថា មិនមែនជាញាតិ ។ ដែល ហៅថា នាងភិក្ខុនី (នោះសំដៅយក) ស្រីដែលបានឧបសម្បទាក្នុង សំណាក់សង្ឃទាំងពី (ភិក្ខុសង្ឃនិងភិក្ខុនីសង្ឃ) ។ សំពត់ដែលភិក្ខុស្លៀក ម្តងក្តី ដណ្តប់ម្តងក្តី ហៅថា ចីវរចាស់ ។ ភិក្ខុប្រើនាងភិក្ខុនីថា នាងចូរ លាងចីវរឲ្យអាត្មា (យ៉ាងនេះ) ត្រូវអាបត្តិទុក្កដ ។ ចីវរដែលនាងភិក្ខុនី លាងហើយនោះ ជានិស្សគ្គិយ ។ ភិក្ខុបង្គាប់នាងភិក្ខុនីថា នាងចូរជ្រ-លក់ចីវរឲ្យអាត្មា ត្រូវអាបត្តិទុក្កដ ។ ចីវរដែលនាងភិក្ខុនីជ្រលក់ហើយ នោះ ជានិស្សគ្គិយ ។ ភិក្ខុប្រើនាងភិក្ខុនីថា នាងចូរបោកចីវរឲ្យអាត្មា ត្រូវ អាបត្តិទុក្កដ ។ កាលបើចីវរដែលនាងភិក្ខុនីយកមកបោក ដោយដៃក្តី ដោយដំបងក្តី អស់វារៈតែម្តង ចីវរនោះជានិស្សគ្គិយ ភិក្ខុត្រូវលះចីវរនោះ ដល់ជំនុំសង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវ លះចីវរយ៉ាងនេះ ។ បេ ។ ថា បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរចាស់នេះ

អញ្ញាតិកាយ ភិក្ខុនិយា ធោវាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[៤៤] អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ ធោវាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ ធោវាបេតិ រជាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ ធោវាបេតិ អាកោដាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ ធោវាបេតិ រជាបេតិ អាកោដាបេតិ និស្សគ្គិយេន អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ រជាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ រជាបេតិ អាកោដាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ រជាបេតិ

ខ្ញុំបានប្រើនាងភិក្ខុនីមិនមែនជាញាតិឲ្យលាង ជានិស្សគ្គិយហើយ ខ្ញុំសូមលះចីវរនេះដល់ជំនុំសង្ឃ ។ (ត្រង់បេយ្យាលទាំងបី មានអធិប្បាយត្រង់សិក្ខាបទទី ១ ក្នុងវគ្គជាមួយគ្នានេះរួចហើយ) ។

[៤៤] នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ហើយប្រើឲ្យលាង នូវចីវរចាស់ ត្រូវនិស្សគ្គិយបាចិត្តិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ហើយប្រើឲ្យលាង ឲ្យជ្រលក់ នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ។ ហើយប្រើឲ្យលាង ឲ្យបោក នូវចីវរចាស់ ត្រូវអាបត្តិទុក្កដនិងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យលាង ឲ្យជ្រលក់ ឲ្យបោក នូវចីវរចាស់ ត្រូវអាបត្តិទុក្កដពីរ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យជ្រលក់ នូវចីវរចាស់ ត្រូវនិស្សគ្គិយបាចិត្តិយ ។ នាងភិក្ខុនីដែលមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យជ្រលក់ ឲ្យបោក នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យជ្រលក់

ជោវាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ រជាបេតិ អាកោដាបេតិ ជោវាបេតិ និស្សគ្គិយេន អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ អាកោដាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ អាកោដាបេតិ ជោវាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ អាកោដាបេតិ រជាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី បុរាណចីវរំ អាកោដាបេតិ ជោវាបេតិ រជាបេតិ និស្សគ្គិយេន អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ អញ្ញាតិកាយ វេមតិកោ ។ បេ ។ អញ្ញាតិកាយ ញាតិកសញ្ញី ។ បេ ។ អញ្ញស្ស បុរាណចីវរំ ជោវាបេតិ អាបត្តិ ទុក្កដស្ស ។ និសីទនប្បច្ចត្ថរណំ ជោវាបេតិ អាបត្តិ ទុក្កដស្ស ។ ឯកតោ ឧបសម្បន្នាយ

ឲ្យលាង នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យជ្រលក់ ឲ្យបោក ឲ្យលាង នូវចីវរចាស់ ត្រូវអាបត្តិទុក្កដពីរ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យបោក នូវចីវរចាស់ ត្រូវនិស្សគ្គិយបាចិត្តិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យបោក ឲ្យលាង នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ហើយប្រើឲ្យបោក ឲ្យជ្រលក់ នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឲ្យបោក ឲ្យលាង ឲ្យជ្រលក់ នូវចីវរចាស់ ត្រូវអាបត្តិទុក្កដពីរ និងនិស្សគ្គិយ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ។ បេ ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ។ បេ ។ ហើយប្រើឲ្យលាង នូវចីវរចាស់របស់ភិក្ខុឯទៀត ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រើ (នាងភិក្ខុនីមិនមែនជាញាតិ) ឲ្យលាងសំពត់និសីទនៈ និងគ្រឿងកម្រាល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រើនាងភិក្ខុនីដែលជាឯកតោឧបសម្បន្នា

ធោវាបេតិ អាបត្តិ ទុក្កដស្ស ។ ញាតិកាយ អញ្ញាតិ-
កសញ្ញី អាបត្តិ ទុក្កដស្ស ។ ញាតិកាយ វេមតិកោ
អាបត្តិ ទុក្កដស្ស ។ ញាតិកាយ ញាតិកសញ្ញី
អនាបត្តិ ។

[៤៥] អនាបត្តិ ញាតិកាយ ធោវន្តិយា អញ្ញាតិកា
ទុតិយា ហោតិ អវុត្តា ធោវតិ អបរិភុត្តំ ធោវាបេតិ
ចីវរំ ឋបេត្វា អញ្ញំ បរិក្ខារំ ធោវាបេតិ សិក្ខមានាយ
សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។

ឲ្យលាងត្រូវអាបត្តិទុក្កដ ។ នាងភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថា មិនមែនញាតិ ត្រូវអាបត្តិទុក្កដ ។ នាងភិក្ខុនីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ នាងភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ មិនត្រូវអាបត្តិឡើយ ។

[៤៥] អាបត្តិ (មិនមានដល់ភិក្ខុ មាន ៨ យ៉ាង) គឺ នាងភិក្ខុនីដែលជាញាតិរបស់ភិក្ខុ កំពុងលាងចីវររបស់ភិក្ខុ ហើយស្រាប់តែមាននាងភិក្ខុនីទីពីរដែលមិនមែនជាញាតិ មកយកចីវរអំពីដៃនាងភិក្ខុនីនោះទៅលាងឲ្យ ១ នាងភិក្ខុនីឃើញចីវររបស់ភិក្ខុ មានមន្ទិលសៅហ្មង ហើយយកមកលាងឲ្យមិនបាច់ចាំប្រើ ១ ភិក្ខុប្រើនាងភិក្ខុនី ឲ្យលាងចីវរថ្មីដែលមិនទាន់បានប្រើប្រាស់ ១ ភិក្ខុប្រើនាងភិក្ខុនី ឲ្យលាងគ្រឿងបរិក្ខារឯទៀតក្រៅពីចីវរ ១ ភិក្ខុប្រើនាងសិក្ខមានាឲ្យលាងចីវរឲ្យ ១ ភិក្ខុប្រើសាមណេរីឲ្យលាងចីវរឲ្យ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៤ ចប់ ។

# បញ្ចមសិក្ខាបទំ

[៤៦] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ឧប្បលវណ្ណា ភិក្ខុនី សាវត្ថិយំ វិហរតិ អន្ធវនេ ។ អថខោ ឧប្បលវណ្ណា ភិក្ខុនី បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ ចាវិសិ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន អន្ធវនំ តេនុបសង្កមិ ទិវាវិហារាយ អន្ធវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។ តេន ខោ បន សមយេន ចោរា កតកម្មា គាវឹ វធិត្វា មំសំ គហេត្វា អន្ធវនំ បវិសឹសុ ។ អទ្ទសា ខោ ចោរគាមណិកោ ឧប្បលវណ្ណំ ភិក្ខុនឹ អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសិន្នំ ។ ទិស្វានស្ស ឯតទហោសិ សចេ មេ បុត្តភាតិកា[១] បស្សិស្សន្តិ វិហេឋយិស្សន្តិ ឥមំ ភិក្ខុនិន្តិ អញ្ញេន មគ្គេន អគមាសិ ។

១ ឱ. ម. បុត្តភាតុកា ។

# សិក្ខាបទទី ៥

[៤៦] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវនកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង នាងឧប្បលវណ្ណាភិក្ខុនីនៅក្នុងអន្ធវ័ន ទៀបក្រុងសាវត្ថី ។ វេលានោះឯង នាងឧប្បលវណ្ណាភិក្ខុនី លុះពេលព្រឹកឡើង ក៏បានស្លៀកដណ្ដប់រួចនាំយកបាត្រនិងចីវរចូលទៅឯក្រុងសាវត្ថីដើម្បីបិណ្ឌបាត លុះដើរទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី រួចត្រឡប់មកអំពីបិណ្ឌបាតក្នុងកាលជាខាងក្រោយនៃភត្តហើយក៏ចូលសំដៅទៅក្នុងអន្ធវ័ន (ព្រៃងងឹត) ដើម្បីសម្រាកក្នុងវេលាថ្ងៃ លុះចូលទៅដល់ព្រៃអន្ធវ័នហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃទៀបគល់ឈើនីមួយ ។ សម័យនោះឯង មានពួកចោរអ្នកធ្វើនូវចោរកម្ម បានសម្លាប់មេគោ ១ អារយកសាច់រួចនាំយកចូលទៅកាន់ព្រៃអន្ធវ័ន ។ ឯមេចោរជាធំបានក្រឡេកមើលទៅឃើញនាងឧប្បលវណ្ណាភិក្ខុនី កំពុងអង្គុយសម្រាកក្នុងវេលាថ្ងៃទៀបគល់ឈើនីមួយ ។ លុះឃើញហើយចោរនោះ ក៏មានសេចក្ដីត្រិះរិះថា បើប្រសិនណាពួកចោរជាកូននិងបងប្អូនអញឃើញនាងភិក្ខុនីនេះហើយ មុខជានឹងបៀតបៀននាងភិក្ខុនីនេះមិនខាន (លុះគិតយ៉ាងនេះហើយ) មេចោរក៏នាំពួកចោរទាំងនោះដើរទៅតាមផ្លូវដទៃវិញ

អថខោ សោ ចោរគាមណិកោ មំសេ បក្កេ វរមំសានិ គហេត្វា បណ្ណេន បុដំ[១] ពន្ធិត្វា ឧប្បលវណ្ណាយ ភិក្ខុនិយា អវិទូរេ រុក្ខេ អាលគ្គេត្វា យោ បស្សតិ សមណោ វា ព្រាហ្មណោ វា ទិន្នំយេវ ហរតូតិ វត្វា បក្កាមិ ។ អស្សោសិ ខោ ឧប្បលវណ្ណា ភិក្ខុនី សមាធិម្ហា វុដ្ឋហិត្វា តស្ស ចោរគាមណិកស្ស ឥមំ វាចំ ភាសមានស្ស ។ អថខោ ឧប្បលវណ្ណា ភិក្ខុនី តំ មំសំ គហេត្វា ឧបស្សយំ អគមាសិ ។ អថខោ ឧប្បលវណ្ណា ភិក្ខុនី តស្សា រត្តិយា អច្ចយេន តំ មំសំ សម្បាទេត្វា ឧត្តរាសង្គេន ភណ្ឌិកំ ពន្ធិត្វា វេហាសំ អព្ភុគ្គន្ត្វា វេឡុវនេ បច្ចុដ្ឋាសិ ។

[៤៧] តេន ខោ បន សមយេន ភគវា គាមំ បិណ្ឌាយ បវិដ្ឋោ ហោតិ ។ អាយស្មា ឧទាយិ ឱហិយកោ ហោតិ វិហារបាលោ ។ អថខោ ឧប្ប-លវណ្ណា ភិក្ខុនី យេនាយស្មា ឧទាយិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧទាយឹ ឯតទវោច កហំ ភន្តេ ភគវាតិ ។ បវិដ្ឋោ ភគិនិ ភគវា គាមំ បិណ្ឌាយាតិ ។

---

១ ឱ. ម. បណ្ណបុដំ ។

វេលានោះឯង មេចោរនោះ កាលបើដុំសាច់គេចម្អិនរួចស្រេចហើយ ក៏យកសាច់យ៉ាងល្អ ខ្ចប់នឹងស្លឹកឈើយកទៅព្យួរនឹងដើមឈើជិតនាងឧប្បលវណ្ណាភិក្ខុនី ហើយពោលថា នរណាមួយ ទោះបីជាសមណៈក្តី ព្រាហ្មណ៍ក្តី បានឃើញដុំសាច់ដែលអញទុកឲ្យនេះហើយ ចូរនាំយកទៅចុះ រួចហើយក៏ចេញដើរទៅ ។ នាងឧប្បលវណ្ណាភិក្ខុនី ចេញពីសមាធិហើយ បានឮសំដីនេះរបស់មេចោរដែលកំពុងពោលនោះ ។ លំដាប់នោះ នាងឧប្បលវណ្ណាភិក្ខុនី ក៏បានយកសាច់នោះទៅឯកន្លែងនៅរបស់ខ្លួន ។ វេលានោះឯង នាងឧប្បលវណ្ណាភិក្ខុនី លុះកន្លងរាត្រីនោះទៅហើយ នាងក៏ចាត់ចែងយកសាច់នោះ មកវេចជាបង្វេចដោយចីពរ រួចហើយក៏ហោះទៅឯអាកាស ទៅចុះក្នុងវត្តវេឡុវន ។

[៤៧] សម័យនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់យាងចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ឧទាយិភិក្ខុដ៏មានអាយុជាអ្នកនៅចាំរក្សាវត្ត ។ លំដាប់នោះ នាងឧប្បលវណ្ណាភិក្ខុនី បានចូលទៅរកឧទាយិភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏សួរទៅឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់យាងទៅណា ។ ឧទាយិប្រាប់ថា ម្នាលប្អូនស្រី ព្រះដ៏មានព្រះភាគ ទ្រង់យាងចូលទៅបិណ្ឌបាតឯស្រុកហើយ ។

ឥមំ ភន្តេ មំសំ ភគវតោ ទេហីតិ ។ សន្តប្បិតោ តេ[១] ភគិនិ ភគវា មំសេន សចេ មេ ត្វំ អន្តរវាសកំ ទទេយ្យាសិ ឯវមហម្បិ[២] សន្តប្បិតោ ភវេយ្យំ អន្តរវាសកេនាតិ ។ មយំ ខោ ភន្តេ មាតុគាមា នាម កិច្ចលាភា ឥទញ្ច មេ អន្តិមំ បញ្ចមំ ចីវរំ នាហំ ទស្សាមីតិ ។ សេយ្យថាបិ ភគិនិ បុរិសោ ហត្ថឹ ទត្វា កច្ឆេ វិស្សជ្ជេយ្យ[៣] ឯវមេវ ខោ ត្វំ ភគិនិ ភគវតោ មំសំ ទត្វា មយ្ហំ[៤] អន្តរវាសកំ វិស្សជ្ជេហីតិ[៥] ។ អថខោ ឧប្បលវណ្ណា ភិក្ខុនី អាយស្មតា ឧទាយិនា និប្បីឡិយមានា អន្តរវាសកំ ទត្វា ឧបស្សយំ អគមាសិ ។ ភិក្ខុនិយោ ឧប្បលវណ្ណាយ ភិក្ខុនិយា បត្តចីវរំ បដិគ្គណ្ហន្តិយោ ឧប្បលវណ្ណំ ភិក្ខុនឹ ឯតទវោចុំ កហន្តេ អយ្យេ អន្តរវាសកោតិ ។ ឧប្បលវណ្ណា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខុនិយោ ឧជ្ឈាយន្តិ ខីយន្តិ

១ ឱ. ម. តយា. រាមញ្ញបោត្ថកេ បន ន ទិស្សតិ ។ ២ ឯវញ្ចាហំបីតិបិ បាឋោ ។ ៣ ឱ. ម. សជ្ជេយ្យ ។ ៤ ឱ. ម. មយិ ។ ៥ ឱ. ម. ន សជ្ជសីតិ ។

នាងឧប្បលវណ្ណាភិក្ខុនី និយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាថ្វាយសាច់នេះដល់ព្រះដ៏មានព្រះភាគឲ្យទានផង ។ ឧទាយិនិយាយថា ម្នាលប្អូនស្រី នាងឲ្យព្រះដ៏មានព្រះភាគ ទ្រង់ឆ្អែតដោយសាច់ (យ៉ាងណា) ប្រសិនបើនាងឲ្យស្បង់ដល់អាត្មាៗ ក៏ឈ្មោះថានាងឲ្យឆ្អែតដោយស្បង់យ៉ាងនោះដែរ ។ នាងឧប្បលវណ្ណាភិក្ខុនីតបវិញថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំជាមាតុគ្រាម មានលាភបានដោយកម្រណាស់ ។ មួយទៀតចីវររបស់ខ្ញុំនេះ ជាចីវរគម្រប់ ៥ ជាទីបំផុត ខ្ញុំមិនប្រគេនលោកម្ចាស់ទេ ។ ឧទាយិនិយាយថា ម្នាលប្អូនស្រី ដូចជាបុរសដែលឲ្យដំរី (ទៅគេ) គួរលះខ្សែដង្កូន់ផង យ៉ាងណាមិញ ម្នាលប្អូនស្រី បើនាងថ្វាយសាច់ដល់ព្រះដ៏មានព្រះភាគហើយ ចូរលះស្បង់របស់នាងដល់អាត្មា ក៏យ៉ាងនោះដែរ ។ គ្រានោះ នាងឧប្បលវណ្ណាភិក្ខុនី កាលបើឧទាយិដ៏មានអាយុចេះតែទទូចសូម ក៏ប្រគេនស្បង់ហើយត្រឡប់ទៅឯលំនៅរបស់ខ្លួនវិញ ។ ពួកនាងភិក្ខុនី កាលទទួលយកបាត្រនិងចីវរពីនាងឧប្បលវណ្ណាភិក្ខុនី ក៏សួរនាងឧប្បលវណ្ណាភិក្ខុនីថា បពិត្រនាងជាម្ចាស់ ស្បង់របស់នាង តើនៅឯណា ។ នាងឧប្បលវណ្ណាភិក្ខុនី ក៏បានប្រាប់សេចក្តីនុ៎ះដល់នាងភិក្ខុនីទាំងឡាយ ។ នាងភិក្ខុនីទាំងឡាយក៏លើកទោស តិះដៀល

វិចាចេន្តិ កថំ ហិ នាម អយ្យោ ឧទាយិ ភិក្ខុនិយា ហត្ថតោ[១] ចីវរំ បដិគ្គហេស្សតិ កិច្ឆលាភោ មាតុគា-មោតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម អាយស្មា ឧទាយិ ភិក្ខុនិយា ហត្ថតោ[២] ចីវរំ បដិគ្គហេស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ត្វំ ឧទាយិ ភិក្ខុនិយា ហត្ថតោ[៣] ចីវរំ បដិគ្គហេសីតិ ។ សច្ចំ ភគវាតិ ។ ញាតិកា តេ ឧទាយិ អញ្ញាតិកាតិ ។ អញ្ញាតិកា ភគវាតិ ។ អញ្ញាតកោ មោឃបុរិស អញ្ញាតិកាយ ន ជានាតិ បដិរូបំ វា អប្បដិរូបំ វា សន្តំ វា អសន្តំ វា តត្ថ នាម ត្វំ មោឃបុរិស អញ្ញាតិកាយ ភិក្ខុនិយា ហត្ថតោ ចីវរំ បដិគ្គហេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ

---

១-២-៣ ឱ. ម. បោត្ថកេសុ ន ហោតិ ។

បន្ទុះបង្អាប់ថា លោកម្ចាស់ឧទាយិ មិនសមបើនឹងទទួលយកចីវរពីដៃនាងភិក្ខុនីសោះ មាតុគ្រាមសុទ្ធតែមានលាភបានដោយកម្រ ។ គ្រានោះ នាងភិក្ខុនីទាំងនោះ ក៏ប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណាដែលមានប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះ ក៏លើកទោស តិះដៀលបន្ទុះបង្អាប់ថា ឧទាយិដ៏មានអាយុមិនគួរបើនឹងទទួលយកចីវរពីដៃនាងភិក្ខុនីសោះ ។ ទើបភិក្ខុទាំងនោះ ក្រាបទូលសេចក្ដីនុ៎ះ ដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលឧទាយិ បានឮថា អ្នកឯងបានទទួលចីវរពីដៃនាងភិក្ខុនី មែនឬ ។ ឧទាយិភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មែន ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរថា ម្នាលឧទាយិ នាងភិក្ខុនីនោះ ត្រូវជាញាតិនឹងអ្នកឯង ឬមិនមែនជាញាតិទេ ។ ឧទាយិក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស (នាងភិក្ខុនីនោះ) មិនមែនជាញាតិទេ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលមោឃបុរស បុរសដែលមិនមែនជាញាតិ មិនស្គាល់អំពើគួរ ឬមិនគួរ ល្អិតល្អ ឬមិនល្អិតល្អ របស់ស្ត្រីដែលមិនមែនជាញាតិ (នោះ) ទេ ម្នាលមោឃបុរស អ្នកឯង ហេតុអ្វី ក៏ទទួលយកចីវរអំពីដៃនាងភិក្ខុនីដែលមិនមែនជាញាតិ (ដូច្នេះ) ម្នាលមោឃ-បុរស អំពើដែលអ្នកឯងធ្វើនេះ នឹងបានដឹកនាំមនុស្សដែលមិនទាន់ជ្រះថ្លា

វា បសាខាយ បសង្ខានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ហត្ថតោ ចីវរំ បដិគ្គណ្ហេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៤៨] តេន ខោ បន សមយេន ភិក្ខូ កុក្កុច្ចា-យន្តា ភិក្ខុនីនំ ចារិវដ្ដកចីវរំ[១] នប្បដិគ្គណ្ហន្តិ ។ ភិក្ខុនិយោ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម អយ្យា អម្ហាកំ ចារិវដ្ដកចីវរំ[២] នប្បដិគ្គណ្ហិស្សន្តីតិ[៣] ។ អស្សោសុំ ខោ ភិក្ខូ តាសំ ភិក្ខុនីនំ ឧជ្ឈាយន្តីនំ ខីយន្តីនំ វិចាចេន្តីនំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ បញ្ចន្នំ ចារិវដ្ដកំ[៤] បដិគ្គហេតុំ ភិក្ខុស្ស ភិក្ខុនិយា សិក្ខមានាយ សាមណេរស្ស

---

១-២ ឱ. ម. បារិវត្តកចីវរំ ។ ៣ ឱ. ន បដិគ្គហេស្សន្តីតិ ។ ម. នប្បដិគ្គហេស្សន្តីតិ ។ ៤ ឱ. ម. បារិវត្តកំ ។ បារិវដ្តកចីវរន្តិបិ បាឋោ ។

ឲ្យបានជ្រះថ្លាឡើង ឬមនុស្សដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ទទួលយកចីវរអំពីដៃនាងភិក្ខុនីដែលមិនមែនជាញាតិ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ ។ សិក្ខា-បទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៤៨] សម័យនោះឯង មានពួកភិក្ខុសង្ស័យ មិនហ៊ានទទួលយកចីវរដែលត្រូវការផ្លាស់ប្តូរ របស់នាងភិក្ខុនីទាំងឡាយ ។ នាងភិក្ខុនីទាំងឡាយ ក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ មិនគួរបើនឹងមិនទទួលយកចីវរ ដែលត្រូវការផ្លាស់ប្តូររបស់យើងសោះ ។ កាលពួកនាងភិក្ខុនីទាំងនោះ កំពុងលើកទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយ ក៏បានឮច្បាស់ ។ វេលានោះ ភិក្ខុទាំងនោះ បានក្រាបទូលសេចក្តីនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានេះព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យអ្នកទាំងឡាយទទួលយកចីវរ ដែលត្រូវការផ្លាស់ប្តូរគ្នារបស់សហធម្មិកបុគ្គល ៥ ពួកគឺ ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ

សាមណេរិយា អនុជានាមិ ភិក្ខវេ ឥមេសំ បញ្ចន្នំ ចារិវដ្ដកំ[១] បដិគ្គហេតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ហត្ថតោ ចីវរំ បដិគ្គណ្ហេយ្យ អញ្ញត្រ ចារិវដ្ដកា[២] និស្សគ្គិយំ បាចិត្តិយន្តិ ។

[៤៩] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អញ្ញាតិកា នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុគា អសម្ពទ្ធា ។ ភិក្ខុនី នាម ឧភតោសង្ឃេ ឧបសម្បន្នា ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនូបគំ បច្ឆិមំ[៣] ។ អញ្ញត្រ ចារិវដ្ដកាតិ ឋបេត្វា ចារិវដ្ដកំ ។ បដិគ្គណ្ហាតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ

---

១ ឱ. ម. បារិវត្តកំ ។ បារិវដ្ដកចីវរន្តិបិ បាឋោ ។ ២ ឱ. ម. បារិវត្តកា ។ ឯវំ សព្វត្ថ ញាតព្វំ ។
៣ ឱ. វិកប្បនុបគបច្ឆិមំ ។

សាមណេរី ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យអ្នកទាំងឡាយ ទទួលយកចីវរដែលត្រូវការផ្លាស់ប្តូរគ្នា នឹងពួកសហធម្មិកទាំង ៥ នេះ ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ទទួលយកចីវរអំពីដៃនាងភិក្ខុនី ដែលមិនមែនជាញាតិ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា ។

[៤៩] ត្រង់ពាក្យថា ភិក្ខុណាមួយ (ត្រង់បេយ្យាលទាំងពីរ មាន អធិប្បាយក្នុងបឋមបារាជិកសិក្ខាបទរួចហើយ) ។ នាងភិក្ខុនី ដែលឥតមាន ជាប់ទងគន្ធងអំពីចំណែកខាងមាតាក្តី ចំណែកខាងបិតាក្តី ដរាបដល់គូ នៃជីដូនជីតាជាគម្រប់ ៧ ហៅថា មិនមែនជាញាតិ ។ ស្រីដែលបាន ឧបសម្បទា អំពីសំណាក់ឧភតោសង្ឃ ហៅថានាងភិក្ខុនី ។ បណ្តាចីវរ ទាំង ៦ ចីវរណាមួយ ដែលតូចបំផុតគួរល្មមភិក្ខុ នឹងវិកប្បបាន ហៅថា ចីវរ ។ ពាក្យថា វៀរលែងតែផ្លាស់ប្តូរគ្នា សេចក្តីថា លើកលែង តែចីវរដែលផ្លាស់ប្តូរគ្នា ។ ភិក្ខុទទួលយកចីវរ ត្រូវអាបត្តិទុក្កដ ក្នុង ប្រយោគដែលទទួល ចីវរនោះ ជានិស្សគ្គិយ ក្នុងខណៈដែលបានមក ភិក្ខុត្រូវលះចីវរនោះដល់ជំនុំសង្ឃ ឬគណៈ ឬបុគ្គល ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ត្រូវលះចីវរយ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន

ចីវរំ អញ្ញាតិកាយ ភិក្ខុនិយា ហត្ថតោ បដិគ្គហិតំ អញ្ញត្រ ចារិវដ្ដកា និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[៥០] អញ្ញាតិកាយ អញ្ញាតិកសញ្ញី ហត្ថតោ(១) ចីវរំ បដិគ្គណ្ហាតិ អញ្ញត្រ ចារិវដ្ដកា និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញាតិកាយ វេមតិកោ ហត្ថតោ(២) ចីវរំ បដិគ្គណ្ហាតិ អញ្ញត្រ ចារិវដ្ដកា និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញាតិកាយ ញាតិកសញ្ញី ហត្ថតោ(៣) ចីវរំ បដិគ្គណ្ហាតិ អញ្ញត្រ ចារិវដ្ដកា និស្សគ្គិយំ ចាចិត្តិយំ ។

[៥១] ឯកតោ ឧបសម្បន្នាយ ហត្ថតោ ចីវរំ បដិគ្គណ្ហាតិ អញ្ញត្រ ចារិវដ្ដកា អាបត្តិ ទុក្កដស្ស ។ ញាតិកាយ អញ្ញាតិកសញ្ញី អាបត្តិ ទុក្កដស្ស ។ ញាតិកាយ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ញាតិកាយ ញាតិកសញ្ញី អនាបត្តិ ។

---

១-២-៣ ឱ. ម. បោត្ថកេសុ ន ហោតិ ។

ចីវរនេះដែលខ្ញុំបានទទួលយកអំពីដៃនាងភិក្ខុនី ដែលមិនមែនជាញាតិ ជានិស្សគ្គិយហើយ វៀរលែងតែផ្លាស់ប្តូរគ្នា ឥឡូវ ខ្ញុំសូមលះចីវរនេះដល់ជំនុំសង្ឃ ។ (ត្រង់បេយ្យាលទាំងបី មានអធិប្បាយ ត្រង់សិក្ខាបទទី ១ ក្នុងវគ្គជាមួយគ្នានេះរួចហើយ) ។

[៨០] នាងភិក្ខុនី មិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ទទួលយកចីវរអំពីដៃ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា ។ នាងភិក្ខុនី មិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ទទួលយកចីវរអំពីដៃ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ ទទួលចីវរអំពីដៃ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា ។

[៨១] ភិក្ខុទទួលយកចីវរ អំពីដៃនាងភិក្ខុនី ដែលបានឧបសម្បទាអំពីសំណាក់ឯកតោសង្ឃ (គឺអំពីចំណែកខាងភិក្ខុនីសង្ឃតែម្យ៉ាង) ត្រូវអាបត្តិទុក្កដ វៀរលែងតែផ្លាស់ប្តូរគ្នា ។ នាងភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ ។ នាងភិក្ខុនីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ នាងភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ មិនត្រូវអាបត្តិឡើយ ។

៤៧

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស បញ្ចមសិក្ខាបទស្ស អនាបត្តិវារោ

[៨២] អនាបត្តិ ញាតិកាយ ចារិវជ្ជកាំ បរិត្តេន វា វិបុលំ វិបុលេន វា បរិត្តំ ភិក្ខុ វិស្សាសំ គណ្ហាតិ តាវកាលិកំ គណ្ហាតិ ចីវរំ បបេត្វា អញ្ញំ បរិក្ខារំ គណ្ហាតិ សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។

និស្សគ្គិយកណ្ឌ ចីវរវគ្គ សិក្ខាបទទី ៥ វារៈដែលមិនត្រូវអាបត្តិ

[៤២] *អាបត្តិមិនមានដល់ភិក្ខុ ក្នុងសិក្ខាបទនេះ មាន ៨ យ៉ាង គឺ ភិក្ខុទទួលយកចីវរអំពីដៃនាងភិក្ខុនីដែលជាញាតិ ១ ភិក្ខុទទួលយកចីវរដោយការផ្លាស់ប្តូរគ្នា ១ ភិក្ខុទទួលយកចីវរមានតម្លៃច្រើន ដោយចីវរមានតម្លៃតិច ឬភិក្ខុទទួលយកចីវរមានតម្លៃតិច ដោយចីវរមានតម្លៃច្រើន ១ ភិក្ខុយកចីវរដោយសេចក្តីស្និទ្ធស្នាល គឺយកដោយអាងសេចក្តីទុកចិត្តគ្នា ១ ភិក្ខុយកចីវរជារបស់ខ្ចីគ្នា ១ ភិក្ខុទទួលយកគ្រឿងបរិក្ខារឯទៀតរបស់សិក្ខមានានិងសាមណេរី លើកលែងតែចីវរចេញ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។*

សិក្ខាបទទី ៥ ចប់ ។

# ឆដ្ឋសិក្ខាបទំ

[៤៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ បដ្ឋោ ហោតិ ធម្មឹ កថំ កាតុំ ។ អថខោ អញ្ញតរោ សេដ្ឋិបុត្តោ យេនាយស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ សេដ្ឋិបុត្តំ អាយស្មា ឧបនន្ទោ សក្យបុត្តោ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ សោ សេដ្ឋិបុត្តោ អាយស្មតា ឧបនន្ទេន សក្យបុត្តេន ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច វទេយ្យាថ ភន្តេ យេន អត្ថោ បដិពលា មយំ អយ្យស្ស ទាតុំ យទិទំ

# សិក្ខាបទទី ៦

[៥៣] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក៏សម័យនោះឯង ភិក្ខុឈ្មោះឧបនន្ទដ៏មានអាយុជាសក្យបុត្ត ជាអ្នកឈ្លាសវៃក្នុងការសំដែងធម៌ ។ គ្រានោះ កូនសេដ្ឋីម្នាក់មាននាមនិងគោត្រមិនប្រាកដ ចូលទៅឯកន្លែងដែលឧបនន្ទភិក្ខុដ៏មានអាយុជាសក្យបុត្តលោកគង់នៅ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត ហើយអង្គុយក្នុងទីសមគួរ ។ ឧបនន្ទភិក្ខុដ៏មានអាយុជាសក្យបុត្ត បានញុំាងសេដ្ឋិបុត្តនោះដែលអង្គុយក្នុងទីសមគួរ ឲ្យឃើញច្បាស់លាស់ ឲ្យកាន់យកល្អ ឲ្យកើតសេចក្ដីប្រឹងប្រែងឡើង ឲ្យរីករាយស្រួល ដោយធម្មីកថា ។ គ្រានោះ សេដ្ឋីបុត្តនោះ កាលបើព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត ឲ្យឃើញច្បាស់លាស់ ឲ្យកាន់យកល្អ ឲ្យក្លាហានឡើងព្រម ឲ្យរីករាយស្រួល ដោយធម្មីកថាហើយ ក៏បានបវារណាពាក្យនេះ នឹងឧបនន្ទភិក្ខុដ៏មានអាយុជាសក្យបុត្តថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ត្រូវការដោយបច្ច័យណា ដែលយើងខ្ញុំអាចប្រគេនដល់លោកម្ចាស់បាន

៤៩

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស ឆដ្ឋសិក្ខាបទស្ស សិក្ខាបទនិទានំ

ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារន្តិ[១] ។ សចេ មេ ត្វំ អាវុសោ ញាតុកាមោសិ ឥតោ ឯកំ សាដកំ ទេហីតិ ។ អម្ហាកំ ខោ ភន្តេ កុលបុត្តានំ កិស្មឹ វិយ ឯកសាដកំ គន្តុំ[២] អាគមេថ[៣] ភន្តេ យាវ ឃរំ គច្ឆាមិ ឃរំ គតោ ឥតោ វា ឯកំ សាដកំ បហិណិស្សាមិ ឥតោ វា សុន្ទរតរន្តិ ។ ទុតិយម្បិ ខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ តំ សេដ្ឋិបុត្តំ ឯតទវោច សចេ មេ ត្វំ អាវុសោ ញាតុកាមោសិ ឥតោ ឯកំ សាដកំ ទេហីតិ ។ អម្ហាកំ ខោ ភន្តេ កុលបុត្តានំ កិស្មឹ វិយ ឯកសាដកំ គន្តុំ អាគមេថ ភន្តេ យាវ ឃរំ គច្ឆាមិ ឃរំ គតោ ឥតោ វា ឯកំ សាដកំ បហិណិស្សាមិ ឥតោ វា សុន្ទរតរន្តិ ។ តតិយម្បិ ខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ តំ សេដ្ឋិបុត្តំ ឯតទវោច

១ ឱ. ចីវរ . . . បរិក្ខារានន្តិ ។ ២ ទ្វីសុ បុរិមេសុ វារេសុ អយមត្តោ ឱ. ម. បោត្ថកេសុ ន បញ្ញាយតិ តតិយវារេយេវ ទិស្សតិ ។ ៣ ឱ. ម. អាគមេហិ ។

ដូចជាចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យជាភេសជ្ជបរិក្ខារ លោកម្ចាស់ត្រូវប្រាប់បច្ច័យទាំងនោះមកចុះ ។ ព្រះឧបនន្ទថា នែអ្នកដ៏មានអាយុ បើអ្នកប្រាថ្នានឹងប្រគេនអាត្មា ចូរអ្នកប្រគេនសាដកមួយ អំពីពួកសាដកដែលអ្នកកំពុងប្រើអស់នេះចុះ ។ សេដ្ឋិបុត្តនិយាយថា ទានប្រោសយើងខ្ញុំជាកូនអ្នកមានត្រកូល នឹងមានតែសាដកមួយដើរទៅហាក់ដូចជាមិនសម (មុខគួរឲ្យអៀនខ្មាស) ទានប្រោស សូមលោកម្ចាស់បង្អង់ចាំសិន ទំរាំខ្ញុំទៅផ្ទះ ខ្ញុំដល់ទៅផ្ទះហើយនឹងបញ្ជូននូវសាដកមួយ អំពីពួកសាដកដែលខ្ញុំកំពុងប្រើអស់នេះ ឬសាដកដែលល្អគ្រាន់ជាងសាដកអស់នេះ មកប្រគេនលោកម្ចាស់ ។ ឧបនន្ទភិក្ខុដ៏មានអាយុជាសក្យបុត្ត បាននិយាយពាក្យនេះនឹងសេដ្ឋិ-បុត្តនោះអស់វារៈពីរដងថា នែអ្នកដ៏មានអាយុ បើអ្នកមានប្រាថ្នានឹងប្រគេនអាត្មា ចូរអ្នកប្រគេនសាដកមួយ អំពីពួកសាដកដែលអ្នកកំពុងប្រើអស់នេះចុះ ។ សេដ្ឋិបុត្តនិយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំជាកុលបុត្តមានតែសាដកមួយដើរទៅ ហាក់ដូចជាមិនសម (គួរឲ្យអៀនខ្លួនណាស់) ទានប្រោសលោកម្ចាស់សូមបង្អង់ចាំសិន ទំរាំខ្ញុំទៅផ្ទះ ខ្ញុំដល់ទៅផ្ទះហើយនឹងបញ្ជូនសាដកមួយ អំពីសាដកអស់នេះ ឬសាដកដែលល្អគ្រាន់បើជាងសាដកអស់នេះ មកប្រគេនលោកម្ចាស់ ។ ឧបនន្ទភិក្ខុដ៏មានអាយុ ជាសក្យបុត្ត បានពោលពាក្យនេះនឹងសេដ្ឋិបុត្តនោះអស់វារៈបីដងថា

សចេ មេ ត្វំ អាវុសោ ទាតុកាមោសិ ឥតោ ឯកំ សាដកំ ទេហីតិ ។ អម្ហាកំ ខោ ភន្តេ កុលបុត្តានំ កិស្មឹ វិយ ឯកសាដកំ គន្តុំ អាគមេថ ភន្តេ យាវ ឃរំ គច្ឆាមិ ឃរំ គតោ ឥតោ វា ឯកំ សាដកំ បហិណិស្សាមិ ឥតោ វា សុន្ទរតរន្តិ ។ កឹ បន តយា អាវុសោ អទាតុកាមេន បវារិតេន យំ ត្វំ បវារេត្វា ន ទេសីតិ ។ អថខោ សោ សេដ្ឋិបុត្តោ អាយស្មតា ឧបនន្ទេន សក្យបុត្តេន និប្បីឡិយមានោ ឯកំ សាដកំ ទត្វា អគមាសិ ។ មនុស្សា តំ សេដ្ឋិបុត្តំ បស្សិត្វា ឯតទវោចុំ កិស្ស ត្វំ អយ្យ[១] ឯកសាដកោ អាគច្ឆសីតិ ។ អថខោ សោ សេដ្ឋិបុត្តោ តេសំ មនុស្សានំ ឯតមត្ថំ អារោចេសិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ មហិច្ឆា ឥមេ សមណា សក្យបុត្តិយា អសន្តុដ្ឋា

១ ឱ. ម. អយ្យោ ។

នៃអ្នកដ៏មានអាយុ បើអ្នកចង់ប្រគេនអាត្មា ចូរអ្នកប្រគេនសាដកមួយ អំពីសាដកអស់នេះចុះ ។ សេដ្ឋិបុត្តនិយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំជាកុលបុត្ត មានសាដកតែមួយដើរទៅ ហាក់ដូចជាមិនសម ទានប្រោស លោកម្ចាស់សូមបង្អង់ចាំសិន ទំរាំខ្ញុំទៅផ្ទះ ខ្ញុំទៅដល់ផ្ទះហើយ នឹងបញ្ជូនសាដកមួយ អំពីសាដកដែលខ្ញុំកំពុងប្រើអស់នេះ ឬសាដកដែលល្អគ្រាន់បើជាងសាដកអស់នេះ មកប្រគេនលោកម្ចាស់ ។ ឧបនន្ទភិក្ខុនិយាយថា នៃអ្នកដ៏មានអាយុ អាត្មាមានប្រយោជន៍អ្វី ដោយអ្នកដែលមិនចង់ប្រគេនសោះហើយបវារណា (ព្រោះ) អ្នកបវារណានូវបច្ច័យណាហើយ មិនឲ្យបច្ច័យនោះ ។ សេដ្ឋិបុត្តនោះ កាលដែលឧបនន្ទភិក្ខុដ៏មានអាយុ ជាសក្យបុត្តបង្ខិតបង្ខំ (ញយៗ) ក៏ប្រគេនសំពត់សាដកមួយហើយ ទៅក្នុងកាលនោះឯង ។ មនុស្សទាំងឡាយឃើញសេដ្ឋិបុត្តនោះហើយ បាននិយាយពាក្យនេះថា អ្នកម្ចាស់ ព្រោះហេតុអ្វីបានជាអ្នកមានសាដកតែមួយដើរមកដូច្នេះ ។ គ្រានោះ សេដ្ឋិបុត្តបានប្រាប់ដំណើរនោះ ដល់មនុស្សទាំងឡាយនោះ ។ មនុស្សទាំងឡាយ ក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាកូនចៅព្រះពុទ្ធ ជាសក្យបុត្តនេះមានប្រាថ្នាច្រើន ឥតមានសន្តោស សមណៈពួកនេះ

៤១

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស ឆដ្ឋសិក្ខាបទស្ស សិក្ខាបទនិទានំ

នយិមេ[១] សុករា ធម្មនិមន្តនាយ[២] កាតុំ កថំ ហិ នាម សេដ្ឋិបុត្តេន ធម្មនិមន្តនាយ កយិរមានាយ សាដកំ គណ្ហិស្សន្តីតិ[៣] ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា សន្តុដ្ឋា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ សេដ្ឋិបុត្តំ ចីវរំ វិញ្ញាបេស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ត្វំ ឧបនន្ទ សេដ្ឋិបុត្តំ ចីវរំ វិញ្ញាបេសីតិ ។ សច្ចំ ភគវាតិ ។ ញាតកោ តេ ឧបនន្ទ អញ្ញាតកោតិ ។ អញ្ញាតកោ ភគវាតិ ។ អញ្ញាតកោ មោឃបុរិស អញ្ញាតកស្ស ន ជានាតិ បដិរូបំ វា អប្បដិរូបំ វា សន្តំ វា អសន្តំ វា តត្ថ នាម ត្វំ មោឃបុរិស អញ្ញាតកំ សេដ្ឋិបុត្តំ ចីវរំ វិញ្ញាបេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ

១ ឱ. ម. នយិមេវំ ។ ២ ឱ. ម. ធម្មនិមន្តនាបិ ។ ៣ ឱ. ម. គហេស្សន្តីតិ ។

គេមិនងាយនឹងនិមន្តដោយធម៌បានទេ កាលបើសេដ្ឋិបុត្តនិមន្តដោយធម៌ មិនសមបីបើនឹងទទួលយកសាដកសោះ ។ ភិក្ខុទាំងឡាយបានឮពាក្យមនុស្សទាំងនោះ លើកទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាដែលមានប្រាថ្នាតិច ជាអ្នកសន្តោស ។ បេ ។ ភិក្ខុទាំងនោះ ក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទដ៏មានអាយុ ជាសក្យបុត្ត មិនសមបីបើនឹងសុំចីវរពីសេដ្ឋិបុត្តសោះ ។ ទើបភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូលដំណើរនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ ទ្រង់ត្រាស់សួរថា នែឧបនន្ទឮថាអ្នកសុំចីវរពីសេដ្ឋិបុត្ត មែនឬ ។ ព្រះឧបនន្ទទូលថា បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះ ពិតមែន ។ ព្រះអង្គត្រាស់សួរថា នែឧបនន្ទ គេត្រូវជាញាតិរបស់អ្នក ឬមិនមែនជាញាតិទេ ។ ព្រះឧបនន្ទទូលថា បពិត្រព្រះដ៏មានព្រះភាគ គេមិនមែនជាញាតិទេ ។ ទ្រង់ត្រាស់ថា នែមោឃបុរស មនុស្សមិនមែនជាញាតិ មិនដឹងការគួរ ឬមិនគួរ ល្អិតល្អ ឬមិនល្អិតល្អរបស់មនុស្សដែលមិនមែនជាញាតិនឹងគ្នា (នោះ) ទេ នែមោឃបុរស មិនគួរបើអ្នកឯងសុំចីវរពីសេដ្ឋិបុត្តដែលមិនមែនជាញាតិ (ដូច្នោះ) សោះ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លា ដល់មនុស្សដែលនៅមិនទាន់ជ្រះថ្លាទេ មិនមែននាំមនុស្សដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ

ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតកំ គហបតឹ វា គហបតានឹ វា ចីវរំ វិញ្ញាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៥៤] តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ សាកេតា សាវត្ថឹ អទ្ធានមគ្គបដិបន្នា ហោន្តិ ។ អន្តរាមគ្គេ ចោរា និក្ខមិត្វា តេ ភិក្ខូ អច្ឆិន្ទឹសុ ។ អថខោ តេ ភិក្ខូ ភគវតា បដិក្ខិត្តំ អញ្ញាតកំ គហបតឹ វា គហបតានឹ វា ចីវរំ វិញ្ញាបេតុន្តិ កុក្កុច្ចាយន្តា ន វិញ្ញាបេសុំ យថានគ្គា វ សាវត្ថឹ គន្ត្វា ភិក្ខូ អភិវាទេន្តិ ។ ភិក្ខូ ឯវមាហំសុ សុន្ទរា ខោ ឥមេ អាវុសោ អាជីវកា យេ ឥមេ ភិក្ខូ អភិវាទេន្តីតិ ។ តេ ឯវមាហំសុ ន មយំ អាវុសោ អាជីវកា ភិក្ខូ មយន្តិ ។ ភិក្ខូ អាយស្មន្តំ ឧបាលឹ ឯតទវោចុំ ឥង្ឃ អាវុសោ ឧបាលិ ឥមេ អនុយុញ្ជាហីតិ ។ អថខោ តេ ភិក្ខូ អាយស្មតា ឧបាលិនា អនុយុញ្ជិយមានា ឯតមត្ថំ អារោចេសុំ[១] ។

---
១ ឱរោបិយបោត្ថកេ អយមត្ថោ ន ទិស្សតិ ។

គប្បីសំដែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សុំចីវរ ចំពោះគហបតីក្តី គហបតានីក្តី ដែលមិនមែនជាញាតិ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ ។

[៥៤] សម័យនោះឯង ពួកភិក្ខុជាច្រើនចេញ អំពីក្រុងសាកេតដើរតាមផ្លូវឆ្ងាយទៅកាន់ក្រុងសាវត្ថី ។ ពួកចោរចេញមកដណ្តើម (យកបាត្រនិងចីវរ) របស់ភិក្ខុទាំងនោះ ក្នុងពាក់កណ្តាលផ្លូវ ។ លំដាប់នោះភិក្ខុអម្បាលនោះរង្កៀសក្នុងចិត្តថា ការសុំចីវរចំពោះគហបតីក្តី គហបតានីក្តី ដែលមិនមែនជាញាតិ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ហើយមិនហ៊ានសុំចីវរ ក៏ដើរទាំងអាក្រាតផ្ទាំងទៅកាន់ក្រុងសាវត្ថីហើយថ្វាយបង្គំភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយ ក៏ពោលពាក្យយ៉ាងនេះថា នែអាវុសោទាំងឡាយ អាជីវកអស់នេះល្អ ចេះសំពះភិក្ខុទាំងឡាយដែរ ។ ភិក្ខុអាក្រាតទាំងនោះនិយាយថា ម្នាលអាវុសោ យើងមិនមែនជាអាជីវកទេ យើងជាភិក្ខុដែរ ។ ពួកភិក្ខុ ក៏និយាយពាក្យនេះ នឹងព្រះឧបាលិដ៏មានអាយុថា នែឧបាលិដ៏មានអាយុ និមន្តលោកសង្កេតសួរមនុស្សអាក្រាតអស់នេះមើល ។ ភិក្ខុអាក្រាតទាំងឡាយនោះ លុះព្រះឧបាលិដ៏មានអាយុសង្កេតសួរ ក៏បានប្រាប់ដំណើរនុ៎ះ (ដោយសព្វគ្រប់) ។

៤៣

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស ឆដ្ឋសិក្ខាបទស្ស អនុប្បញ្ញត្តិនិទានំ

អថខោ អាយស្មា ឧបាលិ តេ ភិក្ខូ អនុយុញ្ជិត្វា ភិក្ខូ ឯតទវោច ភិក្ខូ ឥមេ អាវុសោ ទេថ តេសំ[១] ចីវរានីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ នគ្គា អាគច្ឆិស្សន្តិ ននុ នាម តិណេន វា បណ្ណេន វា បដិច្ឆាទេត្វា អាគន្តព្វន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អច្ឆិន្នចីវរស្ស វា នដ្ឋចីវរស្ស វា អញ្ញាតកំ គហបតឹ វា គហបតានឹ វា ចីវរំ វិញ្ញាបេតុំ យំ អាវាសំ បឋមំ ឧបគច្ឆតិ សចេ តត្ថ ហោតិ សង្ឃស្ស វិហារចីវរំ វា ឧត្តរត្ថរណំ វា ភុម្មត្ថរណំ វា ភិសិច្ឆវិ វា តំ គហេត្វា បារុបិតុំ តញ្ច[២] ខោ[៣] លភិត្វា

១ ឱ. ម. នេសំ ។ ២-៣ ឱ. ម. បោត្ថកេសុ ន ហោន្តិ ។

និស្សគ្គិយកណ្ឌ ចីវរវគ្គ សិក្ខាបទទី ៦ និទាននៃអនុប្បញ្ញត្តិ

ព្រះឧបាលិដ៏មានអាយុ លុះបានសង្កេតសួរភិក្ខុ (អាក្រាត) ទាំងនោះហើយ ក៏ពោលពាក្យនេះ នឹងភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងនេះជាភិក្ខុហើយ លោកទាំងឡាយ ចូរឲ្យចីវរដល់ភិក្ខុ (អាក្រាត) ទាំងនោះផងចុះ ។ ភិក្ខុទាំងឡាយណា ដែលមានប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏លើកទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុទាំងឡាយមិនសមបីបើនឹងមានខ្លួនអាក្រាតដើរមកសោះ គួរតែភិក្ខុទាំងនោះ បិទបាំង (រាងកាយ) ដោយស្មៅ ឬស្លឹកឈើហើយសឹមមកទៅអេះ ។ ទើបភិក្ខុទាំងឡាយនោះ ក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ក៏ទ្រង់សំដែងធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលចោរដណ្តើមយកចីវរទៅក្តី ដែលមានចីវរបាត់ក្តី សុំចីវរចំពោះគហបតី ឬគហបតានី ដែលមិនមែនជាញាតិបាន ភិក្ខុ (ដែលមានចីវរអន្តរាយ) នោះ ចូលដល់អាវាសណាមុន បើចីវរក្នុងវត្តក្តី សំពត់កម្រាលគ្រែក្តី សំពត់កម្រាលផែនដីក្តី ស្រោមពូកក្តី របស់សង្ឃមានក្នុងអាវាសនោះ ឲ្យយកសំពត់នោះស្លៀកដណ្តប់ដោយគិតថា អញបានសំពត់នោះ (ស្លៀកដណ្តប់សិន)

ឱទហិស្សាមីតិ នោ ចេ ហោតិ សង្ឃស្ស វិហារចីវរំ វា ឧត្តរត្ថរណំ វា ភុម្មត្ថរណំ វា ភិសិច្ឆវិ វា តិណេន វា បណ្ណេន វា បដិច្ឆាទេត្វា អាគន្តព្វំ ន ត្វេវ នគ្គេន អាគន្តព្វំ យោ អាគច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតកំ គហបតឹ វា គហបតានឹ វា ចីវរំ វិញ្ញាបេយ្យ អញ្ញត្រ សមយា និស្សគ្គិយំ បាចិត្តិយំ ។ តត្ថាយំ សមយោ អច្ឆិន្នចីវរោ វា ហោតិ ភិក្ខុ នដ្ឋចីវរោ វា អយំ តត្ថ សមយោតិ ។

[៤៩] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អញ្ញាតកោ នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុគា អសម្ពទ្ធោ ។ គហបតិ នាម យោ កោចិ អគារំ អជ្ឈាវសតិ ។ គហបតានី នាម យា កាចិ អគារំ អជ្ឈាវសតិ ។ ចីវរំ នាម ឆន្នំ

ហើយនឹងទុកវិញ បើចីវរក្នុងវត្តក្តី សំពត់សម្រាប់ក្រាលគ្រែក្តី សំពត់សម្រាប់ក្រាលផែនដីក្តី ស្រោមពូកក្តី របស់សង្ឃមិនមានទេ ភិក្ខុនោះត្រូវបិទបាំង (រាងកាយ) ដោយស្មៅ ឬស្លឹកឈើហើយសឹមមក មិនត្រូវដើរមកទាំងអាក្រាតឡើយ ភិក្ខុឯណាមក (ទាំងអាក្រាត) ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សុំចីវរចំពោះគហបតី ឬគហបតានី ដែលមិនមែនជាញាតិ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺភិក្ខុមានចីវរដែលចោរដណ្តើមយកទៅ ឬភិក្ខុមានចីវរខូច នេះជាសម័យក្នុងសិក្ខាបទនោះ ។

[៥៥] ត្រង់ពាក្យថា ភិក្ខុណាមួយ (ត្រង់បេយ្យាលទាំងពីរ មានអធិប្បាយដូចសេចក្តីក្នុងបឋមបារាជិកសិក្ខាបទ) ។ ជនដែលឥតមានជាប់ទងគន្ធង អំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាទី ៧ ហៅថា មិនមែនជាញាតិ ។ បុរសណាមួយនៅគ្រប់គ្រងផ្ទះ (បុរសនោះ) ហៅថា គហបតី (ប្រុសមេផ្ទះ) ។ ស្រីណាមួយនៅគ្រប់គ្រងផ្ទះ (ស្រីនោះ) ហៅថា គហបតានី (ស្រីមេផ្ទះ) ។ ដែលហៅថាចីវរ (នោះ) គឺបណ្តាចីវរទាំង ៦ យ៉ាង

ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនូបគំ បច្ឆិមំ[១] ។ អញ្ញត្រ សមយាតិ ឋបេត្វា សមយំ ។ អច្ឆិន្នចីវរោ នាម ភិក្ខុស្ស ចីវរំ អច្ឆិន្នំ ហោតិ រាជូហិ វា ចោរេហិ វា ធុត្តេហិ វា យេហិ កេហិចិ វា អច្ឆិន្នំ ហោតិ ។ នដ្ឋចីវរោ នាម ភិក្ខុស្ស ចីវរំ អគ្គិនា វា ទឌ្ឍំ ហោតិ ឧទកេន វា វុឡ្ហំ ហោតិ ឧន្ទូរេហិ វា ឧបចិកាហិ វា ខាយិតំ ហោតិ បរិភោគជិណ្ណំ វា ហោតិ ។ អញ្ញត្រ សមយា វិញ្ញាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ ចីវរំ អញ្ញាតកំ គហបតិកំ អញ្ញត្រ សមយា វិញ្ញាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

---

១ ឱ. វិកប្បនុបគបច្ឆិមំ ។

តាមតែចីវរណាមួយក៏ដោយ ដែលមានខ្នាតបើយ៉ាងតូចណាស់ត្រឹមល្មមវិកប្បបាន ។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកនូវសម័យចេញ ។ ចីវររបស់ភិក្ខុដែលស្តេចទាំងឡាយរឹបយកទៅក្តី ចោរទាំងឡាយដណ្តើមយកទៅក្តី អ្នកលេងទាំងឡាយដណ្តើមយកទៅក្តី អ្នកណាមួយដណ្តើមយកទៅក្តី (ភិក្ខុនោះ) ហៅថា មានចីវរគេដណ្តើមយកហើយ ។ ចីវររបស់ភិក្ខុដែលភ្លើងឆេះក្តី ដែលទឹកបន្សាត់ទៅក្តី ដែលកណ្តុរកាត់ ឬកណ្តៀរកោរកាត់ក្តី ដែលចាស់ព្រោះប្រើប្រាស់ក្តី (ភិក្ខុនោះ) ហៅថា មានចីវរខូចហើយ ។ ឥតមានសម័យទេ ភិក្ខុសុំ (ចីវរ) ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលសុំ ចីវរ (នោះ) ជានិស្សគ្គិយ ក្នុងខណៈដែលបានមក ភិក្ខុត្រូវលះចីវរនោះដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះចីវរយ៉ាងនេះ ។ បេ ។ ថា បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះ ខ្ញុំសុំចំពោះគហបតិមិនមែនជាញាតិ ដោយឥតមានសម័យទេ ជានិស្សគ្គិយហើយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ ។ (ត្រង់បេយ្យាលទាំងបី មានអធិប្បាយក្នុងសិក្ខាបទទី ១ ក្នុងវគ្គជាមួយគ្នានេះរួចហើយ) ។

[៤៦] អញ្ញាតកេ អញ្ញាតកសញ្ញី អញ្ញត្រ ស-សមយា ចីវរំ វិញ្ញាបេតិ និស្សគ្គិយំ បាចត្តិយំ ។ អញ្ញាតកេ វេមតិកោ អញ្ញត្រ សមយា ចីវរំ វិញ្ញាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញាតកេ អញ្ញាតកសញ្ញី អញ្ញត្រ សមយា ចីវរំ វិញ្ញាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ ញាតកេ អញ្ញាតកសញ្ញី អាបត្តិ ទុក្កដស្ស ។ ញាតកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ញាតកេ ញាតកសញ្ញី អនាបត្តិ ។

[៤៧] អនាបត្តិ សមយេ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន ឧម្មត្តកស្ស អាទិ-កម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។

[៩៦] គហបតីមិនមែនញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយសុំចីវរ ដោយឥតមានសម័យទេ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតិមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ហើយសុំចីវរ ដោយឥតមានសម័យទេ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ សុំចីវរ ដោយឥតមានសម័យទេ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីជាញាតិ ភិក្ខុសំគាល់ថា មិនមែនញាតិ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិភិក្ខុដឹងច្បាស់ថា ជាញាតិ មិនមានអាបត្តិឡើយ ។

[៩៧] អាបត្តិមិនមានដល់ភិក្ខុ កាលសុំចីវរក្នុងសម័យគួរ ក្នុងសំណាក់ជនទាំងឡាយជាញាតិ ក្នុងសំណាក់ជនទាំងឡាយ ដែលបវារណាហើយ សុំឲ្យអ្នកដទៃ (ដូរ) ដោយទ្រព្យខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិកៈ ។

សិក្ខាបទទី ៦ ចប់ ។

# សត្តមសិក្ខាបទំ

[៥៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អច្ឆិន្នចីវរកេ ភិក្ខូ ឧបសង្កមិត្វា ឯវំ វទេន្តិ ភគវតា អាវុសោ អនុញ្ញាតំ អច្ឆិន្នចីវរស្ស វា នដ្ឋចីវរស្ស វា អញ្ញាតកំ គហបតឹ វា គហបតានឹ វា ចីវរំ វិញ្ញាបេតុំ វិញ្ញាបេថ អាវុសោ ចីវរន្តិ ។ អលំ អាវុសោ លទ្ធំ អម្ហេហិ ចីវរន្តិ ។ មយំ អាវុសោ អាយស្មន្តានំ អត្ថាយ វិញ្ញាបេមាតិ ។ វិញ្ញាបេថ អាវុសោតិ ។ អថខោ ឆព្វគ្គិយា ភិក្ខូ អញ្ញាតកេ គហបតិកេ ឧបសង្កមិត្វា ឯតទវោចុំ អច្ឆិន្នចីវរកា អាវុសោ ភិក្ខូ អាគតា ទេថ នេសំ ចីវរន្តិ ពហុំ ចីវរំ វិញ្ញាបេសុំ ។ តេន ខោ បន សមយេន

# សិក្ខាបទទី ៧

[៥៨] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯងឆព្វគ្គិយភិក្ខុទាំងឡាយ (ភិក្ខុមានពួក ៦) ចូលទៅរកពួកភិក្ខុដែលមានចីវរចោរដណ្តើមយកទៅ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតដល់ភិក្ខុមានចីវរ ដែលចោរដណ្តើមយកទៅក្តី ដែលមានចីវរវិនាសទៅក្តី ឲ្យសុំចីវរនឹងគហបតី ឬនឹងគហបតានី ដែលមិនមែនជាញាតិបាន ម្នាលអាវុសោ អ្នកទាំងឡាយ ចូរសុំចីវរទៅ ។ ពួកភិក្ខុដែលចោរដណ្តើមយកចីវរនោះឆ្លើយថា ណ្ហើយអាវុសោ យើងបានចីវរហើយ ។ ពួកឆព្វគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ យើងនឹងសុំចីវរឲ្យលោកដ៏មានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាលអាវុសោ អ្នកទាំងឡាយ ចូរសុំចុះ ។ គ្រានោះ ពួកឆព្វគ្គិយ-ភិក្ខុចូលទៅរកពួកគហបតីដែលមិនមែនជាញាតិ ហើយបានពោលពាក្យនេះថា ម្នាលអាវុសោ ភិក្ខុទាំងឡាយ ដែលមានចីវរចោរដណ្តើមយកទៅឥឡូវនេះ លោកនិមន្តមក អ្នកទាំងឡាយ ចូរប្រគេនចីវរដល់លោកទាំងនោះផងចុះ ហើយក៏សុំចីវរមានចំនួនច្រើន ។ ក៏ក្នុងសម័យនោះឯង

៤៨



អញ្ញតរោ បុរិសោ សកាយំ និសិន្នោ អញ្ញតរំ បុរិសំ ឯតទវោច អច្ឆិន្នចីវរកា អយ្យា អាគតា ទេសំ មយា ចីវរំ ទិន្នន្តិ ។ សោបិ ឯវមាហ មយាបិ ទិន្នន្តិ ។ អបរោបិ ឯវមាហ មយាបិ ទិន្នន្តិ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ន មត្តំ ជានិត្វា ពហុំ ចីវរំ វិញ្ញាបេស្សន្តិ ទុស្សវណិជ្ជំ វា សមណា សក្យបុត្តិយា ករិស្សន្តិ បគ្គាហិកសាលំ វា[១] បសារេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា សន្តុដ្ឋា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ន មត្តំ ជានិត្វា ពហុំ ចីវរំ វិញ្ញាបេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ន មត្តំ ជានិត្វា ពហុំ ចីវរំ វិញ្ញាបេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ

១ កត្ថចិ បោត្ថកេ វត្ថសន្និច្ចយំ វា អាបណោ បសារេស្សន្តីតិ បាឋោ ទិស្សតិ ។

មានបុរសម្នាក់អង្គុយក្នុងរោងសម្រាប់ប្រជុំ បានពោលពាក្យនេះនឹងបុរសម្នាក់ថា លោកម្ចាស់ទាំងឡាយ ដែលមានចីវរចោរដណ្តើមយកទៅ ឥឡូវលោកនិមន្តមក ខ្ញុំបានប្រគេនចីវរដល់លោកម្ចាស់ទាំងនោះហើយ ។ បុរសនោះឯងពោលយ៉ាងនេះថា ខ្ញុំក៏បានប្រគេនចីវរដែរ ។ បុរសឯទៀតនិយាយយ៉ាងនេះថា ខ្ញុំក៏បានប្រគេនដែរ ។ ជនទាំងឡាយអម្បាលនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យ-បុត្ត មិនសមបើនឹងមិនដឹងប្រមាណហើយសុំចីវរមានចំនួនច្រើន (យ៉ាងនេះសោះ) ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្តនឹងធ្វើជំនួញសំពត់ ឬថានឹងតាំងរានផ្សារលក់សំពត់ (ទេដឹង) ។ ពួកភិក្ខុបានឮពាក្យមនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានប្រាថ្នាតិច ជាអ្នកសន្តោស ។ បេ ។ ភិក្ខុអម្បាលនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយមិនសមបើនឹងមិនដឹងប្រមាណហើយសុំចីវរមានចំនួនច្រើន (យ៉ាងនេះ) សោះ ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលដំណើរនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ មិនដឹងប្រមាណហើយសុំចីវរមានចំនួនច្រើន មែនឬ ។ បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា

៤៩

## និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស សត្តមសិក្ខាបទស្ស បញ្ញត្តិ

ណាម តុម្ហេ មោឃបុរិសា ន មត្តំ ជានិត្វា ពហុំ ចីវរំ[១] វិញ្ញាបេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ តញ្ចេ អញ្ញាតកោ គហបតិ វា គហបតានី វា ពហូហិ ចីវរេហិ អភិហដ្ឋុំ បវារេយ្យ សន្តរុត្តរបរមន្តេន ភិក្ខុណា តតោ ចីវរំ សាទិតព្វំ តតោ ចេ ឧត្តរឹ សាទិយេយ្យ ណិស្សគ្គិយំ ចាចិត្តិយន្តិ ។

[៤៩] តញ្ចេតិ អច្ឆិន្នចីវរកំ ភិក្ខុំ ។ អញ្ញាតកោ ណាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុគា អសម្ពន្ធោ ។ គហបតិ ណាម យោ កោចិ អគារំ អជ្ឈាវសតិ ។ គហបតានី ណាម យា កាចិ អគារំ អជ្ឈាវសតិ ។ ពហូហិ ចីវរេហីតិ ពហុកេហិ ចីវរេហិ ។

១ កត្ថចិ បោត្ថកេ ពហូនិ ចីវរានីតិ ទិស្សតិ ។

និស្សគ្គិយកណ្ឌ ចីវរវគ្គ សិក្ខាបទទី ៧ សេចក្ដីបញ្ញត្ត

ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនសមបើនឹងមិនដឹងប្រមាណ សុំចីវរមានចំនួនច្រើន នៃមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យកើតសេចក្ដីជ្រះថ្លា ដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាហើយ ឬមិនមែននាំឲ្យរឹងរឹតតែកើតសេចក្ដីជ្រះថ្លា ដល់ជនទាំងឡាយ ដែលជ្រះថ្លាហើយទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា បើគហបតិក្ដី គហបតានីក្ដី បវារណាដល់ភិក្ខុនោះ ដើម្បីឲ្យកាន់យកតាមត្រូវការដោយចីវរដ៏ច្រើន ភិក្ខុនោះ គប្បីត្រេកអរចំពោះចីវរនោះ តែត្រឹមអន្តរវាសក និងឧត្តរាសង្គៈ បើភិក្ខុត្រេកអរឲ្យលើសជាងកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[៥៩] ត្រង់ពាក្យថា ដល់ភិក្ខុនោះ គឺភិក្ខុមានចីវរដែលចោរដណ្ដើមយកទៅ ។ ជនដែលមិនជាប់អំពីចំណែកមាតាក្ដី អំពីចំណែកបិតាក្ដី ដរាបដល់គូនៃជីដូនជីតាជាគម្រប់ ៧ ហៅថា មិនមែនញាតិ ។ មនុស្សប្រុសណាមួយនៅគ្រប់គ្រងផ្ទះ មនុស្សប្រុសនោះ ហៅថា គហបតី ។ មនុស្សស្រីណាមួយនៅគ្រប់គ្រងផ្ទះ មនុស្សស្រីនោះ ហៅថា គហបតានី ។ ពាក្យថា ចីវរច្រើន គឺចីវរមានប្រមាណច្រើន ។

អភិហដ្ឋុំ បវារេយ្យាតិ យាវតកំ ឥច្ឆសិ តាវតកំ គណ្ហាហីតិ ។ សន្តរុត្តរបរមន្តេន ភិក្ខុនា តតោ ចីវរំ សាទិតព្វន្តិ សចេ តីណិ នដ្ឋានិ ហោន្តិ ទ្វេ សាទិតព្វានិ ទ្វេ នដ្ឋានិ ឯកំ សាទិតព្វំ ឯកំ នដ្ឋំ ន[១] សាទិតព្វំ ។ តតោ ចេ ឧត្តរឹ សាទិយេយ្យាតិ តទុត្តរឹ វិញ្ញាបេតិ បយោគេ ទុក្កដំ ។ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ ចីវរំ អញ្ញាតកំ គហបតិកំ[២] តទុត្តរឹ វិញ្ញាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

---

១ ឱ. ម. ន កិញ្ចិ ។ ២ ឥតោ បរំ ឱ. ម. បោត្ថកេសុ ឧបសង្កមិត្វាតិ បាឋោ ទិស្សតិ ។

ពាក្យថា នាំមកបវារណា គឺគ្រហស្ថពោលថា លោកម្ចាស់ត្រូវការចីវរប៉ុន្មាន ចូរទទួលយកប៉ុណ្ណោះចុះ ។ ពាក្យថា ភិក្ខុនោះ គប្បីត្រេកអរនឹងចីវរ ចំពោះចីវរដែលគេនាំមកនោះ កំណត់ត្រឹមអន្តរវាសកនិងឧត្តរាសង្គៈ គឺថា បើចីវរទាំងបីវិនាសទៅហើយ ភិក្ខុគប្បីត្រេកអរត្រឹមតែចីវរពីរ (បើ) ចីវរពីរវិនាសទៅ ភិក្ខុគប្បីត្រេកអរត្រឹមតែចីវរមួយ (បើ) ចីវរវិនាសទៅតែមួយ ភិក្ខុកុំគប្បីត្រេកអរ (នឹងចីវរឯទៀត) ឡើយ ។ ពាក្យថា បើភិក្ខុត្រេកអរឲ្យលើសជាងកំណត់នោះ គឺភិក្ខុសុំចីវរលើសជាងកំណត់នោះ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលសុំ ។ ចីវរដែលបានមក ជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ចីវរនោះ ដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះ ភិក្ខុគប្បីលះបង់យ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះ ខ្ញុំសូមពីគហបតីមិនមែនជាញាតិ ឲ្យលើសពីកំណត់នោះ ជានិស្សគ្គិយ ខ្ញុំសូមលះបង់ចីវរនេះ ដល់សង្ឃ ។ បេ ។ គប្បីឲ្យ ។ បេ ។ គប្បីឲ្យ ។ បេ ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

៦១

## និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស សត្តមសិក្ខាបទស្ស អនាបត្តិវារោ

[៦០] អញ្ញាតកេ អញ្ញាតកសញ្ញី តទុត្តរឹ ចីវរំ វិញ្ញាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញាតកេ វេមតិកោ តទុត្តរឹ ចីវរំ វិញ្ញាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញាតកេ ញាតកសញ្ញី តទុត្តរឹ ចីវរំ វិញ្ញាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ញាតកេ អញ្ញាតកសញ្ញី អាបត្តិ ទុក្កដស្ស ។ ញាតកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ញាតកេ ញាតកសញ្ញី អនាបត្តិ ។

[៦១] អនាបត្តិ សេសកំ អាហរិស្សាមីតិ ហរន្តោ គច្ឆតិ សេសកំ តុយ្ហេវ ហោតូតិ ទេន្តិ ន អច្ឆិន្នការណា ទេន្តិ ន នដ្ឋការណា ទេន្តិ ញាតកានំ បវារិតានំ អត្តនោ ធនេន ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។

និស្សគ្គិយកណ្ឌ ចីវរវគ្គ សិក្ខាបទទី ៧ វារៈដែលមិនត្រូវអាបត្តិ

[៦០] គហបតីមិនមែនជាញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយសូមចីវរឲ្យលើសជាងកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតិមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ហើយសូមចីវរឲ្យលើសពីកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ ហើយសូមចីវរឲ្យលើសពីកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីជាញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ មិនត្រូវអាបត្តិ ។

[៦១] អាបត្តិមិនមាន ដល់ភិក្ខុដែលនាំចីវរទៅ ដោយគិតថា អញនឹងនាំចីវរដែលសល់មក ដល់ភិក្ខុដែលទាយកប្រគេន ដោយពាក្យថា ចីវរដែលសល់ ចូរមានដល់លោកចុះ ដល់ភិក្ខុដែលទាយកប្រគេន ដោយឥតមានហេតុគឺចោរដណ្តើមយកចីវរ ដល់ភិក្ខុដែលទាយកប្រគេន ដោយឥតមានហេតុគឺចីវរបាត់ ដល់ភិក្ខុត្រេកអរនឹងចីវររបស់ញាតិទាំងឡាយ ដល់ភិក្ខុត្រេកអរនឹងចីវររបស់ជនដែលគេបវារណាឲ្យ ដល់ភិក្ខុត្រេកអរនឹងចីវរដែលបានដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

# អដ្ឋមសិក្ខាបទំ

[៦២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ បុរិសោ បជាបតឹ ឯតទវោច អយ្យំ ឧបនន្ទំ ចីវរេន អច្ឆាទេស្សាមីតិ ។ អស្សោសិ ខោ អញ្ញតរោ បិណ្ឌចារិកោ ភិក្ខុ តស្ស បុរិសស្ស ឥមំ វាចំ ភាសមានស្ស ។ អថខោ សោ ភិក្ខុ យេនា-យស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច មហាបុញ្ញោសិ ត្វំ អាវុសោ ឧបនន្ទ អមុកស្មឹ ឱកាសេ អញ្ញតរោ បុរិសោ បជាបតឹ ឯតទវោច អយ្យំ ឧបនន្ទំ ចីវរេន អច្ឆាទេស្សាមីតិ ។ អត្ថាវុសោ មំ សោ ឧបដ្ឋាកោតិ ។ អថខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ យេន សោ បុរិសោ តេនុបសង្កមិ ឧបសង្កមិត្វា តំ បុរិសំ ឯតទវោច សច្ចំ កិរ មំ ត្វំ អាវុសោ ចីវរេន អច្ឆាទេតុកាមោសីតិ ។

# សិក្ខាបទទី ៨

[៦២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏ក្នុងសម័យនោះ បុរសម្នាក់ បាននិយាយពាក្យនេះនឹងប្រពន្ធថា អញនឹងឲ្យលោកម្ចាស់ឧបនន្ទស្លៀកដណ្តប់ចីវរ ។ កាលដែលបុរសនោះ កំពុងនិយាយពាក្យយ៉ាងនេះ ភិក្ខុជាអ្នកប្រព្រឹត្តបិណ្ឌបាត ១ អង្គបានឮ (ពាក្យនោះច្បាស់) ។ ទើបភិក្ខុនោះ ចូលទៅរកព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះ នឹងព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្តថា ម្នាលអាវុសោឧបនន្ទ លោកជាអ្នកមានបុណ្យច្រើន (ព្រោះ) ក្នុងឱកាសឯណោះ មានបុរសម្នាក់ និយាយពាក្យនេះនឹងប្រពន្ធថា អញនឹងឲ្យលោកម្ចាស់ឧបនន្ទស្លៀកដណ្តប់ចីវរ ។ ព្រះឧបនន្ទនិយាយថា ម្នាលអាវុសោ បុរសនោះជាឧបដ្ឋាកខ្ញុំ ។ ព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត ចូលទៅរកបុរសនោះ លុះចូលទៅដល់ហើយបាននិយាយពាក្យនេះនឹងបុរសនោះថា ម្នាលអ្នកដ៏មានអាយុ ឮថាអ្នកមានប្រាថ្នានឹងឲ្យអាត្មាស្លៀកដណ្តប់ចីវរ មែនឬ ។

អបិ មយ្យ[១] ឯវំ ហោតិ អយ្យំ ឧបនន្ទំ ចីវរេន អច្ឆាទេស្សាមីតិ ។ សចេ ខោ មំ ត្វំ អាវុសោ ចីវរេន អច្ឆាទេតុកាមោសិ ឯវរូបេន ចីវរេន អច្ឆាទេហិ ក្យាហំ តេន អច្ឆន្នោបិ ករិស្សាមិ យាហំ ន បរិភុញ្ជិស្សាមីតិ ។ អថខោ សោ បុរិសោ ឧជ្ឈាយតិ ខីយតិ វិចាចេតិ មហិច្ឆា ឥមេ សមណា សក្យបត្តិយា អសន្តុដ្ឋា នយិមេ សុករា ចីវរេន អច្ឆាទេតុំ កថំ ហិ នាម អយ្យោ ឧបនន្ទោ មយា បុព្វេ អប្បវារិតោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជិស្សតីតិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស បុរិសស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិចាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា សន្តុដ្ឋា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ បុព្វេ អប្បវារិតោ គហបតិកំ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ត្វំ ឧបនន្ទ បុព្វេ អប្បវារិតោ គហបតិកំ

១ ឱ. ម. មេយ្យ ។ មេ អយ្យ ឥតិ ទ្វីសុបិ វិកប្បេសុ បទច្ឆេទោ ។

បុរសនោះនិយាយថា មែន លោកម្ចាស់ ខ្ញុំគិតយ៉ាងនេះថា អញនឹងឲ្យលោកម្ចាស់ឧបនន្ទស្លៀកដណ្ដប់ចីវរ ។ ព្រះឧបនន្ទនិយាយថា ម្នាលអាវុសោ បើអ្នកមានប្រាថ្នាឲ្យអាត្មាស្លៀកដណ្ដប់ចីវរ ចូរឲ្យអាត្មាស្លៀកដណ្ដប់ចីវរបែបយ៉ាងនេះចុះ (ព្រោះថា) បើអាត្មាមិនប្រើប្រាស់នូវចីវរណា អាត្មានឹងធ្វើខ្លួនឲ្យជាអ្នកស្លៀកដណ្ដប់នូវចីវរនោះ ដូចម្ដេចបាន ។ ឯបុរសនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្តអស់នេះ មានសេចក្ដីប្រាថ្នាច្រើន មិនមានសន្ដោស ពួកសមណៈអស់នេះ ទាយកមិនងាយនឹងឲ្យស្លៀកដណ្ដប់ចីវរទេ មិនសមបើលោកម្ចាស់ឧបនន្ទ ដែលអញមិនទាន់បវារណាមុន ហើយមកកំណត់ចីវរ (យ៉ាងនេះ) ឡើយ ។ ភិក្ខុទាំងឡាយ បានឮពាក្យបុរសនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុទាំងឡាយណា មានប្រាថ្នាតិច ជាអ្នកសន្ដោស ។ បេ ។ ភិក្ខុអម្បាលនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ ព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត គេមិនទាន់បវារណាមុន ហើយចូលទៅរកគហបតី ហើយកំណត់ចីវរ (យ៉ាងនេះ) ទេ ។ គ្រានោះ ភិក្ខុអម្បាលនោះ ក្រាបទូលសេចក្ដីនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯង គេមិនបានបវារណាមុន ហើយចូលទៅរកគហបតី

ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជសីតិ ។ សច្ចំ ភគវាតិ ។ ញាតកោ តេ ឧបនន្ទ អញ្ញាតកោតិ ។ អញ្ញាតកោ ភគវាតិ ។ អញ្ញាតកោ មោឃបុរិស អញ្ញាតកស្ស ន ជានាតិ បដិរូបំ វា អប្បដិរូបំ វា សន្តំ វា អសន្តំ វា តត្ថ នាម[១] ត្វំ មោឃបុរិស បុព្វេ អប្បវារិតោ អញ្ញាតកំ គហបតិកំ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ភិក្ខុំ បនេវ ឧទ្ទិស្ស អញ្ញាតកស្ស គហបតិស្ស វា គហបតានិយា វា ចីវរចេតាបនំ[២] ឧបក្ខដំ ហោតិ ឥមិនា ចីវរចេតាបនេន ចីវរំ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុំ ចីវរេន អច្ឆាទេស្សាមីតិ ។ តត្រ ចេ សោ ភិក្ខុ

១ កត្ថចិ បោត្ថកេ កថញ្ហិ នាម ត្វំ មោឃបុរិសាតិ ទិស្សតិ ។ ២ ចីវរំ ចេតាបេន្តិ បរិវត្តេន្តិ ឯតេន ចីវរមូលេនាតិ ចីវរចេតាបន្នំ ។ យទាទិនា សុត្តេន នាគមោតិ គន្ថិយំ វុត្តំ ។ តស្មា យេភុយ្យេន ចីវរចេតាបន្នន្តិ បឋន្តិ ។ តំ បមាណំ ន ហោតិ ទ្វេភាវស្ស ការណាភាវតោ ។

ហើយកំណត់ចីវរ មែនឬ ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការណ៍នោះ ពិតមែន ។ ម្នាលឧបនន្ទ គ្រហស្ថនោះជាញាតិរបស់អ្នក ឬមិនមែនជាញាតិទេ ។ បពិត្រព្រះដ៏មានព្រះភាគ គ្រហស្ថនោះ មិនមែនជាញាតិទេ ។ ទ្រង់ត្រាស់ថា ម្នាលមោឃបុរស ជនមិនមែនជាញាតិរមែងមិនដឹងការសមគួរក្តី មិនសមគួរក្តី ការល្អិតល្អក្តី មិនល្អិតល្អក្តី របស់ជនដែលមិនមែនជាញាតិទេ ម្នាលមោឃបុរស អ្នកឯងដែលគេមិនបានបវារណាមុន ហើយចូលទៅរកគហបតី មិនមែនជាញាតិហើយកំណត់ចីវរដូចម្តេចបាន ម្នាលមោឃបុរសអំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ឬមិនមែននាំឲ្យរឹងរឹតតែកើតសេចក្តីជ្រះថ្លា ដល់ជនទាំងឡាយ ដែលជ្រះថ្លាហើយទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា តម្លៃចីវរដែលគហបតីក្តី គហបតានីក្តី មិនមែនជាញាតិ ចំពោះភិក្ខុហើយតាំងទុកថា ខ្ញុំនឹងទិញចីវរដោយតម្លៃចីវរនេះ ហើយនឹងឲ្យភិក្ខុឈ្មោះនេះ ស្លៀកដណ្តប់ចីវរ ។ បើភិក្ខុនោះ

បុព្វេ អប្បវារិតោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ សាធុ វត មំ អាយស្មា ឥមិនា ចីវរចេតាបនេន ឯវរូបំ វា ឯវរូបំ វា ចីវរំ ចេតាបេត្វា អច្ឆាទេហីតិ កល្យាណ-កម្យតំ ឧបាទាយ និស្សគ្គិយំ បាចិត្តិយន្តិ ។

[៦៣] ភិក្ខុំ បនេវ ឧទ្ទិស្សាតិ ភិក្ខុស្សត្ថាយ ភិក្ខុំ អារម្មណំ ករិត្វា ភិក្ខុំ អច្ឆាទេតុកាមោ ។ អញ្ញាតកោ នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុគា អសម្ពទ្ធោ ។ គហបតិ នាម យោ កោចិ អគារំ អជ្ឈាវសតិ ។ គហបតានី នាម យា កាចិ អគារំ អជ្ឈាវសតិ ។ ចីវរចេតាបនំ នាម ហិរញ្ញំ វា សុវណ្ណំ វា មណិ វា មុត្តា វា មសារគល្លំ វា ផលិកោ វា បដកោ វា សុត្តំ វា កប្បាសោ វា[១] ។ ឥមិនា ចីវរចេតាបនេនាតិ បច្ចុបដ្ឋិតេន ។ ចេតាបេត្វាតិ បរិវត្តេត្វា[២] ។ អច្ឆាទេស្សាមីតិ ទស្សាមិ ។ តត្រ ចេ សោ ភិក្ខូតិ យំ ភិក្ខុំ ឧទ្ទិស្ស ចីវរចេតាបនំ

១ ឱ. ម. ចីវរចេតាបនំ នាម ហិរញ្ញំ វា សុវណ្ណំ វា មុត្តា វា មណិ វា បវាឡោ វា ផាលោ វា បដកោ វា សុត្តា វា កប្បាសោ វា ។ ២ ឱ. ម. បរិវត្តេត្វា ។

ដែលគេមិនបានបវារណាមុន ហើយចូលទៅក្នុងទីនោះ ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ ហើយកំណត់ចីវរដោយពាក្យថា ល្អហើយអ្នកដ៏មានអាយុ អ្នកចូរទិញចីវរមានបែបយ៉ាងនេះក្តី ៗ ដោយតម្លៃចីវរនេះ ហើយឲ្យអាត្មាស្លៀកដណ្តប់ចុះ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[៦៣] ត្រង់ពាក្យថា ចំពោះភិក្ខុ គឺដើម្បីប្រយោជន៍ដល់ភិក្ខុ ធ្វើភិក្ខុឲ្យជាអារម្មណ៍ មានប្រាថ្នាឲ្យភិក្ខុស្លៀកដណ្តប់ចីវរ ។ ជនដែលមិនជាប់អំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាទី ៧ ហៅថា មិនមែនជាញាតិ ។ បុរសណាមួយ នៅគ្រប់គ្រងផ្ទះ បុរសនោះហៅថា គហបតិ ។ ស្រីណាមួយ នៅគ្រប់គ្រងផ្ទះ ស្រីនោះហៅថា គហបតានី ។ ប្រាក់ក្តី មាសក្តី កែវមណីក្តី កែវមុក្តាក្តី កែវមក៌តក្តី កែវផលិកក្តី សំពត់ ឬសក្វាតក្តី អំបោះក្តី កប្បាសក្តី ហៅថា តម្លៃចីវរ ។ ពាក្យថា ដោយតម្លៃចីវរនេះ គឺដោយតម្លៃចីវរដែលតាំងឡើងចំពោះ ។ ពាក្យថា ទិញ គឺប្តូរគ្នា ។ ពាក្យថា អញនឹងឲ្យស្លៀកដណ្តប់ គឺថា អញនឹងប្រគេន ។ ពាក្យថា បើភិក្ខុនោះ គឺតម្លៃចីវរដែលទាយកតម្កល់ទុកចំពោះភិក្ខុណា

៦៦



ឧបក្ខដំ ហោតិ សោ ភិក្ខុ ។ បុព្វេ អប្បវារិតោតិ បុព្វេ អវុត្តោ ហោតិ កីទិសេន តេ ភន្តេ ចីវរេន អត្ថោ កីទិសំ តេ ចីវរំ ចេតាបេស្សាមីតិ[១] ។ ឧបសង្កមិត្វាតិ ឃរំ គន្ត្វា យត្ថ កត្ថចិ ឧបសង្កមិត្វា ។ ចីវរេ វិកប្បំ អាបជ្ជេយ្យាតិ អាយតំ វា ហោតុ វិត្ថតំ វា អប្បិតំ វា សណ្ហំ វា ។ ឥមិនា ចីវរចេតាបនេនាតិ បច្ចុបដ្ឋិតេន ។ ឯវរូបំ វា ឯវរូបំ វាតិ អាយតំ វា វិត្ថតំ វា អប្បិតំ វា សណ្ហំ វា ។ ចេតាបេត្វាតិ បរិវត្តេត្វា ។ អច្ឆាទេហីតិ ទជ្ជេហិ ។ កល្យាណកម្យតំ ឧបាទាយាតិ សាធុត្ថិកោ មហគ្ឃត្ថិកោ ។ តស្ស វចនេន អាយតំ វា វិត្ថតំ វា អប្បិតំ វា សណ្ហំ វា ចេតាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ ចីវរំ បុព្វេ អប្បវារិតោ[២] អញ្ញាតកំ គហបតិកំ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបន្នំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

១ ឱ. ម. ចេតាបេមីតិ ។ ២ កត្ថចិ បោត្ថកេ អប្បវារិតន្តិ ទិស្សតិ អយម្បន បាឋោ អប្បវារិតេនាតិ យុត្តតរោ ។

គឺភិក្ខុនោះឯង ។ ពាក្យថា គេមិនបានបវារណាមុន គឺគេមិនទាន់និយាយមុនថា បពិត្រលោកដ៏ចម្រើន លោកត្រូវការដោយចីវរដូចម្តេច ខ្ញុំនឹងទិញចីវរដូចម្តេចប្រគេនលោក ។ ពាក្យថា ចូលទៅ គឺទៅកាន់ផ្ទះ (គេ) ឬចូលទៅរកគេក្នុងទីណាមួយ ។ ពាក្យថា កំណត់ចីវរ គឺចីវរវែងក្តី ធំក្តី សាច់ជិតក្តី សាច់ម៉ត់ក្តី ។ ពាក្យថា ដោយតម្លៃចីវរនេះ គឺដោយតម្លៃចីវរដែលតាំងឡើងចំពោះ ។ ពាក្យថា បែបយ៉ាងនេះក្តី ៗ គឺចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ម៉ត់ក្តី ។ ពាក្យថា ទិញ គឺប្តូរគ្នា ។ ពាក្យថា ចូរឲ្យស្លៀកដណ្តប់ គឺចូរឲ្យ ។ ពាក្យថា ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ គឺជាអ្នកត្រូវការចីវរល្អ ជាអ្នកត្រូវការចីវរមានតម្លៃច្រើន ។ ទាយកទិញចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ម៉ត់ក្តី តាមសំដីភិក្ខុនោះ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើចីវរនោះជានិស្សគ្គិយ ក្នុងខណៈដែលបានមក ភិក្ខុត្រូវលះដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ចីវរភិក្ខុត្រូវលះយ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរខ្ញុំនេះ គេមិនបានបវារណាមុន ខ្ញុំចូលទៅរកគហបតិមិនមែនជាញាតិ ហើយកំណត់ចីវរ ជានិស្សគ្គិយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ ។ បេ ។ សង្ឃគប្បីឲ្យ ។ បេ ។ ភិក្ខុទាំងឡាយគប្បីឲ្យ ។ បេ ។ ខ្ញុំឲ្យចីវរដល់លោកដ៏មានអាយុ ។

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស អដ្ឋមសិក្ខាបទស្ស អនាបត្តិវារោ

[៦៨] អញ្ញាតកេ អញ្ញាតកសញ្ញី បុព្វេ អប្បវារិតោ គហបតិកំ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញាតកេ វេមតិកោ បុព្វេ អប្បវារិតោ គហបតិកំ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញាតកេ ញាតកសញ្ញី បុព្វេ អប្បវារិតោ គហបតិកំ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។ ញាតកេ អញ្ញាតកសញ្ញី អាបត្តិ ទុក្កដស្ស ។ ញាតកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ញាតកេ ញាតកសញ្ញី អនាបត្តិ ។

[៦៩] អនាបត្តិ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន មហគ្ឃំ ចេតាបេតុកាមស្ស អប្បគ្ឃំ ចេតាបេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។

និស្សគ្គិយកណ្ឌ ចីវរវគ្គ សិក្ខាបទទី ៨ វារៈដែលមិនត្រូវអាបត្តិ

[៦៨] គហបតីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនញាតិ គេមិនបានបវារណាមុន ចូលទៅរកគហបតី ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនញាតិ ភិក្ខុមានសេចក្តីសង្ស័យ គេមិនបានបវារណាមុន ចូលទៅរកគហបតី ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនញាតិ ភិក្ខុសំគាល់ថា ជាញាតិ គេមិនបានបវារណាមុន ចូលទៅរកគហបតី ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីជាញាតិ ភិក្ខុសំគាល់ថា មិនមែនញាតិ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ មិនត្រូវអាបត្តិ ។

[៦៩] អាបត្តិមិនមានដល់ភិក្ខុដែលកំណត់ចីវរ ក្នុងសំណាក់ជនជាញាតិ ជនដែលបានបវារណាហើយ ដល់ភិក្ខុដែលកំណត់ចីវរ ដើម្បីប្រយោជន៍ភិក្ខុដទៃ ដល់ភិក្ខុដែលកំណត់ចីវរ ដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុដែលទាយកមានប្រាថ្នានឹងទិញចីវរមានតម្លៃច្រើនប្រគេន ឲ្យទិញចីវរមានតម្លៃតិចវិញ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់ ។

# នវមសិក្ខាបទំ

[៦៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ បុរិសោ អញ្ញតរំ បុរិសំ ឯតទវោច អយ្យំ ឧបនន្ទំ ចីវរេន អច្ឆាទេស្សាមីតិ សោបិ ឯវមាហ អហម្បិ អយ្យំ ឧបនន្ទំ ចីវរេន អច្ឆាទេស្សាមីតិ ។ អស្សោសិ ខោ អញ្ញតរោ បិណ្ឌចារិកោ ភិក្ខុ តេសំ បុរិសានំ ឥមំ កថាសល្លាបំ ។ អថខោ សោ ភិក្ខុ យេនាយស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច មហាបុញ្ញោសិ ត្វំ អាវុសោ ឧបនន្ទ អមុកស្មឹ ឱកាសេ អញ្ញតរោ បុរិសោ អញ្ញតរំ បុរិសំ ឯតទវោច អយ្យំ ឧបនន្ទំ ចីវរេន អច្ឆាទេស្សាមីតិ សោបិ ឯវមាហ អហម្បិ អយ្យំ ឧបនន្ទំ ចីវរេន អច្ឆាទេស្សាមីតិ ។ អត្ថាវុសោ មំ តេ ឧបដ្ឋាកាតិ ។ អថខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ យេន តេ បុរិសា តេនុបសង្កមិ

# សិក្ខាបទទី ៩

[៦៦] សម័យនោះ ព្រះពុទ្ធដ៏មានជោគ ទ្រង់គង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏ក្នុងសម័យនោះឯង បុរសម្នាក់ បាននិយាយពាក្យនេះនឹងបុរសម្នាក់ថា ខ្ញុំនឹងឲ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ចីវរ ។ ឯបុរសនោះ បានពោលយ៉ាងនេះថា ខ្ញុំឯងក៏នឹងឲ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ចីវរដែរ ។ ភិក្ខុ ១ រូបជាអ្នកប្រព្រឹត្តបិណ្ឌបាត បានឮពាក្យចរចាគ្នា នៃបុរសទាំងឡាយនោះ ។ ភិក្ខុនោះ ក៏ចូលទៅរកព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្តថា ម្នាលអាវុសោឧបនន្ទ លោកជាអ្នកមានបុណ្យច្រើន (ព្រោះ) ក្នុងឱកាសឯណោះ មានបុរសម្នាក់ បាននិយាយពាក្យនេះនឹងបុរសម្នាក់ថា ខ្ញុំនឹងឲ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ចីវរ ឯបុរសនោះ ក៏និយាយយ៉ាងនេះថា ខ្ញុំឯង ក៏នឹងឲ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ចីវរដែរ ។ ព្រះឧបនន្ទបាននិយាយថា ម្នាលអាវុសោ បុរសទាំងនោះ ជាឧបដ្ឋាករបស់ខ្ញុំ ។ លំដាប់នោះ ព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្តចូលទៅរកបុរសទាំងនោះ

៦៩

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស នវមសិក្ខាបទស្ស បញ្ញត្តិនិទានំ

ឧបសង្កមិត្វា តេ បុរិសេ ឯតទវោច សច្ចំ កិរ មំ តុម្ហេ អាវុសោ ចីវរេហិ អច្ឆាទេតុកាមត្ថាតិ ។ អបិ នយ្យ[១] ឯវំ ហោតិ អយ្យំ ឧបនន្ទំ ចីវរេហិ អច្ឆាទេស្សាមាតិ ។ សចេ ខោ មំ តុម្ហេ អាវុសោ ចីវរេហិ អច្ឆាទេតុកាមត្ថ ឯវរូបេន ចីវរេន អច្ឆាទេថ ក្យាហំ តេហិ អច្ឆន្នោបិ ករិស្សាមិ យានាហំ ន បរិភុញ្ជិស្សាមីតិ ។ អថខោ តេ បុរិសា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ មហិច្ឆា ឥមេ សមណា សក្យបុត្តិយា អសន្តុដ្ឋា នយិមេ សុករា ចីវរេហិ អច្ឆាទេតុំ កថំ ហិ នាម អយ្យោ ឧបនន្ទោ អម្ហេហិ បុព្វេ អប្បវារិតោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជិស្សតីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ បុរិសានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ បុព្វេ អប្បវារិតោ គហបតិកេ ឧបសង្កមិត្វា

១ នោ អយ្យ ឥតិ បទច្ឆេទោ ។

លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងបុរសទាំងនោះថា ម្នាលអាវុសោ ឮថាអ្នកទាំងឡាយចង់ឲ្យអាត្មាស្សៀកដណ្តប់ចីវរ មែនឬ ។ បុរសទាំងនោះឆ្លើយថា មែនលោកម្ចាស់ យើងទាំងឡាយបានគិតយ៉ាងនេះថា យើងខ្ញុំនឹងឲ្យព្រះឧបនន្ទជាម្ចាស់ស្សៀកដណ្តប់ចីវរទាំងឡាយ ។ ព្រះឧបនន្ទនិយាយថា ម្នាលអាវុសោ បើអ្នកទាំងឡាយ ចង់ឲ្យអាត្មាស្សៀកដណ្តប់ចីវរទាំងឡាយ អ្នកទាំងឡាយ ចូរឲ្យអាត្មាស្សៀកដណ្តប់ដោយចីវរបែបយ៉ាងនេះចុះ បើអាត្មាមិនត្រូវប្រើប្រាស់ចីវរទាំងឡាយណា អាត្មានឹងស្សៀកដណ្តប់នូវចីវរទាំងឡាយនោះ ដូចម្តេចបាន ។ គ្រានោះ បុរសទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយ ជាកូនចៅព្រះពុទ្ធជាសក្យបុត្តនេះ មានប្រាថ្នាច្រើន មិនមានសន្តោស សមណៈទាំងនេះ គេមិនងាយនឹងប្រគេនចីវរទេ មិនសមបីបើព្រះឧបនន្ទជាម្ចាស់ដែលយើងទាំងឡាយ មិនបានបវារណាជាមុន ហើយចូលមកកំណត់ចីវរសោះ ។ ភិក្ខុទាំងឡាយបានឮពាក្យបុរសទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ។ ភិក្ខុទាំងឡាយណាមានប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត ដែលគេឥតបានបវារណាមុន ហើយចូលទៅរកគហបតី

ចីវរេ វិកប្បំ អាបជ្ជិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ត្វំ ឧបនន្ទ បុព្វេ អប្បវារិតោ គហបតិកោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជសីតិ ។ សច្ចំ ភគវាតិ ។ ញាតកា តេ ឧបនន្ទ អញ្ញាតកាតិ ។ អញ្ញាតកា ភគវាតិ ។ អញ្ញាតកោ មោឃបុរិស អញ្ញាតកានំ ន ជានាតិ បដិរូបំ វា អប្បដិរូបំ វា សន្តំ វា អសន្តំ វា តត្ថ នាម ត្វំ មោឃបុរិស បុព្វេ អប្បវារិតោ អញ្ញាតកោ គហបតិកោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ភិក្ខុំ បនេវ ឧទ្ទិស្ស ឧភិន្នំ អញ្ញាតកានំ គហបតីនំ វា គហបតានីនំ វា បច្ចេកចីវរចេតាបនា ឧបក្ខដា ហោន្តិ ឥមេហិ មយំ បច្ចេកចីវរចេតាបនេហិ បច្ចេកចីវរានិ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុំ

ហើយកំណត់ចីវរសោះ ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងគេមិនបានបវារណាជាមុន ហើយចូលទៅរកគហបតិ កំណត់ចីវរ មែនឬ ។ បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះ ពិតមែន ។ ម្នាលឧបនន្ទ ជនទាំងឡាយនោះ ជាញាតិ ឬមិនមែនជាញាតិទេ ។ បពិត្រព្រះដ៏មានព្រះភាគ ជនទាំងនោះ មិនមែនជាញាតិទេ ។ ម្នាលមោឃបុរស ជនដែលមិនមែនជាញាតិ រមែងមិនដឹងការសមគួរ ឬមិនសមគួរ ការល្អិតល្អ ឬមិនល្អិតល្អ របស់ជនទាំងឡាយមិនមែនជាញាតិទេ ម្នាលមោឃបុរស អ្នកឯងគេមិនបានបវារណាជាមុន ហើយចូលទៅរកគហបតិ មិនមែនជាញាតិ កំណត់ចីវរដូចម្តេចបាន ម្នាលមោឃបុរស អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនទាំងឡាយ មិនទាន់ជ្រះថ្លាទេ ឬមិនមែននាំឲ្យរឹងរឹតតែកើតសេចក្តីជ្រះថ្លា ដល់ជនទាំងឡាយដែលជ្រះថ្លាហើយទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា តម្លៃចីវរផ្សេងគ្នាដែលគហបតិក្តី គហបតានីក្តី មិនមែនជាញាតិទាំងពីរនាក់ ចំពោះភិក្ខុ ១ រូប ហើយតម្កល់ទុកថា យើងទាំងឡាយនឹងទិញចីវរទាំងឡាយមួយម្នាក់ ដោយតម្លៃចីវរផ្សេងគ្នាទាំងនេះ ហើយនឹងឲ្យភិក្ខុឈ្មោះនេះ

ចីវរេហិ អច្ឆាទេស្សាមាតិ ។ តត្រ ចេ សោ ភិក្ខុ បុព្វេ អប្បវារិតោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ សាធុ វត មំ អាយស្មន្តោ ឥមេហិ បច្ចេកចីវរចេតាបនេហិ ឯវរូបំ វា ឯវរូបំ វា ចីវរំ ចេតាបេត្វា អច្ឆាទេថ ឧភោ វ សន្តា ឯកេនាតិ កល្យាណកម្យតំ ឧបាទាយ និស្សគ្គិយំ បាចិត្តិយន្តិ ។

[៦៧] ភិក្ខុំ បនេវ ឧទ្ទិស្សាតិ ភិក្ខុស្សត្ថាយ ភិក្ខុំ អារម្មណំ ករិត្វា ភិក្ខុំ អច្ឆាទេតុកាមា ។ ឧភិន្នន្តិ ទ្វិន្នំ ។ អញ្ញាតកា នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុគា អសម្ពទ្ធា ។ គហបតី នាម យេ កេចិ អគារំ អជ្ឈាវសន្តិ ។ គហបតានី នាម[១] យា កាចិ អគារំ អជ្ឈាវសន្តិ ។ ចីវរចេតាបនា នាម ហិរញ្ញា វា សុវណ្ណា វា មណី វា មុត្តា វា មសារគល្វា វា ផលិកា វា បដកា វា សុត្តា វា កប្បាសា វា[២] ។

---

១ ឱ. ម. គហបតានិយោ នាម ។ ២ ឱ. ម. ចីវរចេតាបនា នាម ហិរញ្ញា វា សុវណ្ណា វា មុត្តា វា មណី វា បវាឡា វា ផាលា វា បដកា វា សុត្តា វា កប្បាសា វា ។

ស្មៀកដណ្តប់ចីវរទាំងឡាយ ។ បើភិក្ខុនោះ គេមិនបានបវារណា ជាមុន ហើយចូលទៅក្នុងទីនោះ ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ ហើយ កំណត់ចីវរដោយពាក្យថា ស្រួលហើយ អ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងពីរ ចូររួបរួមជាមួយគ្នា ទិញចីវរបែបយ៉ាងនេះផង ៗ ដោយ តម្លៃចីវរម្នាស់ផ្សេងគ្នាទាំងនេះ ហើយឲ្យអាត្មាស្មៀកដណ្តប់ចុះ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[៦៧] ត្រង់ពាក្យថា ចំពោះភិក្ខុ ១ រូប គឺដើម្បីប្រយោជន៍ដល់ភិក្ខុ ធ្វើភិក្ខុឲ្យជាអារម្មណ៍ មានប្រាថ្នាឲ្យភិក្ខុស្មៀកដណ្តប់ ។ ពាក្យថា ទាំង ពីរនាក់ គឺជនទាំងពីរ ។ ជនទាំងឡាយ មិនបានជាប់អំពីចំណែក ខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាទី ៧ ហៅថា មិនមែនញាតិ ។ ប្រុសទាំងឡាយឯណាមួយ នៅគ្រប់គ្រងផ្ទះ ប្រុសទាំងនោះហៅថា គហបតី ។ ស្រីទាំងឡាយឯណាមួយ នៅ គ្រប់គ្រងផ្ទះ ស្រីទាំងនោះហៅថា គហបតានី ។ ប្រាក់ក្តី មាសក្តី កែវមណីក្តី កែវមុក្តាក្តី កែវមក៌ត ឬកែវពព្រុស ពេជ្រត្បែកថ្មាក្តី កែវ ផលិកក្តី សំពត់ឬសក្វាតក្តី អំបោះក្តី កប្បាសក្តី ហៅថា តម្លៃចីវរ ។

ឥមេហិ ចីវរចេតាបនេហីតិ បច្ចុបដ្ឋិតេហិ ។ ចេតាបេត្វាតិ បរិវត្តេត្វា ។ អច្ឆាទេស្សាមាតិ ទស្សាម ។ តត្រ ចេ សោ ភិក្ខូតិ យំ ភិក្ខុំ ឧទ្ទិស្ស ចីវរចេតាបនា ឧបក្ខដា ហោន្តិ សោ ភិក្ខុ ។ បុព្វេ អប្បវារិតោតិ បុព្វេ អវុត្តោ ហោតិ កីទិសេន តេ ភន្តេ ចីវរេន អត្ថោ កីទិសំ តេ ចីវរំ ចេតាបេស្សាមាតិ[១] ។ ឧប-សង្កមិត្វាតិ ឃរំ គន្ត្វា យត្ថ កត្ថចិ ឧបសង្កមិត្វា ។ ចីវរេ វិកប្បំ អាបជ្ជេយ្យាតិ អាយតំ វា ហោតុ វិត្ថតំ វា អប្បិតំ វា សណ្ហំ វា ។ ឥមេហិ ចីវរចេ-តាបនេហីតិ បច្ចុបដ្ឋិតេហិ ។ ឯវរូបំ វា ឯវរូបំ វាតិ អាយតំ វា វិត្ថតំ វា អប្បិតំ វា សណ្ហំ វា ។ ចេតាបេត្វាតិ បរិវត្តេត្វា ។ អច្ឆាទេថាតិ ទជ្ជេថ ។ ឧភោ វ សន្តា ឯកេនាតិ ទ្វេបិ ឯកេន ។ កល្យាណ-កម្យតំ ឧបាទាយាតិ សាធុត្ថិកោ មហគ្ឃត្ថិកោ ។

១ ឱ. ម. ចេតាបេមាតិ ។

ពាក្យថា ដោយតម្លៃចីវរទាំងឡាយនេះ គឺដោយតម្លៃចីវរ ដែលតម្កល់ក្នុងទីចំពោះមុខ ។ ពាក្យថា ទិញ គឺដូរ ។ ពាក្យថា នឹងឲ្យស្លៀកដណ្តប់ គឺនឹងឲ្យ ។ ពាក្យថា បើភិក្ខុនោះ គឺតម្លៃចីវរដែលទាយកចំពោះភិក្ខុរូបណា ហើយតម្កល់ទុក គឺភិក្ខុរូបនោះឯង ។ ពាក្យថា គេមិនបានបវារណាមុន គឺទាយកមិនបាននិយាយមុនថា ទានប្រោស លោកម្ចាស់ត្រូវការចីវរបែបដូចម្តេច ។ យើងទាំងឡាយ នឹងទិញចីវរបែបដូចម្តេចប្រគេនលោកម្ចាស់ ។ ពាក្យថា ចូរទៅ គឺទៅកាន់ផ្ទះ ឬចូលទៅរកគេក្នុងទីណាមួយ ។ ពាក្យថា កំណត់ចីវរ គឺចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ម៉ត់ក្តី ។ ពាក្យថា ដោយតម្លៃចីវរទាំងនេះ គឺតម្លៃចីវរទាំងឡាយ ដែលតម្កល់ក្នុងទីចំពោះមុខ ។ ពាក្យថា បែបយ៉ាងនេះផង ៗ គឺចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ម៉ត់ក្តី ។ ពាក្យថា ទិញ គឺដូរ ។ ពាក្យថា ចូរឲ្យស្លៀកដណ្តប់ គឺចូរប្រគល់ឲ្យ ។ ពាក្យថា អ្នកទាំងពីរ ចូររួបរួមជាមួយគ្នា គឺអ្នកទាំងពីរ ចូររួបរួមគ្នា ។ ពាក្យថា ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ គឺភិក្ខុមានសេចក្តីត្រូវការដោយចីវរស្អាត ត្រូវការដោយចីវរមានតម្លៃច្រើន ។

៧៣

និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស នវមសិក្ខាបទស្ស អាបត្តិវារោ

តស្ស វចនេន អាយតំ វា វិត្ថតំ វា អប្បិតំ វា សណ្ហំ វា ចេតាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ ចីវរំ បុព្វេ អប្បវារិតោ អញ្ញាត-កោ គហបតិកោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបន្នំ និស្ស-គ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[៦៨] អញ្ញាតកោ អញ្ញាតកសញ្ញី បុព្វេ អប្ប-វារិតោ គហបតិកោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជតិ និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញាតកោ វេមតិកោ បុព្វេ អប្បវារិតោ គហបតិកោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជតិ និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញាតកោ ញាតកសញ្ញី បុព្វេ អប្បវារិតោ គហបតិកោ ឧប-សង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជតិ និស្សគ្គិយំ ចាចិត្តិយំ ។

ទាយកទាំងឡាយទិញចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ល្អិតក្តី តាមពាក្យភិក្ខុនោះ ភិក្ខុនោះ ត្រូវទុក្កដក្នុងប្រយោគដែលប្រើ ចីវរនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះដល់សង្ឃក្តី ដល់គណៈក្តី ដល់បុគ្គលក្តី ។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះភិក្ខុត្រូវលះយ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរខ្ញុំនេះ គេមិនបានបវារណាជាមុន ខ្ញុំចូលទៅរកគហបតិមិនមែនជាញាតិ ហើយកំណត់ចីវរ ជានិស្សគ្គិយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ ។ បេ ។ សង្ឃគប្បីឲ្យ ។ បេ ។ លោកដ៏មានអាយុទាំងឡាយ គប្បីឲ្យ ។ បេ ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[៦៨] គហបតីមិនមែនជាញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ គេមិនបានបវារណាមុន ចូលទៅរកគហបតីទាំងឡាយ ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ គេមិនបានបវារណាមុន ចូលទៅរកគហបតីទាំងឡាយ ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ គេមិនបានបវារណាមុន ហើយចូលទៅរកគហបតីទាំងឡាយ ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ ។

ញាតកេ អញ្ញាតកសញ្ញី អាបត្តិ ទុក្កដស្ស ។ ញាតកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ញាតកេ ញាតកសញ្ញី អនាបត្តិ ។

[៦៩] អនាបត្តិ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន មហគ្ឃំ ចេតាបេតុកាមានំ អប្បគ្ឃំ ចេតាបេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។

គហបតីជាញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ គហបតីជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ មិនជាអាបត្តិ ។

[៦៩] អាបត្តិមិនមានដល់ភិក្ខុដែលកំណត់ចីវរ ក្នុងសំណាក់ជនជាញាតិទាំងឡាយ ដល់ភិក្ខុដែលជនបានបវារណាហើយ ដល់ភិក្ខុដែលកំណត់ចីវរដើម្បីភិក្ខុដទៃ ដល់ភិក្ខុដែលកំណត់ចីវរ ដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុដែលញុំាងទាយកមានប្រាថ្នាទិញចីវរមានតម្លៃច្រើន ឲ្យទិញចីវរមានតម្លៃតិចវិញ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់ ។

# ទសមសិក្ខាបទំ

[៧០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស ឧបដ្ឋាកោ មហាមត្តោ អាយស្មតោ ឧបនន្ទស្ស សក្យ-បុត្តស្ស ទូតេន ចីវរចេតាបនំ ចាហេសិ ឥមិនា ចីវរចេតា-បនេន ចីវរំ ចេតាបេត្វា អយ្យំ ឧបនន្ទំ ចីវរេន អច្ឆាទេហីតិ ។ អថខោ សោ ទូតោ យេនាយស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច ឥទំ ខោ ភន្តេ អាយស្មន្តំ ឧទ្ទិស្ស ចីវរចេតាបនំ អាភតំ បដិគ្គ-ណ្ហាតុ អាយស្មា ចីវរចេតាបនន្តិ ។ ឯវំ វុត្តេ អា-យស្មា ឧបនន្ទោ សក្យបុត្តោ តំ ទូតំ ឯតទវោច ន ខោ មយំ អាវុសោ ចីវរចេតាបនំ បដិគ្គណ្ហាម ចីវរញ្ច ខោ មយំ បដិគ្គណ្ហាម កាលេន កប្បិយន្តិ ។ ឯវំ វុត្តេ សោ ទូតោ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ

# សិក្ខាបទទី ១០

[៧០] សម័យនោះ ព្រះពុទ្ធដ៏មានជោគ ទ្រង់គង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង អាមាត្យធំ ជាឧបដ្ឋាករបស់ព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត បញ្ជូនតម្លៃចីវរទៅដោយបម្រើ ដើម្បីព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត ដោយពាក្យថា អ្នកចូរទិញចីវរដោយតម្លៃចីវរនេះ ហើយចូរឲ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្ដប់ចីវរចុះ ។ ឯបម្រើនោះ ក៏ចូលទៅរកព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្តថា បពិត្រលោកម្ចាស់ដ៏ចម្រើន តម្លៃចីវរនេះ ខ្ញុំនាំមកចំពោះលោកដ៏មានអាយុ សូមលោកដ៏មានអាយុទទួលយកតម្លៃចីវរ (នេះ) ចុះ ។ កាលបើបម្រើនោះ និយាយយ៉ាងនេះហើយ ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ បានពោលពាក្យនេះ នឹងបម្រើនោះថា ម្នាលអាវុសោ យើងទទួលតម្លៃចីវរមិនបានទេ យើងទទួលបានតែចីវរដ៏សមគួរដោយកាលគួរ ។ កាលបើព្រះឧបនន្ទសក្យបុត្តដ៏មានអាយុពោលយ៉ាងនេះហើយ បម្រើនោះបានពោលពាក្យនេះ នឹងព្រះឧបនន្ទ

ឯតទហោច អត្ថិ បនាយស្មតោ កោចិ វេយ្យាវច្ចករោតិ ។ តេន ខោ បន សមយេន អញ្ញតរោ ឧបាសកោ អារាមំ អគមាសិ កេនចិទេវ ករណីយេន ។ អថខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ តំ ទូតំ ឯតទហោច ឯសោ ខោ អាវុសោ ឧបាសកោ ភិក្ខូនំ វេយ្យាវច្ចករោតិ ។ អថខោ សោ ទូតោ តំ ឧបាសកំ សញ្ញាបេត្វា យេនាយស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទហោច យំ ខោ ភន្តេ អាយស្មា វេយ្យាវច្ចករំ និទ្ទិសិ សញ្ញត្តោ សោ មយា ឧបសង្កមតុ អាយស្មា កាលេន ចីវរេន តំ អច្ឆាទេស្សតីតិ[១] ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ តំ ឧបាសកំ ន កិញ្ចិ អវចាសិ ។ ទុតិយម្បិ ខោ សោ មហាមត្តោ អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស សន្តិកេ ទូតំ បាហេសិ

១ ឥតោ បរំ ឱរោបិយបោត្ថកេ តេន ខោ បន សមយេន សោ មហាមត្តោ អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស សន្តិកេ ទូតំ បាហេសិ បរិភុញ្ជតុ អយ្យោ តំ ចីវរំ ឥច្ឆាម មយំ អយ្យេន តំ ចីវរំ បរិភុត្តន្តិ បាលិ បញ្ញាយតិ ។ សព្វត្ថ បន ន ទិស្សតិ ។

សក្យបុត្តដ៏មានអាយុថា អ្នកណាមួយជាវេយ្យាវច្ចករ[១] របស់លោកដ៏មានអាយុ មានដែរឬ ។ សម័យនោះ ឧបាសកម្នាក់ បានទៅកាន់អារាមដោយមានកិច្ចការនីមួយ ។ គ្រានោះ ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ បានពោលពាក្យនេះនឹងបម្រើនោះថា ម្នាលអាវុសោ ឧបាសកនេះឯងជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ ។ ឯបម្រើនោះ ក៏ពន្យល់ឧបាសកនោះ ហើយចូលទៅរកព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងព្រះឧបនន្ទសក្យបុត្តដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន វេយ្យាវច្ចករ ដែលលោកដ៏មានអាយុចង្អុលប្រាប់នោះ ខ្ញុំបានពន្យល់រួចហើយ សូមលោកដ៏មានអាយុ ចូរទៅរកគេចុះ វេយ្យាវច្ចករនោះ នឹងឲ្យលោកម្ចាស់ស្លៀកដណ្តប់ចីវរ ដោយកាលដ៏គួរ ។ សម័យនោះឯង ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ មិនបាននិយាយពាក្យអ្វីនីមួយនឹងឧបាសកឡើយ ។ អាមាត្យធំនោះ បញ្ជូនបម្រើទៅក្នុងសំណាក់ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ អស់វារៈជាគម្រប់ពីរដងថា

---

១ អ្នកទទួលធ្វើការខ្វល់ខ្វាយបម្រើ ។

**៧៧**



បរិភុញ្ជតុ អយ្យោ តំ ចីវរំ ឥច្ឆាម មយំ អយ្យេន តំ ចីវរំ បរិភុត្តន្តិ ។ ទុតិយម្បិ ខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ តំ ឧបាសកំ ន កិញ្ចិ អវចាសិ ។ តតិយម្បិ ខោ សោ មហាមត្តោ អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស សន្តិកេ ទូតំ បាហេសិ បរិភុញ្ជតុ អយ្យោ តំ ចីវរំ ឥច្ឆាម មយំ អយ្យេន តំ ចីវរំ បរិភុត្តន្តិ[១] ។ តេន ខោ បន សមយេន និគមស្ស សមយោ ហោតិ ។ និគមេន ច កតិកា កតា ហោតិ យោ បច្ឆា អាគច្ឆតិ បញ្ញាសម្ពទ្ធោតិ ។ អថខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ យេន សោ ឧបាសកោ តេនុបសង្កមិ ឧបសង្កមិត្វា តំ ឧបាសកំ ឯតទវោច អត្ថោ មេ អាវុសោ ចីវរេនាតិ ។ អជ្ជុណ្ហោ ភន្តេ អាគមេហិ អជ្ជ និគមស្ស សមយោ និគមេន ច កតិកា កតា ហោតិ យោ បច្ឆា អាគច្ឆតិ បញ្ញាសម្ពទ្ធោតិ ។ អជ្ជេវ មេ អាវុសោ ចីវរំ ទេហីតិ ឱវដ្ដិកាយ បរាមសិ ។ អថខោ សោ ឧបាសកោ អាយស្មតា ឧបនន្ទេន

១ កត្ថចិ បោត្ថកេ អយ្យស្ស សកំ ចីវរំ បរិភុញ្ជិតុន្តិ ទិស្សតិ ។

លោកម្ចាស់ ចូរប្រើប្រាស់ចីវរនោះ យើងខ្ញុំ ចង់ឲ្យលោកម្ចាស់ប្រើប្រាស់ចីវរនោះ ។ ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ ក៏មិនបាននិយាយពាក្យអ្វីនីមួយនឹងឧបាសកនោះអស់វារៈពីរដង ។ មហាមាត្យនោះ បញ្ជូនបម្រើទៅក្នុងសំណាក់ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ អស់វារៈបីដងថា លោកម្ចាស់ ចូរប្រើប្រាស់ចីវរនោះ យើងខ្ញុំចង់ឲ្យលោកម្ចាស់ប្រើប្រាស់ចីវរនោះ ។ សម័យនោះឯង ជាសម័យនៃអ្នកនៅក្នុងនិគម ។ ក៏អ្នកនិគមបានធ្វើកតិកា (ប្ដេជ្ញា) គ្នាថា អ្នកណាមកក្រោយគេ ត្រូវលក់អ្នកនោះហាសិបកហាបណៈ ។ លំដាប់នោះ ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុចូលទៅរកឧបាសកនោះ លុះចូលទៅជិតហើយ បានពោលពាក្យនេះនឹងឧបាសកនោះថា ម្នាលអាវុសោ អាត្មាត្រូវការចីវរ ។ ឧបាសកនោះតបថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់សូមបង្អង់ថ្ងៃនេះមួយថ្ងៃសិន (ព្រោះ) ថ្ងៃនេះជាសម័យ (ប្ដេជ្ញាគ្នា) នៃអ្នកនៅក្នុងនិគម អ្នកនិគមធ្វើប្ដេជ្ញាគ្នាថា អ្នកណាមកក្រោយគេ ត្រូវលក់អ្នកនោះ ហាសិបកហាបណៈ ។ ព្រះឧបនន្ទក៏លូកចាប់ថ្នក់ថា ម្នាលអាវុសោ ចូរអ្នកឲ្យចីវរដល់អាត្មា ក្នុងថ្ងៃនេះឯង ។ ឯឧបាសកដែលព្រះឧបនន្ទសក្យបុត្តដ៏មានអាយុជំរឹតទារ

សក្យបុត្តេន និប្បីឡិយមានោ អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស ចីវរំ ចេតាបេត្វា បច្ឆា អគមាសិ ។ មនុស្សា តំ ឧបាសកំ ឯតទវោចុំ កិស្ស ត្វំ អយ្យ[១] បច្ឆា អាគតោ បញ្ញាសំ ជិនោសីតិ ។ អថខោ សោ ឧបាសកោ តេសំ មនុស្សានំ ឯតមត្ថំ អារោចេសិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ មហិច្ឆា ឥមេ សមណា សក្យបុត្តិយា អសន្តុដ្ឋា នយិមេសំ សុករំ វេយ្យាវច្ចំបិ កាតុំ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ ឧបាសកេន អជ្ឈិណ្ណោ ភន្តេ អាគមេហីតិ វុច្ចមានោ នាគមេស្សតីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ ឧបាសកេន អជ្ឈិណ្ណោ ភន្តេ អាគមេហីតិ វុច្ចមានោ នាគមេស្សតីតិ[២] ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ត្វំ ឧបនន្ទ

១ ឱ. ម. អយ្យោ ។ ២ ឱ. ម. នាគមិស្សតីតិ ។

ក៏ទិញចីវរ ប្រគេនឧបនន្ទសក្យបុត្តដ៏មានអាយុ ហើយបានទៅដល់ (និគមនោះ) ជាខាងក្រោយគេ ។ មនុស្សទាំងឡាយ បានពោលពាក្យនេះនឹងឧបាសកនោះថា អ្នកជាម្ចាស់ អ្នកមកក្នុងកាលជាខាងក្រោយគេព្រោះហេតុអ្វី យើងឈ្នះអ្នកហាសិបកហាបណៈហើយ ។ ទើបឧបាសកនោះប្រាប់ដំណើរនុ៎ះ ដល់មនុស្សទាំងអម្បាលនោះ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាកូនចៅព្រះពុទ្ធជាសក្យបុត្តអម្បាលនេះ មានសេចក្តីប្រាថ្នាធំ ឥតមានសន្តោសមិនងាយអ្នកណានឹងធ្វើការខ្វល់ខ្វាយបម្រើ ដល់សមណៈអម្បាលនេះទេព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ កាលបើឧបាសកពោលថា លោកម្ចាស់សូមលោកម្ចាស់បង្អង់ក្នុងថ្ងៃនេះ មួយថ្ងៃសិន មិនគួរបើមិនព្រមបង្អង់ថាំសោះ ។ ភិក្ខុទាំងឡាយ បានឮពាក្យមនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា មានប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ កាលបើឧបាសកនិយាយថា លោកម្ចាស់ សូមលោកម្ចាស់បង្អង់ក្នុងថ្ងៃនេះ មួយថ្ងៃសិន មិនគួរបើមិនព្រមបង្អង់ឲ្យសោះ ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថា

## ៧៩

### និស្សគ្គិយកណ្ឌេ ចីវរវគ្គស្ស ទសមសិក្ខាបទស្ស បញ្ញត្តិ

ឧចាសកេន អជ្ជុណ្ហោ ភន្តេ អាគមេហីតិ វុច្ចមានោ ជាគមេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ ជាម ត្វំ មោឃបុរិស ឧចាសកេន អជ្ជុណ្ហោ ភន្តេ អាគមេហីតិ វុច្ចមានោ ជាគមេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ភិក្ខុំ បនេវ ឧទ្ទិស្ស រាជា វា រាជភោគ្គោ វា ព្រាហ្មណោ វា គហបតិកោ វា ទូតេន ចីវរចេតាបនំ បហិណេយ្យ ឥមិជា ចីវរចេតាបនេន ចីវរំ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុំ ចីវរេន អច្ឆាទេហីតិ ។ សោ ចេ ទូតោ តំ ភិក្ខុំ ឧបសង្កមិត្វា ឯវំ វទេយ្យ ឥទំ ខោ ភន្តេ អាយស្មន្តំ ឧទ្ទិស្ស ចីវរចេតាបនំ អាភតំ បដិគ្គណ្ហាតុ អាយស្មា ចីវរចេតាបនន្តិ ។ តេន ភិក្ខុជា សោ ទូតោ ឯវមស្ស វចនីយោ ន ខោ មយំ អាវុសោ ចីវរចេតាបនំ បដិគ្គណ្ហាម ចីវរញ្ច ខោ មយំ បដិគ្គណ្ហាម កាលេន កប្បិយន្តិ ។ សោ ចេ ទូតោ តំ ភិក្ខុំ ឯវំ វទេយ្យ អត្ថិ

និស្សគ្គិយកណ្ឌ ចីវរវគ្គ សិក្ខាបទទី ១០ សេចក្ដីបញ្ញត្ត

អ្នកឯង កាលឧបាសកពោលថា លោកម្ចាស់ សូមលោកម្ចាស់បង្អង់ក្នុងថ្ងៃនេះ មួយថ្ងៃសិន មិនព្រមបង្អង់ចាំ មែនឬ ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការណ៍នោះ ពិតមែន ។ ព្រះពុទ្ធដ៏មានជោគទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងកាលដែលឧបាសកពោលថា លោកម្ចាស់ សូមលោកបង្អង់ក្នុងថ្ងៃនេះ មួយថ្ងៃសិន មិនសមបើមិនបង្អង់ឲ្យគេទេ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យកើតសេចក្ដីជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ឬមិនមែននាំឲ្យរឹងរឹតតែកើតសេចក្ដីជ្រះថ្លាដល់ជនទាំងឡាយ ដែលជ្រះថ្លាហើយទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ស្ដេចក្ដី រាជអាមាត្យក្ដី ព្រាហ្មណ៍ក្ដី គហបតិក្ដី បញ្ជូនតម្លៃចីវរទៅដោយបម្រើចំពោះភិក្ខុ ១ រូបថា អ្នកឯង ចូរទិញចីវរដោយតម្លៃចីវរនេះ ហើយចូរឲ្យភិក្ខុឈ្មោះនេះស្លៀកដណ្ដប់ចីវរចុះ ។ បើបម្រើនោះចូលទៅរកភិក្ខុនោះ ហើយពោលយ៉ាងនេះថា លោកម្ចាស់ តម្លៃចីវរនេះខ្ញុំនាំមកចំពោះលោកដ៏មានអាយុ លោកដ៏មានអាយុ សូមទទួលយកតម្លៃចីវរចុះ ។ ភិក្ខុនោះ ត្រូវនិយាយពាក្យយ៉ាងនេះនឹងបម្រើនោះថា ម្នាលអាវុសោ យើងទទួលយកតម្លៃចីវរមិនបានទេ យើងទទួលបានតែចីវរសមគួរដោយកាលដ៏គួរ ។ បើបម្រើនោះពោលនឹងភិក្ខុនោះយ៉ាងនេះថា

បជាយស្មតោ កោចិ វេយ្យាវច្ចករោតិ ។ ចីវរត្ថិកេន ភិក្ខុវេ ភិក្ខុនា វេយ្យាវច្ចករោ និទ្ទិសិតព្វោ អារាមិកោ វា ឧបាសកោ វា ឯសោ ខោ អាវុសោ ភិក្ខូនំ វេយ្យាវច្ចករោតិ ។ សោ ចេ ទូតោ តំ វេយ្យាវច្ចករំ សញ្ញាបេត្វា តំ ភិក្ខុំ ឧបសង្កមិត្វា ឯវំ វទេយ្យ យំ ខោ ភន្តេ អាយស្មា វេយ្យាវច្ចករំ និទ្ទិសិ សញ្ញត្តោ សោ មយា ឧបសង្កមតុ អាយស្មា កាលេន ចីវរេន តំ អច្ឆាទេស្សតីតិ ។ ចីវរត្ថិកេន ភិក្ខុវេ ភិក្ខុនា វេយ្យាវច្ចករោ ឧបសង្កមិត្វា ទ្វិត្តិក្ខត្តុំ[១] ចោទេតព្វោ សារេតព្វោ អត្ថោ មេ អាវុសោ ចីវរេនាតិ ។ ទ្វិត្តិក្ខត្តុំ ចោទយមានោ សារយមានោ[២] តំ ចីវរំ អភិនិប្ផាទេយ្យ ឥច្ចេតំ កុសលំ នោ ចេ អភិនិប្ផាទេយ្យ ចតុក្ខត្តុំ បញ្ចក្ខត្តុំ ឆក្ខត្តុបរមំ[៣]

---

១ ទ្វត្តិក្ខត្តុន្តិបិ បឋន្តិ ។ ២ យេភុយ្យេន ចោទយមានោ សារិយមានោតិ បឋន្តិ ។ តំ ន យុជ្ជតិ ។ ន ហិ ឥមេ បាឋា កម្មវាចកា ។ តេ ចេ កម្មវាចកា សិយុំ វេយ្យាវច្ចករោតិ បទំ អភិនិប្ផាទេយ្យាតិ បទេ កត្តា សិយា ។ ឯវំ សន្តេ បាលិយា ឧក្កមោ ភវេយ្យ ។ តតោ បរំ ហិ ភិក្ខុសទ្ទោ អភិនិប្ផាទេយ្យាតិ បទេសុ កត្តា ។ កង្ខាវិតរណិយម្បិ កត្តុភាវេន វណ្ណិតា ។ វិចារេត្វា គហេតព្វំ ។ ៣ ឆក្ខត្តុំបរមន្តិបិ បឋន្តិ ។

អ្នកណាមួយជាវេយ្យាវច្ចករ របស់លោកដ៏មានអាយុ មានដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ គប្បីបង្ហាញវេយ្យាវច្ចករ គឺញោមវត្ត ឬឧបាសកថា ម្នាលអាវុសោ អ្នកនេះឯង ជាវេយ្យាវច្ចករ របស់ភិក្ខុទាំងឡាយ ។ បើបម្រើនោះ ពន្យល់វេយ្យាវច្ចករនោះហើយ ក៏ចូលទៅរកភិក្ខុនោះ ហើយពោលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន លោកដ៏មានអាយុបង្ហាញនូវវេយ្យាវច្ចករណា វេយ្យាវច្ចករនោះ ខ្ញុំព្រះករុណាបានពន្យល់ហើយ សូមលោកដ៏មានអាយុ ចូលទៅរក (គេ) ចុះ គេនឹងឲ្យលោកម្ចាស់ស្លៀកដណ្តប់ចីវរ ដោយកាលដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ គប្បីចូលទៅតឹងទារ ដាស់តឿនវេយ្យាវច្ចករពីរបីលើកថា ម្នាលអាវុសោ អាត្មាត្រូវការចីវរ ។ កាលបើភិក្ខុទៅតឹងទារ ទៅដាស់តឿនអស់ពីរបីលើក ក៏ញុំាងចីវរនោះឲ្យសម្រេចបាន ការនេះជាការល្អ បើញុំាងចីវរនោះ ឲ្យសម្រេចមិនបានទេ ភិក្ខុគប្បីទៅឈរស្ងៀមចំពោះមុខបួនលើក ប្រាំលើក ប្រាំមួយលើក យ៉ាងច្រើន

តុណ្ហីភូតេន ឧទ្ទិស្ស ឋាតព្វំ ចតុក្ខត្តុំ បញ្ចក្ខត្តុំ ឆក្ខត្តុបរមំ តុណ្ហីភូតោ ឧទ្ទិស្ស តិដ្ឋមានោ តំ ចីវរំ អភិនិប្ផាទេយ្យ ឥច្ចេតំ កុសលំ នោ ចេ អភិនិប្ផាទេយ្យ តតោ ចេ ឧត្តរឹ វាយមមានោ តំ ចីវរំ អភិនិប្ផាទេយ្យ និស្សគ្គិយំ បាចិត្តិយំ នោ ចេ អភិនិប្ផាទេយ្យ យតស្ស ចីវរចេតាបន្នំ អាភតំ តត្ថ សាមំ វា គន្តព្វំ ទូតោ វា បាហេតព្វោ យំ ខោ តុម្ហេ អាយស្មន្តោ ភិក្ខុំ ឧទ្ទិស្ស ចីវរចេតាបន្នំ បហិណិត្ថ ន តំ តស្ស ភិក្ខុនោ កញ្ចិ អត្ថំ អនុភោតិ យុញ្ជន្តាយស្មន្តោ សកំ មា វោ សកំ វិនស្សាតិ[១] ។ អយំ តត្ថ សាមីចីតិ ។

[៧១] ភិក្ខុំ បនេវ ឧទ្ទិស្សាតិ ភិក្ខុស្សត្ថាយ ភិក្ខុំ អារម្មណំ ករិត្វា ភិក្ខុំ អច្ឆាទេតុកាមោ ។ រាជា នាម យោ កោចិ រជ្ជំ ការេតិ ។ រាជភោគ្គោ នាម យោ កោចិ រញ្ញោ ភត្តវេតនារហោ[២] ។ ព្រាហ្មណោ នាម ជាតិយា ព្រាហ្មណោ ។ គហបតិកោ នាម ឋបេត្វា រាជានំ រាជភោគ្គំ ព្រាហ្មណំ អវសេសោ គហបតិកោ នាម ។ ចីវរចេតាបន្នំ នាម ហិរញ្ញំ វា

១ វិនស្សីតិបិ បឋន្តិ ។ ២ សព្វត្ថ ភត្តវេតនាហារោតិ ទិស្សតិ ។

កាលបើភិក្ខុឈរស្ងៀមនៅចំពោះមុខបួនលើក ប្រាំលើក ប្រាំមួយលើក យ៉ាងច្រើន ញុំាងចីវរនោះឲ្យសម្រេចបាន ការនេះជាការល្អ បើធ្វើចីវរនោះឲ្យសម្រេចមិនបានទេ ហើយភិក្ខុនោះ ចេះតែព្យាយាមឲ្យលើសអំពីកំណត់នោះទាល់តែបានចីវរនោះមក ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ បើភិក្ខុញុំាងចីវរនោះឲ្យសម្រេចមិនបានទេ បម្រើនោះ នាំតម្លៃចីវរមកដើម្បីភិក្ខុនោះ អំពីសំណាក់អ្នកណា ភិក្ខុគប្បីទៅខ្លួនឯង ឬប្រើបម្រើទៅក្នុងសំណាក់អ្នកនោះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយបញ្ជូនតម្លៃចីវរណា ទៅចំពោះភិក្ខុរូបណា តម្លៃចីវរនោះ មិនសម្រេចប្រយោជន៍បន្តិចបន្តួចដល់ភិក្ខុរូបនោះទេ អ្នកដ៏មានអាយុ ចូរទារយករបស់ខ្លួនវិញចុះ ទ្រព្យរបស់អ្នកទាំងឡាយ ចូរកុំឲ្យវិនាស ការនេះជាសាមីចិកម្ម (សេចក្ដីប្រព្រឹត្តិគួរ) ក្នុងសិក្ខាបទនោះ ។

[៧១] ត្រង់ពាក្យថា ចំពោះភិក្ខុ ១ រូប សេចក្ដីថា ដើម្បីប្រយោជន៍ដល់ភិក្ខុ គឺធ្វើភិក្ខុឲ្យជាអារម្មណ៍ មានប្រាថ្នាឲ្យភិក្ខុស្លៀកដណ្ដប់ចីវរ ។ អ្នកណាមួយ សោយរាជសម្បត្តិ អ្នកនោះឈ្មោះថា ស្ដេច ។ អ្នកណាមួយ គួរទទួលបាយនិងបៀវត្សរ៍របស់ស្ដេច អ្នកនោះឈ្មោះថា រាជអាមាត្យ ។ ជនជាព្រាហ្មណ៍ដោយជាតិ ឈ្មោះថា ព្រាហ្មណ៍ ។ ដែលហៅថា គហបតិ គឺជនដ៏សេស វៀរលែងស្ដេច រាជអាមាត្យនិងព្រាហ្មណ៍ចេញ

សុវណ្ណំ វា មណិ វា មុត្តា វា មសារគល្លំ ផលិកោ វា[1] ។ ឥមិនា ចីវរចេតាបនេនាតិ បច្ចុបដ្ឋិតេន ។ ចេតាបេត្វាតិ បរិវដ្តេត្វា ។ អច្ឆាទេហីតិ ទជ្ជេហិ ។ សោ ចេ ទូតោ តំ ភិក្ខុំ ឧបសង្កមិត្វា ឯវំ វទេយ្យ ឥទំ ខោ ភន្តេ អាយស្មន្តំ ឧទ្ទិស្ស ចីវរចេតាបនំ អាភតំ បដិគ្គណ្ហាតុ អាយស្មា ចីវរចេតាបន្តិ ។ តេន ភិក្ខុនា សោ ទូតោ ឯវមស្ស វចនីយោ ន ខោ មយំ អាវុសោ ចីវរចេតាបនំ បដិគ្គណ្ហាម ចីវរញ្ច ខោ មយំ បដិគ្គណ្ហាម កាលេន កប្បិយន្តិ ។ សោ ចេ ទូតោ តំ ភិក្ខុំ ឯវំ វទេយ្យ អត្ថិ បនាយស្មតោ កោចិ វេយ្យាវច្ចករោតិ ។ ចីវរត្ថិកេន ភិក្ខវេ ភិក្ខុនា វេយ្យាវច្ចករោ និទ្ទិសិតព្វោ អារាមិកោ វា ឧបាសកោ វា ឯសោ ខោ អាវុសោ ភិក្ខូនំ វេយ្យាវច្ចករោតិ ។ ន វត្តព្វោ តស្ស ទេហីតិ វា សោ វា និក្ខិបិស្សតិ សោ វា បរិវដ្តិស្សតិ[2] សោ វា ចេតាបេស្សតីតិ ។ សោ ចេ ទូតោ តំ វេយ្យាវច្ចករំ សញ្ញាបេត្វា តំ ភិក្ខុំ ឧបសង្កមិត្វា

១ ឱ. ម. ចីវរចេតាបនំ នាម ហិរញ្ញំ វា សុវណ្ណំ វា មុត្តា វា មណិ វា ។ ២ សព្វត្ថ បរិវត្តិស្សតីតិ ទិស្សតិ ។

ហៅថា គហបតិ ។ ប្រាក់ក្តី មាសក្តី កែវមណីក្តី កែវមុក្តាក្តី កែវមក៌តក្តី កែវផលិកក្តី ហៅថាថ្លៃចីវរ ។ ពាក្យថា ដោយតម្លៃចីវរនេះ គឺតម្លៃចីវរដែលគេតម្កល់ទុកចំពោះ ។ ពាក្យថា ទិញ គឺដូរ ។ ពាក្យថា ឲ្យស្លៀកដណ្តប់ គឺឲ្យ ។ ថាបើបម្រើនោះ ចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា លោកម្ចាស់ តម្លៃចីវរនេះ ខ្ញុំនាំមកចំពោះលោកដ៏មានអាយុ ។ លោកដ៏មានអាយុ ចូរទទួលយកតម្លៃចីវរចុះ ។ ភិក្ខុនោះ គប្បីនិយាយយ៉ាងនេះនឹងបម្រើនោះថា ម្នាលអាវុសោ យើងទទួលយកតម្លៃចីវរមិនបានទេ យើងទទួលបានតែចីវរសមគួរដោយកាលដ៏គួរ ។ បើបម្រើនោះ និយាយនឹងភិក្ខុនោះយ៉ាងនេះថា អ្នកណាមួយ ជាវេយ្យាវច្ចករ របស់លោកដ៏មានអាយុ មានដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ គប្បីបង្ហាញវេយ្យាវច្ចករ គឺញោមវត្ត ឬឧបាសក (ប្រាប់គេ) ថា ម្នាលអាវុសោ បុគ្គលនេះឯង ជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ ។ មិនគប្បីពោលនឹងបម្រើនោះថា អ្នកចូរឲ្យដល់បុគ្គលនោះក្តី ថា បុគ្គលនោះនឹងទុកដាក់ក្តី ថា បុគ្គលនោះនឹងដូរក្តី ថា បុគ្គលនោះនឹងទិញក្តី ។ បើបម្រើនោះ ពន្យល់វេយ្យាវច្ចករនោះ ហើយចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា

ឯវំ វទេយ្យ យំ ខោ ភន្តេ អាយស្មា វេយ្យាវច្ចករំ និទ្ទិសិ សញ្ញត្តោ សោ មយា ឧបសង្កមតុ អាយស្មា កាលេន ចីវរេន តំ អច្ឆាទេស្សតីតិ ។ ចីវរត្ថិកេន ភិក្ខវេ ភិក្ខុនា វេយ្យាវច្ចករោ ឧបសង្កមិត្វា ទ្វិត្តិក្ខត្តុំ ចោទេតព្វោ សារេតព្វោ អត្ថោ មេ អាវុសោ ចីវរេនាតិ ។ ន វត្តព្វោ ទេហិ មេ ចីវរំ អាហរ មេ ចីវរំ បរិវត្តេហិ[១] មេ ចីវរំ ចេតាបេហិ មេ ចីវរន្តិ ។ ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ ។ សចេ អភិនិប្ផាទេតិ ឥច្ចេតំ កុសលំ នោ ចេ អភិនិប្ផាទេតិ តត្ថ គន្ត្វា តុណ្ហីភូតេន ឧទ្ទិស្ស ឋាតព្វំ ន អាសនេ និសីទិតព្វំ ន អាមិសំ បដិគ្គហេតព្វំ ន ធម្មោ ភាសិតព្វោ ។ កឹការណា អាគតោសីតិ បុច្ឆមានោ[២] ជានាហិ អាវុសោតិ វត្តព្វោ ។ សចេ អាសនេ វា និសីទតិ អាមិសំ វា បដិគ្គណ្ហាតិ ធម្មំ វា ភាសតិ ឋានំ ភញ្ជតិ ។ ទុតិយម្បិ ឋាតព្វំ តតិយម្បិ ឋាតព្វំ ចតុក្ខត្តុំ ចោទេត្វា ចតុក្ខត្តុំ ឋាតព្វំ បញ្ចក្ខត្តុំ ចោទេត្វា ទ្វិក្ខត្តុំ ឋាតព្វំ ឆក្ខត្តុំ

---

១ សព្វត្ថ បរិវត្តេហីតិ ទិស្សតិ ។ ២ សព្វត្ថ បុច្ឆិយមានោតិ ទិស្សតិ ។

បពិត្រលោកដ៏ចម្រើន លោកដ៏មានអាយុ បង្ហាញនូវវេយ្យាវច្ចករណា វេយ្យាវច្ចករនោះ ខ្ញុំបានពន្យល់ហើយ សូមលោកដ៏មានអាយុ ចូរទៅរក (គេ) ចុះ វេយ្យាវច្ចករនោះ នឹងឲ្យលោកស្លៀកដណ្ដប់ចីវរ ដោយកាលគួរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរត្រូវចូលទៅរកវេយ្យាវច្ចករ ហើយដាស់តឿនរំលឹកពីរបីលើកថា ម្នាលអ្នកដ៏មានអាយុ អាត្មាត្រូវការចីវរ ។ មិនគប្បីនិយាយថា អ្នកចូរឲ្យចីវរដល់អាត្មា ចូរនាំចីវរមកឲ្យអាត្មា ចូរដូរចីវរឲ្យអាត្មា ចូរចាត់ចែងចីវរឲ្យអាត្មា ។ ភិក្ខុគប្បីនិយាយនឹងវេយ្យាវច្ចករនោះ អស់វារៈពីរដងផង គប្បីនិយាយអស់វារៈបីដងផង ។ បើភិក្ខុញុំាងចីវរនោះ ឲ្យសម្រេចបាន ការនេះជាការល្អ បើភិក្ខុញុំាងចីវរនោះ ឲ្យសម្រេចមិនបានទេ ភិក្ខុគប្បីទៅក្នុងទីនោះ ហើយឈរនៅស្ងៀមក្នុងទីចំពោះមុខ មិនគប្បីអង្គុយលើអាសនៈ មិនគប្បីទទួលអាមិស មិនគប្បីនិយាយធម៌ ។ កាលបើវេយ្យាវច្ចករនោះ សួរថា លោកមកព្រោះហេតុអ្វី ភិក្ខុគប្បីនិយាយថា ម្នាលអ្នកដ៏មានអាយុ អ្នកចូរដឹងចុះ ។ ថាបើភិក្ខុអង្គុយលើអាសនៈក្តី ទទួលអាមិសក្តី និយាយធម៌ក្តី ឈ្មោះថា កាច់កិរិយាឈរ ។ ភិក្ខុគប្បីឈរអស់វារៈពីរដងផង គប្បីឈរអស់វារៈបីដងផង គប្បីទារបួនដង ហើយឈរបួនដង (បើ) ទារប្រាំដងហើយ គប្បីឈរពីរដង (បើ) ទារប្រាំមួយដងហើយ

ចោទេត្វា ន ហាតព្វំ ។ តតោ ចេ ឧត្តរឹ វាយមមានោ តំ ចីវរំ អភិនិប្ផាទេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិ-តព្វំ ។ បេ ។ ឥទំ មេ ភន្តេ ចីវរំ អតិរេកតិក្ខត្តុំ ចោទនាយ អតិរេកឆក្ខត្តុំ ឋានេន អភិនិប្ផាទិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។ នោ ចេ អភិនិប្ផាទេយ្យ យតស្ស ចីវរ-ចេតាបន្នំ អាភតំ តត្ថ សាមំ វា គន្តព្វំ ទូតោ វា បាហេតព្វោ យំ ខោ តុម្ហេ អាយស្មន្តោ ភិក្ខុំ ឧទ្ទិស្ស ចីវរចេតាបន្នំ បហិណិត្ថ ន តំ តស្ស ភិក្ខុនោ កិញ្ចិ អត្ថំ អនុភោតិ យុញ្ជន្តាយស្មន្តោ សកំ មា វោ សកំ វិនស្សាតិ ។ អយំ តត្ថ សាមីចីតិ អយំ តត្ថ អនុធម្មតា ។

[៧២] អតិរេកតិក្ខត្តុំ ចោទនាយ អតិរេកឆក្ខត្តុំ ឋានេ[១] អតិរេកសញ្ញី អភិនិប្ផាទេតិ និស្សគ្គិយំ

១ សព្វត្ថ ឋានេនាតិ ទិស្សតិ ។

មិនគប្បីឈរ (ទៀត) ទេ ។ កាលបើភិក្ខុព្យាយាមឲ្យលើសពីកំណត់នោះ ឲ្យចីវរនោះសម្រេចបាន ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលព្យាយាម ចីវរដែលបានមកជានិស្សគ្គិយ ចីវរនោះ ភិក្ខុត្រូវលះដល់សង្ឃក្តី ដល់គណៈក្តី ដល់បុគ្គលក្តី ។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះ ភិក្ខុគប្បីលះយ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះ ខ្ញុំឲ្យសម្រេចបានដោយទារលើសពី ៣ ដង ដោយឈរលើសពី ៦ ដង ជានិស្សគ្គិយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ ។ បេ ។ សង្ឃ គប្បីឲ្យ ។ បេ ។ លោកដ៏មានអាយុទាំងឡាយ គប្បីឲ្យ ។ បេ ។ ខ្ញុំឲ្យលោកដ៏មានអាយុ ។ បើភិក្ខុឲ្យចីវរនោះ សម្រេចមិនបានទេ ថ្លៃចីវរដែលគេនាំមក ដើម្បីភិក្ខុនោះអំពីសំណាក់បុគ្គលណា ភិក្ខុគប្បីទៅក្នុងសំណាក់បុគ្គលនោះ ខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយបញ្ជូនតម្លៃចីវរណាទៅ ចំពោះភិក្ខុ តម្លៃចីវរនោះ មិនសម្រេចប្រយោជន៍បន្តិចបន្តួចដល់ភិក្ខុនោះទេ អ្នកដ៏មានអាយុទាំងឡាយ ចូរតឿនទារយករបស់ខ្លួនចុះ ទ្រព្យរបស់អ្នកទាំងឡាយចូរកុំឲ្យវិនាស ។ ពាក្យថា ការនេះ ជាសាមីចិកម្មក្នុងសិក្ខាបទនោះ គឺថា ការនេះ ជាសភាពដ៏សមគួរតាមធម៌ក្នុងសិក្ខាបទនោះ ។

[៧២] ភិក្ខុទារលើសពី ៣ ដង ឈរលើសពី ៦ ដង មានសេចក្តីសំគាល់ថា លើសមែន (ហើយ) ឲ្យចីវរនោះសម្រេចបាន ត្រូវនិស្សគ្គិយ

ចាចិត្តិយំ ។ អតិរេកតិក្ខត្តុំ ចោទនាយ អតិរេកឆក្ខត្តុំ ឋានេ ឋេមតិកោ អភិនិប្ផាទេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អតិរេកតិក្ខត្តុំ ចោទនាយ អតិរេកឆក្ខត្តុំ ឋានេ ឩនក-សញ្ញី[១] អភិនិប្ផាទេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ឩនក-តិក្ខត្តុំ ចោទនាយ ឩនកឆក្ខត្តុំ ឋានេ អតិរេកសញ្ញី អាបត្តិ ទុក្កដស្ស ។ ឩនកតិក្ខត្តុំ ចោទនាយ ឩនក-ឆក្ខត្តុំ ឋានេ ឋេមតិកោ អាបត្តិ ទុក្កដស្ស ។ ឩនក-តិក្ខត្តុំ ចោទនាយ ឩនកឆក្ខត្តុំ ឋានេ ឩនកសញ្ញី អនាបត្តិ ។

[៧៣] អនាបត្តិ តិក្ខត្តុំ ចោទនាយ ឆក្ខត្តុំ ឋានេន ឩនកតិក្ខត្តុំ ចោទនាយ ឩនកឆក្ខត្តុំ ឋានេន អចោទិយមានោ ទេតិ សាមិកោ ចោទេត្វា ទេតិ[២] ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

ចីវរវគ្គោ[៣] បឋមោ ។

១ ឩនកសញ្ញីតិបិ ។ ២ តត្ថេវាយំ បយោគោ ពហុវចនវសេន កតោ ។ ៣ ឱ. ម. កឋិនវគ្គោ ។

បាចិត្តិយ ។ ភិក្ខុទារលើសពី ៣ ដង ឈរលើសពី ៦ ដង មានសេចក្តីសង្ស័យ ហើយឲ្យចីវរនោះសម្រេចបាន ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុទារលើសពី ៣ ដង ឈរលើសពី ៦ ដង មានសេចក្តីសំគាល់ថា នៅខ្វះ ហើយឲ្យចីវរនោះសម្រេចបាន ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុទារថយពី ៣ ដង ឈរថយពី ៦ ដង មានសេចក្តីសំគាល់ថា លើស ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទារថយពី ៣ ដង ឈរថយពី ៦ ដង មានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទារថយពី ៣ ដង ឈរថយពី ៦ ដង មានសេចក្តីសំគាល់ថា ថយ ជាអនាបត្តិ ។

[៧៣] អាបត្តិ មិនមានដល់ភិក្ខុញ៉ាំងចីវរឲ្យសម្រេច ដោយទារ (ត្រឹម) ៣ ដង ឈរ (ត្រឹម) ៦ ដង ដល់ភិក្ខុញ៉ាំងចីវរឲ្យសម្រេចដោយទារខ្វះពី ៣ ដង ឈរខ្វះពី ៦ ដង ដល់ភិក្ខុដែលមិនបានតឹងទារ វេយ្យាវច្ចករ គេឲ្យ (ឯង) ដល់ភិក្ខុដែលម្ចាស់របស់ទារឲ្យ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់ ។

ចីវរវគ្គទី ១ ចប់ ។

## តស្សុទ្ទានំ

នសេការត្តិ មាសោ ច ដោវាបដំ បដិក្កហោ

អញ្ញាតកាញូ ឩទ្ទិស្ស ឩភិន្នំ ទូតកោន ចាតិ ។

## ឧទ្ទាន[១]នៃចីវរវគ្គនោះ ដូច្នេះគឺ

សំពត់អតិរេកចីវរដែលភិក្ខុបានមកហើយ មិនបានវិកប្បអធិដ្ឋាន ក្នុងវេលាដែលអស់អំណាចអានិសង្សកឋិនហើយ ទុកឲ្យកន្លងដប់រាត្រី ១ ក្នុងវេលាដែលអស់អំណាចអានិសង្សកឋិនហើយ ភិក្ខុនៅប្រាសចាកត្រៃចីវរឲ្យកន្លងមួយរាត្រី ១ ភិក្ខុទុកអកាលចីវរឲ្យហួសពីមួយខែ ១ ភិក្ខុប្រើនាងភិក្ខុនីមិនមែនជាញាតិឲ្យលាងចីវរចាស់ ១ ភិក្ខុទទួលចីវរពីដៃនាងភិក្ខុនីមិនមែនជាញាតិ ១ ភិក្ខុសូមចីវរពីគ្រហស្ថមិនមែនជាញាតិ ១ ភិក្ខុសូមចីវរហួសពីអន្តរវាសកៈ (ស្បង់) និងឧត្តរាសង្គៈ (ចីពរ) ១ ភិក្ខុទៅនិយាយនឹងគ្រហស្ថដែលមិនមែនជាញាតិ មិនបានបវារណា ដែលគេបម្រុងនឹងប្រគេនចីវរឲ្យគេប្រគេនចីវរឲ្យល្អ ១ ភិក្ខុទៅនិយាយនឹងគ្រហស្ថច្រើនរូប មិនមែនជាញាតិ មិនមែនជនដែលបានបវារណា ឲ្យគេរួបរួមថ្លៃជាមួយគ្នា ដើម្បីទិញចីវរឲ្យល្អ ១ ភិក្ខុទៅតឹងទារចីវរអំពីវេយ្យាវច្ចករហួសពីបីដង និងឈរហួសពីប្រាំមួយដង ១ ។

---

១ ពាក្យរួបរួមជាគ្រឿងរក្សាសេចក្តីដែលពោលហើយមិនឲ្យសេចក្តីនោះវិនាសខ្ចាត់ខ្ចាយទៅ (បានដល់បញ្ជីរឿង) ។

# កោសិយវគ្គស្ស បឋមសិក្ខាបទំ

[៧៤] តេន សមយេន ពុទ្ធោ ភគវា អាឡវិយំ វិហរតិ អគ្គាឡវេ ចេតិយេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កោសិយការកេ ឧបសង្កមិត្វា ឯវំ វទេន្តិ ពហូ អាវុសោ កោសការកេ បចថ អម្ហាកំបិ ទស្សថ មយំបិ ឥច្ឆាម កោសិយមិស្សកំ សន្ថតំ កាតុន្តិ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា អម្ហេ ឧបសង្កមិត្វា ឯវំ វក្ខន្តិ ពហូ អាវុសោ កោសការកេ បចថ អម្ហាកំបិ ទស្សថ មយំបិ ឥច្ឆាម កោសិយមិស្សកំ សន្ថតំ កាតុន្តិ អម្ហាកំបិ អលាភា អម្ហាកំបិ ទុល្លទ្ធំ យេ មយំ អាជីវស្ស ហេតុ បុត្តទារស្ស ការណា ពហូ ខុទ្ទកេ បាណេ សង្ឃាតំ អាបាទេមាតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ

# កោសិយវគ្គ សិក្ខាបទទី ១

[៧៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងអគ្គាឡវចេតិយ ទៀបក្រុងអាឡវី ។ ក៏ក្នុងសម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ចូលទៅរកពួកជនអ្នកធ្វើសូត្រ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរស្ងោរនាងទាំងឡាយឲ្យច្រើន នឹងឲ្យយើងខ្លះ យើងក៏ចង់ធ្វើសន្ថតលាយដោយសូត្រដែរ ។ ជនអ្នកធ្វើសូត្រទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយ ជាកូនចៅព្រះពុទ្ធជាសក្យបុត្ត មិនសមបើនឹងចូលទៅរកយើង ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរស្ងោរនាងឲ្យច្រើន នឹងឲ្យយើងខ្លះ យើងចង់ធ្វើសន្ថតលាយដោយសូត្រដែរ ពួកយើងណាធ្វើសត្វមានជីវិតតូច ៗ ជាច្រើនឲ្យដល់នូវសេចក្តីវិនាស ព្រោះហេតុសេចក្តីចិញ្ចឹមជីវិតខ្លួន និងកូនប្រពន្ធ ពួកយើងទាំងនោះ ឈ្មោះថា មិនមានលាភផង ឈ្មោះថា បានទ្រព្យដោយអាក្រក់ផង ។ ភិក្ខុទាំងឡាយ បានឮពាក្យជនអម្បាលនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា មានប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា

កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ កោសិយការកេ ឧបសង្កមិត្វា ឯវំ វក្ខន្តិ ពហូ អាវុសោ កោសការកេ បចថ អម្ហាកំបិ ទស្សថ មយំបិ ឥច្ឆាម កោសិយមិស្សកំ សន្ថតំ កាតុន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ កោសិយការកេ ឧបសង្កមិត្វា ឯវំ វទេថ ពហូ អាវុសោ កោសការកេ បចថ អម្ហាកំបិ ទស្សថ មយំបិ ឥច្ឆាម កោសិយមិស្សកំ សន្ថតំ កាតុន្តិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា កោសិយការកេ ឧបសង្កមិត្វា ឯវំ វក្ខថ ពហូ អាវុសោ កោសការកេ បចថ អម្ហាកំបិ ទស្សថ មយំបិ ឥច្ឆាម កោសិយមិស្សកំ សន្ថតំ កាតុន្តិ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ

ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងចូលទៅរកជនអ្នកធ្វើសូត្រ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុ អ្នកទាំងឡាយ ចូរស្ទោរនាងឲ្យច្រើន នឹងឲ្យយើងខ្លះ យើងចង់ធ្វើសន្ថតលាយដោយសូត្រដែរ ។ ភិក្ខុទាំងឡាយនោះ ក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ ចូលទៅរកពួកអ្នកធ្វើសូត្រ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរស្ទោរនាងឲ្យច្រើន នឹងឲ្យយើងខ្លះ យើងចង់ធ្វើសន្ថតលាយដោយសូត្រដែរ ពិតមែនឬ ។ បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះ ពិតមែន ។ ព្រះពុទ្ធដ៏មានជោគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនសមបើនឹងចូលទៅរកពួកអ្នកធ្វើសូត្រ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរស្ទោរនាងឲ្យច្រើន នឹងឲ្យយើងខ្លះ យើងចង់ធ្វើសន្ថតលាយដោយសូត្រដែរ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាហើយផង មិនមែននាំឲ្យរឹងរឹតតែជ្រះថ្លាដល់ជនដែលជ្រះថ្លាហើយផង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ

និស្សគ្គិយកណ្ឌេ កោសិយវគ្គស្ស បឋមសិក្ខាបទស្ស សិក្ខាបទវិភង្គោ

ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ កោសិយមិស្សកំ សន្ថតំ ការាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

[៧៤] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សន្ថតំ នាម សន្ថរិត្វា កតំ ហោតិ អវាយិមំ ។ ការាបេយ្យាតិ ឯកេនបិ កោសិយំសុនា មិស្សិត្វា ករោតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ កោ-សិយមិស្សកំ សន្ថតំ ការាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

គប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ឲ្យគេធ្វើ សន្ថ័តលាយដោយសូត្រ សន្ថ័តនោះ ជានិស្សគ្គិយ[១] ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[៧៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ ក្នុងបារាជិកកណ្ឌរួចហើយ ។ គ្រឿងកម្រាលដែលមិនបានត្បាញ គេស្នាច់សម្រេចតែម្តង ហៅថា សន្ថ័ត ។ ពាក្យថា ឲ្យគេធ្វើ គឺភិក្ខុលាយដោយសរសៃសូត្រ សូម្បីមួយសរសៃហើយធ្វើខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ សន្ថ័តដែលបានមកជានិស្សគ្គិយ ភិក្ខុត្រូវលះដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ សន្ថ័តនោះ ភិក្ខុត្រូវលះយ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថ័តលាយដោយសូត្រនេះ ខ្ញុំឲ្យគេធ្វើ ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថ័តនេះដល់សង្ឃ ។ បេ ។ សង្ឃគប្បីឲ្យ ។ បេ ។ លោកដ៏មានអាយុទាំងឡាយ គប្បីឲ្យ ។ បេ ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

---

១ ត្រង់ពាក្យថា និស្សគ្គិយំ បាចិត្តិយំ ប្រែបានជាពីរន័យ គឺប្រែបែបដូចសិក្ខាបទទាំងអស់ក្នុងចីវរវគ្គមួយន័យ ដូចសិក្ខាបទក្នុងកោសិយវគ្គនេះមួយន័យ តាមន័យក្នុងអដ្ឋកថា ។

[៧៦] អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អត្តនា វិប្បកតំ បរេហិ បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

[៧៧] អនាបត្តិ វិតានំ វា ភុម្មត្ថរណំ វា សាណិបាការំ វា ភិសឹ វា ពិម្ពោហនំ វា ករោតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។

[៧៦] សន្ថ័តភិក្ខុធ្វើខ្លួនឯងមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថ័តដែលភិក្ខុធ្វើខ្លួនឯងមិនទាន់ស្រេច ឲ្យអ្នកដទៃសម្រេច សន្ថ័តនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថ័តដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង សន្ថ័តនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថ័តដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេច សន្ថ័តនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី ដើម្បីអ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានសន្ថ័តដែលអ្នកដទៃធ្វើ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៧៧] អាបត្តិមិនមានដល់ភិក្ខុ ដែលធ្វើសំពត់ពិតានក្តី សំពត់កម្រាលលើទីដែលគេបូកលាបក្តី វនាំងក្តី ពូកក្តី ខ្នើយក្តី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ១ ចប់ ។

# ទុតិយសិក្ខាបទំ

[៧៨] តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម ឥមេ សមណា សក្យបុត្តិយា សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេស្សន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិចាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេថាតិ ។ សច្ចំ ភគវាតិ ។

# សិក្ខាបទទី ២

[៧៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងកូដាគារ-សាលា ក្នុងមហាវន ទៀបក្រុងវេសាលី ។ ក៏ក្នុងសម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឲ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ ។ មនុស្សទាំងឡាយដើរទៅកាន់ចារិកវិហារ ឃើញហើយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈទាំងនេះ ជាកូនចៅព្រះពុទ្ធជាសក្យបុត្ត មិនសមបើនឹងឲ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ ដូចជាពួកគ្រហស្ថ ជាអ្នកបរិភោគកាមសោះ ។ ភិក្ខុទាំងឡាយ បានឮពាក្យពួកមនុស្ស ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណា មានប្រាថ្នាតិច ។ បេ ។ ភិក្ខុអម្បាលនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងឲ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធសោះ ។ ភិក្ខុអម្បាលនោះ ក្រាបទូលដំណើរនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ ឲ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ

វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេស្សន្តិ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

[៧៩] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ កាឡកំ នាម ទ្វេ កាឡកានិ ជាតិយា កាឡកំ វា រជនកាឡកំ វា ។ សន្ថតំ នាម សន្ថរិត្វា កតំ ហោតិ អវាយិមំ ។ ការាបេយ្យាតិ ករោតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ សុទ្ធកាឡកានំ

ពិតមែន ។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំង-ឡាយ អ្នកទាំងឡាយ មិនសមបើនឹងឲ្យគេធ្វើសន្ថត ដោយរោមចៀមខ្មៅសុទ្ធទេ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នករាល់គ្នាធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាហើយផង មិនមែននាំឲ្យរឹងរឹតតែជ្រះថ្លាដល់ជនដែលជ្រះថ្លាហើយផង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឲ្យគេធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធ សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[៧៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា រោមចៀមខ្មៅ (នោះសំដៅយក) រោមចៀមខ្មៅទាំងពីរយ៉ាង គឺរោមចៀមខ្មៅពីកំណើត ១ រោមចៀមខ្មៅពីគ្រឿងជ្រលក់ ១ ។ គ្រឿងកម្រាលដែលគេមិនត្បាញ គ្រាន់តែគេស្មាច់ ហើយធ្វើឲ្យសម្រេច ហៅថា សន្ថត ។ ពាក្យថា ឲ្យគេធ្វើ គឺភិក្ខុធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលធ្វើ សន្ថតដែលបានមក ជានិស្សគ្គិយ ភិក្ខុត្រូវលះដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះយ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថតនេះ ខ្ញុំឲ្យគេធ្វើដោយរោមចៀមខ្មៅសុទ្ធ

ឯឡកលោមានំ សន្ថតំ ការាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[៨០] អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អត្តនា វិប្បកតំ បរេហិ បរិ-យោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

[៨១] អនាបត្តិ វិតានំ វា ភុម្មត្ថរណំ វា សា-ណិបាការំ វា ភិសឹ វា ពិម្ពោហនំ វា ករោតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។

ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថ័តនេះដល់សង្ឃ ។ បេ ។ សង្ឃត្រូវឲ្យ ។ បេ ។ លោកដ៏មានអាយុទាំងឡាយត្រូវឲ្យ ។ បេ ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[៨០] សន្ថ័តដែលភិក្ខុធ្វើខ្លួនឯង មិនទាន់ស្រេច ឲ្យសម្រេចដោយខ្លួនឯង សន្ថ័តនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថ័តដែលភិក្ខុធ្វើខ្លួនឯង មិនទាន់ស្រេច ឲ្យអ្នកដទៃសម្រេច សន្ថ័តនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថ័តដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ សន្ថ័តដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេច សន្ថ័តនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើសន្ថ័តខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី ដើម្បីប្រយោជន៍បុគ្គលដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានសន្ថ័តដែលបុគ្គលដទៃធ្វើ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៨១] អាបត្តិ មិនមានដល់ភិក្ខុធ្វើសំពត់ពិតានក្តី គ្រឿងកម្រាលផែនដីក្តី វនាំងក្តី ពូកក្តី ខ្នើយក្តី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់ ។

# តតិយសិក្ខាបទំ

[៨២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភគវតា បដិក្ខិត្តំ សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេតុន្តិ[១] ថោកំយេវ ឱទាតំ អន្តេ អាទិយិត្វា តថេវ សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ថោកំយេវ ឱទាតំ អន្តេ អាទិយិត្វា តថេវ សុទ្ធ-កាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ថោកំយេវ ឱទាតំ អន្តេ អាទិយិត្វា តថេវ សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា

---

១ ឥតោ បរំ ឱ. ម. បោត្ថកេសុ តេតិ បាឋោ ហោតិ ។

# សិក្ខាបទទី ៣

[៨២] សម័យនោះ ព្រះសម្ពុទ្ធដ៏មានបុញ្ញសិរី ព្រះអង្គគង់ក្នុងវត្ត ព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា ព្រះដ៏មានព្រះភាគទ្រង់ឃាត់ហាមមិនឲ្យភិក្ខុប្រើ គេឲ្យធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ ក៏នាំគ្នាប្រើឲ្យគេធ្វើសន្ថ័តដោយ រោមចៀមខ្មៅសុទ្ធដូច្នោះ តែលាយរោមចៀមសបន្តិចត្រង់ជាយ ។ ភិក្ខុ ទាំងឡាយណា អ្នកមានប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើ នឹងទៅឲ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធដូច្នោះ ហើយយករោម ចៀមសលាយបន្តិចត្រង់ជាយប៉ុណ្ណោះទេ ។ គ្រានោះ ភិក្ខុទាំងឡាយ នោះ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គ មានព្រះបន្ទូលសួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកប្រើឲ្យគេធ្វើ សន្ថ័តដោយរោមចៀមខ្មៅសុទ្ធដូច្នោះ ហើយលាយរោមចៀមសបន្តិច ត្រង់ជាយ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុ ក្រាបទូលថា បពិត្រព្រះដ៏មាន ព្រះភាគ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា

កថំ ហិ នាម តុម្ហេ មោឃបុរិសា ថោកំយេវ ឱទាតំ អន្តេ អាទិយិត្វា តថេវ សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ នវំ បន ភិក្ខុនា សន្ថតំ ការយមានេន ទ្វេ ភាគា សុទ្ធកាឡកានំ ឯឡកលោមានំ អាទាតព្វា តតិយំ ឱទាតានំ ចតុត្ថំ គោចរិយានំ ។ អនាទា ចេ ភិក្ខុ ទ្វេ ភាគេ សុទ្ធកាឡកានំ ឯឡកលោមានំ តតិយំ ឱទាតានំ ចតុត្ថំ គោចរិយានំ នវំ សន្ថតំ ការាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

[៨៣] នវំ នាម ករណំ ឧបាទាយ វុច្ចតិ ។ សន្ថតំ នាម សន្ថរិត្វា កតំ ហោតិ អវាយិមំ ។ ការយមានេនាតិ ករោន្តោ វា ការាបេន្តោ វា ។ ទ្វេ ភាគា សុទ្ធកាឡកានំ ឯឡកលោមានំ អាទាតព្វាតិ ធារយិត្វា ទ្វេ តុលា សុទ្ធកាឡកានំ ឯឡកលោមានំ អាទាតព្វា ។ តតិយំ ឱទាតានន្តិ តុលំ

ម្នាលបុរសសោះសូន្យ ហេតុដូចម្តេច បានជាពួកអ្នកឲ្យគេធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធដូច្នោះ ហើយលាយរោមចៀមសបន្តិចត្រង់ជាយដូច្នោះ ម្នាលបុរសសោះសូន្យ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់អ្នកដែលមិនទាន់ជ្រះថ្លាទេ ឬនាំអ្នកដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខា-បទនេះយ៉ាងនេះថា ភិក្ខុកាលឲ្យគេធ្វើសន្ថតថ្មី គប្បីកាន់យករោមចៀមខ្មៅសុទ្ធពីរភាគ រោមចៀមសភាគទីបី (១ ភាគ) រោមចៀមក្រហមភាគទីបួន (១ ភាគ) ។ បើភិក្ខុឲ្យគេធ្វើសន្ថតថ្មី មិនកាន់យករោមចៀមខ្មៅសុទ្ធពីរភាគ រោមចៀមសភាគទីបី រោមចៀមក្រហមភាគទីបួនទេ សន្ថតនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[៨៣] សន្ថតដែលធ្វើជាដំបូង ហៅថា សន្ថតថ្មី ។ គ្រឿងកម្រាលដែលមិនបានត្បាញ គេស្នាច់សម្រេចតែម្តង ហៅថា សន្ថត ។ ត្រង់ពាក្យថា កាលឲ្យគេធ្វើ គឺធ្វើឯងក្តី ប្រើឲ្យគេធ្វើក្តី ។ ពាក្យថា គប្បីកាន់យករោមចៀមខ្មៅសុទ្ធពីរភាគនោះ គឺភិក្ខុត្រូវថ្លឹងរោមចៀមខ្មៅសុទ្ធពីរជញ្ជីង ហើយសឹមកាន់យក ។ ពាក្យថា រោមចៀមសភាគទីបីនោះ

ឱជាតានំ ។ ចតុត្ថំ គោចរិយានន្តិ តុលំ គោចរិយានំ ។ អជានា ចេ ភិក្ខុ ទ្វេ ភាគេ សុទ្ធកាឡកានំ ឯឡកលោមានំ តតិយំ ឱជាតានំ ចតុត្ថំ គោចរិយានន្តិ អជានិយិត្វា តុលំ ឱជាតានំ តុលំ គោចរិយានំ នវំ សន្ថតំ ការេតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ សន្ថតំ អជានិយិត្វា តុលំ ឱជាតានំ តុលំ គោចរិយានំ ការាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[៨៤] អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អត្តនា វិប្បកតំ បរេហិ បរិយោសាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ បរេហិ វិប្បកតំ

គឺពោមចៀមសមួយជញ្ជីង ។ ពាក្យថា ពោមចៀមក្រហមភាគទីបួននោះ គឺពោមចៀមក្រហមមួយជញ្ជីង ។ ពាក្យថា បើភិក្ខុឲ្យគេធ្វើសន្ថតថ្មី មិនកាន់យកពោមចៀមខ្មៅសុទ្ធពីរភាគ ពោមចៀមសភាគទីបី ពោមចៀមក្រហមភាគទីបួន គឺថាភិក្ខុធ្វើឯងក្តី ប្រើឲ្យគេធ្វើក្តី នូវសន្ថតថ្មី មិនលាយពោមចៀមសមួយជញ្ជីង ពោមចៀមក្រហមមួយជញ្ជីងទេ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ វេលាបានមក សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុត្រូវលះដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះថា ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថតនេះ ខ្ញុំឲ្យគេធ្វើមិនបានលាយដោយពោមចៀមសមួយជញ្ជីង ពោមចៀមក្រហមមួយជញ្ជីង ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថតនេះដល់សង្ឃ ។ បេ ។ សង្ឃគប្បីឲ្យ ។ បេ ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។ បេ ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[៨៤] ភិក្ខុធ្វើសន្ថតដោយខ្លួនឯងមិនទាន់ស្រេច (គ្រាក្រោយ) ឲ្យសម្រេចដោយខ្លួនឯង សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើសន្ថតដោយខ្លួនឯងមិនទាន់ស្រេច ឲ្យអ្នកដទៃសម្រេច សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ អ្នកដទៃធ្វើសន្ថតមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ អ្នកដទៃធ្វើសន្ថតមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃ

៩៧



បរេហិ បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

[៨៩] អនាបត្តិ តុលំ ឱទាតានំ តុលំ គោចរិយានំ អាទិយិត្វា ករោតិ ពហុតរំ ឱទាតានំ ពហុតរំ គោចរិយានំ អាទិយិត្វា ករោតិ សុទ្ធំ ឱទាតានំ សុទ្ធំ គោចរិយានំ អាទិយិត្វា ករោតិ វិតានំ វា ភុម្មត្ថរណំ វា សាណិចា-ការំ វា ភិសឹ វា ពិម្ពោហនំ វា ករោតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។

សម្រេច សន្ថ័តនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ដើម្បីប្រយោជន៍ដល់អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបាន សន្ថ័តដែលអ្នកដទៃគេធ្វើហើយយកមកប្រើប្រាស់ ក៏ត្រូវអាបត្តិទុក្កដ ។

[៨៥] អាបត្តិមិនមានដល់ភិក្ខុធ្វើសន្ថ័តយករោមចៀមស មួយជញ្ជីង (១ ភាគ) រោមចៀមក្រហមមួយជញ្ជីង (១ ភាគ) មិនមានដល់ភិក្ខុធ្វើសន្ថ័ត យករោមចៀមសច្រើន យករោមចៀមក្រហមច្រើនជាងកំណត់នោះ មិន មានដល់ភិក្ខុធ្វើសន្ថ័តយករោមចៀមសសុទ្ធ ក្រហមសុទ្ធ មិនមានដល់ ភិក្ខុយករោមចៀមធ្វើជាពិតានក្តី ជាកម្រាលផ្ទៃដែលគេបូកលាបក្តី ជា វនាំងបាំងក្តី ជាពូកក្តី ជាខ្នើយក្តី មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុ ជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៣ ចប់ ។

# ចតុត្ថសិក្ខាបទំ

[៨៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខូ អនុវស្សំ សន្ថតំ ការាបេន្តិ ។ តេ យាចនពហុលា វិញ្ញត្តិពហុលា វិហរន្តិ ឯឡកលោមានិ ទេថ ឯឡកលោមេហិ អត្ថោតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា អនុវស្សំ សន្ថតំ ការាបេស្សន្តិ យាចនពហុលា វិញ្ញត្តិពហុលា វិហរិស្សន្តិ ឯឡកលោមានិ ទេថ ឯឡកលោមេហិ អត្ថោតិ អម្ហាកំ បន សកឹ កតានិ សន្ថតានិ បញ្ចបិ ឆបិ វស្សានិ ហោន្តិ យេសំ នោ ទារកា ឩហទន្តិបិ ឧម្មិហន្តិបិ ឧន្ទុរេហិបិ ខជ្ជន្តិ ឥមេ បន សមណា សក្យបុត្តិយា អនុវស្សំ សន្ថតំ ការាបេស្សន្តិ យាចនពហុលា វិញ្ញត្តិពហុលា វិហរិស្សន្តិ ឯឡកលោមានិ ទេថ ឯឡកលោមេហិ អត្ថោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ

# សិក្ខាបទទី ៤

[៨៦] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏គ្រានោះឯង ភិក្ខុទាំងឡាយឲ្យគេធ្វើសន្ថ័តរាល់ឆ្នាំ ។ ភិក្ខុទាំងនោះ ជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើនដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយ ចូរឲ្យរោមចៀមដល់អាត្មា ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្ត មិនគួរបើនឹងឲ្យគេធ្វើសន្ថ័តរាល់ឆ្នាំយ៉ាងនេះ ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើនដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយ ចូរឲ្យរោមចៀមដល់អាត្មា ក៏ពួកយើងធ្វើសន្ថ័តម្តងប្រើបាន ៥ ឆ្នាំខ្លះ ៦ ឆ្នាំខ្លះ ក្មេងរបស់យើងទាំងឡាយជុះដាក់ខ្លះ នោមដាក់ខ្លះ កណ្តុរកាត់ខ្លះ (ក៏គង់ប្រើបានយូរដល់ត្រឹមនោះ) ចំណែកពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្តទាំងនេះ ឲ្យគេធ្វើសន្ថ័តរាល់ ៗ ឆ្នាំ សមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្តនេះ ជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើនដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយ ចូរឲ្យរោមចៀមដល់អាត្មា ។ ភិក្ខុទាំងឡាយបានឮពាក្យមនុស្សទាំងនោះ

និស្សគ្គិយកណ្ឌេ កោសិយវគ្គស្ស ចតុត្ថសិក្ខាបទស្ស បញ្ញត្តិ

ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ អនុវស្សំ សន្ថតំ ការាបេស្សន្តិ យាចនពហុលា វិញ្ញត្តិពហុលា វិហរិស្សន្តិ ឯឡកលោមានិ នេថ ឯឡកលោមេហិ អត្ថោតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ អនុវស្សំ សន្ថតំ ការាបេន្តិ យាចនពហុលា វិញ្ញត្តិពហុលា វិហរន្តិ ឯឡកលោមានិ នេថ ឯឡកលោមេហិ អត្ថោតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា អនុវស្សំ សន្ថតំ ការាបេស្សន្តិ យាចនពហុលា វិញ្ញត្តិពហុលា វិហរិស្សន្តិ ឯឡកលោមានិ នេថ ឯឡកលោមេហិ អត្ថោតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ

ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា អ្នកមានប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយ មិនគួរបើនឹងឲ្យគេធ្វើសន្ថ័តរាល់ឆ្នាំឡើយ ពួកភិក្ខុទាំងនេះ ជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើនដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយ ចូរឲ្យរោមចៀមដល់អាត្មា ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបទូលដំណើរនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយឲ្យគេធ្វើសន្ថ័តរាល់ឆ្នាំ ភិក្ខុទាំងឡាយជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើនដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយចូរឲ្យរោមចៀមដល់អាត្មាដូច្នេះ ពិតមែនឬ ។ ភិក្ខុទាំងឡាយ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ឯបុរសសោះសូន្យទាំងនោះ មិនគួរបើនឹងឲ្យគេធ្វើសន្ថ័តរាល់ឆ្នាំឡើយ ជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើនដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយ ចូរឲ្យរោមចៀមដល់អាត្មាដូច្នេះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់អ្នកដែលមិនទាន់ជ្រះថ្លាទេ ឬនាំអ្នកដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ

នវំ បន ភិក្ខុនា សន្ថតំ ការាបេត្វា ឆព្វស្សានិ ធារេតព្វំ ។ ឱរេន ចេ ឆន្នំ វស្សានំ តំ សន្ថតំ វិស្សជ្ជេត្វា វា អវិស្សជ្ជេត្វា វា អញ្ញំ នវំ សន្ថតំ ការាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៨៧] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ កោសម្ពិយំ គិលានោ ហោតិ ។ ញាតកា តស្ស ភិក្ខុនោ សន្តិកេ ទូតំ បាហេសុំ អាគច្ឆតុ ភទន្តោ មយំ ឧបដ្ឋហិស្សាមាតិ ។ ភិក្ខូបិ ឯវមា-ហំសុ គច្ឆាវុសោ ញាតកា តំ ឧបដ្ឋហិស្សន្តីតិ ។ សោ ឯវមាហ ភគវតា អាវុសោ សិក្ខាបទំ បញ្ញត្តំ នវំ បន ភិក្ខុនា សន្ថតំ ការាបេត្វា ឆព្វស្សានិ ធារេតព្វន្តិ អហញ្ចម្ហិ គិលានោ ន សក្កោមិ សន្ថតំ អាទាយ បក្កមិតុំ មយ្ហញ្ច វិនា សន្ថតា ន ផាសុ ហោតិ នាហំ គមិស្សាមីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ

គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុឲ្យគេធ្វើសន្ថ័តថ្មី គប្បីប្រើប្រាស់ឲ្យដល់ប្រាំមួយឆ្នាំ ។ បើប្រើប្រាស់មិនទាន់ដល់ប្រាំមួយឆ្នាំទេ លះចោលក្តី មិនបានលះចោលក្តី នូវសន្ថ័តនោះ ហើយឲ្យគេធ្វើសន្ថ័តថ្មីដទៃទៀត សន្ថ័តនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទនេះ ដល់ភិក្ខុទាំងឡាយហើយ ដោយប្រការដូច្នេះ ។

[៨៧] សម័យនោះឯង ភិក្ខុមួយរូបមានជំងឺឈឺ នៅក្នុងនគរកោសម្ពី ។ ពួកញាតិបានប្រើបម្រើទៅក្នុងសំណាក់ភិក្ខុនោះ ដោយពាក្យថា សូមលោកដ៏ចម្រើននិមន្តមក យើងខ្ញុំទាំងឡាយនឹងបានទំនុកបម្រុង ។ ភិក្ខុទាំងឡាយ ក៏បាននិយាយយ៉ាងនេះថា ម្នាលអាវុសោ លោកចូរទៅចុះ ពួកញាតិនឹងបានថែទាំលោក ។ ភិក្ខុនោះ និយាយតបយ៉ាងនេះថា អាវុសោ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទហើយថា ភិក្ខុឲ្យគេធ្វើសន្ថ័តថ្មី គប្បីប្រើប្រាស់ឲ្យដល់ ៦ ឆ្នាំ ក៏ខ្លួនខ្ញុំមានជំងឺ មិនអាចនឹងនាំយកសន្ថ័តទៅបាន ខ្លួនខ្ញុំលះសន្ថ័តចេញហើយមិនសប្បាយទេ (ហេតុនេះ) ខ្ញុំមិនទៅទេ ។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ព្រោះដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយក្នុងខណៈនោះថា ម្នាលភិក្ខុទាំងឡាយ

១០១



អនុជានាមិ ភិក្ខវេ គិលានស្ស ភិក្ខុនោ សន្ថតសម្មតឹ ទាតុំ ឯវញ្ច បន ភិក្ខវេ ទាតព្វា តេន គិលានេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ គិលានោ ន សក្កោមិ សន្ថតំ អាទាយ បក្កមិតុំ សោហំ ភន្តេ សង្ឃំ សន្ថតសម្មតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ គិលានោ ន សក្កោតិ សន្ថតំ អាទាយ បក្កមិតុំ ។ សោ សង្ឃំ សន្ថតសម្មតឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ សន្ថតសម្មតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ គិលានោ ន សក្កោតិ សន្ថតំ អាទាយ បក្កមិតុំ ។ សោ សង្ឃំ សន្ថតសម្មតឹ យាចតិ ។

តថាគតអនុញ្ញាតឲ្យសង្ឃឲ្យសន្ថតសម្មតិដល់ភិក្ខុឈឺ ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីឲ្យដោយសន្ថតសម្មតិយ៉ាងនេះ ភិក្ខុឈឺនោះ គប្បីចូលទៅរកសង្ឃ គ្រងចីវរឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលី ពោលយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាមានជំងឺ មិនអាចនឹងនាំយកសន្ថតទៅផងបានទេ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណានោះ សូមសន្ថតសម្មតិនឹងសង្ឃ ។ ភិក្ខុឈឺនោះ គប្បីសូមសម្មតិអស់វារៈពីរដងផង គប្បីសូមសម្មតិអស់វារៈបីដងផង ។ ភិក្ខុអ្នកឆ្លាសអង់អាចគប្បីញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនេះឈ្មោះនេះមានជំងឺ មិនអាចកាន់យកសន្ថតទៅផងបានទេ ។ ភិក្ខុនោះ សូមសន្ថតសម្មតិនឹងសង្ឃ ។ បើការសន្មតសន្ថតនេះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យសន្ថតសម្មតិដល់ភិក្ខុឈ្មោះនេះ ។ នេះជាវាចាប្រកាសឲ្យសង្ឃដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនេះឈ្មោះនេះមានជំងឺ មិនអាចកាន់យកសន្ថតទៅផងបាន ។ ភិក្ខុឈឺនោះសូមសន្ថតសម្មតិនឹងសង្ឃ ។

សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ សន្ថតសម្មុតឹ ទេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សន្ថតសម្មុតិយា ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ សន្ថតសម្មុតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ នវំ បន ភិក្ខុនា សន្ថតំ ការាបេត្វា ឆព្វស្សានិ ធារេតព្វំ ។ ឱរេន ចេ ឆន្នំ វស្សានំ តំ សន្ថតំ វិស្សជ្ជេត្វា វា អវិស្សជ្ជេត្វា វា អញ្ញំ នវំ សន្ថតំ ការាបេយ្យ អញ្ញត្រ ភិក្ខុសម្មុតិយា និស្សគ្គិយំ បាចិត្តិយន្តិ ។

[៨៨] នវំ នាម ករណំ ឧបាទាយ វុច្ចតិ ។ សន្ថតំ នាម សន្ថរិត្វា កតំ ហោតិ អវាយិមំ ។ ការាបេត្វាតិ ករិត្វា វា ការាបេត្វា វា ។ ឆព្វស្សានិ ធារេតព្វន្តិ ឆព្វស្សបរមតា ធារេតព្វំ ។ ឱរេន ចេ ឆន្នំ វស្សានន្តិ ឩនកឆព្វស្សានិ ។ តំ សន្ថតំ វិស្សជ្ជេត្វា វាតិ

សង្ឃឲ្យការសន្មតសន្ថ័តដល់ភិក្ខុឈ្មោះនេះ ។ ការឲ្យសន្មតិសន្ថ័តដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ សង្ឃបានឲ្យការសន្មតសន្ថ័តដល់ភិក្ខុឈ្មោះនេះហើយ ។ ការសន្មតសន្ថ័តនេះ គួរដល់សង្ឃ ហេតុនោះសង្ឃស្ងៀមនៅ ។ ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុឲ្យគេធ្វើសន្ថ័តថ្មី គប្បីប្រើប្រាស់ឲ្យអស់ ៦ ឆ្នាំ ។ បើមិនទាន់ដល់ ៦ ឆ្នាំទេ លះបោលសន្ថ័តនោះក្តី មិនលះបោលក្តី ហើយឲ្យគេធ្វើសន្ថ័តថ្មីដទៃទៀត វៀរលែងតែភិក្ខុបានសម្មតិ (អំពីសង្ឃ) សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[៨៨] សន្ថ័តដែលទើបនឹងធ្វើ ហៅថា សន្ថ័តថ្មី ។ គ្រឿងកម្រាលដែលគេគ្រាន់តែស្មាច់មិនបានត្បាញ ហៅថា សន្ថ័ត ។ ត្រង់ពាក្យថា ឲ្យគេធ្វើនោះ គឺធ្វើឯង ឬឲ្យគេធ្វើ ។ ពាក្យថា គប្បីប្រើប្រាស់ឲ្យអស់ ៦ ឆ្នាំ គឺគប្បីប្រើប្រាស់យ៉ាងច្រើនត្រឹម ៦ ឆ្នាំ ។ ពាក្យថា បើមិនទាន់ដល់ ៦ ឆ្នាំទេ គឺថយពី ៦ ឆ្នាំចុះមក ។ ពាក្យថា លះបោលសន្ថ័តនោះក្តី

អញ្ញេសំ ទត្វា ។ អវិស្សជ្ជេត្វា វាតិ ន កស្សចិ ទត្វា ។ អញ្ញត្រ ភិក្ខុសម្មតិយាតិ ឋបេត្វា ភិក្ខុសម្មតឹ ។ អញ្ញំ នវំ សន្ថតំ ករោតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ សន្ថតំ ឩន-កឆព្វស្សានិ ការាបិតំ អញ្ញត្រ ភិក្ខុសម្មតិយា និស្ស-គ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[៨៩] អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អត្តនា វិប្បកតំ បរេហិ បរិយោសាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ និស្សគ្គិយំ បាចិត្តិយំ ។

គឺបានឲ្យសន្ថ័តនោះទៅអ្នកដទៃ ។ ពាក្យថា មិនលះបោលក្តី គឺមិនបានឲ្យដល់អ្នកណានីមួយ ។ ពាក្យថា វៀរលែងតែភិក្ខុដែលបានសម្មតិ (អំពីសង្ឃ) គឺលើកលែងនូវភិក្ខុដែលបានសម្មតិ (អំពីសង្ឃ) ។ (កាលប្រើប្រាស់សន្ថ័តចាស់មិនទាន់គ្រប់ ៦ ឆ្នាំ) ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តីនូវសន្ថ័តដទៃថ្មីទៀត ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ សន្ថ័តនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះថា ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថ័តនេះខ្ញុំឲ្យគេធ្វើថ្មី (តែខ្ញុំប្រើប្រាស់សន្ថ័តចាស់) មិនទាន់ដល់ ៦ ឆ្នាំនៅឡើយ (សន្ថ័តថ្មី) ជានិស្សគ្គិយ ព្រោះគ្មានភិក្ខុសម្មតិ ខ្ញុំសូមលះនូវសន្ថ័តនេះដល់សង្ឃ ។ បេ ។ សង្ឃគប្បីឲ្យ ។ បេ ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។ បេ ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[៨៩] ភិក្ខុធ្វើសន្ថ័តដោយខ្លួនឯងមិនទាន់ហើយ (គ្រាក្រោយ) ទើបបង្ហើយដោយខ្លួនឯង ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុធ្វើសន្ថ័តដោយខ្លួនឯងមិនទាន់ហើយ ឲ្យអ្នកដទៃធ្វើបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។ អ្នកដទៃធ្វើមិនទាន់ហើយ ភិក្ខុធ្វើបង្ហើយដោយខ្លួនឯង ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។ អ្នកដទៃធ្វើមិនទាន់ហើយ ភិក្ខុឲ្យអ្នកដទៃធ្វើបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។

[៩០] អជាបត្តិ ឆព្វស្សានិ ករោតិ អតិរេក-ឆព្វស្សានិ ករោតិ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ វិតានំ វា ភុម្មត្ថរណំ វា សាណិបាការំ វា ភិសឹ វា ពិម្ពោហនំ វា ករោតិ ភិក្ខុសម្មតិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។

[៩០] អាបត្តិមិនមានដល់ភិក្ខុប្រើប្រាស់សន្ថ័តចាស់ដល់ ៦ ឆ្នាំ ហើយធ្វើសន្ថ័តថ្មីទៀត មិនមានដល់ភិក្ខុប្រើប្រាស់សន្ថ័តចាស់លើសពី ៦ ឆ្នាំ ហើយធ្វើសន្ថ័តថ្មី មិនមានដល់ភិក្ខុធ្វើដោយខ្លួនឯង ឬឲ្យអ្នកដទៃធ្វើ ដើម្បីប្រយោជន៍ដល់អ្នកដទៃ មិនមានដល់ភិក្ខុបានសន្ថ័តដែលអ្នកដទៃធ្វើ យកមកប្រើប្រាស់ មិនមានដល់ភិក្ខុយកសន្ថ័តធ្វើជាពិតានក្តី ជាកម្រាលផ្ទៃដែលគេបូកលាបក្តី ជាវនាំងបាំងក្តី ជាពូកក្តី ជាខ្នើយក្តី មិនមានដល់ភិក្ខុដែលបានសម្មតិ មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុជាខាង ដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់ ។

# បញ្ចមសិក្ខាបទំ

[៩១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ឥច្ឆាមហំ ភិក្ខវេ តេមាសំ បដិសល្លិយិតុំ នម្ហិ កោចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេនាតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុណិត្វា ។ នាស្សុធ កោចិ ភគវន្តំ ឧបសង្កមតិ អញ្ញត្រ ឯកេន បិណ្ឌបាតនី-ហារកេន ។ តេន ខោ បន សមយេន សាវត្ថិយំ សង្ឃេន កតិកា កតា ហោតិ ឥច្ឆតាវុសោ ភគវា តេមាសំ បដិសល្លិយិតុំ ន ភគវា កោចិ ឧបសង្ក-មិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេន យោ ភគវន្តំ ឧបសង្កមតិ[១] បាចិត្តិយំ នេសាបេតព្វោតិ ។

[៩២] អថខោ អាយស្មា ឧបសេនោ វង្គន្តបុត្តោ សបរិសោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

១ ឥតោ បរំ ឱ. ម. បោត្ថកេសុ សោតិ បាឋោ ទិស្សតិ ។

# សិក្ខាបទទី ៥

[៩១] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដើម្បីនឹងលាក់ខ្លួនសម្ងំបានបីខែ អ្នកណាមួយកុំគប្បីចូលទៅរកតថាគត លើកលែងតែភិក្ខុ ១ រូប ដែលជាអ្នកនាំយកនូវបិណ្ឌបាតទៅឲ្យ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ភិក្ខុនីមួយមិនបានចូលមករកព្រះដ៏មានព្រះភាគ ក្នុងទីនេះជាប្រាកដ លើកលែងតែភិក្ខុ ១ រូប ដែលជាអ្នកនាំយកបិណ្ឌបាតទៅថ្វាយ ។ ក៏វេលានោះឯង សង្ឃក្នុងក្រុងសាវត្ថីបានប្ដេជ្ញាគ្នាថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ប្រាថ្នាដើម្បីនឹងសម្រាកព្រះអង្គនៅបានបីខែ ភិក្ខុណាមួយ កុំគប្បីចូលទៅគាល់ព្រះអង្គ លើកលែងតែភិក្ខុ ១ រូប ដែលជាអ្នកនាំយកបិណ្ឌបាតទៅថ្វាយនោះ ភិក្ខុណា ចូលទៅគាល់ព្រះអង្គ ភិក្ខុដទៃត្រូវឲ្យភិក្ខុនោះសំដែងអាបត្តិបាចិត្តិយចេញ ។

[៩២] គ្រានោះ ភិក្ខុឧបសេនវង្គន្តបុត្រដ៏មានអាយុ ព្រមដោយបរិសទ្យ បានចូលទៅគាល់សម្ដេចព្រះដ៏មានព្រះភាគ ត្រង់ទីដែល

ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ អាចិណ្ណំ ខោ បនេតំ ពុទ្ធានំ ភគវន្តានំ អាគន្តុកេហិ ភិក្ខូហិ សទ្ធឹ បដិសម្មោទិតុំ ។ អថខោ ភគវា អាយស្មន្តំ ឧបសេនំ វង្គន្តបុត្តំ ឯតទវោច[1] កច្ចិ វោ ឧបសេន ខមនីយំ កច្ចិ យាបនីយំ កច្ចិត្ថ អប្បកិលមថេន អទ្ធានំ អាគតាតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា អប្បកិលមថេន ច មយំ ភន្តេ អទ្ធានំ អាគតាតិ ។ តេន ខោ បន សមយេន អាយស្មតោ ឧបសេនស្ស វង្គន្តបុត្តស្ស សទ្ធិវិហារិកោ ភិក្ខុ ភគវតោ អវិទូរេ និសិន្នោ ហោតិ ។ អថខោ ភគវា តំ ភិក្ខុំ ឯតទវោច មនាបានិ តេ ភិក្ខុ បំសុកូលានីតិ ។ ន ខោ មេ ភន្តេ មនាបានិ បំសុកូលានីតិ ។ កិស្ស បន ត្វំ ភិក្ខុ បំសុកូលិកោតិ ។ ឧបជ្ឈាយោ មេ ភន្តេ បំសុកូលិកោ

---

១ ឱ. ម. រា. ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ ឧបសេនំ វង្គន្តបុត្តំ ភគវា ឯតទវោច ។

ព្រះអង្គគង់នៅ លុះចូលទៅដល់ហើយបានថ្វាយបង្គំគាល់ព្រះអង្គ ក្នុងទីដ៏សមគួរ ។ សេចក្តីស្រុះស្រួលរាក់ទាក់មួយអន្លើដោយពួកអាគន្តុកភិក្ខុនេះ ជាកិច្ចដែលព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយ ទ្រង់ប្រព្រឹត្តសន្សំទុកមកហើយ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរពាក្យនេះ នឹងឧបសេនភិក្ខុវង្គន្តបុត្រដ៏មានអាយុថា ម្នាលឧបសេន អ្នកពល់គ្នាល្មមធន់ទ្រាំបានដែរឬ អ្នកពល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលដែរឬ អ្នកពល់គ្នាដើរផ្លូវឆ្ងាយមកមិនលំបាកទេឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំទាំងឡាយល្មមធន់ទ្រាំបាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំទាំងឡាយល្មមប្រព្រឹត្តទៅបានស្រួល ម្យ៉ាងទៀត បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយដើរផ្លូវឆ្ងាយមកមិនបានលំបាកទេ ។ ក៏សម័យនោះឯង ភិក្ខុជាសទ្ធិវិហារិករបស់ឧបសេនវង្គន្តបុត្រដ៏មានអាយុ អង្គុយជិតព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរភិក្ខុនោះយ៉ាងនេះថា ម្នាលភិក្ខុ បំសុកូលទាំងឡាយជាទីគាប់ចិត្តរបស់អ្នកដែរឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បំសុកូលទាំងឡាយមិនជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គទេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ក៏អ្នកប្រព្រឹត្តបំសុកូល (នោះ) ដើម្បីអ្វី ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន (ព្រោះ) ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គប្រព្រឹត្តបំសុកូល

១០៧



ឯវំ អហំ បិ បំសុកូលិកោតិ ។ អថខោ ភគវា អាយស្មន្តំ ឧបសេនំ វង្គន្តបុត្តំ ឯតទវោច ចាសាទិកា ខោ ត្យាយំ ឧបសេន បរិសា កថំ ត្វំ ឧបសេន បរិសំ វិនេសីតិ ។ យោ មំ ភន្តេ ឧបសម្បទំ យាចតិ តមហំ[១] ឯវំ វទាមិ អហំ ខោ អាវុសោ អារញ្ញកោ បិណ្ឌបាតិកោ បំសុកូលិកោ សចេ ត្វំ បិ អារញ្ញកោ ភវិស្សសិ បិណ្ឌបាតិកោ បំសុកូលិកោ ឯវាហំ តំ ឧបសម្បាទេស្សាមីតិ សចេ មេ បដិស្សុណាតិ ឧបសម្បាទេមិ នោ ចេ មេ បដិស្សុណាតិ ន ឧបសម្បាទេមិ យោ មំ និស្សយំ យាចតិ តមហំ[២] ឯវំ វទាមិ អហំ ខោ អាវុសោ អារញ្ញកោ បិណ្ឌបាតិកោ បំសុកូលិកោ សចេ ត្វំ បិ អារញ្ញកោ ភវិស្សសិ បិណ្ឌបាតិកោ បំសុកូលិកោ ឯវាហំ តេ និស្សយំ ទស្សាមីតិ សចេ មេ បដិស្សុណាតិ និស្សយំ ទេមិ នោ ចេ មេ បដិស្សុណាតិ ន ទេមិ[៣] ឯវំ ខោ អហំ ភន្តេ

១ ឱ. ម. តាហំ ។ ២ ឱ. ម. តាហំ ។ ៣ ឱ. ម. ន និស្សយំ ទេមិ ។

ខ្ញុំព្រះអង្គ ក៏ត្រូវប្រព្រឹត្តបំសុកូលយ៉ាងនោះដែរ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរភិក្ខុឧបសេនវង្គន្តបុត្រដ៏មានអាយុ យ៉ាងនេះថា ម្នាលឧបសេន បរិសទ្យរបស់អ្នកនេះប្រកបដោយសេចក្ដីជ្រះថ្លា ម្នាលឧបសេន អ្នកទូន្មានបរិសទ្យដូចម្ដេច ។ ឧបសេនភិក្ខុដ៏មានអាយុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កុលបុត្រណាមកសូមឧបសម្បទានឹងខ្ញុំព្រះអង្គ ៗ រមែងប្រាប់កុលបុត្រនោះយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបំសុកូល បើអ្នកនឹងជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបំសុកូលដែរ ខ្ញុំនឹងឲ្យអ្នកបានឧបសម្បទា បើអ្នកណាទទួលស្ដាប់ខ្ញុំព្រះអង្គ ៗ នឹងឲ្យអ្នកនោះបានឧបសម្បទា បើអ្នកណាមិនទទួលស្ដាប់ខ្ញុំព្រះអង្គទេ ខ្ញុំព្រះអង្គមិនឲ្យអ្នកនោះបានឧបសម្បទាទេ អ្នកណាសូមនិស្ស័យនឹងខ្ញុំព្រះអង្គ ៗ នឹងប្រាប់អ្នកនោះយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបំសុកូល បើអ្នកឯងនឹងជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបំសុកូលដែរ ខ្ញុំនឹងឲ្យនិស្ស័យដល់អ្នក បើអ្នកណាទទួលស្ដាប់ខ្ញុំព្រះអង្គ ៗ នឹងឲ្យនិស្ស័យដល់អ្នកនោះ បើមិនទទួលស្ដាប់ខ្ញុំព្រះអង្គទេ ខ្ញុំព្រះអង្គមិនឲ្យនិស្ស័យដល់អ្នកនោះទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ

បរិសំ វិនេមីតិ ។ សាធុ សាធុ ឧបសេន សាធុ ខោ ត្វំ ឧបសេន បរិសំ វិនេសិ ជានាសិ បន ត្វំ ឧបសេន សាវត្ថិយំ[១] សង្ឃស្ស កតិកន្តិ ។ ន ខោ អហំ ភន្តេ ជានាមិ សាវត្ថិយំ សង្ឃស្ស កតិកន្តិ ។ សាវត្ថិយំ ខោ ឧបសេន សង្ឃេន កតិកា កតា ឥច្ឆតាវុសោ ភគវា តេមាសំ បដិសល្លិយិតុំ ន ភគវា កោចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេន យោ ភគវន្តំ ឧបសង្កមតិ បាចិត្តិយំ ទេសាបេតព្វោតិ ។ បញ្ញាយិស្សតិ ភន្តេ សាវត្ថិយំ សង្ឃោ សកាយ កតិកាយ ន មយំ អប្បញ្ញត្តំ បញ្ញាបេស្សាម បញ្ញត្តំ វា ន សមុច្ឆិន្ទិស្សាម យថាបញ្ញត្តេសុ សិក្ខាបទេសុ សមាទាយ វត្តិស្សាមាតិ ។ សាធុ សាធុ ឧបសេន ន អប្បញ្ញត្តំ បញ្ញាបេតព្វំ បញ្ញត្តំ វា ន សមុច្ឆិន្ទិតព្វំ

១ ឱ. ម. សាវត្ថិយា ។

រមែងណែនាំបរិសទ្យដោយអាការយ៉ាងនេះឯង ។ ព្រះដ៏មានព្រះភាគត្រាស់ប្រទានពរសាធុការថា ឧបសេន ល្អហើយ ៗ ឧបសេន អ្នកណែនាំបរិសទ្យល្អពិតហើយ ឧបសេន អ្នកដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីដែរឬទេ ។ ឧបសេនភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបសេន សង្ឃបានប្តេជ្ញាហើយក្នុងក្រុងសាវត្ថីថា អាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ប្រាថ្នាដើម្បីនឹងសម្ងំសម្រាកព្រះអង្គនៅអស់បីខែ ភិក្ខុណាមួយ កុំគប្បីចូលទៅគាល់ព្រះអង្គ លើកលែងតែភិក្ខុ ១ រូប អ្នកនាំយកបិណ្ឌបាតទៅថ្វាយ ភិក្ខុណាចូលទៅគាល់ព្រះអង្គ ភិក្ខុដទៃគប្បីឲ្យភិក្ខុនោះសំដែងអាបត្តិបាចិត្តិយចេញ ។ ភិក្ខុឧបសេន ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សង្ឃក្នុងក្រុងសាវត្ថីបានបញ្ញត្តដោយសេចក្តីប្តេជ្ញារបស់ខ្លួន ខ្ញុំព្រះអង្គទាំងឡាយ នឹងមិនបញ្ញត្តនូវហេតុដែលព្រះអង្គមិនទាន់បានបញ្ញត្តទេ ម្យ៉ាងទៀត នឹងមិនដកចេញនូវសិក្ខាបទដែលទ្រង់បានបញ្ញត្តទុកហើយទេ នឹងប្រព្រឹត្តកាន់យកតាមសិក្ខាបទដែលទ្រង់បញ្ញត្តទុកមកហើយ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ល្អណាស់ហើយឧបសេន ភិក្ខុមិនត្រូវបញ្ញត្តនូវសិក្ខាបទ ដែលតថាគតមិនទាន់បានបញ្ញត្តហើយ ម្យ៉ាងទៀត មិនត្រូវដកនូវសិក្ខាបទដែលតថាគតបញ្ញត្តហើយ

## និស្សគ្គិយកណ្ឌេ កោសិយវគ្គស្ស បញ្ចមសិក្ខាបទស្ស ឧបសេនវត្ថុ

យថាបញ្ញត្តេសុ សិក្ខាបទេសុ សមាទាយ វត្តិតព្វំ អនុជានាមិ ឧបសេន យេ តេ ភិក្ខូ អារញ្ញកា បិណ្ឌបាតិកា បំសុកូលិកា យថាសុខំ មំ ទស្ស-នាយ ឧបសង្កមន្តូតិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ពហិទ្វារកោដ្ឋកេ ឋិតា ហោន្តិ មយំ អាយស្មន្តំ ឧបសេនំ វង្គន្តបុត្តំ ចាចិត្តិយំ ទេសាបេស្សាមាតិ ។ អថខោ អាយស្មា ឧបសេនោ វង្គន្តបុត្តោ សបរិសោ ឧដ្ឋាយាសនា ភគវន្តំ អភិវា-ទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ តេ ភិក្ខូ អាយស្មន្តំ ឧបសេនំ វង្គន្តបុត្តំ ឯតទវោចុំ ជានាសិ ត្វំ អាវុសោ ឧបសេន សាវត្ថិយំ សង្ឃស្ស កតិកន្តិ ។ ភគវាបិ មំ អាវុសោ ឯវមាហ ជានាសិ បន ត្វំ ឧបសេន សាវត្ថិយំ សង្ឃស្ស កតិកន្តិ ន ខោ អហំ ភន្តេ ជានាមិ សាវត្ថិយំ សង្ឃស្ស កតិកន្តិ សាវត្ថិយំ ខោ ឧបសេន សង្ឃេន កតិកា កតា ឥច្ឆតាវុសោ ភគវា តេមាសំ បដិសល្លិយិតុំ ន ភគវា កោនចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន

ត្រូវប្រព្រឹត្តកាន់យកតាមសិក្ខាបទ ដែលតថាគតបានបញ្ញត្តទុកហើយ ឧបសេន តថាគតអនុញ្ញាតឲ្យភិក្ខុអ្នកប្រព្រឹត្តនៅព្រៃ អ្នកប្រព្រឹត្តបិណ្ឌបាត និងប្រព្រឹត្តបំសុកូល ចូលទៅរកតថាគតតាមសប្បាយចុះ ។ ក៏គ្រានោះឯង ភិក្ខុច្រើនរូបឈរនៅជិតក្លោងទ្វារខាងក្រៅ បាននិយាយគ្នាថា យើងទាំងឡាយ ត្រូវឲ្យលោកឧបសេនវង្គន្តបុត្រដ៏មានអាយុសំដែងអាបត្តិបាចិត្តិយចេញ ។ វេលានោះ ឧបសេនភិក្ខុវង្គន្តបុត្រដ៏មានអាយុព្រមទាំងបរិសទ្យក្រោកចេញចាកអាសនៈ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ភិក្ខុទាំងនោះ បាននិយាយពាក្យនេះនឹងឧបសេនវង្គន្តបុត្រដ៏មានអាយុក្នុងវេលានោះថា អាវុសោឧបសេន អ្នកដឹងសេចក្តីប្តេជ្ញា របស់សង្ឃក្នុងក្រុងសាវត្ថីដែរឬ ។ ឧបសេនភិក្ខុបាននិយាយតបថា អាវុសោ ព្រះដ៏មានព្រះភាគ ក៏បានត្រាស់សួរខ្ញុំយ៉ាងនេះថា ម្នាលឧបសេន អ្នកបានដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ ខ្ញុំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលឧបសេន សេចក្តីប្តេជ្ញាសង្ឃបានធ្វើហើយក្នុងក្រុងសាវត្ថីថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ប្រាថ្នានឹងសម្ងំសម្រាកព្រះអង្គនៅអស់បីខែ ភិក្ខុណាមួយកុំគប្បីចូលទៅគាល់ព្រះដ៏មានព្រះភាគ លើកលែងតែភិក្ខុ ១ រូប

បិណ្ឌបាតនីហារកេន យោ ភគវន្តំ ឧបសង្កមតិ ចាចិត្តិយំ ទេសាបេតព្វោតិ បញ្ញាយិស្សតិ ភន្តេ សាវត្ថិយំ សង្ឃោ សកាយ កតិកាយ ន មយំ អប្បញ្ញត្តំ បញ្ញាបេស្សាម បញ្ញត្តំ វា ន សមុច្ឆិន្ទិស្សាម យថាបញ្ញត្តេសុ សិក្ខាបទេសុ សមាទាយ វត្តិស្សាមាតិ អនុញ្ញាតាវុសោ ភគវតា យេ តេ ភិក្ខូ អារញ្ញកា បិណ្ឌបាតិកា បំសុកូលិកា យថាសុខំ មំ ទស្សនាយ ឧបសង្កមន្តូតិ ។ អថខោ តេ ភិក្ខូ សច្ចំ ខោ អាយស្មា ឧបសេនោ វង្គន្តបុត្តោ អាហ ន អប្បញ្ញត្តំ បញ្ញាបេតព្វំ បញ្ញត្តំ វា ន សមុច្ឆិន្ទិតព្វំ យថាបញ្ញត្តេសុ សិក្ខាបទេសុ សមាទាយ វត្តិតព្វន្តិ ។

[៩៣] អស្សោសុំ ខោ ភិក្ខូ អនុញ្ញាតា កិរ ភគវតា យេ តេ ភិក្ខូ អារញ្ញកា បិណ្ឌបាតិកា បំសុកូលិកា យថាសុខំ មំ ទស្សនាយ ឧបសង្កមន្តូតិ ។

អ្នកនាំយកបិណ្ឌបាតទៅថ្វាយប៉ុណ្ណោះ ភិក្ខុណា ចូលទៅគាល់ព្រះដ៏មានព្រះភាគ ភិក្ខុដទៃត្រូវឲ្យភិក្ខុនោះ សំដែងអាបត្តិបាចិត្តិយចេញ ខ្ញុំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន សង្ឃក្នុងក្រុងសាវត្ថីបានបញ្ញត្តដោយសេចក្តីប្តេជ្ញារបស់ខ្លួន ខ្ញុំព្រះអង្គទាំងឡាយ នឹងមិនបញ្ញត្តនូវហេតុដែលព្រះអង្គមិនទាន់បានបញ្ញត្ត ម្យ៉ាងទៀត នឹងមិនដកនូវពុទ្ធប្បញ្ញត្តិដែលព្រះអង្គបានបញ្ញត្តទុកស្រេចហើយ នឹងប្រព្រឹត្តកាន់យកតាមសិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្តទុកមកហើយ ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយថា ភិក្ខុទាំងឡាយណាជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបង្សុកូល ភិក្ខុទាំងឡាយនោះ ចូលមករកតថាគតតាមសប្បាយចុះ ។ គ្រានោះ ភិក្ខុទាំងនោះបានពោលថា ឧបសេនភិក្ខុវង្គន្តបុត្រដ៏មានអាយុ បានពោលពាក្យពិតមែន ភិក្ខុមិនត្រូវបញ្ញត្តនូវសិក្ខាបទ ដែលព្រះអង្គមិនទាន់បានបញ្ញត្ត ម្យ៉ាងទៀត មិនត្រូវដកនូវសិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្តទុកមកហើយ ត្រូវប្រព្រឹត្តកាន់យកតាមសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តទុកមកហើយ ។

[៩៣] ភិក្ខុទាំងឡាយបានឮ (ដំណឹង) ថា ឮថាព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យភិក្ខុអ្នកប្រព្រឹត្តនៅព្រៃ អ្នកប្រព្រឹត្តបិណ្ឌបាត អ្នកប្រព្រឹត្តបំសុកូល ចូលទៅរកតថាគតតាមសប្បាយចុះ ។

១១១

និស្សគ្គិយកណ្ឌេ កោសិយវគ្គស្ស បញ្ចមសិក្ខាបទស្ស សិក្ខាបទនិទានំ

តេ ភគវន្តំ ទស្សនាយ(១) បិហយន្តា(២) សន្ថតានិ ឧជ្ឈិត្វា អារញ្ញកង្គំ បិណ្ឌបាតិកង្គំ បំសុកូលិកង្គំ សមាទិយឹសុ ។ អថខោ ភគវា សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ សេនាសនចារិកំ អាហិណ្ឌន្តោ អទ្ទស សន្ថតានិ តហឹ តហឹ(៣) ឧជ្ឈិតានិ បស្សិត្វាន(៤) ភិក្ខូ អាមន្តេសិ កស្សិមានិ ភិក្ខវេ សន្ថតានិ តហឹ តហឹ ឧជ្ឈិតានីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អ-ថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខូនំ សិក្ខាបទំ បញ្ញាបេស្សាមិ ទស អត្ថវសេ បដិច្ច សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បសន្នានំ

---

១ ឱ. ម. ទស្សនំ ។ ២ ឱ. ម. បិហាន្តា ។ ៣ ឱ. ម. តហំ តហំ ។ ៤ ឱ. ម. បស្សិត្វា ។

ភិក្ខុទាំងនោះ កាលប្រាថ្នានឹងឃើញព្រះដ៏មានព្រះភាគ ទើបលះបោលនូវសន្ថ័តទាំងឡាយ ហើយសមាទានអារញ្ញកង្គធុតង្គ បិណ្ឌបាតិកង្គធុតង្គ និងបំសុកូលិកង្គធុតង្គ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ចារិកសេនាសនៈ ព្រមដោយភិក្ខុទាំងឡាយច្រើនរូប បានទតព្រះនេត្រឃើញនូវសន្ថ័តទាំងឡាយ ដែលពួកភិក្ខុចោលរាត់រាយក្នុងទីនោះ ៗ លុះទតឃើញហើយទើបត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយហេតុអ្វី ពួកអ្នកក៏លះបោលសន្ថ័តទាំងឡាយនេះក្នុងទីនោះ ៗ ។ ទើបភិក្ខុទាំងនោះ ក្រាបទូលព្រះដ៏មានព្រះភាគតាមដំណើរនុ៎ះ ។ ព្រោះនិទាននេះព្រោះដំណើរនេះ ព្រះដ៏មានព្រះភាគទើបទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ដប់យ៉ាងគឺ ដើម្បីសេចក្តីប្រពៃដល់សង្ឃ ១ ដើម្បីសេចក្តីសប្បាយដល់សង្ឃ ១ដើម្បីនឹងសង្កត់សង្កិននូវបុគ្គលទាំងឡាយអ្នកមានគំនិតអាក្រក់ ១ ដើម្បីនៅសប្បាយនៃភិក្ខុទាំងឡាយអ្នកមានសីលជាទីស្រឡាញ់ ១ ដើម្បីឃាត់ហាមនូវអាសវៈទាំងឡាយជាបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមនូវអាសវៈទាំងឡាយដែលនឹងមានទៅខាងមុខ ១ ដើម្បីសេចក្តីជ្រះថ្លានៃបុគ្គលទាំងឡាយ

បសាទាយ បសន្នានំ ភិយ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ និសីទនសន្ថតំ បន ភិក្ខុនា ការយមានេន បុរាណសន្ថតស្ស សាមន្តា សុគតវិទត្ថិ អាទាតព្វា ទុព្វណ្ណករណាយ ។ អនាទា ចេ ភិក្ខុ បុរាណសន្ថតស្ស សាមន្តា សុគតវិទត្ថឹ នវំ និសីទនសន្ថតំ ការាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

[៩៤] និសីទនំ នាម សទសំ វុច្ចតិ ។ សន្ថតំ នាម សន្ថរិត្វា កតំ ហោតិ អវាយិមំ ។ ការយមានោតិ ករោន្តោ វា ការាបេន្តោ វា ។ បុរាណសន្ថតំ នាម សកឹ និវត្ថំ បិ សកឹ បារុតំ បិ ។ សាមន្តា សុគតវិទត្ថិ អាទាតព្វា ទុព្វណ្ណករណាយាតិ ថិរភាវាយ វដ្ដំ វា ចតុរស្សំ វា ឆិន្ទិត្វា ឯកទេសេ វា សន្ថរិតព្វំ វិជដេត្វា វា សន្ថរិតព្វំ ។ អនាទា

អ្នកមិនទាន់ជ្រះថ្លា ១ ដើម្បីញ៉ាំងបុគ្គលអ្នកជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើង ១ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម ១ ដើម្បីសេចក្តីអនុគ្រោះដល់ព្រះវិន័យ ១ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុកាលឲ្យគេធ្វើសន្ថ័តសម្រាប់ទ្រាប់អង្គុយ គប្បីយកសន្ថ័តចាស់ ១ ចំអាមព្រះសុគតដោយជុំវិញ (មកផ្សំលាយនឹងសន្ថ័តថ្មី) ដើម្បីនឹងធ្វើសន្ថ័តថ្មីនោះឲ្យខូចពណ៌ ។ បើភិក្ខុឲ្យគេធ្វើនិសីទនសន្ថ័តថ្មី មិនយកសន្ថ័តចាស់ ១ ចំអាមព្រះសុគតដោយជុំវិញ (មកផ្សំលាយនឹងសន្ថ័តថ្មីទេ) សន្ថ័តនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[៩៤] ដែលហៅថា និសីទនៈនោះ គឺកម្រាលដែលប្រកបដោយជាយ ។ ដែលហៅថា សន្ថ័តនោះ គឺកម្រាលដែលគេគ្រាន់តែស្មាច់មិនបានត្បាញ ។ ត្រង់ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯង ឬឲ្យគេធ្វើ ។ សន្ថ័តសូម្បីស្លៀកម្តង សូម្បីដណ្តប់ម្តង[១] ហៅថា សន្ថ័តចាស់ ។ ពាក្យថា គប្បីយកសន្ថ័តចាស់ ១ ចំអាមព្រះសុគតដោយជុំវិញ (មកលាយនឹងសន្ថ័តថ្មី) ដើម្បីធ្វើសន្ថ័តថ្មីនោះ ឲ្យខូចពណ៌ គឺថា ភិក្ខុត្រូវកាត់ (សន្ថ័តចាស់) ជាវង់មូលក្តី ជាបួនជ្រុងក្តី ហើយយកមកលាតក្រាលលាយចុះក្នុងទីមួយ ឬសិតហើយលាតក្រាលក្តី ដើម្បីធ្វើឲ្យជារបស់ខ្ជាប់ខ្ជួន ។ ពាក្យថា

១ អដ្ឋកថា ពន្យល់ថា អង្គុយម្តង ដេកម្តង ។

ចេ ភិក្ខុ បុរាណសន្ថតស្ស សាមន្តា សុគតវិទត្ថិំ អនាទិយិត្វា បុរាណសន្ថតស្ស សាមន្តា សុគតវិទត្ថឹ នវំ និសីទនសន្ថតំ ករោតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ និសីទនសន្ថតំ អនាទិយិត្វា បុរាណសន្ថតស្ស សាមន្តា សុគតវិទត្ថឹ ការាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[៩៨] អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អត្តនា វិប្បកតំ បរេហិ បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។

បើភិក្ខុមិនយកសន្ថតចាស់ ១ ចំអាមព្រះសុគតដោយជុំវិញ (មកលាយនឹងសន្ថតថ្មីទេ) គឺថា ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី នូវសន្ថតសម្រាប់ទ្រាប់អង្គុយថ្មី មិនយកសន្ថតចាស់ ១ ចំអាមព្រះសុគតដោយជុំវិញមកលាយ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ សន្ថតនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុគប្បីលះដល់សង្ឃ ឬគណៈ ឬបុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថតសម្រាប់ទ្រាប់អង្គុយនេះ ខ្ញុំឲ្យគេធ្វើមិនបានកាត់យកសន្ថតចាស់ ១ ចំអាមព្រះសុគតដោយជុំវិញមកលាយ ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថតនេះដល់សង្ឃ ។ បេ ។ សង្ឃគប្បីឲ្យ ។ បេ ។ លោកដ៏មានអាយុទាំងឡាយ គប្បីឲ្យ ។ បេ ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[៩៥] ភិក្ខុធ្វើសន្ថតដោយខ្លួនឯងនៅមិនទាន់ហើយ (គ្រាក្រោយ) ធ្វើឲ្យហើយដោយខ្លួនឯងម្តងទៀត ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុធ្វើខ្លួនឯងមិនទាន់ហើយ ឲ្យអ្នកដទៃបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។ អ្នកដទៃធ្វើមិនទាន់ហើយ ភិក្ខុធ្វើឲ្យហើយដោយខ្លួនឯង ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។ អ្នកដទៃធ្វើមិនទាន់ហើយ ភិក្ខុឲ្យអ្នកដទៃធ្វើបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុធ្វើខ្លួនឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ដើម្បីប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។

[៩៦] អជាបត្តិ បុរាណសង្ឃតស្ស សាមណ្ណា សុគ-តវិជត្តី អាជិយិត្វា ករោតិ អលកង្គោ ថោកតរំ អាជិយិត្វា ករោតិ អលកង្គោ អជាជិយិត្វា ករោតិ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ វិតានំ វា កុម្ភត្ថរណំ វា សាណិចាការំ វា ភិសឹ វា ពិម្ពោហនំ វា ករោតិ ឧម្មត្តកស្ស អាជិកម្មិកស្សាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។

[៩៦] *អាបត្តិមិនមានដល់ភិក្ខុធ្វើសន្ថ័តថ្មីយកសន្ថ័តចាស់ ១ ចំអាមព្រះសុគតដោយជុំវិញមកលាយ មិនមានដល់ភិក្ខុកាលរកសន្ថ័តចាស់មិនបាន ១ ចំអាមធ្វើលាយតែបន្តិច មិនមានដល់ភិក្ខុកាលរកសន្ថ័តចាស់បន្តិចមិនបានធ្វើមិនបានលាយ មិនមានដល់ភិក្ខុបានសន្ថ័តដែលអ្នកដទៃធ្វើយកមកប្រើប្រាស់ មិនមានដល់ភិក្ខុធ្វើជាពិតានក្តី ជាកម្រាលផ្ទៃដែលគេបូកលាបក្តី ជារនាំងបាំងក្តី ជាពូកក្តី ជាខ្នើយក្តី មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។*

សិក្ខាបទទី ៥ ចប់ ។

# ឆដ្ឋសិក្ខាបទំ

[៩៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ កោស-លេសុ ជនបទេសុ សាវត្ថឹ គច្ឆន្តស្ស អន្តរាមគ្គេ ឯឡកលោមានិ ឧប្បជ្ជឹសុ ។ អថខោ សោ ភិក្ខុ តានិ ឯឡកលោមានិ ឧត្តរាសង្គេន ភណ្ឌិកំ ពន្ធិត្វា អគមាសិ ។ មនុស្សា តំ ភិក្ខុំ បស្សិត្វា ឧប្បណ្ឌេសុំ កិត្តកេន តេ ភន្តេ កីតានិ កិត្តកោ ឧទយោ ភវិស្សតីតិ ។ សោ ភិក្ខុ តេហិ មនុស្សេហិ ឧប្បណ្ឌិ-យមានោ មង្កុ អហោសិ ។ អថខោ សោ ភិក្ខុ សាវត្ថឹ គន្ត្វា តានិ ឯឡកលោមានិ ឋិតកោ វ អាសុម្ភិ ។ ភិក្ខូ តំ ភិក្ខុំ ឯវមាហំសុ[១] កិស្ស ត្វំ អាវុសោ ឥមានិ ឯឡកលោមានិ ឋិតកោ វ អាសុម្ភសីតិ ។ តថា ហិ បនាហំ អាវុសោ ឥមេសំ

១ ឱ. ម. ឯតទវោចុំ ។

# សិក្ខាបទទី ៦

[៩៧] *សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេត-ពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក៏គ្រានោះឯង កាលភិក្ខុមួយរូបទៅកាន់ក្រុងសាវត្ថី ក្នុងកោសលជនបទ ក៏បានរោមចៀមជាច្រើនក្នុងពាក់កណ្តាលផ្លូវ* (*ដោយទាយកប្រគេន*) *។ ភិក្ខុនោះ ក៏ចងវេចរោមចៀមទាំងឡាយនោះ ដាបង្វេចដោយឧត្តរាសង្គ* (*ចីពរ*) *ហើយទៅ ។ មនុស្សទាំងឡាយឃើញភិក្ខុនោះហើយនាំគ្នានិយាយចំអកថា ព្រះករុណារោមចៀមព្រះករុណាទិញមកថ្លៃប៉ុន្មាន នឹងបានចំណេញប៉ុន្មាន ។ កាលមនុស្សទាំងឡាយនោះ និយាយចំអកដូច្នោះហើយ ភិក្ខុនោះ ក៏មានសេចក្តីអៀនខ្មាស ។ លុះភិក្ខុនោះ ទៅដល់ក្រុងសាវត្ថី ក៏ឈរទំលាក់រោមចៀមទាំងនោះ ។ ភិក្ខុទាំងឡាយបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ អ្នកឈរទំលាក់ចោលនូវរោមចៀមទាំងនេះដើម្បីអ្វី ។ ភិក្ខុនោះ និយាយតបថា អាវុសោ ព្រោះហេតុតែរោមចៀមទាំងនេះ បានជាមនុស្សទាំងឡាយនាំគ្នានិយាយចំអកខ្ញុំ ហេតុនេះឯង*

ឯឡកលោមានំ ការណា មនុស្សេហិ ឧប្បណ្ឌិតោតិ ។ កីវទូរតោ បន ត្វំ អាវុសោ ឥមានិ ឯឡកលោមានិ អាហរសីតិ ។ អតិរេកតិយោជនំ អាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម ភិក្ខុ អតិរេកតិយោជនំ ឯឡកលោមានិ អាហរិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ត្វំ ភិក្ខុ អតិរេកតិយោជនំ ឯឡកលោមានិ អាហរសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស អតិរេកតិយោជនំ ឯឡកលោមានិ អាហរិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ភិក្ខុនោ បនេវ អទ្ធានមគ្គប្បដិបន្នស្ស ឯឡកលោមានិ ឧប្បជ្ជេយ្យុំ អាកង្ខមានេន ភិក្ខុនា បដិគ្គហេតព្វានិ បដិគ្គហេត្វា តិយោជនបរមំ សហត្ថា

(ទើបខ្ញុំទំលាក់ចោលចេញ) ។ ភិក្ខុទាំងឡាយនោះសួរថា ម្នាលអាវុសោក៏លោកនាំយករោមចៀមទាំងនេះមកអំពីទីមានចម្ងាយប៉ុន្មាន ។ ភិក្ខុនោះឆ្លើយថា អាវុសោ ខ្ញុំនាំរោមចៀមទាំងនេះមកអស់ទីឆ្ងាយជាងបីយោជន៍ ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុមិនសមបើនឹងនាំយករោមចៀមមកឆ្ងាយជាងបីយោជន៍ដូច្នេះឡើយ ។ គ្រានោះ ភិក្ខុទាំងនោះ ក៏ក្រាបទូលដំណើរនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងនាំយករោមចៀមមកឆ្ងាយជាងបីយោជន៍ ពិតមែនឬ ។ ភិក្ខុនោះ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស ហេតុដូចម្ដេចបានជាអ្នកឯង នាំយករោមចៀមមកកាន់ចម្ងាយផ្លូវជាងបីយោជន៍ដូច្នេះ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យកើតសេចក្ដីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ មិនមែនញុំាងអ្នកដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា រោមចៀមទាំងឡាយកើតឡើងដល់ភិក្ខុអ្នកដើរផ្លូវឆ្ងាយ កាលបើភិក្ខុប្រាថ្នា គប្បីទទួលយកបាន លុះទទួលហើយ បើមិនមានអ្នកនាំយកទៅឲ្យទេ គប្បីនាំយកទៅ

ហារេតព្វានិ អសន្តេ ហារកេ តតោ ចេ ឧត្តរឹ ហារេយ្យ អសន្តេបិ ហារកេ និស្សគ្គិយំ បាចិត្តិយន្តិ ។

[៩៨] ភិក្ខុនោ បនេវ អទ្ធានមគ្គប្បដិបន្នស្សាតិ បថំ គច្ឆន្តស្ស ។ ឯឡកលោមានិ ឧប្បជ្ជេយ្យុន្តិ ឧប្បជ្ជេយ្យុំ សង្ឃតោ វា គណតោ វា ញាតិតោ វា មិត្តតោ វា បំសុកូលតោ វា អត្តនោ វា ធនេន ។ អាកង្ខមានេនាតិ ឥច្ឆមានេន បដិគ្គហេតព្វានិ ។ បដិគ្គហេត្វា តិយោជនបរមំ សហត្ថា ហារេតព្វានីតិ តិយោជនបរមតា សហត្ថា ហារេតព្វានិ ។ អសន្តេ ហារកេតិ ន អញ្ញោ កោចិ ហារកោ ហោតិ ឥត្ថី វា បុរិសោ វា គហដ្ឋោ វា បព្វជិតោ វា ។ តតោ ចេ ឧត្តរឹ ហារេយ្យ អសន្តេបិ ហារកេតិ បឋមំ បាទំ តិយោជនំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ទុតិយំ បាទំ អតិក្កាមេតិ និស្សគ្គិយានិ ហោន្តិ[១] អន្តោតិយោជនេ ឋិតោ ពហិតិយោជនំ បាតេតិ និស្សគ្គិយានិ ហោន្តិ[២] អញ្ញស្ស យានេ វា ភណ្ឌេ វា

១-២ និស្សគ្គិយំ បាចិត្តិយន្តិ សព្វត្ថ អាគតំ ។

ដោយដៃខ្លួនឯងកាន់ចម្ងាយផ្លូវយ៉ាងច្រើនត្រឹមបីយោជន៍ កាលបើមិនមានអ្នកនាំយកទៅឲ្យទេ ភិក្ខុនាំយករោមចៀមទៅដោយខ្លួនឯង លើសពីកំណត់នោះទៅ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[៩៨] ត្រង់ពាក្យថា ភិក្ខុអ្នកដើរផ្លូវឆ្ងាយ គឺភិក្ខុអ្នកដើរទៅតាមផ្លូវ ។ ពាក្យថា រោមចៀមទាំងឡាយកើតឡើង គឺថា រោមចៀមទាំងឡាយកើតឡើងអំពីសង្ឃក្តី អំពីគណៈក្តី អំពីញាតិក្តី អំពីមិត្រក្តី អំពីបង្សុកូលក្តី ដោយទ្រព្យរបស់ខ្លួនក្តី ។ ពាក្យថា កាលបើភិក្ខុប្រាថ្នា គឺថា កាលបើភិក្ខុចង់បានត្រូវទទួលយកបាន ។ ពាក្យថា លុះទទួលហើយ គប្បីនាំទៅដោយដៃខ្លួនឯងកាន់ចម្ងាយផ្លូវយ៉ាងច្រើនត្រឹមបីយោជន៍ គឺថា ភិក្ខុគប្បីនាំទៅដោយដៃខ្លួនឯងត្រឹមបីយោជន៍យ៉ាងច្រើន ។ ពាក្យថា បើមិនមានអ្នកនាំយកទៅឲ្យ គឺគ្មានអ្នកដទៃនីមួយ ស្រីក្តី ប្រុសក្តី គ្រហស្ថក្តី បព្វជិតក្តី នាំយកទៅឲ្យ ។ ពាក្យថា កាលបើមិនមានអ្នកនាំយកទៅឲ្យទេ ភិក្ខុនាំយករោមចៀមទៅដោយខ្លួនឯងលើសពីកំណត់នោះទៅ គឺថា ភិក្ខុឈានជំហានទី ១ ឲ្យលើសអំពីបីយោជន៍ទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី ២ ឲ្យលើសទៅ រោមចៀមទាំងនោះ ជានិស្សគ្គិយ កាលភិក្ខុឋិតនៅក្នុងខាងក្នុងបីយោជន៍ តែចោលរោមចៀមឲ្យធ្លាក់ចុះខាងក្រៅបីយោជន៍ រោមចៀមទាំងនោះក៏ជានិស្សគ្គិយ ភិក្ខុដាក់ចុះនូវរោមចៀមក្នុងយានក្តី ក្នុងបង្វេចក្តីនៃអ្នកដទៃ

អជានន្តស្ស បក្កមិត្វា តិយោជនំ អតិក្កាមេតិ និស្សគ្គិយានិ ហោន្តិ និស្សជ្ជិតព្វានិ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វានិ ។ បេ ។ ឥមានិ មេ ភន្តេ ឯឡកលោមានិ តិយោជនំ អតិក្កាមិតានិ និស្សគ្គិយានិ ឥមាជាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[៩៩] អតិរេកតិយោជនេ អតិរេកសញ្ញី តិយោជនំ[១] អតិក្កាមេតិ និស្សគ្គិយំ បាចិត្តិយំ ។ អតិរេកតិយោជនេ វេមតិកោ តិយោជនំ អតិក្កាមេតិ និស្សគ្គិយំ បាចិត្តិយំ ។ អតិរេកតិយោជនេ ឩនកសញ្ញី តិយោជនំ អតិក្កាមេតិ និស្សគ្គិយំ បាចិត្តិយំ ។ ឩនកតិយោជនេ អតិរេកសញ្ញី អាបត្តិ ទុក្កដស្ស ។ ឩនកតិយោជនេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឩនកតិយោជនេ ឩនកសញ្ញី អនាបត្តិ ។

១ ឱ. ម. បោត្ថកេសុ អយំ បាឋោ ន ហោតិ ។

គេមិនដឹង ឲ្យកន្លងបីយោជន៍ទៅ រោមចៀមទាំងនោះ ក៏ជានិស្សគ្គិយ ភិក្ខុគប្បីលះដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីលះយ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន រោមចៀមទាំងឡាយនេះ ខ្ញុំបាននាំមកឲ្យលើសអំពីបីយោជន៍ទៅហើយ ជានិស្សគ្គិយ ខ្ញុំសូមលះនូវរោមចៀមទាំងឡាយនេះដល់សង្ឃ ។ បេ ។ សង្ឃគប្បីឲ្យ ។ បេ ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។ បេ ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[៩៩] ទីលើសអំពីបីយោជន៍ ភិក្ខុសំគាល់ថា លើសមែន ហើយនាំរោមចៀមឲ្យលើសអំពីបីយោជន៍ទៅ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ទីលើសអំពីបីយោជន៍ ភិក្ខុសង្ស័យហើយនាំរោមចៀមឲ្យលើសអំពីបីយោជន៍ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ទីលើសអំពីបីយោជន៍ ភិក្ខុសំគាល់ថា មិនទាន់លើស ហើយនាំរោមចៀមឲ្យលើសអំពីបីយោជន៍ទៅ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ទីខ្វះអំពីបីយោជន៍ ភិក្ខុសំគាល់ថាលើស ត្រូវអាបត្តិទុក្កដ ។ ទីខ្វះអំពីបីយោជន៍ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ទីខ្វះអំពីបីយោជន៍ ភិក្ខុសំគាល់ថា ខ្វះមែន មិនត្រូវអាបត្តិ ។

១១៩

និស្សគ្គិយកណ្ឌេ កោសិយវគ្គស្ស ឆដ្ឋសិក្ខាបទស្ស អនាបត្តិ

[១០០] អនាបត្តិ តិយោជនំ ហរតិ ឩនកតិយោជនំ ហរតិ តិយោជនំ ហរតិបិ បច្ចាហរតិបិ តិយោជនំ វាសាធិប្បាយោ គន្ត្វា តតោ បរំ ហរតិ អច្ឆិន្នំ បដិលភិត្វា ហរតិ និស្សដ្ឋំ បដិលភិត្វា ហរតិ អញ្ញំ ហរាបេតិ កតភណ្ឌំ ហរតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។

និស្សគ្គិយកណ្ឌ កោសិយវគ្គ សិក្ខាបទទី ៦ វារៈដែលមិនត្រូវអាបត្តិ

[១០០] *អាបត្តិមិនមានដល់ភិក្ខុនាំយករោមចៀម ទៅត្រឹមបីយោជន៍ មិនមានដល់ភិក្ខុនាំយកទៅថយអំពីបីយោជន៍ មិនមានដល់ភិក្ខុនាំយកទៅក្តី នាំត្រឡប់មកក្តី ត្រឹមបីយោជន៍ មិនមានដល់ភិក្ខុប្រាថ្នា ដើម្បីនឹងនៅ តែត្រូវទៅកាន់ទីមានចម្ងាយផ្លូវបីយោជន៍ ហើយនាំយករោមចៀមទៅកាន់ទីដទៃចាកទីនោះ*[១] *មិនមានដល់ភិក្ខុត្រឡប់បានរោមចៀម ដែលចោរលួចយកទៅហើយនាំយកទៅ មិនមានដល់ភិក្ខុត្រឡប់បានរោមចៀម ដែលលះបង់ដោយវិនយកម្មហើយនាំយកទៅ មិនមានដល់ភិក្ខុឲ្យអ្នកដទៃនាំយកទៅ មិនមានដល់ភិក្ខុនាំយករបស់ដែលធ្វើហើយ (ធ្វើសម្រេចជាសំពត់កម្ពល និងព្រំ និងសន្ថតជាដើម) មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។*

សិក្ខាបទទី ៦ ចប់ ។

---

១ ភិក្ខុនាំរោមចៀមទៅនៅក្នុងទីណាៗ មានចម្ងាយបីៗ យោជន៍ ហើយមិនបានប្រកបដោយកិច្ចមានឧទ្ទេស និងបរិបុច្ឆាជាដើម ឬដោយសក្ការមានបច្ច័យជាដើមក្នុងទីនោះ ហើយនឹងនាំរោមចៀមចេញអំពីទីនោះ ទៅកាន់ទីដទៃៗ កំណត់ត្រឹមតែបីៗ យោជន៍ ក៏បាន ដរាបដល់រយយោជន៍ ក៏បាន ។

# សត្តមសិក្ខាបទំ

[១០១] តេន សមយេន ពុទ្ធោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភិក្ខុនីហិ ឯឡក-លោមានិ ធោវាបេន្តិបិ រជាបេន្តិបិ វិជដាបេន្តិបិ ។ ភិក្ខុនិយោ ឯឡកលោមានិ ធោវន្តិយោ រជន្តិយោ វិជដេន្តិយោ រិញ្ចន្តិ ឧទ្ទេសំ បរិបុច្ឆំ អធិសីលំ អធិចិត្តំ អធិប្បញ្ញំ ។ អថខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ មហាបជាបតឹ គោតមឹ ភគវា ឯតទវោច កច្ចិ គោតមិ ភិក្ខុនិយោ អប្បមត្តា អាតាបិនិយោ បហិតត្តា វិហរន្តីតិ ។ កុតោ ភន្តេ ភិក្ខុនីនំ អប្បមាទោ អយ្យា ឆព្វគ្គិយា[១] ភិក្ខុនីហិ ឯឡក-លោមានិ ធោវាបេន្តិបិ រជាបេន្តិបិ វិជដាបេន្តិបិ

១ ឥតោ បរំ សព្វត្ថ ភិក្ខូតិ បាឋោ ទិស្សតិ ។ សោ អតិរេកោតិ ទដ្ឋព្វោ ។

# សិក្ខាបទទី ៧

[១០១] សម័យនោះ សម្តេចព្រះសម្ពុទ្ធដ៏ទ្រង់យស ទ្រង់គង់ក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងសក្កជនបទ ។ គ្រានោះឯង ពួកភិក្ខុឆព្វគ្គិយ ប្រើនាងភិក្ខុនីទាំងឡាយឲ្យលាងខ្លះ ឲ្យជ្រលក់ខ្លះ ឲ្យសិត ឬត្រដោះខ្លះ នូវរោមចៀមទាំងឡាយ ។ ភិក្ខុនីទាំងឡាយកាល (ធ្វើកិច្ច) លាង ជ្រលក់ សិត នូវរោមចៀម (ដូច្នោះ) ទើបលះចោលនូវការរៀនសូត្របាលី អដ្ឋកថា និងអធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា ។ គ្រានោះ នាងមហាបជាបតិគោតមីភិក្ខុនី ចូលទៅគាល់សម្តេចព្រះដ៏មានព្រះភាគ លុះចូលទៅហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយបានឋិតក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគមានបន្ទូលនឹងនាងមហាបជាបតិគោតមី ដែលកំពុងឋិតនៅក្នុងទីដ៏សមគួរយ៉ាងនេះថា នែព្រះនាងគោតមី នាងភិក្ខុនីទាំងឡាយ ជាអ្នកមិនប្រមាទ ជាអ្នកមានព្យាយាមដុតកំដៅបាប ជាអ្នកមានចិត្តបញ្ជូនទៅ កាន់ព្រះនិព្វានដែរឬទេ ។ ព្រះនាងមហាបជាបតិគោតមីទូលថា បពិត្រព្រះអង្គ ពួកនាងភិក្ខុនីមិនប្រមាទឯណាបាន លោកម្ចាស់ឆព្វគ្គិយទាំងឡាយ ប្រើពួកនាងភិក្ខុនីឲ្យលាងខ្លះ ឲ្យជ្រលក់ខ្លះ ឲ្យសិតខ្លះ នូវរោមចៀមទាំងឡាយ

ភិក្ខុនិយោ ឯឡកលោមានិ ធោវន្តិយោ រជន្តិយោ វិជដេន្តិយោ រិញ្ចន្តិ ឧទ្ទេសំ បរិបុច្ឆំ អធិសីលំ អធិចិត្តំ អធិប្បញ្ញន្តិ ។ អថខោ ភគវា មហាប-ជាបតឹ គោតមឹ ធម្មិយា កថាយ សន្ទស្សេសិ ស-មាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ មហាបជាបតី គោតមី ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ឆព្វគ្គិយេ ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខុនីហិ ឯឡកលោមានិ ធោវាបេថ រជាបេថ វិជដាបេថាតិ ។ សច្ចំ ភគវាតិ ។ ញាតិកាយោ តុម្ហាកំ ភិក្ខវេ អញ្ញាតិ-កាយោតិ ។ អញ្ញាតិកាយោ ភគវាតិ ។ អញ្ញាតិ-កា មោឃបុរិសា អញ្ញាតិកានំ ន ជានន្តិ បដិរូបំ វា

និស្សគ្គិយកណ្ឌ កោសិយវគ្គ សិក្ខាបទទី ៧ និទាននៃសិក្ខាបទ

កាលបើភិក្ខុនីទាំងឡាយមានរវល់ លាង ជ្រលក់ សិត នូវរោមចៀមទាំងឡាយ (ដូច្នោះហើយ) ទើបលះចោលការរៀនសូត្របាលី អដ្ឋកថា និងអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ព្រះនាងមហាបជាបតិគោតមី ឲ្យឃើញ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថា ។ គ្រានោះ ព្រះនាងមហាបជា-បតិគោតមី កាលបើព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណចៀសចេញទៅ ។ ព្រោះនិទាននេះ ព្រោះដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំនូវភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ពួកភិក្ខុឆព្វគ្គិយថា នែភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយប្រើពួកនាងភិក្ខុនីឲ្យលាងខ្លះ ឲ្យជ្រលក់ខ្លះ ឲ្យសិតខ្លះ នូវរោមចៀមទាំងឡាយ ពិតមែនឬទេ ។ ពួកភិក្ខុឆព្វគ្គិយទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះដ៏មានព្រះភាគ ត្រាស់សួរថា នែភិក្ខុទាំងឡាយ ពួកនាងភិក្ខុនីទាំងនោះ ជាញាតិរបស់អ្នកទាំងឡាយ ឬមិនមែនជាញាតិទេ ។ ពួកភិក្ខុឆព្វគ្គិយទូលថា សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុនីទាំងនោះមិនមែនជាញាតិទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែមោឃបុរសទាំងឡាយ ជនទាំងឡាយដែលមិនមែនជាញាតិ រមែងមិនដឹងនូវកម្មដ៏សមគួរ

អប្បដិរូបំ វា ចាសាទិកំ វា អប្បាសាទិកំ វា តត្ថ ជាម តុម្ហេ មោឃបុរិសា អញ្ញាតិកាហិ ភិក្ខុនីហិ ឯឡកលោមានិ ធោវាបេស្សថបិ រជាបេស្សថបិ វិជដាបេស្សថបិ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ឯឡក-លោមានិ ធោវាបេយ្យ វា រជាបេយ្យ វា វិជដាបេយ្យ វា និស្សគ្គិយំ ចាចិត្តិយន្តិ ។

[១០២] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អញ្ញាតិកា នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហាយុគា អសម្ពទ្ធា ។ ភិក្ខុនី នាម ឧភតោសង្ឃេ ឧបសម្បន្នា ។ ធោវាតិ អាណាបេតិ អាបត្តិ ទុក្កដស្ស ធោតានិ និស្សគ្គិយានិ ហោន្តិ ។

ឬមិនសមគួរ និងកម្មជាទីជ្រះថ្លា ឬមិនជាទីជ្រះថ្លានៃស្រ្តីទាំងឡាយដែលមិនមែនជាញាតិទេ នៃមោឃបុរសទាំងឡាយ កាលបើអំពើដែលប្រកបដោយទោសយ៉ាងនេះ ពួកអ្នកក៏ហ៊ានប្រើភិក្ខុនីទាំងឡាយ ដែលមិនមែនជាញាតិឲ្យលាងខ្លះ ឲ្យជ្រលក់ខ្លះ ឲ្យសិតខ្លះ នូវរោមចៀមទាំងឡាយនៃមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ឬមួយនាំបុគ្គលដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយប្រើនាងភិក្ខុនីមិនមែនជាញាតិ ឲ្យលាងក្តី ឲ្យជ្រលក់ក្តី ឲ្យសិត ឬគ្រដោះក្តីនូវរោមចៀមទាំងឡាយ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[១០២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយ ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ភិក្ខុនីដែលមិនជាប់សាច់ញាតិអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបអំពីគូនៃជីដូនជីតាជាគម្រប់ ៧ ត ឈ្មោះថា មិនមែនជាញាតិ ។ ស្រីបានឧបសម្បទា ក្នុងឧភតោសង្ឃ[១] ឈ្មោះថា នាងភិក្ខុនី ។ ភិក្ខុបង្គាប់ថា នាងចូរលាងដូច្នេះត្រូវអាបត្តិទុក្កដ រោមចៀមដែលលាងហើយនោះ ជានិស្សគ្គិយ ។

១ បានដល់សង្ឃពីរចំណែក គឺភិក្ខុសង្ឃមួយចំណែក ភិក្ខុនីសង្ឃមួយចំណែក ។

រជាតិ អាណាបេតិ អាបត្តិ ទុក្កដស្ស រត្តានិ និស្សគ្គិយានិ ហោន្តិ ។ វិជដេហីតិ អាណាបេតិ អាបត្តិ ទុក្កដស្ស វិជដិតានិ និស្សគ្គិយានិ ហោន្តិ និស្សជ្ជិតព្វានិ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វានិ ។ បេ ។ ឥមានិ មេ ភន្តេ ឯឡកលោមានិ អញ្ញាតិកាយ ភិក្ខុនិយា ធោវាបិតានិ និស្សគ្គិយានិ ឥមានាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[១០៣] អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ ធោវាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ ធោវាបេតិ រជាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ ធោវាបេតិ វិជដាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ ធោវាបេតិ

ភិក្ខុបង្គាប់ថា នាងចូរជ្រលក់ដូច្នេះ ត្រូវអាបត្តិទុក្កដ រោមចៀមដែលជ្រលក់ហើយនោះ ជានិស្សគ្គិយ ។ ភិក្ខុបង្គាប់ថា នាងចូរសិត ឬត្រដោះដូច្នេះ ត្រូវអាបត្តិទុក្កដ រោមចៀមដែលសិត ឬត្រដោះហើយ ជានិស្សគ្គិយ រោមចៀមដែលជានិស្សគ្គិយនោះ ភិក្ខុគប្បីលះដល់សង្ឃ ឬគណៈ ឬបុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីលះយ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន រោមចៀមទាំងនេះ ខ្ញុំបានប្រើនាងភិក្ខុនី មិនមែនជាញាតិ ឲ្យលាងហើយ ជានិស្សគ្គិយ ខ្ញុំសូមលះរោមចៀមទាំងនេះ ដល់សង្ឃ ។ បេ ។ សង្ឃគប្បីឲ្យ ។ បេ ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។ បេ ។ ខ្ញុំឲ្យដល់លោកដ៏មានអាយុ ។

[១០៣] ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យលាងនូវរោមចៀមទាំងឡាយ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យលាង ឲ្យជ្រលក់ នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យលាង ឲ្យសិត នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យលាង ឲ្យជ្រលក់ ឲ្យសិត

វជាបេតិ វិជជាបេតិ និស្សគ្គិយេន អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ វជាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ វជាបេតិ វិជជាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ វជាបេតិ ជោវាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ វជាបេតិ វិជជាបេតិ ជោវាបេតិ និស្សគ្គិយេន អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ វិជជាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ វិជជាបេតិ ជោវាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ វិជជាបេតិ វជាបេតិ និស្សគ្គិយេន អាបត្តិ ទុក្កដស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី ឯឡកលោមានិ វិជជាបេតិ ជោវាបេតិ វជាបេតិ

នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដពីរ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យជ្រលក់ នូវរោមចៀមទាំងឡាយ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យជ្រលក់ ឲ្យសិត នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យជ្រលក់ ឲ្យលាង នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យជ្រលក់ ឲ្យសិត ឲ្យលាង នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដពីរ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យសិត នូវរោមចៀមទាំងឡាយ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យសិត ឲ្យលាង នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យសិត ឲ្យជ្រលក់នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឲ្យសិត ឲ្យលាង ឲ្យជ្រលក់

និស្សគ្គិយេន អាបត្តិ ទ្វិន្នំ ទុក្កដានំ ។ អញ្ញាតិកាយ វេមតិកោ ។ បេ ។ អញ្ញាតិកាយ ញាតិកសញ្ញី ។ បេ ។ អញ្ញស្ស ឯឡកលោមានិ ធោវាបេតិ អាបត្តិ ទុក្កដស្ស ។ ឯកតោ ឧបសម្បន្នាយ ធោវាបេតិ អាបត្តិ ទុក្កដស្ស ។ ញាតិកាយ អញ្ញាតិកសញ្ញី អាបត្តិ ទុក្កដស្ស ។ ញាតិកាយ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ញាតិកាយ ញាតិកសញ្ញី អនាបត្តិ ។

[១០៤] អនាបត្តិ ញាតិកាយ ធោវន្តិយា អញ្ញាតិកា ទុតិយា ហោតិ អវុត្តា ធោវតិ អបរិភុត្តំ កតភណ្ឌំ ធោវាបេតិ សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។

នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដពីរ និងនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសង្ស័យ ។ បេ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ ។ បេ ។ ភិក្ខុប្រើភិក្ខុនីឲ្យលាងនូវរោមចៀមភិក្ខុដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រើភិក្ខុនីដែលបានឧបសម្បទា អំពីឯកតោសង្ឃឲ្យលាង ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថា ជាញាតិ មិនត្រូវអាបត្តិអ្វីឡើយ ។

[១០៤] អាបត្តិមិនមានដល់ភិក្ខុ ដែលឲ្យភិក្ខុនីជាញាតិលាងរោមចៀម ស្រាប់តែមានភិក្ខុនីឯទៀតមិនមែនជាញាតិ (មកកាន់យករោមចៀមអំពីដៃភិក្ខុនីនោះ ទៅលាងឲ្យ) មិនមានដល់ភិក្ខុដែលមិនប្រើ ស្រាប់តែភិក្ខុនីមិនមែនជាញាតិ យករោមចៀមទៅលាងឲ្យ មិនមានដល់ភិក្ខុដែលប្រើភិក្ខុនីមិនមែនជាញាតិឲ្យលាងភណ្ឌដទៃ ដែលធ្វើហើយនៅមិនទាន់ប្រើប្រាស់ មិនមានដល់ភិក្ខុដែលប្រើនាងសិក្ខមានាឲ្យលាង មិនមានដល់ភិក្ខុដែលប្រើនាងសាមណេរីឲ្យលាង (នូវរោមចៀមទាំងឡាយ) មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

# អដ្ឋមសិក្ខាបទំ

[១០៨] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ អញ្ញតរស្ស កុលស្ស កុលូបកោ ហោតិ និច្ចភត្តិកោ ។ យំ តស្មឹ កុលេ ឧប្បជ្ជតិ ខាទនីយំ វា ភោជនីយំ វា តតោ អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស បដិវិសោ ឋបិតោ ហោតិ[១] ។ តេន ខោ បន សមយេន សាយំ តស្មឹ កុលេ មំសំ ឧប្បន្នំ ហោតិ ។ តតោ អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស បដិវិសោ ឋបិតោ ហោតិ ។ តស្ស កុលស្ស ទារកោ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ រោទតិ មំសំ មេ ទេថាតិ ។ អថខោ សោ បុរិសោ បជាបតឹ ឯតទវោច អយ្យស្ស បដិវិសំ ទារកស្ស ទេហិ អញ្ញំ ចេតាបេត្វា អយ្យស្ស ទស្សាមាតិ ។ អថខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ

១ ឱ. ម. ឋបិយ្យតិ ។

# សិក្ខាបទទី ៨

[១០៥] សម័យនោះ សម្តេចព្រះសម្ពុទ្ធដ៏មានបុញ្ញសិរី ទ្រង់គង់ក្នុងអារាមវេឡុវន កលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ឧបនន្ទភិក្ខុដ៏មានអាយុ ជាសក្យបុត្តជាជីតុនរបស់ត្រកូលមួយ ជាអ្នកទទួលកត្តជានិច្ច ។ ខាទនីយក្តី ភោជនីយក្តី ឯណាមួយ កើតឡើងក្នុងត្រកូលនោះ ត្រកូលនោះ តោងបែងចំណែកអំពីនោះ ទុកឲ្យឧបនន្ទភិក្ខុសក្យបុត្ត ។ ក៏វេលានោះឯង ត្រកូលនោះ បានសាច់មកក្នុងវេលាល្ងាច ។ ត្រកូលនោះ បានបែងចំណែកសាច់នោះ ទុកប្រគេនឧបនន្ទសក្យបុត្តដ៏មានអាយុ ។ ក្មេងតូចនៃត្រកូលនោះ ភ្ញាក់ពីព្រលឹមហើយស្រែកយំទារសាច់ថា ឲ្យសាច់មកខ្ញុំ ។ បុរសប្តីនោះ ទើបនិយាយនឹងប្រពន្ធយ៉ាងនេះថា នាងចូរឲ្យចំណែកសាច់របស់លោកម្ចាស់ដល់ក្មេងនេះទៅ យើងចាំទិញសាច់ដទៃប្រគេនលោកវិញ ។ វេលានោះ ឧបនន្ទសក្យបុត្តដ៏មានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រចីវរ ក្នុងសម័យព្រឹកព្រហាម

១២៧

## និស្សគ្គិយកណ្ឌេ កោសិយវគ្គស្ស អដ្ឋមសិក្ខាបទស្ស សិក្ខាបទនិទានំ

យេន តំ កុលំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សោ បុរិសោ យេនាយស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច ហិយ្យោ ខោ ភន្តេ សាយំ មំសំ ឧប្បន្នំ តតោ អយ្យស្ស បដិវិសោ ឋបិតោ អយំ ភន្តេ ទារកោ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ រោទតិ មំសំ មេ ទេថាតិ អយ្យស្ស បដិវិសោ ទារកស្ស ទិន្នោ កហាបណេន ភន្តេ កឹ អាហរិយតូតិ ។ បរិច្ចត្តោ មេ អាវុសោ កហាបណោតិ ។ អាម ភន្តេ បរិច្ចត្តោតិ ។ តញ្ញេវ មេ អាវុសោ កហាបណំ ទេហីតិ ។ អថខោ សោ បុរិសោ អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស កហាបណំ ទត្វា ឧជ្ឈាយតិ ខីយតិ វិបាចេតិ យថេវ មយំ រូបិយំ បដិគ្គណ្ហាម ឯវមេវិមេ សមណា

ហើយដើរចូលទៅកាន់ត្រកូលនោះ លុះទៅដល់ហើយ បានអង្គុយលើអាសនៈដែលគេតាក់តែងបម្រុងទុក ។ បុរសនោះទើបចូលទៅរកឧបនន្ទសក្យបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ បានថ្វាយបង្គំឧបនន្ទសក្យបុត្តដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ កាលបុរសនោះ អង្គុយក្នុងទីដ៏សមគួរហើយ បាននិយាយនឹងឧបនន្ទសក្យបុត្តដ៏មានអាយុយ៉ាងនេះថា ព្រះករុណា ខ្ញុំករុណាបានសាច់ក្នុងពេលល្ងាចម្សិលមិញ ខ្ញុំបានបែងចំណែកសាច់នោះ ទុកប្រគេនលោកម្ចាស់ បពិត្រលោកម្ចាស់ ក្មេងតូចនេះភ្ញាក់ពីព្រលឹមឡើងស្រែកយំទារថា ឲ្យសាច់មកខ្ញុំ ខ្ញុំករុណាបានយកសាច់ចំណែករបស់លោកម្ចាស់ឲ្យក្មេងតូចទៅហើយ ព្រះករុណា លោកម្ចាស់នឹងឲ្យខ្ញុំទិញអ្វីមកដោយកហាបណៈ (នេះ) ។ ឧបនន្ទដ៏មានអាយុសួរថា អាវុសោ អ្នកបរិច្ចាគកហាបណៈដល់អាត្មាឬ ។ បុរសនោះ តបថា ព្រះករុណាលោកម្ចាស់ ខ្ញុំករុណាបរិច្ចាគដល់លោកម្ចាស់ ។ ឧបនន្ទភិក្ខុនិយាយថា អាវុសោ អ្នកចូរប្រគេនកហាបណៈនោះដល់អាត្មាចុះ ។ បុរសនោះទើបប្រគេនកហាបណៈទៅឧបនន្ទសក្យបុត្តដ៏មានអាយុ ហើយពោលទោស តិះដៀល បន្ទោកបន្ទាបថា យើងទាំងឡាយទទួលរូបិយ[១]បាន

១ រូបិយ បានដល់ មាសប្រាក់ ។

សក្យបុត្តិយា រូបិយំ បដិគ្គណ្ហន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស បុរិសស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ រូបិយំ បដិគ្គហេស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ត្វំ ឧបនន្ទ រូបិយំ បដិគ្គណ្ហាសីតិ[១] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស រូបិយំ បដិគ្គហេស្សសិ នេតំ មោឃ-បុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជាតរូប-រជតំ[២] ឧគ្គណ្ហេយ្យ វា ឧគ្គណ្ហាបេយ្យ វា ឧបនិក្ខិត្តំ វា សាទិយេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

---

១ សព្វត្ថ បដិគ្គហេសីតិ ទិស្សតិ ។ ២ ជាតរូបរជតន្តិបិ បាឋោ ។

យ៉ាងណា ពួកសមណសក្យបុត្តអម្បាលនេះ ក៏ទទួលរូបិយបានយ៉ាងនោះដែរ ។ ភិក្ខុទាំងឡាយ បានឮបុរសនោះ ពោលទោស តិះដៀលបន្ទោកបន្ទាបហើយ ។ ភិក្ខុទាំងឡាយណា ជាអ្នកប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ រមែងពោលទោស តិះដៀល បន្ទុះបង្អាប់ថា ហេតុដូចម្តេច ក៏ឧបនន្ទសក្យបុត្តដ៏មានអាយុមកទទួលយករូបិយ ។ ភិក្ខុទាំងនោះនាំគ្នាក្រាបទូលដំណើរនេះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែឧបនន្ទ ឮថាអ្នកទទួលរូបិយ ពិតមែនឬទេ ។ ឧបនន្ទភិក្ខុ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការណ៍នោះ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទើបទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងមិនសមបើនឹងទទួលរូបិយទេ នែមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លានោះទេ ឬធ្វើបុគ្គលដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយទទួលខ្លួនឯងក្តី ប្រើគេឲ្យទទួលក្តី នូវមាសប្រាក់ ឬមួយត្រេកអរនូវមាសប្រាក់ដែលគេទុកដាក់ឲ្យ មាសប្រាក់នោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

និស្សគ្គិយកណ្ឌេ កោសិយវគ្គស្ស អដ្ឋមសិក្ខាបទស្ស សិក្ខាបទវិភង្គោ

[១០៦] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជាតរូបំ នាម សត្ថុវណ្ណោ វុច្ចតិ ។ រជតំ នាម កហាបណោ លោហមាសកោ ទារុមាសកោ ជតុមាសកោ យេ វោហារំ គច្ឆន្តិ ។ ឧគ្គណ្ហេយ្យាតិ សយំ គណ្ហាតិ និស្សគ្គិយំ ហោតិ[១] ។ ឧគ្គណ្ហាបេយ្យាតិ អញ្ញំ គណ្ហាបេតិ និស្សគ្គិយំ ហោតិ[២] ។ ឧបនិក្ខិត្តំ វា សាទិយេយ្យាតិ ឥទំ អយ្យស្ស ហោតូតិ ឧបនិក្ខិត្តំ វា សាទិយតិ និស្សគ្គិយំ ហោតិ ។ សង្ឃមជ្ឈេ និស្សជ្ជិតព្វំ ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ តេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ រូបិយំ បដិគ្គហេសឹ ឥទំ មេ និស្សគ្គិយំ

១-២ និស្សគ្គិយំ បាចិត្តិយន្តិ សព្វត្ថ អាគតំ ។

និស្សគ្គិយកណ្ឌ កោសិយវគ្គ សិក្ខាបទទី ៨ សិក្ខាបទវិភង្គ

[១០៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយ ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ (លោហវិសេសមានពណ៌លឿង) បីដូចជាពណ៌នៃព្រះសាស្តា ឈ្មោះថា មាស ។ កហាបណៈក្តី មាសកដែលធ្វើដោយជាតិលោហៈក្តី មាសកធ្វើដោយឈើក្តី មាសកធ្វើដោយជ័រក្តី រមែងដល់នូវវោហារ (គេចាយវាយបាន) ហៅថា ប្រាក់ ។ ពាក្យថា ទទួលដោយខ្លួនឯង គឺកាន់យកដោយខ្លួនឯង មាសប្រាក់ដែលកាន់យកដោយខ្លួនឯងនោះ ជានិស្សគ្គិយ ។ ពាក្យថា ប្រើគេឲ្យទទួល គឺញុំាងអ្នកដទៃឲ្យកាន់យក មាសប្រាក់នោះ ជានិស្សគ្គិយ ។ ពាក្យថា ឬត្រេកអរនូវមាសប្រាក់ដែលគេទុកដាក់ឲ្យនោះ សេចក្តីថា ភិក្ខុត្រេកអរនូវមាសប្រាក់ដែលគេទុកដាក់ឲ្យដោយវាចាថា មាសប្រាក់នេះ ចូរជារបស់លោកម្ចាស់ចុះ មាសប្រាក់នោះ ជានិស្សគ្គិយ ។ មាសប្រាក់នោះ ភិក្ខុគប្បីលះក្នុងកណ្តាលនៃសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះ ។ ភិក្ខុនោះត្រូវចូលទៅរកសង្ឃហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលី ពោលយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំបានទទួលនូវរូបិយ រូបិយនេះខ្ញុំត្រូវលះបង់

ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន អាបត្តិ បដិគ្គហេតព្វា ។ សចេ តត្ថ អាគច្ឆតិ អារាមិកោ វា ឧបាសកោ វា សោ វត្តព្វោ អាវុសោ ឥមំ ជានាហីតិ ។ សចេ សោ ភណតិ ឥមិនា កឹ អាហរិយតូតិ ។ ន វត្តព្វោ ឥមំ វា ឥមំ វា អាហរាតិ ។ កប្បិយំ អាចិក្ខិតព្វំ សប្បឹ វា តេលំ វា មធុំ វា ផាណិតំ វា ។ សចេ សោ តេន បរិវត្តេត្វា កប្បិយំ អាហរតិ រូបិយប្បដិគ្គាហកំ ឋបេត្វា សព្វេហេវ បរិភុញ្ជិតព្វំ ។ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ សោ វត្តព្វោ អាវុសោ ឥមំ ឆឌ្ឌេហីតិ ។ សចេ សោ ឆឌ្ឌេតិ ឥច្ចេតំ កុសលំ នោ ចេ ឆឌ្ឌេតិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ រូបិយឆឌ្ឌកោ សម្មន្និតព្វោ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ ឆឌ្ឌិតាឆឌ្ឌិតញ្ច ជានេយ្យ ។

ខ្ញុំសូមលះបង់នូវរូបិយនេះដល់សង្ឃ ។ ភិក្ខុលះហើយ គប្បីសំដែងអាបត្តិចេញ ។ ភិក្ខុដែលឆ្លាសអង់អាចគប្បីទទួលដឹងនូវអាបត្តិ ។ បើញោមវត្តក្តី ឧបាសកក្តី មកក្នុងទីនោះ ភិក្ខុគប្បីពោលនឹងគេថា អាវុសោ អ្នកចូរដឹងនូវរូបិយនេះចុះ ។ បើគេពោលថា លោកម្ចាស់ឲ្យនាំយកនូវវត្ថុអ្វីមកដោយរូបិយនេះ ។ ភិក្ខុកុំគប្បីពោលថា អ្នកចូរនាំយកនូវវត្ថុនេះ ឬរបស់នេះមក ។ ភិក្ខុគប្បីប្រាប់វត្ថុដែលគួរ គឺ សប្បិ ឬប្រេង ឬទឹកឃ្មុំ ឬស្ករអំពៅ ។ បើញោមវត្ត ឬឧបាសកអ្នកចាត់ការនោះ ផ្លាស់ប្តូរដោយរូបិយនោះហើយ នាំយកវត្ថុដ៏គួរមក ភិក្ខុទាំងពួង គប្បីបរិភោគបានទាំងអស់ លើកលែងតែភិក្ខុអ្នកទទួលរូបិយមួយចេញ បើអ្នកចាត់ការនោះ បានវត្ថុដែលគួរយ៉ាងនោះមក នេះជាការល្អ បើមិនបានទេ ភិក្ខុគប្បីពោលនឹងគេថា នែអ្នកដ៏មានអាយុ អ្នកចូរចោលរូបិយនេះទៅ ។ បើគេចោលរូបិយនោះទៅ នេះជាការល្អ បើគេមិនចោលទេ ភិក្ខុទាំងឡាយគប្បីសន្មតភិក្ខុ (មួយរូប) ប្រកបដោយអង្គ ៥ ឲ្យជាអ្នកចោលនូវរូបិយ គឺភិក្ខុដែលមិនដល់នូវឆន្ទាគតិ ១ មិនដល់នូវទោសាគតិ ១ មិនដល់នូវមោហាគតិ ១ មិនដល់នូវភយាគតិ ១ ស្គាល់រូបិយដែលចោលហើយឬនៅមិនទាន់ចោល ១ ។

ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ រូបិយឆឌ្ឌកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ រូបិយឆឌ្ឌកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ រូបិយឆឌ្ឌកស្ស សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ រូបិយឆឌ្ឌកោ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ តេន សម្មតេន ភិក្ខុនា អនិមិត្តំ កត្វា ចាតេតព្វំ ។ សចេ និមិត្តំ កត្វា ចាតេតិ អាបត្តិ ទុក្កដស្ស ។

[១០៧] រូបិយេ រូបិយសញ្ញី រូបិយំ បដិគ្គណ្ហាតិ និស្សគ្គិយំ ចាចិត្តិយំ ។ រូបិយេ វេមតិកោ រូបិយំ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសន្មតភិក្ខុជាអ្នកចោលរូបិយយ៉ាងនេះ ។ ភិក្ខុអ្នកឆ្លាសត្រូវអង្វរភិក្ខុ (អ្នកចោលរូបិយ) ជាមុន ។ ភិក្ខុអ្នកឆ្លាសអង់អាចលុះអង្វររួចហើយត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃចូរស្តាប់ខ្ញុំ បើសម្មតិកម្មនេះ មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសម្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកចោលនូវរូបិយ ។ នេះជាវាចាដែលប្រកាសឲ្យសង្ឃជ្រាប ។ បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃចូរស្តាប់ខ្ញុំ សង្ឃសន្មតនូវភិក្ខុឈ្មោះនេះ ឲ្យជាអ្នកចោលនូវរូបិយ ។ ការសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកចោលនូវរូបិយ គួរដល់លោកដ៏មានអាយុអង្គណា សូមលោកដ៏មានអាយុអង្គនោះស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះសង្ឃបានសន្មតឲ្យជាអ្នកចោលនូវរូបិយហើយ ។ ការសន្មតគួរដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវកម្មនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។ ភិក្ខុដែលសង្ឃសន្មតហើយនោះ មិនត្រូវកំណត់ទី ហើយទើបចោលរូបិយនោះទេ ។ បើភិក្ខុនោះកំណត់ទីហើយទើបទម្លាក់ចោល ត្រូវអាបត្តិទុក្កដ ។

[១០៧] រូបិយ ភិក្ខុសំគាល់ថារូបិយមែន ហើយទទួលនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ រូបិយ ភិក្ខុសង្ស័យ

បដិគ្គណ្ហាតិ និស្សគ្គិយំ ចាចិត្តិយំ ។ រូបិយេ អរូបិយ-សញ្ញី រូបិយំ បដិគ្គណ្ហាតិ និស្សគ្គិយំ ចាចិត្តិយំ ។ អរូបិយេ រូបិយសញ្ញី អាបត្តិ ទុក្កដស្ស ។ អរូបិយេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អរូបិយេ អរូបិយ-សញ្ញី អនាបត្តិ ។

[១០៨] អនាបត្តិ អជ្ឈារាមេ វា អជ្ឈាវសថេ វា ឧគ្គហេត្វា វា ឧគ្គហាបេត្វា វា និក្ខិបតិ យស្ស ភវិស្សតិ សោ ហរិស្សតីតិ ឧម្មត្តកស្ស អាទិក-ម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។

ហើយទទួលនូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបា-ចិត្តិយ ។ រូបិយ ភិក្ខុសំគាល់ថា មិនមែនរូបិយ ហើយទទួលនូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ របស់មិនមែនរូបិយ ភិក្ខុសំគាល់ថា ជារូបិយ ត្រូវអាបត្តិទុក្កដ ។ របស់មិនមែនរូបិយ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ របស់មិនមែនរូបិយ ភិក្ខុសំគាល់ថា មិនមែនរូបិយ មិនត្រូវអាបត្តិ ។

[១០៨] អាបត្តិមិនមានដល់ភិក្ខុ ដែលរើសយក ដោយខ្លួនឯងឬ ប្រើគេឲ្យរើសយកនូវរូបិយដែលធ្លាក់ចុះ ក្នុងអារាមក្តី ក្នុងលំនៅរបស់ខ្លួនក្តី ដោយគិតថា រូបិយនេះរបស់អ្នកណា អ្នកនោះនឹងនាំយកទៅចុះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់ ។

# នវមសិក្ខាបទំ

[១០៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ជានប្បការកំ រូបិយសំវោហារំ សមាបជ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម សមណា សក្យ-បុត្តិយា ជានប្បការកំ រូបិយសំវោហារំ សមាបជ្ជិស្សន្តិ សេយ្យថាបិ គិហីកាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិចាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ជានប្បការកំ រូបិយសំវោហារំ សមាបជ្ជិស្សន្តី-តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ជានប្បការកំ រូបិយសំ-វោហារំ សមាបជ្ជថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា

# សិក្ខាបទទី ៩

[១០៩] សម័យនោះ ព្រះសម្ពុទ្ធដ៏ទ្រង់យស ទ្រង់គង់ក្នុងអារាម ជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកភិក្ខុឆព្វគ្គិយប្រព្រឹត្តទិញដូរ ដោយរូបិយមានប្រការផ្សេង ៗ ។ មនុស្ស ទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅ ព្រះពុទ្ធជាសក្យបុត្ត មិនសមបើនឹងប្រព្រឹត្តទិញដូរ ដោយរូបិយមានប្រការ ផ្សេង ៗ ដូចជាពួកគ្រហស្ថអ្នកបរិភោគនូវកាមទេ ។ ភិក្ខុទាំងឡាយបានឮ មនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយ ណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ រមែងពោល ទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយមិនសមនឹងប្រព្រឹត្តទិញ ដូរ ដោយរូបិយមានប្រការផ្សេៗទេ ។ ទើបភិក្ខុទាំងនោះនាំគ្នា ក្រាបទូល ដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គមានបន្ទូលសួរថា ម្នាល ភិក្ខុទាំងឡាយ ឮថាពួកអ្នកប្រព្រឹត្តទិញដូរ ដោយរូបិយមានប្រការផ្សេង ៗ ពិតមែនឬទេ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការណ៍នោះ ពិតមែន ។ សម្តេចព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀល ថា នែមោឃបុរសទាំងឡាយ ពួកអ្នកមិនសមបើនឹងប្រព្រឹត្តទិញដូរ

នានប្បការកំ រូបិយសំវោហារំ សមាបជ្ជិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ នានប្បការកំ រូបិយសំវោហារំ សមាបជ្ជេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

[១១០] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មិំ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ នានប្បការកំ នាម កតំបិ អកតំបិ កតាកតំបិ ។ កតំ នាម សីសូបកំ គីវូបកំ ហត្ថូបកំ បាទូបកំ កដូបកំ ។ អកតំ នាម ឃនកតំ វុច្ចតិ ។ កតាកតំ នាម តទុភយំ ។ រូបិយំ នាម សត្ថុវណ្ណោ កហាបណោ លោហមាសកោ ទារុមាសកោ ជតុមាសកោ យេ វោហារំ គច្ឆន្តិ ។ សមាបជ្ជេយ្យាតិ កតេន កតំ ចេតាបេតិ

ដោយរូបិយមានប្រការផ្សេង ៗ ដូច្នោះទេ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ពួកបុគ្គលដែលមិនទាន់ជ្រះថ្លានោះទេ ឬមួយនាំពួកអ្នកដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង មិនបានទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ប្រព្រឹត្តទិញដូរដោយរូបិយ មានប្រការផ្សេង ៗ វត្ថុដែលទិញមកនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[១១០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយ ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ មាសប្រាក់ដែលធ្វើសម្រេចជារូបហើយក្តី មិនទាន់បានធ្វើជារូបក្តី ធ្វើខ្លះមិនបានធ្វើខ្លះក្តី ហៅថា រូបិយមានប្រការផ្សេង ៗ ។ រូបិយដែលគេធ្វើសម្រាប់ពាក់លើក្បាលក្តី ពាក់ឰដ៏កក្តី ពាក់នឹងដៃក្តី ពាក់នឹងជើងក្តី ពាក់នឹងចង្កេះក្តី ហៅថា រូបិយធ្វើសម្រេចហើយ ។ រូបិយដែលនៅជាដុំ ហៅថា រូបិយគេមិនទាន់ធ្វើសម្រេច ។ រូបិយដែលធ្វើសម្រេចជារូប និងមិនទាន់ធ្វើសម្រេចជារូបទាំងពីរយ៉ាងនេះ ហៅថា រូបិយគេបានធ្វើខ្លះ មិនបានធ្វើខ្លះ ។ មាសក្តី កហាបណៈក្តី មាសកធ្វើដោយជាតិលោហៈក្តី មាសកធ្វើដោយឈើក្តី មាសកធ្វើដោយជ័រក្តី នៅចាយវាយបាន ហៅថា រូបិយ ។ ពាក្យថា ប្រព្រឹត្ត សេចក្តីថា ភិក្ខុទិញដូរនូវរូបិយ

១៣៤

និស្សគ្គិយកណ្ឌេ កោសិយវគ្គស្ស នវមសិក្ខាបទស្ស អាបត្តិវារោ

និស្សគ្គិយំ ហោតិ[១] ។ កាតេន អកាតំ ចេតាបេតិ និស្សគ្គិយំ ហោតិ[២] ។ កាតេន កាតាកាតំ ចេតាបេតិ និស្សគ្គិយំ ហោតិ[៣] ។ អកាតេន កាតំ ចេតាបេតិ និស្សគ្គិយំ ហោតិ[៤] ។ អកាតេន អកាតំ ចេតាបេតិ និស្សគ្គិយំ ហោតិ[៥] ។ អកាតេន កាតាកាតំ ចេតា-បេតិ និស្សគ្គិយំ ហោតិ[៦] ។ កាតាកាតេន កាតំ ចេតាបេតិ និស្សគ្គិយំ ហោតិ[៧] ។ កាតាកាតេន អកាតំ ចេតាបេតិ និស្សគ្គិយំ ហោតិ[៨] ។ កាតាកាតេន កាតាកាតំ ចេតាបេតិ និស្សគ្គិយំ ហោតិ[៩] ។ សង្ឃមជ្ឈេ និស្សជ្ជិតព្វំ ។ ឯវញ្ច បន ភិក្ខវេ

១....៩ និស្សគ្គិយំ បាចិត្តិយន្តិ សព្វត្ថ អាគតំ ។

ដែលធ្វើសម្រេចហើយ ដោយរូបិយដែលធ្វើសម្រេចហើយ រូបិយនោះ ជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលគេមិនទាន់ធ្វើសម្រេចហើយ ដោយរូបិយដែលគេធ្វើសម្រេចហើយ រូបិយនោះ ជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលធ្វើសម្រេចហើយខ្លះ មិនទាន់ធ្វើសម្រេចហើយខ្លះ ដោយរូបិយដែលធ្វើសម្រេចហើយ រូបិយនោះ ជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលធ្វើសម្រេចហើយ ដោយរូបិយដែលមិនទាន់ធ្វើសម្រេចហើយ រូបិយនោះ ជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលមិនទាន់ធ្វើសម្រេចហើយ ដោយរូបិយដែលមិនទាន់ធ្វើសម្រេចហើយ រូបិយនោះ ជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលធ្វើសម្រេចហើយខ្លះ មិនទាន់ធ្វើសម្រេចខ្លះ ដោយរូបិយដែលមិនទាន់ធ្វើសម្រេចហើយ រូបិយនោះ ជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលគេធ្វើសម្រេចហើយ ដោយរូបិយដែលគេធ្វើសម្រេចហើយខ្លះ មិនទាន់ធ្វើសម្រេចហើយខ្លះ រូបិយនោះ ជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលមិនទាន់ធ្វើសម្រេច ដោយរូបិយដែលធ្វើសម្រេចហើយខ្លះ និងមិនទាន់ធ្វើសម្រេចខ្លះ រូបិយនោះ ជានិស្សគ្គិយ ។ ភិក្ខុទិញដូរនូវរូបិយដែលធ្វើសម្រេចហើយខ្លះ មិនទាន់ធ្វើសម្រេចហើយខ្លះ ដោយរូបិយដែលធ្វើសម្រេចហើយខ្លះ មិនទាន់ធ្វើសម្រេចហើយខ្លះ រូបិយនោះ ជានិស្សគ្គិយ ។ រូបិយដែលជានិស្សគ្គិយនោះ ភិក្ខុគប្បីលះក្នុងទីកណ្ដាលនៃសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ

និស្សជ្ជិតព្វំ ។ តេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ ជានប្បការកំ រូបិយសំវោហារំ សមាបជ្ជឹ ឥទំ មេ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន អាបត្តិ បដិគ្គហេតព្វា ។ សចេ តត្ថ អាគច្ឆតិ អារាមិកោ វា ឧបាសកោ វា សោ វត្តព្វោ អាវុសោ ឥមំ ជានាហីតិ ។ សចេ សោ ភណតិ ឥមិនា កឹ អាហរិយតូតិ ។ ន វត្តព្វោ ឥមំ វា ឥមំ វា អាហរាតិ ។ កប្បិយំ អាចិក្ខិតព្វំ សប្បឹ វា តេលំ វា មធុំ វា ផាណិតំ វា ។ សចេ សោ តេន បរិវត្តេត្វា កប្បិយំ អាហរតិ រូបិយចេតាបកំ ឋបេត្វា សព្វេហេវ បរិភុញ្ជិតព្វំ ។ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ សោ វត្តព្វោ អាវុសោ ឥមំ ឆឌ្ឌេហីតិ ។ សចេ សោ ឆឌ្ឌេតិ ឥច្ចេតំ កុសលំ នោ ចេ

ភិក្ខុគប្បីលះយ៉ាងនេះឯង ។ ភិក្ខុនោះ គប្បីចូលទៅរកសង្ឃហើយពាក់ចីពរឆៀងស្មាម្ខាងថ្វាយបង្គំបាទានៃភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីពោលយ៉ាងនេះ (នឹងសង្ឃ) ថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំជាអ្នកប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេង ៗ រូបិយវត្ថុរបស់ខ្ញុំនេះជានិស្សគ្គិយ ខ្ញុំសូមលះនូវរូបិយវត្ថុនេះដល់សង្ឃ ។ លុះលះស្រេចហើយ គប្បីសំដែងអាបត្តិចេញ ។ ភិក្ខុអ្នកឆ្លាសអង់អាច គប្បីទទួលសំដែងអាបត្តិ ។ បើញោមវត្ត ឬឧបាសកមកក្នុងទីនោះ ភិក្ខុទាំងឡាយ គប្បីពោលនឹងគេថា អាវុសោ អ្នកចូរដឹងនូវរូបិយវត្ថុនេះចុះ ។ បើគេពោលថា ពួកលោកម្ចាស់ត្រូវការឲ្យខ្ញុំនាំយកវត្ថុអ្វីមកដោយរូបិយវត្ថុនេះ ។ ភិក្ខុទាំងឡាយ មិនគប្បីពោលថា អ្នកចូរនាំយកនូវវត្ថុនេះ ឬរបស់នេះមកឡើយ ។ គប្បីប្រាប់តែរបស់ដែលគួរ គឺជាសប្បិ ឬប្រេង ឬទឹកឃ្មុំ ឬស្ករអំពៅ ក៏បាន ។ បើគេផ្លាស់ប្តូរដោយរូបិយវត្ថុនោះ ហើយនាំយករបស់ដែលគួរមក ភិក្ខុទាំងពួង គប្បីបរិភោគបាន វៀរលែងតែភិក្ខុអ្នកទិញដូរដោយរូបិយចេញ ។ បើភិក្ខុបានរបស់គួរយ៉ាងនេះ នេះជាការល្អ បើមិនបានទេ គប្បីពោលនឹងគេថា អាវុសោ អ្នកចូរបោលនូវរូបិយវត្ថុនេះទៅ ។ បើគេបោលទៅ នេះជាការល្អ

និស្សគ្គិយកណ្ឌេ កោសិយវគ្គស្ស នវមសិក្ខាបទស្ស រូបិយឆឌ្ឌកសម្មតិ

ឆឌ្ឌេតិ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ រូបិយឆឌ្ឌកោ សម្មន្និតព្វោ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ ឆឌ្ឌិតាឆឌ្ឌិតញ្ច ជានេយ្យ ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ រូបិយ-ឆឌ្ឌកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ រូបិយឆឌ្ឌកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ រូបិយឆឌ្ឌកស្ស សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ រូបិយឆឌ្ឌកោ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

បើគេមិនចោលទេ ភិក្ខុទាំងឡាយគប្បីសន្មតភិក្ខុ (មួយរូប) ដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកចោលនូវរូបិយ គឺភិក្ខុមិនដល់នូវឆន្ទាគតិ ១ មិនដល់នូវទោសាគតិ ១ មិនដល់នូវមោហាគតិ ១ មិនដល់នូវភយាគតិ ១ ដឹងនូវរូបិយដែលខ្លួនបានចោល និងមិនទាន់ចោល ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសន្មតយ៉ាងនេះ ។ ភិក្ខុអ្នកឆ្លាសត្រូវអង្វរភិក្ខុ (ជាអ្នកចោលនូវរូបិយ) ជាមុន ។ ភិក្ខុអ្នកឆ្លាសអង់អាចលុះអង្វររួចហើយ ត្រូវប្រកាសសង្ឃឲ្យដឹងដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃចូរស្តាប់ខ្ញុំ បើសម្មតិកម្មនេះមានកាលដ៏គួរដល់សង្ឃហើយសោត សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកចោលនូវរូបិយ ។ នេះជាវាចាដែលប្រកាសឲ្យសង្ឃជ្រាប ។ បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃចូរស្តាប់ខ្ញុំ សង្ឃសន្មតនូវភិក្ខុឈ្មោះនេះ ឲ្យជាអ្នកចោលនូវរូបិយ ។ ការសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកចោលនូវរូបិយ គួរដល់លោកដ៏មានអាយុអង្គណា សូមលោកដ៏មានអាយុអង្គនោះស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកចោលនូវរូបិយហើយ ។ សម្មតិកម្មនេះគួរដល់សង្ឃ ហេតុនោះសង្ឃទើបស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសម្មតិកម្មនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

តេន សម្មតេន ភិក្ខុនា អនិមិត្តំ កត្វា ចាតេតព្វំ ។ សចេ និមិត្តំ កត្វា ចាតេតិ អាបត្តិ ទុក្កដស្ស ។

[១១១] រូបិយេ រូបិយសញ្ញី រូបិយំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ រូបិយេ វេមតិកោ រូបិយំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ រូបិយេ អរូបិយ-សញ្ញី រូបិយំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អរូបិយេ រូបិយសញ្ញី រូបិយំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អរូបិយេ វេមតិកោ រូបិយំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អរូបិយេ អរូបិយសញ្ញី រូបិយំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អរូបិយេ រូបិយសញ្ញី អាបត្តិ ទុក្កដស្ស ។ អរូបិយេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អរូបិយេ អរូបិយសញ្ញី អនាបត្តិ ។

[១១២] អនាបត្តិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។

ភិក្ខុដែលសង្ឃសន្មតនោះ កុំគប្បីកំណត់ទីហើយចោលនូវរូបិយនោះ ។ បើភិក្ខុនោះ កំណត់ទីហើយចោល ត្រូវអាបត្តិទុក្កដ ។

[១១១] រូបិយ ភិក្ខុសំគាល់ថា រូបិយមែន ហើយទិញដូរនូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ រូបិយ ភិក្ខុសង្ស័យ ហើយទិញដូរនូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ រូបិយ ភិក្ខុសំគាល់ថាមិនមែនរូបិយ ហើយទិញដូរនូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ មិនមែនរូបិយ ភិក្ខុសំគាល់ថា រូបិយ ហើយទិញដូរនូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ មិនមែនរូបិយ ភិក្ខុសង្ស័យ ហើយទិញដូរនូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ មិនមែនរូបិយ ភិក្ខុសំគាល់ថា មិនមែនរូបិយ ហើយទិញដូរនូវរូបិយ រូបិយនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ មិនមែនរូបិយ ភិក្ខុសំគាល់ថា រូបិយ ត្រូវអាបត្តិទុក្កដ ។ មិនមែនរូបិយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនរូបិយ ភិក្ខុសំគាល់ថា មិនមែនរូបិយ មិនត្រូវអាបត្តិ ។

[១១២] អាបត្តិមិនមានដល់ភិក្ខុឆ្កួត និងភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់ ។

# ទសមសិក្ខាបទំ

[១១៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យ-បុត្តោ បដ្ឋោ ហោតិ ចីវរកម្មំ កាតុំ ។ សោ បដបិលោតិកានំ សង្ឃាដឹ ការិត្វា សុរត្តំ សុបរិកម្ម-កតំ កត្វា ចារុបិ ។ អថខោ អញ្ញតរោ បរិព្វាជកោ មហគ្ឃំ បដំ ចារុបិត្វា យេនាយស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច សុន្ទរា ខោ ត្យាយំ អាវុសោ សង្ឃាដិ(១) ទេហិ មេ បដេនាតិ ។ ជានាហិ អាវុសោតិ ។ អាមាវុសោ ជានាមីតិ ។ ហន្ទាវុសោតិ អទាសិ ។ អថខោ សោ បរិព្វាជកោ តំ សង្ឃាដឹ ចារុបិត្វា បរិព្វាជការាមំ អគមាសិ ។ បរិព្វាជកា តំ បរិព្វាជកំ ឯតទវោចុំ សុន្ទរា ខោ ត្យាយំ អាវុសោ

---

១ ឱ. សង្ឃាដី ។

# សិក្ខាបទទី ១០

[១១៣] សម័យនោះ ព្រះសម្ពុទ្ធដ៏មានយស ទ្រង់គង់ក្នុងអារាម ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះឧបនន្ទដ៏មានអាយុ ជាបុត្តនៃសក្យ ប្រសប់ធ្វើចីវរកម្ម ។ ឧបនន្ទភិក្ខុនោះ យកកំណាត់សំពត់ចាស់ ៗ ទៅធ្វើជាសង្ឃាដិ ធ្វើកិច្ចជ្រលក់គក់បោកល្អហើយ យកមកដណ្តប់ ។ គ្រានោះឯង បរិព្វាជកម្នាក់ ដណ្តប់សំពត់ដ៏មានតម្លៃច្រើន ហើយចូលទៅរកឧបនន្ទសក្យបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយ នឹងឧបនន្ទសក្យបុត្តដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោ សង្ឃាដិរបស់លោកនេះល្អមែន លោកចូរប្តូរនឹងសំពត់របស់យើងចុះ ។ ឧបនន្ទភិក្ខុនិយាយតបថា ម្នាលអាវុសោ អ្នកចូរដឹងចុះ (អ្នកមើលសិន) ។ បរិព្វាជកនិយាយថា អើ អាវុសោ យើងដឹង ។ ឧបនន្ទភិក្ខុ បានឲ្យនូវសង្ឃាដិនោះ ដោយវាចាថា ហ៏ អាវុសោ ។ បរិព្វាជកនោះ ទើបដណ្តប់នូវសង្ឃាដិនោះ ហើយបានទៅកាន់អារាមរបស់បរិព្វាជក ។ បរិព្វាជកទាំងឡាយបាននិយាយពាក្យនេះនឹងបរិព្វាជកនោះថា ម្នាលអាវុសោ

សង្ឃាដិ កុតោ តយា លទ្ធាតិ ។ តេន មេ អាវុសោ បដេន បរិវដ្ដិតាតិ[១] ។ កតិហិបិ ត្យាយំ អាវុសោ សង្ឃាដិ ភវិស្សតិ សោ យេវ តេ បដោ វភតិ ។ អថខោ សោ បរិព្វាជកោ សច្ចំ ខោ បរិព្វាជកា អាហំសុ កតិហិបិ ម្យាយំ សង្ឃាដិ ភវិស្សតិ សោ យេវ មេ បដោ វភតិ យេនាយស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច ហន្ទ តេ អាវុសោ សង្ឃាដឹ ទេហិ មេ បដន្តិ ។ ននុ ត្វំ អាវុសោ មយា វុត្តោ ជានាហិ អាវុសោតិ នាហំ ទស្សាមីតិ ។ អថខោ សោ បរិព្វាជកោ ឧជ្ឈាយតិ ខីយតិ វិចាចេតិ គិហិបិ[២] នំ គិហិស្ស វិប្បដិសារិស្ស ទេតិ[៣] កឹ បន បព្វជិតោ បព្វជិតស្ស ន ទស្សតីតិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស បរិព្វាជកស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិចាចេន្តស្ស ។ យេ តេ ភិក្ខូ

---

១ សព្វត្ថ បរិវត្តិតាតិ ទិស្សតិ ។ ២ គិហិបិ នំ គិហិស្សាតិ ឯត្ថ នន្តិ នាមត្ថេ និបាតោ ។ គិហិបិ នាម គិហិស្សាតិ វុត្តំ ហោតីតិ តព្វណ្ណនា ។ ៣ ឱ. ម. ទេន្តិ ។

សង្ឃាដិរបស់អ្នកនេះល្អមែន អ្នកបានមកអំពីទីណា ។ បរិព្វាជកនោះ តបថា ម្នាលអាវុសោ យើងបានប្តូរដោយសំពត់របស់យើងនោះមក ។ ពួកបរិព្វាជកសួរថា ម្នាលអាវុសោ សង្ឃាដិរបស់អ្នកនេះនឹងធន់នៅបានប៉ុន្មានថ្ងៃ ឯសំពត់របស់អ្នកពីមុននោះ ប្រសើរជាង ។ បរិព្វាជកនោះ ទើបគិតថា បរិព្វាជកទាំងឡាយ បានពោលនូវពាក្យនោះ ជាពាក្យពិតមែន សង្ឃាដិរបស់អញនេះ នឹងធន់នៅបានប៉ុន្មានថ្ងៃ សំពត់របស់អញនោះឯងប្រសើរ ទើបចូលទៅរកឧបនន្ទសក្យបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះ នឹងឧបនន្ទដ៏មានអាយុជាសក្យបុត្តថា ណ្ហើយចុះ អ្នកចូរយកសង្ឃាដិរបស់អ្នកទៅវិញចុះ ចូរឲ្យសំពត់មកយើងវិញ ។ ឧបនន្ទភិក្ខុបាននិយាយថា ម្នាលអាវុសោ យើងបានប្រាប់អ្នកហើយថា អ្នកចូរដឹង (ចូរមើលសិន) ដូច្នេះ មិនមែនទេឬ យើងមិនឲ្យទេ ។ ឯបរិព្វាជកនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សូម្បីគ្រហស្ថ ក៏រមែងឲ្យនូវវត្ថុនោះដល់គ្រហស្ថ ដែលមានសេចក្តីក្តៅក្រហាយដែរ ចុះហេតុអ្វីបព្វជិតត្រឡាំង ក៏មិនឲ្យដល់បព្វជិតដូចគ្នា ។ ភិក្ខុទាំងឡាយបានឮបរិព្វាជកនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា

អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ បរិព្វាជកេន សទ្ធឹ កយវិក្កយំ សមាបជ្ជិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ត្វំ ឧបនន្ទ បរិព្វាជកេន សទ្ធឹ កយវិក្កយំ សមាបជ្ជសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស បរិព្វាជកេន សទ្ធឹ កយវិក្កយំ សមាបជ្ជិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ នានប្បការកំ កយវិក្កយំ សមាបជ្ជេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

[១១៤] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ នានប្បការកំ នាម ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា អន្តមសោ

មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ឧបនន្ទសក្យបុត្តដ៏មានអាយុ មិនគួរនឹងប្រព្រឹត្ត ទិញដូររបស់មួយអន្លើ ដោយបរិវ្វាជកទេ ។ ភិក្ខុទាំងនោះ ក៏នាំគ្នាក្រាបទូល ដំណើរនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ឧបនន្ទ ឮថាអ្នកឯងប្រព្រឹត្តទិញដូររបស់ មួយអន្លើដោយបរិវ្វាជក ពិតមែនឬ ។ ឧបនន្ទភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការណ៍នោះពិតមែន ។ សម្តេចព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯង មិនគួរនឹងប្រព្រឹត្តទិញដូររបស់មួយអន្លើ ដោយបរិវ្វាជនទេ នែមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់បុគ្គលដែលមិនទាន់ជ្រះ ថ្លាទេ ឬមួយនាំបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងមិនបាន ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវ សិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ប្រព្រឹត្តទិញដូររបស់មានប្រការ ផ្សេង ៗ របស់នោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[១១៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយ ក្នុងសិក្ខាបទ ទី ១ នៃបារាជិកកណ្ឌរួចហើយ ។ បរិក្ខារទាំងឡាយ គឺចីវរបិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ដោយហោចទៅ

ចុណ្ណបិណ្ឌោបិ ទន្តកដ្ឋំបិ ទសិកសុត្តំបិ ។ កយវិក្កយំ សមាបជ្ជេយ្យាតិ ឥមិនា ឥមំ ទេហិ ឥមិនា ឥមំ អាហរ ឥមិនា ឥមំ បរិវត្តេហិ[១] ឥមិនា ឥមំ ចេតាបេហីតិ អជ្ឈាចរតិ អាបត្តិ ទុក្កដស្ស យតោ កយិតញ្ច ហោតិ វិក្កីតញ្ច[២] អត្តនោ ភណ្ឌំ បរហត្ថគតំ បរភណ្ឌំ អត្តនោ ហត្ថគតំ និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ អហំ ភន្តេ នានប្បការកំ កយវិក្កយំ សមាបជ្ជឹ ឥទំ មេ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[១១៨] កយវិក្កយេ កយវិក្កយសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ កយវិក្កយេ វេមតិកោ និស្សគ្គិយំ

---

១ សព្វត្ថ បរិវត្តេហីតិ ទិស្សតិ ។ ២ ឱ. ម. យតោ កយិតញ្ច ហោតិ វិក្កយិតញ្ច ។

សូម្បីតែដុំនៃលំអិត[១] សូម្បីឈើស្ទន់ សូម្បីអំបោះរង្វើង ហៅថា វត្ថុមានប្រការផ្សេង ៗ ។ ពាក្យថា ប្រព្រឹត្តទិញដូរ សេចក្តីថា ភិក្ខុពោល ពាក្យមិនសមគួរថា អ្នកចូរឲ្យនូវវត្ថុនេះ[២] ដោយរបស់នេះចុះ អ្នកចូរនាំ យកវត្ថុនេះ ដោយរបស់នេះចុះ អ្នកចូរប្តូរវត្ថុនេះ ដោយរបស់នេះចុះ អ្នក ចូរទិញនូវវត្ថុនេះ ដោយរបស់នេះចុះ ត្រូវអាបត្តិទុក្កដ កាលណាបើភិក្ខុធ្វើ ទ្រព្យរបស់ខ្លួន ឲ្យតាំងនៅក្នុងដៃនៃអ្នកដទៃ ធ្វើទ្រព្យរបស់អ្នកដទៃឲ្យមក តាំងនៅក្នុងដៃរបស់ខ្លួនវិញ ហៅថា ទិញ ហៅថា លក់ ទ្រព្យដែលភិក្ខុទិញ លក់នោះ ជានិស្សគ្គិយ ភិក្ខុគប្បីលះដល់សង្ឃ ឬដល់គណៈ ឬដល់បុគ្គល ក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះ ។ បេ ។ បពិត្រ ព្រះសង្ឃដ៏ចម្រើន ខ្ញុំប្រព្រឹត្តទិញដូរនូវទ្រព្យមានប្រការផ្សេង ៗ ទ្រព្យ របស់ខ្ញុំនេះ ជានិស្សគ្គិយ ខ្ញុំសូមលះទ្រព្យនេះដល់សង្ឃ ។ បេ ។ សង្ឃ គប្បីឲ្យ ។ បេ ។ លោកដ៏មានអាយុទាំងឡាយគប្បីឲ្យ ។ បេ ។ ខ្ញុំឲ្យ ដល់លោកដ៏មានអាយុ ។

[១១៥] ទ្រព្យដែលខ្លួនទិញដូរ ភិក្ខុសំគាល់ថា ទិញដូរ ទ្រព្យ នោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសង្ស័យក្នុងទ្រព្យ

---

១ បានដល់ដុំកំទេច ដែលគេប្រើសម្រាប់ដុសខ្លួនវេលាងូតទឹក ដើម្បីឲ្យជ្រះក្អែល ឬជារោគ ជាដើម ។ ២ បានដល់គ្រឿងប្រើប្រាស់ទាំងអស់ ។

ចាចិត្តិយំ ។ កយវិក្កយេ ឥកយវិក្កយសញ្ញី និស្ស-គ្គិយំ ចាចិត្តិយំ ។ ឥកយវិក្កយេ កយវិក្កយសញ្ញី អាបត្តិ ទុក្កស្ស ។ ឥកយវិក្កយេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឥកយវិក្កយេ ឥកយវិក្កយសញ្ញី អជាបត្តិ ។

[១១៦] អជាបត្តិ អគ្ឃំ បុច្ឆតិ កប្បិយការកស្ស អាចិក្ខតិ ឥជំ អម្ហាកំ អត្ថិ អម្ហាកញ្ច ឥមិជា ច ឥមិជា ច អត្ថោតិ ភណាតិ ឧម្មត្តកស្ស អាជិកម្មិ-កស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

កោសិយវគ្គោ ទុតិយោ ។

ដែលខ្លួនទិញដូរ ទ្រព្យនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ទ្រព្យដែលខ្លួនទិញដូរ ភិក្ខុសំគាល់ថា មិនមែនទ្រព្យទិញដូរវិញ ទ្រព្យនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ទ្រព្យដែលខ្លួនមិនបានទិញដូរ ភិក្ខុសំគាល់ថា ទ្រព្យទិញដូរវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យក្នុងទ្រព្យដែលខ្លួនមិនបានទិញដូរ ត្រូវអាបត្តិទុក្កដ ។ ទ្រព្យដែលខ្លួនមិនបានទិញដូរ ភិក្ខុសំគាល់ថា ទ្រព្យមិនបានទិញដូរ មិនត្រូវអាបត្តិ ។

[១១៦] អាបត្តិមិនមាន ដល់ភិក្ខុដែលគ្រាន់តែសួរតម្លៃ ដល់ភិក្ខុដែលប្រាប់ដល់កប្បិយការកៈ ដល់ភិក្ខុដែលពោលថា ទ្រព្យនេះរបស់យើងមាន យើងត្រូវការដោយទ្រព្យនេះផងនេះផង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់ ។

កោសិយវគ្គទី ២ ចប់ ។

# តស្សុទ្ទានំ

កោសិយា សុទ្ធទ្វេភាគា ឆព្វស្សានិ និសីទនំ
ទ្វេ ច លោមានិ ឧគ្គណ្ហោ ឧភោ នានប្បការកានិ ។

ចំនួននៃសិក្ខាបទក្នុងកោសិយវគ្គនោះ គឺ

ភិក្ខុធ្វើសន្ថ័តដោយរោមចៀមលាយសូត្រ ១ ភិក្ខុធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ ១ ភិក្ខុធ្វើសន្ថ័តត្រូវយករោមចៀមខ្មៅពីរភាគមកលាយ ១ ភិក្ខុធ្វើសន្ថ័តថ្មីហើយត្រូវប្រើប្រាស់ឲ្យបាន ៦ ឆ្នាំ ១ ភិក្ខុធ្វើសន្ថ័តសម្រាប់ទ្រាប់អង្គុយត្រូវកាត់យកសន្ថ័តចាស់មកលាយ ១ ភិក្ខុកាន់យករោមចៀមដែលកើតឡើងពាក់កណ្តាលផ្លូវ បានតែត្រឹមបីយោជន៍ ១ ភិក្ខុប្រើនាងភិក្ខុនីឲ្យលាងជ្រលក់គក់រោមចៀម ១ ភិក្ខុទទួលរូបិយ ១ ភិក្ខុលក់ទិញដោយរូបិយ ១ ភិក្ខុលក់ទិញផ្លាស់ប្តូរដោយកប្បិយវត្ថុ ១ ។

# បត្តវគ្គស្ស បឋមសិក្ខាបទំ

[១១៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ពហូ បត្តេ សន្និចយំ ករោន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ពហូ បត្តេ សន្និចយំ ករិស្សន្តិ បត្តវណិជ្ជំ វា សមណា សក្យបុត្តិយា ករិស្សន្តិ អាមត្តិកាបណំ វា បសារេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិចាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ អតិរេកបត្តំ ធារេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ អតិរេកបត្តំ ធារេថាតិ ។ សច្ចំ ភគវាតិ ។

# បត្តវគ្គ សិក្ខាបទទី ១

[១១៧] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានយស ទ្រង់សម្រេចឥរិយាបថ ក្នុងវត្តជេតវន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសន្សំបាត្រទុកជាច្រើន ។ មនុស្សទាំងឡាយដើរទៅវិហារបានឃើញ នាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្ត មិនសមបីបើនឹងសន្សំបាត្រទុកជាច្រើនទេ សមណៈទាំងឡាយ ជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្ត នឹងធ្វើនូវជំនួញបាត្រ ឬនឹងតាំងរានផ្សារលក់ភាជន៍ដី ។ ភិក្ខុទាំងឡាយ បានឮពាក្យមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ។ ពួកភិក្ខុណា ដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយ-ភិក្ខុ មិនសមបើនឹងប្រើប្រាស់អតិរេកបាត្រ[១]ឡើយ ។ ខណៈនោះ ភិក្ខុទាំងនោះ ក៏ក្រាបទូលរឿងនុ៎ះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ ប្រើប្រាស់អតិរេក-បាត្រ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលតបថា សូមទ្រង់ព្រះមេត្តាប្រោស

១ បាត្រដែលលើស គឺបាត្រដែលមិនបានវិកប្ប មិនបានអធិដ្ឋាន ។

វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃ-
បុរិសា អតិរេកបត្តំ ធារេស្សថ នេតំ មោឃបុរិសា
អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោ-
ភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ
ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អតិរេកបត្តំ ធារេយ្យ
និស្សគ្គិយំ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ
សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១១៨] តេន ខោ បន សមយេន អាយស្មតោ
អានន្ទស្ស អតិរេកបត្តោ ឧប្បន្នោ ហោតិ ។ អាយស្មា
ច អានន្ទោ តំ បត្តំ អាយស្មតោ សារីបុត្តស្ស ទាតុ-
កាមោ ហោតិ ។ អាយស្មា ច សារីបុត្តោ សាកេតេ
វិហរតិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ
ភគវតា សិក្ខាបទំ បញ្ញត្តំ ន អតិរេកបត្តោ ធារេ-
តព្វោតិ អយញ្ច មេ អតិរេកបត្តោ ឧប្បន្នោ អ-
ហញ្ចិមំ បត្តំ អាយស្មតោ សារីបុត្តស្ស ទាតុកាមោ
អាយស្មា ច សារីបុត្តោ សាកេតេ វិហរតិ កថំ
នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ អថខោ អាយស្មា

ការណ៍នោះ ពិតមែន ។ ព្រះពុទ្ធដ៏ទ្រង់ឥស្សរិយយស ត្រាស់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរនឹងប្រើប្រាស់អតិរេកបាត្រទេ ម្នាលមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬថានាំឲ្យជ្រះថ្លាក្រៃលែង ដល់ពួកជនដែលមានសេចក្តីជ្រះថ្លារួចហើយទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយទ្រទ្រង់នូវអតិរេកបាត្រ អតិរេកបាត្រនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបញ្ញត្តដល់ភិក្ខុទាំងឡាយដោយប្រការដូច្នេះ ។

[១១៨] សម័យនោះឯង អតិរេកបាត្រកើតឡើង ដល់ព្រះអានន្ទដ៏មានអាយុ ឯព្រះអានន្ទដ៏មានអាយុប្រាថ្នា នឹងប្រគេនបាត្រនោះ ដល់ព្រះសារីបុត្តដ៏មានអាយុ ។ ចំណែកព្រះសារីបុត្តដ៏មានអាយុ នៅក្រុងសាកេត ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ក៏មានបរិវិតក្កថា សិក្ខាបទព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តរួចហើយថា អតិរេកបាត្រ ភិក្ខុមិនគប្បីទ្រទ្រង់ ក៏អតិរេកបាត្រនេះ កើតឡើងដល់អញ ហើយអញ ក៏ចង់ប្រគេនបាត្រនេះ ដល់ព្រះសារីបុត្តដ៏មានអាយុ ឯព្រះសារីបុត្តដ៏មានអាយុ គង់នៅក្រុងសាកេត (កិច្ចនេះ) ខ្លួនអញត្រូវប្រតិបត្តិដូចម្តេចហ្ន៎ ។ ខណៈនោះ

អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ កីវចិរំ បនានន្ទ សារីបុត្តោ អាគច្ឆិស្សតីតិ ។ នវមំ វា ភគវា ទិវសំ ទសមំ វាតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ទសាហបរមំ អតិរេកបត្តំ ធារេតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ទសាហបរមំ អតិរេកបត្តោ ធារេតព្វោ តំ អតិក្កាម-យតោ និស្សគ្គិយំ បាចិត្តិយន្តិ ។

[១១៩] ទសាហបរមន្តិ ទសាហបរមតា ធារេ-តព្វោ ។ អតិរេកបត្តោ នាម អនធិដ្ឋិតោ អវិកប្បិតោ ។ បត្តោ នាម ទ្វេ បត្តា អយោបត្តោ មត្តិកាបត្តោ ។ តយោ បត្តស្ស វណ្ណា ឧក្កដ្ឋោ បត្តោ មជ្ឈិមោ បត្តោ ឱមកោ បត្តោ ។ ឧក្កដ្ឋោ នាម បត្តោ អឌ្ឍាឡ្ហកោ-ទនំ គណ្ហាតិ ចតុព្ភាគំ ខាទនីយំ[១] តទុបិយំ ព្យញ្ជនំ ។

១ ឱ. ម. ខាទនំ ។

អានន្ទដ៏មានអាយុបានក្រាបទូលរឿងនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលអានន្ទ ប៉ុន្មានថ្ងៃទៀត សារីបុត្តនឹងមក ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ប្រហែលជា ៩ ថ្ងៃ ឬ ១០ ថ្ងៃទៀត ទើបលោកនិមន្តមក ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមក ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុទ្រទ្រង់នូវអតិរេកបាត្របាន ១០ ថ្ងៃជាកំណត់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា អតិរេកបាត្រភិក្ខុទ្រទ្រង់ទុកបានត្រឹមកំណត់ ១០ ថ្ងៃ កន្លងហួសអំពីនោះទៅ អតិរេកបាត្រនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[១១៩] ត្រង់ពាក្យថា ត្រឹមកំណត់ ១០ ថ្ងៃនោះ គឺភិក្ខុគប្បីរក្សាទុកបានត្រឹម ១០ ថ្ងៃជាយ៉ាងច្រើន ។ បាត្រដែលភិក្ខុមិនបានអធិដ្ឋាន មិនបានវិកប្បហៅថា អតិរេកបាត្រ ។ ដែលហៅថា បាត្រ ។ នោះ មានពីរយ៉ាង គឺបាត្រដែក ១ បាត្រដី ១ ។ ខ្នាតនៃបាត្រមាន ៣ យ៉ាង គឺបាត្រយ៉ាងធំ បាត្រយ៉ាងកណ្ដាល បាត្រយ៉ាងតូច ។ បាត្រចំណុះបាយនៃអឌ្ឍរកន្ទះអាឡ្ហក (គឺ ២ នាឡិមគធៈ) ចំណុះខាទនីយស្មើចំណែកបាយជាគម្រប់ ៤ នឹងចំណុះម្ហូបល្មមសមគួរនឹងបាយនោះ ហៅថា បាត្រយ៉ាងធំ ។

មជ្ឈិមោ នាម បត្តោ នាឡិកោទនំ គណ្ហាតិ ចតុព្ភាគំ ខាទនីយំ តទុបិយំ ព្យញ្ជនំ ។ ឱមកោ នាម បត្តោ បត្ថោទនំ គណ្ហាតិ ចតុព្ភាគំ ខាទនីយំ តទុបិយំ ព្យញ្ជនំ ។ តតោ ឧក្កដ្ឋោ អបត្តោ ឱមកោ អបត្តោ ។

[១៦០] តំ អតិក្កាមយតោ និស្សគ្គិយោ ហោតិ(១) ឯកាទសេ អរុណុគ្គមនេ និស្សគ្គិយោ ហោតិ និស្សជ្ជិតព្វោ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វោ ។

[១៦១] តេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អយំ មេ ភន្តេ បត្តោ ទសាហាតិក្កន្តោ និស្សគ្គិយោ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន អាបត្តិ បដិគ្គហេតព្វា ។

១ ឥតោ បរំ សព្វត្ថ ឥតិសទ្ទោ ទិស្សតិ ។ សោ អតិរេកោតិ វេទិតព្វោ ។ តស្ស អតិរេកតា បឋមកឋិនសិក្ខាបទេ វុត្តនយេន វេទិតព្វា ។

បាត្រចំណុះបាយនៃអឡ្ហៈ ១ នាឡិមគធៈ ចំណុះខាទនីយស្មើចំណែកបាយជាគម្រប់ ៤ នឹងចំណុះម្ហូបល្មមសមគួរដល់បាយនោះ ហៅថា បាត្រយ៉ាងកណ្តាល ។ បាត្រចំណុះបាយនៃអឡ្ហៈ ១ បត្ថ គឺកន្លះនាឡិមគធៈចំណុះខាទនីយស្មើចំណែកបាយជាគម្រប់ ៤ នឹងចំណុះម្ហូបល្មមសមគួរ ដល់បាយនោះ ហៅថា បាត្រយ៉ាងតូច ។ បាត្រដែលធំហួស ឬតូចហួសជាងប្រមាណនោះ មិនហៅថា បាត្រទេ ។

[១២០] កាលភិក្ខុទុកបាត្រ ឲ្យកន្លងហួស អំពីកំណត់នោះទៅបាត្រនោះជានិស្សគ្គិយ គឺជានិស្សគ្គិយក្នុងពេលអរុណទី ១១ រះឡើងហើយ ភិក្ខុត្រូវលះបង់ដល់សង្ឃ ឬគណៈ ឬបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះបង់បាត្រយ៉ាងនេះឯង ។

[១២១] ភិក្ខុនោះ គប្បីចូលទៅរកសង្ឃ ហើយធ្វើចីពរឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុទាំងឡាយ ដែលជាចាស់រួចហើយអង្គុយច្រហោងប្រណម្យអញ្ជលី ហើយត្រូវពោលពាក្យយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន បាត្ររបស់ខ្ញុំនេះកន្លងហួស ១០ ថ្ងៃជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះ ដល់សង្ឃ ។ ភិក្ខុនោះ លុះលះបង់ហើយ ត្រូវសំដែងអាបត្តិចេញ ។ ភិក្ខុដែលឆ្លាសប្រតិពលគប្បីទទួលដឹងអាបត្តិ (របស់ភិក្ខុនោះ) ។

និស្សដ្ឋបត្តោ ទាតព្វោ[1] សុណាតុ មេ ភន្តេ សង្ឃោ អយំ បត្តោ ឥត្ថន្នាមស្ស ភិក្ខុនោ និស្សគ្គិយោ សង្ឃស្ស និស្សដ្ឋោ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ បត្តំ ឥត្ថន្នាមស្ស ភិក្ខុនោ ទទេយ្យាតិ ។

[១២២] តេន ភិក្ខុនា សម្ពហុលេ ភិក្ខូ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្សុ វចនីយា អយំ មេ ភន្តេ បត្តោ ទសាហាតិក្កន្តោ និស្សគ្គិយោ ឥមាហំ អាយស្មន្តានំ និស្សជ្ជាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន អាបត្តិ បដិគ្គហេតព្វា ។ និស្សដ្ឋបត្តោ ទាតព្វោ សុណន្តុ មេ អាយស្មន្តា អយំ បត្តោ[2] ឥត្ថន្នាមស្ស ភិក្ខុនោ និស្សគ្គិយោ អាយស្មន្តានំ និស្សដ្ឋោ ។ យទាយស្មន្តានំ បត្តកល្លំ អាយស្មន្តា ឥមំ បត្តំ ឥត្ថន្នាមស្ស ភិក្ខុនោ ទទេយ្យុន្តិ ។

---

១ និស្សដ្ឋបត្តោ ទាតព្វោ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ បត្តោ ទសាហាតិក្កន្តោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ បត្តោ ទសាហាតិក្កន្តោតិបិ ទិស្សតិ ។

បាត្រដែលភិក្ខុនោះលះបង់ហើយ សង្ឃត្រូវឲ្យ (ដល់លោកជាម្ចាស់ដើមវិញ) ដោយពោលពាក្យប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បាត្រនេះជារបស់ភិក្ខុឈ្មោះនេះ ជានិស្សគ្គិយ លោកបានលះបង់ហើយដល់សង្ឃ ។ បើកម្មនេះ មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវបាត្រនេះ ដល់ភិក្ខុឈ្មោះនេះវិញ ។

[១២២] ភិក្ខុអង្គនោះគប្បីចូលទៅរកពួកភិក្ខុច្រើន ហើយធ្វើចីពរឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងប្រណម្យអញ្ជលី ហើយត្រូវពោលពាក្យយ៉ាងនេះ នឹងគណភិក្ខុថា បពិត្រលោកទាំងឡាយដ៏ចម្រើន បាត្ររបស់ខ្ញុំនេះកន្លងហួស ១០ ថ្ងៃ ជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះ ដល់លោកដ៏មានអាយុទាំងឡាយ ។ ភិក្ខុនោះលុះលះបង់ហើយ ត្រូវសំដែងអាបត្តិចេញ ។ ភិក្ខុអ្នកឆ្លាសប្រតិពលគប្បីទទួលដឹងអាបត្តិ (របស់ភិក្ខុនោះ) ។ បាត្រដែលភិក្ខុលះបង់ហើយ គណភិក្ខុត្រូវឲ្យ (ដល់លោកវិញ) ដោយពោលពាក្យយ៉ាងនេះថា សូមលោកដ៏មានអាយុទាំងឡាយស្តាប់ខ្ញុំ បាត្រនេះ ជារបស់ភិក្ខុឈ្មោះនេះ ជានិស្សគ្គិយ លោកបានលះបង់ហើយ ដល់លោកដ៏មានអាយុទាំងឡាយ ។ បើកម្មនេះ មានកាលដ៏សមគួរ ដល់លោកដ៏មានអាយុទាំងឡាយ លោកដ៏មានអាយុទាំងឡាយ គប្បីឲ្យបាត្រនេះ ដល់ភិក្ខុឈ្មោះនេះវិញ ។

[១២៣] តេន ភិក្ខុនា ឯកំ ភិក្ខុំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អយំ មេ អាវុសោ បត្តោ ទសាហាតិក្កន្តោ និស្សគ្គិយោ ឥមាហំ អាយ-ស្មតោ និស្សជ្ជាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា ។ តេន ភិក្ខុនា អាបត្តិ បដិគ្គហេតព្វា ។ និស្សដ្ឋបត្តោ ទាតព្វោ ឥមំ បត្តំ អាយស្មតោ ទម្មីតិ ។

[១២៤] ទសាហាតិក្កន្តេ អតិក្កន្តសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ ទសាហាតិក្កន្តេ វេមតិកោ និស្សគ្គិយំ បាចិត្តិយំ ។ ទសាហាតិក្កន្តេ អនតិក្កន្តសញ្ញី និស្ស-គ្គិយំ បាចិត្តិយំ ។ អនធិដ្ឋិតេ អធិដ្ឋិតសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ អវិកប្បិតេ វិកប្បិតសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ អវិសជ្ជិតេ វិសជ្ជិតសញ្ញី

[១២៣] ភិក្ខុនោះ គប្បីចូលទៅរកភិក្ខុមួយអង្គ ហើយធ្វើចីពរឆៀងស្មាម្ខាង ហើយអង្គុយច្រហោងប្រណម្យអញ្ជលី ហើយត្រូវពោលពាក្យយ៉ាងនេះ នឹងភិក្ខុមួយអង្គថា ម្នាលអ្នកដ៏មានអាយុ បាត្ររបស់ខ្ញុំនេះ កន្លងហួស ១០ ថ្ងៃ ជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះ ដល់លោកដ៏មានអាយុ ។ លុះភិក្ខុនោះ លះបង់ហើយត្រូវសំដែងអាបត្តិចេញ ។ ភិក្ខុមួយអង្គនោះ ត្រូវទទួលដឹងអាបត្តិ (របស់ភិក្ខុនោះ) ។ បាត្រដែលភិក្ខុនោះលះបង់ហើយ ត្រូវបុគ្គលនោះឲ្យវិញដោយពោលថា ខ្ញុំឲ្យបាត្រនេះដល់លោកដ៏មានអាយុវិញ ។

[១២៤] បាត្រដែលកន្លងហួស ១០ ថ្ងៃហើយ ភិក្ខុសំគាល់ថា កន្លងហើយមែន បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលកន្លងហួស ១០ ថ្ងៃ តែភិក្ខុមានសេចក្តីសង្ស័យ បាត្រនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលកន្លងហួស ១០ ថ្ងៃហើយ តែភិក្ខុសំគាល់ថា មិនទាន់កន្លង បាត្រនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់បានអធិដ្ឋាន ភិក្ខុសំគាល់ថា បានអធិដ្ឋានហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់បានវិកប្ប ភិក្ខុសំគាល់ថា បានវិកប្បហើយ បាត្រនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់បានលះបង់ ភិក្ខុសំគាល់ថា បានលះបង់ហើយ

និស្សគ្គិយំ ចាចិត្តិយំ ។ អនជ្ជេ នជ្ជសញ្ញី និស្សគ្គិយំ ចាចិត្តិយំ ។ អវិនជ្ជេ វិនជ្ជសញ្ញី និស្សគ្គិយំ ចាចិត្តិយំ ។ អភិន្នេ ភិន្នសញ្ញី និស្សគ្គិយំ ចាចិត្តិយំ ។ អវិលុត្តេ វិលុត្តសញ្ញី និស្សគ្គិយំ ចាចិត្តិយំ ។

[១២៥] និស្សគ្គិយំ បត្តំ អវិសជ្ជិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។ ទសាហានតិក្កន្តេ អតិក្កន្តសញ្ញី អាបត្តិ ទុក្កដស្ស ។ ទសាហានតិក្កន្តេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ទសាហានតិក្កន្តេ អនតិក្កន្ត-សញ្ញី អនាបត្តិ ។

[១២៦] អនាបត្តិ អន្តោទសាហំ អធិដ្ឋេតិ វិកប្បេតិ វិសជ្ជេតិ នស្សតិ វិនស្សតិ ភិជ្ជតិ អច្ឆិន្ទិ-ត្វា គណ្ហាតិ[១] វិស្សាសំ គណ្ហាតិ[២] ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

១-២ ឱ. ម. គណ្ហន្តិ ។

បាត្រនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់បាត់ ភិក្ខុសំគាល់ថា បាត់ហើយ បាត្រនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់ខូចទេ តែភិក្ខុសំគាល់ថា ខូចហើយ បាត្រនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលមិនទាន់បែក ភិក្ខុសំគាល់ថា បែកហើយ បាត្រនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ បាត្រដែលចោរមិនទាន់ដណ្តើម ភិក្ខុសំគាល់ថា ចោរដណ្តើមយកទៅហើយ បាត្រនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[១២៥] ភិក្ខុមិនលះបង់បាត្រ ដែលជានិស្សគ្គិយ ហើយប្រើប្រាស់ (បាត្រនោះ) ត្រូវអាបត្តិទុក្កដ ។ បាត្រដែលមិនទាន់កន្លងហួស ១០ ថ្ងៃ ភិក្ខុសំគាល់ថា កន្លងហើយ ត្រូវអាបត្តិទុក្កដ ។ បាត្រដែលមិនទាន់កន្លងហួស ១០ ថ្ងៃ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ បាត្រដែលមិនទាន់កន្លងហួស ១០ ថ្ងៃ ភិក្ខុសំគាល់ថា មិនទាន់កន្លង ជាអនាបត្តិ ។

[១២៦] អាបត្តិមិនមានដល់ភិក្ខុ ដែលបានអធិដ្ឋាន បានវិកប្ប បានលះបង់ឲ្យទៅគេ ដល់ភិក្ខុដែលមានបាត្របាត់វិនាសបែកទៅ ចោរដណ្តើមយកទៅ ភិក្ខុដទៃកាន់យក ដោយវិស្សាសៈ ក្នុងរវាង ១០ ថ្ងៃ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

[១២៧] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ និស្សជ្ជិតព្វំ ន ទេន្តិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ និស្សជ្ជិតព្វោ ន ទាតព្វោ យោ ន ទទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។

[១២៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ មិនបានឲ្យនូវបាត្រ ដែលភិក្ខុលះបង់ហើយទៅម្ចាស់បាត្រវិញ ។ ភិក្ខុទាំងឡាយ បានក្រាបទូលរឿងនុ៎ះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បាត្រដែលគេលះបង់ហើយ ភិក្ខុមិនឲ្យវិញ មិនគួរទេ ភិក្ខុណា មិនឲ្យវិញ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

សិក្ខាបទទី ១ ចប់ ។

# ទុតិយសិក្ខាបទំ

[១២៨] តេន សមយេន ពុទ្ធោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន អញ្ញតរេន កុម្ភការេន ភិក្ខូ បវារិតា ហោន្តិ យេសំ អយ្យានំ បត្តេន អត្ថោ អហំ បត្តេនាតិ ។ តេន ខោ បន សមយេន ភិក្ខូ ន បត្តំ ជានិត្វា ពហូ បត្តេ វិញ្ញាបេន្តិ ។ យេសំ ខុទ្ទកា បត្តា តេ មហន្តេ បត្តេ វិញ្ញាបេន្តិ ។ យេសំ មហន្តា បត្តា តេ ខុទ្ទកេ បត្តេ វិញ្ញាបេន្តិ ។ អថខោ សោ កុម្ភការោ ភិក្ខូនំ ពហូ បត្តេ ករោន្តោ ន សក្កោតិ អញ្ញំ វិក្កាយិកំ ភណ្ឌំ កាតុំ អត្តនាបិ ន យាបេតិ បុត្តទារាបិស្ស កិលមន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ន មត្តំ ជានិត្វា ពហូ បត្តេ វិញ្ញាបេស្សន្តិ អយំ ឥមេសំ ពហូ បត្តេ ករោន្តោ ន សក្កោតិ អញ្ញំ វិក្កាយិកំ ភណ្ឌំ

# សិក្ខាបទទី ២

[១២៨] សម័យនោះ ព្រះពុទ្ធដ៏ទ្រង់យស កាលសម្រេចឥរិយាបថក្នុងនិគ្រោធារាម ជិតក្រុងកបិលវត្ថុ នាដែនសក្កៈ ។ សម័យនោះឯង ស្មូនឆ្នាំងម្នាក់ បវារណាភិក្ខុទាំងឡាយដោយពាក្យថា លោកម្ចាស់ទាំងឡាយណា មានសេចក្តីត្រូវការដោយបាត្រ ខ្ញុំព្រះករុណានឹងប្រគេនបាត្រដល់លោកម្ចាស់អង្គនោះ ៗ ។ ខណៈនោះឯង ភិក្ខុទាំងឡាយមិនដឹងប្រមាណ សូមបាត្រទាំងឡាយជាច្រើន ។ ពួកភិក្ខុណា មានបាត្រតូច ៗ ភិក្ខុទាំងនោះ ក៏សូមបាត្រធំ ៗ ។ ពួកភិក្ខុណា ដែលមានបាត្រធំ ៗ ភិក្ខុទាំងនោះ ក៏សូមបាត្រតូច ៗ ។ គ្រានោះឯង ស្មូនឆ្នាំងនោះ រវល់ធ្វើបាត្រជាច្រើនប្រគេនពួកភិក្ខុ ក៏មិនអាចដើម្បីនឹងធ្វើភាជន៍ សម្រាប់ចំណាយឯទៀតបាន សូម្បីនឹងរកចិញ្ចឹមខ្លួនក៏មិនបាន កូននឹងប្រពន្ធទាំងឡាយរបស់ស្មូនឆ្នាំងនោះសោត ក៏ព្រួយលំបាក ។ មនុស្សទាំងឡាយ ក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា គួរបើដែរ ពួកសមណៈជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្ត មិនដឹងប្រមាណហើយសូមបាត្រជាច្រើន ស្មូនឆ្នាំងនេះរវល់តែធ្វើបាត្រជាច្រើនប្រគេនភិក្ខុទាំងនេះ ក៏មិនអាចដើម្បីនឹងធ្វើនូវភាជន៍សម្រាប់ចំណាយឯទៀតបាន សូម្បីនឹងរកចិញ្ចឹមជីវិតខ្លួនក៏មិនបាន

កាតុំ អត្តនាបិ ន យាចេតិ បុត្តទារបិស្ស ភិល-មន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ ន មត្តំ ជានិត្វា ពហូ បត្តេ វិញ្ញាបេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ ន មត្តំ ជានិត្វា ពហូ បត្តេ វិញ្ញាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា ន មត្តំ ជានិត្វា ពហូ បត្តេ វិញ្ញាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ បត្តោ វិញ្ញាបេតព្វោ យោ វិញ្ញាបេយ្យ អាបត្តិ ទុក្កដស្ស ។

កូននឹងប្រពន្ធទាំងឡាយរបស់ស្មូនផ្ទាំងនោះសោតក៏ព្រួយលំបាក ។ ភិក្ខុទាំងឡាយ បានស្តាប់ច្បាស់ពាក្យដែលមនុស្សទាំងឡាយនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណា ដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា គួរបើដែរ ភិក្ខុទាំងឡាយ មិនដឹងប្រមាណហើយសូមបាត្រជាច្រើន ។ ខណៈនោះ ពួកភិក្ខុនោះ ក៏ក្រាបទូលរឿងនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយមិនដឹងប្រមាណហើយសូមបាត្រជាច្រើន ពិតមែនឬ ។ ភិក្ខុទាំងឡាយទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការណ៍នោះ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ គួរបើដែរ មោឃបុរសទាំងនោះមិនដឹងប្រមាណហើយសូមបាត្រជាច្រើន ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនឹងបាននាំឲ្យរឹងរឹតតែជ្រះថ្លាដល់ពួកជនដែលជ្រះថ្លាហើយ ក៏ទេ ។ បេ ។ លុះត្រាស់តិះដៀលហើយ ក៏ធ្វើនូវធម្មីកថា ត្រាស់ហៅពួកភិក្ខុមក ទើបទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសូមបាត្រឡើយ ភិក្ខុណាសូម ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

និស្សគ្គិយកណ្ឌេ បត្តវគ្គស្ស ទុតិយសិក្ខាបទស្ស អនុប្បញ្ញត្តិនិទានំ

[១២៩] តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ បត្តោ ភិន្នោ ហោតិ ។ អថខោ សោ ភិក្ខុ ភគវតា បដិក្ខិត្តំ បត្តំ វិញ្ញាបេតុន្តិ កុក្កុច្ចាយន្តោ ន វិញ្ញាបេតិ ហត្ថេសុ បិណ្ឌាយ ចរតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ហត្ថេសុ បិណ្ឌាយ ចរិស្សន្តិ សេយ្យថាបិ តិត្ថិយាតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ នដ្ឋបត្តស្ស វា ភិន្នបត្តស្ស វា បត្តំ វិញ្ញាបេតុន្តិ ។

[១៣០] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភគវតា អនុញ្ញាតំ នដ្ឋបត្តស្ស វា ភិន្នបត្តស្ស វា បត្តំ វិញ្ញាបេតុន្តិ តេ អប្បមត្តកេនបិ ភិន្នេន អប្បមត្តកេនបិ ឆិន្នេន អប្បមត្តកេនបិ ខណ្ឌេន

និស្សគ្គិយកណ្ឌ បត្តវគ្គ សិក្ខាបទទី ២ អនុប្បញ្ញត្តិនិទាន

[១២៩] សម័យនោះឯង ភិក្ខុ ១ រូបមានបាត្របែក ។ ឯភិក្ខុនោះសង្ស័យថា ការសូមបាត្រព្រះដ៏មានព្រះភាគទ្រង់ហាមហើយ មិនហ៊ានសូមបាត្រ ក៏ប្រព្រឹត្តបិណ្ឌបាត ដោយដៃទទេ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្ត មិនសមបីបើនឹងចរទៅបិណ្ឌបាត ដោយដៃទទេ ដូចជាពួកតិរ្ថិយសោះ ។ ភិក្ខុទាំងឡាយ បានស្តាប់ច្បាស់នូវពាក្យដែលមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ។ ទើបភិក្ខុទាំងនោះ ក្រាបទូលរឿងនុ៎ះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅពួកភិក្ខុមក ហើយទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានបាត្របាត់ ឬមានបាត្របែក ត្រូវសូមបាត្របាន ។

[១៣០] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថា ព្រះដ៏មានព្រះភាគបានទ្រង់អនុញ្ញាតឲ្យភិក្ខុដែលមានបាត្របាត់ ឬមានបាត្របែក គួរសូមបាត្របានដូច្នេះ សូម្បីមានបាត្របែក ឬធ្លុះ ឬដាច់ ឬស្នាមប្រេះ

អប្បមត្តកោនបិ វិលិខិតកោន ន មត្តំ ជានិត្វា ពហូ បត្តេ វិញ្ញាបេន្តិ[១] ។ អថខោ សោ កុម្ភការោ ភិក្ខូនំ តថេវ ពហូ បត្តេ ករោន្តោ ន សក្កោតិ អញ្ញំ វិក្កាយិកំ ភណ្ឌំ កាតុំ អត្តនាបិ ន យាបេតិ បុត្តទារាបិស្ស កិលមន្តិ ។ មនុស្សា តថេវ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ន មត្តំ ជានិត្វា ពហូ បត្តេ វិញ្ញា-បេស្សន្តិ អយំ ឥមេសំ ពហូ បត្តេ ករោន្តោ ន សក្កោតិ អញ្ញំ វិក្កាយិកំ ភណ្ឌំ កាតុំ អត្តនាបិ ន យាបេតិ បុត្តទារាបិស្ស កិលមន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ អប្បមត្តកោនបិ ភិន្នេន អប្ប-មត្តកោនបិ ខណ្ឌេន អប្បមត្តកោនបិ ខណ្ឌោន អប្ប-មត្តកោនបិ វិលិខិតកោន ន មត្តំ ជានិត្វា ពហូ បត្តេ

១ ឱ. ម. តេ អប្បមត្តកេនបិ ភិន្នេន អប្បមត្តកេនបិ ខណ្ឌេន វិលិខិតមត្តេនបិ ពហូ បត្តេ វិញ្ញាបេន្តិ ។

គ្រាន់តែបន្តិចបន្តួច ក៏គ្មានដឹងប្រមាណ ចេះតែសូមបាត្រគេជាច្រើន ។ គ្រានោះ ស្មូនផ្ទាំងនោះ រវល់ធ្វើបាត្រជាច្រើនប្រគេនភិក្ខុទាំងឡាយ ដូចកាលជាន់មុន ក៏មិនអាចនឹងធ្វើភាជន៍សម្រាប់ចំណាយឯទៀតបាន សូម្បីរកចិញ្ចឹមជីវិតខ្លួនក៏មិនកើត កូននឹងប្រពន្ធទាំងឡាយ របស់ស្មូនផ្ទាំងនោះ ក៏ព្រួយលំបាក ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ ដូចកាលជាន់មុនទៀតថា ហេតុអ្វីបានជាសមណៈទាំងឡាយជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្ត មិនដឹងប្រមាណ សូមបាត្រគេជាច្រើន ស្មូនផ្ទាំងនេះ រវល់តែធ្វើបាត្រជាច្រើនប្រគេនភិក្ខុទាំងនេះ ក៏មិនអាចដើម្បីនឹងធ្វើភាជន៍ដទៃ សម្រាប់ចំណាយបាន សូម្បីនឹងរកចិញ្ចឹមជីវិតខ្លួនក៏មិនកើត កូននឹងប្រពន្ធទាំងឡាយ របស់ស្មូនផ្ទាំងនោះសោតក៏ព្រួយលំបាក ។ ភិក្ខុទាំងឡាយ បានឮពាក្យដែលពួកមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វី បានជាពួកឆព្វគ្គិយភិក្ខុមានបាត្របែក ឬធ្លុះ ឬដាច់ ឬស្នាមប្រេះ គ្រាន់តែបន្តិចបន្តួចមិនដឹងប្រមាណ ចេះតែសូមបាត្រគេជាច្រើន ។ ទើបភិក្ខុទាំងនោះ

វិញ្ញាបេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ អប្បមត្តកេនបិ ភិន្នេន អប្បមត្តកេនបិ ឆិទ្ទេន អប្បមត្តកេនបិ ខណ្ឌេន អប្បមត្តកេនបិ វិលិខិតេន ន មត្តំ ជានិត្វា ពហូ បត្តេ វិញ្ញាបេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា អប្បមត្តកេនបិ ភិន្នេន អប្បមត្តកេនបិ ឆិទ្ទេន អប្បមត្តកេនបិ ភិន្នេន អប្បមត្តកេនបិ វិលិខិតេន ន មត្តំ ជានិត្វា ពហូ បត្តេ វិញ្ញាបេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឩនបញ្ចពន្ធនេន បត្តេន អញ្ញំ នវំ បត្តំ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។ តេន ភិក្ខុនា សោ បត្តោ ភិក្ខុបរិសាយ និស្សជ្ជិតព្វោ ។ យោ ច តស្សា ភិក្ខុបរិសាយ បត្តបរិយន្តោ សោ ច

ក្រាបទូលរឿងនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយមានបាត្របែក ឬធ្លុះ ឬដាច់ ឬស្នាមប្រេះគ្រាន់តែបន្តិចបន្តួច ក៏មិនដឹងប្រមាណ ចេះតែសូមបាត្រគេជាច្រើន ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការណ៍នោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ហេតុអ្វី បានជាអ្នកទាំងឡាយមានបាត្របែកតែបន្តិចបន្តួចខ្លះ ធ្លុះតែបន្តិចបន្តួចខ្លះ ដាច់តែបន្តិចបន្តួចខ្លះ ស្នាមប្រេះតែបន្តិចបន្តួចខ្លះ ក៏មិនដឹងប្រមាណហើយនាំគ្នា សូមបាត្រជាច្រើន ម្នាលមោឃបុរសទាំងឡាយ កម្មដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនឹងបាននាំឲ្យរឹងរឹតតែជ្រះថ្លាដល់ជនទាំងឡាយដែលជ្រះថ្លាហើយ ក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមានបាត្រមិនទាន់មានចំណងគ្រប់ ៥ អន្លើ ឲ្យគេរកបាត្រថ្មីទៀត (បាត្រនោះ) ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនោះ ត្រូវលះបង់បាត្រនោះក្នុងភិក្ខុបរិសទ្យ ។ បាត្រណាជាទីបំផុតរបស់ភិក្ខុបរិសទ្យនោះ

តស្ស ភិក្ខុនោ បទាតព្វោ អយន្តេ ភិក្ខុ បត្តោ យាវ ភេទនាយ ធារេតព្វោតិ ។ អយំ តត្ថ សាមីចីតិ ។

[១៣១] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ឩនបញ្ចពន្ធនោ នាម បត្តោ អពន្ធនោ វា ឯកពន្ធនោ វា ទ្វិពន្ធនោ វា តិពន្ធនោ វា ចតុព្ពន្ធនោ វា ។ អពន្ធនោកាសោ នាម បត្តោ យស្ស ទ្វង្គុលា រាជិ ន ហោតិ ។ ពន្ធនោកាសោ នាម បត្តោ យស្ស ទ្វង្គុលា រាជិ ហោតិ ។ នវោ នាម បត្តោ វិញ្ញត្តឹ ឧបាទាយ វុច្ចតិ ។ ចេតាបេយ្យាតិ វិញ្ញាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយោ ហោតិ សង្ឃមជ្ឈេ និស្សជ្ជិតព្វោ ។ សព្វេហេវ អធិដ្ឋិតបត្តំ គហេត្វា សន្និបតិតព្វំ ។ ន លាមកោ បត្តោ អធិដ្ឋាតព្វោ មហគ្ឃំ បត្តំ គហេស្សាមីតិ ។ សចេ លាមកំ បត្តំ អធិដ្ឋេតិ មហគ្ឃំ បត្តំ គហេស្សាមីតិ អាបត្តិ ទុក្កដស្ស ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វោ ។

បាត្រនោះ ភិក្ខុដែលបានសន្មត ត្រូវប្រគល់បាត្រនោះ ឲ្យដល់ភិក្ខុនោះ ដោយពាក្យថា ម្នាលភិក្ខុ នេះបាត្ររបស់លោក ៗ គប្បីប្រើប្រាស់ត្រាតែបែក ។ នេះ ជាសាមីចិកម្ម (គឺការប្រពៃ) ក្នុងការលះបង់បាត្រនោះ ។

[១៣១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ បាត្រដែលគ្មានចំណង ឬមានចំណងតែមួយអន្ទើ ឬពីរអន្ទើ បីអន្ទើ បួនអន្ទើ ហៅថា បាត្រមានចំណងមិនទាន់ដល់ ៥ អន្ទើ ។ បាត្រដែលមានស្នាមប្រេះបែកមិនទាន់ដល់ពីរធ្នាប់ ហៅថា បាត្រមិនទាន់មានឱកាសនៃចំណង ។ បាត្រដែលមានស្នាមប្រេះបែកប្រមាណដល់ពីរធ្នាប់ ហៅថា បាត្រមានឱកាសនៃចំណង (មួយអន្ទើ) ។ ដែលហៅថា បាត្រថ្មី សំដៅយកការសូមបាត្រជាប្រមាណ ។ ពាក្យថា ឲ្យគេរក សេចក្ដីថា ភិក្ខុសូមបាត្រ ត្រូវអាបត្តិទុក្កដតាមប្រយោគ បាត្រនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះបង់ក្នុងកណ្ដាលសង្ឃ ។ ភិក្ខុទាំងពួងត្រូវយកបាត្រ ដែលភិក្ខុបានអធិដ្ឋានហើយទៅប្រជុំគ្នា ។ ភិក្ខុមិនត្រូវអធិដ្ឋានបាត្រអាក្រក់ទុកដោយគិតថា អញនឹងយកបាត្រថ្លៃច្រើន ។ បើភិក្ខុអធិដ្ឋានបាត្រអាក្រក់ទុកដោយគិតថា អញនឹងយកបាត្រថ្លៃច្រើន ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់បាត្រយ៉ាងនេះ ។

និស្សគ្គិយកណ្ឌេ បត្តវគ្គស្ស ទុតិយសិក្ខាបទស្ស បត្តគ្គាហាបកភិក្ខុសម្មតិ

[១៣២] តេន ភិក្ខុនា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អយំ មេ ភន្តេ បត្តោ ឩនបញ្ចពន្ធនេន បត្តេន ចេតាបិតោ និស្សគ្គិយោ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន អាបត្តិ បដិគ្គហេតព្វា ។ បញ្ចហង្គេហិ សមន្នាគតោ ភិក្ខុ បត្តគ្គាហាបកោ សម្មន្និតព្វោ យោ ន ឆន្ទាគតឹ គច្ឆេយ្យ ន ទោសាគតឹ គច្ឆេយ្យ ន មោហាគតឹ គច្ឆេយ្យ ន ភយាគតឹ គច្ឆេយ្យ គហិតាគហិតញ្ច ជានេយ្យ ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ ភិក្ខុ យាចិតព្វោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ បត្តគ្គាហាបកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ

និស្សគ្គិយកណ្ឌ បត្តវគ្គ សិក្ខាបទទី ២ ការសន្មតភិក្ខុឲ្យជាអ្នកប្រគល់បាត្រ

[១៣២] ភិក្ខុនោះ ត្រូវចូលទៅរកសង្ឃ ធ្វើចីពរឆៀងស្មាម្ខាង ហើយសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ប្រណម្យអញ្ជលី ហើយពោលនឹងសង្ឃយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចម្រើន បាត្រ (ថ្មី) របស់ខ្ញុំនេះ គឺខ្ញុំមានបាត្រ (ចាស់) មិនទាន់មានចំណាង គ្រប់ ៥ អន្លើ ខ្ញុំឲ្យគេរកបាត្រទៀត បាត្រនេះ ជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះដល់សង្ឃ ។ លុះភិក្ខុលះបង់បាត្ររួចហើយ ត្រូវសំដែងអាបត្តិចេញ ។ ភិក្ខុអ្នកឈ្លាសអង់អាច ត្រូវទទួលអាបត្តិ ។ សង្ឃត្រូវសន្មតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកប្រគល់បាត្រ គឺភិក្ខុណាមួយដែលមិនបានប្រព្រឹត្តទៅដោយឆន្ទាគតិ ១ ទោសាគតិ ១ មោហាគតិ ១ ភយាគតិ ១ ដឹងនូវបាត្រដែលគេបានទទួល និងមិនទាន់បានទទួល ១ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ ។ ភិក្ខុឈ្លាសត្រូវអង្វរភិក្ខុ (នោះ) ជាមុន ។ លុះភិក្ខុឈ្លាសប្រតិពលអង្វររួចហើយ គប្បីប្រកាសឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មនេះ មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកប្រគល់បាត្រ ។ នេះវាចាប្រកាសសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ព្រះសង្ឃសន្មតភិក្ខុឈ្មោះនេះ

ឥត្ថន្នាមំ ភិក្ខុំ បត្តគ្គាហាបកំ សម្មន្នតិ ។ យស្សាយ-
ស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ បត្តគ្គាហាបកស្ស
សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។
សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ បត្តគ្គាហាបកោ ។
ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។
តេន សម្មតេន ភិក្ខុនា បត្តោ គាហេតព្វោ ។ ថេរោ
វត្តព្វោ គណ្ហាតុ ភន្តេ ថេរោ បត្តន្តិ ។ សចេ ថេរោ
គណ្ហាតិ ថេរស្ស បត្តោ ទុតិយស្ស គាហេតព្វោ ន ច
តស្ស អនុទ្ទយតាយ ន គាហេតព្វោ យោ ន គណ្ហេយ្យ
អាបត្តិ ទុក្កដស្ស ។ អបត្តកស្ស ន គាហេតព្វោ ។
ឯតេនេវ ឧបាយេន យាវ សង្ឃនវកា គាហេតព្វោ ។
យោ ច តស្សា ភិក្ខុបរិសាយ បត្តបរិយន្តោ សោ ច
តស្ស ភិក្ខុនោ បទាតព្វោ អយន្តេ ភិក្ខុ បត្តោ យាវ
ភេទនាយ ធារេតព្វោតិ ។ តេន ភិក្ខុនា សោ
បត្តោ ន អទេសេ និក្ខិបិតព្វោ ន អភោគេន

ឲ្យជាអ្នកប្រគល់បាត្រ ។ ការសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកប្រគល់បាត្រ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវពោលឡើង ។ សង្ឃបានសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកប្រគល់បាត្រហើយ ។ ការសន្មតនេះ សមគួរដល់សង្ឃ ហេតុនោះបានជាព្រះសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។ ភិក្ខុដែលសង្ឃសន្មតហើយនោះ ត្រូវប្រគល់បាត្រ (ឲ្យព្រះថេរៈ) ។ ភិក្ខុនោះ ត្រូវប្រាប់ព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមព្រះថេរៈទទួលយកបាត្រចុះ ។ បើព្រះថេរៈទទួល (បាត្រនោះ) ភិក្ខុនោះ ត្រូវយកបាត្ររបស់ព្រះថេរៈប្រគល់ឲ្យភិក្ខុទីពីរ ព្រះថេរៈមិនត្រូវខានទទួលយកបាត្រនោះទេ ដោយសេចក្តីអាណិតភិក្ខុនោះ ភិក្ខុណាមួយ មិនទទួល ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះមិនត្រូវប្រគល់បាត្រដល់ភិក្ខុដែលគ្មានបាត្រទេ ។ ភិក្ខុនោះ ត្រូវប្រគល់បាត្រដោយឧបាយនេះ ត្រាតែដល់ភិក្ខុខ្ជីក្នុងសង្ឃ ។ បាត្រណាមួយដែលជាទីបំផុតរបស់ភិក្ខុបរិសទ្យនោះ ភិក្ខុដែលសង្ឃបានសន្មតនោះ ត្រូវប្រគល់បាត្រឲ្យទៅភិក្ខុនោះ ដោយពាក្យថា នែភិក្ខុ បាត្ររបស់លោកនេះ លោកចូរប្រើប្រាស់ត្រាតែបែក ។ ភិក្ខុនោះ មិនត្រូវទុកបាត្រនោះក្នុងទីមិនគួរ

បរិភុញ្ជិតព្វោ ន វិសជ្ជេតព្វោ កថាយំ បត្តោ នស្សេយ្យ វា វិនស្សេយ្យ វា ភិជ្ជេយ្យ វាតិ សចេ អទេសេ វា និក្ខិបតិ អភោគេន វា បរិភុញ្ជតិ វិសជ្ជេតិ វា អាបត្តិ ទុក្កដស្ស ។ អយំ តត្ថ សាមីចីតិ អយំ តត្ថ អនុធម្មតា ។

[១៣៣] អពន្ធនេន បត្តេន អពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អពន្ធនេន បត្តេន ឯកពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អពន្ធនេន បត្តេន ទ្វិពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អពន្ធនេន បត្តេន តិពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អពន្ធនេន បត្តេន ចតុព្ពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ ឯកពន្ធនេន បត្តេន អពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ ឯកពន្ធនេន បត្តេន ឯកពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ ឯកពន្ធនេន បត្តេន ទ្វិពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។

មិនត្រូវប្រើប្រាស់បាត្រនោះ ដោយការប្រើប្រាស់មិនសមគួរ មិនត្រូវចោលបាត្រនោះឡើយ ដោយពាក្យថា បាត្រនេះ អប្រិយណាស់ បាត់ទៅចុះ ខូចទៅចុះ ឬបែកទៅចុះ បើភិក្ខុទុកដាក់ក្នុងទីមិនគួរក្តី ប្រើប្រាស់ដោយការប្រើប្រាស់មិនសមគួរក្តី លះបង់ចោលទៅក្តី ត្រូវអាបត្តិទុក្កដ ។ ពាក្យថា នេះជាសាមីចិកម្ម (គឺការប្រពៃ) ក្នុងការលះបង់បាត្រនោះ គឺថាពាក្យនេះជាពាក្យសមគួរតាមធម៌ក្នុងរឿងលះបង់បាត្រនោះ ។

[១៣៣] ភិក្ខុមានបាត្រមិនទាន់មានចំណាង (បើ) សុំបាត្រគ្មានចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង (បើ) សុំបាត្រមានចំណាងតែមួយអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង (បើ) សុំបាត្រមានចំណាងតែពីរអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង (បើ) សុំបាត្រមានចំណាងបីអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង (បើ) សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្លើ (បើ) សុំបាត្រគ្មានចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្លើ (បើ) សុំបាត្រមានចំណាងតែមួយអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្លើ (បើ) សុំបាត្រមានចំណាងពីរអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមាន

ឯកាពន្ធនេន បត្តេន តិពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ឯកាពន្ធនេន បត្តេន ចតុពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ទ្វិពន្ធនេន បត្តេន អពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ទ្វិពន្ធនេន បត្តេន ឯកាពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ទ្វិពន្ធនេន បត្តេន ទ្វិពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ទ្វិពន្ធនេន បត្តេន តិពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ទ្វិពន្ធនេន បត្តេន ចតុពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ តិពន្ធនេន បត្តេន អពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ តិពន្ធនេន បត្តេន ឯកាពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ តិពន្ធនេន បត្តេន ទ្វិពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ តិពន្ធនេន បត្តេន តិពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ តិពន្ធនេន បត្តេន ចតុពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ចតុពន្ធនេន បត្តេន អពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។

ចំណាងតែមួយអន្ទើ (បើ) សុំបាត្រមានចំណាងបីអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្ទើ (បើ) សុំបាត្រមានចំណាងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងពីរអន្ទើ (បើ) សុំបាត្រគ្មានចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងពីរអន្ទើ (បើ) សុំបាត្រមានចំណាងតែមួយអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងពីរអន្ទើ (បើ) សុំបាត្រមានចំណាងពីរអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងពីរអន្ទើ (បើ) សុំបាត្រមានចំណាងបីអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងពីរអន្ទើ (បើ) សុំបាត្រមានចំណាងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបីអន្ទើ (បើ) សុំបាត្រឥតចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបីអន្ទើ (បើ) សុំបាត្រមានចំណាងតែមួយអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបីអន្ទើ (បើ) សុំបាត្រមានចំណាងពីរអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបីអន្ទើ (បើ) សុំបាត្រមានចំណាងបីអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបីអន្ទើ (បើ) សុំបាត្រមានចំណាងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាងបួនអន្ទើ (បើ) សុំបាត្រឥតចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ ។

ចតុព្ពន្ធនេន បត្តេន ឯកពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ចតុព្ពន្ធនេន បត្តេន ទ្វិពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ចតុព្ពន្ធនេន បត្តេន តិពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ចតុព្ពន្ធនេន បត្តេន ចតុព្ពន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។

[១៣៤] អពន្ធនេន បត្តេន អពន្ធនោកាសំ បត្តំ... ឯកពន្ធនោកាសំ បត្តំ... ទ្វិពន្ធនោកាសំ បត្តំ... តិ-ពន្ធនោកាសំ បត្តំ... ចតុព្ពន្ធនោកាសំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ឯកពន្ធនេន បត្តេន អពន្ធ-នោកាសំ បត្តំ... ឯកពន្ធនោកាសំ បត្តំ... ទ្វិពន្ធនោ-កាសំ បត្តំ... តិពន្ធនោកាសំ បត្តំ... ចតុព្ពន្ធនោកាសំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ទ្វិពន្ធនេន បត្តេន អពន្ធនោកាសំ បត្តំ... ឯកពន្ធនោកាសំ បត្តំ... ទ្វិពន្ធនោកាសំ បត្តំ... តិពន្ធនោកាសំ បត្តំ...

ភិក្ខុមានបាត្រមានចំណាំងបួនអន្ទើ (បើ) សុំបាត្រមានចំណាំងតែមួយអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាំងបួនអន្ទើ (បើ) សុំបាត្រមានចំណាំងពីរអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាំងបួនអន្ទើ (បើ) សុំបាត្រមានចំណាំងបីអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាំងបួនអន្ទើ (បើ) សុំបាត្រមានចំណាំងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[១៣៤] ភិក្ខុមានបាត្រគ្មានចំណាំង (បើ) សុំបាត្រគ្មានឱកាសនៃចំណាំង... (បើ) សុំបាត្រមានឱកាសនៃចំណាំងតែមួយអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាំងពីរអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាំងបីអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាំងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាំងតែមួយអន្ទើ (បើ) សុំបាត្រគ្មានឱកាសនៃចំណាំង... (បើ) សុំបាត្រមានឱកាសនៃចំណាំងតែមួយអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាំងពីរអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាំងបីអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាំងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាំងពីរអន្ទើ (បើ) សុំបាត្រគ្មានឱកាសនៃចំណាំង... (បើ) សុំបាត្រមានឱកាសនៃចំណាំងតែមួយអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាំងពីរអន្ទើ...

ចតុព្ភង្គោកាសំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិ-យំ ។ តិពង្គេនេ បត្តេន អពង្គោកាសំ បត្តំ... ឯកពង្គ-ោកាសំ បត្តំ... ទ្វិពង្គោកាសំ បត្តំ... តិពង្គោកា-សំ បត្តំ... ចតុព្ភង្គោកាសំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ចតុព្ភង្គេនេ បត្តេន អពង្គោកាសំ បត្តំ... ឯកពង្គោកាសំ បត្តំ... ទ្វិពង្គោកាសំ បត្តំ... តិពង្គោកាសំ បត្តំ... ចតុព្ភង្គោកាសំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។

[១៣៥] អពង្គោកាសេន បត្តេន អពង្គំ បត្តំ... ឯកពង្គំ បត្តំ... ទ្វិពង្គំ បត្តំ... តិពង្គំ បត្តំ... ច-តុព្ភង្គំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ឯក-ពង្គោកាសេន បត្តេន អពង្គំ បត្តំ... ឯកពង្គំ បត្តំ... ទ្វិពង្គំ បត្តំ... តិពង្គំ បត្តំ... ចតុព្ភង្គំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ទ្វិពង្គោកាសេន

(បើ) សុំបាត្រមានឱកាសនៃចំណាង៍បីអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាង៍បួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាង៍បីអន្ទើ (បើ) សុំបាត្រគ្មានឱកាសនៃចំណាង៍... (បើ) សុំបាត្រមានឱកាសនៃចំណាង៍តែមួយអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាង៍ពីរអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាង៍បីអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាង៍បួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានចំណាង៍បួនអន្ទើ (បើ) សុំបាត្រគ្មានឱកាសនៃចំណាង៍.. (បើ) សុំបាត្រមានឱកាសនៃចំណាង៍តែមួយអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាង៍ពីរអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាង៍បីអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាង៍បួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[១៣៥] ភិក្ខុមានបាត្រ គ្មានឱកាសនៃចំណាង៍ (បើ) សុំបាត្រឥតចំណាង៍... បាត្រមានចំណាង៍តែមួយអន្ទើ... បាត្រមានចំណាង៍ពីរអន្ទើ... បាត្រមានចំណាង៍បីអន្ទើ... (បើ) សុំបាត្រមានចំណាង៍បួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រ មានឱកាសនៃចំណាង៍តែមួយអន្ទើ (បើ) សុំបាត្រគ្មានចំណាង៍... បាត្រមានចំណាង៍តែមួយអន្ទើ... បាត្រមានចំណាង៍ពីរអន្ទើ... បាត្រមានចំណាង៍បីអន្ទើ... (បើ) សុំបាត្រមានចំណាង៍បួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាង៍ពីរអន្ទើ

បត្តេន អពន្ធនំ បត្តំ... ឯកពន្ធនំ បត្តំ... ទ្វិពន្ធនំ បត្តំ... តិពន្ធនំ បត្តំ... ចតុព្វន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ តិពន្ធនោកាសេន បត្តេន អពន្ធនំ បត្តំ... ឯកពន្ធនំ បត្តំ... ទ្វិពន្ធនំ បត្តំ... តិ-ពន្ធនំ បត្តំ... ចតុព្វន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ចតុព្វន្ធនោកាសេន បត្តេន អពន្ធនំ បត្តំ... ឯកពន្ធនំ បត្តំ... ទ្វិពន្ធនំ បត្តំ... តិពន្ធនំ បត្តំ... ចតុព្វន្ធនំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។

[១៣៦] អពន្ធនោកាសេន បត្តេន អពន្ធនោកាសំ បត្តំ... ឯកពន្ធនោកាសំ បត្តំ... ទ្វិពន្ធនោកាសំ បត្តំ... តិពន្ធនោកាសំ បត្តំ... ចតុព្វន្ធនោកាសំ បត្តំ ចេតា-បេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ឯកពន្ធនោកាសេន បត្តេន អពន្ធនោកាសំ បត្តំ... ឯកពន្ធនោកាសំ បត្តំ... ទ្វិពន្ធនោកាសំ បត្តំ... តិពន្ធនោកាសំ បត្តំ... ចតុព្វន្ធ-នោកាសំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។

(បើ) សុំបាត្រឥតចំណាង... បាត្រមានចំណាងតែមួយអន្ទើ... បាត្រមានចំណាងពីរអន្ទើ... បាត្រមានចំណាងបីអន្ទើ... (បើ) សុំបាត្រមានចំណាងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រ មានឱកាសនៃចំណាងបីអន្ទើ (បើ) សុំបាត្រឥតចំណាង... បាត្រមានចំណាងតែមួយអន្ទើ... បាត្រមានចំណាងពីរអន្ទើ... បាត្រមានចំណាងបីអន្ទើ... (បើ) សុំបាត្រមានចំណាងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រ មានឱកាសនៃចំណាងបួនអន្ទើ (បើ) សុំបាត្រឥតចំណាង... បាត្រមានចំណាងតែមួយអន្ទើ... បាត្រមានចំណាងពីរអន្ទើ... បាត្រមានចំណាងបីអន្ទើ... (បើ) សុំបាត្រមានចំណាងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[១៣៦] ភិក្ខុមានបាត្រឥតឱកាសនៃចំណាង (បើ) សុំបាត្រឥតឱកាសនៃចំណាង... បាត្រមានឱកាសនៃចំណាងតែមួយអន្ទើ... បាត្រមានឱកាសនៃចំណាងពីរអន្ទើ... បាត្រមានឱកាសនៃចំណាងបីអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាងតែមួយអន្ទើ (បើ) សុំបាត្រឥតឱកាសនៃចំណាង... បាត្រមានឱកាសនៃចំណាងតែមួយអន្ទើ... បាត្រមានឱកាសនៃចំណាងពីរអន្ទើ... បាត្រមានឱកាសនៃចំណាងបីអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណាងបួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រ

ទ្វិពន្ធនោកាសេន បត្តេន អពន្ធនោកាសំ បត្តំ... ឯកពន្ធនោកាសំ បត្តំ... ទ្វិពន្ធនោកាសំ បត្តំ... តិពន្ធនោកាសំ បត្តំ... ចតុព្វន្ធនោកាសំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ តិពន្ធនោកាសេន បត្តេន អពន្ធនោកាសំ បត្តំ... ឯកពន្ធនោកាសំ បត្តំ... ទ្វិពន្ធនោកាសំ បត្តំ... តិពន្ធនោកាសំ បត្តំ... ចតុព្វន្ធនោកាសំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។ ចតុព្វន្ធនោកាសេន បត្តេន អពន្ធ-នោកាសំ បត្តំ... ឯកពន្ធនោកាសំ បត្តំ... ទ្វិពន្ធ-នោកាសំ បត្តំ... តិពន្ធនោកាសំ បត្តំ... ចតុព្វន្ធនោ-កាសំ បត្តំ ចេតាបេតិ និស្សគ្គិយំ ចាចិត្តិយំ ។

[១៣៧] អនាបត្តិ នដ្ឋបត្តស្ស ភិន្នបត្តស្ស ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។

មានឱកាសនៃចំណង៍ពីរអន្ទើ (បើ) សុំបាត្រឥតឱកាសនៃចំណង៍... បាត្រមានឱកាសនៃចំណង៍មួយអន្ទើ... បាត្រមានឱកាសនៃចំណង៍ពីរអន្ទើ... បាត្រមានឱកាសនៃចំណង៍បីអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណង៍បួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រ មានឱកាសនៃចំណង៍បីអន្ទើ (បើ) សុំបាត្រឥតឱកាសនៃចំណង៍... បាត្រមានឱកាសនៃចំណង៍តែមួយអន្ទើ... បាត្រមានឱកាសនៃចំណង៍ពីរអន្ទើ... បាត្រមានឱកាសនៃចំណង៍បីអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណង៍បួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានបាត្រមានឱកាសនៃចំណង៍បួនអន្ទើ (បើ) សុំបាត្រឥតឱកាសនៃចំណង៍... បាត្រមានឱកាសនៃចំណង៍តែមួយអន្ទើ... បាត្រមានឱកាសនៃចំណង៍ពីរអន្ទើ... បាត្រមានឱកាសនៃចំណង៍បីអន្ទើ... (បើ) សុំបាត្រមានឱកាសនៃចំណង៍បួនអន្ទើ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[១៣៧] អាបត្តិមិនត្រូវដល់ភិក្ខុដែលមានបាត្របាត់ ដល់ភិក្ខុមានបាត្របែក ដល់ភិក្ខុសុំបាត្រអំពីសំណាក់ពួកញាតិ ដល់ភិក្ខុសុំបាត្រអំពីសំណាក់ពួកជនដែលបវារណា ដល់ភិក្ខុសុំបាត្រដើម្បីឲ្យអ្នកដទៃ ដល់ភិក្ខុបានបាត្រមកដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាង៍ដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់ ។

# តតិយសិក្ខាបទំ

[១៣៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា បិលិន្ទវច្ឆោ រាជគហេ បព្ភារំ សោធាបេតិ លេណំ[១] កត្តុកាមោ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ យេនាយស្មា បិលិន្ទវច្ឆោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ បិលិន្ទវច្ឆំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អាយស្មន្តំ បិលិន្ទវច្ឆំ ឯតទវោច កឹ ភន្តេ ថេរោ ការាបេតីតិ ។ បព្ភារំ មហារាជ សោធាបេមិ លេណំ កត្តុកាមោតិ ។ អត្ថោ ភន្តេ អយ្យស្ស អារាមិកេ-ជាតិ ។ ន ខោ មហារាជ ភគវតា អារាមិកោ

---

១ លេនន្តិបិ បាឋោ ។

# សិក្ខាបទទី ៣

[១៣៨] សម័យនោះ ព្រះពុទ្ធដ៏ទ្រង់យស កាលគង់ក្នុងវិហារជេតពន ដែលជារបស់អនាថបិណ្ឌិកមហាសេដ្ឋី ក្បែរក្រុងសាវត្ថី ។ គ្រានោះឯង បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ប្រាថ្នានឹងធ្វើទីជ្រកកោន ទើបឲ្យគេជម្រះសំអាតញកភ្នំក្បែរក្រុងរាជគ្រឹះ ។ លំដាប់នោះ ព្រះបាទពិម្ពិសារសេនិយរាជ(១)ជាធំក្នុងដែនមគធៈ ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរដ៏មានអាយុ លុះព្រះរាជដំណើរទៅដល់ហើយ ក៏បង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយគង់នៅក្នុងទីសមគួរ ។ ព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈ ទ្រង់គង់នៅក្នុងទីសមគួរហើយ ទើបមានព្រះរាជឱង្ការនឹងបិលិន្ទវច្ឆត្ថេរដ៏មានអាយុថា លោកម្ចាស់ លោកឲ្យគេធ្វើអ្វី ។ បិលិន្ទវច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ អាត្មាភាពចង់ធ្វើកន្លែងជ្រកកោន បានជាឲ្យគេជម្រះសំអាតញកភ្នំ ។ ទ្រង់ក៏សួរថា លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ត្រូវការអារាមិកជន (មនុស្សថែទាំរក្សាអារាម) ឬទេ ។ ព្រះថេរៈថ្វាយព្រះពរថា បពិត្រមហារាជ អារាមិកជនព្រះដ៏ទ្រង់ព្រះភាគ

---

១ ស្តេចជាធំលើសេនាទាហានគង់សំដៅសេចក្តីថា ព្រះបាទពិម្ពិសារទ្រង់ជាមហាក្សត្រិយ៍សឹក បានជាមានគុណសព្ទមេទ័ពនាំមុខថា សេនិយោ មាគធោ រាជា ។

អនុញ្ញាតោតិ ។ តេនហិ ភន្តេ ភគវន្តំ បដិបុច្ឆិត្វា មម អារោចេយ្យាថាតិ ។ ឯវំ មហារាជាតិ ខោ អាយស្មា បិលិន្ទវច្ឆោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស បច្ចស្សោសិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ រាជានំ មាគធំ សេនិយំ ពិម្ពិសារំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អាយស្មតា បិលិន្ទវច្ឆេន ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា អាយស្មន្តំ បិលិន្ទវច្ឆំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ ភគវតោ សន្តិកេ ទូតំ បាហេសិ រាជា ភន្តេ មាគធោ សេនិយោ ពិម្ពិសារោ អារាមិកំ ទាតុកាមោ កថំ នុ ខោ ភន្តេ បដិបជ្ជិតព្វន្តិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អារាមិកន្តិ ។ ទុតិយម្បិ ខោ រាជា មាគធោ សេនិយោ

មិនទាន់ទ្រង់អនុញ្ញាតនៅឡើយទេ ។ ទ្រង់ត្រាស់ថា លោកម្ចាស់ បើដូច្នោះ លោកម្ចាស់គួរទូលសួរព្រះដ៏ទ្រង់ព្រះភាគ ហើយសឹមមកប្រាប់ញោម ។ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ក៏ទទួលព្រះរាជឱង្ការព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែលមគធៈថា ថ្វាយព្រះពរមហារាជ ។ ខណៈនោះឯង បិលិន្ទវច្ឆត្ថេរដ៏មានអាយុ បានពន្យល់ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈឲ្យទ្រង់ឃើញច្បាស់ ឲ្យទ្រង់សមាទាន ឲ្យទ្រង់ក្លៀវក្លា ឲ្យទ្រង់រីករាយដោយធម្មីកថា ។ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ដែលបិលិន្ទវច្ឆត្ថេរដ៏មានអាយុបានឲ្យទ្រង់ឃើញជាក់ស្តែង ឲ្យទ្រង់សមាទាន ឲ្យទ្រង់ក្លៀវក្លា ឲ្យទ្រង់រីករាយ ដោយធម្មីកថាហើយ ទ្រង់ក៏ក្រោកចាកអាសនៈ បង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយទ្រង់ធ្វើប្រទក្សិណយាត្រាចេញទៅ ។ លំដាប់នោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុប្រើបម្រើទៅកាន់សំណាក់ព្រះដ៏មានព្រះភាគម្ចាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់ចង់ប្រទានអារាមិកជនឲ្យ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគួរបដិបត្តិដូចម្តេច ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគម្ចាស់ ឲ្យប្រជុំភិក្ខុសង្ឃហើយទ្រង់សំដែងធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអារាមិកជន ។ ព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈ

និស្សគ្គិយកណ្ឌេ បត្តវគ្គស្ស តតិយសិក្ខាបទស្ស និទានំ

ពិម្ពិសារោ យេនាយស្មា បិលិន្ទវច្ឆោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ បិលិន្ទវច្ឆំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អាយស្មន្តំ បិលិន្ទវច្ឆំ ឯតទវោច អនុញ្ញាតោ ភន្តេ ភគវតា អារាមិកោតិ ។ ឯវំ មហារាជាតិ ។ តេនហិ ភន្តេ អយ្យស្ស អារាមិកំ ទម្មីតិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អាយស្មតោ បិលិន្ទវច្ឆស្ស អារាមិកំ បដិស្សុណិត្វា វិស្សរិត្វា ចិរេន សតឹ បដិលភិត្វា អញ្ញតរំ សព្វត្ថកំ មហាមត្តំ អាមន្តេសិ យោ មយា ភណេ អយ្យស្ស អារាមិកោ បដិស្សុតោ ទិន្នោ សោ អារាមិកោតិ ។ នខោ ទេវ អយ្យស្ស អារាមិកោ ទិន្នោតិ ។ កីវចិរំ នុ ខោ ភណេ ឥតោ រត្តិ[១] ហោតីតិ ។ អថខោ សោ មហាមត្តោ រត្តិយោ គណេត្វា[២] រាជានំ មាគធំ សេនិយំ ពិម្ពិសារំ ឯតទវោច

១ ឱ. ម. ហិតំ ។ ២ ឱ. ម. វិគណេត្វា ។

ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរដ៏មានអាយុជាគម្រប់ពីរដង លុះយាងចូលទៅហើយ ទើបទ្រង់បង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយគង់នៅក្នុងទីសមគួរមួយ ។ លុះព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈគង់ស្រួលបួលហើយ មានព្រះបន្ទូលនឹងបិលិន្ទវច្ឆត្ថេរដ៏មានអាយុថា បពិត្រលោកម្ចាស់ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់អនុញ្ញាតអារាមិកជនហើយឬ ។ បិលិន្ទ-វច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ ព្រះអង្គបានអនុញ្ញាតហើយ ។ ទ្រង់ត្រាស់ថា បពិត្រលោកដ៏ចម្រើន បើដូច្នោះ ញោមប្រគេនអារាមិកជនម្នាក់ដល់លោកម្ចាស់ ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈទ្រង់ប្ដេជ្ញាថា ប្រគេនអារាមិកជន ដល់បិលិន្ទវច្ឆត្ថេរដ៏មានអាយុហើយក៏ភ្លេចព្រះស្មារតី យូរបន្តិចទៅទ្រង់រលឹកឃើញវិញ ទើបទ្រង់ត្រាស់ហៅមហាអាមាត្យម្នាក់ ជាអ្នកសម្រេចរាជការទាំងពួងថា នែមហាអាមាត្យអារាមិកជនណា ដែលយើងបម្រុងនឹងប្រគេនលោកម្ចាស់ អារាមិកជននោះយើងបានប្រគេនលោកហើយឬ ។ មហាអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព អារាមិកជនទ្រង់មិនទាន់ប្រគេនដល់លោកម្ចាស់នៅឡើយទេ ។ ស្ដេចត្រាស់សួរថា នែមហាអាមាត្យ រាប់ពីរាត្រីនេះទៅបានប៉ុន្មានរាត្រីហើយ ។ លំដាប់នោះ មហាអាមាត្យនោះ បានរាប់រាត្រីសព្វគ្រប់ហើយ ក្រាបទូលព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ដូច្នេះថា

បញ្ច នេវ វត្ថិសតានីតិ ។ តេនហិ ភណេ អយ្យស្ស បញ្ច អាភមិកសតានិ នេហីតិ[១] ។ ឯវំ នេភតិ ខោ សោ មហាមត្តោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស បដិស្សុណិត្វា អាយស្មតោ បិលិន្ទវច្ឆស្ស បញ្ច អាភមិកសតានិ អទាសិ[២] ។ ចាដិយេក្កោ គាមោ និវិសិ ។ អាភមិកគាមកោតិបិ នំ អាហំសុ បិលិន្ទវច្ឆគាមកោតិបិ[៣] នំ អាហំសុ ។

[១៣៩] តេន ខោ បន សមយេន អាយស្មា បិលិន្ទវច្ឆោ តស្មឹ គាមកេ កុលុបកោ ហោតិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ បិលិន្ទវច្ឆគាមកំ បិណ្ឌាយ ចារិសិ ។ តេន ខោ បន សមយេន តស្មឹ គាមកេ ឧស្សវោ ហោតិ ។ ទារកា អលង្កតា មាលាកិតា កីឡន្តិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ បិលិន្ទវច្ឆគាមកេ សបទានំ បិណ្ឌាយ ចរមានោ យេន អញ្ញតរស្ស អាភមិកស្ស និវេសនំ តេនុបសង្កមិ

១ ឱ. ម. ទេថាតិ ។ ២ ឱ. ម. បាទាសិ ។ ៣ ឱ. ម. បិលិន្ទគាមកោតិបិ ។

បពិត្រព្រះសម្មតិទេព បាន ៥០០ រាត្រីហើយ ។ ស្ដេចត្រាស់ថា នែមហាអាមាត្យ បើដូច្នោះ អ្នកចូរប្រគេនអារាមិកជន ៥០០ នាក់ទៅលោកម្ចាស់ចុះ ។ មហាអាមាត្យនោះ ទទួលព្រះរាជឱង្ការព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈថា សូមទ្រង់មេត្តាប្រោសយ៉ាងហ្នឹងហើយ ៗ បានប្រគេនអារាមិកជន ៥០០ នាក់ដល់បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ។ ទីនោះបានជាស្រុកមួយផ្សេងដោយឡែក ។ ជនទាំងឡាយហៅស្រុកនោះថា អារាមិកគ្រាមខ្លះ ហៅថា បិលិន្ទវច្ឆគ្រាមខ្លះ ។

[១៣៩] សម័យនោះឯង បិលិន្ទវច្ឆត្ថេរដ៏មានអាយុជាជីតុន ក្នុងស្រុកនោះ ។ គ្រានោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ ចូលទៅបិណ្ឌបាតក្នុងបិលិន្ទវច្ឆគ្រាម នាវេលាព្រឹកព្រហាម ។ សម័យនោះឯង មានល្បែងមហោស្រពក្នុងស្រុកនោះ ។ ពួកក្មេង ៗ បានប្រដាប់តាក់តែងដោយផ្កាកម្រង លេងមហោស្រប ។ លំដាប់នោះ បិ-លិន្ទវច្ឆត្ថេរដ៏មានអាយុ កំពុងត្រេចទៅបិណ្ឌបាត តាមលំដាប់ច្រកក្នុងបិលិន្ទ-វច្ឆគ្រាម បានចូលទៅកាន់លំនៅរបស់អារាមិកជនម្នាក់ លុះចូលទៅហើយ

១៧១

និស្សគ្គិយកណ្ឌេ បត្តវគ្គស្ស តតិយសិក្ខាបទស្ស និទានំ

ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ តេន ខោ បន សមយេន តស្សា អារាមិកិនិយា ធីតា អញ្ញេ ទារ-កេ អលង្កតេ មាលាកិតេ បស្សិត្វា រោទតិ មាលំ មេ ទេថ អលង្ការំ មេ ទេថាតិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ តំ អារាមិកិនឹ ឯតទវោច កិស្សាយំ ទារិកា រោទតីតិ ។ អយំ ភន្តេ ទារិកា អញ្ញេ ទារកេ អលង្កតេ មាលាកិតេ បស្សិត្វា រោទតិ មាលំ មេ ទេថ អលង្ការំ មេ ទេថាតិ កុតោ អម្ហាកំ ទុគ្គតានំ មាលា កុតោ អលង្ការោតិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ អញ្ញតរំ តិណណ្ឌុបកំ គហេត្វា តំ អារាមិកិនឹ ឯតទវោច ហន្ទិមំ តិណណ្ឌុបកំ តស្សា ទារិកាយ សីសេ បដិមុញ្ចាហីតិ[១] ។ អថខោ សា អារាមិកិនី តំ តិណណ្ឌុបកំ គហេត្វា តស្សា ទារិកាយ សីសេ បដិមុញ្ចិ ។ សា អហោសិ សុវណ្ណមាលា អភិរូបា ទស្សនីយា បាសាទិកា ។ នត្ថិ តាទិសា រញ្ញោបិ អន្តេបុរេ សុវណ្ណមាលា ។ មនុស្សា រញ្ញោ មាគធស្ស

១ ឱ. ម. បដិមុញ្ចាតិ ។

ទើបអង្គុយលើអាសនៈដែលគេរៀបចំប្រគេន ។ សម័យនោះឯង ធីតារបស់ស្រីរក្សាអារាមនោះឃើញទារកឯទៀត ៗ ប្រដាប់តាក់តែងដោយផ្កាកម្រងហើយ ក៏យំសុំថា ម៉ែចូរឲ្យផ្កាកម្រងមកខ្ញុំ ម៉ែចូរឲ្យគ្រឿងប្រដាប់មកខ្ញុំ ។ គ្រានោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ បាននិយាយពាក្យនេះនឹងស្រីរក្សាអារាមនោះថា នាងទារិកានេះ យំទារអ្វី ។ ស្រីរក្សាអារាមទូលថា លោកម្ចាស់ នាងទារិកានេះ ឃើញទារកឯទៀត ៗ ប្រដាប់តាក់តែងដោយផ្កាកម្រង បានជាយំទារថា ម៉ែចូរឲ្យផ្កាកម្រងមកខ្ញុំ ម៉ែចូរឲ្យគ្រឿងប្រដាប់មកខ្ញុំ យើងខ្ញុំជាអ្នកក្រលំបាក នឹងបានផ្កាកម្រងមកពីណា នឹងបានគ្រឿងប្រដាប់មកពីណា ។ ខណៈនោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុចាប់រង្វេលស្មៅ ១ ហើយនិយាយពាក្យនេះ នឹងស្រីរក្សាអារាមនោះថា ហ៏! នាងចូរបំពាក់រង្វេលស្មៅនេះ លើក្បាលរបស់ក្មេងស្រីនោះចុះ ។ ពេលនោះ ស្រីរក្សាអារាមនោះ យករង្វេលស្មៅនោះ បំពាក់លើក្បាលរបស់នាងទារិកានោះ ។ រង្វេលស្មៅនោះ ក៏ក្លាយជាកម្រងមាសល្អល្អះមុខគួរពិតពិលរមិលមើលជារបស់គួរស្រឡាញ់ ។ កម្រងមាសបែបនោះ សូម្បីក្នុងព្រះរាជវាំងស្តេច ក៏រកគ្មានដែរ ។ មនុស្សទាំងឡាយទៅក្រាបទូល ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈថា

សេនិយស្ស ពិម្ពិសារស្ស អារោចេសុំ អមុកស្ស ទេវ អារាមិកស្ស ឃរេ សុវណ្ណមាលា អភិរូបា ទស្សនីយា បាសាទិកា នត្ថិ តាទិសា ទេវស្សាបិ អន្តេបុរេ សុវណ្ណមាលា កុតោ តស្ស ទុគ្គតស្ស និស្សំសយំ ចោរិកាយ អាភតាតិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ តំ អារាមិកកុលំ ពន្ធាបេសិ ។ ទុតិយម្បិ ខោ អាយស្មា បិលិន្ទវច្ឆោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ បិលិន្ទវច្ឆគាមកំ បិណ្ឌាយ បាវិសិ បិលិន្ទវច្ឆគាមកេ សបទានំ បិណ្ឌាយ ចរមានោ យេន តស្ស អារាមិកស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បដិវិស្សកេ បុច្ឆិ កហំ ឥមំ អារាមិកកុលំ គតន្តិ ។ ឯតិស្សា ភន្តេ សុវណ្ណមាលាយ ការណា រញ្ញា ពន្ធាបិតន្តិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ យេន រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ យេនាយស្មា

បពិត្រសម្មតិទេព កម្រងមាសក្នុងផ្ទះ របស់អារាមិកជនឯនោះ ល្អល្អះ មុខគួរពិតពិលរមិលមើលជារបស់គួរស្រឡាញ់ សូម្បីក្នុងព្រះរាជវាំងរបស់ព្រះអង្គក៏ពុំមានកម្រងមាសដូច្នោះដែរ មនុស្សខ្សត់ទុគ៌តនោះ នឹងបានកម្រងមាសមកពីណា ច្បាស់ជាវាលួចយករបស់គេ ជាប្រាកដ ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់ឲ្យរាជបុរសទៅកោះពួកត្រកូលអារាមិកជននោះមក ។ វេលាព្រឹក ព្រហាមបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ ចូលទៅបិណ្ឌបាតនាបិលិន្ទវច្ឆគ្រាមជាគម្រប់ពីរដង កាលដើរទៅបិណ្ឌបាត ក្នុងបិលិន្ទវច្ឆគ្រាមជាលំដាប់ ៗ ទៅ ទើបចូលទៅកាន់លំនៅរបស់អារាមិកជននោះ លុះចូលទៅដល់ហើយ សួរពួកជនដែលជាទីស្និទ្ធស្នាលថា ត្រកូលអារាមិកជននេះ ទៅណាទៅ ។ ពួកជនពិតថា លោកម្ចាស់ ស្តេចឲ្យរាជបុរស មកចាប់ចងយកទៅហើយ ព្រោះហេតុតែកម្រងមាសនោះឯង ។ លំដាប់នោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ក៏ចូលទៅកាន់ព្រះរាជ-និវេសន៍របស់ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ លុះទៅដល់ហើយ គង់លើអាសនៈដែលគេតាក់តែងប្រគេន ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរ

១៧៣

និស្សគ្គិយកណ្ឌេ បត្តវគ្គស្ស តតិយសិក្ខាបទស្ស និទានំ

បិលិន្ទវច្ឆោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ បិលិន្ទវច្ឆំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ រាជានំ មាគធំ សេនិយំ ពិម្ពិសារំ អាយស្មា បិលិន្ទវច្ឆោ ឯតទវោច កិស្ស មហារាជ អារាមិកកុលំ ពន្ធាមិតន្តិ ។ តស្ស ភន្តេ អារាមិកស្ស ឃរេ សុវណ្ណ-មាលា អភិរូចា ទស្សនីយា ចាសាទិកា នត្ថិ តាទិសា អម្ហាកំបិ អន្តេបុរេ សុវណ្ណមាលា កុតោ តស្ស ទុគ្គតស្ស និស្សំសយំ ចោរិកាយ អាភតាតិ ។ អថខោ អាយស្មា បិលិន្ទវច្ឆោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស ចាសាទំ សុវណ្ណន្តិ អធិមុច្ចិ ។ សោ អហោសិ សព្វ-សោវណ្ណមយោ ។ ឥទំ បន តេ មហារាជ តាវពហុំ សុវណ្ណំ កុតោតិ ។ អញ្ញាតំ ភន្តេ អយ្យស្សេវេសោ[១] ឥទ្ធានុភាវោតិ តំ អារាមិកកុលំ មុញ្ចាបេសិ ។

១ ឱ. ម. អយ្យស្ស ។

ដ៏មានអាយុ លុះដល់ហើយក៏ថ្វាយបង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយគង់នៅក្នុងទីសមគួរ ។ លុះព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈ ទ្រង់គង់ស្រួលបួលហើយ ទើបបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ថ្វាយព្រះពរថា បពិត្រមហារាជ ហេតុអ្វីបានជាព្រះអង្គ ឲ្យរាជបុរសទៅចាប់ត្រកូលអារាមិកជនមកឃុំ ។ ព្រះបាទពិម្ពិសារត្រាស់ថា លោកម្ចាស់ នាផ្ទះរបស់អារាមិកជននោះ មានកម្រងមាសល្អល្អះ មុខគួរពិតពិលរមិលមើល ជារបស់មានតម្លៃ សូម្បីក្នុងវាំងរបស់ញោម ក៏មិនមានកម្រងមាសដូច្នោះដែរ អ្នកខ្សត់ទុគ៌តនោះ នឹងបានកម្រងមាសមកពីណា ច្បាស់ជាវាលួចយករបស់គេហើយ ។ ខណៈនោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ក៏អធិដ្ឋានប្រាសាទរបស់ព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈ ឲ្យក្លាយជាមាសទៅ ។ ប្រាសាទទាំងនោះ ក៏ក្លាយទៅជាមាសទាំងអស់ ។ បិលិន្ទវច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ មាសនេះច្រើនដល់ម៉្លេះ ព្រះអង្គបានមកពីណា ។ ស្តេចត្រាស់ថា ខ្ញុំមិនដឹងទេ លោកម្ចាស់ របស់ទាំងនេះ ប្រហែលជាសម្រេចដោយឥទ្ធានុភាព[១] របស់លោកម្ចាស់ទេដឹង ហើយត្រាស់ឲ្យដោះលែងត្រកូលអារាមិកជននោះទៅ ។

---

១ គឺសម្រេចដោយឫទ្ធិ ដែលព្រះថេរៈអធិស្ឋាន ។

[១៤០] មនុស្សា អយ្យេន កិរ បិលិន្ទវច្ឆេន សរា-ជិកាយ បរិសាយ ឧត្តរិមនុស្សធម្មំ ឥទ្ធិបាដិហារិយំ[១] ទស្សិតន្តិ អត្តមនា អភិប្បសន្នា អាយស្មតោ បិ-លិន្ទវច្ឆស្ស បញ្ច ភេសជ្ជានិ អភិហរឹសុ សេយ្យថីទំ សប្បឹ នវនីតំ តេលំ មធុំ ផាណិតំ ។ បកតិយាបិចាយ-ស្មា បិលិន្ទវច្ឆោ លាភី ហោតិ បញ្ចន្នំ ភេសជ្ជានំ លទ្ធំ លទ្ធំ បរិសាយ វិសជ្ជេតិ ។ បរិសា ចស្ស ហោតិ ពាហុល្លិកា លទ្ធំ លទ្ធំ កោលម្ពេបិ ឃដេបិ បូរេត្វា បដិសាមេតិ បរិស្សាវនានិបិ ថវិកាយោបិ បូរេត្វា វាត-បានេសុ លគ្គេតិ ។ តានិ ឱលីនវិលីនានិ តិដ្ឋន្តិ ។ ឧន្ទុរេហិបិ វិហារា ឱកិណ្ណវិកិណ្ណា ហោន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ អន្តោកោដ្ឋាគារិកា ឥមេ សមណា សក្យ-បុត្តិយា សេយ្យថាបិ រាជា មាគធោ សេនិយោ ពិម្ពិសារោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ

១ ឥទ្ធិប្បាដិហារិយន្តិ អម្ហាកំ មតិ ។

[១៤០] មនុស្សទាំងឡាយឮដំណឹងថា បិលិន្ទវច្ឆត្ថេរ ជាម្ចាស់ បានសំដែងឥទ្ធិបាដិហារិយៈ (ឥទ្ធិឫទ្ធិដ៏អស្ចារ្យចំឡែក) ជាមនុស្សធម៌ ដ៏ខ្ពង់ខ្ពស់ ដល់បរិស័ទ្យព្រមទាំងព្រះរាជា ហើយក៏មានចិត្តត្រេកអរជ្រះថ្លា នាំយកនូវភេសជ្ជៈ ៥ យ៉ាងមកបូជាបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ភេសជ្ជៈ ៥ នោះគឺ សប្បិ (ទឹកដោះរាវ) នវនីតៈ (ទឹកដោះខាប់) តេលៈ (ប្រេង) មធុ (ទឹកឃ្មុំ) ផាណិតៈ (ទឹកអំពៅ ឬស្ករអំពៅ) ។ ឯបិលិន្ទវច្ឆត្ថេរដ៏មានអាយុតែងបានភេសជ្ជៈ ៥ ហើយរមែងចែករបស់ដែលលោកបានមក ៗ ទៅដល់បរិស័ទ្យ (សិស្សរបស់លោក) ដោយប្រក្រតី ។ ឯបរិស័ទ្យរបស់លោកនោះ តែងបានភេសជ្ជៈទាំងនោះច្រើនរឿយ ៗ បានដាក់ទុករបស់ដែលបានមក ៗ ក្នុងថ្លាងផង ក្នុងក្អមផង ខ្ទប់នឹងសំពត់សម្រាប់ត្រងទឹកផង ទុកក្នុងថង់យាមផង ត្រាតែពេញហើយព្យួរទុកតាមបង្អួចដេរដាស ។ ភេសជ្ជៈទាំងនោះ ក៏សើមលេចហៀរចេញពាសពេញ ។ វិហារទាំងឡាយក៏ដេរដាសពាសពេញដោយសត្វកណ្ដុរទាំងឡាយ ។ មនុស្សទាំងឡាយកាលដើរទៅកាន់វិហារចារិក បានឃើញហើយទើបពោលទោស តិះដៀលបន្តុះបង្អាប់ថា សមណៈពួកនេះ ជាកូនចៅព្រះពុទ្ធសក្យបុត្រ មានភណ្ឌៈតម្កល់ទុកក្នុងឃ្លាំង ដូចជាព្រះបាទពិម្ពិសារសេនិយរាជ ជាធំក្នុងដែនមគធៈដែរ ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះ ពោលទោស តិះដៀល

ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ ឯវរូបាយ ពាហុល្លាយ ចេតេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ ឯវរូបាយ ពាហុល្លាយ ចេតេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា ឯវរូបាយ ពាហុល្លាយ ចេតេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យានិ ខោ បន តានិ គិលានានំ ភិក្ខូនំ បដិសាយនីយានិ ភេសជ្ជានិ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ ។ តានិ បដិគ្គហេត្វា សត្តាហបរមំ សន្និធិការកំ បរិភុញ្ជិតព្វានិ តំ អតិក្កាមយតោ និស្សគ្គិយំ បាចិត្តិយន្តិ ។

បន្ទុះបង្អាប់ហើយ ។ ពួកភិក្ខុណា ជាអ្នកមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា មិនសម បើពួកភិក្ខុមកព្យាយាម ដើម្បីសេចក្ដីល្មោភច្រើន មានសភាពដូច្នេះឡើយ ។ ទើបពួកភិក្ខុទាំងនោះ នាំសេចក្ដីនុ៎ះទៅក្រាបទូល ដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុព្យាយាម ដើម្បីសេចក្ដីល្មោភច្រើន មានសភាពដូច្នេះ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគជាម្ចាស់ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មិនសមបី បើពួកមោឃបុរសទាំងនោះ មកព្យាយាមដើម្បីសេចក្ដីល្មោភច្រើន មានសភាពដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកបានធ្វើមកនេះ មិនមែននាំឲ្យកើតជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឬថែមសេចក្ដីជ្រះថ្លាដល់ជនទាំងឡាយ ដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៅទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភេសជ្ជៈណាមួយ ដែលពួកភិក្ខុមានជំងឺ គប្បីឆាន់បាន ភេសជ្ជៈនេះគឺ ទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ ។ ភិក្ខុទទួលភេសជ្ជៈទាំងនោះហើយ គួរទុកឆាន់បានយ៉ាងយូរត្រឹម ៧ ថ្ងៃ បើភិក្ខុទុកឲ្យកន្លងកំណត់នោះទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

[១៤១] យានិ ខោ បន តានិ គិលានានំ ភិក្ខូនំ បដិសាយនីយានិ ភេសជ្ជានីតិ សប្បិ នាម គោសប្បិ វា អជិកាសប្បិ វា មហិសសប្បិ វា ។ យេសំ មំសំ កប្បតិ តេសំ សប្បិ ។ នវនីតំ នាម តេសំយេវ នវនីតំ ។ តេលំ នាម តិលតេលំ សាសបតេលំ មធុកតេលំ ឯរណ្ឌតេលំ វសាតេលំ ។ មធុ នាម មក្ខិកាមធុ ។ ផាណិតំ នាម ឧច្ឆុម្ហា និព្វត្តំ ។ តានិ បដិគ្គហេត្វា សត្តាហបរមំ សន្និធិការកំ បរិភុញ្ជិតព្វានីតិ សត្តាហបរមតា បរិភុញ្ជិតព្វានិ ។ តំ អតិក្កាមយតោ និស្សគ្គិយំ ហោតិ[១] អដ្ឋមេ អរុណុគ្គមនេ និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ ភេសជ្ជំ សត្តាហាតិក្កន្តំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

---

១ ឥតោ បរំ សព្វត្ថ ឥតិសទ្ទោ ទិស្សតិ ។ សោ អតិរេកោតិ វេទិតព្វោ ។ តស្ស អតិរេកតា បឋមកឋិនសិក្ខាបទេ វុត្តនយេន វេទិតព្វា ។

[១៤១] ត្រង់ពាក្យថា ភេសជ្ជៈណាមួយ ដែលពួកភិក្ខុមានជំងឺគប្បីឆាន់បាន គឺ សប្បិ(១) របស់គោក្តី សប្បិរបស់ពពែក្តី សប្បិរបស់ក្របីក្តី ឈ្មោះថា សប្បិ (ទឹកដោះរាវ) ។ សាច់របស់សត្វទាំងឡាយណា ដែលសមគួរដល់ពុទ្ធានុញ្ញាត សប្បិរបស់សត្វទាំងឡាយនោះ ក៏សមគួរដែរ ។ ដែលហៅថា ទឹកដោះខាប់ គឺទឹកដោះខាប់របស់សត្វទាំងនោះឯង ។ ប្រេងល្ង ប្រេងស្ពៃ ប្រេងស្រគំ ប្រេងល្ហុងខ្វែរ ប្រេងធ្វើពីខ្លាញ់រាវ ឈ្មោះថា ប្រេង ។ ទឹកផ្អែមកើតពីមេឃ្មុំជាដើម ឈ្មោះថា ទឹកឃ្មុំ ។ ទឹកកើតពីដើមអំពៅ ឈ្មោះថា ទឹកអំពៅ ។ ពាក្យថា ភិក្ខុទទួលភេសជ្ជៈនោះ ហើយគួរទុកឆាន់បានយ៉ាងយូរត្រឹម ៧ ថ្ងៃ មានអធិប្បាយថា ភេសជ្ជៈទាំងនោះ គប្បីទុកឆាន់បានយ៉ាងយូរត្រឹម ៧ ថ្ងៃ ។ បើទុកឲ្យកន្លងកំណត់នោះទៅ ភេសជ្ជៈនោះ ជានិស្សគ្គិយ គឺថា ជានិស្សគ្គិយក្នុងកាលអរុណរះឡើងក្នុងថ្ងៃទី ៨ ភេសជ្ជៈដែលជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់យ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន ភេសជ្ជៈរបស់ខ្ញុំនេះកន្លងហួស ៧ ថ្ងៃហើយ ជានិស្សគ្គិយវត្ថុ ខ្ញុំសូមលះបង់ភេសជ្ជៈនេះដល់សង្ឃ ។ សេចក្តីតអំពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គ ។

១ ទឹកដោះរាវរបស់គោ គេះ ពពែជាដើម ហៅថា សប្បិ ។

និស្សគ្គិយកណ្ឌេ បត្តវគ្គស្ស តតិយសិក្ខាបទស្ស អាបត្តិវារោ

[១៤២] សត្តាហាតិក្កន្តេ អតិក្កន្តសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ សត្តាហាតិក្កន្តេ វេមតិកោ និស្សគ្គិយំ បាចិត្តិយំ ។ សត្តាហាតិក្កន្តេ អនតិក្កន្តសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ អនធិដ្ឋិតេ អធិដ្ឋិតសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ អវិស្សជ្ជិតេ វិស្សជ្ជិតសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ អនដ្ឋេ នដ្ឋសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ អវិនដ្ឋេ វិនដ្ឋសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ អទឌ្ឍេ ទឌ្ឍសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។ អវិលុត្តេ វិលុត្តសញ្ញី និស្សគ្គិយំ បាចិត្តិយំ ។

[១៤៣] និស្សដ្ឋំ បដិលភិត្វា ន កាយិកេន បរិភោគេន បរិភុញ្ជិតព្វំ ន អជ្ឈោហារិតព្វំ ។ បទីបេ វា

និស្សគ្គិយកណ្ឌ បត្តវគ្គ សិក្ខាបទទី ៣ វារៈដែលត្រូវអាបត្តិ

[១៨២] កាលភេសជ្ជៈកន្លងហួស ៧ ថ្ងៃទៅហើយ ភិក្ខុសំគាល់ថា កន្លងហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ កាលភេសជ្ជៈកន្លង ៧ ថ្ងៃហួសទៅហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ កាលភេសជ្ជៈកន្លងហួស ៧ ថ្ងៃទៅហើយ ភិក្ខុសំគាល់ថា មិនទាន់កន្លង ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ (ភេសជ្ជៈនោះ) ភិក្ខុមិនទាន់បានតាំងចិត្តទុកទេ ភិក្ខុសំគាល់ថា បានតាំងចិត្តទុកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភេសជ្ជៈមិនទាន់បានលះបង់ទេ តែភិក្ខុសំគាល់ថា បានលះបង់ហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភេសជ្ជៈមិនទាន់បាត់ទៅទេ ភិក្ខុសំគាល់ថា បាត់ទៅហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភេសជ្ជៈមិនទាន់វិនាសទៅទេ តែភិក្ខុសំគាល់ថា វិនាសហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភេសជ្ជៈភ្លើងមិនទាន់ឆេះទេ តែភិក្ខុសំគាល់ថា ភ្លើងឆេះហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភេសជ្ជៈចោរមិនទាន់លួចយកទៅទេ តែភិក្ខុសំគាល់ថា ចោរលួចយកទៅហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

[១៨៣] ភិក្ខុត្រឡប់បានភេសជ្ជៈដែលខ្លួនលះបង់ហើយ មិនត្រូវយកមកបរិភោគប្រើប្រាស់ដោយកាយ មិនត្រូវយកមកឆាន់ ។ (ភេសជ្ជៈនោះ)

កាឡវណ្ណោ វា ឧបនេតព្វំ ។ អញ្ញេន ភិក្ខុនា កាយិកេន បរិភោគេន បរិភុញ្ជិតព្វំ ន អជ្ឈោហរិតព្វំ ។ សត្តាហាតិក្កន្តេ អតិក្កន្តសញ្ញី អាបត្តិ ទុក្កដស្ស ។ សត្តាហាតិក្កន្តេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ សត្តាហាតិក្កន្តេ អនតិក្កន្តសញ្ញី អនាបត្តិ ។

[១៤៤] អនាបត្តិ អន្តោសត្តាហំ អធិដ្ឋេតិ វិសជ្ជេតិ នស្សតិ វិនស្សតិ ឌយ្ហតិ អច្ឆិន្ទិត្វា គណ្ហាតិ[១] វិស្សាសំ គណ្ហាតិ[២] អនុបសម្បន្នស្ស ចត្តេន វន្តេន មុត្តេន អនបេក្ខោ ទត្វា បដិលភិត្វា បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។

---

១-២ ឱ. ម. គណ្ហន្តិ ។

*ភិក្ខុគប្បីបង្អោនចូលទៅក្នុងប្រទីប ឬក្នុងវត្ថុមានពណ៌ខ្មៅ[១] ។ ភិក្ខុដទៃគប្បីបរិភោគប្រើប្រាស់ដោយកាយបាន តែមិនត្រូវយកមកឆាន់ ។ ភេសជ្ជៈមិនទាន់កន្លង ៧ ថ្ងៃទេ ភិក្ខុសំគាល់ថា កន្លងហើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងភេសជ្ជៈដែលមិនទាន់កន្លង ៧ ថ្ងៃ ត្រូវអាបត្តិទុក្កដ ។ ភេសជ្ជៈមិនទាន់កន្លង ៧ ថ្ងៃ ភិក្ខុសំគាល់ថា មិនទាន់កន្លង មិនត្រូវអាបត្តិឡើយ ។*

[១៤៤] *អាបត្តិមិនមានដល់ភិក្ខុ ដែលតាំងចិត្តទុក*[២] (*ក្តី*) *លះបង់ចោល* (*ក្តី*) *នូវភេសជ្ជៈដល់ភិក្ខុដែលមានភេសជ្ជៈបាត់ទៅ* (*ក្តី*) *វិនាសទៅ* (*ក្តី*) *ភ្លើងឆេះ* (*ក្តី*) *ចោរលួចយកទៅ* (*ក្តី*) *គេយកទៅដោយសេចក្តីស្និទ្ធស្នាល* (*ក្តី*) *ដល់ភិក្ខុដែលបរិច្ចាគលះបង់ដាច់ស្រឡះ ឥតអាល័យឲ្យអនុបសម្បន្នហើយទទួលយកមកបរិភោគវិញ ក្នុងរវាង ៧ ថ្ងៃ ដល់ភិក្ខុខួចចរិត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។*

សិក្ខាបទទី ៣ ចប់ ។

---

១ យកទៅលាយនឹងវត្ថុទាំងឡាយមានធ្យូងជាដើម សម្រាប់លាបមានលាបជញ្ជាំងជាដើម ។
២ គឺរវាង ៧ ថ្ងៃ ភិក្ខុផ្ទេរភេសជ្ជៈនោះ ឲ្យទៅជារបស់ដទៃក្រៅពីរបស់ឆាន់ គឺធ្វើជាថ្នាំលាបក្បាល លាបដំបៅ លាបភ្នែកជាដើម ។

# ចតុត្ថសិក្ខាបទំ

[១៤៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវតា ភិក្ខូនំ វស្សិកសាដិកា អនុញ្ញាតា ហោតិ ។ ឆព្វគ្គិយា ភិក្ខូ ភគវតា វស្សិកសាដិកា អនុញ្ញាតាតិ បដិកច្ចេវ វស្សិកសាដិ-កចីវរំ បរិយេសន្តិ បដិកច្ចេវ កត្វា និវាសេន្តិ ជិណ្ណាយ វស្សិកសាដិកាយ នគ្គា កាយំ ឱវស្សា-បេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ បដិកច្ចេវ វស្សិកសាដិកចីវរំ បរិយេសិស្សន្តិ បដិកច្ចេវ កត្វា និវាសេស្សន្តិ ជិណ្ណាយ វស្សិក-សាដិកាយ នគ្គា កាយំ ឱវស្សាបេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ បដិកច្ចេវ វស្សិកសាដិកចីវរំ បរិយេសថ

# សិក្ខាបទទី ៤

[១៤៥] សម័យនោះ ព្រះពុទ្ធដ៏ទ្រង់យស កាលទ្រង់គង់នៅក្នុងវត្តជេតវនមហាវិហារ ជារបស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី ។ ពេលនោះឯង ព្រះទ្រង់យសជាម្ចាស់ ទ្រង់អនុញ្ញាតវស្សិក-សាដិក (សំពត់ងូតទឹកភ្លៀង) ដល់ភិក្ខុទាំងឡាយហើយ ។ ពួកភិក្ខុឆព្វគ្គិយបានដំណឹងថា ព្រះទ្រង់យសជាម្ចាស់ ទ្រង់អនុញ្ញាតវស្សិកសាដិកហើយ ក៏នាំគ្នាស្វែងរកចីវរ សម្រាប់ងូតទឹកភ្លៀងមុនគេ ហើយធ្វើប្រើប្រាស់ក៏មុនគេដែរ កាលសំពត់ងូតទឹកភ្លៀង ចាស់ខូចខាតហើយ (ឆព្វគ្គិយភិក្ខុ) ក៏ងូតទឹកភ្លៀងដោយខ្លួនទទេ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយៈ មិនសមបីបើនឹងប្រញាប់ស្វែងរកចីវរសម្រាប់ងូតទឹកភ្លៀង ហើយប្រញាប់ធ្វើប្រើប្រាស់សោះ កាលសំពត់វស្សិកសាដិកចាស់ខូចខាតហើយ ក៏ត្រឡប់ងូតទឹកភ្លៀង ដោយខ្លួនទទេទៅវិញ ។ គ្រានោះ ពួកភិក្ខុទាំងនោះ ក៏នាំសេចក្តីនុ៎ះ ក្រាបទូលចំពោះព្រះទ្រង់ជោគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នៃភិក្ខុទាំងឡាយ គេថា ពួកអ្នកឯងប្រញាប់ស្វែងរកចីវរ សម្រាប់ងូតទឹកភ្លៀងមុនគេ

បដិកច្ចេវ កត្វា និវាសេថ ជិណ្ណាយ វស្សិកសាដិកាយ នគ្គា កាយំ ឱវស្សាបេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា បដិកច្ចេវ វស្សិកសាដិកចីវរំ បរិយេសិស្សថ បដិកច្ចេវ កត្វា និវាសេស្សថ ជិណ្ណាយ វស្សិកសាដិកាយ នគ្គា កាយំ ឱវស្សាបេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ មាសោ សេសោ គិម្ហានន្តិ ភិក្ខុនា វស្សិកសាដិកចីវរំ បរិយេសិតព្វំ អឌ្ឍមាសោ សេសោ គិម្ហានន្តិ កត្វា និវាសេតព្វំ ។ ឱរេន ចេ មាសោ សេសោ គិម្ហានន្តិ វស្សិកសាដិកចីវរំ បរិយេសេយ្យ ឱរេនឌ្ឍមាសោ សេសោ គិម្ហានន្តិ កត្វា និវាសេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

ប្រញាប់ធ្វើប្រើប្រាស់មុនគេ លុះសំពត់វស្សិកសាដិក ចាស់ខូចហើយ ត្រឡប់ជាផ្ងូតទឹកភ្លៀងដោយខ្លួនទទេទៅវិញ ពិតមែនឬ ។ ឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានជោគជាម្ចាស់ទ្រង់តិះដៀលថា ម្នាលពួកមោឃបុរស មិនសមបីបើពួកអ្នកឯង ប្រញាប់ស្វែងរកចីវរសម្រាប់ផ្ងូតទឹកភ្លៀងមុនគេ ប្រញាប់ធ្វើប្រើប្រាស់មុនគេ លុះសំពត់ផ្ងូតទឹកភ្លៀងចាស់គ្រាំគ្រា ត្រឡប់ជានាំគ្នាផ្ងូតទឹកភ្លៀងដោយខ្លួនទទេសោះ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យកើតសេចក្ដីជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុកំណត់ដឹងថា ខែមួយជាខាងចុងនៃគិម្ហរដូវ[១] គប្បីស្វែងរកសាដិកចីវរ សម្រាប់ផ្ងូតទឹកភ្លៀង ភិក្ខុកំណត់ដឹងថា នៅកន្លះខែជាខាងចុងនៃគិម្ហរដូវទៀត គប្បីធ្វើឲ្យស្រេចហើយប្រើប្រាស់ចុះ ។ បើមិនទាន់ដល់ខែមួយជាខាងចុងនៃគិម្ហរដូវទេ ភិក្ខុស្វែងរកសាដិកចីវរសម្រាប់ផ្ងូតទឹកភ្លៀង និងមិនទាន់ដល់កន្លះខែជាខាងចុងគិម្ហរដូវទេ ភិក្ខុធ្វើឲ្យស្រេចហើយប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

---

១ តាំងតែ ១ រោចខែជេស្ឋទៅដល់ថ្ងៃពេញបូណ៌មីខែអាសាឡ្ហ ហៅថា ខែមួយជាខាងចុងគិម្ហរដូវ។តាំងតែ១កើតខែអាសាឡ្ហទៅដល់ថ្ងៃពេញបូណ៌មីហៅថា កន្លះខែជាខាងចុងគិម្ហរដូវ ។

[១៤៦] មាសោ សេសោ គិម្ហានន្តិ ភិក្ខុនា វស្សិកសាដិកចីវរំ បរិយេសិតព្វន្តិ យេ មនុស្សា បុព្វេបិ វស្សិកសាដិកចីវរំ ទេន្តិ តេ ឧបសង្កមិត្វា ឯវមស្សុ វចនីយា កាលោ វស្សិកសាដិកាយ សមយោ វស្សិកសាដិកាយ អញ្ញេបិ មនុស្សា វស្សិកសាដិកចីវរំ ទេន្តីតិ ។ ន វត្តព្វា ទេថ មេ វស្សិកសាដិកចីវរំ អាហរថ មេ វស្សិកសាដិកចីវរំ បរិវត្តេថ[១] មេ វស្សិកសាដិកចីវរំ ចេតាបេថ មេ វស្សិកសាដិកចីវរន្តិ ។ អឌ្ឍមាសោ សេសោ គិម្ហានន្តិ កត្វា និវាសេតព្វន្តិ អឌ្ឍមាសេ សេសេ គិម្ហានេ កត្វា និវាសេតព្វំ ។ ឱរេន ចេ មាសោ សេសោ គិម្ហានន្តិ អតិរេកមាសេ សេសេ គិម្ហានេ វស្សិកសាដិកចីវរំ បរិយេសតិ និស្សគ្គិយំ ហោតិ[២] ។ ឱរេនឌ្ឍមាសោ សេសោ គិម្ហានន្តិ អតិរេកឌ្ឍមាសេ សេសេ គិម្ហានេ កត្វា និវាសេតិ និស្សគ្គិយំ ហោតិ

១ សព្វត្ថ បរិវត្តេថាតិ ទិស្សតិ ។ ២ សព្វត្ថ និស្សគ្គិយំ បាចិត្តិយន្តិ ទិស្សតិ ។

និស្សគ្គិយកណ្ឌ បត្តវគ្គ សិក្ខាបទទី ៩ សិក្ខាបទវិភង្គ

[១៤៦] ត្រង់ពាក្យថា ភិក្ខុកំណត់ដឹងថា ខែមួយជាខាងចុងនៃគិម្ហរដូវ ត្រូវស្វែងរកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀង មានអធិប្បាយថា អំពីដើមមក មនុស្សទាំងឡាយណា ធ្លាប់ប្រគេនសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ពួកភិក្ខុគប្បីចូលទៅរកមនុស្សទាំងឡាយនោះ ហើយពោលយ៉ាងនេះថា ពេលនេះ ជាកាលនៃវស្សិកសាដិក ពេលនេះ ជាសម័យនៃវស្សិកសាដិក សូម្បីពួកមនុស្សឯទៀត គេតែងប្រគេនសាដិកចីវរ សម្រាប់ងូតទឹកភ្លៀងដែរ ។ ពួកភិក្ខុមិនត្រូវនិយាយថា អ្នកទាំងឡាយ ចូរឲ្យសាដិកចីវរ សម្រាប់ងូតទឹកភ្លៀងដល់អាត្មា ចូរនាំយកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀងមកឲ្យអាត្មា ចូរផ្លាស់ប្តូរសាដិកចីវរ សម្រាប់ងូតទឹកភ្លៀងឲ្យអាត្មា ចូរទិញសាដិកចីវរ សម្រាប់ងូតទឹកភ្លៀងឲ្យអាត្មា ។ ពាក្យថា ភិក្ខុកំណត់ដឹងថា នៅកន្លះខែជាខាងចុងគិម្ហរដូវទៀត គប្បីធ្វើឲ្យស្រេចហើយប្រើប្រាស់ចុះ គឺភិក្ខុគប្បីធ្វើឲ្យស្រេចហើយប្រើប្រាស់ក្នុងកន្លះខែជាខាងចុងគិម្ហរដូវ ។ ពាក្យថា បើមិនទាន់ដល់ខែ ១ ជាខាងចុងនៃគិម្ហរដូវទេ គឺថ្ងៃមុនពីមួយខែជាខាងចុងគិម្ហរដូវ ភិក្ខុស្វែងរកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀង ចីវរនោះ ជានិស្សគ្គិយ ។ ពាក្យថា មិនទាន់ដល់កន្លះខែជាខាងចុងគិម្ហរដូវទេ គឺថ្ងៃមុនពីកន្លះខែជាខាងចុងគិម្ហរដូវ ភិក្ខុធ្វើស្រេចហើយប្រើប្រាស់

និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ វស្សិកសាដិកចីវរំ អតិរេកមាសេ សេសេ គិម្ហានេ បរិយិដ្ឋំ អតិរេកឌ្ឍមាសេ សេសេ គិម្ហានេ កត្វា និវត្ថំ[១] និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[១៤៧] អតិរេកមាសេ សេសេ គិម្ហានេ អតិរេកសញ្ញី វស្សិកសាដិកចីវរំ បរិយេសតិ និស្សគ្គិយំ ចាចិត្តិយំ ។ អតិរេកមាសេ សេសេ គិម្ហានេ វេមតិកោ វស្សិកសាដិកចីវរំ បរិយេសតិ និស្សគ្គិយំ ចាចិត្តិយំ ។ អតិរេកមាសេ សេសេ គិម្ហានេ ឩនកសញ្ញី វស្សិកសាដិកចីវរំ បរិយេសតិ និស្សគ្គិយំ ចាចិត្តិយំ ។ អតិរេកឌ្ឍមាសេ សេសេ គិម្ហានេ អតិរេកសញ្ញី កត្វា និវាសេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អតិរេកឌ្ឍមាសេ សេសេ គិម្ហានេ វេមតិកោ កត្វា និវាសេតិ និស្សគ្គិយំ ចាចិត្តិយំ ។ អតិរេកឌ្ឍមាសេ

១ ឱ. ម. បរិទហិតំ ។

សំពត់នោះជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ឲ្យស្រឡះដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះបង់យ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន វស្សិកសាដិកចីវររបស់ខ្ញុំនេះ ខ្ញុំស្វែងរកបានមកក្នុងកាលមុន ពីមួយខែជាខាងចុងគិម្ហរដូវ ធ្វើស្រេចហើយប្រើប្រាស់ក្នុងកាលមុន ពីកន្លះខែជាខាងចុងគិម្ហរដូវ សំពត់នេះ ជានិស្សគ្គិយ ខ្ញុំសូមលះបង់នូវវស្សិកសាដិកចីវរនេះដល់សង្ឃ ។ បេ ។ ពាក្យតពីនេះទៅមានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គ ។

[១៨៧] ខាងចុងគិម្ហរដូវនៅលើសមួយខែ ភិក្ខុសំគាល់ថា លើសមែន ហើយស្វែងរកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀង ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ខាងចុងគិម្ហរដូវនៅលើសមួយខែ តែភិក្ខុមានសេចក្ដីសង្ស័យ ហើយស្វែងរកវស្សិកសាដិកចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ខាងចុងគិម្ហរដូវនៅលើសមួយខែ ភិក្ខុសំគាល់ថា នៅខ្វះ ហើយស្វែងរកវស្សិក-សាដិកចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ខាងចុងគិម្ហរដូវនៅលើសកន្លះខែទៀត ភិក្ខុសំគាល់ថា លើសមែន ហើយធ្វើឲ្យស្រេចប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ខាងចុងគិម្ហរដូវនៅលើសកន្លះខែទៀត ភិក្ខុមានសេចក្ដីសង្ស័យ ហើយធ្វើឲ្យស្រេចប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ខាងចុងគិម្ហរដូវនៅលើសកន្លះខែទៀត

សេសេ គិម្ហានេ ឩនកសញ្ញី កត្វា និវាសេតិ និស្សគ្គិយំ បាចិត្តិយំ ។ សតិយា វស្សិកសាដិកាយ នគ្គោ កាយំ ឱវស្សាបេតិ អាបត្តិ ទុក្កដស្ស ។ ឩនកមាសេ សេសេ គិម្ហានេ អតិរេកសញ្ញី អាបត្តិ ទុក្កដស្ស ។ ឩនកមាសេ សេសេ គិម្ហានេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឩនកមាសេ សេសេ គិម្ហានេ ឩនកសញ្ញី អណាបត្តិ ។ ឩនកឌ្ឍមាសេ សេសេ គិម្ហានេ អតិរេកសញ្ញី អាបត្តិ ទុក្កដស្ស ។ ឩនកឌ្ឍមាសេ សេសេ គិម្ហានេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឩនកឌ្ឍមាសេ សេសេ គិម្ហានេ ឩនកសញ្ញី អណាបត្តិ ។

[១៤៨] អណាបត្តិ មាសោ សេសោ គិម្ហានន្តិ វស្សិកសាដិកចីវរំ បរិយេសតិ អឌ្ឍមាសោ សេសោ គិម្ហានន្តិ កត្វា និវាសេតិ ឩនកមាសោ សេសោ គិម្ហានន្តិ វស្សិកសាដិកចីវរំ បរិយេសតិ ឩនកឌ្ឍមាសោ សេសោ គិម្ហានន្តិ កត្វា និវាសេតិ បរិយិដ្ឋាយ

ភិក្ខុសំគាល់ថានៅខ្វះ ហើយធ្វើឲ្យស្រេចប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ វស្សិកសាដិកចីវររបស់ភិក្ខុមាន តែភិក្ខុស្រាតងូតទឹកភ្លៀង ត្រូវអាបត្តិទុក្កដ ។ ខាងចុងគិម្ហរដូវនៅខ្វះ មិនដល់មួយខែ ភិក្ខុសំគាល់ថា លើសទៅវិញ ត្រូវអាបត្តិទុក្កដ ។ ខាងចុងគិម្ហរដូវនៅខ្វះ មិនដល់មួយខែ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខាងចុងគិម្ហរដូវនៅខ្វះ មិនដល់មួយខែ ភិក្ខុសំគាល់ថា នៅខ្វះមិនដល់មួយខែមែន មិនត្រូវអាបត្តិ ។ ខាងចុងគិម្ហរដូវនៅខ្វះ មិនដល់កន្លះខែ ភិក្ខុសំគាល់ថា លើសទៅវិញ ត្រូវអាបត្តិទុក្កដ ។ ខាងចុងគិម្ហរដូវនៅខ្វះ មិនដល់កន្លះខែ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខាងចុងគិម្ហរដូវនៅខ្វះ មិនដល់កន្លះខែ ភិក្ខុសំគាល់ថា មិនដល់កន្លះខែមែន មិនត្រូវអាបត្តិឡើយ ។

[១៤៨] អាបត្តិមិនមានដល់ភិក្ខុដែលដឹងថា ខាងចុងគិម្ហរដូវនៅសល់មួយខែ ហើយស្វែងរកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀង ដល់ភិក្ខុដែលដឹងថា ខាងចុងគិម្ហរដូវនៅសល់កន្លះខែទៀត ហើយធ្វើឲ្យស្រេចប្រើប្រាស់ ដល់ភិក្ខុដែលដឹងថា ខាងចុងគិម្ហរដូវនៅខ្វះ មិនដល់មួយខែ ហើយស្វែងរកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀង ដល់ភិក្ខុដែលដឹងថាខាងចុងគិម្ហរដូវនៅ ខ្វះមិនដល់កន្លះខែ ហើយធ្វើឲ្យស្រេចប្រើប្រាស់

វស្សិកសាដិកាយ វស្សំ ឧក្កឌ្ឍិយតិ និវត្ថាយ វស្សិ-កសាដិកាយ វស្សំ ឧក្កឌ្ឍិយតិ ធោវិត្វា និក្ខិបិតព្វំ សមយេ និវាសេតព្វំ អច្ឆិន្នចីវរស្ស នដ្ឋចីវរស្ស អាប-ទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។

ដល់ភិក្ខុដែលស្វែងរកវស្សិកសាដិកចីវរបានស្រេចហើយ (ស្រាប់តែដឹងជាខាងក្រោយថា) គេលើកខែមួយជាខាងដើមនៃវស្សានរដូវ (ឆ្នាំមានខែអធិកមាស) ដល់ភិក្ខុដែលស្លៀកវស្សិកសាដិកនោះហើយ (ទើបដឹងថា) គេលើកខែមួយជាខាងដើមនៃវស្សានរដូវ ដល់ភិក្ខុដែលលាងវស្សិកសាដិកហើយតម្កល់ទុក ដល់ភិក្ខុដែលប្រើប្រាស់វស្សិកសាដិក ក្នុងកាលដ៏គួរ ដល់ភិក្ខុមានចីវរ[១] ដែលចោរដណ្តើមយកទៅ ដល់ភិក្ខុមានចីវរបាត់[២] ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ[៣] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទ ទី ៤ ចប់ ។

---

១ ពាក្យថា ចីវរក្នុងទីនេះសំដៅយកវស្សិកសាដិកចីវរ បើចោរដណ្តើមយកសំពត់របស់ភិក្ខុនោះទៅហើយភិក្ខុនោះងូតទឹកភ្លៀងដោយខ្លួនទទេ មិនត្រូវអាបត្តិទុក្កដ ព្រោះស្រាតនិងងូតទឹកភ្លៀង ។ ២ បើភិក្ខុមានចីវរដទៃៗ ក្រៅពីវស្សិកសាដិកចីវរដែលបាត់ទៅនោះ នឹងស្លៀកក្តី នឹងស្វែងរកក្តីនូវសំពត់វស្សិកសាដិក ក្នុងសម័យក្រៅពីពុទ្ធានុញ្ញាត មិនត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ បើភិក្ខុមានវស្សិកសាដិកចីវរបាត់វិញ ហើយស្រាតងូតទឹក មិនត្រូវអាបត្តិទុក្កដឡើយ ។ ៣ បើភិក្ខុស្លៀកសំពត់វស្សិកសាដិក មានតម្លៃច្រើនងូតទឹក ហើយមានចោរមកដណ្តើមយកទៅ ភិក្ខុស្រាតងូតទឹក មិនត្រូវអាបត្តិទុក្កដទេ ។ ម្យ៉ាងទៀត ពួកចោរលួចយកសំពត់ដទៃក្រៅពីវស្សិកសាដិកចីវរ ដែលភិក្ខុមិនទាន់បានស្លៀកហើយ បើភិក្ខុស្លៀកសំពត់វស្សិកសាដិកក្នុងសម័យក្រៅពីពុទ្ធានុញ្ញាត មិនត្រូវនិស្សគ្គិយបាចិត្តិយទេ ។

# បញ្ចមសិក្ខាបទំ

[១៨៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ ភាតុនោ សទ្ធិវិហារិកំ ភិក្ខុំ ឯតទវោច ឯហាវុសោ ជនបទចារិកំ បក្កមិស្សាមាតិ ។ នាហំ ភន្តេ គមិស្សាមិ ទុព្វលចីវរោម្ហីតិ ។ ឯហាវុសោ អហន្តេ ចីវរំ ទស្សាមីតិ តស្ស ចីវរំ អទាសិ ។ អស្សោសិ ខោ សោ ភិក្ខុ ភគវា កិរ ជនបទចារិកំ បក្កមិស្សតីតិ ។ អថខោ តស្ស ភិក្ខុនោ ឯតទហោសិ នទានាហំ អាយស្មតា ឧបនន្ទេន សក្យបុត្តេន សទ្ធឹ ជនបទចារិកំ បក្កមិស្សាមិ ភគវតា សទ្ធឹ ជនបទចារិកំ បក្កមិស្សាមីតិ ។ អថខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ តំ ភិក្ខុំ ឯតទវោច ឯហិទានិ អាវុសោ ជនបទចារិកំ បក្កមិស្សាមាតិ ។ នាហំ ភន្តេ តយា សទ្ធឹ

# សិក្ខាបទទី ៥

[១៤៩] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់ក្នុងវត្តជេតវន ជារបស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ឧបនន្ទសក្យបុត្រដ៏មានអាយុ បាននិយាយពាក្យនេះ នឹងភិក្ខុដែលជាសទ្ធិវិហារិករបស់ព្រះថេរៈជាបងថា នែអាវុសោ អ្នកចូរមក យើងនឹងចៀសទៅកាន់ចារិកក្នុងជនបទ ។ ភិក្ខុនោះឆ្លើយថា បពិត្រលោកដ៏ចម្រើនខ្ញុំករុណាទៅមិនបានទេ (ដ្បិត) ខ្ញុំករុណាមានចីវរចាស់គ្រាំគ្រាហើយ ។ ឧបនន្ទភិក្ខុនិយាយថា មកចុះអាវុសោ ខ្ញុំនឹងឲ្យចីវរលោក ហើយបានឲ្យចីវរទៅភិក្ខុនោះ ។ ភិក្ខុនោះបានឮថា ព្រះដ៏មានព្រះភាគម្ចាស់នឹងទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងជនបទ ។ ទើបភិក្ខុនោះត្រិះរិះយ៉ាងនេះថា ឥឡូវនេះ អញមិនចៀសទៅកាន់ចារិកក្នុងជនបទ ជាមួយនឹងឧបនន្ទសក្យបុត្រដ៏មានអាយុទេ អញមុខជានឹងទៅកាន់ចារិកក្នុងជនបទ ជាមួយនឹងព្រះដ៏មានព្រះភាគវិញ ។ លំដាប់នោះ ឧបនន្ទសក្យបុត្រដ៏មានអាយុនិយាយពាក្យនេះនឹងភិក្ខុនោះថា ឥឡូវនេះ អាវុសោ លោកចូរមកយើងនឹងនាំគ្នាទៅកាន់ចារិកក្នុងជនបទ ។ ភិក្ខុនោះឆ្លើយថា បពិត្រលោកដ៏ចម្រើន ករុណាមិនទៅកាន់ចារិកក្នុងជនបទជាមួយនឹងលោកទេ

ជនបទចារិកំ បក្កមិស្សាមិ ភគវតា សទ្ធឹ ជនបទ-ចារិកំ បក្កមិស្សាមីតិ ។ យំបិ ត្យាហំ អាវុសោ ចីវរំ អ-ទាសឹ មយា សទ្ធឹ ជនបទចារិកំ បក្កមិស្សតីតិ ក្ុបិតោ អនត្តមនោ ចីវរំ អច្ឆិន្ទិ ។ អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ ភិក្ខុស្ស សាមំ ចីវរំ ទត្វា ក្ុបិតោ អនត្តមនោ អច្ឆិន្ទិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ត្វំ ឧបនន្ទ ភិក្ខុស្ស សាមំ ចីវរំ ទត្វា ក្ុបិតោ អនត្តមនោ អច្ឆិន្ទសីតិ[១] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស ភិក្ខុស្ស សាមំ ចីវរំ ទត្វា ក្ុបិតោ អនត្តមនោ អច្ឆិន្ទិស្សសិ នេតំ មោឃ-បុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ

១ ឱ. ម. អច្ឆិន្ទីតិ ។

ខ្ញុំករុណាមុខជានឹងទៅកាន់ចារិកក្នុងជនបទ ជាមួយនឹងព្រះដ៏មានព្រះភាគវិញ ។ ឧបនន្ទខឹងអន់ចិត្តហើយពោលថា អាវុសោ ខ្ញុំបានឲ្យចីវរណាដល់លោក (ព្រោះ) លោកថានឹងទៅកាន់ចារិកជាមួយនឹងខ្ញុំ (ថាដូច្នោះហើយ) ក៏ដណ្តើមយកចីវរមកវិញ ។ គ្រានោះ ភិក្ខុនោះ ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ទើបភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនទំនងសោះ ឧបនន្ទសក្យ-បុត្តដ៏មានអាយុឲ្យចីវរទៅភិក្ខុ ដោយខ្លួនឯងហើយ ត្រឡប់ជាខឹងអន់ចិត្តដណ្តើមយកមកវិញ ។ លំដាប់នោះ ភិក្ខុទាំងនោះ នាំសេចក្តីនុ៎ះក្រាបទូលចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងបានឲ្យចីវរទៅភិក្ខុដោយខ្លួនឯងហើយ ត្រឡប់ក្រោធខឹងអន់ចិត្តដណ្តើមយកពីគេមកវិញ មែនឬ ។ ឧបនន្ទសក្យបុត្រក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការណ៍នោះ ពិតមែន ។ ព្រះសម្ពុទ្ធដ៏ទ្រង់យសជាម្ចាស់ទ្រង់តិះដៀលថា ម្នាលមោឃបុរស មិនសមបីបើអ្នកឯងបានឲ្យចីវរទៅភិក្ខុដោយខ្លួនឯងហើយ ត្រឡប់ក្រោធខឹងអន់ចិត្តដណ្តើមយកចីវរពីគេមកវិញសោះ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឬនាំឲ្យជនទាំងឡាយដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុស្ស សាមំ ចីវរំ ទត្វា កុបិតោ អនត្តមនោ អច្ឆិន្ទេយ្យ វា អច្ឆិន្ទាបេយ្យ វា និស្សគ្គិយំ បាចិត្តិយន្តិ ។

[១៩០] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុស្សាតិ អញ្ញស្ស ភិក្ខុស្ស ។ សាមន្តិ សយំ ទត្វា ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនុបគំ បច្ឆិមំ ។ កុបិតោ អនត្តមនោតិ អនភិរទ្ធោ អាហតចិត្តោ ខិលជាតោ ។ អច្ឆិន្ទេយ្យាតិ សយំ អច្ឆិន្ទតិ និស្សគ្គិយំ ហោតិ[១] ។ អច្ឆិន្ទាបេយ្យាតិ អញ្ញំ អាណាបេតិ អាបត្តិ ទុក្កដស្ស ។ សកឹ អាណត្តោ ពហុកំបិ អច្ឆិន្ទតិ និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ ចីវរំ

១ សព្វត្ថ និស្សគ្គិយំ បាចិត្តិយន្តិ ទិស្សតិ ។

អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឲ្យចីវរដល់ភិក្ខុ (ដទៃ) ដោយខ្លួនឯងហើយ ខឹងអន់ចិត្តដណ្តើមយក (ចីវរ) មកវិញក្តី ប្រើឲ្យគេដណ្តើមយកមកវិញក្តី ភិក្ខុនោះ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

[១៩០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីអធិប្បាយ ក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ដល់ភិក្ខុ គឺដល់ភិក្ខុដទៃ ។ ពាក្យថា ខ្លួនឯង គឺបានឲ្យទៅខ្លួនឯង ។ ដែលហៅថាចីវរនោះ បានដល់ចីវរ ៦ យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតល្មមសម្រេចកិច្ចវិកប្បបាន ។ ពាក្យថា ខឹងអន់ចិត្ត គឺមិនត្រេកអរ មានចិត្តក្តួលក្តៅ រឹងរូស ។ ពាក្យថា ដណ្តើមយកមកវិញ គឺដណ្តើមយកមកដោយខ្លួនឯងវិញ ចីវរនោះ ជានិស្សគ្គិយ ។ ពាក្យថា ប្រើឲ្យគេដណ្តើមយកមកវិញ គឺភិក្ខុបង្គាប់អ្នកដទៃ (ឲ្យដណ្តើមយកមកវិញ) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ទៅតែម្តងទេ អ្នកទទួលបង្គាប់ទៅដណ្តើមយកច្រើនដងចីវរទាំងនោះ ជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បានបុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់យ៉ាងនេះ ។ បេ ។ ថា បពិត្រព្រះសង្ឃដ៏ចម្រើន ចីវររបស់ខ្ញុំនេះ ខ្ញុំបានឲ្យទៅភិក្ខុ (ដទៃ)

ភិក្ខុស្ស សាមំ ធត្វា អច្ឆិន្នំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[១៩១] ឧបសម្បន្នេ ឧបសម្បន្នសញ្ញី សាមំ ចីវរំ ទត្វា កុបិតោ អនត្តមនោ អច្ឆិន្ទតិ វា អច្ឆិន្ទាបេតិ វា និស្សគ្គិយំ បាចិត្តិយំ ។ ឧបសម្បន្នេ វេមតិកោ សាមំ ចីវរំ ទត្វា កុបិតោ អនត្តមនោ អច្ឆិន្ទតិ វា អច្ឆិន្ទាបេតិ វា និស្សគ្គិយំ បាចិត្តិយំ ។ ឧបសម្បន្នេ អនុបសម្បន្ន-សញ្ញី សាមំ ចីវរំ ទត្វា កុបិតោ អនត្តមនោ អច្ឆិន្ទតិ វា អច្ឆិន្ទាបេតិ វា និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញំ បរិក្ខារំ ទត្វា កុបិតោ អនត្តមនោ អច្ឆិន្ទតិ វា អច្ឆិន្ទាបេតិ វា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នស្ស ចីវរំ វា អញ្ញំ វា បរិក្ខារំ ទត្វា កុបិតោ អនត្តមនោ អច្ឆិន្ទតិ វា អច្ឆិន្ទាបេតិ វា អាបត្តិ ទុក្កដស្ស ។

ដោយខ្លួនឯងហើយ ខ្ញុំត្រឡប់ដណ្តើមយកមកវិញ ជានិស្សគ្គិយ ខ្ញុំសូមលះបង់ចីវរនេះដល់សង្ឃ ។ ពាក្យតអំពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ ក្នុងចីវរវគ្គ ។

[១៩១] ភិក្ខុសំគាល់បុគ្គលដែលជាឧបសម្បន្ន[១] ថា ឧបសម្បន្នពិតមែន ហើយឲ្យចីវរទៅដោយខ្លួនឯង ក៏ត្រឡប់ក្រោធខឹងអន់ចិត្ត ដណ្តើមយកវិញក្តី ប្រើឲ្យអ្នកដទៃដណ្តើមយកមកវិញក្តី ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងបុគ្គលដែលជាឧបសម្បន្ន ហើយឲ្យចីវរទៅដោយខ្លួនឯង ក៏ត្រឡប់ជាក្រោធខឹងអន់ចិត្ត ដណ្តើមយកមកខ្លួនឯងវិញក្តី ប្រើឲ្យអ្នកដទៃដណ្តើមមកវិញក្តី ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុសំគាល់បុគ្គលដែលជាឧបសម្បន្នថា អនុបសម្បន្ន[២] ទៅវិញហើយឲ្យចីវរទៅដោយខ្លួនឯង ក៏ត្រឡប់ក្រោធខឹងអន់ចិត្ត ដណ្តើមយកមកខ្លួនឯងវិញក្តី ប្រើឲ្យអ្នកដទៃដណ្តើមយកមកវិញក្តី ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុឲ្យបរិក្ខារដទៃហើយ ត្រឡប់ក្រោធខឹងអន់ចិត្ត ដណ្តើមយកមកខ្លួនឯងវិញក្តី ប្រើឲ្យអ្នកដទៃដណ្តើមយកមកវិញក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឲ្យចីវរក្តីបរិក្ខារដទៃក្តី ទៅអនុបសម្បន្ន ហើយក្រោធខឹងអន់ចិត្ត ដណ្តើមយកមកខ្លួនឯងវិញក្តី ប្រើឲ្យអ្នកដទៃដណ្តើមយកមកវិញក្តី ត្រូវអាបត្តិទុក្កដ ។

១ អ្នកដែលបានឧបសម្បទាជាភិក្ខុភាវៈដោយត្រឹមត្រូវហើយ ហៅថា ឧបសម្បន្ន ។ ២ បានដល់បុគ្គលក្រៅពីភិក្ខុ មានសាមណេរជាដើម ។

១៨៩

និស្សគ្គិយកណ្ឌេ បត្តវគ្គស្ស បញ្ចមសិក្ខាបទស្ស អនាបត្តិ

អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

[១៨២] អនាបត្តិ សោ វា ទេតិ តស្ស វា វិស្សាសន្តោ គណ្ហាតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។

ភិក្ខុសំគាល់អនុសម្បន្នថា ជាឧបសម្បន្នទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្ដីសង្ស័យក្នុងបុគ្គលដែលជាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់អនុបសម្បន្នថា អនុបសម្បន្នពិតមែន ត្រូវអាបត្តិទុក្កដ ។

[១៥២] អាបត្តិមិនមានដល់ភិក្ខុ ដែលភិក្ខុអ្នកទទួលចីវរនោះ គេឲ្យត្រឡប់មកវិញ ឬភិក្ខុដែលមានសេចក្ដីស្និទ្ធស្នាល នឹងភិក្ខុអ្នកទទួលចីវរនោះ ហើយកាន់យកមកវិញ ដល់ភិក្ខុដែលខ្លួចចរិត ដល់ភិក្ខុដែលជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់ ។

# ឆដ្ឋសិក្ខាបទំ

[១៨៣] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ចីវរការសមយេ ពហុំ សុត្តំ វិញ្ញាបេសុំ ។ កតេបិ ចីវរេ ពហុ សុត្តំ អវសិដ្ឋំ ហោតិ ។ អថខោ ឆព្វគ្គិយានំ ភិក្ខូនំ ឯតទហោសិ ហន្ទ មយំ អាវុសោ អញ្ញំបិ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេមាតិ ។ អថខោ ឆព្វគ្គិយា ភិក្ខូ អញ្ញំបិ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេសុំ ។ វីតេបិ ចីវរេ ពហុ សុត្តំ អវសិដ្ឋំ ហោតិ ទុតិយម្បិ ខោ ឆព្វគ្គិយា ភិក្ខូ អញ្ញំបិ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេសុំ ។ វីតេបិ ចីវរេ ពហុ សុត្តំ អវសិដ្ឋំ ហោតិ ។ តតិយម្បិ ខោ ឆព្វគ្គិយា ភិក្ខូ អញ្ញំបិ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេសុំ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា

# សិក្ខាបទទី ៦

[១៥៣] សម័យនោះ ព្រះសម្ពុទ្ធដ៏ទ្រង់យស កាលគង់ក្នុងវិហារ វេឡុវនជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុបានសូមអំបោះមកជាច្រើន ក្នុងសម័យធ្វើចីវរកម្ម ។ លុះធ្វើចីវរសម្រេចហើយ មានអំបោះសេសសល់ជាច្រើន ។ ទើបពួកឆព្វគ្គិយ-ភិក្ខុបានជំនុំគ្នាដូច្នេះថា ម្នាលអាវុសោ បើដូច្នេះ មានតែពួកយើងនឹងសូមអំបោះដទៃ មកថែមទៀត ហើយឲ្យពួកជាងតម្បាញត្បាញចីវរ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុទៅសូមអំបោះឯទៀតមក ហើយក៏ឲ្យជាងតម្បាញត្បាញចីវរ ។ កាលត្បាញចីវររួចហើយ អំបោះនៅសេសសល់ជាច្រើន ពួកឆព្វគ្គិយភិក្ខុ ក៏ទៅសូមអំបោះដទៃ ៗ មកថែមទៀត ហើយឲ្យពួកជាងតម្បាញត្បាញចីវរជាគម្រប់ពីរដង ។ កាលគេត្បាញរួចហើយ អំបោះនៅសល់ជាច្រើន ។ ពួកឆព្វគ្គិយភិក្ខុទៅសូមអំបោះដទៃ ៗ មកថែមទៀត ហើយឲ្យពួកជាងតម្បាញត្បាញចីវរជាគម្រប់បីដង ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ មិនសមនឹងទៅសូមអំបោះមកដោយខ្លួនឯង

១៩១

## និស្សគ្គិយកណ្ឌេ បត្តវគ្គស្ស ឆដ្ឋសិក្ខាបទស្ស បញ្ញត្តិ

សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

ហើយឲ្យពួកជាងតម្បាញត្បាញចីវរឲ្យសោះ ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងទៅសូមអំបោះមកដោយខ្លួនឯង ហើយឲ្យពួកជាងតម្បាញត្បាញចីវរឲ្យ (ដូច្នេះ) សោះ ។ ទើបភិក្ខុទាំងនោះ នាំសេចក្តីនុ៎ះក្រាបទូលចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងទៅសូមអំបោះមកនឹងខ្លួនឯង ហើយឲ្យពួកជាងតម្បាញត្បាញចីវរឲ្យពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការណ៍នោះ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស ពួកអ្នកឯង មិនសមបើហ៊ានទៅសូមអំបោះមកនឹងខ្លួនឯង ហើយឲ្យពួកជាងតម្បាញត្បាញចីវរឲ្យ (ដូច្នេះ) សោះ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើមកនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា និងមិននាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សូមអំបោះមកដោយខ្លួនឯង ហើយឲ្យពួកជាងតម្បាញត្បាញចីវរឲ្យ ភិក្ខុនោះ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

[១៨៦] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សាមន្តិ សយំ វិញ្ញាបេត្វា ។ សុត្តំ នាម ឆ សុត្តានិ ខោមំ កប្បាសិកំ កោសេយ្យំ កម្ពលំ សាណំ ភង្គំ ។ តន្តវាយេហីតិ បេសការកេហិ វាយាបេតិ បយោគេ ទុក្កដំ ។ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ ចីវរំ សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ វាយាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[១៨៨] វាយាបិតេ វាយាបិតសញ្ញី និស្សគ្គិយំ ចាចិត្តិយំ ។ វាយាបិតេ វេមតិកោ និស្សគ្គិយំ

[១៩៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌឯណោះ ។ ពាក្យថា ដោយខ្លួនឯង គឺសូមមកខ្លួនឯង ។ ដែលហៅថា អំបោះ បានដល់អំបោះ ៦ យ៉ាង គឺ អំបោះដែលកើតពីសម្បកឈើ ១ អំបោះដែលកើតពីកប្បាស ១ សូត្រ ១ អំបោះដែលកើតពីរោមសត្វ ១ អំបោះដែលកើតពីធ្មៃ ១ អំបោះកើតពីភង្គៈ (គឺយករបស់ខាងដើមទាំង ៥ មកធ្វើជាអំបោះ) ១ ។ ពាក្យថា ឲ្យពួកជាងតម្បាញត្បាញ គឺប្រើពួកជាងតម្បាញឲ្យត្បាញ ត្រូវអាបត្តិទុក្កដតាមប្រយោគ ។ ចីវរនោះ ជានិស្សគ្គិយ ក្នុងខណៈដែលបានមក ភិក្ខុគប្បីលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះបង់យ៉ាងនេះ ។ បេ ។ ថា បពិត្រព្រះសង្ឃដ៏ចម្រើន ចីវររបស់ខ្ញុំនេះ ខ្ញុំបានសូមអំបោះមកដោយខ្លួនឯង ហើយឲ្យពួកជាងតម្បាញត្បាញ ចីវរនេះ ជានិស្សគ្គិយ ខ្ញុំសូមលះបង់ចីវរនេះដល់សង្ឃ ។ ពាក្យតពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គ ។

[១៩៥] ភិក្ខុសំគាល់ចីវរដែលឲ្យគេត្បាញរួចហើយថា ឲ្យគេត្បាញរួចហើយពិតមែន ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងចីវរដែលឲ្យគេត្បាញរួចហើយ ត្រូវអាបត្តិនិស្សគ្គិយ

ចាចិត្តិយំ ។ វាយាបិតេ អវាយាបិតសញ្ញី និស្សគ្គិយំ ចាចិត្តិយំ ។ អវាយាបិតេ វាយាបិតសញ្ញី អាបត្តិ ទុក្កដស្ស ។ អវាយាបិតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អវាយាបិតេ អវាយាបិតសញ្ញី អនាបត្តិ ។

[១៩៦] អនាបត្តិ ចីវរំ សិព្វិតុំ អាយោគេ កាយពន្ធនេ អំសពន្ធកេ បត្តត្ថវិកាយ បរិស្សាវនេ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។

បាចិត្តិយ ។ ភិក្ខុសំគាល់ចីវរដែលឲ្យគេត្បាញរួចហើយថា មិនមែនចីវរដែលឲ្យគេត្បាញទេ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុសំគាល់ចីវរដែលមិនមែនឲ្យគេត្បាញថា ចីវរដែលឲ្យគេត្បាញហើយ ត្រូវអាបត្តិទុក្កដ ។ មិនមែនចីវរដែលឲ្យគេត្បាញទេ តែភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ចីវរដែលមិនមែនឲ្យគេត្បាញថា មិនមែនចីវរដែលឲ្យគេត្បាញពិតមែន មិនត្រូវអាបត្តិឡើយ ។

[១៥៦] អាបត្តិមិនមានដល់ភិក្ខុ ដែលសូមអំបោះមក ដើម្បីដេរចីវរ ដើម្បីធ្វើសំពត់អាយោគ ដើម្បីធ្វើវត្ថពន្ធចង្កេះ ដើម្បីធ្វើយោគបាត្រ ដើម្បីធ្វើស្បោកបាត្រ ដើម្បីធ្វើសំពត់ត្រងទឹក ដល់ភិក្ខុដែលសូមអំបោះអំពីពួកញាតិ ដល់ភិក្ខុដែលសូមអំបោះ ពីពួកជនដែលបានបវារណាទុក ដល់ភិក្ខុដែលសូមអំបោះ ដើម្បីជាប្រយោជន៍ដល់ភិក្ខុដទៃ ដល់ភិក្ខុដែលបានមកដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុដែលខ្លួចចរិត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៦ ចប់ ។

# សត្តមសិក្ខាបទំ

[១៩៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ បុរិសោ បវាសំ គច្ឆន្តោ បជាបតឹ ឯតទវោច សុត្តំ ធារយិត្វា អមុកស្ស តន្តវាយស្ស ទេហិ ចីវរំ វាយាបេត្វា និក្ខិចាហិ[១] អាគតោ អយ្យំ ឧបនន្ទំ ចីវរេន អច្ឆាទេស្សាមីតិ ។ អស្សោសិ ខោ អញ្ញតរោ បិណ្ឌចារិកោ ភិក្ខុ តស្ស បុរិសស្ស ឥមំ វាចំ ភាសមានស្ស ។ អថខោ សោ ភិក្ខុ យេនាយស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច មហាបុញ្ញោសិ ត្វំ អាវុសោ ឧបនន្ទ អមុកស្មឹ ឱកាសេ អញ្ញតរោ បុរិសោ បវាសំ គច្ឆន្តោ បជាបតឹ ឯតទវោច សុត្តំ ធារយិត្វា អមុកស្ស តន្តវាយស្ស ទេហិ ចីវរំ វាយាបេត្វា និក្ខិចាហិ អាគតោ អយ្យំ ឧបនន្ទំ ចីវរេន អច្ឆាទេស្សាមីតិ ។ អត្ថាវុសោ

---

១ ឱ. ម. និក្ខិប ។

# សិក្ខាបទទី ៧

[១៩៧] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលទ្រង់គង់នៅវត្តជេតវន ជារបស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានបុរសម្នាក់ កាលចេញទៅកាន់និវាសស្ថាន បាននិយាយពាក្យនេះនឹងប្រពន្ធថា ចូរនាងថ្លឹងអំបោះយកទៅឲ្យជាងតម្បាញឯណោះ ហើយប្រាប់ឲ្យគេត្បាញចីវរទុកទៅ ចាំអញត្រឡប់មកវិញនឹងប្រគេនចីវរ (នោះ) ឲ្យព្រះឧបនន្ទជាម្ចាស់គ្រង ។ ភិក្ខុមួយរូបជាអ្នកកាន់បិណ្ឌចារិកវត្ត បានឮពាក្យដែលបុរសនោះ និយាយហើយ ។ ទើបភិក្ខុនោះ ចូលទៅរកឧបនន្ទសក្យបុត្រដ៏មានអាយុ លុះដល់ហើយបាននិយាយពាក្យនេះនឹងឧបនន្ទសក្យបុត្រដ៏មានអាយុថា ម្នាលអាវុសោ ឧបនន្ទ លោកជាអ្នកមានបុណ្យធំ ព្រោះបុរសម្នាក់នៅទីឯណោះ កាលគាត់ចេញទៅកាន់និវាសស្ថាន បាននិយាយនឹងប្រពន្ធគាត់ថា ចូរនាងថ្លឹងអំបោះ (សម្រាប់ត្បាញចីវរ) ហើយយកទៅឲ្យជាងតម្បាញឯណោះឲ្យគេត្បាញចីវរទុកឲ្យ (អញ) ចាំអញត្រឡប់មកវិញនឹងប្រគេនចីវរឲ្យព្រះឧបនន្ទជាម្ចាស់គ្រង ។ ឧបនន្ទដ៏មានអាយុឆ្លើយថា ម្នាលអាវុសោ

មំ សោ ឧបដ្ឋាកោតិ ។ សោបិ ខោ តន្តវាយោ អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស ឧបដ្ឋាកោ ហោតិ ។ អថខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ យេន សោ តន្តវាយោ តេនុបសង្កមិ ឧបសង្កមិត្វា តំ តន្តវាយំ ឯតទវោច ឥទំ ខោ អាវុសោ ចីវរំ មំ ឧទ្ទិស្ស វីយតិ អាយតញ្ច ករោហិ វិត្ថតញ្ច អប្បិតញ្ច សុវីតញ្ច សុប្បវាយិតញ្ច សុវិលេខិតញ្ច សុវិតច្ឆិតញ្ច ករោហីតិ ។ ឯតេ ខោ មេ ភន្តេ សុត្តំ ធារយិត្វា អទំសុ ឥមិនា សុត្តេន ចីវរំ វិនាហីតិ ន ភន្តេ សក្កា អាយតំ វា វិត្ថតំ វា អប្បិតំ វា កាតុំ សក្កា ច ខោ ភន្តេ សុវីតញ្ច សុប្បវាយិតញ្ច សុវិលេខិតញ្ច សុវិតច្ឆិតញ្ច កាតុន្តិ ។ ឥង្ឃ ត្វំ អាវុសោ អាយតញ្ច ករោហិ វិត្ថតញ្ច អប្បិតញ្ច ន តេន សុត្តេន បដិពទ្ធំ ភវិស្សតីតិ ។ អថខោ សោ តន្ត-វាយោ យថាភតំ សុត្តំ តន្តេ ឧបនេត្វា យេន សា ឥត្ថី តេនុបសង្កមិ ឧបសង្កមិត្វា តំ ឥត្ថឹ ឯតទវោច សុត្តេន អយ្យេ អត្ថោតិ ។ ននុ ត្វំ

ការនោះ ពិតមែនហើយ ព្រោះបុរសនោះជាញោមឧបដ្ឋាករបស់ខ្ញុំ ។ ឯជាងតម្បាញនោះ ជាញោមឧបដ្ឋាករបស់ឧបនន្ទសក្យបុត្រដ៏មានអាយុមែន ។ លំដាប់នោះ ឧបនន្ទសក្យបុត្រដ៏មានអាយុ ចូលទៅរកជាងតម្បាញនោះ លុះចូលទៅដល់ហើយបាននិយាយពាក្យនេះនឹងជាងតម្បាញនោះថា ម្នាលអ្នកដ៏មានអាយុ ចីវរនេះគេត្បាញចំពោះអាត្មា អ្នកចូរធ្វើឲ្យវែង ឲ្យទូលាយ ឲ្យណែន ត្បាញឲ្យស្មើល្អ រឹតតម្បាញឲ្យតឹង កួតឲ្យល្អ សិតឲ្យស្អាត ។ ជាងតម្បាញឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន គេថ្លឹងអំបោះទាំងនេះ មកឲ្យខ្ញុំករុណាថា អ្នកឯងចូរត្បាញចីវរដោយអំបោះនេះ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមិនអាចធ្វើឲ្យវែង ឲ្យទូលាយ ឲ្យណែនបានទេ បពិត្រលោកម្ចាស់ ប៉ុន្តែខ្ញុំករុណាអាចត្បាញឲ្យស្មើល្អ រឹតតម្បាញឲ្យតឹង កួតឲ្យល្អ សិតឲ្យស្អាតបាន ។ ឧបនន្ទដ៏មានអាយុពោលថា ណ្ហើយចុះ ម្នាលអ្នកដ៏មានអាយុ អ្នកចូរធ្វើឲ្យវែង ឲ្យទូលាយ ឲ្យណែនល្អចុះ អំបោះនោះមិនខ្វះទេ ។ លំដាប់នោះ ជាងតម្បាញនោះ បញ្ចូលអំបោះដែលបានមកទាំងប៉ុន្មានទៅក្នុងតម្បាញអស់ហើយ ទើបចូលទៅរកស្រីនោះ លុះចូលទៅដល់ហើយបាននិយាយពាក្យនេះនឹងស្រីនោះថា នែនាងដ៏ចម្រើន ឥឡូវត្រូវការអំបោះ (ថែមទៀត) ។ នាងនោះត្រឡប់សួរថា នែអ្នក

អយ្យ[១] មយា វុត្តោ ឥមិនា សុត្តេន ចីវរំ វិនាហីតិ ។ សច្ចាហំ អយ្យេ តយា វុត្តោ ឥមិនា សុត្តេន ចីវរំ វិនាហីតិ អបិច មំ អយ្យោ ឧបនន្ទោ ឯវមាហ ឥង្ឃ ត្វំ អាវុសោ អាយតញ្ច ករោហិ វិត្ថតញ្ច អប្បិតញ្ច ន តេន សុត្តេន បដិពទ្ធំ ភវិស្សតីតិ ។ អថខោ សា ឥត្ថី យត្តកញ្ញេវ សុត្តំ បឋមំ អទាសិ តត្តកំ បច្ឆា អទាសិ ។ អស្សោសិ ខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ សោ កិរ បុរិសោ បវាសតោ អាគតោតិ ។ អថខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ យេន តស្ស បុរិសស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សោ បុរិសោ យេនាយស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ បជាបតឹ ឯតទវោច ភយាបិតំ[២] ចីវរន្តិ ។ អាម អយ្យ ភយាបិតំ[៣] ចីវរន្តិ ។ អាហរ អយ្យំ ឧបនន្ទំ

១ ឱ. ម. អយ្យា ។ ២-៣ ឱ. ម. វីតំ ។

ខ្ញុំបានប្រាប់អ្នកហើយថា អ្នកចូរត្បាញចីវរដោយអំបោះប៉ុណ្ណោះឲ្យគ្រាន់ ។ ជាងតម្បាញឆ្លើយថា នែនាងដ៏ចម្រើន នាងបានប្រាប់ខ្ញុំថា អ្នកចូរត្បាញចីវរដោយអំបោះប៉ុណ្ណោះ ក៏ពិតមែនហើយ តែព្រះឧបនន្ទជាម្ចាស់លោកនិយាយយ៉ាងនេះនឹងខ្ញុំថា ណ្ហើយចុះ ម្នាលអ្នកដ៏មានអាយុ អ្នកចូរធ្វើឲ្យវែង ឲ្យទូលាយ ឲ្យណែនល្អ អំបោះនោះ មិនខ្វះទេ ។ ស្រីនោះ ក៏ឲ្យអំបោះទៅជាងតម្បាញ ក្នុងជាន់ក្រោយនេះ ប្រហែលអំបោះដែលបានឲ្យជាន់មុនដែរ ។ ឯឧបនន្ទសក្យបុត្រដ៏មានអាយុបានដំណឹងថា បុរសនោះត្រឡប់មកពីនិវាសស្ថានហើយ ។ ឧបនន្ទសក្យបុត្រដ៏មានអាយុចូលទៅកាន់លំនៅរបស់បុរសនោះ លុះចូលទៅហើយ ក៏អង្គុយលើអាសនៈដែលគេចាត់ចែងស្រាប់ ។ ឯបុរសនោះ ក៏ចូលទៅរកឧបនន្ទសក្យបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំឧបនន្ទសក្យបុត្រដ៏មានអាយុហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះបុរសនោះអង្គុយស្រួលបួលហើយក៏និយាយពាក្យនេះនឹងប្រពន្ធថា នាងឯងបានឲ្យជាងតម្បាញត្បាញចីវររួចហើយឬ ។ ប្រពន្ធឆ្លើយថា ចាំះ អ្នកជាម្ចាស់ ខ្ញុំបានឲ្យគេត្បាញចីវររួចហើយ ។ ប្តីទាររកថា ចូរនាងយកមក អញនឹងប្រគេនចីវរឲ្យព្រះឧបនន្ទ

១៩៧



ចីវរេន អច្ឆាទេស្សាមីតិ ។ អថខោ សា ឥត្ថី តំ ចីវរំ នីហរិត្វា សាមិកស្ស ទត្វា ឯតមត្ថំ អារោចេសិ ។ អថខោ សោ បុរិសោ អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស តំ ចីវរំ ទត្វា ឧជ្ឈាយតិ ខីយតិ វិបាចេតិ មហិច្ឆា ឥមេ សមណា សក្យបុត្តិយា អសន្តុដ្ឋា នយិមេ សុករា ចីវរេន អច្ឆាទេតុំ កថំ ហិ នាម អយ្យោ ឧបនន្ទោ មយា បុព្វេ អប្បវារិតោ តន្តវាយេ[១] ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជិស្សតីតិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស បុរិសស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ បុព្វេ អប្បវារិតោ គហបតិកស្ស តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ត្វំ ឧបនន្ទ បុព្វេ អប្បវារិតោ គហបតិកស្ស តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ

១ ឱ. ម. គហបតិកស្ស តន្តវាយេ ។

ជាម្ចាស់គ្រង ។ លំដាប់នោះ ស្រីនោះបាននាំយកចីវរនោះទៅឲ្យស្វាមី ហើយក៏ប្រាប់សេចក្តីនុ៎ះឲ្យដឹង ។ ទើបបុរសនោះ ប្រគេនចីវរនោះដល់ឧបនន្ទសក្យបុត្រដ៏មានអាយុហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រទាំងនេះ ជាអ្នកប្រាថ្នាច្រើន មិនសន្តោស យើងមិនងាយនឹងឲ្យសមណៈពួកនេះស្លៀកដណ្តប់ចីវរបានទេ អញមិនបានបវារណាព្រះឧបនន្ទជាម្ចាស់មកពីមុនទេ មិនសមបើនឹងហ៊ានចូលទៅរកជាងតម្បាញ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (គឺរិះគន់ចង់បានហួសហេតុ) ។ ភិក្ខុទាំងឡាយបានឮបុរសនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបនន្ទសក្យបុត្រដ៏មានអាយុ គេមិនបានបវារណាមកពីមុនសោះ មិនសមបើនឹងហ៊ានចូលទៅរកពួកជាងតម្បាញរបស់គហបតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (គឺរិះគន់ចង់បានហួសហេតុ) ។ លំដាប់នោះ ភិក្ខុទាំងនោះ នាំសេចក្តីនុ៎ះក្រាបទូល ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់ថា ឧបនន្ទ គេថាអ្នកឯង ជនជាម្ចាស់ចីវរគេមិនបានបវារណាមកពីមុនសោះ ហ៊ានចូលទៅរកពួកជាងតម្បាញរបស់គហបតី ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (គឺរិះគន់ចង់បានហួសហេតុ)

អាបជ្ជសីតិ[១] ។ សច្ចំ ភគវាតិ ។ ញាតកោ តេ ឧបនន្ទ អញ្ញាតកោតិ ។ អញ្ញាតកោ ភគវាតិ ។ អញ្ញាតកោ មោឃបុរិស អញ្ញាតកស្ស ន ជានាតិ បដិរូបំ វា អប្បដិរូបំ វា សន្តំ វា អសន្តំ វា តត្ថ នាម ត្វំ មោឃបុរិស បុព្វេ អប្បវារិតោ អញ្ញាតកស្ស គហបតិកស្ស តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ភិក្ខុំ បនេវ ឧទ្ទិស្ស អញ្ញាតកោ គហបតិ វា គហបតានី វា តន្តវាយេហិ ចីវរំ វាយាបេយ្យ ។ តត្រ ចេ សោ ភិក្ខុ បុព្វេ អប្បវារិតោ តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ

១ ឱ. ម. អាបជ្ជីតិ ។

ពិតមែនឬ ។ ឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះ ពិតមែន ។ ព្រះអង្គត្រាស់សួរថា នែឧបនន្ទ បុរសនោះជាញាតិរបស់អ្នកឯង ឬមិនមែនជាញាតិទេ ។ ឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ បុរសនោះ មិនមែនជាញាតិទេ ។ ម្នាលមោឃបុរស បុគ្គលមិនមែនជាញាតិ តែងមិនទទួលដឹងនូវការសមគួរ និងមិនសមគួរ ការល្អិតល្អ និងមិនល្អិតល្អ របស់បុគ្គលដែលមិនមែនជាញាតិទេ នែមោឃបុរស ក្នុងរឿងចីវរនោះ (បើ) ម្ចាស់ចីវរគេមិនបានបវារណាមកពីដើមទេ អ្នកឯងមិនសមបើនឹងហ៊ានចូលទៅរកពួកជាងតម្បាញរបស់គហបតីដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (គឺរិះគន់ចង់បានល្អឲ្យហួសហេតុដូច្នេះសោះ) នែមោឃបុរស អំពើដែលអ្នកឯងធ្វើមកនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា និងមិនមែននាំឲ្យជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា គហបតី (គឺបុរសជាម្ចាស់ផ្ទះ) ក្តី គហបតានី (គឺស្រីជាម្ចាស់ផ្ទះ)ក្តី ដែលមិនមែនជាញាតិ ឲ្យជាងតម្បាញត្បាញចីវរចំពោះភិក្ខុណាមួយ ។ បើភិក្ខុនោះ ដែលអ្នកម្ចាស់ចីវរគេមិនបានបវារណាមកពីមុនក្នុងរឿងចីវរនោះ អាចហ៊ានចូលទៅរកជាងតម្បាញ

ឥទំ ខោ អាវុសោ ចីវរំ មំ ឧទ្ទិស្ស វីយតិ អាយតញ្ច ករោថ វិត្ថតញ្ច អប្បិតញ្ច សុវីតញ្ច សុប្បវាយិតញ្ច សុវិលេខិតញ្ច សុវិតច្ឆិតញ្ច ករោថ អប្បេវនាម មយម្បិ អាយស្មន្តានំ កិញ្ចិមត្តំ អនុបទជ្ជេយ្យាមាតិ ។ ឯវញ្ច សោ ភិក្ខុ វត្វា កិញ្ចិមត្តំ អនុបទជ្ជេយ្យ[១] អន្តមសោ បិណ្ឌបាតមត្តម្បិ និស្សគ្គិយំ បាចិត្តិយន្តិ ។

[១៩៨] ភិក្ខុំ បនេវ ឧទ្ទិស្សាតិ ភិក្ខុស្សត្ថាយ ភិក្ខុំ អារម្មណំ កត្វា ភិក្ខុំ អច្ឆាទេតុកាមោ ។ អញ្ញាតកោ នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុគា អសម្ពទ្ធោ ។ គហបតិ នាម យោ កោចិ អគារំ អជ្ឈាវសតិ ។ គហបតានី នាម យា កាចិ អគារំ អជ្ឈាវសតិ ។ តន្តវាយេហីតិ បេសការេហិ ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនុបគំ បច្ឆិមំ ។ វាយាបេយ្យាតិ វិនាបេតិ ។

---

១ អនុប្បទជ្ជេយ្យាតិ យុត្តតរំ ។

ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (គឺរិះគន់ចង់បានល្អឲ្យហួសហេតុ) គឺពោលថា នៃអ្នកដ៏មានអាយុ ចីវរនេះគេឲ្យត្បាញចំពោះអាត្មា អ្នកទាំង-ឡាយ ចូរធ្វើឲ្យវែង ឲ្យទូលាយ ឲ្យមានសាច់ញឹក ឲ្យស្មើល្អ រឹតឲ្យតឹងល្អ ចូរត្រដោះកួតហើយសិតឲ្យល្អ សឹមអាត្មាថែមរង្វាន់ឲ្យអ្នកបន្តិចបន្តួច ។ ភិក្ខុនោះ លុះនិយាយយ៉ាងនេះហើយ ក៏ថែមរង្វាន់បន្តិចបន្តួចឲ្យដោយហោចទៅ ទុកជាគ្រាន់តែចង្ហាន់បិណ្ឌបាត (១ ឆ្អែត) ក៏ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

[១៥៨] ត្រង់ពាក្យថា ចំពោះភិក្ខុណាមួយ គឺដើម្បីជាប្រយោ-ជន៍ដល់ភិក្ខុ គឺធ្វើភិក្ខុឲ្យជាអារម្មណ៍ ហើយចង់ឲ្យភិក្ខុស្លៀកដណ្តប់ចីវរ ។ គហបតិដែលមិនជាប់ចំពាក់ (ជាសាច់ញាតិ) ពីចំណែកខាងមាតាក្តី បិតាក្តី រៀងរាល់ដល់គូជីដូនជីតាទី ៧ ហៅថា មិនមែនជាញាតិ ។ បុគ្គលណាមួយ ដែលគ្រប់គ្រងគេហស្ថាន បុគ្គលនោះហៅថា គហបតិ ។ ស្រីណាមួយដែលគ្រប់គ្រងគេហស្ថាន ស្រីនោះហៅថា គហបតានី ។ ពាក្យថា ជាងតម្បាញ បានដល់ពួកអ្នកធ្វើការត្បាញ ។ បណ្តាចីវរ ៦ យ៉ាង ចីវរយ៉ាងណានីមួយ យ៉ាងតូចបំផុតល្មមសម្រេចកិច្ចវិកប្បបាន ហៅថា ចីវរ ។ ពាក្យថា ឲ្យត្បាញ គឺថាឲ្យចាក់អំបោះឬសូត្រធ្វើសំពត់ ។

តត្រ ចេ សោ ភិក្ខូតិ យំ ភិក្ខុំ ឧទ្ទិស្ស ចីវរំ វីយតិ សោ ភិក្ខុ ។ បុព្វេ អប្បវារិតោតិ បុព្វេ អវុត្តោ ហោតិ កីទិសេន តេ ភន្តេ ចីវរេន អត្ថោ កីទិសំ តេ ចីវរំ វាយាបេមីតិ ។ តន្តវាយេ ឧបសង្កមិត្វាតិ ឃរំ គន្ត្វា យត្ថ កត្ថចិ ឧបសង្កមិត្វា ។ ចីវរេ វិកប្បំ អាបជ្ជេយ្យាតិ ឥទំ ខោ អាវុសោ ចីវរំ មំ ឧទ្ទិស្ស វីយតិ អាយតញ្ច ករោថ វិត្ថតញ្ច អប្បិតញ្ច សុវីតញ្ច សុប្បវាយិតញ្ច សុវិលេខិតញ្ច សុវិតច្ឆិតញ្ច ករោថ អប្បេវនាម មយម្បិ អាយស្មន្តានំ កិញ្ចិមត្តំ អនុបទជ្ជេយ្យាមាតិ ។ ឯវញ្ច សោ ភិក្ខុ វត្វា កិញ្ចិមត្តំ អនុបទជ្ជេយ្យ អន្តមសោ បិណ្ឌបាតមត្តម្បីតិ បិណ្ឌបាតោ នាម យាគុបិ ភត្តំបិ ខាទនីយំបិ ចុណ្ណបិណ្ឌោបិ ទន្តកដ្ឋំបិ ទសិកសុត្តំបិ អន្តមសោ ធម្មំបិ ភណតិ ។ តស្ស វចនេន អាយតំ វា វិត្ថតំ វា អប្បិតំ វា ករោតិ បយោគេ ទុក្កដំ ។

ពាក្យថា បើភិក្ខុនោះ សេចក្ដីថា ម្ចាស់ចីវរឲ្យត្បាញចីវរ ចំពោះភិក្ខុអង្គណា សំដៅយកភិក្ខុនោះ ។ ពាក្យថា គេមិនបានបវារណាមកពីមុន គឺមិនបាននិយាយគ្នាទុកមកពីមុនថា បពិត្រលោកម្ចាស់ លោកត្រូវការចីវរយ៉ាងណា ខ្ញុំករុណានឹងឲ្យជាងតម្បាញត្បាញចីវរយ៉ាងណាប្រគេនលោក ។ ពាក្យថា ចូលទៅរកជាងតម្បាញ គឺទៅផ្ទះជាងតម្បាញ ឬចូលទៅរកគេក្នុងកន្លែងណាមួយ ។ ពាក្យថា ដល់នូវកិរិយាកំណត់ ក្នុងចីវរ គឺនិយាយថា នៃអ្នកដ៏មានអាយុ ចីវរនេះ គេឲ្យត្បាញចំពោះអាត្មាហើយ អ្នកទាំងឡាយ ចូរធ្វើឲ្យវែង ឲ្យទូលាយ ឲ្យសាច់ញឹក ធ្វើឲ្យស្មើល្អ រឹតឲ្យតឹងល្អ ត្រដោះកួតឲ្យល្អ និងសិតឲ្យល្អ សឹមអាត្មាឯងនឹងថែមរបស់អ្វី ៗ ឲ្យពួកអ្នកដ៏មានអាយុខ្វះមិនខាន ។ ពាក្យថា ភិក្ខុនោះ លុះនិយាយយ៉ាងនេះហើយ ក៏ថែមវត្ថុជាទានបន្តិចបន្តួចឲ្យ ដោយហោចទៅទុកជាគ្រាន់តែចង្ហាន់បិណ្ឌបាត អធិប្បាយថា បបរក្ដី បាយក្ដី របស់គួរទំពាស៊ីក្ដី ហៅថា បិណ្ឌបាត ដោយហោចទៅ សូម្បីដុំលំអិតសម្រាប់ផ្ងូតក្ដី ឈើស្ទន់ក្ដី អំបោះរងដើងក្ដី ភិក្ខុសំដែងធម៌ឲ្យស្ដាប់ក្ដី (ក៏ហៅថា បិណ្ឌបាតក្នុងសិក្ខាបទនេះដែរ) ។ បើជាងតម្បាញត្បាញចីវរឲ្យវែងក្ដី ឲ្យទូលាយក្ដី ឲ្យមានសាច់ញឹកក្ដី តាមពាក្យ (បង្គាប់) របស់ភិក្ខុនោះ ត្រូវអាបត្តិទុក្កដតាមប្រយោគ ។

បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ ចីវរំ បុព្វេ អប្បវារិតោ អញ្ញាតកស្ស គហបតិកស្ស តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបន្នំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[១៨៩] អញ្ញាតកេ អញ្ញាតកសញ្ញី បុព្វេ អប្បវារិតោ គហបតិកស្ស តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញាតកេ វេមតិកោ បុព្វេ អប្បវារិតោ គហបតិកស្ស តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញាតកេ ញាតកសញ្ញី បុព្វេ អប្បវារិតោ

ចីវរនោះជានិស្សគ្គិយ ក្នុងខណៈដែលបានមក ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់យ៉ាងនេះថា ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវររបស់ខ្ញុំករុណានេះ ម្ចាស់ចីវរមិនបានបវារណាមកពីមុនទេ ខ្ញុំករុណាបានចូលទៅរកពួកជាងតម្បាញរបស់គហបតីដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (គឺចង់បានល្អហួសហេតុ) ចីវរនេះ ជានិស្សគ្គិយ ខ្ញុំករុណាសូមលះបង់ចីវរនេះដល់សង្ឃ ។ ពាក្យតអំពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គខាងដើមនោះហើយ ។

[១៥៩] ភិក្ខុសំគាល់គហបតីមិនមែនជាញាតិថា មិនមែនជាញាតិពិតមែន គេមិនបានបវារណាមកពីដើមទេ ចូលទៅរកជាងតម្បាញរបស់គហបតី ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ គហបតីមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ គេមិនបានបវារណាមកពីមុន ចូលទៅរកជាងតម្បាញរបស់គហបតី ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុសំគាល់គហបតីដែលមិនមែនជាញាតិថា ជាញាតិ គេមិនបានបវារណាទុកមុន

គហបតិកស្ស តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជតិ និស្សគ្គិយំ ចាចិត្តិយំ ។ ញាតកេ អញ្ញាតកសញ្ញី អាបត្តិ ទុក្កដស្ស ។ ញាតកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ញាតកេ ញាតក-សញ្ញី អនាបត្តិ ។

[១៦០] អនាបត្តិ ញាតកានំ បវារិតានំ អញ្ញស្ស-ត្ថាយ អត្តនោ ធនេន មហគ្ឃំ វាយាបេតុកាមស្ស អប្បគ្ឃំ វាយាបេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។

ចូលទៅរកពួកជាងតម្បាញរបស់គហបតី ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុសំគាល់គហបតីដែលជាញាតិថា មិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យនឹងគហបតីដែលជាញាតិ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់គហបតិដែលជាញាតិថា ជាញាតិពិតមែន មិនត្រូវអាបត្តិអ្វីឡើយ ។

[១៦០] អាបត្តិមិនមានដល់ភិក្ខុដែលកំណត់ចីវរ ក្នុងសំណាក់នៃពួកគហបតីដែលជាញាតិ ដល់ភិក្ខុដែលកំណត់ចីវរ ក្នុងសំណាក់នៃពួកគហបតីដែលបានបវារណា ដល់ភិក្ខុដែលកំណត់ចីវរដើម្បីជាប្រយោជន៍ដល់ភិក្ខុឯទៀត ដល់ភិក្ខុដែលធ្វើចីវរដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុដែលម្ចាស់ចីវរគេចង់ឲ្យត្បាញចីវរមានតម្លៃច្រើន តែភិក្ខុឲ្យគេត្បាញចីវរ មានតម្លៃតិចវិញ ដល់ភិក្ខុដែលខ្ចួចចរិត ដល់ភិក្ខុដែលជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

# អដ្ឋមសិក្ខាបទំ

[១៦១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ មហាមត្តោ បវាសំ គច្ឆន្តោ ភិក្ខូនំ សន្តិកេ ទូតំ បាហេសិ អាគច្ឆន្តុ ភទន្តា វស្សាវាសិកំ ទស្សាមីតិ ។ ភិក្ខូ វស្សំ វុត្ថានំ ភគវតា វស្សាវាសិកំ អនុញ្ញាតន្តិ កុក្កុច្ចាយន្តា នាគមំសុ ។ អថខោ សោ មហាមត្តោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភទន្តា មយា បហិតេ ទូតេ នាគច្ឆិស្សន្តិ អហំ ហិ សេនាយ គច្ឆាមិ ទុជ្ជានំ ជីវិតំ ទុជ្ជានំ មរណន្តិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស មហាមត្តស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ

# សិក្ខាបទទី ៨

[១៦១] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មហាអាមាត្យម្នាក់ កាលចេញទៅកាន់ទីនិវាសស្ថានជាទីព្រាត់ប្រាស បានប្រើបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយ ដោយពាក្យថា លោកម្ចាស់ទាំងឡាយ ចូរនិមន្តមក ខ្ញុំនឹងថ្វាយសំពត់ចំណាំវស្សា ។ ឯពួកភិក្ខុសង្ស័យថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់អនុញ្ញាតសំពត់ចំណាំវស្សាដល់ពួកភិក្ខុដែលចាំវស្សហើយ ទើបមិននាំគ្នាមក (ព្រោះវេលានៅមិនទាន់ចេញវស្សា) ។ លំដាប់នោះ មហាអាមាត្យនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា អញបានប្រើបម្រើទៅហើយ មិនសមបីបើលោកម្ចាស់ទាំងឡាយមិននិមន្តមក ខ្លួនអញចេញទៅក្នុងកងទ័ព ការរស់នៅ ឬ ស្លាប់ទៅមិនងាយដឹងទេ ។ ភិក្ខុទាំងឡាយបានឮ មហាអាមាត្យនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ទើបពួកភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សំដែងធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយក្នុងខណៈនោះថា ម្នាលភិក្ខុទាំងឡាយ

អនុជានាមិ ភិក្ខវេ អច្ចេកចីវរំ បដិគ្គហេត្វា និក្ខិបិតុន្តិ ។ តេន ខោ បន សមយេន ភិក្ខូ ភគវតា អនុញ្ញាតំ អច្ចេកចីវរំ បដិគ្គហេត្វា និក្ខិបិតុន្តិ អច្ចេកចីវរំ[១] បដិគ្គហេត្វា ចីវរកាលសមយំ អតិក្កាមេន្តិ ។ តានិ ចីវរានិ ចីវរវំសេ ភណ្ឌិកាពទ្ធានិ តិដ្ឋន្តិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ សេនាសនចារិកំ អាហិណ្ឌន្តោ តានិ ចីវរានិ ចីវរវំសេ ភណ្ឌិកាពទ្ធានិ បិតានិ[២] ទិស្វាន ភិក្ខូ អាមន្តេសិ[៣] កស្សិមានិ អាវុសោ ចីវរានិ ចីវរវំសេ ភណ្ឌិកាពទ្ធានិ តិដ្ឋន្តីតិ ។ អម្ហាកំ អាវុសោ អច្ចេកចីវរានីតិ ។ កីវចិរំ បនាវុសោ ឥមានិ ចីវរានិ និក្ខិត្តានីតិ ។ អថខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស យថានិក្ខិត្តំ អារោចេសុំ ។ អាយស្មា អានន្ទោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខូ អច្ចេកចីវរានិ បដិគ្គហេត្វា ចីវរកាលសមយំ អតិក្កាមេស្សន្តីតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ សច្ចំ កិរ ភិក្ខវេ

១ ឱ. ម. អច្ចេកចីវរានិ ។ ២ ឱ. ម. តិដ្ឋន្តេ ។ ៣ សព្វត្ថ ឯតទវោចាតិ ទិស្សតិ ។

តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទទួលអច្ចេកចីវរទុកដាក់បាន ។ សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់អនុញ្ញាតឲ្យភិក្ខុទាំងឡាយ ទទួលអច្ចេកចីវរទុកដាក់បាន ហើយក៏ទទួលអច្ចេកចីវរទុកឲ្យកន្លងហួសចីវរកាលទៅ ។ ភិក្ខុទាំងឡាយ បានវេចខ្ចប់នូវចីវរទាំងនោះ ព្យួរទុកនឹងខ្សែស្ទៀង ។ អានន្ទត្ថេរដ៏មានអាយុ ដើរទៅកាន់ចារិកនៃសេនាសនៈ ក៏បានឃើញចីវរទាំងនោះ ដែលភិក្ខុខ្ចប់ព្យួរទុកនឹងខ្សែស្ទៀង លុះឃើញហើយទើបហៅភិក្ខុទាំងឡាយមកសួរថា ម្នាលអាវុសោទាំងឡាយ ចីវរទាំងនេះ ដែលគេព្យួរទុកនឹងខ្សែស្ទៀង តើជារបស់អ្នកណា ។ ពួកភិក្ខុឆ្លើយថា អាវុសោ អច្ចេកចីវររបស់យើងខ្ញុំទាំងឡាយ ។ អានន្ទត្ថេរសួរទៀតថា ម្នាលអាវុសោ ចីវរទាំងនេះ លោករាល់គ្នាបានដាក់ទុកមកយូរអស់កាលប៉ុន្មានហើយ ។ ទើបភិក្ខុទាំងនោះបានប្រាប់កាលដែលខ្លួនបានដាក់ទុកចីវរនោះ ដល់ព្រះអានន្ទត្ថេរដ៏មានអាយុ ។ អានន្ទត្ថេរដ៏មានអាយុ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុមិនសមបើនឹងទទួលអច្ចេកចីវរ ហើយទុកឲ្យកន្លងហួសចីវរកាលទៅ ។ លំដាប់នោះ អានន្ទត្ថេរដ៏មានអាយុ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ

២០៨

និស្សគ្គិយកណ្ឌោ បត្តវគ្គស្ស អដ្ឋមសិក្ខាបទស្ស បញ្ញត្តិ

ភិក្ខូ អច្ចេកចីវរំ បដិគ្គហេត្វា ចីវរកាលសមយំ អតិក្កាមេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា អច្ចេកចីវរំ បដិគ្គហេត្វា ចីវរកាលសមយំ អតិក្កាមេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ទសាហានាគតំ កត្តិកតេមាសិបុណ្ណមំ ភិក្ខុនោ បនេវ អច្ចេកចីវរំ ឧប្បជ្ជេយ្យ អច្ចេកំ មញ្ញមានេន ភិក្ខុនា បដិគ្គហេតព្វំ បដិគ្គហេត្វា យាវចីវរកាលសមយំ និក្ខិបិតព្វំ តតោ ចេ ឧត្តរឹ និក្ខិបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

ឮថាពួកភិក្ខុទទួលអច្ចេកចីវរហើយ បណ្តោយឲ្យកន្លងហួសចីវរកាលទៅ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការណ៍នោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មិនសមបី បើពួកមោឃបុរសនោះ ទទួលអច្ចេកចីវរហើយ បណ្តោយឲ្យកន្លងហួសចីវរកាលទៅទេ ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាផង មិននាំឲ្យជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងផង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ថ្ងៃពេញបូណ៌មីខែកត្តិក[១] ដែលជាខែទី ៣ នៃវស្សានរដូវនៅខ្វះ ១០ ថ្ងៃ[២] ទៀតនឹងគ្រប់ (គឺថ្ងៃ ៥ កើតខែអស្សុជ) បើអច្ចេកចីវរកើតឡើងដល់ភិក្ខុ ៗ សំគាល់ថា ជាអច្ចេកចីវរ គប្បីទទួលទុក លុះទទួលហើយ គប្បីទុកដាក់ដរាបអស់សម័យចីវរកាល បើភិក្ខុទុកយូរឲ្យហួសកំណត់នោះទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។

---

១ ថ្ងៃពេញបូណ៌មីខែបឋមកត្តិក គឺថ្ងៃ ១៥ កើតខែអស្សុជ ។ ២ គិតពីត្រឹមថ្ងៃ ៥ កើតទៅដល់ថ្ងៃ ១៥ កើតខែអស្សុជ ។ បើភិក្ខុមិនបានក្រាលកឋិនទេ ត្រូវទុកអច្ចេកចីវរបានត្រឹម ១ ខែ ១១ ថ្ងៃ បើបានក្រាលកឋិន ត្រូវទុកបាន ៥ ខែ ១១ ថ្ងៃ ទុកឲ្យហួសអំពីកំណត់នោះទៅ សូម្បីត្រឹមតែ ១ ថ្ងៃក៏ពុំបានឡើយ (អដ្ឋកថា) ។

[១៦២] ទសាហានាគតន្តិ ទសាហានាគតាយ បវារណាយ ។ កត្តិកតេមាសិបុណ្ណមន្តិ បវារណា កត្តិកា វុច្ចតិ ។ អច្ចេកចីវរំ នាម សេនាយ វា គន្តុកាមោ ហោតិ បវាសំ វា គន្តុកាមោ ហោតិ គិលានោ វា ហោតិ គព្ភិនី វា ហោតិ អស្សទ្ធស្ស វា សទ្ធា ឧប្បន្នា ហោតិ អប្បសន្នស្ស វា បសាទោ ឧប្បន្នោ ហោតិ ។ សោ ចេ ភិក្ខុំ សន្តិកេ ទូតំ បហិណេយ្យ អាគច្ឆន្តុ ភទន្តា វស្សាវាសិកំ ទស្សា-មីតិ ។ ឯតំ អច្ចេកចីវរំ នាម ។ អច្ចេកំ មញ្ញមានេន ភិក្ខុនា បដិគ្គហេតព្វំ បដិគ្គហេត្វា យាវចីវរកាល-សមយំ និក្ខិបិតព្វន្តិ សញ្ញាណំ កត្វា និក្ខិបិតព្វំ ឥទំ អច្ចេកចីវរន្តិ ។ ចីវរកាលសមយោ នាម អនត្ថតេ កឋិនេ វស្សានស្ស បច្ឆិមោ មាសោ អត្ថតេ

[១៦២] ត្រង់ពាក្យថា ខ្វះ ១០ ថ្ងៃទៀត គឺនៅខ្វះ ១០ ថ្ងៃទៀត នឹងដល់ថ្ងៃបវារណា ។ ថ្ងៃបវារណាក្នុងខែកត្តិក តថាគតត្រាស់ហៅថា ថ្ងៃពេញបូណ៌មីនៃខែកត្តិក ដែលជាខែទី ៣ នៃវស្សានរដូវ ។ ដែលហៅថា អច្ចេកចីវរនោះ គឺសំពត់ដែលបុគ្គលណាមួយ ត្រូវការនឹងចេញទៅក្នុងកងទ័ពក្តី ត្រូវការនឹងចេញទៅកាន់និវាសស្ថានក្តី មនុស្សមានជំងឺក្តី ស្រីមានគភ៌ក្តី បុគ្គលឥតសទ្ធាត្រឡប់មានសទ្ធាកើតឡើងក្តី បុគ្គលគ្មានសេចក្តីជ្រះថ្លាត្រឡប់ជាមានសេចក្តីជ្រះថ្លាកើតឡើងក្តី ។ បើបុគ្គលនោះប្រើបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយ (ចំពោះចីវរណា) ដោយពាក្យថាលោកម្ចាស់ទាំងឡាយ សូមនិមន្តមក ខ្ញុំព្រះករុណានឹងប្រគេនសំពត់វស្សាវាសិក (សំពត់ចំណាំវស្សា) ។ ចីវរនេះឈ្មោះថា អច្ចេកចីវរ (គឺចីវរដែលបុគ្គលធ្វើដោយរួសរាន់) ។ ពាក្យថា ភិក្ខុសំគាល់ថា ជាអច្ចេកចីវរ គប្បីទទួលទុក លុះទទួលរួចហើយ គប្បីទុកដរាបអស់សម័យចីវរកាល សេចក្តីថា ភិក្ខុត្រូវធ្វើសេចក្តីសំគាល់ថា នេះជាអច្ចេកចីវរហើយទុកដាក់ចុះ ។ ដែលហៅថា សម័យចីវរកាលនោះ គឺថា បើភិក្ខុមិនបានក្រាលកឋិនទេ នោះត្រូវកំណត់យកខែខាងចុង[១] នៃវស្សានរដូវ ១ ខែ

---

១ បើភិក្ខុមិនបានក្រាលកឋិនទេ ចីវរកាលមានតែ ១ ខែ គឺរាប់តាំងពីថ្ងៃ ១ រោចខែអស្សុជ ទៅដល់ថ្ងៃ ១៥ កើតខែកត្តិក បើបានក្រាលកឋិន ចីវរកាលមាន ៥ ខែ គឺរាប់តាំងពីថ្ងៃ ១ រោច ខែអស្សុជ ទៅដល់ថ្ងៃ ១៥ កើតខែផល្គុន នេះហៅថា ចីវរកាលសម័យ ។

កឋិនេ បញ្ច មាសា ។ តតោ ចេ ឧត្តរឹ និក្ខិបេយ្យាតិ អនត្ថតេ កឋិនេ វស្សានស្ស បច្ឆិមំ ទិវសំ អតិក្កាមេតិ និស្សគ្គិយំ ហោតិ[១] ។ អត្ថតេ កឋិនេ កឋិនុទ្ធារទិវសំ អតិក្កាមេតិ និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ អច្ចេកចីវរំ ចីវរ-កាលសមយំ អតិក្កាមិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[១៦៣] អច្ចេកចីវរេ អច្ចេកចីវរសញ្ញី ចីវរកា-លសមយំ អតិក្កាមេតិ និស្សគ្គិយំ បាចិត្តិយំ ។ អច្ចេកចីវរេ វេមតិកោ ចីវរកាលសមយំ អតិក្កាមេតិ និស្សគ្គិយំ បាចិត្តិយំ ។ អច្ចេកចីវរេ អនច្ចេកចីវរសញ្ញី ចីវរកាលសមយំ អតិក្កាមេតិ និស្សគ្គិយំ បាចិត្តិយំ ។ អនធិដ្ឋិតេ អធិដ្ឋិតសញ្ញី... អវិកប្បិតេ វិកប្បិតសញ្ញី...

---

១ សព្វត្ថ និស្សគ្គិយំ បាចិត្តិយន្តិ ទិស្សតិ ។

បើបានក្រាលកឋិនត្រូវកំណត់យក ៥ ខែ ។ ពាក្យថា ថាបើភិក្ខុទុកដាក់ឲ្យហួសកំណត់នោះទៅ គឺថាបើមិនបានក្រាលកឋិន ភិក្ខុបណ្ដោយឲ្យអច្ចេកចីវរកន្លងថ្ងៃខាងចុងនៃវស្សានរដូវ គឺថ្ងៃពេញបូណ៌មីខែកត្តិកទៅ អច្ចេកចីវរនោះ ជានិស្សគ្គិយ ។ បើភិក្ខុក្រាលកឋិនរួចហើយ បណ្ដោយឲ្យអច្ចេកចីវរកន្លងហួសថ្ងៃដែលភិក្ខុដោះកឋិនទៅ អច្ចេកចីវរនោះ ជានិស្សគ្គិយដែរ ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះបង់យ៉ាងនេះថា ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន អច្ចេកចីវររបស់ខ្ញុំនេះ ខ្ញុំទុកឲ្យកន្លងសម័យចីវរកាលទៅហើយ ចីវរនេះ ជានិស្សគ្គិយ ខ្ញុំករុណា សូមលះបង់អច្ចេកចីវរនេះដល់សង្ឃ ។ សេចក្ដីតអំពីនេះទៅមានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គខាងដើមហើយ ។

[១៦៣] អច្ចេកចីវរពិតមែន ភិក្ខុក៏សំគាល់ថា ជាអច្ចេកចីវរ បើភិក្ខុទុកឲ្យកន្លងសម័យចីវរកាលទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានសេចក្ដីសង្ស័យក្នុងអច្ចេកចីវរ ហើយទុកឲ្យកន្លងសម័យចីវរកាលទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។ អច្ចេកចីវរមែន ភិក្ខុសំគាល់ថា មិនមែនជាអច្ចេកចីវរ ទុកឲ្យកន្លងហួសសម័យចីវរកាលទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុសំគាល់អច្ចេកចីវរដែលមិនបានអធិដ្ឋាន ថាបានអធិដ្ឋានហើយក្ដី សំគាល់អច្ចេកចីវរ

អវិស្សជ្ជិតេ វិស្សជ្ជិតសញ្ញី... អនដ្ឋេ នដ្ឋសញ្ញី... អវិនដ្ឋេ វិនដ្ឋសញ្ញី... អនឌ្ឍេ ទឌ្ឍសញ្ញី... អវិលុត្តេ វិលុត្តសញ្ញី ចីវរកាលសមយំ អតិក្កាមេតិ និស្សគ្គិយំ បាចិត្តិយំ ។ និស្សគ្គិយំ ចីវរំ អនិស្សជ្ជិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។ អនច្ចេកចីវរេ អច្ចេកចីវរសញ្ញី អាបត្តិ ទុក្កដស្ស ។ អនច្ចេកចីវរេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនច្ចេកចីវរេ អនច្ចេកចីវរសញ្ញី អនាបត្តិ ។

[១៦៤] អនាបត្តិ អន្តោសមយំ អធិដ្ឋេតិ វិកប្បេតិ វិសជ្ជេតិ នស្សតិ វិនស្សតិ ឌយ្ហតិ អច្ឆិន្ទិត្វា គណ្ហាតិ[១] វិស្សាសំ គណ្ហាតិ[២] ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។

១-២ ឱ. ម. គណ្ហន្តិ ។

ដែលមិនបានវិកប្ប ថាបានវិកប្បរួចហើយក្តី សំគាល់អច្ចេកចីវរដែលមិនបានលះបង់ ថាបានលះបង់ហើយក្តី សំគាល់អច្ចេកចីវរដែលមិនបាត់ថា បាត់ទៅហើយក្តី សំគាល់អច្ចេកចីវរដែលមិនវិនាសថា វិនាសហើយក្តី សំគាល់អច្ចេកចីវរដែលភ្លើងមិនឆេះ ថាភ្លើងឆេះហើយក្តី សំគាល់អច្ចេកចីវរដែលចោរមិនបានប្លន់ ថាចោរប្លន់យកទៅហើយក្តី ហើយទុកឲ្យកន្លងហួសចីវរកាលទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមិនលះបង់ចីវរដែលជានិស្សគ្គិយហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់សំពត់ដែលមិនមែនអច្ចេកចីវរ ថាជាអច្ចេកចីវរ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងសំពត់ដែលមិនមែនអច្ចេកចីវរ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់សំពត់ដែលមិនមែនជាអច្ចេកចីវរ ថាមិនមែនអច្ចេកចីវរ មិនត្រូវអាបត្តិឡើយ ។

[១៦៤] អាបត្តិមិនមាន ដល់ភិក្ខុដែលបានអធិដ្ឋានអច្ចេកចីវរទុក (ក្តី) វិកប្បទុក (ក្តី) លះបង់ឲ្យគេ (ក្តី) ដល់ភិក្ខុដែលមានអច្ចេកចីវរបាត់ទៅ (ក្តី) វិនាសទៅ (ក្តី) ភ្លើងឆេះ (ក្តី) ចោរដណ្តើមយកទៅ (ក្តី) សហធម្មិកកាន់យកទៅដោយសេចក្តីស្និទ្ធស្នាល (ក្តី) ខាងក្នុងសម័យចីវរកាល ដល់ភិក្ខុឆ្កួត ដល់ភិក្ខុខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់ ។

# នវមសិក្ខាបទំ

[១៦៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខូ វុត្ថវស្សា អារញ្ញកេសុ សេនាសនេសុ វិហរន្តិ ។ កត្តិកចោរកា ភិក្ខូ លទ្ធលាភាតិ បរិបាតេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អារញ្ញកេសុ សេនាសនេសុ វិហរន្តេន តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបិតុន្តិ ។ តេន ខោ បន សមយេន ភិក្ខូ ភគវតា អនុញ្ញាតំ អារញ្ញកេសុ សេនាសនេសុ វិហរន្តេន តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបិតុន្តិ ។ តេ[១] តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបិត្វា អតិរេកឆារត្តំ វិប្បវសន្តិ ។ តានិ ចីវរានិ នស្សន្តិបិ

១ អារញ្ញកេសុ សេនាសនេសុ វិហរន្តា តិណ្ណន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។

# សិក្ខាបទទី ៩

[១៦៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគកាល គង់នៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកមហាសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុទាំងឡាយនៅចាំវស្សាហើយ ទៅនៅក្នុងសេនាសនៈ ដែលឋិតនៅក្នុងព្រៃ ។ ពួកចោរខែកត្តិក[១]គិតគ្នាថា ពួកភិក្ខុបានលាភ(ច្រើន) ហើយក៏នាំគ្នាមកបៀតបៀន ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សំដែងធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលអាស្រ័យនៅសេនាសនៈក្នុងព្រៃ តថាគតអនុញ្ញាតឲ្យទុក បណ្ដាចីវរទាំង ៣ ចីវរណាមួយ ក្នុងចន្លោះផ្ទះបាន ។ សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់អនុញ្ញាតឲ្យភិក្ខុដែលអាស្រ័យនៅសេនាសនៈក្នុងព្រៃទុកដាក់ បណ្ដាចីវរទាំង ៣ ចីវរណាមួយ ក្នុងចន្លោះផ្ទះបាន ។ ពួកភិក្ខុនោះ ក៏បានទុកដាក់ បណ្ដាចីវរទាំង ៣ ចីវរណាមួយ ក្នុងចន្លោះផ្ទះហើយនៅប្រាសចាកហួស ៦ រាត្រី ។ ចីវរទាំងនោះ បាត់ទៅខ្លះ

១ អដ្ឋកថា ប្រាប់ថា ពួកចោរដែលធ្វើចោរកម្មក្នុងខែកត្តិក ។

វិនស្សន្តិបិ ឌយ្ហន្តិបិ ឧន្ទុរេហិបិ ខជ្ជន្តិ ។ ភិក្ខូ ទុច្ចោលា ហោន្តិ លូខចីវរា ។ ភិក្ខូ ឯវមាហំសុ កិស្ស តុម្ហេ អាវុសោ ទុច្ចោលា លូខចីវរាតិ ។ អថខោ តេ ភិក្ខូ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបិត្វា អតិរេកឆារត្តំ វិប្បវសិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបិត្វា អតិរេកឆារត្តំ វិប្បវសន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបិត្វា អតិរេកឆារត្តំ វិប្បវសិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ

ខ្វះបខាតទៅខ្លះ ភ្លើងឆេះខ្លះ កណ្ដុរកាត់ខ្លះ ។ ភិក្ខុទាំងឡាយ មានសំពត់អាក្រក់មានចីវរសៅហ្មង ។ ពួកភិក្ខុ (ឯទៀត) សួរយ៉ាងនេះថា នែអាវុសោ ហេតុម្ដេចបានជាអ្នកទាំងឡាយ មានសំពត់អាក្រក់មានចីវរសៅហ្មង ។ ភិក្ខុទាំងនោះ ក៏ប្រាប់សេចក្ដីនុ៎ះ ដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចុះហេតុអ្វីបានជាភិក្ខុទាំងឡាយទុក បណ្ដាចីវរទាំង ៣ ចីវរណាមួយក្នុងចន្លោះផ្ទះ (គឺក្នុងភូមិ ឬក្នុងស្រុក) ហើយនៅប្រាសចាក (ត្រៃចីវរ) នោះហួស ៦ រាត្រី ។ ខណៈនោះ ភិក្ខុទាំងនោះ ក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុទុកបណ្ដាចីវរទាំង ៣ ចីវរណាមួយក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាកហួស ៦ រាត្រី ពិតមែនឬ ។ ភិក្ខុទាំងនោះ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះ ពិតមែន ។ ព្រះពុទ្ធដ៏មានយសជាម្ចាស់ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចុះហេតុអ្វី បានជាពួកមោឃបុរសទាំងនោះទុក បណ្ដាចីវរទាំង ៣ ចីវរណាមួយក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាកហួស ៦ រាត្រីទៅ នែភិក្ខុទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាផង មិនមែននាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតផង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

២១១

និស្សគ្គិយកណ្ឌេ បត្តវគ្គស្ស នវមសិក្ខាបទស្ស បទភាជនីយំ

ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ឧបវស្សំ ខោ បន កត្តិកបុណ្ណមំ ។ យានិ ខោ បន តានិ អារញ្ញកានិ សេនាសនានិ សាសង្កសម្មតានិ សប្បដិភយានិ តថារូបេសុ ភិក្ខុ សេនាសនេសុ វិហរន្តោ អាកង្ខមានោ តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបេយ្យ ។ សិយា ច តស្ស ភិក្ខុនោ កោចិទេវ បច្ចយោ តេន ចីវរេន វិប្បវាសាយ ឆារត្តបរមន្តេន ភិក្ខុនា តេន ចីវរេន វិប្បវសិតព្វំ ។ តតោ ចេ ឧត្តរឹ វិប្បវសេយ្យ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយន្តិ ។

[១៦៦] ឧបវស្សំ ខោ បនាតិ វុត្ថវស្សានំ ។ កត្តិកបុណ្ណមន្តិ កត្តិកចាតុម្មាសិនី វុច្ចតិ ។ យានិ ខោ បន តានិ អារញ្ញកានិ សេនាសនានីតិ អារញ្ញកំ នាម សេនាសនំ បញ្ចធនុសតិកំ បច្ឆិមំ ។ សាសង្កំ នាម អារាមេ អារាមុបចារេ ចោរានំ និវិដ្ឋោកាសោ ទិស្សតិ ភុត្តោកាសោ ទិស្សតិ ឋិតោកាសោ ទិស្សតិ និសិន្នោកាសោ ទិស្សតិ និបន្នោកាសោ ទិស្សតិ ។

អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើភិក្ខុទាំងឡាយចាំវស្សារួចហើយ លុះដល់មកពេញបូណ៌មីខែកត្តិក ។ សេនាសនៈទាំងឡាយណា ដែលតាំងនៅក្នុងព្រៃ ដែលគេសម្មតថា ជាទីមានសេចក្តីរង្កៀស មានភ័យចំពោះមុខ កាលភិក្ខុនៅក្នុងសេនាសនៈទាំងឡាយមានសភាពដូច្នោះ បើមានចំណង់នឹងទុកចីវរ គប្បីទុកបណ្តាចីវរទាំង ៣ ចីវរណាមួយក្នុងចន្លោះផ្ទះ ។ តែបើភិក្ខុនោះមានហេតុអ្វីនីមួយល្មមឲ្យនៅប្រាសចាកចីវរនោះបាន ភិក្ខុនោះ គប្បីនៅប្រាសចាកចីវរនោះ យ៉ាងយូរត្រឹម ៦ រាត្រី ។ បើនៅប្រាសចាកឲ្យហួសពីកំណត់នោះទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានសេចក្តីសម្មតអំពីសង្ឃ ។

[១៦៦] ត្រង់ពាក្យថា ចាំវស្សារួចហើយ គឺចេញវស្សាហើយ ។ ពាក្យថា ពេញបូណ៌មីខែកត្តិក គឺថាព្រះដ៏មានព្រះភាគត្រាស់សំដៅយកខែទី ៤ (នៃវស្សានរដូវ) ឈ្មោះថា កត្តិក[១] ។ ពាក្យថា សេនាសនៈទាំងឡាយណា ដែលតាំងនៅក្នុងព្រៃ គឺសេនាសនៈដែលតាំងនៅក្នុងព្រៃមានចម្ងាយពីស្រុក ៥០០ ធ្នូរផ្លូវកំណត់យ៉ាងជិតបំផុត ។ ដែលហៅថាទីមានសេចក្តីរង្កៀសនោះ បានដល់ឱកាសដែលពួកចោរអាស្រ័យនៅបរិភោគ ឈរ អង្គុយ ដេក មានប្រាកដក្នុងអារាមឬឧបចារនៃអារាម ។

១ តាមអដ្ឋកថា ហៅថា បច្ឆិមកត្តិក ។

សប្បដិភយំ នាម អារាមេ អារាមូបចារេ ចោរេហិ មនុស្សា ហតា ទិស្សន្តិ វិលុត្តា ទិស្សន្តិ អាកោដិតា ទិស្សន្តិ ។ តថារូបេសុ ភិក្ខុ សេនាសនេសុ វិហរន្តោតិ ឯវរូបេសុ ភិក្ខុ សេនាសនេសុ វិហរន្តោ ។ អាកង្ខមានោតិ ឥច្ឆមានោ ។ តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរន្តិ សង្ឃាដឹ វា ឧត្តរាសង្គំ វា អន្តរវាសកំ វា ។ អន្តរឃរេ និក្ខិបេយ្យាតិ សមន្តា គោចរគាមេ និក្ខិបេយ្យ ។ សិយា ច តស្ស ភិក្ខុនោ កោចិទេវ បច្ចយោ តេន ចីវរេន វិប្បវាសាយាតិ សិយា បច្ចយោ សិយា ករណីយំ ។ ឆារត្តបរមន្តេន ភិក្ខុនា តេន ចីវរេន វិប្បវសិតព្វន្តិ ឆារត្តបរមតា វិប្បវសិតព្វំ ។ អញ្ញត្រ ភិក្ខុសម្មតិយាតិ ឋបេត្វា ភិក្ខុសម្មតឹ ។ តតោ ចេ ឧត្តរឹ វិប្បវសេយ្យាតិ សត្តមេ អរុណុគ្គមនេ និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ចបន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ ចីវរំ

ដែលហៅថា ទីមានភ័យចំពោះមុខនោះ គឺ ក្នុងអារាម ឬ ឧបចារៈនៃអារាម ប្រាកដថា មានពួកចោរសម្លាប់មនុស្សទាំងឡាយ ប្រាកដថា មានពួកចោរប្លន់ ប្រាកដថា មានពួកចោរវាយដំ ។ ពាក្យថា កាលភិក្ខុនៅក្នុងសេនាសនៈទាំងឡាយមានសភាពដូច្នោះ គឺថាកាលភិក្ខុនៅក្នុងសេនាសនៈទាំងឡាយមានសភាពយ៉ាងនេះ ។ ពាក្យថា បើមានចំណង់ គឺកាលប្រាថ្នា (នឹងទុកចីវរ) ។ ពាក្យថា បណ្តាចីវរទាំង ៣ ចីវរណាមួយ គឺភិក្ខុទុកសង្ឃាដិ ឬឧត្តរាសង្គៈ (ចីពរ) ឬអន្តរវាសក (ស្បង់) ។ ពាក្យថា គប្បីទុកក្នុងចន្លោះផ្ទះ គឺគប្បីទុកក្នុងស្រុកជាទីគោចរ ដោយជុំវិញបាន ។ ពាក្យថា តែបើភិក្ខុនោះ មានហេតុអ្វីមួយល្មមឲ្យនៅប្រាសចាកចីវរនោះបានគឺ មានហេតុ មានកិច្ចដែលត្រូវធ្វើ ។ ពាក្យថា ភិក្ខុនោះ គប្បីនៅប្រាសចាកចីវរនោះយ៉ាងយូរត្រឹម ៦ រាត្រី គឺភិក្ខុគប្បីនៅប្រាសចាកត្រឹម ៦ រាត្រីជាយ៉ាងយូរ ។ ពាក្យថា វៀរលែងតែភិក្ខុដែលបានសេចក្តីសម្មតអំពីសង្ឃ គឺលើកទុកតែភិក្ខុដែលបានសេចក្តីសម្មតអំពីសង្ឃ ។ ពាក្យថា បើនៅប្រាសចាកឲ្យហួសពីកំណត់នោះទៅ មានអធិប្បាយថា កាលអរុណរះឡើងក្នុងថ្ងៃទី ៧ ចីវរនោះ ជានិស្សគ្គិយ ភិក្ខុម្ចាស់ចីវរត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុម្ចាស់ចីវរត្រូវលះបង់យ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន

២១៣

និស្សគ្គិយកណ្ឌេ បត្តវគ្គស្ស នវមសិក្ខាបទស្ស បទភាជនីយំ

អតិរេកចីវរត្តំ វិប្បវុត្ថំ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។

[១៦៧] អតិរេកចីវរត្តេ អតិរេកសញ្ញី វិប្បវសតិ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ អតិរេកចីវរត្តេ វេមតិកោ វិប្បវសតិ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ អតិរេកចីវរត្តេ ឩនកសញ្ញី វិប្បវសតិ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ អប្បច្ចុទ្ធដេ បច្ចុទ្ធដសញ្ញី... អវិស្សជ្ជិតេ វិស្សជ្ជិតសញ្ញី... អនដ្ឋេ នដ្ឋសញ្ញី... អវិនដ្ឋេ វិនដ្ឋសញ្ញី... អទឌ្ឍេ ទឌ្ឍសញ្ញី... អវិលុត្តេ វិលុត្តសញ្ញី វិប្បវសតិ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។ និស្សគ្គិយំ ចីវរំ

ចីវររបស់ខ្ញុំនេះដែលខ្ញុំនៅប្រាសហើយអស់កាលជាង ៦ រាត្រី ជានិស្សគ្គិយ ព្រោះមិនមានភិក្ខុសម្មតិ ខ្ញុំសូមលះបង់ចីវរនេះ ដល់សង្ឃ ។ បេ ។ ពាក្យត អំពីនេះទៅមានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គខាងដើមហើយ ។

[១៦៧] ចីវរកន្លងហួសជាង ៦ រាត្រី ភិក្ខុសំគាល់ថា ហួសជាង ហើយនៅប្រាសចាកចោល ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែ ភិក្ខុដែលបានសម្មតិអំពីសង្ឃ ។ ភិក្ខុមានសេចក្ដីសង្ស័យ ក្នុងចីវរដែល កន្លងហួស ៦ រាត្រី ហើយនៅប្រាសចាកចោល ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានសម្មតិអំពីសង្ឃ ។ ចីវរកន្លងហួស ៦ រាត្រី ភិក្ខុសំគាល់ថា នៅខ្វះ ហើយនៅប្រាសចាកចោល ត្រូវនិស្សគ្គិយ បាចិត្តិយ វៀរលែងតែភិក្ខុដែលបានសម្មតិអំពីសង្ឃ ។ ចីវរដែលភិក្ខុ មិនទាន់បានដកអធិដ្ឋាន ភិក្ខុសំគាល់ថា បានដកអធិដ្ឋានហើយ (ក្ដី) ចីវរដែលភិក្ខុមិនទាន់លះបង់ទេ ភិក្ខុសំគាល់ថា បានលះបង់ហើយ (ក្ដី) ចីវរ មិនបាត់ទេ ភិក្ខុសំគាល់ថា បាត់ទៅហើយ (ក្ដី) ចីវរមិនវិនាសទេ សំគាល់ ថា វិនាសទៅហើយ (ក្ដី) ចីវរភ្លើងមិនឆេះទេ ភិក្ខុសំគាល់ថា ភ្លើងឆេះហើយ (ក្ដី) ចីវរដែលចោរមិនបានលួចយកទេ ភិក្ខុសំគាល់ថា ចោរលួចយកទៅ ហើយ (ក្ដី) បើនៅប្រាសចាក ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែ ភិក្ខុដែលបានសម្មតិអំពីសង្ឃ ។ ភិក្ខុមិនលះបង់ចីវរ ដែលជានិស្សគ្គិយ

អនិស្សជ្ជិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។ ឩនកចាតុរេ្ត អតិរេកសញ្ញី អាបត្តិ ទុក្កដស្ស ។ ឩនកចាតុរេ្ត វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឩនកចាតុរេ្ត ឩនកសញ្ញី អនាបត្តិ ។

[១៦៨] អនាបត្តិ ចាតុរត្តំ វិប្បវសតិ ឩនកចាតុរត្តំ វិប្បវសតិ ចាតុរត្តំ វិប្បវសិត្វា បុន គាមសីមំ ឱក្កមិត្វា វសិត្វា បក្កមតិ អន្តោចាតុរត្តំ បច្ចុទ្ធរតិ វិស្សជ្ជេតិ នស្សតិ វិនស្សតិ ឌយ្ហតិ អច្ឆិន្ទិត្វា គណ្ហាតិ[១] វិស្សាសំ គណ្ហាតិ[២] ភិក្ខុសម្មតិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។

---

១-២ ឱ. ម. គណ្ហន្តិ ។

ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់ដល់ ៦ រាត្រី តែភិក្ខុសំគាល់ថា លើសហើយ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់ដល់ ៦ រាត្រី តែភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទាន់ដល់ ៦ រាត្រី ភិក្ខុសំគាល់ថា មិនទាន់ដល់ ៦ រាត្រី មិនត្រូវអាបត្តិ ។

[១៦៨] អាបត្តិមិនមាន ដល់ភិក្ខុដែលនៅប្រាសចាកចីវរត្រឹម ៦ រាត្រី ដល់ភិក្ខុដែលនៅប្រាសចាកខ្វះពី ៦ រាត្រីចុះមក ដល់ភិក្ខុដែលនៅប្រាសចាក ៦ រាត្រី ហើយត្រឡប់មកកាន់ដែន នៃស្រុកនោះវិញឈប់នៅកន្លែងណាមួយ ហើយចៀសចេញទៅ ដល់ភិក្ខុដកអធិដ្ឋាន (ក្តី) លះបង់ (ក្តី) ក្នុង ៦ រាត្រីចុះមក ចីវរបាត់ទៅ (ក្តី) វិនាសទៅ (ក្តី) ភ្លើងឆេះ (ក្តី) ចោរដណ្តើមយកទៅ (ក្តី) សហធម្មិកកាន់យកទៅដោយស្និទ្ធស្នាល (ក្តី) ក្នុង ៦ រាត្រីចុះមក ដល់ភិក្ខុដែលបានសម្មតិ (អំពីសង្ឃ) ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់ ។

# ទសមសិក្ខាបទំ

[១៦៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សាវត្ថិយំ អញ្ញតរស្ស បូគស្ស សង្ឃស្ស សចីវរភត្តំ បដិយត្តំ ហោតិ ភោជេត្វា ចីវរេន អច្ឆាទេស្សាមាតិ ។ អថខោ ឆព្វគ្គិយា ភិក្ខូ យេន សោ បូគោ តេនុបសង្កមឹសុ ឧបសង្កមិត្វា តំ បូគំ ឯតទវោចុំ ទេថាវុសោ អម្ហាកំ ឥមានិ ចីវរានីតិ ។ ន មយំ ភន្តេ ទស្សាម អម្ហាកំ សង្ឃស្ស អនុវស្សំ សចីវរភិក្ខា បញ្ញត្តាតិ ។ ពហូ អាវុសោ សង្ឃស្ស ទាយកា ពហូ សង្ឃស្ស ភត្តា មយំ តុម្ហេ និស្សាយ តុម្ហេ សម្បស្សន្តា ឥធ វិហរាម តុម្ហេ ចេ អម្ហាកំ ន ទស្សថ អថ កោ ចរហិ អម្ហាកំ ទស្សតិ ទេថាវុសោ អម្ហាកំ ឥមានិ ចីវរានីតិ ។ អថខោ សោ បូគោ ឆព្វគ្គិយេហិ ភិក្ខូហិ និប្បីឡិយមានោ

# សិក្ខាបទទី ១០

[១៦៩] សម័យនោះ ព្រះពុទ្ធដ៏មានយសជាម្ចាស់ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានប្រជុំជនមួយពួក ក្នុងក្រុងសាវត្ថីតាក់តែងកត្តព្រមទាំងចីវរប្រ-គេនដល់សង្ឃដោយសេចក្តីព្រមព្រៀងគ្នាថា ពួកយើងនឹងនិមន្តឲ្យសង្ឃឆាន់ហើយប្រគេនចីវរឲ្យគ្រង់ ។ លំដាប់នោះ ពួកភិក្ខុឆព្វគ្គិយ ចូលទៅរកប្រជុំជនពួកនោះ លុះចូលទៅដល់ហើយបាននិយាយពាក្យនេះនឹងប្រជុំជនពួកនោះថា នែអ្នកមានអាយុទាំងឡាយ ពួកអ្នកឯង ចូរប្រគេនចីវរទាំងនេះមកពួកអាត្មាចុះ ។ ជនពួកនោះ និយាយថា លោកម្ចាស់ ពួកខ្ញុំករុណាមិនបានប្រគេនទេ ឯចង្ហាន់ព្រមទាំងចីវរពួកខ្ញុំករុណា ធ្លាប់ចាត់ចែងទុកប្រគេនដល់សង្ឃតែរាល់ឆ្នាំ ។ ពួកឆព្វគ្គិយភិក្ខុឆ្លើយថា នែអាវុសោ ពួកទាយករបស់សង្ឃក៏មានច្រើន ចង្ហាន់របស់សង្ឃក៏មានច្រើន ពួកយើងអា-ស្រ័យពឹងពាក់នឹងអ្នកទាំងឡាយ ទើបនៅក្នុងទីនេះបាន បើអ្នកទាំងឡាយមិនឲ្យមកពួកអាត្មា អ្នកណាហ្ន៎ គេនឹងឲ្យដល់ពួកអាត្មា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ពួកអ្នកចូរឲ្យចីវរទាំងនេះមកពួកអាត្មាចុះ ។ លំដាប់នោះ ប្រជុំជនពួកនោះ កាលបើពួកឆព្វគ្គិយភិក្ខុនិយាយគ្ទឹះគ្នៀលណាស់ទៅ

យថាបដិយត្តំ ចីវរំ ឆព្វគ្គិយានំ ភិក្ខូនំ ទត្វា សង្ឃំ ភត្តេន បរិវិសិ ។ យេ តេ ភិក្ខូ ជានន្តិ សង្ឃស្ស សចីវរ-ភត្តំ បដិយត្តំ ន ច ជានន្តិ ឆព្វគ្គិយានំ ភិក្ខូនំ ទិន្នន្តិ តេ ឯវមាហំសុ ឱណោជេថ អាវុសោ សង្ឃស្ស ចីវរន្តិ ។ នត្ថិ ភន្តេ យថាបដិយត្តំ ចីវរំ អយ្យា ឆព្វគ្គិយា អត្តនោ បរិណាមេសុន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ជានំ សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិណាមេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ជានំ សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិ-ណាមេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ជានំ សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិណាមេស្សថ

ទើបប្រគេនចីវរដែលខ្លួនតាក់តែងទាំងប៉ុន្មានទៅពួកឆព្វគ្គិយភិក្ខុ ហើយអង្គាសសង្ឃដោយចង្ហាន់ (តែម្យ៉ាង) ។ ពួកភិក្ខុណាដឹងថាចង្ហាន់ព្រមទាំងចីវរដែលគេតាក់តែងទុក សម្រាប់ប្រគេនសង្ឃ តែមិនដឹងថា ចីវរគេប្រគេនដល់ពួកភិក្ខុឆព្វគ្គិយទៅហើយ ភិក្ខុទាំងនោះ ទើបពោលយ៉ាងនេះថា នៃអ្នកដ៏មានអាយុទាំងឡាយ ពួកអ្នកចូរវេរប្រគេនចីវរដល់សង្ឃទៅ ។ ឯប្រជុំជនពួកនោះ ឆ្លើយថា បពិត្រលោកម្ចាស់ទាំងឡាយ ចីវរដែលតាក់តែងទុកប្រគេនសង្ឃគ្មានទេ (ព្រោះ) ពួកភិក្ខុឆព្វគ្គិយបង្អោនទៅ ដើម្បីខ្លួនលោកអស់ហើយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយដឹងថា លាភគេបង្អោនទៅដើម្បីសង្ឃហើយ ហេតុអ្វីបានជាត្រឡប់បង្អោនមកដើម្បីខ្លួនវិញ ។ លំដាប់នោះ ពួកភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងដឹងថា លាភគេបង្អោនទៅ ដើម្បីសង្ឃហើយ ត្រឡប់បង្អោនមកដើម្បីខ្លួនវិញ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការណ៍នោះ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគជាម្ចាស់ទ្រង់បន្ទោសថា នៃពួកមោឃបុរស ពួកអ្នកឯងដឹងថា លាភគេបង្អោនទៅដើម្បីរបស់សង្ឃហើយ ចុះហេតុអ្វីបានជាបង្អោនមក ដើម្បីខ្លួនវិញ

ទេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជានំ សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិណាមេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

[១៧០] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ វា តស្ស អារោចេន្តិ សោ វា អារោចេតិ ។ សង្ឃិកំ នាម សង្ឃស្ស ទិន្នំ ហោតិ បរិច្ចត្តំ ។ លាភោ នាម ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា អន្តមសោ ចុណ្ណបិណ្ឌោបិ ទន្តកដ្ឋំបិ ទសិកសុត្តំបិ ។ បរិណតំ នាម ទស្សាម ករិស្សាមាតិ វាចា ភិន្នា ហោតិ ។ អត្តនោ បរិណាមេតិ បយោគេ ទុក្កដំ ។ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា

នៃពួកមោឃបុរស ដំណើរនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទយ៉ាងនេះថា ភិក្ខុណាមួយកាលដឹង ហើយបង្អោនទូវលាភរបស់សង្ឃ ដែលគេនឹងបង្អោនទៅ (ដើម្បីសង្ឃ) មកដើម្បីខ្លួនវិញ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[១៧០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយ ក្នុងសិក្ខាបទបឋមបារាជិករួចហើយ ។ ដែលហៅថា ដឹង (ក្នុងសិក្ខាបទនេះ) គឺដឹងខ្លួនឯងក្តី អ្នកដទៃមកប្រាប់ភិក្ខុនោះក្តី អ្នកម្ចាស់ទាននោះមកប្រាប់ (ដល់ភិក្ខុនោះ) ក្តី ។ ដែលហៅថា របស់សង្ឃនោះ គឺទាយកបានវេរប្រគេនបរិច្ចាគដល់សង្ឃហើយ ។ ដែលហៅថា លាភនោះ បានដល់ចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់មនុស្សជំងឺ ដោយហោចទៅ ដុំនៃលំអិតក្តី ឈើស្ទន់ក្តី អំបោះរងដើងក្តី ក៏ហៅថា លាភដែរ ។ ដែលហៅថា បង្អោននោះ គឺម្ចាស់ទានបញ្ចេញវាចាថា ពួកយើងនឹងឲ្យ ពួកយើងនឹងធ្វើ ។ ភិក្ខុបង្អោន (លាភ) មកដើម្បីខ្លួន ត្រូវអាបត្តិទុក្កដ តាមប្រយោគ ។ លាភនោះ ជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន

បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ ភន្តេ ជានំ សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិណាមិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អាយស្មតោ ទម្មីតិ ។ បរិណតេ បរិណតសញ្ញី អត្តនោ បរិណាមេតិ និស្សគ្គិយំ បាចិត្តិយំ ។ បរិណតេ វេមតិកោ អត្តនោ បរិណាមេតិ អាបត្តិ ទុក្កដស្ស ។ បរិណតេ អបរិណតសញ្ញី អត្តនោ បរិណាមេតិ អនាបត្តិ ។ សង្ឃស្ស បរិណតំ អញ្ញសង្ឃស្ស វា ចេតិយស្ស វា បរិណាមេតិ អាបត្តិ ទុក្កដស្ស ។ ចេតិយស្ស បរិណតំ អញ្ញចេតិយស្ស វា សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា បរិណាមេតិ អាបត្តិ ទុក្កដស្ស ។ បុគ្គលស្ស បរិណតំ អញ្ញបុគ្គលស្ស វា សង្ឃស្ស វា គណស្ស វា ចេតិយស្ស វា បរិណាមេតិ

បុគ្គលក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់យ៉ាងនេះ ។ បេ ។ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំដឹងថា លាភនេះទាយកបង្អោនទៅ ដើម្បីរបស់សង្ឃហើយ ខ្ញុំត្រឡប់បង្អោនមកដើម្បីខ្លួនវិញ (លាភនេះ) ជានិស្សគ្គិយ ខ្ញុំសូមលះបង់លាភនេះ ដល់សង្ឃ ។ បេ ។ ពាក្យតអំពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គខាងដើមហើយ ។ ភិក្ខុសំគាល់ក្នុងលាភដែលទាយកបានបង្អោនហើយថា ទាយកបានបង្អោនមកមែន ហើយបង្អោនមកដើម្បីខ្លួនវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងលាភដែលទាយកបានបង្អោនទៅហើយ ត្រឡប់បង្អោនមកដើម្បីខ្លួនវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ក្នុងលាភដែលទាយកបានបង្អោនទៅហើយ ថាមិនទាន់បង្អោនទៅទេ ត្រឡប់បង្អោនមកដើម្បីខ្លួន មិនត្រូវអាបត្តិ ។ លាភដែលទាយកបង្អោនទៅដើម្បីសង្ឃហើយ ភិក្ខុបង្អោនទៅដើម្បីសង្ឃដទៃក្តី ដើម្បីចេតិយក្តី ត្រូវអាបត្តិទុក្កដ ។ លាភដែលទាយកបង្អោនទៅ ដើម្បីចេតិយហើយ ភិក្ខុត្រឡប់បង្អោនទៅដើម្បីចេតិយដទៃក្តី សង្ឃក្តី គណៈក្តី បុគ្គលក្តី ត្រូវអាបត្តិទុក្កដ ។ លាភដែលទាយកបង្អោនទៅ ដើម្បីបុគ្គល ភិក្ខុត្រឡប់បង្អោនទៅដើម្បីបុគ្គលឯទៀត សង្ឃក្តី គណៈក្តី ចេតិយក្តី

អាបត្តិ ទុក្កដស្ស ។ អបរិណតេ បរិណតសញ្ញី អាបត្តិ ទុក្កដស្ស ។ អបរិណតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អបរិណតេ អបរិណតសញ្ញី អនាបត្តិ ។

[១៧១] អនាបត្តិ កត្ថ ទេមាតិ បុច្ឆិយមានោ យត្ថ តុម្ហាកំ ទេយ្យធម្មោ បរិភោគំ វា លភេយ្យ បដិសង្ខារំ វា លភេយ្យ ចិរដ្ឋិតិកោ វា អស្ស យត្ថ វា បន តុម្ហាកំ ចិត្តំ បសីទតិ តត្ថ ទេថាតិ ភណតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

បត្តវគ្គោ តតិយោ ។

ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ក្នុងលាភដែលទាយកមិនបានបង្អោនទៅ ថា បានបង្អោនទៅហើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងលាភដែលទាយកមិនបានបង្អោនទៅ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ក្នុងលាភដែលគេមិនបានបង្អោនទៅថា គេមិនបានបង្អោនទៅ មិនត្រូវអាបត្តិឡើយ ។

[១៧១] អាបត្តិមិនមានដល់ភិក្ខុដែលទាយកគេសួរថា យើងទាំងឡាយនឹងវេរប្រគេនក្នុងទីណា ហើយប្រាប់គេថា ទេយ្យធម៌របស់អ្នកទាំងឡាយគួរបាននូវការបរិភោគក្តី គួរបាននូវការជួសជុលក្តី គួរតាំងនៅអស់កាលដ៏យូរក្តីក្នុងទីណា ម្យ៉ាងទៀត បើចិត្តរបស់អ្នកទាំងឡាយជ្រះថ្លាក្នុងទីណា អ្នកទាំងឡាយ ចូរវេរប្រគេនក្នុងទីនោះ ។ ចុះ ដល់ភិក្ខុខ្ចួចចរិត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់ ។

បត្តវគ្គទី ៣ ចប់ ។

## តស្សុទ្ទានំ

ទ្វេ ច បត្តានិ ភេសជ្ជំ វស្សិកា ធានបញ្ចមំ
សាមំ វាយាបនាច្វេកោ សាសង្កំ សង្ឃិកេន ចាតិ ។

[១៧២] ឧទ្ទិដ្ឋា ខោ អាយស្មន្តោ តឹស និស្សគ្គិយា ចាចិត្តិយា ធម្មា ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា បរិសុទ្ធេត្ថាយស្មន្តោ តស្មា តុណ្ហី ឯវមេតំ ធារយាមីតិ ។

និស្សគ្គិយកណ្ឌំ និដ្ឋិតំ ។

ចំនួនសិក្ខាបទក្នុងបត្តវគ្គនោះ គឺ

សិក្ខាបទទី ១ (ទី) ២ និយាយអំពីបាត្រ សិក្ខាបទទី ៣ និយាយអំពីថ្នាំ សិក្ខាបទទី ៤ និយាយអំពីសំពត់ងូតទឹកភ្លៀង សិក្ខា-បទទី ៥ និយាយអំពីការឲ្យចីវរ សិក្ខាបទទី ៦ និយាយអំពីការសូមអំបោះគេមកខ្លួនឯង សិក្ខាបទី ៧ និយាយអំពីការប្រើឲ្យគេត្បាញ សិក្ខាបទទី ៨ និយាយអំពីអច្ចេក-ចីវរ សិក្ខាបទទី ៩ និយាយអំពីទីមានសេចក្ដីរង្កៀស សិក្ខាបទទី ១០ និយាយអំពីការបង្អោនលាភរបស់សង្ឃ ។

[១៧២] បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិនិស្សគ្គិយបាចិត្តិយទាំង ៣០ ខ្ញុំសំដែងឡើយហើយ ។ ខ្ញុំសូមសួរលោកដ៏មានអាយុទាំងឡាយក្នុងអាបត្តិទាំងនោះ លោកទាំងឡាយ បរិសុទ្ធហើយឬ ខ្ញុំសួរជាគម្រប់ពីរដងផង លោកទាំងឡាយ បរិសុទ្ធហើយឬ ខ្ញុំសួរជាគម្រប់បីដងផង លោកទាំងឡាយ បរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធក្នុងអាបត្តិទាំងនេះហើយ ហេតុនោះបានជាស្ងៀមនៅ ខ្ញុំចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។

និស្សគ្គិយកណ្ឌ ចប់ ។

# បាចិត្តិយកណ្ឌំ

ឥមេ ខោ បនាយស្មន្តោ ទ្វេ នវុតិ ចាចិត្តិយា

ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

## មុសាវាទវគ្គស្ស បឋមសិក្ខាបទំ

[១៧៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ហត្ថកោ សក្យបុត្តោ វាទក្ខិត្តោ ហោតិ ។ សោ តិត្ថិយេហិ សទ្ធឹ សល្លបន្តោ អវជានិត្វា បដិជានាតិ បដិជានិត្វា អវជានាតិ អញ្ញេនញ្ញំ បដិចរតិ សម្បជានមុសា ភាសតិ សង្កេតំ កត្វា វិសំវាទេតិ ។ តិត្ថិយា ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម ហត្ថកោ សក្យបុត្តោ អម្ហេហិ សទ្ធឹ សល្លបន្តោ អវជានិត្វា បដិជានិស្សតិ បដិជានិត្វា អវជានិស្សតិ

# បាចិត្តិយកណ្ឌ

*បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិបាចិត្តិយ ៩២ ទាំងនេះឯង តែងមកកាន់ឧទ្ទេស ។*

## មុសាវាទវគ្គ បឋមសិក្ខាបទ

[១៧៣] *សម័យនោះ ព្រះសព្វញ្ញុពុទ្ធ ជាម្ចាស់ដ៏មានព្រះភាគ ព្រះអង្គគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ហត្ថកភិក្ខុ ជាសក្យបុត្រ ជាអ្នកហុចពាក្យសំដី ។ ហត្ថកភិក្ខុនោះចរចាជាមួយនឹងតិរ្ថិយទាំងឡាយ គេចកែសំដី*[១] *ហើយទទួលដឹង*[២] *ទទួលដឹងហើយត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ហើយ ពោលឲ្យខុសពីកំណត់នោះវិញ ។ តិរ្ថិយទាំងឡាយពោលទោស តិះដៀលបន្តុះបង្អាប់ថា ចុះហេតុអ្វីបានជាហត្ថកភិក្ខុ ជាសក្យបុត្រពោលចរចាជាមួយនឹងយើងទាំងឡាយ គេចកែសំដីហើយទទួលដឹង ទទួលដឹងហើយ*

---

១ គឺពាក្យណាដែលខ្លួននិយាយទៅហើយមានទោស ជាពាក្យខុសមិនល្អ ក៏បដិសេធពាក្យនោះថា មិនមែនជាពាក្យរបស់ខ្លួន ហៅថា គេចកែសំដី ។ ២ គឺពាក្យណាដែលខ្លួននិយាយទៅហើយជាពាក្យល្អត្រឹមត្រូវ ក៏ប្តេជ្ញាថា ជាពាក្យរបស់ខ្លួន នេះហៅថា ទទួលដឹង ។ អដ្ឋកថា ។

អញ្ញេនញ្ញំ បដិចរិស្សតិ សម្បជានមុសា ភាសិស្សតិ សង្កេតំ កត្វា វិសំវាទេស្សតីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ តិត្ថិយានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ យេន ហត្ថកោ សក្យបុត្តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា ហត្ថកំ សក្យបុត្តំ ឯតទវោចុំ សច្ចំ កិរ ត្វំ អាវុសោ ហត្ថក តិត្ថិយេហិ សទ្ធឹ សល្លបន្តោ អវជានិត្វា បដិជានាសិ បដិជា-និត្វា អវជានាសិ អញ្ញេនញ្ញំ បដិចរសិ សម្បជានមុសា ភាសសិ សង្កេតំ កត្វា វិសំវាទេសីតិ ។ ឯតេ ខោ អាវុសោ តិត្ថិយា នាម យេន កេនចិ ជេតព្វា ន តេសំ ជយោ ទាតព្វោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ហត្ថកោ សក្យបុត្តោ តិត្ថិយេហិ សទ្ធឹ សល្លបន្តោ អវជានិត្វា បដិជានិស្សតិ បដិជានិត្វា អវជានិស្សតិ

ត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ ហើយពោលឲ្យខុសពីកំណត់នោះវិញ ។ ភិក្ខុទាំងឡាយបានឮតិរ្ថិយទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ទើបភិក្ខុទាំងនោះ ចូលទៅរកហត្ថកភិក្ខុជាសក្យបុត្រលុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងហត្ថកភិក្ខុ ជាសក្យ-បុត្រថា ម្នាលអាវុសោហត្ថក បានឮថា អ្នកពោលចរចាមួយអន្ទើដោយតិរ្ថិយទាំងឡាយ គេចកែសំដីហើយទទួលដឹង ទទួលដឹងហើយត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ ហើយពោលឲ្យខុសពីកំណត់នោះវិញ មែន ឬដូចម្តេច ។ ហត្ថកភិក្ខុឆ្លើយថា ម្នាលអាវុសោធម្មតាតិរ្ថិយទាំងឡាយនុ៎ះ ត្រូវតែបុគ្គលឯណានីមួយផ្ចាញ់ផ្ចាលចេញ មិនត្រូវឲ្យការឈ្នះទៅតិរ្ថិយទាំងឡាយនោះទេ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចុះហេតុអ្វី បានជាហត្ថកភិក្ខុជាសក្យបុត្រ ពោលចរចាមួយអន្ទើដោយតិរ្ថិយទាំងឡាយ គេចកែសំដីហើយទទួលដឹង ទទួលដឹងហើយត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ និយាយពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ហើយពោលឲ្យខុស

២២៣

បាចិត្តិយកណ្ឌោ មុសាវាទវគ្គស្ស បឋមសិក្ខាបទស្ស បញ្ញត្តិ

អញ្ញេនញ្ញំ បដិចរិស្សតិ សម្បជានមុសា ភាសិស្សតិ សង្កេតំ កត្វា វិសំវាទេស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ហត្ថកំ សក្យបុត្តំ បដិបុច្ឆិ សច្ចំ កិរ ត្វំ ហត្ថក តិត្ថិយេហិ សទ្ធឹ សល្លបន្តោ អវជានិត្វា បដិជានាសិ បដិជានិត្វា អវជានាសិ អញ្ញេនញ្ញំ បដិចរសិ សម្បជានមុសា ភាសសិ សង្កេតំ កត្វា វិសំវាទេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស តិត្ថិយេហិ សទ្ធឹ សល្លបន្តោ អវជានិត្វា បដិជានិស្សសិ បដិជានិត្វា អវជានិស្សសិ អញ្ញេនញ្ញំ បដិចរិស្សសិ សម្បជានមុសា ភាសិស្សសិ សង្កេតំ កត្វា វិសំ វាទេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ សម្បជានមុសាវាទេ បាចិត្តិយន្តិ ។

ពីកំណត់នោះវិញ ។ ទើបភិក្ខុទាំងឡាយនោះ យកសេចក្តីនុ៎ះក្រាបទូលចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះហត្ថកភិក្ខុជាសក្យបុត្រក្នុងពេលនោះថា ម្នាលហត្ថកភិក្ខុ បានឮថា អ្នកពោលចរចាមួយអន្ទើដោយតិរ្ថិយទាំងឡាយ គេចកែសំដីហើយទទួលដឹង ទទួលដឹងហើយត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ ហើយពោលឲ្យខុសពីកំណត់នោះវិញ តើពិតមែនឬ ។ ហត្ថកភិក្ខុឆ្លើយថា បពិត្រព្រះដ៏មានព្រះភាគ ការណ៍នោះពិតមែន ។ ព្រះសព្វញ្ញូពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា នៃបុរសទទេ ចុះហេតុអ្វី បានជាអ្នកឯងពោលចរចាមួយអន្ទើដោយតិរ្ថិយទាំងឡាយ គេចកែសំដីហើយទទួលដឹង ទទួលដឹងហើយត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្តីកំណត់ហើយពោលឲ្យខុសពីកំណត់នោះវិញ នៃមោឃបុរស ការណ៍នេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លា ឬថានឹងនាំជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួន ត្រូវអាបត្តិបាចិត្តិយ ។

[១៧៤] សម្បជានមុសាវាទោ នាម វិសំវាទន-បុរេក្ខារស្ស វាចា គីរា ព្យបថោ វចីភេទោ វាចសិកា វិញ្ញត្តិ អដ្ឋ អនរិយវោហារា អទិដ្ឋំ ទិដ្ឋំ មេតិ អសុតំ សុតំ មេតិ អមុតំ មុតំ មេតិ អវិញ្ញាតំ វិញ្ញាតំ មេតិ ទិដ្ឋំ អទិដ្ឋំ មេតិ សុតំ អសុតំ មេតិ មុតំ អមុតំ មេតិ វិញ្ញាតំ អវិញ្ញាតំ មេតិ ។

[១៧៥] អទិដ្ឋំ នាម ន ចក្ខុនា ទិដ្ឋំ ។ អសុតំ នាម ន សោតេន សុតំ ។ អមុតំ នាម ន ឃានេន ឃាយិតំ ន ជិវ្ហាយ សាយិតំ ន កាយេន ផុដ្ឋំ ។ អវិញ្ញាតំ នាម ន មនសា វិញ្ញាតំ ។ ទិដ្ឋំ នាម ចក្ខុនា ទិដ្ឋំ ។ សុតំ នាម សោតេន សុតំ ។ មុតំ នាម ឃានេន ឃាយិតំ ជិវ្ហាយ សាយិតំ កាយេន ផុដ្ឋំ ។ វិញ្ញាតំ នាម មនសា វិញ្ញាតំ ។

[១៧៤] ដែលហៅថា ពោលពាក្យកុហក ដោយដឹងខ្លួននោះ បានដល់វាចា សំដីគន្លងពាក្យវចីភេទ វិញ្ញត្តិប្រព្រឹត្តទៅ ក្នុងវាចារបស់បុគ្គលដែលធ្វើគំនិត នឹងពោលឲ្យខុសជាប្រធាន និងវោហារមិនមែនរបស់ព្រះអរិយ ៨ យ៉ាង គឺ ការដែលមិនឃើញនិយាយថា អញឃើញ ១ មិនឮនិយាយថាអញឮ ១ មិនបានពាល់ត្រូវនិយាយថា អញបានពាល់ត្រូវ ១ មិនដឹងច្បាស់និយាយថា អញដឹងច្បាស់ ១ ឃើញនិយាយថា អញមិនឃើញ ១ ឮនិយាយថា អញមិនឮ ១ បានពាល់ត្រូវនិយាយថា អញមិនបានពាល់ត្រូវ ១ ដឹងច្បាស់និយាយថា អញមិនដឹងច្បាស់ ១ ។

[១៧៥] ដែលហៅថា មិនឃើញ គឺមិនឃើញដោយភ្នែក ។ ដែលហៅថា មិនឮ គឺមិនឮដោយត្រចៀក ។ ដែលហៅថា មិនពាល់ត្រូវ គឺមិនហិតដោយច្រមុះ មិនលិទ្ធដោយអណ្តាត មិនប៉ះពាល់ដោយកាយ ។ ដែលហៅថា មិនដឹងច្បាស់ គឺមិនដឹងច្បាស់ដោយចិត្ត ។ ដែលហៅថា ឃើញ គឺឃើញដោយភ្នែក ។ ដែលហៅថា ឮ គឺឮដោយត្រចៀក ។ ដែលហៅថា ពាល់ត្រូវ គឺហិតដោយច្រមុះ លិទ្ធដោយអណ្តាត ប៉ះពាល់ដោយកាយ ។ ដែលហៅថា ដឹងច្បាស់ គឺដឹងច្បាស់ដោយចិត្ត ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស បឋមសិក្ខាបទស្ស បទភាជនីយំ

[១៧៦] តីហាការេហិ អទិដ្ឋំ ទិដ្ឋំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ បាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ ។ ចតូហាការេហិ អទិដ្ឋំ ទិដ្ឋំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ បាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ វិនិធាយ ទិដ្ឋឹ ។ បញ្ចហាការេហិ អទិដ្ឋំ ទិដ្ឋំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ បាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ វិនិធាយ ទិដ្ឋឹ វិនិធាយ ខន្តឹ ។ ឆហាការេហិ អទិដ្ឋំ ទិដ្ឋំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ បាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា

បាចិត្តិយកណ្ឌ មុសាវាទវគ្គ សិក្ខាបទទី ១ បទភាជនីយ

[១៧៦] ភិក្ខុនិយាយកុហក ដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញដូច្នេះ ដោយអាការ ៣ យ៉ាង គឺ មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញ ដោយអាការ ៤ យ៉ាង គឺ មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ[១] ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញ ដោយអាការ ៥ យ៉ាង គឺ មុននឹងពោលដឹងថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញ ដោយអាការ ៦ យ៉ាង គឺ មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១

១ គឺលាក់បំបិទបំបាំងសេចក្តីឃើញខុសរបស់ខ្លួន ។

ភណិតន្តិ វិជិជាយ ជិជ្ជឹ វិជិជាយ ខជ្ជឹ វិជិជាយ រុចឹ ។ សត្តហាកោរេហិ អជិជ្ជំ ជិជ្ជំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ វិជិជាយ ជិជ្ជឹ វិជិជាយ ខជ្ជឹ វិជិជាយ រុចឹ វិជិជាយ ភាវំ ។ តីហាកោរេហិ អសុតំ សុតំ មេតិ ។ បេ ។ អមុតំ មុតំ មេតិ ។ បេ ។ អវិញ្ញាតំ វិញ្ញាតំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ ។ ចតូហា-កោរេហិ ។ បេ ។ បញ្ចហាកោរេហិ ។ បេ ។ ឆហាកា-រេហិ ។ បេ ។ សត្តហាកោរេហិ អវិញ្ញាតំ វិញ្ញាតំ មេតិ

បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីពេញចិត្ត ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញដោយអាការ ៧ យ៉ាង គឺ មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថាអញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះពាក្យដែលមិនឮថា អាត្មាឮ ។ បេ ។ វត្ថុដែលមិនបានពាល់ត្រូវថា អាត្មាបានពាល់ត្រូវ ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះហេតុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ ដោយអាការ ៣ យ៉ាង គឺ មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះហេតុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ ដោយអាការ ៤ យ៉ាង ។ បេ ។ អាការ ៥ យ៉ាង ។ បេ ។ អាការ ៦ យ៉ាង ។ បេ ។ អាការ ៧ យ៉ាង គឺ មុននឹងពោលគិតថា

សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ វិនិធាយ ទិដ្ឋឹ វិនិធាយ ខន្តឹ វិនិធាយ រុចឹ វិនិធាយ ភាវំ ។

[១៧៧] តីហាការេហិ អទិដ្ឋំ ទិដ្ឋំ មេ សុតន្តិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ បេ ។ តីហាការេហិ អទិដ្ឋំ ទិដ្ឋំ មេ មុតន្តិ ។ បេ ។ តីហាការេហិ អទិដ្ឋំ ទិដ្ឋំ មេ វិញ្ញាតន្តិ សម្បជា-នមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ បេ ។ តីហាការេហិ អទិដ្ឋំ ទិដ្ឋំ មេ សុតញ្ច មុតញ្ចាតិ ។ បេ ។ តីហាការេហិ អទិដ្ឋំ ទិដ្ឋំ មេ សុតញ្ច វិញ្ញាតញ្ចាតិ ។ បេ ។ តីហាការេហិ អទិដ្ឋំ ទិដ្ឋំ មេ សុតញ្ច មុតញ្ច វិញ្ញាតញ្ចាតិ សម្បជានមុសា ភណន្តស្ស

អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ ។

[១៧៧] ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញផង ថា អាត្មាឮផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញផង ថា អាត្មាពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញផង ថា អាត្មាដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញផង ឮផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញផង ឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង

អាបត្តិ ចាចិត្តិយស្ស ។ បេ ។ តីហាការេហិ អសុតំ សុតញ្ច មេ មុតញ្ចាតិ ។ បេ ។ តីហាការេហិ អសុតំ សុតញ្ច មេ វិញ្ញាតញ្ចាតិ ។ បេ ។ តីហាការេហិ អសុតំ សុតញ្ច មេ ឋិដ្ឋញ្ចាតិ ។ បេ ។ តីហាការេហិ អសុតំ សុតញ្ច មេ មុតញ្ច វិញ្ញាតញ្ចាតិ ។ បេ ។ តីហាការេហិ អសុតំ សុតញ្ច មេ មុតញ្ច ឋិដ្ឋញ្ចាតិ ។ បេ ។ តីហា-ការេហិ អសុតំ សុតញ្ច មេ មុតញ្ច វិញ្ញាតញ្ច ឋិដ្ឋញ្ចាតិ ។ បេ ។ តីហាការេហិ អមុតំ មុតញ្ច មេ វិញ្ញាតញ្ចាតិ ។ បេ ។ តីហាការេហិ អមុតំ មុតញ្ច មេ ឋិដ្ឋញ្ចាតិ ។ បេ ។ តីហាការេហិ អមុតំ មុតញ្ច មេ សុតញ្ចាតិ ។ បេ ។ តីហាការេហិ អមុតំ មុតញ្ច

ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮថា អាត្មាឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះពាក្យដែលខ្លួនមិនឮថា អាត្មាឮផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮថា អាត្មាឮផង ឃើញផងដោយអាការ ៣ យ៉ាង ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮថា អាត្មាឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮថា អាត្មាឮផង ពាល់ត្រូវផង ឃើញផង ដោយអាការ ៣ យ៉ាង ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮថា អាត្មាឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនបានពាល់ត្រូវថា អាត្មាបានពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវថា អាត្មាពាល់ត្រូវផង ឃើញផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវថា អាត្មាពាល់ត្រូវផង ឮផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវថា

មេ វិញ្ញាតញ្ច ធិដ្ឋញ្ចាតិ ។ បេ ។ តីហាកាវេហិ អមុតំ មុតញ្ច មេ វិញ្ញាតញ្ច សុតញ្ចាតិ ។ បេ ។ តីហាកាវេហិ អមុតំ មុតញ្ច មេ វិញ្ញាតញ្ច ធិដ្ឋញ្ច សុតញ្ចាតិ ។ បេ ។ តីហាកាវេហិ អវិញ្ញាតំ វិញ្ញាតញ្ច មេ ធិដ្ឋញ្ចាតិ ។ បេ ។ តីហាកាវេហិ អវិញ្ញាតំ វិញ្ញាតញ្ច មេ សុតញ្ចាតិ ។ បេ ។ តីហាកាវេហិ អវិញ្ញាតំ វិញ្ញាតញ្ច មេ មុតញ្ចាតិ ។ បេ ។ តីហាកាវេហិ អវិញ្ញាតំ វិញ្ញាតញ្ច មេ ធិដ្ឋញ្ច សុតញ្ចាតិ ។ បេ ។ តីហាកាវេហិ អវិញ្ញាតំ វិញ្ញាតញ្ច មេ ធិដ្ឋញ្ច មុតញ្ចាតិ ។ បេ ។ តីហាកាវេហិ អវិញ្ញាតំ វិញ្ញាតញ្ច មេ ធិដ្ឋញ្ច សុតញ្ច មុតញ្ចាតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ បេ ។

[១៧៨] តីហាកាវេហិ ធិដ្ឋំ អធិដ្ឋំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា

អាត្មាបានពាល់ត្រូវផង ដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវថា អាត្មាបានពាល់ត្រូវផង ដឹងច្បាស់ផង ឮផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវថា អាត្មាបានពាល់ត្រូវផង ដឹងច្បាស់ផង ឃើញផង ឮផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ឮផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ឃើញផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ។ បេ ។ ភិក្ខុនិយាយកុហក ដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។ បេ ។

[១៧៨] ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនបានឃើញថា អាត្មាមិនឃើញ ដោយអាការ ៣ យ៉ាង គឺ មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១

ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិ-
តន្តិ ។ ចតូហាការេហិ ។ បេ ។ បញ្ចហាការេហិ
។ បេ ។ ឆហាការេហិ ។ បេ ។ សត្តហាការេហិ ទិដ្ឋំ
អទិដ្ឋំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ថាចិ-
ត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស
ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា
មយា ភណិតន្តិ វិនិធាយ ទិដ្ឋំ វិនិធាយ ខន្តឹ វិនិធាយ
រុចឹ វិនិធាយ ភាវំ ។ តីហាការេហិ សុតំ អសុតំ
មេតិ ។ បេ ។ មុតំ អមុតំ មេតិ ។ បេ ។ វិញ្ញាតំ
អវិញ្ញាតំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ
ថាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ
ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស
ហោតិ មុសា មយា ភណិតន្តិ ។ ចតូហាការេហិ
។ បេ ។ បញ្ចហាការេហិ ។ បេ ។ ឆហាការេហិ ។ បេ ។

ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនបានឃើញថា អាត្មាមិនឃើញ ដោយអាការ ៤ យ៉ាង ។ បេ ។ អាការ ៥ យ៉ាង ។ បេ ។ អាការ ៦ យ៉ាង ។ បេ ។ អាការ ៧ យ៉ាងគឺ មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះពាក្យដែលខ្លួនបានឮថា អាត្មាមិនបានឮ ដោយអាការ ៣ យ៉ាង ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនបានពាល់ត្រូវថា អាត្មាមិនបានពាល់ត្រូវ ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះហេតុដែលខ្លួនបានដឹងច្បាស់ថា អាត្មាមិនបានដឹងច្បាស់ ដោយអាការ ៣ យ៉ាងគឺ មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះហេតុដែលខ្លួនដឹងច្បាស់ថា អាត្មាមិនដឹងច្បាស់ ដោយអាការ ៤ យ៉ាង ។ បេ ។ អាការ ៥ យ៉ាង ។ បេ ។ អាការ ៦ យ៉ាង ។ បេ ។

សត្តហាកាវេហិ វិញ្ញាតំ អវិញ្ញាតំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ វិនិធាយ ទិដ្ឋឹ វិនិធាយ ខន្តឹ វិនិធាយ រុចឹ វិនិធាយ ភាវំ ។

[១៧៩] តីហាកាវេហិ ទិដ្ឋំ សុតំ មេតិ ។ បេ ។ តីហាកាវេហិ ទិដ្ឋំ មុតំ មេតិ ។ បេ ។ តីហាកាវេហិ ទិដ្ឋំ វិញ្ញាតំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ បេ ។ តីហាកាវេហិ ទិដ្ឋំ សុតញ្ច មេ មុតញ្ចាតិ ។ បេ ។ តីហាកាវេហិ ទិដ្ឋំ សុតញ្ច មេ វិញ្ញាតញ្ចាតិ ។ បេ ។ តីហាកាវេហិ ទិដ្ឋំ សុតញ្ច មេ មុតញ្ច វិញ្ញាតញ្ចាតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ បេ ។ តីហាកាវេហិ សុតំ មុតំ មេតិ ។ បេ ។ សុតំ វិញ្ញាតំ មេតិ ។ បេ ។ សុតំ ទិដ្ឋំ មេតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិ-យស្ស ។ បេ ។ តីហាកាវេហិ សុតំ មុតញ្ច មេ

អាការ ៧ យ៉ាង មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ ។

[១៧៩] ភិក្ខុនិយាយកុហក ដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនឃើញថា អាត្មាឮវិញ ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនឃើញថា អាត្មាបានពាល់ត្រូវវិញ ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនឃើញថា អាត្មាដឹងច្បាស់វិញ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនឃើញថា អាត្មាឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនឃើញថា អាត្មាឮផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនឃើញថា អាត្មាឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនឮថា អាត្មាពាល់ត្រូវ ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនឮថា អាត្មាដឹងច្បាស់ ។ បេ ។ វត្ថុដែលខ្លួនឮថា អាត្មាឃើញ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនឮថា អាត្មាពាល់ត្រូវផង ដឹងច្បាស់ផង

វិញ្ញាតញ្ចាតិ ។ បេ ។ សុតំ មុតញ្ច មេ ជិជ្ឈញ្ចាតិ ។ បេ ។ សុតំ មុតញ្ច មេ វិញ្ញាតញ្ច ជិជ្ឈញ្ចាតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ បេ ។ តីហាការេហិ មុតំ វិញ្ញាតំ មេតិ ។ បេ ។ មុតំ ជិជ្ឈំ មេតិ ។ បេ ។ មុតំ សុតំ មេតិ ។ បេ ។ តីហាការេហិ មុតំ វិញ្ញាតញ្ច មេ ជិជ្ឈញ្ចាតិ ។ បេ ។ មុតំ វិញ្ញាតញ្ច មេ សុតញ្ចាតិ ។ បេ ។ មុតំ វិញ្ញាតញ្ច មេ ជិជ្ឈញ្ច សុតញ្ចាតិ ។ បេ ។ តីហា-ការេហិ វិញ្ញាតំ ជិជ្ឈំ មេតិ ។ បេ ។ វិញ្ញាតំ សុតំ មេតិ ។ បេ ។ វិញ្ញាតំ មុតំ មេតិ ។ បេ ។ តីហាការេហិ វិញ្ញាតំ ជិជ្ឈញ្ច មេ សុតញ្ចាតិ ។ បេ ។ វិញ្ញាតំ ជិជ្ឈញ្ច មេ មុតញ្ចាតិ ។ បេ ។ វិញ្ញាតំ ជិជ្ឈញ្ច មេ សុតញ្ច មុតញ្ចាតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ បេ ។

ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនពុថា អាត្មាពាល់ត្រូវផង ឃើញផង ។ បេ ។ វត្ថុដែលខ្លួនពុថា អាត្មាពាល់ត្រូវផង ដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ភិក្ខុនិយាយកុហក ដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនពាល់ត្រូវថា អាត្មាដឹងច្បាស់ ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនពាល់ត្រូវថា អាត្មាឃើញ ។ បេ ។ វត្ថុដែលខ្លួនពាល់ត្រូវថា អាត្មាពុ ។ បេ ។ វត្ថុដែលខ្លួនពាល់ត្រូវថា អាត្មាដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនពាល់ត្រូវថា អាត្មាដឹងច្បាស់ផង ពុផង ។ បេ ។ វត្ថុដែលខ្លួនពាល់ត្រូវថា អាត្មាដឹងច្បាស់ផង ឃើញផង ពុផង ។ បេ ។ វត្ថុដែលខ្លួនដឹងច្បាស់ថា អាត្មាឃើញដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនដឹងច្បាស់ថា អាត្មាពុ ។ បេ ។ វត្ថុដែលខ្លួនដឹងច្បាស់ថា អាត្មាពាល់ត្រូវវិញ ។ បេ ។ វត្ថុដែលខ្លួនដឹងច្បាស់ថា អាត្មាឃើញផង ពុផង ដោយអាការ ៣ យ៉ាង ។ បេ ។ វត្ថុដែលខ្លួនដឹងច្បាស់ថា អាត្មាឃើញផង ពាល់ត្រូវផង ។ បេ ។ វត្ថុដែលខ្លួនដឹងច្បាស់ថា អាត្មាឃើញផង ពុផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។ បេ ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស បឋមសិក្ខាបទស្ស បទភាជនីយំ

[១៨០] តីហាការេហិ ទិដ្ឋេ វេមតិកោ ទិដ្ឋំ នោកប្បេតិ ទិដ្ឋំ នស្សរតិ ទិដ្ឋំ បមុដ្ឋោ[១] ហោតិ ទិដ្ឋញ្ច មេ សុតញ្ចាតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ បេ ។ ទិដ្ឋញ្ច មេ សុតញ្ច មុតញ្ច វិញ្ញាតញ្ចាតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ បេ ។ សុតេ វេមតិកោ សុតំ នោកប្បេ-តិ សុតំ នស្សរតិ សុតំ បមុដ្ឋោ ហោតិ ។ បេ ។ មុតេ វេមតិកោ មុតំ នោកប្បេតិ មុតំ នស្សរតិ មុតំ បមុដ្ឋោ ហោតិ ។ បេ ។ តីហាការេហិ វិញ្ញាតេ វេមតិកោ វិញ្ញាតំ នោកប្បេតិ វិញ្ញាតំ នស្សរតិ វិញ្ញាតំ បមុដ្ឋោ ហោតិ វិញ្ញាតញ្ច មេ ទិដ្ឋញ្ចាតិ ។ បេ ។ វិញ្ញាតញ្ច មេ សុត-ញ្ចាតិ ។ បេ ។ វិញ្ញាតញ្ច មេ មុតញ្ចាតិ ។ បេ ។

---

១ ឱ. ម. សម្មុដ្ឋោ ។

[១៨០] ភិក្ខុមានសេចក្តីសង្ស័យក្នុងវត្ថុដែលខ្លួនឃើញ (ក្តី) មិនជឿវត្ថុដែលខ្លួនបានឃើញ (ក្តី) រលឹកមិនបាននូវវត្ថុដែលខ្លួនឃើញហើយ (ក្តី) ភ្លេចនូវវត្ថុដែលខ្លួនបានឃើញ (ក្តី) ហើយពោលពាក្យកុហក ដោយដឹងខ្លួនថាអាត្មាឃើញផង ឮផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ភិក្ខុពោលពាក្យកុហក ដោយដឹងខ្លួនថា អាត្មាឃើញផង ឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងពាក្យដែលខ្លួនបានឮ (ក្តី) មិនជឿពាក្យដែលខ្លួនបានឮ (ក្តី) រលឹកមិនបាននូវពាក្យដែលខ្លួនបានឮ (ក្តី) ភ្លេចពាក្យដែលខ្លួនឮហើយ (ក្តី) ។ បេ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងវត្ថុដែលខ្លួនបានពាល់ត្រូវ (ក្តី) មិនជឿវត្ថុដែលខ្លួនបានពាល់ត្រូវ (ក្តី) រលឹកមិនបាននូវវត្ថុដែលខ្លួនបានពាល់ត្រូវ (ក្តី) ភ្លេចវត្ថុដែលខ្លួនបានពាល់ត្រូវ (ក្តី) ។ បេ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងហេតុដែលខ្លួនដឹងច្បាស់ (ក្តី) មិនជឿហេតុដែលខ្លួនបានដឹងច្បាស់ (ក្តី) រលឹកមិនបាននូវហេតុដែលខ្លួនដឹងច្បាស់ (ក្តី) ភ្លេចហេតុដែលខ្លួនដឹងច្បាស់ (ក្តី) ហើយពោលពាក្យកុហក ដោយដឹងខ្លួនថា អាត្មាដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង ។ បេ ។ ថាអាត្មាដឹងច្បាស់ផង ឮផង ។ បេ ។ ថាអាត្មាដឹងច្បាស់ផង ពាល់ត្រូវផង

វិញ្ញាតញ្ច មេ ទិដ្ឋញ្ច សុតញ្ចាតិ ។ បេ ។ វិញ្ញាតញ្ច មេ ទិដ្ឋញ្ច មុតញ្ចាតិ ។ បេ ។ វិញ្ញាតញ្ច មេ ទិដ្ឋញ្ច សុតញ្ច មុតញ្ចាតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ ។ ចតូហាកាវេហិ ។ បេ ។ បញ្ចហាកាវេហិ ។ បេ ។ ឆហាកាវេហិ ។ បេ ។ សត្ត-ហាកាវេហិ វិញ្ញាតេ វេមតិកោ វិញ្ញាតេ ដោកប្បេតិ វិញ្ញាតំ នស្សរតិ វិញ្ញាតំ បមុដ្ឋោ ហោតិ វិញ្ញាតញ្ច មេ ទិដ្ឋញ្ច សុតញ្ច មុតញ្ចាតិ សម្បជានមុសា ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស បុព្វេវស្ស ហោតិ មុសា ភណិស្ស-ន្តិ ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស ហោតិ មុសា មយា ភណិតន្តិ វិនិធាយ ទិដ្ឋំ វិនិធាយ ខន្តឹ វិនិធាយ រុចឹ វិនិធាយ ភាវំ ។

។ បេ ។ ថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង ។ បេ ។ ថា អាត្មាដឹងច្បាស់ផង ឃើញផង ពាល់ត្រូវផង ។ បេ ។ ភិក្ខុពោលពាក្យកុហក ដោយដឹងខ្លួនថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង គឺ មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងហេតុដែលខ្លួនដឹងច្បាស់ (ក្តី) មិនជឿហេតុដែលខ្លួនដឹងច្បាស់ (ក្តី) រលឹកមិនបាននូវហេតុដែលខ្លួនដឹងច្បាស់ (ក្តី) ភ្លេចហេតុដែលខ្លួនដឹងច្បាស់ (ក្តី) ហើយពោលពាក្យកុហក ដោយដឹងខ្លួនថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ ៤ យ៉ាង ។ បេ ។ អាការ ៥ យ៉ាង ។ បេ ។ អាការ ៦ យ៉ាង ។ បេ ។ អាការ ៧ យ៉ាង គឺ មុននឹងពោលដឹងថា អញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក ១ ពោលរួចហើយដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស បឋមសិក្ខាបទស្ស អនាបត្តិវារោ

[១៨១] អនាបត្តិ ទវាយ ភណតិ រវាយ ភណតិ (ទវាយ ភណតិ នាម សហសា ភណតិ ។ រវាយ ភណតិ នាម អញ្ញំ ភណិស្សាមីតិ អញ្ញំ ភណតិ ។) ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។

[១៨១] អាបត្តិមិនមានដល់ភិក្ខុពោល ដោយញាប់ម៉ាត់ ដល់ភិក្ខុពោលដោយភ្ញាត់ម៉ាត់ (ភិក្ខុពោលដោយរហ័ស ឈ្មោះថា ពោលដោយញាប់ម៉ាត់ ។ ភិក្ខុគិតថា អញនឹងពោលពាក្យដទៃ ហើយត្រឡប់ពោលពាក្យដទៃក្រៅ អំពីគំនិតនោះវិញ ឈ្មោះថា ពោលដោយភ្ញាត់ម៉ាត់) ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

បឋមសិក្ខាបទ ចប់ ។

# ទុតិយសិក្ខាបទំ

[១៨២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្សារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បេសលេហិ ភិក្ខូហិ សទ្ធឹ ភណ្ឌន្តា[១] បេសលេ ភិក្ខូ ឱមសន្តិ ជាតិយាបិ នាមេនបិ គោត្តេនបិ កម្មេនបិ សិប្បេនបិ អាពាធេនបិ លិង្គេនបិ កិលេសេនបិ អាបត្តិយាបិ ហីនេនបិ អក្កោសេន ខុំសេន្តិ[២] វម្ភេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ បេសលេហិ ភិក្ខូហិ សទ្ធឹ ភណ្ឌន្តា បេសលេ ភិក្ខូ ឱមសិស្សន្តិ ជាតិយាបិ នាមេនបិ គោត្តេនបិ កម្មេនបិ សិប្បេនបិ អាពាធេនបិ លិង្គេនបិ កិលេសេនបិ អាបត្តិយាបិ ហីនេនបិ អក្កោសេន ខុំសេស្សន្តិ[៣] វម្ភេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

---

១ ឱ. ម. ភណ្ឌេន្តា ។ ២-៣ ខុង្សេន្តិបិ ។

# សិក្ខាបទទី ២

[១៨២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ ឈ្លោះនឹងពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ពោលចាក់ដោតភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ គឺជេរប្រទេចដោយជាតិខ្លះ ឈ្មោះខ្លះ គោត្តខ្លះ ការងារខ្លះ សិល្បសាស្ត្រខ្លះ អាពាធខ្លះ ភេទខ្លះ កិលេសខ្លះ អាបត្តិខ្លះ ពាក្យជេរដ៏ថោកទាបខ្លះ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏បានជាឆព្វគ្គិយ-ភិក្ខុទាំងឡាយ ឈ្លោះនឹងភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ពោលចាក់ដោតភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ គឺជេរប្រទេចដោយជាតិខ្លះ ឈ្មោះខ្លះ គោត្តខ្លះ ការងារខ្លះ សិល្បសាស្ត្រខ្លះ អាពាធខ្លះ ភេទខ្លះ កិលេសខ្លះ អាបត្តិខ្លះ ពាក្យជេរដ៏ថោកទាបខ្លះ ។ ភិក្ខុទាំងនោះយកសេចក្តីនុ៎ះក្រាបទូលដល់ព្រះដ៏មានព្រះភាគ ។

២៣៧



សច្ចំ កិរ តុម្ហេ ភិក្ខវេ បេសលេហិ ភិក្ខូហិ សទ្ធឹ ភណ្ឌន្តា បេសលេ ភិក្ខូ ឱមសថ ជាតិយាបិ នាមេនបិ គោត្តេនបិ កម្មេនបិ សិប្បេនបិ អាពាធេនបិ លិង្គេនបិ កិលេសេនបិ អាបត្តិយាបិ ហីនេនបិ អក្កោសេន ខុំសេថ(១) វម្ភេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា បេសលេហិ ភិក្ខូហិ សទ្ធឹ ភណ្ឌន្តា បេសលេ ភិក្ខូ ឱមសិស្សថ ជាតិយាបិ ។ បេ ។ ហីនេនបិ អក្កោ-សេន ខុំសេស្សថ(២) វម្ភេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោ-ភាវាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ។

[១៨៣] ភូតបុព្វំ ភិក្ខវេ តក្កសិលាយំ អញ្ញត-រស្ស ព្រាហ្មណស្ស នន្ទិវិសាលោ នាម ពលិពទ្ទោ

១-២ ខុង្សេថាតិបិ ។

ព្រះបរមគ្រូត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយ ឈ្មោះនឹងភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ពោលចាក់ដោត ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ គឺជេរប្រទេចដោយជាតិខ្លះ ឈ្មោះខ្លះ គោត្តខ្លះ ការងារខ្លះ សិល្បសាស្ត្រខ្លះ អាពាធខ្លះ ភេទខ្លះ កិលេសខ្លះ អាបត្តិខ្លះ ពាក្យជេរដ៏ថោកទាបខ្លះ ពិតមែនឬ ។ ឆព្វគ្គិយភិក្ខុទាំងនោះ ក៏ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការណ៍នោះ ពិតមែន ។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែ បុរសសាបសូន្យចាកមគ្គផលទាំងឡាយ ចុះហេតុអ្វី បានជាអ្នកទាំងឡាយ ឈ្មោះនឹងភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ពោលចាក់ដោត ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ គឺជេរប្រទេចដោយជាតិខ្លះ ។ បេ ។ ដោយពាក្យជេរដ៏ថោកទាបខ្លះ នែពួកមោឃបុរស ការណ៍នេះមិន មែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ និងមិនមែននាំ ជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ ។ បេ ។ លុះ ព្រះអង្គទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយ មកថា ។

[១៨៣] ម្នាលភិក្ខុទាំងឡាយ កាលពីដើម មានព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងតក្កសិលា (ព្រាហ្មណ៍នោះ) មានគោ ១ ឈ្មោះនន្ទិវិសាល ។

អហោសិ ។ អថខោ ភិក្ខវេ នន្ទិវិសាលោ ពលិពទ្ទោ តំ ព្រាហ្មណំ ឯតទវោច កច្ច ត្វំ ព្រាហ្មណ សេដ្ឋិនា សទ្ធឹ សហស្សេន អព្ភុតំ ការេហិ មយ្ហំ ពលិពទ្ទោ សកដសតំ អតិពទ្ធំ បវត្តេស្សតីតិ ។ អថខោ ភិក្ខវេ សោ ព្រាហ្មណោ សេដ្ឋិនា សទ្ធឹ សហស្សេន អព្ភុតំ អកាសិ មយ្ហំ ពលិពទ្ទោ សកដសតំ អតិពទ្ធំ បវត្តេស្សតីតិ ។ អថខោ ភិក្ខវេ សោ ព្រាហ្មណោ សកដសតំ អតិពន្ធិត្វា នន្ទិវិសាលំ ពលិពទ្ទំ យុញ្ជិត្វា ឯតទវោច អញ្ឆ កូដ វហស្សុ កូដាតិ ។ អថខោ ភិក្ខវេ នន្ទិវិសាលោ ពលិពទ្ទោ តត្ថេវ អដ្ឋាសិ ។ អថខោ ភិក្ខវេ សោ ព្រាហ្មណោ សហស្សេន បរា-ជិតោ បជ្ឈាយិ ។ អថខោ ភិក្ខវេ នន្ទិវិសាលោ ពលិពទ្ទោ តំ ព្រាហ្មណំ ឯតទវោច កិស្ស ត្វំ ព្រាហ្មណ បជ្ឈាយសីតិ ។ តថា ហិ បណាហំ ភោ តយា សហស្សេន បរាជិតោតិ ។ កិស្ស បន មំ ត្វំ ព្រាហ្មណ អកូដំ កូដវាទេន ចាបេសិ កច្ច ត្វំ

ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ គោឈ្មោះនន្ទិវិសាល បាននិយាយពាក្យនេះនឹងព្រាហ្មណ៍នោះថា បពិត្រព្រាហ្មណ៍ ចូរអ្នកទៅនិយាយភ្នាល់នឹងសេដ្ឋីដាក់មួយពាន់កហាបណៈថា គោរបស់ខ្ញុំនឹងទាញរទេះមួយរយដែលចងភ្ជាប់គ្នាឲ្យរួចបាន ។ ម្នាលភិក្ខុទាំងឡាយ ទើបព្រាហ្មណ៍នោះបានភ្នាល់នឹងសេដ្ឋីដាក់មួយពាន់កហាបណៈថា គោរបស់ខ្ញុំនឹងទាញរទេះចំនួនមួយរយដែលចងភ្ជាប់គ្នាបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នោះចងរទេះមួយរយភ្ជាប់គ្នា រួចក៏ទឹមគោឈ្មោះនន្ទិវិសាល ហើយនិយាយពាក្យនេះថា នែគោគៀច ឯងខំទាញទៅ នែគោគៀច ឯងខំអូសទៅ ។ ម្នាលភិក្ខុទាំងឡាយ កាលនោះ គោឈ្មោះនន្ទិវិសាល ក៏ឈរទ្រើងក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ឯព្រាហ្មណ៍នោះ ក៏ចាញ់សេដ្ឋីអស់មួយពាន់កហាបណៈហើយ ក៏សុបសៅក្នុងកាលនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ទើបគោនន្ទិវិសាលបាននិយាយពាក្យនេះ នឹងព្រាហ្មណ៍នោះថា បពិត្រព្រាហ្មណ៍ ហេតុអ្វី ក៏អ្នកសុបសៅ ។ ព្រាហ្មណ៍ឆ្លើយថា នែគោដ៏ចម្រើន បានជាសុបសៅ ព្រោះអ្នកឯងឲ្យខ្ញុំចាញ់សេដ្ឋីអស់មួយពាន់កហាបណៈ ។ គោនន្ទិវិសាលសួរថា ព្រាហ្មណ៍ ខ្ញុំមិនមែនជាសត្វគៀចចុះហេតុអ្វី ក៏អ្នកឯងហៅខ្ញុំថា សត្វគៀច ព្រាហ្មណ៍ចូរអ្នកឯងទៅភ្នាល់

ព្រាហ្មណា សេដ្ឋិនា សទ្ធឹ ទ្វីហិ សហស្សេហិ អព្ភុតំ ករោហិ មយ្ហំ ពលិពទ្ទោ សកដសតំ អតិពទ្ធំ បវដ្ដេស្សតីតិ មា ច មំ អកូដំ កូដវាទេន ចោទេសីតិ ។ អថខោ ភិក្ខវេ សោ ព្រាហ្មណោ សេដ្ឋិនា សទ្ធឹ ទ្វីហិ សហស្សេហិ អព្ភុតំ អកាសិ មយ្ហំ ពលិពទ្ទោ សកដសតំ អតិពទ្ធំ បវដ្ដេស្សតីតិ ។ អថខោ ភិក្ខវេ សោ ព្រាហ្មណោ សកដសតំ អតិពន្ធិត្វា នន្ទិវិសាលំ ពលិពទ្ទំ យុញ្ជិត្វា ឯតទវោច អញ្ជ ភទ្រ វហស្សុ ភទ្រាតិ ។ អថខោ ភិក្ខវេ នន្ទិវិសាលោ ពលិពទ្ទោ សកដសតំ អតិពទ្ធំ បវដ្ដេសិ ។

[១៨៤] មនាបមេវ ភាសេយ្យ នាមនាបំ កុទាចនំ មនាបំ ភាសមានស្ស គរុភារំ ឧទព្វហិ ធនញ្ច នំ អលព្ភេសិ តេន ចិត្តមនោ អហូតិ ។

នឹងសេដ្ឋីដាក់មួយពាន់កហាបណៈថា គោរបស់ខ្ញុំទាញរទេះចំនួនមួយរយដែលគេចងភ្ជាប់គ្នាបាន តែថាអ្នកឯងកុំហៅខ្ញុំថា គោគៀចទៀត ព្រោះខ្ញុំមិនមែនជាគោគៀចទេ ។ ម្នាលភិក្ខុទាំងឡាយ ឯព្រាហ្មណ៍នោះ ភ្នាល់នឹងសេដ្ឋីដាក់ពីរពាន់កហាបណៈ ដោយពាក្យថា គោរបស់ខ្ញុំអាចទាញរទេះចំនួនមួយរយដែលគេចងភ្ជាប់គ្នាបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នោះ ក៏ចងរទេះ ចំនួនមួយរយភ្ជាប់គ្នា រួចទឹមគោនន្ទិវិសាលហើយបាននិយាយពាក្យនេះក្នុងពេលនោះថា ម្នាលគោដ៏ចម្រើន ចូរអ្នកឯងទាញទៅ ម្នាលគោដ៏ចម្រើន ចូរអ្នកឯងអូសទៅ ។ ម្នាលភិក្ខុទាំងឡាយ កាលនោះ គោនន្ទិវិសាល ក៏ទាញរទេះចំនួនមួយរយដែលគេចងភ្ជាប់គ្នាឲ្យវិលទៅបាន ។

[១៨៤] បុគ្គលត្រូវពោលតែពាក្យដែលជាទីគាប់ចិត្តម្យ៉ាង
ពាក្យដែលមិនជាទីគាប់ចិត្ត សូម្បីតែម្តង ក៏មិនត្រូវពោល
ឡើយ (ព្រាហ្មណ៍) ពោលពាក្យជាទីគាប់ចិត្ត (គោនន្ទិ-
វិសាល) ក៏នាំទៅនូវភារៈដ៏ធ្ងន់រួច ហើយញុំាងព្រាហ្មណ៍
នោះឲ្យបានទ្រព្យផង មានសេចក្តីពេញចិត្ត ព្រោះព្រាហ្មណ៍
នោះបានទ្រព្យផង ព្រោះការងាររបស់ខ្លួនផង ។

[១៨៥] តទាបិ មេ ភិក្ខវេ អមនាបា ខុំសនា[១] វម្ភនា កិមង្គំ បនេតរហិ មនាបា ភវិស្សតិ ខុំសនា[២] វម្ភនា នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ឱមសវាទេ បាចិត្តិយន្តិ ។

[១៨៦] ឱមសវាទោ នាម ទសហិ អាការេហិ ឱមសតិ ជាតិយាបិ នាមេនបិ គោត្តេនបិ កម្មេនបិ សិប្បេនបិ អាពាធេនបិ លិង្គេនបិ កិលេសេនបិ អាបត្តិយាបិ ហីនេនបិ អក្កោសេនាតិ ។

[១៨៧] ជាតិ នាម ទ្វេ ជាតិយោ ហីនា ច ជាតិ ឧក្កដ្ឋា ច ជាតិ ។ ហីនា នាម ជាតិ ចណ្ឌាលជាតិ វេណជាតិ នេសាទជាតិ រថការជាតិ បុក្កុសជាតិ ឯសា ហីនា នាម ជាតិ ។ ឧក្កដ្ឋា នាម ជាតិ ខត្តិយជាតិ ព្រាហ្មណជាតិ ឯសា ឧក្កដ្ឋា នាម ជាតិ ។

---

១-២ ខុង្សនាតិបិ ។

[១៨៥] ម្នាលភិក្ខុទាំងឡាយ ពាក្យជេរប្រទេច មិនជាទីគាប់ចិត្ត ដល់តថាគតក្នុងកាលនោះ សំដីជេរប្រទេចនឹងជាទីគាប់ចិត្តក្នុងកាលឥឡូវនេះដូចម្តេចបាន ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់អ្នកដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុពោលពាក្យចាក់ដោត ត្រូវអាបត្តិបាចិត្តិយ ។

[១៨៦] ដែលហៅថា ពាក្យចាក់ដោតនោះ គឺភិក្ខុពោលចាក់ដោតដោយអាការ ១០ យ៉ាង គឺ ជាតិ ១ ឈ្មោះ ១ គោត្ត ១ ការងារ ១ សិល្បសាស្ត្រ ១ អាពាធ ១ ភេទ ១ កិលេស ១ អាបត្តិ ១ ពាក្យជេរដ៏ថោកទាប ១ ។

[១៨៧] ដែលហៅថា ជាតិ គឺ ជាតិមានពីរយ៉ាង បានដល់ហីនជាតិ[១] ១ ឧក្កដ្ឋជាតិ[២] ១ ។ ដែលហៅថា ហីនជាតិ គឺជាតិមនុស្សចណ្ឌាល[៣] ជាតិជាងត្បាញផែង[៤] ជាតិអ្នកនេសាទ[៥] ជាតិអ្នកធ្វើរទេះ ជាតិអ្នកចោលសំរាម ជាតិទាំងនេះ ហៅថា ហីនជាតិ ។ ដែលហៅថា ឧក្កដ្ឋជាតិ គឺជាតិក្សត្រីយ៍ ជាតិព្រាហ្មណ៍ ជាតិទាំងនេះហៅថា ឧក្កដ្ឋជាតិ ។

---

១ ជាតិថោកទាប ។ ២ ជាតិខ្ពង់ខ្ពស់ ។ ៣ ជាតិមនុស្សច្រលោងខាម ។ ៤ អាចារ្យខ្លះពោលថា ជាងចាំង ។ ៥ ជាតិព្រានម្រឹគជាដើម ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស ទុតិយសិក្ខាបទស្ស បទភាជនីយំ

[១៨៨] ណាមំ ណាម ទ្វេ ណាមានិ ហីនញ្ច ណាមំ ឧក្កដ្ឋញ្ច ណាមំ ។ ហីនំ ណាម ណាមំ អវកណ្ណកំ ជវកណ្ណកំ ធនិដ្ឋកំ សវិដ្ឋកំ កុលវឌ្ឍកំ តេសុ តេសុ វា បន ជនបទេសុ ឱញ្ញាតំ អវញ្ញាតំ ហីឡិតំ បរិភូតំ អចិតីកតំ ឯតំ ហីនំ ណាម ណាមំ ។ ឧក្កដ្ឋំ ណាម ណាមំ ពុទ្ធបដិសំយុត្តំ ធម្មបដិសយុត្តំ សង្ឃបដិសំយុត្តំ តេសុ តេសុ វា បន ជនបទេសុ អនោញ្ញាតំ អនវញ្ញាតំ អហីឡិតំ អបរិភូតំ ចិតីកតំ ឯតំ ឧក្កដ្ឋំ ណាម ណាមំ ។

[១៨៩] គោត្តំ ណាម ទ្វេ គោត្តានិ ហីនញ្ច គោត្តំ ឧក្កដ្ឋញ្ច គោត្តំ ។ ហីនំ ណាម[១] ភារទ្វាជគោត្តំ តេសុ តេសុ វា បន ជនបទេសុ ឱញ្ញាតំ អវញ្ញាតំ ហីឡិតំ បរិភូតំ អចិតីកតំ ឯតំ ហីនំ ណាម គោត្តំ ។ ឧក្កដ្ឋំ ណាម គោត្តំ គោតមគោត្តំ មោគ្គល្លានគោត្តំ កច្ចាយនគោត្តំ វាសេដ្ឋគោត្តំ តេសុ តេសុ វា បន

១ គោត្តំ កោសិយគោត្តន្តិបិ ទិស្សតិ ។

[១៨៨] ដែលហៅថា នាម គឺ នាមមានពីរយ៉ាង បានខាងឯ ហីននាម ១ ឧក្កដ្ឋនាម ១ ។ ដែលហៅថា ហីននាម គឺ អវកណ្ណកនាម[១] ជវកណ្ណកនាម[២] ធនិដ្ឋកនាម[៣] សវិដ្ឋកនាម[៤] កុលវឌ្ឍកនាម[៥] ពុំនោះសោត នាមណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះ ៗ នាមទាំងនេះហៅថា ហីននាម ។ ដែលហៅថា ឧក្កដ្ឋនាម គឺ នាមដែលប្រកបព្រមចំពោះដោយព្រះពុទ្ធ ប្រកបព្រមចំពោះដោយព្រះធម៌ ប្រកបព្រមចំពោះដោយព្រះសង្ឃ ពុំនោះសោត នាមណាដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះ ៗ នាមទាំងនេះ ហៅថា ឧក្កដ្ឋនាម ។

[១៨៩] ដែលហៅថា គោត្ត គឺ គោត្តមានពីរយ៉ាង បានខាង ហីនគោត្ត ១ ឧក្កដ្ឋគោត្ត ១ ។ ដែលហៅថា ហីនគោត្ត គឺ ភារទ្វាជគោត្ត ពុំនោះសោត គោត្តណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះ ៗ គោត្តទាំងនេះហៅថា ហីនគោត្ត ។ ដែលហៅថា ឧក្កដ្ឋគោត្ត គឺ គោតមគោត្ត មោគ្គល្លានគោត្ត កច្ចាយនគោត្ត វាសេដ្ឋគោត្ត ពុំនោះសោត

១-២-៣-៤-៥ នាម ទាំង ៥ នេះ តាមអដ្ឋកថា ថាជាឈ្មោះពួកមនុស្សដែលជាខ្ញុំបម្រើគេ ។

ផនបទេសុ អនោញ្ញាតំ អនវញ្ញាតំ អហីឡិតំ អបរិភូតំ ចិតីកតំ ឯតំ ឧក្កដ្ឋំ ជាម គោត្តំ ។

[១៩០] កម្មំ ជាម ទ្វេ កម្មានិ ហីនញ្ច កម្មំ ឧក្កដ្ឋញ្ច កម្មំ ។ ហីនំ ជាម កម្មំ កោដ្ឋកកម្មំ បុប្ផឆឌ្ឌកកម្មំ តេសុ តេសុ វា បន ផនបទេសុ ឱញ្ញាតំ អវញ្ញាតំ ហីឡិតំ បរិភូតំ អចិតីកតំ ឯតំ ហីនំ ជាម កម្មំ ។ ឧក្កដ្ឋំ ជាម កម្មំ កសិ វណិជ្ជា គោរក្ខា តេសុ តេសុ វា បន ផនបទេសុ អនោញ្ញាតំ អនវញ្ញាតំ អហីឡិតំ អបរិភូតំ ចិតីកតំ ឯតំ ឧក្កដ្ឋំ ជាម កម្មំ ។

[១៩១] សិប្បំ ជាម ទ្វេ សិប្បានិ ហីនញ្ច សិប្បំ ឧក្កដ្ឋញ្ច សិប្បំ ។ ហីនំ ជាម សិប្បំ នឡការសិប្បំ កុម្ភការសិប្បំ បេសការសិប្បំ

គោត្តណា ដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះ ៗ គោត្តទាំងនេះ ហៅថា ឧក្កដ្ឋគោត្ត ។

[១៩០] ដែលហៅថា ការងារ គឺ ការងារមានពីរយ៉ាង បានដល់ការងារដ៏ថោកទាប ១ ការងារដ៏ខ្ពង់ខ្ពស់ ១ ។ ដែលហៅថា ការងារដ៏ថោកទាប គឺ ការងាររបស់អ្នកចាំងឈើ ការងាររបស់អ្នកចោលផ្កា (ចោលសំរាម) ពុំនោះសោត ការងារណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះ ៗ ការងារទាំងនេះហៅថា ការងារដ៏ថោកទាប ។ ដែលហៅថា ការងារដ៏ខ្ពង់ខ្ពស់ គឺ ការភ្ជួររាស់ ការជួញប្រែ ការរក្សាគោ ពុំនោះសោត ការងារណាដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះ ៗ ការងារទាំងនេះ ហៅថា ការងារដ៏ខ្ពង់ខ្ពស់ ។

[១៩១] ដែលហៅថា សិល្បសាស្រ្ត គឺ សិល្បសាស្រ្ត មានពីរយ៉ាង បានដល់សិល្បសាស្រ្តដ៏ថោកទាប ១ សិល្បសាស្រ្តដ៏ខ្ពង់ខ្ពស់ ១ ។ ដែលហៅថា សិល្បសាស្រ្តដ៏ថោកទាប គឺ សិល្បសាស្រ្តអ្នកត្បាញផែង សិល្បសាស្រ្តអ្នកធ្វើឆ្នាំង សិល្បសាស្រ្តអ្នកត្បាញសំពត់

ចម្មការសិប្បំ នហាបិតសិប្បំ តេសុ តេសុ វា បន ជនបទេសុ ឱញ្ញាតំ អវញ្ញាតំ ហីឡិតំ បរិភូតំ អចិតីកតំ ឯតំ ហីនំ នាម សិប្បំ ។ ឧក្កដ្ឋំ នាម សិប្បំ មុទ្ទា គណនា លេខា តេសុ តេសុ វា បន ជនបទេសុ អនោញ្ញាតំ អនវញ្ញាតំ អហីឡិតំ អបរិភូតំ ចិតីកតំ ឯតំ ឧក្កដ្ឋំ នាម សិប្បំ ។

[១៩២] សព្វេបិ អាពាធា ហីនា នាម អបិច មធុមេហោ អាពាធោ ឧក្កដ្ឋោ ។

[១៩៣] លិង្គំ នាម ទ្វេ លិង្គានិ ហីនញ្ច លិង្គំ ឧក្កដ្ឋញ្ច លិង្គំ ។ ហីនំ នាម លិង្គំ អតិទីឃំ អតិរស្សំ អតិកណ្ហំ អច្ចោទាតំ ឯតំ ហីនំ នាម លិង្គំ ។ ឧក្កដ្ឋំ នាម លិង្គំ នាតិទីឃំ នាតិរស្សំ នាតិកណ្ហំ នាច្ចោទាតំ ឯតំ ឧក្កដ្ឋំ នាម លិង្គំ ។

សិល្បសាស្ត្រអ្នកធ្វើស្បែក[១] សិល្បសាស្ត្រខាន់ព្រះកេស ពុំនោះសោត សិល្បសាស្ត្រណា ដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះ ៗ សិល្បសាស្ត្រទាំងនេះ ហៅថា សិល្បសាស្ត្រដ៏ថោកទាប ។ ដែលហៅថា សិល្ប-សាស្ត្រដ៏ខ្ពង់ខ្ពស់ គឺរាប់ដោយដៃទទេ រាប់ដោយវិធីនព្វន្ត ការសរសេរអក្សរ ពុំនោះសោត សិល្បសាស្ត្រណា ដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះ ៗ សិល្បសាស្ត្រទាំងនេះ ហៅថា សិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់ ។

[១៩២] បណ្ដាអាពាធទាំងឡាយ សុទ្ធតែថោកទាបទាំងអស់ ចំណែកខាងអាពាធទឹកនោមផ្អែម (រោគប្រមេះ) ហៅថា អាពាធយ៉ាងស្រាល ។

[១៩៣] ដែលហៅថា ភេទ គឺភេទមានពីរយ៉ាង បានដល់ ភេទដ៏ថោកទាប ១ ភេទដ៏ខ្ពង់ខ្ពស់ ១ ។ ដែលហៅថា ភេទថោកទាបគឺ ភេទខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ភេទទាំងនេះ ហៅថា ភេទថោកទាប ។ ដែលហៅថា ភេទខ្ពង់ខ្ពស់ គឺ ភេទមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ភេទទាំងនេះ ហៅថា ភេទខ្ពង់ខ្ពស់ ។

១ ឬសិល្បសាស្ត្រអ្នកធ្វើរថ ។

[១៩៤] សព្វេបិ កិលេសា ហីនា ។

[១៩៥] សព្វាបិ អាបត្តិយោ ហីនា អបិច សោតាបត្តិ សមាបត្តិ ឧក្កដ្ឋា ។

[១៩៦] អក្កោសោ នាម ទ្វេ អក្កោសា ហីនោ ច អក្កោសោ ឧក្កដ្ឋោ ច អក្កោសោ ។ ហីនោ នាម អក្កោសោ ឱដ្ឋោសិ មេណ្ឌោសិ គោណោសិ គទ្រភោសិ តិរច្ឆានគតោសិ នេរយិកោសិ នត្ថិ តុយ្ហំ សុគតិ ទុគ្គតិយេវ តុយ្ហំ បាដិកង្ខាតិ យការេន វា ភការេន វា កាដកោដចិកាយ វា ឯសោ ហីនោ នាម អក្កោសោ ។ ឧក្កដ្ឋោ នាម អក្កោសោ បណ្ឌិតោសិ ព្យត្តោសិ មេធាវីសិ ពហុស្សុតោសិ ធម្មកថិកោសិ នត្ថិ តុយ្ហំ ទុគ្គតិ សុគតិយេវ តុយ្ហំ បាដិកង្ខាតិ ឯសោ ឧក្កដ្ឋោ នាម អក្កោសោ ។

[១៩៤] ឯកិលេសទាំងឡាយ សុទ្ធតែថោកទាបទាំងអស់ ។

[១៩៥] ឯអាបត្តិទាំងឡាយ សុទ្ធតែថោកទាបទាំងអស់ ចំណែកខាងសោតាបត្តិ និងសមាបត្តិ សុទ្ធតែខ្ពង់ខ្ពស់ទាំងអស់ ។

[១៩៦] ដែលហៅថា ជេរ គឺ ជេរមានពីរយ៉ាង បានដល់ជេរយ៉ាងថោកទាប ១ ជេរយ៉ាងខ្ពង់ខ្ពស់ ១ ។ ដែលហៅថា ជេរយ៉ាងថោកទាប គឺ ជេរថា លោកជាសត្វឱដ្ឋ លោកជាសត្វពពែ លោកជាសត្វគោ លោកជាសត្វលា លោកជាសត្វតិរច្ឆាន លោកជាសត្វនរក[១] លោកគ្មានគតិល្អទេ លោកមានតែគតិអាក្រក់ម្យ៉ាង ជេរដោយយអក្ខរ[២]ក្តី ដោយភអក្ខរ[៣]ក្តី ដោយនិម្មិតបុរស និងនិម្មិតស្រីក្តី ជេរទាំងនេះ ហៅថា ជេរយ៉ាងថោកទាប ។ ដែលហៅថា ជេរយ៉ាងខ្ពង់ខ្ពស់ គឺ ជេរថា លោកជាបណ្ឌិត លោកឆ្លៀវឆ្លាស លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត[៤] លោកជាធម្មកថិក[៥] លោកគ្មានគតិអាក្រក់ទេ លោកមានតែគតិល្អម្យ៉ាង ជេរទាំងនេះ ហៅថា ជេរយ៉ាងខ្ពង់ខ្ពស់ ។

---

១ សត្វកើតក្នុងស្ថានគ្មានសេចក្តីចម្រើន ។ ២-៣ យ អក្ខរ និង ភ អក្ខរនោះ ជាឈ្មោះមេថុនធម្ម ។ ៤ អ្នកចេះដឹងធម្មវិន័យច្រើន ។ ៥ អ្នកសំដែងធម៌ ។

[១៩៧] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ[១] ហីនេន ហីនំ វទេតិ ចណ្ឌាលំ វេនំ នេសាទំ រថការំ បុក្កុសំ ចណ្ឌាលោសិ វេណោសិ នេសាទោសិ រថការោសិ បុក្កុសោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[១៩៨] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ឧក្កដ្ឋំ វទេតិ ខត្តិយំ ព្រាហ្មណំ ចណ្ឌាលោសិ វេណោសិ នេសា-ទោសិ រថការោសិ បុក្កុសោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[១៩៩] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ហីនំ វទេតិ

---

១ ឱ. ម. មង្កុំ កត្តុកាមោ ។

បាចិត្តិយកណ្ឌ មុសាវាទវគ្គ សិក្ខាបទទី ២ បទភាជនីយ

[១៩៧] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យមានមុខចុះក្រោម[១] ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោល ចំពោះបុគ្គលដែលមានជាតិថោកទាប ដោយពាក្យថោកទាប គឺថា និយាយចំពោះឧបសម្បន្នជាតិចណ្ឌាល ជាតិអ្នកធ្វើផែងឫស្សី ជាតិអ្នកនេសាទ ជាតិអ្នកធ្វើរថ ជាតិអ្នកចោលសំរាម ដោយពាក្យថា លោកជាមនុស្សចណ្ឌាល ជាអ្នកធ្វើផែង ជាអ្នកនេសាទ ជាអ្នកធ្វើរថ ជាអ្នកចោលសំរាម ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[១៩៨] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះបុគ្គលដែលមានជាតិខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថានិយាយចំពោះឧបសម្បន្នជាតិក្សត្រិយ៍ ជាតិព្រាហ្មណ៍ ដោយពាក្យថា អ្នកឯងជាអ្នកចណ្ឌាល ជាជាងផែង ជាអ្នកនេសាទ ជាអ្នកធ្វើរថ ជាអ្នកចោលសំរាម ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[១៩៩] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះបុគ្គលដែលមានជាតិថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺនិយាយចំពោះ

---

១ ធ្វើមិនឲ្យមានអំណាចតេជៈ ។

ចណ្ឌាលំ វេណំ នេសាទំ រថការំ បុក្កុសំ ខត្តិយោសិ ព្រាហ្មណោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទាចិត្តិយស្ស ។

[២០០] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ ខត្តិយំ ព្រាហ្មណំ ខត្តិយោសិ ព្រាហ្មណោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទាចិត្តិយស្ស ។

[២០១] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ហីនំ វទេតិ អវកណ្ណកំ ជវកណ្ណកំ ធនិដ្ឋកំ សវិដ្ឋកំ កុលវឌ្ឍកំ អវកណ្ណកោសិ ជវកណ្ណកោសិ ធនិដ្ឋកោសិ សវិដ្ឋ-កោសិ កុលវឌ្ឍកោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទាចិត្តិយស្ស ។

[២០២] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ឧក្កដ្ឋំ វទេតិ

ឧបសម្បន្នជាតិអ្នកចណ្ឌាល ជាតិអ្នកជាងផែង ជាតិអ្នកនេសាទ ជាតិអ្នកធ្វើរថ ជាតិអ្នកចោលសំរាម ដោយពាក្យថា លោកជាក្សត្រិយ៍ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២០០] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះបុគ្គលដែលមានជាតិខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺនិយាយចំពោះឧបសម្បន្នដែលមានជាតិជាក្សត្រិយ៍ ជាតិព្រាហ្មណ៍ ដោយពាក្យថា លោកជាក្សត្រិយ៍ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២០១] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះនាមថោកទាប ដោយពាក្យថោកទាប គឺនិយាយចំពោះឧបសម្បន្នដែលមាននាមជាអវកណ្ណក ជាជវកណ្ណក ជាធនិដ្ឋក ជាសវិដ្ឋក ជាកុលវឌ្ឍក ដោយពាក្យថា លោកជាអវកណ្ណក លោកជាជវកណ្ណក លោកជាធនិដ្ឋក លោកជាសវិដ្ឋក លោកជាកុលវឌ្ឍក ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២០២] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះនាមខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺនិយាយចំពោះឧបសម្បន្ន

ពុទ្ធរក្ខិតំ ធម្មរក្ខិតំ សង្ឃរក្ខិតំ អវកណ្ណកោសិ ជវកណ្ណកោសិ ធនិដ្ឋកោសិ សវិដ្ឋកោសិ កុលវឌ្ឍកោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២០៣] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ហីនំ វទេតិ អវកណ្ណកំ ជវកណ្ណកំ ធនិដ្ឋកំ សវិដ្ឋកំ កុលវឌ្ឍកំ ពុទ្ធរក្ខិតោសិ ធម្មរក្ខិតោសិ សង្ឃរក្ខិតោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២០៤] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ ពុទ្ធរក្ខិតំ ធម្មរក្ខិតំ សង្ឃរក្ខិតំ ពុទ្ធរក្ខិតោសិ ធម្មរក្ខិតោសិ សង្ឃរក្ខិតោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២០៥] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ហីនំ វទេតិ

ដែលមាននាមជាពុទ្ធរក្ខិត ជាធម្មរក្ខិត ជាសង្ឃរក្ខិត ដោយពាក្យថា លោកជាអវកណ្ណក លោកជាជវកណ្ណក លោកជាធនិដ្ឋក លោកជាសវិដ្ឋក លោកជាកុលវឌ្ឍក ត្រូវអាបត្តិយបាចិត្តិយគ្រប់ ៗ វាចា ។

[២០៣] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នផង៍គ្នា ពោលចំពោះនាមថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺនិយាយចំពោះឧបសម្បន្នមាននាមជាអវ-កណ្ណក ជាជវកណ្ណក ជាធនិដ្ឋក ជាសវិដ្ឋក ជាកុលវឌ្ឍក ដោយពាក្យថា លោកឈ្មោះពុទ្ធរក្ខិត លោកឈ្មោះធម្មរក្ខិត លោកឈ្មោះសង្ឃរក្ខិត ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២០៤] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផង៍គ្នា ពោលសំដៅនាមដ៏ខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នដែលមាននាមជាពុទ្ធរក្ខិត ជាធម្មរក្ខិត ជាសង្ឃរក្ខិត ដោយពាក្យថា លោកឈ្មោះពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២០៥] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផង៍គ្នា ពោលសំដៅគោត្តថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្ន

កោសិយំ ការាបេយ្យ កោសិយោសិ ការាបេយ្យាសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២០៦] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ឧក្កដ្ឋំ វទេតិ តោតមំ មោគ្គល្លានំ កាត្យាយនំ វាសេដ្ឋំ កោសិយោសិ ការាបេយ្យាសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២០៧] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ហីនំ វទេតិ កោសិយំ ការាបេយ្យំ គោតមោសិ មោគ្គល្លានោសិ កាត្យាយនោសិ វាសេដ្ឋោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២០៨] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ

ជាកោសិយគោត្ត ភារទ្វាជគោត្ត ដោយពាក្យថា លោកជាកោសិយ-គោត្ត លោកជាភារទ្វាជគោត្ត ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២០៦] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅគោត្តដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នជាគោតមគោត្ត ជាមោគ្គល្លានគោត្ត ជាកច្ចាយនគោត្ត ជាវាសេដ្ឋគោត្ត ដោយពាក្យថា លោកជាកោសិយគោត្ត លោកជាភារទ្វាជគោត្ត ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២០៧] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅគោត្តដ៏ថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នជាកោសិយគោត្ត ជាភារទ្វាជគោត្ត ដោយពាក្យថា លោកជាគោតមគោត្ត លោកជាមោគ្គល្លានគោត្ត លោកជាកច្ចាយនគោត្ត លោកជាវាសេដ្ឋគោត្ត ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២០៨] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅគោត្តដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្ន

គោតមំ មោគ្គល្លានំ កច្ចាយនំ វាសេដ្ឋំ គោតមោសិ មោគ្គល្លានោសិ កច្ចាយនោសិ វាសេដ្ឋោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២០៩] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ហីនំ វទេតិ កោដ្ឋកំ បុប្ផឆឌ្ឌកំ កោដ្ឋកោសិ បុប្ផឆឌ្ឌកោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២១០] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ឧក្កដ្ឋំ វទេតិ កាសកំ វាណិជំ គោរក្ខំ កោដ្ឋកោសិ បុប្ផឆឌ្ឌកោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២១១] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ហីនំ វទេតិ

ជាគោតមគោត្ត ជាមោគ្គល្លានគោត្ត ជាកច្ចាយនគោត្ត ជាវាសេដ្ឋគោត្ត ដោយពាក្យថា លោកជាគោតមគោត្ត លោកជាមោគ្គល្លានគោត្ត លោកជាកច្ចាយនគោត្ត លោកជាវាសេដ្ឋគោត្ត ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២០៩] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នថា អ្នកចាំងឈើ ជាអ្នកចោលសំរាម ដោយពាក្យថា លោកជាជាងចាំងឈើ លោកជាអ្នកចោលសំរាម ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២១០] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នថា ជាអ្នកភ្ជួររាស់ ជាអ្នកជួញប្រែ ជាអ្នករក្សាគោ ដោយពាក្យថា លោកជាជាងចាំងឈើ លោកជាអ្នកចោលសំរាម ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២១១] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឲ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្ន

កោដ្ឋកំ បុប្ផឆឌ្ឌកំ កសកោសិ វាណិជោសិ គោរក្ខោ-សីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២១២] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ កសកំ វាណិជំ គោរក្ខំ កសកោសិ វាណិជោសិ គោរក្ខោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២១៣] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ហីនំ វទេតិ នឡការំ កុម្ភការំ បេសការំ ចម្មការំ នហាបិតំ នឡការោសិ កុម្ភការោសិ បេសការោសិ ចម្មកា-រោសិ នហាបិតោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

ថា ជាជាងចាំងឈើ ជាអ្នកចោលសំរាម ដោយពាក្យថា លោកជាអ្នកក្ជួរ រាស់ លោកជាអ្នកជំនួញ លោកជាអ្នករក្សាគោ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២១២] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្ន ថា ជាអ្នកក្ជួររាស់ អ្នកជំនួញ អ្នករក្សាគោ ដោយពាក្យថា លោកជាអ្នកក្ជួររាស់ លោកជាអ្នកជំនួញ លោកជាអ្នករក្សាគោ ត្រូវអាបត្តិបាចិត្តិយ គ្រប់ ៗ វាចា ។

[២១៣] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅសិល្បសាស្ត្រដ៏ថោកទាប ដោយពាក្យដ៏ថោកទាប គឺថាពោលសំដៅឧបសម្បន្នថា ជាជាងត្បាញផែង ជាស្មូនឆ្នាំង ជាជាងតម្បាញ ជាជាងស្បែក ជាខ្មាន់ព្រះកេស ដោយពាក្យថា លោកជាជាងត្បាញផែង លោកជាស្មូនឆ្នាំង លោកជាជាងតម្បាញ លោកជាជាងស្បែក លោកជាខ្មាន់ព្រះកេស ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស ទុតិយសិក្ខាបទស្ស បទភាជនីយំ

[២១៤] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ឧក្កដ្ឋំ វទេតិ មុទ្ធិកំ គណកំ លេខកំ នឡការោសិ កុម្ភការោសិ បេសការោសិ ចម្មការោសិ នហាបិតោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២១៥] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ហីនំ វទេតិ នឡការំ កុម្ភការំ បេសការំ ចម្មការំ នហាបិតំ មុទ្ធិកោសិ គណកោសិ លេខកោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២១៦] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ

បាចិត្តិយកណ្ឌ មុសាវាទវគ្គ សិក្ខាបទទី ២ បទភាជនីយ

[២១៤] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅសិល្បសាស្រ្តដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្ន ជាអ្នករាប់ដៃទទេ អ្នករាប់ដោយវិធីនព្វន្ត អ្នកសរសេរអក្សរ (នាយស្មេរ) ដោយពាក្យថា លោកជាជាងត្បាញផែង លោកជាស្មូនឆ្នាំង លោកជាជាងតម្បាញ លោកជាអ្នកធ្វើស្បែក លោកជាខ្មាន់ព្រះកេស ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២១៥] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅសិល្បសាស្រ្តថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្ន ជាជាងត្បាញផែង ស្មូនឆ្នាំង ជាងតម្បាញ អ្នកធ្វើស្បែក ខ្មាន់ព្រះកេស ដោយពាក្យថា លោកជាអ្នករាប់ដោយដៃទទេ លោកជាអ្នករាប់ដោយវិធីនព្វន្ត លោកជាអ្នកសរសេរអក្សរ (នាយស្មេរ) ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២១៦] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅ

មុទ្ធិកំ គណកំ លេខកំ មុទ្ធិកោសិ គណកោសិ លេខកោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២១៧] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ហីនំ វទេតិ កុដ្ឋិកំ គណ្ឌិកំ កិលាសិកំ សោសិកំ អបមារិកំ កុដ្ឋិកោសិ គណ្ឌិកោសិ កិលាសិកោសិ សោសិ-កោសិ អបមារិកោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២១៨] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ឧក្កដ្ឋំ វទេតិ

សិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្ន ជាអ្នករាប់ដោយដៃទទេ អ្នករាប់ដោយវិធីនព្វន្ត អ្នកសរសេរអក្សរ (នាយស្មេរ) ដោយពាក្យថា លោកជាអ្នករាប់ដោយដៃទទេ លោកជាអ្នករាប់ដោយវិធីនព្វន្ត លោកជាអ្នកសរសេរអក្សរ (នាយស្មេរ) ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២១៧] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផង်គ្នា ពោលសំដៅអាពាធថោកទាប ដោយពាក្យដ៏ថោកទាប គឺថាពោលសំដៅឧបសម្បន្នបុគ្គលដែលកើតឃ្លង់ បូស ស្រែង រោគរីងរៃ ឆ្កួតជ្រូក ដោយពាក្យថា លោកជាមនុស្សឃ្លង់ លោកជាមនុស្សកើតបូស លោកជាមនុស្សស្រែង លោកជាមនុស្សកើតរោគរីងរៃ លោកជាមនុស្សឆ្កួតជ្រូក ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២១៨] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផង់គ្នា ពោលសំដៅអាពាធដ៏ខ្ពង់ខ្ពស់ (អាពាធស្រាល) ដោយពាក្យដ៏ថោកទាប គឺថាពោលសំដៅ

មធុមេហិកំ កុដ្ឋិកោសិ គណ្ឌិកោសិ កិលាសិកោសិ សោសិកោសិ អបមារិកោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២១៩] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ហីនំ វទេតិ កុដ្ឋិកំ គណ្ឌិកំ កិលាសិកំ សោសិកំ អបមារិកំ មធុមេហិកោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២២០] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ មធុមេហិកំ មធុមេហិកោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២២១] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ហីនំ វទេតិ

បាចិត្តិយកណ្ឌ មុសាវាទវគ្គ សិក្ខាបទទី ២ បទភាជនីយ

ឧបសម្បន្នបុគ្គលដែលមានអាពាធទឹកនោមផ្អែម (កើតប្រមេះផ្អែមម៉ាត់) ដោយពាក្យថា លោកជាមនុស្សឃ្លង់ លោកជាមនុស្សកើតបូស លោកជាមនុស្សកើតស្រែង លោកជាមនុស្សកើតរោគរីងរៃ លោកជាមនុស្សឆ្កួតជ្រូក ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២១៩] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅអាពាធថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលជាមនុស្សឃ្លង់ មនុស្សកើតបូស មនុស្សកើតស្រែង មនុស្សកើតរោគរីងរៃ មនុស្សឆ្កួតជ្រូក ដោយពាក្យថា លោកជាមនុស្សមានអាពាធទឹកនោមផ្អែម ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២២០] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅអាពាធខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នបុគ្គលដែលជាអ្នកមានអាពាធទឹកនោមផ្អែម ដោយពាក្យថា លោកជាមនុស្សមានអាពាធទឹកនោមផ្អែម ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២២១] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅ

អតិជីឃំ អតិរស្សំ អតិកណ្ហំ អច្ចោទាតំ អតិជីឃោសិ អតិរស្សោសិ អតិកណ្ហោសិ អច្ចោទាតោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទាចិត្តិយស្ស ។

[២២២] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ឧក្កដ្ឋំ វទេតិ ជាតិជីឃំ ជាតិរស្សំ ជាតិកណ្ហំ ជាច្ចោទាតំ អតិជីឃោសិ អតិរស្សោសិ អតិកណ្ហោសិ អច្ចោទាតោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទាចិត្តិយស្ស ។

[២២៣] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ហីនំ វទេតិ អតិជីឃំ អតិរស្សំ អតិកណ្ហំ អច្ចោទាតំ ជាតិជីឃោសិ ជាតិរស្សោសិ ជាតិកណ្ហោសិ ជាច្ចោទាតោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទាចិត្តិយស្ស ។

ភេទថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ដោយពាក្យថា លោកខ្ពស់ពេក លោកទាបពេក លោកខ្មៅពេក លោកសពេក ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២២២] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផង៏គ្នា ពោលសំដៅភេទដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ដោយពាក្យថា លោកខ្ពស់ពេក លោកទាបពេក លោកខ្មៅពេក លោកសពេក ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២២៣] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផង៏គ្នា ក៏ពោលសំដៅភេទថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ដោយពាក្យថា លោកមិនខ្ពស់ពេក លោកមិនទាបពេក លោកមិនខ្មៅពេក លោកមិនសពេក ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស ទុតិយសិក្ខាបទស្ស បទភាជនីយំ

[២២៤] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ ជាតិឌីឃំ ជាតិវស្សំ ជាតិកណ្ហំ ជាច្ចោទាតំ ជាតិឌី-ឃោសិ ជាតិវស្សោសិ ជាតិកណ្ហោសិ ជាច្ចោទាតោសីតិ ភណាតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២២៥] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ហីនំ វទេតិ រាគបរិយុដ្ឋិតំ ទោសបរិយុដ្ឋិតំ មោហបរិយុដ្ឋិតំ រាគប-រិយុដ្ឋិតោសិ ទោសបរិយុដ្ឋិតោសិ មោហបរិយុដ្ឋិតោសីតិ ភណាតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២២៦] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ឧក្កដ្ឋំ វទេតិ

បាចិត្តិយកណ្ឌ មុសាវាទវគ្គ សិក្ខាបទទី ២ បទភាជនីយ

[២២៤] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភេទដ៏ខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ដោយពាក្យថា លោកមិនខ្ពស់ពេក លោកមិនទាបពេក លោកមិនខ្មៅពេក លោកមិនសពេក ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២២៥] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅកិលេសដែលជាធម៌ដ៏ថោកទាប ដោយពាក្យដ៏ថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលរាគៈគ្របសង្កត់ហើយ ទោសៈគ្រប់សង្កត់ហើយ មោហៈគ្រប់សង្កត់ហើយ ដោយពាក្យថា លោកត្រូវរាគៈគ្របសង្កត់ហើយ លោកត្រូវទោសៈគ្របសង្កត់ហើយ លោកត្រូវមោហៈគ្របសង្កត់ហើយ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២២៦] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅកិលេសដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុ

វីតរាគំ វីតទោសំ វីតមោហំ រាគបរិយុដ្ឋិតោសិ ទោសបរិយុដ្ឋិតោសិ មោហបរិយុដ្ឋិតោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២២៧] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ហីនំ វទេតិ រាគបរិយុដ្ឋិតំ ទោសបរិយុដ្ឋិតំ មោហបរិយុដ្ឋិតំ វីតរាគោសិ វីតទោសោសិ វីតមោហោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២២៨] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ វីតរាគំ វីតទោសំ វីតមោហំ វីតរាគោសិ វីតទោសោសិ វីតមោហោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

ដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ដោយពាក្យថា លោកត្រូវរាគៈគ្របសង្កត់ហើយ លោកត្រូវទោសៈគ្របសង្កត់ហើយ លោកត្រូវមោហៈគ្របសង្កត់ហើយ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២២៧] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផង៏គ្នា ក៏ពោលសំដៅកិលេសដែលជាធម៌ដ៏ថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុ ដែលត្រូវរាគៈគ្របសង្កត់ហើយ ត្រូវទោសៈគ្របសង្កត់ហើយ ត្រូវមោហៈគ្របសង្កត់ហើយ ដោយពាក្យថា លោកប្រាសចាករាគៈ លោកប្រាសចាកទោសៈ លោកប្រាសចាកមោហៈ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២២៨] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផង៏គ្នា ក៏ពោលសំដៅធម៌ដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ដោយពាក្យថា លោកប្រាសចាករាគៈ លោកប្រាសចាកទោសៈ លោកប្រាសចាកមោហៈ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស ទុតិយសិក្ខាបទស្ស បទភាជនីយំ

[២២៩] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ហីនំ វទេតិ ចាភជិកំ អជ្ឈាបន្នំ សង្ឃាទិសេសំ អជ្ឈាបន្នំ ថុល្លច្ចយំ អជ្ឈាបន្នំ ចាចិត្តិយំ អជ្ឈាបន្នំ ចាដិទេសនីយំ អជ្ឈាបន្នំ ទុក្កដំ អជ្ឈាបន្នំ ទុព្ភាសិតំ អជ្ឈាបន្នំ ចាភជិកំ អជ្ឈាបន្នោសិ សង្ឃាទិសេសំ អជ្ឈាបន្នោសិ ថុល្លច្ចយំ អជ្ឈាបន្នោសិ ចាចិត្តិយំ អជ្ឈាបន្នោសិ ចាដិទេសនីយំ អជ្ឈាបន្នោសិ ទុក្កដំ អជ្ឈាបន្នោសិ ទុព្ភាសិតំ អជ្ឈា-បន្នោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២៣០] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ឧក្កដ្ឋំ វទេតិ សោតាបន្នំ ចាភជិកំ អជ្ឈាបន្នោសិ ។ បេ ។ ទុព្ភាសិតំ អជ្ឈាបន្នោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២៣១] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ហីនំ វទេតិ

បាចិត្តិយកណ្ឌ មុសាវាទវគ្គ សិក្ខាបទទី ២ បទភាជនីយ

[២២៩] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលត្រូវអាបត្តិបារាជិក ត្រូវអាបត្តិសង្ឃាទិសេស ត្រូវអាបត្តិថុល្លច្ច័យ ត្រូវអាបត្តិបាចិត្តិយ ត្រូវអាបត្តិបាដិទេសនីយ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិទុព្ភាសិត ដោយពាក្យថា លោក ត្រូវអាបត្តិបារាជិក លោក ត្រូវអាបត្តិសង្ឃាទិសេស លោក ត្រូវអាបត្តិថុល្លបច្ច័យ លោក ត្រូវអាបត្តិបាចិត្តិយ លោក ត្រូវអាបត្តិបាដិទេសនីយ លោក ត្រូវអាបត្តិទុក្កដ លោក ត្រូវអាបត្តិទុព្ភាសិត ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២៣០] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលជាសោតាបន្ន ដោយពាក្យថា លោក ត្រូវអាបត្តិបារាជិក ។ បេ ។ លោក ត្រូវអាបត្តិទុព្ភាសិត ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២៣១] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុ

ចារជិកំ អជ្ឈាបន្នំ ។ បេ ។ ទុព្ភាសិតំ អជ្ឈាបន្នំ សោតាបន្នោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២៣២] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ សោតាបន្នំ សោតាបន្នោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២៣៣] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ហីនំ វទេតិ ឱដ្ឋំ មេណ្ឌំ គោណំ គទ្រភំ តិរច្ឆានគតំ នេរយិកំ ឱដ្ឋោសិ មេណ្ឌោសិ គោណោសិ គទ្រភោសិ តិ-រច្ឆានគតោសិ នេរយិកោសិ នត្ថិ តុយ្ហំ សុគតិ ទុគ្គតិយេវ តុយ្ហំ ចាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២៣៤] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ឧក្កដ្ឋំ វទេតិ

ដែលត្រូវអាបត្តិបារាជិក ។ បេ ។ ត្រូវអាបត្តិទុក្កដសិត ដោយពាក្យថា លោកជាសោតាបន្នបុគ្គល ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២៣២] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផង់គ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលជាសោតាបន្ន ដោយពាក្យថា លោកជាសោតាបន្នបុគ្គល ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២៣៣] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផង់គ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅសត្វឱដ្ឋ សត្វពពែ សត្វគោ សត្វលា សត្វតិរច្ឆាន សត្វនរក ដោយពាក្យថា លោកជាសត្វឱដ្ឋ លោកជាសត្វពពែ លោកជាសត្វគោ លោកជាសត្វលា លោកជាសត្វតិរច្ឆាន លោកជាសត្វនរក លោកមិនមានគតិល្អទេ លោកមានតែគតិអាក្រក់ម្យ៉ាង ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២៣៤] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផង់គ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុ

បណ្ឌិតំ ព្យត្តំ មេធាវី ពហុស្សុតំ ធម្មកថិកំ ឱដ្ឋោសិ មេណ្ឌោសិ គោណោសិ គទ្រភោសិ តិរច្ឆានគតោសិ នេរយិកោសិ នត្ថិ តុយ្ហំ សុគតិ ទុគ្គតិយេវ តុយ្ហំ បាដិ-កង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៣៥] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ហីនំ វទេតិ ឱដ្ឋំ មេណ្ឌំ គោណំ គទ្រភំ តិរច្ឆានគតំ នេរយិកំ បណ្ឌិតោសិ ព្យត្តោសិ មេធាវីសិ ពហុស្សុតោសិ ធម្ម-កថិកោសិ នត្ថិ តុយ្ហំ ទុគ្គតិ សុគតិយេវ តុយ្ហំ បាដិ-កង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៣៦] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ បណ្ឌិតំ ព្យត្តំ មេធាវី ពហុស្សុតំ ធម្មកថិកំ បណ្ឌិតោសិ

ដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា លោកជាសត្វឱដ្ឋ លោកជាសត្វពពែ លោកជាសត្វគោ លោកជាសត្វលា លោកជាសត្វតិរច្ឆាន លោកជាសត្វនរក លោកគ្មានគតិល្អទេ លោកមានតែគតិអាក្រក់ម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២៣៥] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅសត្វឱដ្ឋ សត្វពពែ សត្វគោ សត្វលា សត្វតិរច្ឆាន សត្វនរក ដោយពាក្យថា លោកជាបណ្ឌិត លោកជាមនុស្សឈ្លាស លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត លោកជាធម្មកថិក លោកគ្មានគតិអាក្រក់ទេ លោកមានគតិល្អតែម្យ៉ាង ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២៣៦] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា លោកជាបណ្ឌិត លោកជាមនុស្សឈ្លាស

ព្យត្តោសិ មេធាវីសិ ពហុស្សុតោសិ ធម្មកថិកោសិ នត្ថិ តុយ្ហំ ទុគ្គតិ សុគតិយេវ តុយ្ហំ ចាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២៣៧] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឯវំ វទេតិ សន្តិ ឥធេ-កច្ចេ ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៣៨] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឯវំ វទេតិ សន្តិ ឥធេ-កច្ចេ ខត្តិយា ព្រាហ្មណាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៣៩] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឯវំ វទេតិ សន្តិ ឥធេ-កច្ចេ អវកណ្ណកា ជវកណ្ណកា ធនិដ្ឋកា សវិដ្ឋកា កុលវឌ្ឍកាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។ បេ ។ សន្តិ ឥធេកច្ចេ ពុទ្ធរក្ខិតា

លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត លោកជាធម្មកថិក លោកគ្មានគតិអាក្រក់ទេ លោកមានតែគតិល្អម្យ៉ាង ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា ។

[២៣៧] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះ គឺនិយាយថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាចណ្ឌាល ជាជាងត្បាញផែង ជាអ្នកនេសាទ ជាជាងធ្វើរទេះ ជាអ្នកចោលសំរាម ភិក្ខុនោះ ត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។

[២៣៨] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នផងគ្នា ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាក្សត្រិយ៍ ជាព្រាហ្មណ៍ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។

[២៣៩] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ឈ្មោះអវកណ្ណក ឈ្មោះជវកណ្ណក ឈ្មោះធនិដ្ឋក ឈ្មោះសវិដ្ឋក ឈ្មោះកុលវឌ្ឍក ភិក្ខុនោះ ត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ឈ្មោះពុទ្ធរក្ខិត

២៦១



ធម្មរក្ខិតា សង្ឃរក្ខិតាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។ បេ ។ សន្តិ ឥធេកច្ចេ កោសិយា ភារទ្វាជាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ គោតមា មោគ្គល្លានា កច្ចាយនា វាសេដ្ឋាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ កោដ្ឋកា បុប្ផឆឌ្ឌកាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ កសកា វាណិជា គោរក្ខាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ នឡការា កុម្ភការា បេសការា ចម្មការា នហាបិតាតិ ។ បេ ។ សន្តិ ឥធេកច្ចេ មុទ្ទិកា គណកា លេខកាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ កុដ្ឋិកា គណ្ឌិកា កិលា-សិកា សោសិកា អបមារិកាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ មធុមេហិកាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ អតិទីឃា អតិរស្សា អតិកណ្ហា អច្ចោទាតាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ ជា-តិទីឃា ជាតិរស្សា ជាតិកណ្ហា ជាច្ចោទាតាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ រាគបរិយុដ្ឋិតា ទោស-បរិយុដ្ឋិតា មោហបរិយុដ្ឋិតាតិ ភណតិ ។ បេ ។

ធម្មរក្ខិត សង្ឃរក្ខិត ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាកោសិយគោត្ត ជាភារទ្វាជគោត្ត ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាគោតមគោត្ត ជាមោគ្គល្លានគោត្ត ជាកច្ចាយនគោត្ត ជាវាសេដ្ឋគោត្ត ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាជាងថាំង ជាអ្នកចោលផ្កា ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាអ្នកភ្ជួររាស់ ជាឈ្មួញ ជាអ្នករក្សាគោ ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាជាងត្បាញផែងបបុស ជាស្មូនឆ្នាំង ជាជាងតម្បាញ ជាអ្នកធ្វើស្បែក ជាខ្មាន់ព្រះកេស ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាអ្នករាប់ដៃទទេ ជាអ្នករាប់ដោយវិធីនព្វន្ត ជាអ្នកសរសេរអក្សរ (ស្មេរ) ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាមនុស្សគម្ងង់ ជាមនុស្សកើតបូស ជាមនុស្សសម្រែង ជាមនុស្សកើតរោគរីងរៃ ជាមនុស្សឆ្កួតជ្រូក ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ កើតរោគប្រមេះទឹកនោមផ្អែម ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ មិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ត្រូវរាគៈគ្របសង្កត់ ត្រូវទោសៈគ្របសង្កត់ ត្រូវមោហៈគ្របសង្កត់ ។ បេ ។

សន្តិ ឥធេកច្ចេ វីតរាគា វីតទោសា វីតមោហាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ ចារជិកំ អជ្ឈាបន្នា ។ បេ ។ ទុព្ភាសិតំ អជ្ឈាបន្នាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ សោតាបន្នាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ ឱដ្ឋា មេណ្ឌា គោណា គទ្រភា តិរច្ឆានគតា នេរយិកា នត្ថិ តេសំ សុគតិ ទុគ្គតិ-យេវ តេសំ បាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤០] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឯវំ វទេតិ សន្តិ ឥធេកច្ចេ បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ តេសំ ទុគ្គតិ សុគតិយេវ តេសំ បាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤១] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឯវំ វទេតិ យេ ឆ្វេ ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។ បេ ។

ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ត្រូវអាបត្តិបារាជិក ។ បេ ។ ត្រូវអាបត្តិទុព្ភាសិត ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាសោតាបន្នបុគ្គល ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាសត្វឱដ្ឋ សត្វពពែ សត្វគោ សត្វលា សត្វតិរច្ឆាន សត្វនរក មនុស្សទាំងនោះគ្មានគតិល្អទេ មនុស្សទាំងនោះមានតែគតិអាក្រក់ម្យ៉ាង ភិក្ខុនោះ ត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។

[២៤០] ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ជនទាំងនោះគ្មានគតិអាក្រក់ទេ មនុស្សទាំងនោះមានតែគតិល្អម្យ៉ាង ភិក្ខុនោះ ត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។

[២៤១] ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា មនុស្សទាំងឡាយណាមួយ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។ បេ ។

ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឯវំ វទេតិ យេ ឆូន បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ តេសំ ទុគ្គតិ សុគតិយេវ តេសំ បាដិកង្ខាតិ ភណាតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤២] ឧបសម្បន្នោ ឧបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឯវំ វទេតិ ន មយំ ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណាតិ ។ បេ ។ ន មយំ បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ អម្ហាកំ ទុគ្គតិ សុគតិ-យេវ អម្ហាកំ បាដិកង្ខាតិ ភណាតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤៣] ឧបសម្បន្នោ អនុបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ហីនេន ហីនំ វទេតិ

ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា មនុស្សទាំងឡាយណាមួយ ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក មនុស្សទាំងនោះ គ្មានគតិអាក្រក់ មនុស្សទាំងនោះ មានតែគតិល្អម្យ៉ាងទេ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។

[២៤២] ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា យើងទាំងឡាយ មិនមែនជាចណ្ឌាល មិនមែនជាងត្បាញផែងឫស្សី មិនមែនអ្នកនេសាទ មិនមែនជាជាងធ្វើរថ មិនមែនអ្នកចោលសំរាម ។ បេ ។ ថា យើងទាំងឡាយមិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់មិនមានដល់យើងទាំងឡាយទេ ដំណើរល្អតែម្យ៉ាង ប្រាកដដល់យើងទាំងឡាយ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។

[២៤៣] ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោន ចំពោះអនុបសម្បន្ន[១]បុគ្គល ក៏ពោលសំដៅបុគ្គលដ៏ថោកទាប

---

១ បានដល់សិក្ខមានា សាមណេរ សាមណេរី និងគ្រហស្ថ ។

។ បេ ។ ហីនេន ឧក្កដ្ឋំ វទេតិ ។ បេ ។ ឧក្កដ្ឋេន ហីនំ វទេតិ ។ បេ ។ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ បណ្ឌិតំ ព្យត្តំ មេធាវឹ ពហុស្សុតំ ធម្មកថិកំ បណ្ឌិតោសិ ព្យត្តោសិ មេធាវីសិ ពហុស្សុតោសិ ធម្មកថិកោសិ នត្ថិ តុយ្ហំ ទុគ្គតិ សុគតិយេវ តុយ្ហំ បាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤៤] ឧបសម្បន្នោ អនុបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឯវំ វទេតិ សន្តិ ឥធេកច្ចេ ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ តេសំ ទុគ្គតិ សុគតិយេវ តេសំ បាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤៥] ឧបសម្បន្នោ អនុបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឯវំ វទេតិ យេ នូន

ដោយពាក្យដ៏ថោកទាប ។ បេ ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ថោកទាប ។ បេ ។ ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ ។ បេ ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺនិយាយសំដៅអនុបសម្បន្នបុគ្គល ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា អ្នកឯងជាបណ្ឌិត អ្នកឯងជាអ្នកឈ្លាស អ្នកឯងជាអ្នកប្រាជ្ញ អ្នកឯងជាពហុស្សូត អ្នកឯងជាធម្មកថិក ដំណើរអាក្រក់មិនមានដល់អ្នកឯងទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់អ្នកឯង ភិក្ខុនោះ ត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។

[២៤៤] ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាបណ្ឌិត ជាមនុស្សឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក មនុស្សទាំងនោះ គ្មានគតិអាក្រក់ទេ មនុស្សទាំងនោះ មានតែគតិល្អម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។

[២៤៥] ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ហើយពោលយ៉ាងនេះ គឺនិយាយថា មនុស្ស

ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។ បេ ។ យេ ឆេក បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។ ឧបសម្បន្នោ អនុបសម្បន្នំ ខុំសេតុកាមោ វម្ភេតុកាមោ មង្កុកត្តុកាមោ ឯវំ វទេតិ ន មយំ ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណតិ ។ បេ ។ ន មយំ បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ អម្ហាកំ ទុគ្គតិ សុគតិយេវ អម្ហាកំ បាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤៦] ឧបសម្បន្នោ ឧបសម្បន្នំ ន ខុំសេតុកាមោ ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យតា ហីនេន ហីនំ វទេតិ ចណ្ឌាលំ វេណំ នេសាទំ រថការំ បុក្កុសំ

ទាំងឡាយណាមួយ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។ បេ ។ ថា មនុស្សទាំងឡាយណាមួយ ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។ ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ក៏ពោលយ៉ាងនេះថា យើងទាំងឡាយ មិនមែនជាចណ្ឌាល មិនមែនជាជាងត្បាញផែងឫស្សី មិនមែនជាអ្នកនេសាទ មិនមែនជាជាងធ្វើរថ មិនមែនជាអ្នកចោលសំរាម ។ បេ ។ ថា យើងទាំងឡាយមិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់មិនមានដល់យើងទាំងឡាយ ដំណើរល្អតែម្យ៉ាងប្រាកដដល់យើងទាំងឡាយ ត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា ។

[២៤៦] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ថោកទាប គឺពោលសំដៅបុគ្គលជាមនុស្សចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម

ចណ្ឌាលោសិ វេណោសិ នេសាទោសិ រថការោសិ បុក្កុសោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុព្ភាសិតស្ស ។ ឧបសម្បន្នោ ឧបសម្បន្នំ ន ខុំសេតុកាមោ ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យតា ហីនេន ឧក្កដ្ឋំ វទេតិ ខត្តិយំ ព្រាហ្មណំ ចណ្ឌាលោសិ វេណោសិ នេសាទោសិ រថការោសិ បុក្កុសោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុព្ភាសិតស្ស ។ ឧបសម្បន្នោ ឧបសម្បន្នំ ន ខុំសេតុកាមោ ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យតា ឧក្កដ្ឋេន ហីនំ វទេតិ ចណ្ឌាលំ វេណំ នេសាទំ រថការំ បុក្កុសំ ខត្តិយោសិ ព្រាហ្មណោសីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុព្ភាសិតស្ស ។ ឧបសម្បន្នោ ឧបសម្បន្នំ ន ខុំសេតុកាមោ ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យតា ឧក្កដ្ឋេន

ដោយពាក្យថា លោកជាចណ្ឌាល លោកជាជាងត្បាញផែងឫស្សី លោកជាអ្នកនេសាទ លោកជាជាងធ្វើរថ លោកជាអ្នកចោលសំរាម ត្រូវអាបត្តិទុក្កដសិតគ្រប់ ៗ វាចា ។ ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ថោកទាប គឺនិយាយសំដៅឧបសម្បន្នភិក្ខុដែលជាជាតិក្សត្រ ជាតិព្រាហ្មណ៍ ដោយពាក្យថា លោកជាចណ្ឌាល លោកជាជាងត្បាញផែងឫស្សី លោកជាអ្នកនេសាទ លោកជាជាងធ្វើរថ លោកជាអ្នកចោលសំរាម ត្រូវអាបត្តិទុក្កដសិតគ្រប់ ៗ វាចា ។ ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថានិយាយសំដៅឧបសម្បន្នភិក្ខុជាចណ្ឌាល ជាជាងត្បាញផែង ជាអ្នកនេសាទ ជាជាងធ្វើរថ អ្នកចោលសំរាម ដោយពាក្យថា លោកជាក្សត្រ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិទុក្កដសិតគ្រប់ ៗ វាចា ។ ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់

ឧក្កដ្ឋំ វទេតិ ខត្តិយំ ព្រាហ្មណំ ខត្តិយោសិ ព្រាហ្មណោ-
សីតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស
។ បេ ។ ឧបសម្បន្នោ ឧបសម្បន្នំ ន ខុំសេតុកាមោ
ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យតា ហីនេន
ហីនំ វទេតិ ។ បេ ។ ហីនេន ឧក្កដ្ឋំ វទេតិ ។ បេ ។
ឧក្កដ្ឋេន ហីនំ វទេតិ ។ បេ ។ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ
បណ្ឌិតំ ព្យត្តំ មេធាវឹ ពហុស្សុតំ ធម្មកថិកំ បណ្ឌិតោសិ
ព្យត្តោសិ មេធាវីសិ ពហុស្សុតោសិ ធម្មកថិកោសិ
នត្ថិ តុយ្ហំ ទុគ្គតិ សុគតិយេវ តុយ្ហំ ចាដិកង្ខាតិ ភណតិ
អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤៧] ឧបសម្បន្នោ ឧបសម្បន្នំ ន ខុំសេតុកាមោ
ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យតា ឯវំ វទេតិ
សន្តិ ឥធេកច្ចេ ចណ្ឌាលា វេណា នេសាទា រថការា

ដោយពាក្យដ៏ខ្លង់ខ្លស់ គឺនិយាយសំដៅឧបសម្បន្នភិក្ខុដែលជាក្សត្រ ជាព្រាហ្មណ៍ ដោយពាក្យថា លោកជាក្សត្រ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិទុក្កដសិតគ្រប់ ៗ វាចា ។ បេ ។ ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផង់គ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ថោកទាបដោយពាក្យដ៏ថោកទាប ។ បេ ។ ពោលសំដៅបុគ្គលដ៏ខ្លង់ខ្លស់ ដោយពាក្យដ៏ថោកទាប ។ បេ ។ ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ខ្លង់ខ្លស់ ។ បេ ។ ពោលសំដៅបុគ្គលដ៏ខ្លង់ខ្លស់ ដោយពាក្យដ៏ខ្លង់ខ្លស់ គឺនិយាយសំដៅឧបសម្បន្នភិក្ខុដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា លោកជាបណ្ឌិត លោកជាអ្នកឈ្លាស លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត លោកជាធម្មកថិក ដំណើរអាក្រក់មិនមានដល់លោកទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់លោក ត្រូវអាបត្តិទុក្កដសិតគ្រប់ ៗ វាចា ។

[២៤៧] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផង់គ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ

បុក្កុសាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ តេសំ ទុគ្គតិ សុគតិយេវ តេសំ បាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤៨] ឧបសម្បន្នោ ឧបសម្បន្នំ ន ខុំសេតុកាមោ ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យតា ឯវំ វទេតិ យេ នូន ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណតិ ។ បេ ។ យេ នូន បណ្ឌិ-តា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤៩] ឧបសម្បន្នោ ឧបសម្បន្នំ ន ខុំសេតុកាមោ ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យតា ឯវំ វទេតិ ន មយំ ចណ្ឌាលា វេណា នេសាទា រថការា

ជាអ្នកចោលសំរាម ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក មនុស្សទាំងនោះ គ្មានគតិអាក្រក់ទេ មនុស្សទាំងនោះ មានតែគតិល្អម្យ៉ាង ត្រូវអាបត្តិទុក្កដាសិតគ្រប់ ៗ វាចា ។

[២៤៨] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា មនុស្សទាំងឡាយណាមួយ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ។ បេ ។ ថា មនុស្សទាំងឡាយណាមួយ ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ត្រូវអាបត្តិទុក្កដាសិតគ្រប់ ៗ វាចា ។

[២៤៩] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា យើងទាំងឡាយមិនមែនជាចណ្ឌាល មិនមែនជាជាងត្បាញផែងឫស្សី មិនមែនជាអ្នកនេសាទ មិនមែនជាជាងធ្វើរថ

បុក្កុសាតិ ភណតិ ។ បេ ។ ន មយំ បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ អម្ហាកំ ទុគ្គតិ សុគតិយេវ អម្ហាកំ ចាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤០] ឧបសម្បន្នោ អនុបសម្បន្នំ ន ខុំសេតុ-កាមោ ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យ-តា ហីនេន ហីនំ វទេតិ ។ បេ ។ ហីនេន ឧក្កដ្ឋំ វទេតិ ។ បេ ។ ឧក្កដ្ឋេន ហីនំ វទេតិ ។ បេ ។ ឧក្កដ្ឋេន ឧក្កដ្ឋំ វទេតិ បណ្ឌិតំ ព្យត្តំ មេធាវឹ ពហុស្សុតំ ធម្មកថិកំ បណ្ឌិតោសិ ព្យត្តោសិ មេធាវីសិ ពហុស្សុ-តោសិ ធម្មកថិកោសិ នត្ថិ តុយ្ហំ ទុគ្គតិ សុគតិយេវ តុយ្ហំ ចាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៤១] ឧបសម្បន្នោ អនុបសម្បន្នំ ន ខុំសេតុ-កាមោ ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យតា

មិនមែនជាអ្នកចោលសំរាម ។ បេ ។ ថា យើងទាំងឡាយមិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់មិនមានដល់យើងទាំងឡាយទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់យើងទាំងឡាយ ត្រូវអាបត្តិទុក្កដសិតគ្រប់ ៗ វាចា ។

[២៥០] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ថោកទាប ។ បេ ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ថោកទាប ។ បេ ។ ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ ។ បេ ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺនិយាយសំដៅអនុបសម្បន្នបុគ្គលដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា អ្នកឯងជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដំណើរអាក្រក់មិនមានដល់អ្នកឯងទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់អ្នកឯង ត្រូវអាបត្តិទុក្កដសិតគ្រប់ ៗ វាចា ។

[២៥១] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល

ឯវំ វទេតិ សន្តិ ឥធេកច្ចេ ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណតិ ។ បេ ។ សន្តិ ឥធេកច្ចេ បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ តេសំ ទុគ្គតិ សុគតិយេវ តេសំ បាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៥២] ឧបសម្បន្នោ អនុបសម្បន្នំ ន ខុំសេតុ-កាមោ ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យតា ឯវំ វទេតិ យេ នូន ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណតិ ។ បេ ។ យេ នូន បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៥៣] ឧបសម្បន្នោ អនុបសម្បន្នំ ន ខុំសេតុ-កាមោ ន វម្ភេតុកាមោ ន មង្កុកត្តុកាមោ ទវកម្យ-តា ឯវំ វទេតិ ន មយំ ចណ្ឌាលា វេណា នេសាទា

ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ។ បេ ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដំណើរអាក្រក់មិនមានដល់មនុស្សទាំងឡាយនោះទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់មនុស្សទាំងឡាយនោះ ត្រូវអាបត្តិទុក្កដសិតគ្រប់ ៗ វាចា ។

[២៥២] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា មនុស្សទាំងឡាយណាមួយ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសំរាម ។ បេ ។ ថា មនុស្សទាំងឡាយណាមួយ ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ត្រូវអាបត្តិទុក្កដសិតគ្រប់ ៗ វាចា ។

[២៥៣] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា យើងទាំងឡាយមិនមែនជាចណ្ឌាល មិនមែនជាជាងត្បាញផែងឫស្សី មិនមែនជាអ្នកនេសាទ

វេទកោ បុក្កុសោតិ ភណតិ ។ បេ ។ ន មយំ បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ អម្ហាកំ ទុគ្គតិ សុគតិយោ អម្ហាកំ ចាដិកង្ខាតិ ភណតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៩៤] អនាបត្តិ អត្ថបុរេក្ខារស្ស ធម្មបុរេក្ខារស្ស អនុសាសនីបុរេក្ខារស្ស ឧម្មត្តកស្ស ខិត្តចិត្តស្ស វេទ-នដ្ដស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។

*មិនមែនជាជាងធ្វើរថ មិនមែនជាអ្នកចោលសំរាម ។ បេ ។ ថា យើង ទាំងឡាយ មិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់មិនមាន ដល់យើងទាំងឡាយទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់យើងទាំងឡាយ ត្រូវអាបត្តិទុក្កដសិតគ្រប់ ៗ វាចា ។*

[២៥២] *អាបត្តិមិនមានដល់ភិក្ខុធ្វើសេចក្តីអធិប្បាយ ជាប្រធាន*[១] *ដល់ភិក្ខុធ្វើធម៌ជាប្រធាន*[២] *ដល់ភិក្ខុធ្វើពាក្យប្រៀនប្រដៅជាប្រធាន*[៣] *ដល់ភិក្ខុឆ្កួត ដល់ភិក្ខុមានចិត្តរវើរវាយ ដល់ភិក្ខុដែលវេទនាគ្របសង្កត់ ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។*

សិក្ខាបទទី ២ ចប់ ។

---

១ ភិក្ខុពណ៌នានូវសេចក្តីអធិប្បាយរបស់បាលី ។ ២ ភិក្ខុបង្រៀនបាលី ។ ៣ ភិក្ខុអាស្រ័យពាក្យប្រៀនប្រដៅ ហើយនិយាយដោយន័យជាដើមថា អ្នកឯងជាចណ្ឌាល អ្នកឯងកុំធ្វើបាប អ្នកឯងបានជាងងឹតហើយ កុំឲ្យងងឹតទៅទៀតឡើយ ។

# តតិយសិក្ខាបទំ

[២៨៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ បេសុញ្ញំ ឧបសំហរន្តិ ឥមស្ស[១] សុត្វា អមុស្ស[២] អក្ខាយន្តិ ឥមស្ស ភេទាយ អមុស្ស សុត្វា ឥមស្ស អក្ខាយន្តិ អមុស្ស ភេទាយ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ បេសុញ្ញំ ឧបសំហរិស្សន្តិ ឥមស្ស សុត្វា អមុស្ស អក្ខាយិស្សន្តិ ឥមស្ស ភេទាយ អមុស្ស

---

១-២ កត្ថចិ បោត្ថកេ ឥមេសំ សុត្វា អមុស្សន្តិ ទិស្សតិ តតោ បរំ អមុស្សិមស្សាតិ បទំ ពហុវចនវសេនេវ យោជិតំ ។

# សិក្ខាបទទី ៣

[២៥៥] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុតែងពាំនាំពាក្យញុះញង់របស់ភិក្ខុទាំងឡាយដែលបង្កហេតុប្រកួតប្រកាន់ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះហើយយកទៅនិយាយប្រាប់ភិក្ខុខាងណោះ ដើម្បីបំបែកភិក្ខុខាងណេះ ឮពាក្យភិក្ខុខាងណោះហើយ យកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ព្រោះហេតុនោះ សេចក្តីកហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើងផង សេចក្តីកហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនដោយក្រៃលែងឡើងផង ។ ពួកភិក្ខុណាមួយដែលជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីបានជាពួកឆព្វគ្គិយភិក្ខុតែងពាំនាំពាក្យញុះញង់របស់ភិក្ខុទាំង-ឡាយ ដែលបង្កហេតុប្រកួតប្រកាន់ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះហើយយកទៅនិយាយប្រាប់ភិក្ខុខាងណោះ ដើម្បីបំបែកភិក្ខុខាងណេះ

២៧៣

## បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស តតិយសិក្ខាបទស្ស បទភាជនីយំ

សុត្វា ឥមស្ស អក្ខាយិស្សន្តិ អមុស្ស ភេទាយ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ បេសុញ្ញំ ឧបសំហ-រថ ឥមស្ស សុត្វា អមុស្ស អក្ខាយថ ឥមស្ស ភេទាយ អមុស្ស សុត្វា ឥមស្ស អក្ខាយថ អមុស្ស ភេទាយ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ បេសុញ្ញំ ឧបសំហរិស្សថ ឥមស្ស សុត្វា អមុស្ស

ឮពាក្យភិក្ខុខាងណោះហើយយកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ព្រោះហេតុនោះ សេចក្តីបង្កហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើងផង សេចក្តីបង្កហេតុទាំងឡាយដែលបានកើតឡើងហើយ ក៏រឹងរឹតតែចម្រើនដោយក្រៃលែងផង ។ គ្រានោះពួកភិក្ខុទាំងនោះ ក៏បានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថាអ្នកទាំងឡាយតែងពាំនាំពាក្យញុះញង់របស់ភិក្ខុទាំងឡាយ ដែលបង្កហេតុប្រកួតប្រកាន់ ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះហើយយកទៅនិយាយប្រាប់ភិក្ខុខាងណោះ ដើម្បីបំបែកភិក្ខុខាងណេះ ឮពាក្យភិក្ខុខាងណោះហើយយកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ព្រោះហេតុនោះ សេចក្តីបង្កហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើងផង សេចក្តីបង្កហេតុទាំងឡាយដែលបានកើតឡើងហើយ ក៏រឹងរឹតតែចម្រើនដោយក្រៃលែងឡើងផង (រឿងនេះ) ពិតឬ ។ ពួកឆព្វគ្គិយភិក្ខុ ក៏ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ មិនសមបើអ្នកទាំងឡាយនឹងពាំនាំពាក្យញុះញង់របស់ពួកភិក្ខុដែលបង្កហេតុ ប្រកួតប្រកាន់ ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះហើយយកទៅនិយាយប្រាប់ភិក្ខុខាងណោះ

អក្ខាយិស្សថ ឥមស្ស ភេទាយ អមុស្ស សុត្វា ឥមស្ស អក្ខាយិស្សថ អមុស្ស ភេទាយ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ភិក្ខុ បេសុញ្ញេ បាចិត្តិយន្តិ ។

[២៨៦] បេសុញ្ញំ នាម ទ្វីហាការេហិ បេសុញ្ញំ ហោតិ បិយកម្យស្ស វា ភេទាធិប្បាយស្ស វា ។ ទសហិ អាការេហិ បេសុញ្ញំ ឧបសំហរតិ ជាតិតោបិ នាមតោបិ គោត្តតោបិ កម្មតោបិ សិប្បតោបិ អាពាធ-តោបិ លិង្គតោបិ កិលេសតោបិ អាបត្តិតោបិ អក្កោ-សតោបិ ។ ជាតិ នាម ទ្វេ ជាតិយោ ហីនា ច ជាតិ ឧក្កដ្ឋា ច ជាតិ ។ ហីនា នាម ជាតិ ចណ្ឌាលជាតិ វេណជាតិ នេសាទជាតិ រថការជាតិ

ដើម្បីបំបែកភិក្ខុខាងណេះ ឮពាក្យភិក្ខុខាងណោះ ហើយយកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ម៉្លោះហើយ សេចក្តីបង្កហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើងផង សេចក្តីបង្កហេតុទាំងឡាយដែលបានកើតឡើងហើយ ក៏រឹងរឹតតែចម្រើនដោយក្រៃលែងឡើងផង ម្នាលមោឃបុរសទាំងឡាយ កម្មដែលអ្នករាល់គ្នាធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាផង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះពោលពាក្យញុះញង់ភិក្ខុផងគ្នា ។

[២៥៦] ដែលហៅថា ពាក្យញុះញង់ គឺ ញុះញង់ដោយអាការពីរយ៉ាង បានខាងឯបុគ្គលចង់ឲ្យគេស្រឡាញ់ខ្លួន ១ ចង់បំបែកគេ ១ ។ ភិក្ខុពាំនាំពាក្យញុះញង់ដោយអាការ ១០ យ៉ាង គឺ ដោយជាតិក្តី ដោយនាមក្តី ដោយគោត្តក្តី ដោយការងារក្តី ដោយសិល្បសាស្ត្រក្តី ដោយអាពាធក្តី ដោយភេទក្តី ដោយធម៌ជាគ្រឿងសៅហ្មងក្តី ដោយអាបត្តិក្តី ដោយពាក្យជេរក្តី ។ ដែលហៅថា ជាតិ គឺ ជាតិមានពីរយ៉ាង បានខាងជាតិថោកទាប ១ ជាតិខ្ពង់ខ្ពស់ ១ ។ ដែលហៅថា ជាតិថោកទាបនោះ គឺ ជាតិចណ្ឌាល ជាតិជាងផែង ជាតិអ្នកនេសាទ ជាតិជាងរថ

បុក្កុសជាតិ ឯសា ហីនា នាម ជាតិ ។ ឧក្កដ្ឋា នាម ជាតិ ខត្តិយជាតិ ព្រាហ្មណជាតិ ឯសា ឧក្កដ្ឋា នាម ជាតិ ។ បេ ។ អក្កោសោ នាម ទ្វេ អក្កោសា ហីនោ ច អក្កោសោ ឧក្កដ្ឋោ ច អក្កោសោ ។ ហីនោ នាម អក្កោសោ ឱដ្ឋោសិ មេណ្ឌោសិ គោ-ណោសិ គទ្រភោសិ តិរច្ឆានគតោសិ នេរយិកោសិ នត្ថិ តុយ្ហំ សុគតិ ទុគ្គតិយេវ តុយ្ហំ បាដិកង្ខាតិ យការេន វា ភការេន វា កាដកោដចិកាយ វា ឯសោ ហីនោ នាម អក្កោសោ ។ ឧក្កដ្ឋោ នាម អក្កោសោ បណ្ឌិតោសិ ព្យត្តោសិ មេធាវីសិ ពហុស្សុតោសិ ធម្មកថិកោសិ នត្ថិ តុយ្ហំ ទុគ្គតិ សុគតិយេវ តុយ្ហំ បាដិកង្ខាតិ ឯសោ ឧក្កដ្ឋោ នាម អក្កោសោ ។

[២៨៧] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ

ជាតិអ្នកចោលសំរាម ប៉ុណ្ណោះឈ្មោះថា ជាតិថោកទាប ។ ដែលហៅថា ជាតិខ្ពង់ខ្ពស់នោះ គឺ ជាតិក្សត្រ ជាតិព្រាហ្មណ៍ ប៉ុណ្ណោះឈ្មោះថា ជាតិខ្ពង់ខ្ពស់ ។ បេ ។ ដែលហៅថា ពាក្យជេរនោះ គឺ ពាក្យជេរមានពីរយ៉ាង បានខាងពាក្យជេរដ៏ថោកទាប ១ ពាក្យជេរដ៏ខ្ពង់ខ្ពស់ ១ ។ ដែលហៅថា ពាក្យជេរដ៏ថោកទាបនោះ គឺ ជេរថា អ្នកឯងជាសត្វឱដ្ឋ អ្នកឯងជាពពែ អ្នកឯងជាគោ អ្នកឯងជាលា អ្នកឯងជាសត្វតិរច្ឆាន អ្នកឯងជាសត្វនរក សុគតិរបស់អ្នកឯងគ្មានទេ ទុគ្គតិតែម្យ៉ាងនឹងប្រាកដដល់អ្នកឯង ពុំនោះសោត ជេរដោយ យអក្ខរៈ[១] ឬដោយ ភអក្ខរៈ ឬមួយដោយបុរិសនិមិត្ត និងឥត្ថីនិមិត្ត ប៉ុណ្ណោះឈ្មោះថា ពាក្យជេរដ៏ថោកទាប ។ ដែលហៅថា ពាក្យជេរដ៏ខ្ពង់ខ្ពស់នោះ គឺ ជេរថា អ្នកឯងជាបណ្ឌិត អ្នកឯងជាមនុស្សឈ្លាស អ្នកឯងជាអ្នកប្រាជ្ញ អ្នកឯងជាពហុស្សូត អ្នកឯងជាធម្មកថិក ទុគ្គតិរបស់អ្នកឯងគ្មានទេ សុគតិតែម្យ៉ាងនឹងប្រាកដដល់អ្នកឯង ប៉ុណ្ណោះឈ្មោះថា ពាក្យជេរដ៏ខ្ពង់ខ្ពស់ ។

[២៩៧] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុហើយ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយ

១ ត្រង់ យ អក្ខរ និង ភ អក្ខរ ជាឈ្មោះមេថុនធម្ម ។

តំ ចណ្ឌាលោ វេណោ នេសាទោ រថការោ បុក្កុសោតិ ភណាតីតិ អាបត្តិ វាចាយ វាចាយ ទាចិត្តិយស្ស ។

[២៥៨] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ ខត្តិយោ ព្រាហ្មណោតិ ភណាតីតិ អាបត្តិ វាចាយ វាចាយ ទាចិត្តិយស្ស ។

[២៥៩] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ អវកណ្ណកោ ជវកណ្ណកោ ធនិដ្ឋកោ សវិដ្ឋកោ កុលវឌ្ឍកោតិ ភណាតីតិ អាបត្តិ វាចាយ វាចាយ ទាចិត្តិយស្ស ។

[២៦០] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ ពុទ្ធរក្ខិតោ ធម្មរក្ខិតោ សង្ឃរក្ខិតោតិ ភណាតីតិ អាបត្តិ វាចាយ វាចាយ ទាចិត្តិយស្ស ។

ចំពោះលោកថា លោកជាជាតិចណ្ឌាល ជាតិជាងផែង ជាតិអ្នកនេសាទ ជាតិជាងរថ ជាតិអ្នកចោលសំរាម (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៥៨] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាក្សត្រ ជាព្រាហ្មណ៍ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៥៩] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកឈ្មោះអវកណ្ណក[១] ឈ្មោះជវកណ្ណក ឈ្មោះធនិដ្ឋក ឈ្មោះសវិដ្ឋក ឈ្មោះកុលវឌ្ឍក (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៦០] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកឈ្មោះពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

---

១ ពាក្យទាំងនេះជាឈ្មោះរបស់មនុស្សដែលជាខ្ញុំបម្រើគេ ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស តតិយសិក្ខាបទស្ស បទភាជនីយំ

[២៦១] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ កោសិយោ ភារទ្វាជោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៦២] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ គោតមោ មោគ្គល្លានោ កច្ចាយនោ វាសេដ្ឋោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៦៣] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ កោដ្ឋកោ បុប្ផឆឌ្ឌកោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៦៤] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ កសកោ វាណិជោ គោរក្ខោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

បាចិត្តិយកណ្ឌ មុសាវាទវគ្គ សិក្ខាបទទី ៣ បទភាជនីយ

[២៦១] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាកោសិយគោត្ត ភារទ្វាជគោត្ត (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៦២] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាគោតមគោត្ត មោគ្គល្លានគោត្ត កច្ចាយនគោត្ត វាសេដ្ឋ-គោត្ត (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៦៣] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាជាងចាំង ជាអ្នកចោលនូវផ្កា (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៦៤] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាអ្នកភ្ជួររាស់ ជាអ្នកជួញ ជាអ្នករក្សាគោ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៦៥] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ នឡការោ កុម្ភការោ បេសការោ ចម្មការោ នហាបិតោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៦៦] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ មុទ្ទិកោ គណកោ លេខកោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៦៧] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ កុដ្ឋិកោ គណ្ឌិកោ កិលាសិកោ សោសិកោ អបមារិកោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៦៨] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ មធុមេហិកោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៦៥] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាជាងផែងបបុស ជាស្មូនឆ្នាំង ជាជាងតម្បាញ ជាជាងស្បែក ជាខ្មាន់ព្រះកេស (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៦៦] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាអ្នករាប់ដៃទទេ ជាហោរ ជាស្មៀន (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៦៧] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះពោលចំពោះលោកថា លោកជាមនុស្សឃ្វង់ ជាមនុស្សដំបៅពក ជាមនុស្សស្រែង ជាមនុស្សកើតរោគរីងរៃ ជាមនុស្សឆ្កួតជ្រូក (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៦៨] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាមនុស្សកើតរោគប្រមេះផ្អែម (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស តតិយសិក្ខាបទស្ស បទភាជនីយំ

[២៦៩] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧប-សម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ អតិជី-យោ អតិវស្សោ អតិកណ្ណោ អចេ្ចាជាតោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២៧០] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ ជាតិជីយោ ជាតិវស្សោ ជាតិកណ្ណោ ជាចេ្ចាជាតោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២៧១] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ រាគបរិយុដ្ឋិតោ ទោសបរិយុដ្ឋិតោ មោហបរិយុដ្ឋិតោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

[២៧២] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ វីតរាគោ វីតទោសោ វីតមោហោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ ចាចិត្តិយស្ស ។

បាចិត្តិយកណ្ឌ មុសាវាទវគ្គ សិក្ខាបទទី ៣ បទភាជនីយ

[២៦៩] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាបុគ្គលខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយារាល់ ៗ ម៉ាត់ ។

[២៧០] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាបុគ្គលមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៧១] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាបុគ្គលមានរាគៈរួបរឹតហើយ មានទោសៈរួបរឹតហើយ មានមោហៈរួបរឹតហើយ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៧២] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាមនុស្សប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៧៣] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ បារាជិកំ អជ្ឈាបន្នោ សង្ឃាទិសេសំ អជ្ឈាបន្នោ ថុល្លច្ចយំ អជ្ឈាបន្នោ បាចិត្តិយំ អជ្ឈាបន្នោ បាដិទេសនីយំ អជ្ឈាបន្នោ ទុក្កដំ អជ្ឈាបន្នោ ទុព្ភាសិតំ អជ្ឈាបន្នោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៧៤] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ សោតាបន្នោតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៧៥] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ ឱដ្ឋោ មេណ្ឌោ គោណោ គទ្រភោ តិរច្ឆានគតោ នេរយិកោ នត្ថិ តស្ស សុគតិ ទុគ្គតិយេវ តស្ស បាដិកង្ខាតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៧៣] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកត្រូវអាបត្តិបារាជិកហើយ ត្រូវអាបត្តិសង្ឃាទិសេសហើយ ត្រូវអាបត្តិថុល្លច្ច័យហើយ ត្រូវអាបត្តិបាចិត្តិយហើយ ត្រូវអាបត្តិបាដិទេសនីយហើយ ត្រូវអាបត្តិទុក្កដហើយ ត្រូវអាបត្តិទុព្ភាសិតហើយ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៧៤] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាបុគ្គលដល់ហើយនូវសោតាបត្តិផល (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៧៥] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាសត្វឱដ្ឋ ជាសត្វពពែ ជាសត្វគោ ជាសត្វលា ជាសត្វតិរច្ឆាន ជាសត្វនរក សុគតិរបស់លោកគ្មានទេ ទុគ្គតិតែម្យ៉ាងនឹងប្រាកដដល់លោក (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស តតិយសិក្ខាបទស្ស បទភាជនីយំ

[២៧៦] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ តំ បណ្ឌិតោ ព្យត្តោ មេធាវី ពហុស្សុតោ ធម្មកថិកោ នត្ថិ តស្ស ទុគ្គតិ សុគតិយេវ តស្ស បាដិកង្ខាតិ ភណតីតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។

[២៧៧] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ សន្តិ ឥធេកច្ចេ ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណតិ ន សោ អញ្ញំ ភណតិ តញ្ញេវ ភណតីតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៧៨] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ សន្តិ ឥធេកច្ចេ ខត្តិយា ព្រាហ្មណាតិ ភណតិ ន សោ អញ្ញំ ភណតិ តញ្ញេវ ភណតីតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។ បេ ។

បាចិត្តិយកណ្ឌ មុសាវាទវគ្គ សិក្ខាបទទី ៣ បទភាជនីយ

[២៧៦] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ទុគ្គតិរបស់លោកគ្មានទេ សុគតិតែម្យ៉ាងនឹងប្រាកដដល់លោក (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។

[២៧៧] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះ និយាយថា ក្នុងលោកនេះ ជនពួកខ្លះ ជាចណ្ឌាល ជាជាងផែង ជាអ្នកនេសាទ ជាជាងរថ ជាអ្នកចោលសំរាម ក៏សិងមាន ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ) មិនមែនពោលឲ្យអ្នកដទៃទេ ពោលចំពោះលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ ៗ ម៉ាត់ ។

[២៧៨] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ក្នុងលោកនេះ ជនពួកខ្លះជាក្សត្រ ជាព្រាហ្មណ៍ ក៏សិងមាន ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ) មិនមែនពោលឲ្យអ្នកដទៃទេ គឺពោលចំពោះលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ ៗ ម៉ាត់ ។បេ។

[២៧៩] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ សទ្ធិ ឥជេកាច្ចេ បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ តេសំ ទុគ្គតិ សុគតិយេវ តេសំ បាដិកង្ខាតិ ភណតិ ន សោ អញ្ញំ ភណតិ តញ្ញេវ ភណតីតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៨០] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ យេ ឆ្វន ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណតិ ន សោ អញ្ញំ ភណតិ តញ្ញេវ ភណតីតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។ បេ ។ ឧប-សម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ យេ ឆ្វន បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ តេសំ ទុគ្គតិ

[២៧៩] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ក្នុងលោកនេះ ជនទាំងឡាយពួកខ្លះ ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ក៏សិងមាន ទុគ្គតិរបស់លោកទាំងនោះគ្មានទេ សុគតិតែម្យ៉ាង នឹងប្រាកដដល់លោកទាំងនោះ ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ) មិនមែនពោលឲ្យអ្នកដទៃទេ គឺពោលចំពោះលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ ៗ ម៉ាត់ ។

[២៨០] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ជនពួកណា ពិតជាចណ្ឌាល ជាជាងផែង ជាអ្នកនេសាទ ជាជាងរថ ជាអ្នកចោលសំរាម ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ) មិនមែនពោលឲ្យអ្នកដទៃទេ គឺពោលចំពោះលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ ៗ ម៉ាត់ ។ បេ ។ ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា ហើយនាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ជនពួកណា ពិតជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ទុគ្គតិរបស់ជនទាំងនោះគ្មានទេ

១៨៣



សុគតិយោ តេសំ ចាជិកង្ខាតិ ភណាតិ ន សោ អញ្ញំ ភណាតិ តញ្ញេវ ភណាតីតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

[២៨១] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ ន មយំ ចណ្ឌាលា វេណា នេសាទា រថការា បុក្កុសាតិ ភណាតិ ន សោ អញ្ញំ ភណាតិ តញ្ញេវ ភណាតីតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។ បេ ។ ឧប-សម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ ឥត្ថន្នាមោ ន មយំ បណ្ឌិតា ព្យត្តា មេធាវិនោ ពហុស្សុតា ធម្មកថិកា នត្ថិ អម្ហាកំ ទុគ្គតិ សុគតិយោ អម្ហាកំ ចាជិកង្ខាតិ ភណាតិ ន សោ អញ្ញំ ភណាតិ តញ្ញេវ ភណាតីតិ អាបត្តិ វាចាយ វាចាយ ទុក្កដស្ស ។

សុគតិតែម្យ៉ាងនឹងប្រាកដដល់ជនទាំងនោះ ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ) មិនមែនពោលឲ្យអ្នកដទៃទេ គឺពោលចំពោះលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ ៗ ម៉ាត់ ។

[២៨១] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា យើងទាំងឡាយ មិនមែនជាចណ្ឌាល មិនមែនជាជាងផែង មិនមែនជាអ្នកនេសាទ មិនមែនជាជាងរថ មិនមែនជាអ្នកចោលសំរាម ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ) មិនមែនពោលឲ្យអ្នកដទៃទេ គឺពោលសំដៅលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ ៗ ម៉ាត់ ។ បេ ។ ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា ហើយនាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា យើងទាំងឡាយ មិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ទុគ្គតិរបស់ពួកយើងគ្មានទេ សុគតិតែម្យ៉ាងនឹងប្រាកដដល់ពួកយើង ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ) មិនមែនពោលឲ្យអ្នកដទៃទេ គឺពោលសំដៅលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ ៗ ម៉ាត់ ។

[២៨២] ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ អាបត្តិ វាចាយ វាចាយ បាចិត្តិយស្ស ។ ឧបសម្បន្នោ ឧបសម្បន្នស្ស សុត្វា អនុបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ អាបត្តិ ទុក្កដស្ស ។ ឧបសម្បន្នោ អនុបសម្បន្នស្ស សុត្វា ឧបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ អាបត្តិ ទុក្កដស្ស ។ ឧបសម្បន្នោ អនុបសម្បន្នស្ស សុត្វា អនុបសម្បន្នស្ស បេសុញ្ញំ ឧបសំហរតិ អាបត្តិ ទុក្កដស្ស ។

[២៨៣] អនាបត្តិ នបិ្បយកម្យស្ស នភេទាធិប្បា-យស្ស ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។

[២៨២] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀត ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់ ។ ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា ហើយនាំពាក្យញុះញង់ទៅប្រាប់អនុបសម្បន្នបុគ្គល ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្នភិក្ខុ ឮពាក្យរបស់អនុបសម្បន្នបុគ្គលហើយ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុ ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្នភិក្ខុ ឮពាក្យរបស់អនុសម្បន្នបុគ្គលហើយ នាំពាក្យញុះញង់ទៅប្រាប់អនុបសម្បន្នបុគ្គល ត្រូវអាបត្តិទុក្កដ ។

[២៨៣] អាបត្តិមិនមាន ដល់ភិក្ខុអ្នកមិនចង់ឲ្យគេស្រឡាញ់ខ្លួន ដល់ភិក្ខុមិនប្រាថ្នាឲ្យគេបែកគ្នា ដល់ភិក្ខុឆ្កួត ដល់ភិក្ខុខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៣ ចប់ ។

# ចតុត្ថសិក្ខាបទំ

[២៨៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧបាសកេ បទសោ ធម្មំ វាចេន្តិ ។ ឧបាសកា ភិក្ខូសុ អគារវា អប្បតិស្សា អសភាគវុត្តិកា វិហរន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ឧបាសកេ បទសោ[១] ធម្មំ វាចេស្សន្តិ ឧបាសកា ភិក្ខូសុ អគារវា អប្បតិស្សា អសភាគវុត្តិកា វិហរន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ឧបាសកេ បទសោ ធម្មំ វាចេថ ឧបាសកា ភិក្ខូសុ អគារវា អប្បតិស្សា អសភាគវុត្តិកា វិហរន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ

---

១ បទសោតិ បទំ ធម្មន្តិ បទស្ស វិសេសនន្តិ យោជនា ។

# សិក្ខាបទទី ៤

[២៨២] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគកាលគង់នៅវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបង្ហាញធម៌ជាបទចំពោះពួកឧបាសក ។ ឧបាសកទាំងឡាយ ក៏ទៅជាមិនមានសេចក្តីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា មិនសមបីបើពួកឆព្វគ្គិយភិក្ខុបង្ហាញធម៌ជាបទចំពោះឧបាសកទាំងឡាយ ៗ ក៏ទៅជាមិនមានសេចក្តីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ ។ គ្រានោះឯង ពួកភិក្ខុទាំងនោះ ក៏ក្រាបទូលរឿងនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយបង្ហាញធម៌ជាបទចំពោះឧបាសកទាំងឡាយ ៗ ក៏ទៅជាមិនមានសេចក្តីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ (រឿងនេះ) ពិតឬ ។ ភិក្ខុទាំងនោះ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ

ឆាម តុម្ហេ មោឃបុរិសា ឧចាសកោ បឋសោ ជម្មំ ភាចេស្សថ ឧចាសកា ភិក្ខូសុ អគារវា អប្បតិស្សា អសភាគវុត្តិកា វិហរន្តិ នេតំ មោឃបុរិសា អប្ប-សន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អនុបសម្បន្នំ បឋសោ ជម្មំ វាចេយ្យ ចាចិត្តិយន្តិ ។

[១៨៥] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អនុបសម្បន្នោ នាម ភិក្ខុញ្ច ភិក្ខុនិញ្ច ឋបេត្វា អវសេសោ អនុបសម្បន្នោ នាម ។

[១៨៦] បឋសោ នាម[១] បទំ អនុបទំ អន្វក្ខរំ អនុព្យញ្ជនំ ។ បទំ នាម ឯកតោ បដ្ឋបេត្វា ឯកតោ ឱសាបេន្តិ ។ អនុបទំ នាម ចាដេក្កំ បដ្ឋបេត្វា ឯកតោ ឱសាបេន្តិ ។ អន្វក្ខរំ នាម រូបំ អនិច្ចន្តិ វុច្ចមានោ រូតិ ឱចាតេតិ ។ អនុព្យញ្ជនំ នាម

---

១ ឱរោបិយបោត្ថកេ ឥទំ បាឋទ្វយំ ន ទិស្សតិ ។

មិនសមបីអ្នកទាំងឡាយបង្ហាញធម៌ជាបទចំពោះពួកឧបាសក ៗ ក៏ទៅជាមិនមានសេចក្តីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ ម្នាលបុរសទទេទាំងឡាយ កម្មដែលអ្នកទាំងឡាយធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយបង្រៀនធម៌ជាបទចំពោះអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ ។

[២៨៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា អនុបសម្បន្ននោះ គឺជនទាំងអស់ លើកលែងតែភិក្ខុ និងភិក្ខុនីចេញ ហៅថា អនុបសម្បន្ន ។

[២៨៦] ដែលហៅថា បទនោះ គឺបទ ១ អនុបទ ១ អន្វក្ខរៈ ១ អនុព្យញ្ជនៈ[១] ១ ។ ដែលហៅថា ជាបទនោះ គឺឧបសម្បន្នទាំងអនុបសម្បន្នផ្តើមតាំងព្រមគ្នា បញ្ចប់ព្រមគ្នា ។ ដែលហៅថា ជាអនុបទនោះ គឺឧបសម្បន្នទាំងអនុបសម្បន្នផ្តើមតាំងផ្សេងគ្នា បញ្ចប់ព្រមគ្នា ។ ដែលហៅថា អន្វក្ខរៈនោះ គឺ ឧបសម្បន្នប្រាប់អនុបសម្បន្នថា រូបំ អនិច្ចំ អនុបសម្បន្នទទួលថា រូព្រមគ្នា ។ ដែលហៅថា ជាអនុព្យញ្ជនៈនោះគឺ ឧបសម្បន្នប្រាប់

---

១ អក្សរមួយ ៗ ហៅថា អន្វក្ខរៈប្រជុំនៃអក្ខរៈមួយសព្ទ ៗ ហៅថា អនុព្យញ្ជនៈប្រជុំនៃអក្ខរៈនិងអនុព្យញ្ជនៈហៅថា បទ បទទី ១ ហៅថា បទ បទទី ២ ហៅថា អនុបទ ។

រូបំ អនិច្ចន្តិ វុច្ចមានោ វេទនា អនិច្ចាតិ សទ្ទំ និច្ឆា-រេតិ ។ យញ្ច បទំ យញ្ច អនុបទំ យញ្ច អន្វក្ខរំ យញ្ច អនុព្យញ្ជនំ សព្វមេតំ បទសោ ធម្មោ[១] នាម ។ ធម្មោ នាម ពុទ្ធភាសិតោ សាវកភាសិតោ ឥសិភាសិ-តោ ទេវតាភាសិតោ អត្ថុបសញ្ហិតោ ធម្មុបសញ្ហិតោ ។ វាចេយ្យាតិ បទេន វាចេតិ បទេ បទេ អាបត្តិ ចាចិត្តិយស្ស ។ អក្ខរាយ វាចេតិ អក្ខរក្ខរាយ អាបត្តិ ចាចិត្តិយស្ស ។

[២៨៧] អនុបសម្បន្នេ អនុបសម្បន្នសញ្ញី បទសោ ធម្មំ វាចេតិ អាបត្តិ ចាចិត្តិយស្ស ។ អនុបសម្បន្នេ វេមតិកោ បទសោ ធម្មំ វាចេតិ អាបត្តិ ចាចិត្តិ-យស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី បទសោ ធម្មំ វាចេតិ អាបត្តិ ចាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ ឧបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឧបសម្បន្នេ ឧប-សម្បន្នសញ្ញី អនាបត្តិ ។

១ អតិរេកបាឋេន ភវិតព្វំ ។

អនុបសម្បន្នថា រូបំ អនិច្ចំ អនុបសម្បន្នបញ្ចេញសំឡេង (ដោយរហ័ស) ថា វេទនា អនិច្ចា[១] ដូច្នេះ ឈ្មោះថា បង្រៀនជាអនុព្យញ្ជនៈ ។ បទណាក្តី អនុបទណាក្តី អន្វក្ខរៈណាក្តី អនុព្យញ្ជនៈណាក្តី ទាំងអស់នុ៎ះ ឈ្មោះថា ធម៌ជាបទ (គឺជាចំណែក) ។ ពាក្យដែលជាពុទ្ធភាសិត សាវកភាសិត ឥសិភាសិត ទេវតាភាសិត ដែលអាស្រ័យនូវអដ្ឋកថា អាស្រ័យនូវបាលី ឈ្មោះថា ធម៌ ។ ពាក្យថា បង្រៀន សេចក្តីថា ភិក្ខុបង្រៀនដោយបទ ត្រូវអាបត្តិបាចិត្តិយរាល់ ៗ បទ ។ ភិក្ខុបង្រៀនដោយអក្ខរៈ ត្រូវអាបត្តិបាចិត្តិយរាល់ ៗ អក្ខរៈ ។

[២៨៧] អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្នពិតមែនហើយ បង្រៀនធម៌ជាបទ ត្រូវអាបត្តិបាចិត្តិយ ។ អនុបសម្បន្នពិតមែន តែភិក្ខុមានសេចក្តីសង្ស័យ ហើយបង្រៀនធម៌ជាបទ ត្រូវអាបត្តិបាចិត្តិយ ។ អនុបសម្បន្ន តែភិក្ខុសំគាល់ថា ឧបសម្បន្នទៅវិញ ហើយបង្រៀនធម៌ជាបទ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន តែភិក្ខុសំគាល់ថា អនុបសម្បន្នទៅវិញ ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្ន តែភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្នពិតមែន មិនត្រូវអាបត្តិ ។

---

១ ភិក្ខុប្រាប់ថា រូបំ អនិច្ចំ សាមណេរចាប់សូត្រថា វេទនា អនិច្ចា បទខាងដើមគឺ រូបំ និង វេទនានោះថាផ្សេងគ្នា ដល់បទខាងចុងគឺ អនិច្ចំនិងអនិច្ចានោះថាត្រូវស្មើគ្នា គឺស្មើត្រង់ថា អនិច្ច អនិច្ចនោះឯង ។

[២៨៨] អនាបត្តិ ឯកតោ ឧទ្ទិសាបេន្តោ[១] ឯកតោ សជ្ឈាយំ ករោន្តោ[២] យេភុយ្យេន បគុណំ គន្ថំ ភណន្តំ ឱបាតេតិ[៣] ឱសារេន្តំ ឱបាតេតិ[៤] ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។

---

១ តព្វណ្ណនាយំ ឯកតោ ឧទ្ទិសាបេន្តោតិ អនុបសម្បន្នេន សទ្ធឹ ឯកតោ ឧទ្ទេសំ គណ្ហន្តោបិ ឯកតោ វទតិ អនាបត្តីតិ អត្ថោ ។ ល ។ ២ ឯកតោ សជ្ឈាយំ ករោន្តោតិ អនុបសម្បន្នេន សទ្ធឹ ឧបសម្បន្នោ ឯកតោ សជ្ឈាយំ ករោន្តោ តេន សទ្ធឹយេវ ភណតិ អនាបត្តិ ។ ល ។ ៣ យេភុយ្យេន បគុណំ គន្ថំ ភណន្តំ ឱបាតេតីតិ សចេ ឯកគាថាយ ឯកោ បាទោ ន អាគច្ឆតិ សេសំ អាគច្ឆតិ អយំ យេភុយ្យេន បគុណគន្ថោ នាម ។ ល ។ ៤ ឱសារេន្តំ ឱបាតេតីតិ សុត្តំ ឧច្ចារេន្តំ បរិសមជ្ឈេ បរិសង្កមានំ ឯវំ វទេហីតិ តេន សទ្ធឹ ឯកតោបិ វទន្តស្ស អនាបត្យាទិ វុត្តំ ។

[២៨៨] *អាបត្តិមិនមានដល់ភិក្ខុរៀនបាលីជាមួយ*[១] *(នឹងអនុបសម្បន្ន) ដល់ភិក្ខុស្វាធ្យាយជាមួយ*[២] *(នឹងអនុបសម្បន្ន) ដល់ភិក្ខុកំពុងសូត្រគម្ពីរដែលស្ទាត់ដោយច្រើន*[៣] *ដល់ភិក្ខុថា ជាមួយនឹងអនុបសម្បន្នកំពុងសូត្រធម៌*[៤] *ដល់ភិក្ខុឆ្កួត ដល់ភិក្ខុអ្នកដើមបញ្ញត្តិ ។*

សិក្ខាបទទី ៤ ចប់ ។

---

១ ក្នុងអដ្ឋកថា ថា ១ ភិក្ខុរៀនបាលីជាមួយនឹងអនុបសម្បន្ន ថាព្រមគ្នា មិនត្រូវអាបត្តិឡើយ ។ ល ។ ២ ភិក្ខុស្វាធ្យាយជាមួយនឹងអនុបសម្បន្ន សូត្រព្រមគ្នាជាមួយនឹងអនុបសម្បន្ននោះ មិនត្រូវអាបត្តិឡើយ ។ ល ។ ៣ បើក្នុងគាថាមួយ (បួនបាទ) អនុបសម្បន្នបានចេះស្ទាត់បីបាទហើយ នៅមិនទាន់ស្ទាត់តែមួយបាទ អនុបសម្បន្នចេះ ហៅថា មានគន្ថស្ទាត់ហើយដោយច្រើន ។ ល ។ ៤ កាលបើអនុបសម្បន្នកំពុងសូត្រនូវសុត្ត រអាក់រអួលក្នុងកណ្តាលបរិសទ្យ ភិក្ខុបង្គាប់ថា អ្នកឯងចូរសូត្រយ៉ាងនេះទៅ (បង្គាប់យ៉ាងនេះហើយ) ទុកជាថាព្រមគ្នាជាមួយនឹងអនុបសម្បន្ននោះទៅ ក៏មិនត្រូវអាបត្តិឡើយ ។

# បញ្ចមសិក្ខាបទំ

[២៨៩] តេន សមយេន ពុទ្ធោ ភគវា អាឡ-
វិយំ វិហរតិ អគ្គាឡវេ ចេតិយេ ។ តេន ខោ បន
សមយេន ឧបាសកា អារាមំ អាគច្ឆន្តិ ធម្មស្ស-
វនាយ ។ ធម្មេ ភាសិតេ ថេរា ភិក្ខូ យថាវិហារំ
គច្ឆន្តិ ។ នវកា ភិក្ខូ តត្ថេវ ឧបដ្ឋានសាលាយំ
ឧបាសកេហិ សទ្ធឹ មុដ្ឋស្សតី អសម្បជានា នគ្គា
វិកុជ្ជមានា កាកច្ឆមានា សេយ្យំ កប្បេន្តិ ។ ឧ-
បាសកា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ
នាម ភទន្តា មុដ្ឋស្សតី អសម្បជានា នគ្គា វិកុជ្ជមានា
កាកច្ឆមានា សេយ្យំ កប្បេស្សន្តីតិ ។ អស្សោសុំ
ខោ ភិក្ខូ តេសំ ឧបាសកានំ ឧជ្ឈាយន្តានំ ខីយន្តានំ
វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។
តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម
ភិក្ខូ អនុបសម្បន្នេន សហ សេយ្យំ កប្បេស្សន្តីតិ ។
អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។

# សិក្ខាបទទី ៥

[២៨៩] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគកាលគង់នៅអគ្គាឡវចេតិយ ជិតក្រុងអាឡវី ។ សម័យនោះឯង ពួកឧបាសកតែងមកកាន់អារាមដើម្បីនឹងស្តាប់ធម៌ ។ កាលបើធម្មកថិកសំដែងធម៌ចប់ហើយពួកភិក្ខុជាថេរក៏ទៅកាន់ទីដែលខ្លួននៅ ។ ភិក្ខុបួសថ្មីទាំងឡាយ ក៏ភ្លេចសតិមិនដឹងខ្លួន ជាអ្នកអាក្រាតកាយ ថ្ងូរស្រមុកដេកលក់ជាមួយនឹងឧបាសកទាំងឡាយក្នុងសាលាសម្រាប់ធ្វើបុណ្យនោះឯង ។ ឧបាសកទាំងឡាយក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ មិនទំនងជាមនុស្សភ្លេចសតិ មិនដឹងខ្លួន ជាអ្នកអាក្រាតកាយថ្ងូរស្រមុកសិងលក់ឡើយ ។ ភិក្ខុទាំងឡាយបានឮពាក្យរបស់ឧបាសកទាំងនោះ ពោលទោសតិះដៀល បន្ទុះបង្អាប់ហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា មិនសមបីភិក្ខុទាំងឡាយសិងជាមួយនឹងអនុបសម្បន្នឡើយ ។ ខណៈនោះឯងភិក្ខុទាំងនោះ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។

សច្ចំ កិរ ភិក្ខវេ ភិក្ខូ អនុបសម្បន្នេន សហ សេយ្យំ កប្បេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា អនុបសម្បន្នេន សហ សេយ្យំ កប្បេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អនុបសម្បន្នេន សហ សេយ្យំ កប្បេយ្យ ចាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[២៩០] អថខោ ភគវា អាឡវិយំ យថាភិរន្តំ វិហរិត្វា យេន កោសម្ពី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន កោសម្ពី តទវសរិ ។ តត្រ សុទំ ភគវា កោសម្ពិយំ វិហរតិ ពទរិការាមេ(១) ។ ភិក្ខូ អាយស្មន្តំ រាហុលំ ឯតទវោចុំ

១ វទរិការាមេតិបិ ទិស្សតិ ។

ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុទៅសិងជាមួយនឹងអនុបសម្បន្ន (រឿងនេះ) ពិតឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការណ៍នោះ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះមិនទំនងដេកជាមួយនឹងអនុបសម្បន្នសោះ ម្នាលភិក្ខុទាំងឡាយ កម្មនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដេកជាមួយនឹងអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះឯង ។

[២៩០] គ្រានោះឯង ព្រះដ៏មានព្រះភាគកាលគង់នៅក្រុងអាឡវី គួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់ចារិក នាក្រុងកោសម្ពី ទ្រង់យាងដោយលំដាប់ទៅ ក៏បានដល់ក្រុងកោសម្ពីនោះឯង ។ បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់សម្រេចឥរិយាបថនៅពទរិការាម ជិតក្រុងកោសម្ពីនោះ ។ ភិក្ខុទាំងឡាយបានពោលពាក្យនេះនឹងរាហុល

២៩១

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស បញ្ចមសិក្ខាបទស្ស និទានំ

ភគវតា អាវុសោ រាហុល សិក្ខាបទំ បញ្ញត្តំ ន អនុបសម្បន្នេន សហ សេយ្យា កប្បេតព្វាតិ សេយ្យំ អាវុសោ រាហុល ជានាហីតិ ។ អថខោ អាយស្មា រាហុលោ សេយ្យំ អលភមានោ វច្ចកុដិយា[១] សេយ្យំ កប្បេសិ ។ អថខោ ភគវា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ យេន វច្ចកុដី តេនុបសង្កមិ ឧបសង្កមិត្វា ឧក្កាសិ ។ អាយស្មាបិ រាហុលោ ឧក្កាសិ ។ កោ ឯត្ថាតិ ។ អហំ ភគវា រាហុលោតិ ។ កិស្ស ត្វំ រាហុល ឥធ និបន្នោសីតិ[២] ។ អថខោ អាយស្មា រាហុលោ ភគវតោ ឯតមត្ថំ អារោចេសិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ

១ ភគវតោ វច្ចកុដិយាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ. ម. និសិន្នោសីតិ ។

ដ៏មានអាយុថា ម្នាលរាហុលដ៏មានអាយុ សិក្ខាបទព្រះដ៏មានព្រះភាគទ្រង់ត្រាស់បញ្ញត្តដូច្នេះថា ភិក្ខុមិនត្រូវដេកជាមួយនឹងអនុបសម្បន្នទេ ម្នាលរាហុល (សាមណេរ) ដ៏មានអាយុ អ្នកចូរដឹងនូវទីសិងចុះ ។ គ្រានោះ រាហុលដ៏មានអាយុរកទីសិងមិនបាន ក៏ទៅសិងក្នុងវច្ចកុដិ (បង្គន់) ។ ខណៈនោះ ព្រះដ៏មានព្រះភាគ ទ្រង់តើនអំពីយប់ក្នុងវេលាបច្ចូសសម័យនៃរាត្រីហើយយាងចូលទៅទីវច្ចកុដិ លុះយាងចូលទៅដល់ហើយ ទ្រង់ឲ្យនូវព្រះសូរសៀង (គឺគ្រហែមតាមទំនៀមវច្ចកុដិវត្ត) ។ ឯរាហុលដ៏មានអាយុក៏គ្រហែមត ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរថា នរណានៅក្នុងវច្ចកុដិនេះ ។ រាហុលក៏ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះរាហុល ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលរាហុល ហេតុអ្វីបានជាអ្នកមកដេក ក្នុងវច្ចកុដិនេះ ។ គ្រានោះ រាហុលដ៏មានអាយុ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ សំដែងថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យអ្នកទាំងឡាយ

អនុបសម្បន្នេន ទ្វិរត្តតិរត្តំ សហ សេយ្យំ កប្បេតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អនុបសម្បន្នេន ឧត្តរិទ្វិរត្តតិរត្តំ សហ សេយ្យំ កប្បេយ្យ បាចិត្តិយន្តិ ។

[២៩១] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អនុបសម្បន្នោ នាម ភិក្ខុំ ឋបេត្វា អវសេសោ អនុបសម្បន្នោ នាម ។ ឧត្តរិទ្វិរត្តតិរត្តន្តិ អតិរេកទ្វិរត្តតិរត្តំ ។ សហាតិ ឯកតោ ។ សេយ្យា នាម សព្វច្ឆន្នា សព្វបរិច្ឆន្នា យេភុយ្យេនច្ឆន្នា យេភុយ្យេន បរិច្ឆន្នា ។ សេយ្យំ កប្បេយ្យាតិ ចតុត្ថេ ទិវសេ អត្ថង្គតេ សុរិយេ អនុបសម្បន្នេ និបន្នេ ភិក្ខុ និបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុ[១] និបន្នេ អនុបសម្បន្នោ និបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។

១ ភិក្ខុស្មិន្តិ បទេន ភវិតព្វំ ។

សម្រេចនូវទីដេកជាមួយនឹងអនុបសម្បន្នអស់ពីរយប់ឬបីយប់បាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សម្រេចនូវទីដេកជាមួយនឹងអនុបសម្បន្ន លើសជាងពីរយប់ឬបីយប់ឡើងទៅ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[២៩១] ត្រង់ពាក្យថា ភិក្ខុណាមួយ បានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា អនុបសម្បន្ននោះ គឺលើកលែងតែភិក្ខុចេញ ក្រៅអំពីនោះជាអនុបសម្បន្នទាំងអស់ ។ ពាក្យថា លើសជាងពីរយប់ឬបីយប់ឡើងទៅ គឺច្រើនជាងពីរយប់បីយប់ ។ ពាក្យថា ជាមួយ សេចក្តីថា ជាមួយគ្នា ។ ដែលហៅថា ទីដេក គឺទីដែលគេប្រក់ទាំងអស់ ដែលគេបិទបាំងទាំងអស់ ដែលគេប្រក់ដោយច្រើន ដែលគេបិទបាំងដោយច្រើន ។ ពាក្យថា សម្រេចនូវទីដេក សេចក្តីថា កាលបើព្រះអាទិត្យក្នុងថ្ងៃជាគម្រប់ ៤ អស្តង្គតទៅហើយ កាលបើអនុបសម្បន្នដេក ភិក្ខុក៏នៅដេក ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ កាលបើភិក្ខុដេក អនុបសម្បន្នក៏នៅដេក ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

ឧភោ វា និបជ្ជន្តិ អាបត្តិ បាចិត្តិយស្ស ។ ឧដ្ឋហិត្វា បុនប្បុនំ និបជ្ជន្តិ អាបត្តិ បាចិត្តិយស្ស ។

[២៩២] អនុបសម្បន្នេ អនុបសម្បន្នសញ្ញី ឧត្តរិទ្វិរត្តតិរត្តំ សហ សេយ្យំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នេ វេមតិកោ ឧត្តរិទ្វិរត្តតិរត្តំ សហ សេយ្យំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី ឧត្តរិទ្វិរត្តតិរត្តំ សហ សេយ្យំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបឌ្ឍច្ឆន្នេ ឧបឌ្ឍបរិច្ឆន្នេ អាបត្តិ ទុក្កដស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ ឧបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឧបសម្បន្នេ ឧបសម្បន្នសញ្ញី អនាបត្តិ ។

[២៩៣] អនាបត្តិ ទ្វេ តិស្សោ រត្តិយោ វសតិ ឩនកទ្វេតិស្សោ រត្តិយោ វសតិ ទ្វេ រត្តិយោ វសិត្វា តតិយាយ រត្តិយា បុរារុណា និក្ខមិត្វា បុន វសតិ

ពុំនោះសោត នៅដេកទាំងពីរនាក់ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ អ្នកទាំងពីរនាក់ក្រោកឡើងហើយដេកទៅវិញរឿយ ៗ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[២៩២] អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន សម្រេចនូវទីដេករួមគ្នាលើសជាងពីរយប់ ឬបីយប់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ ។ អនុបសម្បន្ន តែភិក្ខុមានសេចក្ដីសង្ស័យ ហើយសម្រេចនូវទីដេករួមគ្នាលើសជាងពីរយប់ ឬបីយប់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្នទៅវិញ ហើយសម្រេចនូវទីដេករួមគ្នាលើសជាងពីរយប់ឬបីយប់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុត្រូវអាបត្តិទុក្កដក្នុងទីដែលប្រក់បានពាក់កណ្ដាល បិទបាំងពាក់កណ្ដាល ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្ន តែភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ពិតមែន ជាអនាបត្តិ ។

[២៩៣] អាបត្តិមិនមាន ដល់ភិក្ខុនៅអស់ពីររាត្រី ឬបីរាត្រី (គឺដេកនៅជាមួយអនុបសម្បន្ន) ដល់ភិក្ខុដែលដេកនៅថយអំពីពីរ ឬបីរាត្រីចុះមកដល់ភិក្ខុដែលដេកនៅបានពីររាត្រីរួចហើយ ចេញទៅអំពីពេលមុនអរុណរះ

សព្វច្ឆន្នេ សព្វអបរិច្ឆន្នេ សព្វបរិច្ឆន្នេ សព្វអច្ឆន្នេ យេភុយ្យេន អច្ឆន្នេ យេភុយ្យេន អបរិច្ឆន្នេ អនុប-សម្បន្នេ និបន្នេ ភិក្ខុ និសីទតិ ភិក្ខុ និបន្នេ អនុបសម្បន្នោ និសីទតិ ឧភោ វា និសីទន្តិ ឧម្មត្ត-កស្ស អាទិកម្មិកស្សាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។

នៃរាត្រីជាគម្រប់បីហើយទើបមកដេកនៅជាថ្មីទៀត ដល់ភិក្ខុដែលដេកនៅក្នុងទីដែលគេប្រក់ទាំងអស់ តែគេមិនបានបិទបាំងទាំងអស់ ដល់ភិក្ខុដែលដេកនៅក្នុងទីដែលគេបិទបាំងជិត តែគេប្រក់មិនពេញ ដល់ភិក្ខុដែលដេកនៅក្នុងទីដែលគេមិនបានប្រក់ដោយច្រើន (គឺប្រក់បានបន្តិចបន្តួច) ដល់ភិក្ខុដែលដេកនៅក្នុងទីដែលគេមិនបានបិទបាំងដោយច្រើន (គឺបិទបាំងបន្តិចបន្តួច) ដល់ភិក្ខុអ្នកអង្គុយ អនុបសម្បន្នដេក ដល់ភិក្ខុដេក អនុបសម្បន្នអង្គុយ ឬភិក្ខុដែលអង្គុយពីរនាក់នឹងអនុបសម្បន្ន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុអ្នកដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់ ។

# ឆដ្ឋសិក្ខាបទំ

[២៩៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា អនុរុទ្ធោ កោសលេសុ ជនបទេសុ សាវត្ថឹ គច្ឆន្តោ[១] សាយំ អញ្ញតរំ គាមំ ឧបគច្ឆិ ។ តេន ខោ បន សមយេន តស្មឹ គាមេ អញ្ញតរិស្សា ឥត្ថិយា អាវសថាគារំ បញ្ញត្តំ ហោតិ ។ អថខោ អាយស្មា អនុរុទ្ធោ យេន សា ឥត្ថី តេនុបសង្កមិ ឧបសង្កមិត្វា តំ ឥត្ថឹ ឯតទវោច សចេ តេ ភគិនិ អគរុ វសេយ្យាមិ ឯករត្តឹ អាវសថាគារេតិ ។ វសេយ្យាថ ភន្តេតិ ។ អញ្ញេបិ អទ្ធិកា យេន សា ឥត្ថី តេនុបសង្កមឹសុ ឧបសង្កមិត្វា តំ ឥត្ថឹ ឯតទវោចុំ សចេ តេ អយ្យេ អគរុ វសេយ្យាម ឯករត្តឹ អាវសថាគារេតិ ។ ឯសោ ខោ អយ្យោ សមណោ បឋមំ ឧបគតោ សចេ សោ អនុជានាតិ

១ អាគច្ឆន្តោតិបិ ទិស្សតិ ។

## សិក្ខាបទទី ៦

[២៩៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះអនុរុទ្ធដ៏មានអាយុនិមន្តទៅក្រុងសាវត្ថី ក្នុងកោសលជនបទ បានចូលទៅកាន់ស្រុកមួយក្នុងវេលាល្ងាច ។ សម័យនោះឯង ក្នុងស្រុកនោះ មានផ្ទះសម្រាប់សំណាក់ដែលស្រីម្នាក់បានសង់ទុកហើយ ។ គ្រានោះឯង ព្រះអនុរុទ្ធដ៏មានអាយុចូលទៅរកស្រីនោះ លុះចូលទៅដល់ហើយបានពោលពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី បើនាងមិនមានសេចក្តីចង្អៀតចង្អល់ទេ អាត្មាសូមនៅក្នុងផ្ទះសំណាក់បានមួយយប់ ។ ស្រីនោះទូលតបថា និមន្តគង់នៅចុះលោកម្ចាស់ ។ សូម្បីពួកជនអ្នកដំណើរដទៃទៀត ក៏ចូលទៅរកស្រីនោះ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងស្រីនោះថា បពិត្រនាងជាម្ចាស់ បើនាងមិនមានសេចក្តីចង្អៀតចិត្តទេ យើងទាំងឡាយសូមនៅក្នុងផ្ទះសំណាក់បានមួយយប់ ។ ស្រីនោះប្រាប់ថា មានសមណៈជាម្ចាស់ ១ អង្គនុ៎ះ លោកចូលទៅមុនហើយ បើសមណៈនោះលោកព្រម

វសេយ្យាថាតិ ។ អថខោ តេ អទ្ធិកា យេនាយស្មា អនុរុទ្ធោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ អនុរុទ្ធំ ឯតទវោចុំ សចេ តេ ភន្តេ អគរុ វសេយ្យាម ឯករត្តឹ អាវសថាគារេតិ ។ វសេយ្យាថ អាវុសោតិ ។ អថខោ សា ឥត្ថី អាយស្មន្តេ អនុរុទ្ធេ សហ ទស្សនេន បដិពទ្ធចិត្តា អហោសិ ។ អថខោ សា ឥត្ថី យេនាយស្មា អនុរុទ្ធោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អនុរុទ្ធំ ឯតទវោច អយ្យោ ភន្តេ ឥមេហិ មនុស្សេហិ អាកិណ្ណោ ន ផាសុ វិហរិស្សតិ សាហំ ភន្តេ អយ្យស្ស មញ្ចកំ អព្ភន្តរំ បញ្ញាបេយ្យន្តិ ។ អធិវាសេសិ ខោ អាយស្មា អនុរុទ្ធោ តុណ្ហីភាវេន ។ អថខោ សា ឥត្ថី អាយស្មតោ អនុរុទ្ធស្ស សាមំ មញ្ចកំ អព្ភន្តរំ បញ្ញាបេត្វា អលង្កតបដិយត្តា គន្ធគន្ធិនី យេនាយស្មា អនុរុទ្ធោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អនុរុទ្ធំ ឯតទវោច អយ្យោ ភន្តេ អភិរូបោ ទស្សនីយោ បាសាទិកោ អហញ្ចម្ហិ អភិរូបា

អ្នកទាំងឡាយចូរនៅចុះ ។ គ្រានោះឯង អ្នកដំណើរទាំងនោះ ក៏ចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ លុះចូលទៅដល់ហើយ បានទូលពាក្យនេះនឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន បើលោកមិនមានសេចក្តីចង្អៀតចិត្តទេ ខ្ញុំករុណាទាំងឡាយសូមនៅក្នុងផ្ទះសំណាក់ (នេះ) បានមួយយប់ផង ។ ព្រះអនុរុទ្ធប្រាប់ថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយនៅចុះ ។ ឯស្រីនោះ ក៏មានចិត្តប្រតិព័ទ្ធក្នុងព្រះអនុរុទ្ធដ៏មានអាយុតាំងអំពីបានឃើញ ។ លំដាប់នោះ ស្រីនោះក៏ចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់នឹងគង់នៅច្រឡូកច្រឡំដោយមនុស្សទាំងឡាយនេះមិនស្រួលទេ បពិត្រលោកដ៏ចម្រើន ចាំខ្ញុំករុណារៀបចំគ្រែតូចមួយខាងក្នុងដើម្បីលោកម្ចាស់ ។ ព្រះអនុរុទ្ធដ៏មានអាយុក៏ទទួលព្រមដោយតុណ្ហីភាព ។ ឯស្រីនោះក៏រៀបចំគ្រែតូចខាងក្នុងដោយខ្លួនឯងដើម្បីព្រះអនុរុទ្ធដ៏មានអាយុ ហើយប្រដាប់តាក់តែងជាស្ត្រីមានក្លិនក្រអូប ចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ ក្នុងទីដែលលោកគង់នៅ[១] លុះចូលទៅដល់ហើយ បានពិតពាក្យនេះ នឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ មានរូបល្អគួរទស្សនាការនាំមកនូវសេចក្តីជ្រះថ្លា ឯខ្ញុំករុណាក៏ជាស្រីមានរូបល្អដែរ គួររមិលមើល

---

១ ច្បាប់ដើម បាត់សេចក្តីជាភាសាខ្មែរមួយប្រយោគនេះ ប៉ុន្តែ ភាសាបាលី មាន ។

ទស្សនីយា បាសាទិកា សាធាហំ ភន្តេ អយ្យស្ស បជាបតិ ភវេយ្យន្តិ ។ ឯវំ វុត្តេ អាយស្មា អនុរុទ្ធោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ សា ឥត្ថី អាយស្មន្តំ អនុរុទ្ធំ ឯតទវោច អយ្យោ ភន្តេ អភិរូបោ ទស្សនីយោ បាសាទិកោ អហញ្ចម្ហិ អភិរូបា ទស្សនីយា បាសាទិកា សាធុ ភន្តេ អយ្យោ មញ្ចេវ សម្បដិច្ឆតុ[១] សព្វញ្ច សាបតេយ្យន្តិ ។ តតិយម្បិ ខោ អាយស្មា អនុរុទ្ធោ តុណ្ហី អហោសិ ។ អថខោ សា ឥត្ថី សាដកំ និក្ខិបិត្វា អាយស្មតោ អនុរុទ្ធស្ស បុរតោ ចង្កមតិបិ តិដ្ឋតិបិ និសីទតិបិ សេយ្យម្បិ កប្បេតិ ។ អថខោ អាយស្មា អនុរុទ្ធោ ឥន្ទ្រិយានិ ឱក្ខិបិត្វា តំ ឥត្ថឹ នេវ ឱលោកេសិ នបិ អាលបិ ។ អថខោ សា ឥត្ថី អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ពហូ មេ មនុស្សា សតេនបិ សហស្សេនបិ បហីណន្តិ អយំ បន សមណោ

១ ឱ. ម. បដិច្ឆតុ ។

នាំមកនូវសេចក្តីជ្រះថ្លាដែរ បពិត្រលោកដ៏ចម្រើន ខ្ញុំករុណា សូមធ្វើជាប្រ-ពន្ធរបស់លោកម្ចាស់ ។ កាលដែលស្រីនោះ និយាយយ៉ាងនេះហើយ ព្រះអនុរុទ្ធដ៏មានអាយុក៏ស្ងៀមនៅ ។ ស្រីនោះបាននិយាយពាក្យនេះនឹងព្រះអនុរុទ្ធដ៏មានអាយុជាគម្រប់ពីរដងទៀត ។ បេ ។ ជាគម្រប់បីដងទៀតថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់មានរូបល្អ គួរទស្សនាការ នាំមកនូវសេច-ក្តីជ្រះថ្លា ឯខ្ញុំករុណាក៏ជាស្រីមានរូបល្អ គួររមិលមើល នាំមកនូវសេចក្តីជ្រះថ្លាដែរ បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់ព្រមទទួលយកនូវខ្ញុំករុណានិងសម្បត្តិទាំងពួងចុះ ។ ព្រះអនុរុទ្ធដ៏មានអាយុ ក៏ស្ងៀមនៅអស់វារៈជាគម្រប់បីដង ។ ឯស្រីនោះ ក៏ដាក់សំពត់សាដកទាំងអស់ផុតចេញ (ពីខ្លួន) ហើយ ដើរខ្វះ ឈរខ្វះ អង្គុយខ្វះ ដេកខ្វះ ខាងមុខនៃព្រះអនុរុទ្ធដ៏មានអាយុ ។ ខណៈនោះ ព្រះអនុរុទ្ធដ៏មានអាយុ ក៏សង្រួមនូវឥន្ទ្រិយទាំងឡាយហើយមិនបានក្រឡេកមើល មិនបានចរចានឹងស្រីនោះឡើយ ។ ឯស្រីនោះក៏លាន់ម៉ាត់ថា អើហ្ន៎គួរឲ្យអស្ចារ្យពេកណាស់ អើហ្ន៎មិនដែលឃើញទេតើ មនុស្សទាំងឡាយជាច្រើនរមែងបញ្ជូនមកដោយរយកហាបណៈខ្វះ ដោយពាន់កហាបណៈខ្វះ ដើម្បីរូបអញ ឯសមណៈនេះអញខំលួងលោមដល់ម្ល៉េះ

មយា សាមំ យាចិយមានោ ន ឥច្ឆតិ មញ្ចេវ សម្បដិច្ឆិតុំ[១] សព្វញ្ច សាបតេយ្យន្តិ សាជកំ និវាសេត្វា អាយស្មតោ អនុរុទ្ធស្ស បាទេសុ សិរសា និបតិត្វា អាយស្មន្តំ អនុរុទ្ធំ ឯតទវោច អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យាហំ ឯវរូបមកាសឹ តស្សា មេ ភន្តេ អយ្យោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។ ឥង្ឃ តំ ភគិនិ អច្ចយោ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យា ត្វំ ឯវមកាសិ យតោ ច ខោ ត្វំ ភគិនិ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោសិ តន្តេ មយំ បដិគ្គណ្ហាម វុឌ្ឍិ ហេសា ភគិនិ អរិយស្ស វិនយេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ[២] សំវរំ អាបជ្ជតីតិ ។ អថខោ សា ឥត្ថី តស្សា រត្តិយា អច្ចយេន អាយស្មន្តំ អនុរុទ្ធំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា

១ ឱ. ម. បដិច្ឆិតុំ ។ ២ ឱ. ម. អាយតឹច ។

ដោយខ្លួនឯង ក៏ឥតមានត្រូវការចំពោះខ្លួនអញ និងទ្រព្យសម្បត្តិទាំងពួង ដល់តិចសោះ (ថាដូច្នេះ) ហើយក៏ស្លៀកសំពត់សាដកហើយក្រាបចុះដោយត្បូងទៀបបាទានៃព្រះអនុរុទ្ធដ៏មានអាយុ ហើយសូមខមាទោសនឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិ្រលោកដ៏ចម្រើន ខ្ញុំព្រះករុណាជាស្រីមានកំហុសហើយ ព្រោះខ្ញុំព្រះករុណាជាស្រីពាល ជាស្រីល្ងង់ ជាស្រីមិនឈ្លាស ខ្ញុំឯណាដែលបានធ្វើនូវកំហុសមានសភាពយ៉ាងនេះហើយ បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់ទទួលនូវកំហុសតាមទោសរបស់ខ្ញុំព្រះករុណានោះដើម្បីនឹងសង្រួមតទៅទៀត ។ ព្រះអនុរុទ្ធក៏តបថា ម្នាលប្អូនស្រី ណ្ហើយចុះនាងមានកំហុសហើយ ព្រោះនាងជាស្រីពាល ជាស្រីល្ងង់ ជាស្រីមិនឈ្លាស នាងណាដែលបានធ្វើនូវកំហុស មានសភាពយ៉ាងនេះហើយ ម្នាលប្អូនស្រី តែនាងឯងបានឃើញនូវកំហុសដោយកំហុសពិត ហើយសំដែងដោយសមគួរតាមធម៌ យើងនឹងទទួលនូវកំហុសរបស់នាងឯងនោះបាន អ្នកណាមួយបានឃើញនូវកំហុស ដោយកំហុសពិត ហើយសំដែងដោយសមគួរតាមធម៌ ហើយតាំងនៅក្នុងសេចក្តីសង្រួមតទៅ ម្នាលប្អូនស្រី ការនេះជាសេចក្តីចម្រើនរបស់អ្នកនោះ ក្នុងអរិយវិន័យ ។ ឯស្រីនោះលុះកន្លងរាត្រីនោះទៅ ក៏បវារណា និមន្តព្រះអនុរុទ្ធដ៏មានអាយុឲ្យឆាន់បង្អែម និងចំអាបដ៏ផ្ចិតផ្ចង់ដោយដៃខ្លួនឯង ហើយអង្គុយនៅក្នុងទីដ៏សមគួរ

២៩៩



សម្បវារេត្វា អាយស្មន្តំ អនុរុទ្ធំ ភុត្តាវឹ ឱនីតបត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ ឥត្ថឹ អាយស្មា អនុរុទ្ធោ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ សា ឥត្ថី អាយស្មតា អនុរុទ្ធេន ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា អាយស្មន្តំ អនុរុទ្ធំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ[១] អយ្យេន អនុរុទ្ធេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសិកំ មំ អយ្យោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។ អថខោ អាយស្មា អនុរុទ្ធោ

---

១ សព្វត្ថ ឯវមេវាតិ បាឋោ បញ្ញាយតិ ។

ជាមួយនឹងព្រះអនុរុទ្ធដ៏មានអាយុ ដែលឆាន់ហើយ និងលាងបាត្រលាងដៃរួចហើយ ។ ព្រះអនុរុទ្ធដ៏មានអាយុបានពន្យល់ស្រីដែលអង្គុយក្នុងទីដ៏សមគួរនោះឲ្យយល់ច្បាស់ ឲ្យទទួលយក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយវាចាប្រកបដោយធម៌ ។ ឯស្រីនោះ លុះព្រះអនុរុទ្ធដ៏មានអាយុបានពន្យល់ឲ្យយល់ច្បាស់ ឲ្យទទួលយក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយវាចាប្រកបដោយធម៌ហើយ ក៏បាននិយាយពាក្យនេះ នឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន ពាក្យនេះ ភ្លឺច្បាស់ណាស់ បពិត្រលោកដ៏ចម្រើន ពាក្យនេះភ្លឺច្បាស់ណាស់ បពិត្រលោកដ៏ចម្រើន បុគ្គលផ្ងារឡើងនូវភាជន៍ដែលគេផ្កាប់ចុះ ឬបើកចេញនូវវត្ថុដែលគេបិទបាំងទុកពុំនោះសោតដូចបុគ្គល ប្រាប់ផ្លូវដល់មនុស្សដែលវង្វេងផ្លូវ ឬដូចបុគ្គលកាន់ប្រទីបទ្រោលក្នុងទីងងឹត បំភ្លឺដល់មនុស្សដែលមានចក្ខុឲ្យឃើញរូបគ្នាបាន សេចក្តីនេះមានឧបមាដូចម្តេចមិញ ព្រះអនុរុទ្ធជាម្ចាស់បានប្រកាសធម៌ដោយបរិយាយដ៏ច្រើន ក៏មានឧបមេយ្យដូច្នោះដែរ បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណានេះ សូមដល់នូវព្រះដ៏មានព្រះភាគនោះ ព្រមទាំងព្រះធម៌ និងព្រះភិក្ខុសង្ឃថា ជាទីពឹងទីរលឹក សូមលោកម្ចាស់ចាំទុកនូវខ្ញុំព្រះករុណាថា ជាឧបាសិកាដល់នូវ (ត្រៃ) សរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះជាដើមតទៅ ។ គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ

សាវត្ថឹ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម អាយស្មា អនុរុទ្ធោ មាតុគ្គាមេន សហ សេយ្យំ កប្បេស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ត្វំ អនុរុទ្ធ មាតុគ្គាមេន សហ សេយ្យំ កប្បេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ អនុរុទ្ធ មាតុគ្គាមេន សហ សេយ្យំ កប្បេស្សសិ នេតំ អនុរុទ្ធ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ មាតុគ្គាមេន សហ សេយ្យំ កប្បេយ្យ ចាចិត្តិយន្តិ ។

[២៩៨] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ មាតុគ្គាមោ នាម មនុស្សិត្ថី ន យក្ខី ន បេតី ន តិរច្ឆានគតា អន្តមសោ តទហុជាតាបិ

និមន្តទៅក្រុងសាវត្ថីហើយបានប្រាប់សេចក្តីនេះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះអនុរុទ្ធដ៏មានអាយុមិនគួរនឹងទៅអាស្រ័យទីដេកនៅជាមួយនឹងមាតុគ្រាមសោះ ។ ខណៈនោះ ភិក្ខុទាំងនោះក៏បានទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលអនុរុទ្ធ បានឮថា អ្នកសម្រេចនូវទីដេកជាមួយនឹងមាតុគ្រាមពិតមែនឬ ។ ព្រះអនុរុទ្ធក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលអនុរុទ្ធ អ្នកមិនគួរនឹងសម្រេចនូវទីដេកជាមួយនឹងមាតុគ្រាមទេ ម្នាលអនុរុទ្ធ អំពើដែលអ្នកឯងធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សម្រេចនូវទីដេកជាមួយនឹងមាតុ-គ្រាម ត្រូវអាបត្តិបាចិត្តិយ ។

[២៩៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខា-បទទី ១ នៃបារាជិកកណ្ឌ ។ បេ ។ ដែលហៅថា មាតុគ្រាមនោះ គឺស្រីមនុស្ស ឯយក្សស្រី ប្រេតស្រី តិរច្ឆានញី មិនហៅថា មាតុគ្រាមទេ ដោយហោចទៅសូម្បីតែក្មេងស្រីដែលកើតក្នុងថ្ងៃនោះ (ក៏ហៅថាមាតុគ្រាមដែរ)

ជាតិកា បគេវ មហន្តតរី[១] ។ សហាតិ ឯកតោ ។ សេយ្យា នាម សព្វច្ឆន្នា សព្វបរិច្ឆន្នា យេភុយ្យេនច្ឆន្នា យេភុយ្យេន បរិច្ឆន្នា ។ សេយ្យំ កប្បេយ្យាតិ អត្ថង្គតេ សុរិយេ មាតុគាមេ និបន្នេ ភិក្ខុ និបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុ[២] និបន្នេ មាតុគ្គាមោ និបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ឧភោ វា និបជ្ជន្តិ អាបត្តិ បាចិត្តិយស្ស ។ ឧដ្ឋហិត្វា បុនប្បុនំ និបជ្ជន្តិ អាបត្តិ បាចិត្តិយស្ស ។

[២៩៦] មាតុគ្គាមេ មាតុគ្គាមសញ្ញី សហ សេយ្យំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ មាតុគ្គាមេ វេមតិកោ សហ សេយ្យំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ មាតុគ្គាមេ អមាតុគ្គាមសញ្ញី សហ សេយ្យំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបឌ្ឍច្ឆន្នេ ឧបឌ្ឍបរិច្ឆន្នេ អាបត្តិ ទុក្កដស្ស ។ យក្ខិយា វា បេតិយា វា បណ្ឌកេន វា តិរច្ឆានគតិត្ថិយា វា សហ សេយ្យំ កប្បេតិ អាបត្តិ ទុក្កដស្ស ។ អមាតុគ្គាមេ មាតុគ្គាមសញ្ញី

១ ឱ. ម. មហាតរី ។ ២ ភិក្ខុស្មិន្តិ បទេន ភវិតព្វំ ។

នឹងបាច់ពោលថ្វី ដល់មនុស្សស្រីដែលធំ ។ ពាក្យថា ជាមួយ គឺក្នុងទីជាមួយគ្នា ។ ដែលហៅថា ទីដេក គឺទីដេកដែលគេប្រក់ទាំងអស់ គេបិទបាំងទាំងអស់ គេប្រក់ដោយច្រើន គេបិទបាំងដោយច្រើន ។ ពាក្យថា សម្រេចទីដេក សេចក្តីថា វេលាព្រះអាទិត្យអស្តង្គតហើយមាតុគ្រាមដេក ភិក្ខុក៏ដេកដែរ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ កាលភិក្ខុដេក មាតុគ្រាមក៏ដេកដែរ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ពុំនោះសោត ជនទាំងពីរគឺភិក្ខុ និងមាតុគ្រាមដេកព្រមគ្នា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។ ជនទាំងពីរនោះ ក្រោកឡើងហើយដេកទៅវិញរឿយ ៗ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[២៩៦] មាតុគ្រាម ភិក្ខុសំគាល់ថា មាតុគ្រាមពិតមែន ហើយសម្រេចទីដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម តែភិក្ខុមានសេចក្តីសង្ស័យ ហើយសម្រេចទីដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម ហើយសម្រេចទីដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុត្រូវអាបត្តិទុក្កដ (ព្រោះដេក) ក្នុងទីដេកដែលគេប្រក់បានពាក់កណ្តាល គេបិទបាំងបានពាក់កណ្តាល ។ ភិក្ខុសម្រេចទីដេកជាមួយនឹងយក្សស្រីក្តី ប្រេតស្រីក្តី ជនខ្ទើយក្តី តិរច្ឆានញីក្តី ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថា មាតុគ្រាម

អាបត្តិ ទុក្កដស្ស ។ អមាតុគ្គាមេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អមាតុគ្គាមេ អមាតុគ្គាមសញ្ញី អនាបត្តិ ។

[២៩៧] អនាបត្តិ សព្វច្ឆន្នេ សព្វអបរិច្ឆន្នេ សព្វបរិច្ឆន្នេ សព្វអច្ឆន្នេ យេភុយ្យេន អច្ឆន្នេ យេភុយ្យេន អបរិច្ឆន្នេ មាតុគ្គាមោ និបន្នេ ភិក្ខុ និសីទតិ ភិក្ខុ និបន្នេ មាតុគ្គាមេ និសីទតិ ឧភោ វា និសីទន្តិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។

ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម តែភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម មិនត្រូវអាបត្តិឡើយ ។

[២៩៧] (អាបត្តិមិនមាន ដល់ភិក្ខុសម្រេចទីដេកជាមួយនឹងមាតុគ្រាម) ក្នុងទីដែលគេប្រក់ទាំងអស់ តែមិនបានបិទបាំងជុំវិញ ដល់ភិក្ខុដែលដេកជាមួយនឹងមាតុគ្រាមក្នុងទីដែលគេបិទបាំងជុំវិញ តែគេមិនបានប្រក់សោះឡើយ ដល់ភិក្ខុដែលដេកជាមួយនឹងមាតុគ្រាម ក្នុងទីដែលគេមិនបានប្រក់ដោយច្រើន គឺប្រក់បានបន្តិចបន្តួច គេមិនបានបិទបាំងដោយច្រើន គឺបិទបាំងបន្តិចបន្តួច ដល់ភិក្ខុដែលអង្គុយ មាតុគ្រាមដេក ដល់ភិក្ខុដេក មាតុគ្រាមអង្គុយ ដល់ភិក្ខុដែលអង្គុយ មាតុគ្រាមក៏អង្គុយទាំងពីរនាក់ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៦ ចប់ ។

# សត្តមសិក្ខាបទំ

[២៩៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧទាយិ សាវត្ថិយំ កុលុបកោ ហោតិ ពហុកានិ កុលានិ ឧបសង្កមតិ ។ អថខោ អាយស្មា ឧទាយិ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន អញ្ញតរំ កុលំ តេនុបសង្កមិ ។ តេន ខោ បន សមយេន ឃរណី និវេសនទ្វារេ និសិន្នា ហោតិ ។ ឃរសុណ្ហា អាវសថទ្វារេ និសិន្នា ហោតិ ។ អថខោ អាយស្មា ឧទាយិ យេន ឃរណី តេនុបសង្កមិ ឧបសង្កមិត្វា ឃរណិយា ឧបកណ្ណកេ ធម្មំ ទេសេសិ ។ អថខោ ឃរសុណ្ហាយ ឯតទហោសិ កិន្នុ ខោ សោ សមណោ សស្សុយា ជារោ ឧទាហុ ឱភាសតីតិ ។ អថខោ អាយស្មា ឧទាយិ ឃរណិយា ឧបកណ្ណកេ ធម្មំ ទេសេត្វា យេន ឃរសុណ្ហា តេនុបសង្កមិ ឧបសង្កមិត្វា

# សិក្ខាបទទី ៧

[២៩៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់គង់នៅវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ កាលណោះឯង ឧទាយិដ៏មានអាយុ ជាអ្នកចូលទៅកាន់ត្រកូលក្នុងក្រុងសាវត្ថី តែងចូលទៅរកត្រកូលទាំងឡាយច្រើន ។ លំដាប់នោះ ឧទាយិដ៏មានអាយុ វេលាព្រឹកព្រហាម ក៏ស្លៀកស្បង់ហើយប្រដាប់ដោយបាត្រចីវរចូលទៅរកត្រកូលមួយ ។ គ្រានោះឯង ស្រីជាមេផ្ទះអង្គុយជិតទ្វារផ្ទះ ។ ស្រីជាកូនប្រសានៃស្រីមេផ្ទះនោះ ក៏អង្គុយជិតទ្វារផ្ទះសំណាក់ ។ លំដាប់នោះ ឧទាយិដ៏មានអាយុ ចូលទៅរកស្រីជាមេផ្ទះ លុះចូលទៅហើយ ក៏សំដែងធម៌ជិតត្រចៀកស្រីជាមេផ្ទះ ។ ទើបស្រីជាកូនប្រសានៃស្រីមេផ្ទះនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា សមណៈនោះជាសហាយរបស់ម្តាយក្មេក ឬនិយាយចង់គ្នា ។ ពេលនោះ ឧទាយិដ៏មានអាយុ លុះសំដែងធម៌ជិតត្រចៀកស្រីជាមេផ្ទះហើយ ក៏ចូលទៅរកស្រីជាកូនប្រសានៃស្រីមេផ្ទះ លុះចូលទៅហើយ

ឃរសុណ្ហាយ ឧបកណ្ណកេ ធម្មំ ទេសេសិ ។ អថខោ ឃរណិយា ឯតទហោសិ កិន្នុ ខោ សោ សមណោ ឃរសុណ្ហាយ ជារោ ឧទាហុ ឱភាសតីតិ ។ អថខោ អាយស្មា ឧទាយិ ឃរសុណ្ហាយ ឧបកណ្ណកេ ធម្មំ ទេសេត្វា បក្កាមិ ។ អថខោ ឃរណី ឃរសុណ្ហំ ឯតទវោច ហេ ជេ កឹ តេ សោ[១] សមណោ អវោចាតិ ។ ធម្មំ មេ អយ្យេ ទេសេសិ អយ្យាយ បន កឹ អវោចាតិ ។ មយ្ហំបិ ធម្មំ ទេសេសីតិ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យោ ឧទាយិ មាតុគ្គាមស្ស ឧបកណ្ណកេ ធម្មំ ទេសេស្សតិ ននុ នាម វិស្សដ្ឋេន វិវដេន ធម្មោ ទេសេតព្វោតិ ។ អស្សោសុំ ខោ ភិក្ខូ តាសំ ឥត្ថីនំ ឧជ្ឈាយន្តីនំ ខីយន្តីនំ វិបាចេន្តីនំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧទាយិ មាតុ-គាមស្ស ធម្មំ ទេសេស្សតីតិ ។ អថខោ តេ ភិក្ខូ

១ ឱ. ឯសោ ។

ក៏សំដែងធម៌ជិតត្រចៀកស្រីជាកូនប្រសា នៃស្រីមេផ្ទះ (នោះទៀត) ។ ទើបស្រីជាមេផ្ទះមានសេចក្តីត្រិះរិះដូច្នេះថា សមណៈនោះជាសហាយរបស់ស្រីជាកូនប្រសានៃអញជាមេផ្ទះ ឬថានិយាយចង់គ្នា ។ លំដាប់នោះ ឧទាយិដ៏មានអាយុ លុះសំដែងធម៌ជិតត្រចៀកស្រីជាកូនប្រសានៃស្រីមេផ្ទះហើយ ក៏ចៀសចេញទៅ ។ គ្រានោះឯង ស្រីជាមេផ្ទះបាននិយាយពាក្យនេះនឹងស្រីជាកូនប្រសានៃខ្លួនជាមេផ្ទះថា នែហង សមណៈនោះ បាននិយាយពាក្យអ្វីខ្លះនឹងហងឯង ។ ស្រីជាកូនប្រសាតបថា បពិត្រអ្នកម៉ែ សមណៈនោះសំដែងធម៌ដល់ខ្ញុំ ចំណែកឯអ្នកម៉ែ សមណៈនោះ បាននិយាយពាក្យអ្វីឲ្យខ្លះ ។ ម្តាយក្មេកប្រាប់ថា សមណៈនោះសំដែងធម៌ដល់អញដែរ ។ ស្រីទាំងពីរនាក់នោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ឧទាយិ មិនសមបីបើនឹងសំដែងធម៌ (ខ្សឹប) ជិតត្រចៀកមាតុគ្រាមសោះ ធម្មតាសមណៈគួរតែសំដែងធម៌ដោយសំឡេងក្បោះក្បាយ ដោយច្បាស់លាស់ទេតើ ។ ភិក្ខុទាំងឡាយបានឮពាក្យស្រីទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧទាយិដ៏មានអាយុមិនសមបីបើនឹងសំដែងធម៌ដល់មាតុគ្រាមសោះ ។ ឯភិក្ខុទាំងនោះ

## បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស សត្តមសិក្ខាបទស្ស បញ្ញត្តិ

ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ត្វំ ឧទាយិ មាតុគ្គាមស្ស ធម្មំ ទេសេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស មាតុគ្គាមស្ស ធម្មំ ទេសេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ មាតុគ្គាមស្ស ធម្មំ ទេសេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[២៩៩] តេន ខោ បន សមយេន ឧបាសិកា ភិក្ខូ បស្សិត្វា ឯតទវោចុំ ឥង្ឃ អយ្យា ធម្មំ ទេសេថាតិ ។ ន ភគិនិ កប្បតិ មាតុគ្គាមស្ស ធម្មំ ទេសេតុន្តិ ។ ឥង្ឃ អយ្យា ឆប្បញ្ចវាចាហិ ធម្មំ ទេសេថ សក្កា ឯត្តកេនបិ ធម្មោ អញ្ញាតុន្តិ ។

ក៏នាំគ្នាក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគម្ចាស់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧទាយិ បានឮថាអ្នកឯងសំដែងធម៌ ដល់មាតុគ្រាម ពិតមែនឬ ។ ឧទាយិភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែនហើយ ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះ-ដៀលថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងសំដែងធម៌ ដល់មាតុគ្រាមទេ ម្នាលមោឃបុរស អំពើនេះមិននាំឲ្យជ្រះថ្លា ដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយសំដែងធម៌ ដល់មាតុគ្រាម ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តសិក្ខា-បទនេះដល់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។

[២៩៩] សម័យនោះឯង ពួកឧបាសិកាឃើញភិក្ខុទាំងឡាយ ក៏និយាយពាក្យនេះថា បពិត្រលោកម្ចាស់ទាំងឡាយ ពួកខ្ញុំករុណា សូមអារាធនា សូមលោកម្ចាស់ទាំងឡាយមេត្តាសំដែងធម៌ឲ្យទាន ។ ពួកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី ការសំដែងធម៌ដល់មាតុគ្រាមមិនគួរទេ ។ ពួកឧបាសិកាទូលថា បពិត្រលោកម្ចាស់ទាំងឡាយ ពួកខ្ញុំករុណា សូមអារាធនា សូមលោកម្ចាស់ទាំងឡាយ មេត្តាសំដែងធម៌ត្រឹមប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឲ្យទានចុះ ពួកខ្ញុំករុណា អាចចាំធម៌បានដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ន ភគិនិ កប្បតិ មាតុគ្គាមស្ស ធម្មំ ទេសេតុន្តិ កុក្កុច្ចាយន្តា ន ទេសេសុំ ។ ឧបាសិកា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា អម្ហេហិ យាចិយមានា ធម្មំ ន ទេសេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តាសំ ឧបាសិកានំ ឧជ្ឈាយន្តីនំ ខីយន្តីនំ វិបាចេន្តីនំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ មាតុគ្គាមស្ស ឆប្បញ្ចវាចាហិ ធម្មំ ទេសេតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ មាតុគ្គាមស្ស ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៣០០] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភគវតា អនុញ្ញាតំ មាតុគ្គាមស្ស ឆប្បញ្ចវាចាហិ ធម្មំ ទេសេតុន្តិ ។ តេ អវិញ្ញុ បុរិសវិគ្គហំ

ពួកភិក្ខុនិយាយថា ម្នាលប្អូនស្រី ការសំដែងធម៌ដល់មាតុគ្រាមមិនគួរទេ ថា ដូច្នោះហើយក៏មានសេចក្ដីរង្កៀសខានសំដែងធម៌ទៅ ។ ពួកឧបាសិកា ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបីបើលោកម្ចាស់ទាំងឡាយ ពួកយើងខំអង្វរទាំងម៉្លេះ ក៏មិនសំដែងធម៌ឲ្យទានសោះ ។ ភិក្ខុទាំងឡាយបានឮពាក្យឧបាសិកាទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ទើបភិក្ខុទាំងនោះនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏-មានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសំដែងធម៌ដល់មាតុគ្រាមបានតែត្រឹមប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ប៉ុណ្ណោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយសំដែងធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគ បានទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំង-ឡាយ ដោយប្រការដូច្នេះ ។

[៣០០] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបានដឹងថា ព្រះដ៏មានព្រះភាគបានអនុញ្ញាតឲ្យភិក្ខុសំដែងធម៌ ដល់មាតុគ្រាមបានត្រឹមប្រាំម៉ាត់ឬប្រាំមួយម៉ាត់ហើយ ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះ ក៏ឲ្យបុរសដែលមិនដឹងក្ដី

ឧបនិសីទាបេត្វា មាតុក្កាមស្ស ឧត្តរិធប្បញ្ញូវាចាហិ ជម្មំ ងេសេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ ណាម ឆព្វគ្គិយា ភិក្ខូ អវិញ្ញូ បុរិសវិគ្គហំ ឧបនិសីទាបេត្វា មាតុកាមស្ស ឧត្តរិធប្បញ្ញូវាចាហិ ជម្មំ ងេសេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ អវិញ្ញូ បុរិសវិគ្គហំ ឧបនិសីទាបេត្វា មាតុក្កាមស្ស ឧត្តរិធប្បញ្ញូវាចាហិ ជម្មំ ងេសេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ ណាម តុម្ហេ មោឃបុរិសា អវិញ្ញូ បុរិសវិគ្គហំ ឧបនិសីទាបេត្វា មាតុក្កាមស្ស ឧត្តរិធប្បញ្ញូវាចាហិ ជម្មំ ងេសេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ

អង្គុយជិត ហើយសំដែងធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា មិនសមបីបើពួកឆព្វ-គ្គិយភិក្ខុឲ្យបុរសដែលមិនដឹងក្តីអង្គុយជិត ហើយសំដែងធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅសោះ ។ ឯភិក្ខុទាំងនោះនាំគ្នាក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយឲ្យបុរសដែលមិនដឹងក្តីអង្គុយជិត ហើយសំដែងធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើទៅ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគជាម្ចាស់ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ មិនសមបីបើអ្នកទាំងឡាយឲ្យបុរសដែលមិនដឹងក្តីអង្គុយជិត ហើយសំដែងធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ មាតុគ្គាមស្ស ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេយ្យ អញ្ញត្រ វិញ្ញុនា បុរិសវិគ្គហេន ចាចិត្តិយន្តិ ។

[៣០១] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ មាតុគ្គាមោ នាម មនុស្សិត្ថី ន យក្ខី ន បេតី ន តិរច្ឆានគតា វិញ្ញូ បដិពលា សុភាសិត-ទុព្ភាសិតំ ទុដ្ឋុល្លាទុដ្ឋុល្លំ អាជានិតុំ ។ ឧត្តរិឆប្បញ្ច-វាចាហីតិ អតិរេកឆប្បញ្ចវាចាហិ ។ ធម្មោ នាម ពុទ្ធភាសិតោ សាវកភាសិតោ ឥសិភាសិតោ ទេវតាភា-សិតោ អត្ថុបសញ្ហិតោ ធម្មុបសញ្ហិតោ ។ ទេសេយ្យាតិ បទេន ទេសេតិ បទេ បទេ អាបត្តិ ចាចិត្តិយស្ស ។ អក្ខរាយ ទេសេតិ អក្ខរក្ខរាយ អាបត្តិ ចាចិត្តិយស្ស ។ អញ្ញត្រ វិញ្ញុនា បុរិសវិគ្គហេនាតិ ឋបេត្វា វិញ្ញុំ បុរិស-វិគ្គហំ ។ វិញ្ញូ នាម បុរិសវិគ្គហោ បដិពលោ ហោតិ សុភាសិតទុព្ភាសិតំ ទុដ្ឋុល្លាទុដ្ឋុល្លំ អាជានិតុំ ។

ភិក្ខុណាមួយ សំដែងធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានបុរសដែលដឹងក្តី (អន្តុយជិត) ។

[៣០១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា មាតុគ្រាម គឺមនុស្សស្រីដែលដឹងក្តីអាចដឹងពាក្យល្អពាក្យអាក្រក់ ពាក្យទ្រគោះពាក្យមិនទ្រគោះ ឯយក្សស្រី ប្រេតស្រី តិរច្ឆានញី មិនហៅថា មាតុគ្រាមទេ ។ ពាក្យថា លើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ គឺច្រើនជាងប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ ។ ដែលហៅថា ធម៌ គឺធម៌ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងទុកហើយ សាវកសំដែងទុកហើយ ឥសីសំដែងទុកហើយ ទេវតាសំដែងទុកហើយ ដែលអាស្រ័យនូវអដ្ឋកថា អាស្រ័យនូវបាលី ។ ពាក្យថា សំដែង គឺភិក្ខុសំដែងដោយបទ ត្រូវអាបត្តិបាចិត្តិយរាល់ ៗ បទ ។ ភិក្ខុសំដែងដោយអក្ខរៈ ត្រូវអាបត្តិបាចិត្តិយរាល់ ៗ អក្ខរៈ ។ ពាក្យថា វៀរលែងតែមានបុរសដែលដឹងក្តី គឺលើកលែងតែបុរសដែលដឹងក្តី ។ ដែលហៅថា អ្នកដឹងក្តី គឺបុរសដែលអាចដឹងនូវពាក្យល្អ ពាក្យអាក្រក់ ពាក្យទ្រគោះ ពាក្យមិនទ្រគោះ ។

[៣០៦] មាតុគ្គាមេ មាតុគ្គាមសញ្ញី ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេតិ អញ្ញត្រ វិញ្ញុនា បុរិសវិគ្គហេន អាបត្តិ ចាចិត្តិយស្ស ។ មាតុគ្គាមេ វេមតិកោ ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេតិ អញ្ញត្រ វិញ្ញុនា បុរិសវិគ្គហេន អាបត្តិ ចាចិត្តិយស្ស ។ មាតុគ្គាមោ អមាតុគ្គាមសញ្ញី ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេតិ អញ្ញត្រ វិញ្ញុនា បុរិសវិគ្គហេន អាបត្តិ ចាចិត្តិយស្ស ។ យក្ខិយា វា បេតិយា វា បណ្ឌកស្ស វា តិរច្ឆានគតមនុស្សវិគ្គហិត្ថិយា វា ឧត្តរិឆប្បញ្ចវាចាហិ ធម្មំ ទេសេតិ អញ្ញត្រ វិញ្ញុនា បុរិសវិគ្គហេន អាបត្តិ ទុក្កដស្ស ។ អមាតុគ្គាមេ មាតុគ្គាមសញ្ញី អាបត្តិ ទុក្កដស្ស ។ អមាតុគ្គាមេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អមាតុគ្គាមេ អមាតុគ្គាមសញ្ញី អនាបត្តិ ។

[៣០២] មាតុគ្រាម ភិក្ខុសំគាល់ថា មាតុគ្រាម ហើយសំដែងធម៌ឲ្យលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ ដោយគ្មានបុរសដឹងក្តី (នៅជិតខាង) ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុមានសេចក្តីសង្ស័យ ហើយសំដែងធម៌ឲ្យលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ ដោយគ្មានបុរសដឹងក្តី (នៅជិតខាង) ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម ហើយសំដែងធម៌ឲ្យលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ ដោយគ្មានបុរសដឹងក្តី (នៅជិតខាង) ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសំដែងធម៌ឲ្យលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ ដល់យក្សស្រីក្តី ប្រេតស្រីក្តី ជនខ្ទើយក្តី តិរច្ឆានញីមានរាងកាយដូចមនុស្សស្រីក្តី ដោយគ្មានបុរសដឹងក្តី (នៅជិតខាង) ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុ-គ្រាម ភិក្ខុសំគាល់ថា ជាមាតុគ្រាម ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំ-គាល់ថា មិនមែនមាតុគ្រាម មិនត្រូវអាបត្តិយអ្វីឡើយ ។

[៣០៣] អនាបត្តិ វិញ្ញូនា បុរិសវិគ្គហេន ឆប្បញ្ច- វាចាហិ ធម្មំ ទេសេតិ ឩនកឆប្បញ្ចវាចាហិ ធម្មំ ទេសេតិ ឧដ្ឋហិត្វា បុន និសីទិត្វា ធម្មំ ទេសេតិ មាតុគាមោ ឧដ្ឋហិត្វា បុន និសីទតិ តស្មឹ ទេសេតិ អញ្ញស្ស មាតុគ្គាមស្ស ទេសេតិ បញ្ហំ បុច្ឆតិ បញ្ហំ បុដ្ឋោ កថេតិ អញ្ញស្សត្ថាយ ភណន្តំ មាតុគ្គាមោ សុណាតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។

[៣០៣] អាបត្តិមិនមាន ដល់ភិក្ខុដែលសំដែងធម៌ (ដល់មាតុគ្រាម) មានបុរសដឹងក្តី (នៅជិតខាង) ដល់ភិក្ខុសំដែងធម៌ត្រឹមប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ ដល់ភិក្ខុសំដែងធម៌តិចជាងប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ ដល់ភិក្ខុសំដែងធម៌ប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ក្រោកឡើង ហើយអង្គុយទៅវិញសំដែងទៀត ដល់ភិក្ខុសំដែងធម៌ដល់មាតុគ្រាមដែលក្រោកឡើងហើយ អង្គុយទៅវិញក្នុងខណៈនោះ ដល់ភិក្ខុសំដែងធម៌ដល់មាតុគ្រាមឯទៀត (ក្រៅពីមាតុគ្រាមដែលបានសំដែងឲ្យស្តាប់ហើយ) ដល់ភិក្ខុដែលមាតុគ្រាមសួរប្រស្នាហើយឆ្លើយដោះប្រស្នា (នោះ) ដល់ភិក្ខុសំដែងធម៌ឲ្យអ្នកដទៃស្តាប់ មាតុគ្រាមអង្គុយស្តាប់ផង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

# អដ្ឋមសិក្ខាបទំ

[៣០៤] តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន សម្ពហុលា សន្ទិដ្ឋា សម្ភត្តា ភិក្ខូ វគ្គុមុទាយ នទិយា តីរេ វស្សំ ឧបគច្ឆឹសុ ។ តេន ខោ បន សមយេន វជ្ជី ទុព្ភិក្ខា ហោតិ ទ្វីហិតិកា សេតដ្ឋិកា សលាកាវុត្តា ន សុករា ឧញ្ឆេន បគ្គ-ហេន យាបេតុំ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ ឯតរហិ ខោ វជ្ជី ទុព្ភិក្ខា ទ្វីហិតិកា សេតដ្ឋិកា សលាកាវុត្តា ន សុករា ឧញ្ឆេន បគ្គហេន យាបេតុំ កេន នុ ខោ មយំ ឧបាយេន សមគ្គា សម្មោ-ទមានា អវិវទមានា ផាសុកំ វស្សំ វសេយ្យាម

# សិក្ខាបទទី ៨

[៣០៤] *សម័យនោះ ព្រះភគវន្តសម្មាសម្ពុទ្ធជាម្ចាស់ កាលគង់នៅកូដាគារសាលា ព្រៃមហាវន ទៀបក្រុងវេសាលី ។ គ្រានោះឯង មានភិក្ខុច្រើនរូបជាមិត្របានជួបប្រទះគ្នាថ្មី និងមិត្រស្និទ្ធស្នាលមាំមួន បាននៅចាំវស្សាប្របច្រៀនស្ទឹងវគ្គុមុទា ។ វេលានោះឯង ដែនវជ្ជីកើតទុរ្ភិក្ស* (*អត់បាយ*) *មនុស្សទាំងឡាយ ចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក ក៏ដល់នូវសេចក្តីស្លាប់មានឆ្អឹងស* (*ដេរដាសលើផែនដី*) *នឹងទិញដូរស្រូវអង្ករ លុះតែមានស្លាកកាន់ជាសំគាល់ ទើបទិញដូរបាន មនុស្សទាំងអស់ក្នុងដែននោះ មិនងាយនឹងចិញ្ចឹមជីវិតដោយការព្យាយាមស្វែងរកអាហារ ។ ខណៈនោះ ភិក្ខុទាំងនោះគិតគ្នាដូច្នេះថា ឥឡូវនេះ ដែនវជ្ជីកើតទុរ្ភិក្ស* (*អត់បាយ*) *មនុស្សទាំងឡាយ ចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក ក៏ដល់នូវសេចក្តីស្លាប់មានឆ្អឹងស* (*ដេរដាសលើផែនដី*) *និងទិញដូរស្រូវអង្ករលុះតែមានស្លាកកាន់ជាសំគាល់ ទើបទិញដូរបាន មនុស្សទាំងអស់ក្នុងដែននោះ មិនងាយនឹងចិញ្ចឹមជីវិត ដោយការព្យាយាមស្វែងរកអាហារឡើយ តើយើងនឹងគិតធ្វើឧបាយដូចម្តេចហ្ន ឲ្យបានសាមគ្គីស្មោះសរ កុំឲ្យមានវិវាទទាស់ទែងគ្នា នៅចាំវស្សាឲ្យបានស្រួលផង កុំឲ្យលំបាក*

ន ច បិណ្ឌកេន កិលមិស្សាមាតិ ។ ឯកច្ចេ ឯវមាហំសុ ហន្ទ មយំ អាវុសោ គិហីនំ កម្មន្តំ អធិដ្ឋេម ឯវន្តេ អម្ហាកំ ទាតុំ មញ្ញិស្សន្តិ ឯវំ មយំ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសេយ្យាម ន ច បិណ្ឌកេន កិលមិស្សាមាតិ ។ ឯកច្ចេ ឯវមាហំសុ អលំ អាវុសោ កឹ គិហីនំ កម្មន្តំ អធិដ្ឋិតេន ហន្ទ មយំ អាវុសោ គិហីនំ ទូតេយ្យំ ហរាម ឯវន្តេ អម្ហាកំ ទាតុំ មញ្ញិស្សន្តិ ឯវំ មយំ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសេយ្យាម ន ច បិណ្ឌកេន កិលមិស្សាមាតិ ។ ឯកច្ចេ ឯវមាហំសុ អលំ អាវុសោ កឹ គិហីនំ កម្មន្តំ អធិដ្ឋិតេន កឹ គិហីនំ ទូតេយ្យំ ហដេន ហន្ទ មយំ អាវុសោ គិហីនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសិស្សាម អសុកោ ភិក្ខុ បឋមស្ស ឈានស្ស លាភី អសុកោ ភិក្ខុ ទុតិយស្ស ឈានស្ស លាភី អសុកោ ភិក្ខុ តតិយស្ស

ដោយអាហារបិណ្ឌបាតផង ។ ភិក្ខុពួកខ្លះឆ្លើយថា អាវុសោ បើដូច្នោះ យើងត្រូវទទួលរ៉ាប់រងការងាររបស់គ្រហស្ថចុះ កាលបើយើងធ្វើយ៉ាងនេះហើយ គ្រហស្ថទាំងនោះ គង់នឹងនឹកនាឲ្យអាហារដល់យើងមិនខាន កាលបើបានអាហារយ៉ាងនេះហើយ យើងក៏បានសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលផង ហើយមិនលំបាកដោយអាហារបិណ្ឌបាតផង ។ ភិក្ខុពួកខ្លះឆ្លើយថា អាវុសោ កុំឡើយ ប្រយោជន៍អ្វី នឹងទទួលរ៉ាប់រងការងាររបស់គ្រហស្ថនោះ អាវុសោ ណ្ហើយចុះ យើងត្រូវធ្វើជាអ្នកបម្រើ នាំដំណឹងដល់ពួកគ្រហស្ថវិញ កាលបើយើងធ្វើយ៉ាងនេះហើយ គ្រហស្ថទាំងនោះគង់នឹងនឹកនាឲ្យអាហារបិណ្ឌបាតដល់យើងមិនខាន កាលបើបានអាហារយ៉ាងនេះហើយ យើងនឹងព្រមព្រៀងស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលផង ហើយមិនលំបាក ដោយអាហារបិណ្ឌបាតផង ។ ភិក្ខុពួកខ្លះឆ្លើយថា អាវុសោ កុំឡើយ ប្រយោជន៍អ្វីនឹងទទួលរ៉ាប់រងការងាររបស់គ្រហស្ថ ប្រយោជន៍អ្វីនឹងធ្វើជាអ្នកបម្រើ នាំដំណឹងដល់ពួកគ្រហស្ថ អាវុសោ ណ្ហើយចុះ យើងនឹងពោលសរសើរនូវឧត្តរិមនុស្សធម៌របស់គ្នានឹងគ្នា ដល់ពួកគ្រហស្ថវិញថា ភិក្ខុឯណោះបានឈានទី ១ ភិក្ខុឯណោះបានឈានទី ២ ភិក្ខុឯណោះបានឈានទី ៣

៣១៣

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស អដ្ឋមសិក្ខាបទស្ស និទានំ

ឈានស្ស លាភី អសុកោ ភិក្ខុ ចតុត្ថស្ស ឈានស្ស លាភី អសុកោ ភិក្ខុ សោតាបន្នោ អសុកោ ភិក្ខុ សកទាគាមី អសុកោ ភិក្ខុ អនាគាមី អសុកោ ភិក្ខុ អរហា អសុកោ ភិក្ខុ តេវិជ្ជោ អសុកោ ភិក្ខុ ឆឡភិញ្ញោតិ ឯវន្តេ អម្ហាកំ ជាតុំ មញ្ញិស្សន្តិ ឯវំ មយំ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសេយ្យាម ន ច បិណ្ឌកេន កិលមិស្សាមាតិ ឯសោយេវ ខោ អាវុសោ សេយ្យោ យោ អម្ហាកំ គិហីនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណោ ភាសិតោតិ ។ អថខោ តេ ភិក្ខូ គិហីនំ អញ្ញ-មញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសឹសុ អសុកោ ភិក្ខុ បឋមស្ស ឈានស្ស លាភី ។ បេ ។ អសុកោ ភិក្ខុ ឆឡភិញ្ញោតិ ។ អថខោ តេ មនុស្សា លាភា វត នោ សុលទ្ធំ វត នោ យេសំ នោ ឯវរូបា ភិក្ខូ វស្សំ ឧបគតា ន វត នោ ឥតោ បុព្វេ ឯវរូបា ភិក្ខូ វស្សំ ឧបគតា យថយិមេ ភិក្ខូ សីល-វន្តោ កល្យាណធម្មាតិ ។ តេ ន តាទិសានិ ភោជនានិ

ភិក្ខុឯណោះបានឈានទី ៤ ភិក្ខុឯណោះជាសោតាបន្ន ភិក្ខុឯណោះជាសកទាគាមី ភិក្ខុឯណោះជាអនាគាមី ភិក្ខុឯណោះជាព្រះអរហន្ត ភិក្ខុឯ-ណោះបានវិជ្ជា ៣ ភិក្ខុឯណោះបានអភិញ្ញា ៦ កាលបើយើងពោលយ៉ាងនេះហើយ គ្រហស្ថទាំងនោះគង់នឹងនឹកនាំឲ្យអាហារបិណ្ឌបាតដល់យើងមិនខាន បើបានអាហារយ៉ាងនេះហើយ យើងក៏នឹងមានសេចក្តីសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នាទេ នៅចាំវស្សាក៏ស្រួល ហើយមិនលំបាកដោយបិណ្ឌបាតផង ។ ភិក្ខុទាំងនោះ ក៏យល់ព្រមថា អាវុសោ ពួកយើងពោលសរសើរគុណឧត្តរិមនុស្សធម៌ណារបស់គ្នាយើង ទៅវិញទៅមកដល់ពួកគ្រហស្ថ ការពោលសរសើរគុណឧត្តរិមនុស្សធម៌នេះ ស្រួលហើយ ។ លំដាប់នោះភិក្ខុទាំងនោះ ក៏បានពោលសរសើរគុណឧត្តរិមនុស្ស-ធម៌ទៅវិញទៅមកដល់ពួកគ្រហស្ថថា ភិក្ខុឯណោះបានឈានទី ១ ។ បេ ។ ភិក្ខុឯណោះបានអភិញ្ញា ៦ ។ គ្រានោះ មនុស្សទាំងឡាយនោះ ក៏និ-យាយគ្នាថា អើហ្ន៎យើងរាល់គ្នាបានភិក្ខុបែបនេះមកនៅចាំវស្សា ហៅពេញជាលាភរបស់យើង ឈ្មោះថាយើងបានបុណ្យដោយងាយណាស់ហ្ន៎ តាំងពីដើមមកដល់ឥឡូវនេះ យើងរាល់គ្នាមិនដែលបានពួកភិក្ខុមានសីលមានធម៌ជាកុសលដូចបែបនេះមកនៅចាំវស្សាសោះឡើយ ។ មនុស្សទាំងនោះ

អត្តនា កុញ្ជន្តិ មាតាបិតូនំ ទេន្តិ បុត្តទារស្ស ទេន្តិ ទាសកម្មករបោរិសស្ស ទេន្តិ មិត្តាមច្ចានំ ទេន្តិ ញាតិសាលោហិតានំ ទេន្តិ យាទិសានិ ភិក្ខូនំ ទេន្តិ ន តាទិសានិ ខាទនីយានិ សាយនីយានិ ចាជានិ អត្តនា បិវន្តិ មាតាបិតូនំ ទេន្តិ បុត្តទារស្ស ទេន្តិ ទាសកម្មករបោរិសស្ស ទេន្តិ មិត្តាមច្ចានំ ទេន្តិ ញាតិសាលោហិតានំ ទេន្តិ យាទិសានិ ភិក្ខូនំ ទេន្តិ ។ អថខោ តេ ភិក្ខូ វណ្ណវន្តោ អហេសុំ បីណិន្ទ្រិយា បសន្នមុខវណ្ណា វិប្បសន្នច្ឆវិវណ្ណា ។

[៣០៥] អាចិណ្ណំ ខោ បនេតំ វស្សំ វុត្ថានំ ភិក្ខូនំ ភគវន្តំ ទស្សនាយ ឧបសង្កមិតុំ ។ អថខោ តេ ភិក្ខូ វស្សំ វុត្ថា តេមាសច្ចយេន សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន វេសាលី

តែងប្រគេនភោជនាហារ(១)យ៉ាងណា ដល់ភិក្ខុទាំងឡាយ ភោជនាហារយ៉ាងនោះមិនហ៊ានបរិភោគម៉ាត់ខ្លួនឡើយ ហើយមិនបានជូនទៅមាតាបិតា កូនប្រពន្ធ ខ្ញុំកំដរ កម្មករបុរស មិត្ត អាមាត្យ និងញាតិសាលោហិតសោះឡើយ (ម្យ៉ាងទៀត) ធ្លាប់ប្រគេនខាទនីយ(២) គ្រឿងសម្រាប់ភ្លក់(៣) និងទឹកបាន(៤) យ៉ាងណា ដល់ពួកភិក្ខុ ខាទនីយ និងគ្រឿងភ្លក់ ទឹកបានយ៉ាងនោះ ក៏មិនហ៊ានបរិភោគផឹកខ្លួនឯងឡើយ ហើយមិនបានជូនទៅមាតាបិតា កូនប្រពន្ធ ខ្ញុំកំដរ កម្មករបុរស មិត្ត អាមាត្យ និងញាតិសាលោហិតសោះឡើយ ។ គ្រានោះឯង ភិក្ខុទាំងនោះ (លុះបានអាហារឆ្អែតបរិបូណ៌) ក៏មានសម្បុរល្អ មានឥន្ទ្រិយពេញលេញ មានសម្បុរមុខស្រស់បស់ សម្បុរស្បែកក៏ផូរផង់ ។

[៣០៥] ភិក្ខុទាំងឡាយ កាលបើចេញវស្សារួចហើយ តែងនាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ ជាទំនៀមមិនដែលខានឡើយ ។ វេលានោះឯង ភិក្ខុទាំងនោះលុះបាននៅចាំវស្សាគ្រប់ ៣ ខែហើយ ក៏រៀបចំទុកដាក់គ្រឿងសេនាសនៈ រួចនាំយកបាត្រនិងចីវរចូលទៅក្រុងវេសាលី ដើរ

១ ភោជនមាន ៥ យ៉ាង គឺបាយ ១ នំ ១ សត្តុ ១ ត្រី ១ សាច់ ១ ។ ខាទនីយ បានខាងឯមើមឈើ ផ្លែឈើជាដើម ។ ៣ បានខាងឯគ្រឿងសម្រាប់បរិភោគ គឺទឹកដោះរាវ ១ ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ ១ ទឹកអំពៅ ១ ។ ៤ ទឹកបាននោះ បានខាងទឹកបាន ៨ យ៉ាង មានទឹកបានធ្វើពីផ្លែស្វាយ ផ្លែព្រីងជាដើម ។

តេនុបសង្កមឹសុ អនុបុព្វេន យេន វេសាលី មហាវនំ កូដាគារសាលា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ តេន ខោ បន សមយេន ទិសាសុ វស្សំ វុត្ថា ភិក្ខូ កិសា ហោន្តិ លូខា ទុព្វណ្ណា ឧប្បណ្ឌុប្បណ្ឌុកជាតា ធមនិសន្ថតគត្តា ។ វគ្គុមុទាតីរិយា បន ភិក្ខូ វណ្ណវន្តោ ហោន្តិ បីនិន្ទ្រិយា បសន្នមុខវណ្ណា វិប្បសន្នច្ឆវិវណ្ណា ។ អាចិណ្ណំ ខោ បនេតំ ពុទ្ធានំ ភគវន្តានំ អាគន្តុកេហិ ភិក្ខូហិ សទ្ធឹ បដិសម្មោទិតុំ ។ អថខោ ភគវា វគ្គុមុទាតីរិយេ ភិក្ខូ ឯតទវោច កច្ចិ ភិក្ខវេ ខមនីយំ កច្ចិ យាបនីយំ កច្ចិ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិត្ថ ន ច បិណ្ឌកេន កិលមិត្ថាតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា សមគ្គា ច មយំ ភន្តេ សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិម្ហា

ទៅតាមលំដាប់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ដែលគង់នៅឯកូដាគារ-សាលាក្នុងព្រៃមហាវ័នទៀបក្រុងវេសាលី លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ សម័យនោះឯង ពួកភិក្ខុដែលនៅចាំវស្សាក្នុងទិសទាំងឡាយ សិងមានកាយស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់កើតជារោគលឿងស្មេកស្មាំង មានខ្លួនរវាមដោយសរសៃ ។ ចំណែកខាងពួកភិក្ខុដែលនៅទៀបត្រើយស្ទឹងវគ្គុមុទា មានសម្បុរល្អ មានឥន្ទ្រិយពេញលេញ មានសម្បុរមុខក៏ស្រស់បស់ សម្បុរស្បែកក៏ផូរផង់ ។ ឯទំនៀមរបស់ព្រះភគវន្តសម្ពុទ្ធទាំងឡាយ ព្រះអង្គតែងស្មោះសរចំពោះជាមួយនឹងអាគន្តុកភិក្ខុ គឺភិក្ខុដែលទើបនឹងមកដល់ថ្មី ។ គ្រានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សួរទៅពួកភិក្ខុដែលនៅទៀបឆ្នេរស្ទឹងវគ្គុមុទាថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាល្មមអត់ធន់បានឬទេ អ្នករាល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលឬទេ អ្នកទាំងឡាយមានសេចក្តីសាមគ្គីស្មោះសរមិនវិវាទទាស់ទែងគ្នា នៅចាំវស្សាស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតទេឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំរាល់គ្នាល្មមអត់ធន់បាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំរាល់គ្នាល្មមប្រព្រឹត្តទៅបាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំរាល់គ្នាមានសេចក្តីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលបួល

ន ច បិណ្ឌកេន កិលមិម្ហាតិ ។ ជានន្តាបិ តថាគតា បុច្ឆន្តិ ជានន្តាបិ ន បុច្ឆន្តិ កាលំ វិទិត្វា បុច្ឆន្តិ កាលំ វិទិត្វា ន បុច្ឆន្តិ អត្ថសញ្ហិតំ តថាគតា បុច្ឆន្តិ នោ អនត្ថសញ្ហិតំ អនត្ថសញ្ហិតេ សេតុឃាតោ តថាគតានំ ។ ទ្វីហាការេហិ ពុទ្ធា ភគវន្តោ ភិក្ខូ បដិបុច្ឆន្តិ ធម្មំ វា ទេសេស្សាម សាវកានំ វា សិក្ខាបទំ បញ្ញាបេស្សាមាតិ ។ អថខោ ភគវា វគ្គុមុទាតីរិយេ ភិក្ខូ ឯតទវោច យថាកថំ បន តុម្ហេ ភិក្ខវេ សមគ្គា សម្មោទមានា អវិវទមានា ផាសុកំ វស្សំ វសិត្ថ ន ច បិណ្ឌកេន កិលមិត្ថាតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ កច្ចិ បន វោ ភិក្ខវេ ភូតន្តិ ។ ភូតំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម

មិនលំបាកដោយអាហារបិណ្ឌបាតផង ។ ព្រះតថាគតទាំងឡាយទ្រង់ជ្រាប នូវហេតុហើយត្រាស់សួរក៏មាន ជ្រាបហើយមិនត្រាស់សួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយត្រាស់សួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយមិនត្រាស់សួរក៏មាន ព្រះតថាគតទាំងឡាយ ទ្រង់ត្រាស់សួរតែកម្មដែលប្រកបព្រមដោយប្រយោជន៍ កម្មដែលមិនប្រកបព្រមដោយប្រយោជន៍ ព្រះអង្គមិនទ្រង់ត្រាស់សួរឡើយ ព្រះតថាគតទាំងឡាយ ព្រះអង្គផ្ដាច់បង់នូវកម្មមិនប្រកបដោយប្រយោជន៍ ដោយអរិយមគ្គជ្រះស្រលះអស់ហើយ ។ ព្រះភគវន្តសម្ពុទ្ធទាំងឡាយ ទ្រង់សួរបញ្ជាក់ពួកភិក្ខុដោយហេតុពីរប្រការ គឺសួរដោយទ្រង់ព្រះតម្រិះថា តថាគតនឹងសំដែងធម៌ ១ នឹងបញ្ញត្តនូវសិក្ខាបទដល់ពួកសាវក ១ ។ កាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរទៅពួកភិក្ខុដែលនៅទៀបឆ្នេរស្ទឹងវគ្គុមុទាថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានជាមានសេចក្ដីសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាត តើដោយហេតុអ្វី ។ គ្រានោះ ភិក្ខុអម្បាលនោះ ក៏ក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ (ដោយសព្វគ្រប់) ។ ទើបព្រះអង្គទ្រង់ត្រាស់ថា នែភិក្ខុទាំងឡាយ ពាក្យរបស់អ្នកទាំងឡាយ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះភគវន្តសម្ពុទ្ធ

តុម្ហេ ភិក្ខវេ ឧទរស្ស ការណា គិហីនំ អញ្ញមញ្ញស្ស ឧត្តរិមនុស្សធម្មស្ស វណ្ណំ ភាសិស្សថ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អនុ-បសម្បន្នស្ស ឧត្តរិមនុស្សធម្មំ អារោចេយ្យ ភូតស្មឹ បាចិត្តិយន្តិ ។

[៣០៦] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អនុបសម្បន្នោ នាម ភិក្ខុញ្ច ភិក្ខុនិញ្ច ឋបេត្វា អវសេសោ អនុបសម្បន្នោ នាម ។

[៣០៧] ឧត្តរិមនុស្សធម្មោ នាម ឈានំ វិមោក្ខោ សមាធិ សមាបត្តិ ញាណទស្សនំ មគ្គភាវនា ផល-សច្ឆិកិរិយា កិលេសប្បហានំ វិនីវរណតា ចិត្តស្ស សុញ្ញាគារេ អភិរតិ ។

[៣០៨] ឈានន្តិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ។ វិមោក្ខោតិ សុញ្ញ-តោ វិមោក្ខោ អនិមិត្តោ វិមោក្ខោ អប្បណិហិតោ

ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អ្នកពល់គ្នាមិនសមបើនឹងហ៊ាន ពោលសរសើរគុណឧត្តរិមនុស្សធម៌របស់គ្នានិងគ្នា ចំពោះពួកគ្រហស្ថ ព្រោះហេតុតែចង់ឆ្អែតផ្ទៃទេ ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកធ្វើនេះមិនបាននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយប្រាប់ឧត្តរិមនុស្សធម៌ ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ ព្រោះឧត្តរិមនុស្សធម៌នោះ ភិក្ខុបានពិតមែន ។

[៣០៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបារាជិកកណ្ឌសិក្ខាបទទី ១ ហើយ ។ ដែលហៅថា អនុបសម្បន្ននោះ គឺលើកលែងតែភិក្ខុ និងភិក្ខុនីចេញ ក្រៅអំពីនោះហៅថា អនុបសម្បន្នទាំងអស់ ។

[៣០៧] ដែលហៅថា ឧត្តរិមនុស្សធម្ម[១]នោះ សំដៅយកឈាន ១ វិមោក្ខ ១ សមាធិ ១ សមាបត្តិ ១ ញាណទស្សនៈ ១ មគ្គភាវនា ១ ផលសច្ឆិកិរិយា ១ កិលេសប្បហាន ១ ចិត្តវិនីវរណៈ ១ សុញ្ញាគារអភិរតិ ១ ។

[៣០៨] បទថា ឈាន គឺសំដៅយកបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ។ បទថា វិមោក្ខ គឺសំដៅយកសុញ្ញតវិមោក្ខ

---

១ ពួកឧត្តរិមនុស្សធម្មនេះ បានអធិប្បាយក្នុងបារាជិកទី ៤ រួចហើយ ។

វិមោក្ខោ ។ សមាធីតិ សុញ្ញតោ សមាធិ អនិមិត្តោ សមាធិ អប្បណិហិតោ សមាធិ ។ សមាបត្តីតិ សុ-ញ្ញតា សមាបត្តិ អនិមិត្តា សមាបត្តិ អប្បណិហិតា សមាបត្តិ ។ ញាណន្តិ តិស្សោ វិជ្ជា ។ មគ្គភាវនាតិ ចត្តារោ សតិប្បដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ។ ផលសច្ឆិកិរិយាតិ សោ-តាបត្តផលស្ស សច្ឆិកិរិយា សកទាគាមិផលស្ស សច្ឆិកិរិយា អនាគាមិផលស្ស សច្ឆិកិរិយា អរហត្ត-ផលស្ស សច្ឆិកិរិយា ។ កិលេសប្បហានន្តិ រាគស្ស បហានំ ទោសស្ស បហានំ មោហស្ស បហានំ ។ វិនីវរណតា ចិត្តស្សាតិ រាគា ចិត្តស្ស វិនីវរណតា ទោសា ចិត្តស្ស វិនីវរណតា មោហា ចិត្តស្ស វិនីវរ-ណតា ។ សុញ្ញាគារេ អភិរតីតិ បឋមេន ឈានេន សុញ្ញាគារេ អភិរតិ ទុតិយេន ឈានេន សុញ្ញាគារេ អភិរតិ តតិយេន ឈានេន សុញ្ញាគារេ អភិរតិ ច-តុត្ថេន ឈានេន សុញ្ញាគារេ អភិរតិ ។

អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ ។ បទថា សមាធិ គឺសំដៅយក សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ ។ បទថា សមា-បត្តិ គឺសំដៅយក សុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិត-សមាបត្តិ ។ បទថា ញាណ គឺសំដៅយកវិជ្ជា ៣ ។ បទថា មគ្គភាវនា គឺសំដៅយក សតិបដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ បទថា ផលសច្ឆិកិរិយា គឺកិរិយាធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល កិរិយាធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល កិរិយាធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល កិរិយាធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។ បទថា កិលេសប្បហាន គឺកិរិយាលះរាគៈ លះទោសៈ លះមោហៈ ។ បទថា ចិត្តវិនីវរណៈ គឺចិត្តដែលប្រាសចាករាគៈ ចិត្តដែលប្រាសចាកទោសៈ ចិត្តដែលប្រាសចាកមោហៈ ។ សុញ្ញាគារអភិរតិ គឺសេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ដោយបឋមជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ដោយទុតិយជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ដោយតតិយជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ដោយចតុត្ថជ្ឈាន ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស អដ្ឋមសិក្ខាបទស្ស សិក្ខាបទវិភង្គោ

[៣០៩] អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមំ ឈានំ សមាបជ្ជិន្តិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមំ ឈានំ សមាបជ្ជាមីតិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមំ ឈានំ សមាបន្នោតិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមស្ស ឈានស្ស លាភិម្ហីតិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមស្ស ឈានស្ស វសិម្ហីតិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមំ ឈានំ សច្ឆិកាតំ មយាតិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។

[៣១០] អាបោចេយ្យាតិ អនុបសម្បន្នស្ស ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ ចតុត្ថស្ស ឈានស្ស លាភិម្ហិ វសិម្ហិ ចតុត្ថំ ឈានំ សច្ឆិកាតំ មយាតិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។

[៣០៩] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានចូលបឋមជ្ឈានរួចហើយ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាកំពុងចូលបឋមជ្ឈាន ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាជាអ្នកចូលបឋមជ្ឈានហើយ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាជាអ្នកបានបឋមជ្ឈាន ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈាន ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា បឋមជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣១០] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អាត្មាជាអ្នកបាននូវចតុត្ថជ្ឈាន អាត្មាជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈាន ចតុត្ថជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣១១] អារោចេយ្យាតិ អនុបសម្បន្នស្ស សុញ្ញតំ វិមោក្ខំ អនិមិត្តំ វិមោក្ខំ អប្បណិហិតំ វិមោក្ខំ សុញ្ញតំ សមាធឹ អនិមិត្តំ សមាធឹ អប្បណិហិតំ សមាធឹ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ អប្បណិហិតស្ស សមាធិស្ស លាភិម្ហិ វសិម្ហិ អប្បណិហិតោ សមាធិ សច្ឆិកតោ មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[២១២] អារោចេយ្យាតិ អនុបសម្បន្នស្ស សុញ្ញតំ សមាបត្តឹ អនិមិត្តំ សមាបត្តឹ អប្បណិហិតំ សមាបត្តឹ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ អប្បណិហិតាយ សមាបត្តិយា លាភិម្ហិ វសិម្ហិ អប្បណិហិតា សមាបត្តិ សច្ឆិកតា មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣១៣] អារោចេយ្យាតិ អនុបសម្បន្នស្ស តិស្សោ វិជ្ជា សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ តិស្សន្នំ វិជ្ជានំ លាភិម្ហិ វសិម្ហិ តិស្សោ វិជ្ជា សច្ឆិកតា មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣១៤] អារោចេយ្យាតិ អនុបសម្បន្នស្ស ចត្តារោ សតិប្បដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ

[៣១១] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់ នូវសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ អាត្មាជាអ្នកបាននូវអប្បណិហិតសមាធិ អាត្មាជាអ្នកស្ទាត់ក្នុងអប្បណិហិត-សមាធិ អប្បណិហិតសមាធិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣១២] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានចូល កំពុងចូល ជាអ្នកចូល នូវសុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិតសមាបត្តិ អាត្មាជាអ្នកបាននូវអប្បណិហិតសមាបត្តិ អាត្មាជាអ្នកស្ទាត់ក្នុងអប្បណិហិតសមាបត្តិ អប្បណិហិតសមាបត្តិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តយ ។

[៣១៣] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់ នូវត្រៃវិជ្ជា អាត្មាជាអ្នកបាននូវត្រៃវិជ្ជា អាត្មាជាអ្នកស្ទាត់ក្នុងត្រៃវិជ្ជា ត្រៃវិជ្ជា អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣១៤] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់ នូវសតិបដ្ឋាន ៤ សម្មប្បធាន ៤

ឥទ្ធិបាទេ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ ចតុន្នំ ឥទ្ធិបាទានំ លាភិម្ហិ វសិម្ហិ ចត្តារោ ឥទ្ធិបាទា សច្ឆិកតា មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣១៥] អារោចេយ្យាតិ អនុបសម្បន្នស្ស បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ បញ្ចន្នំ ពលានំ លាភិម្ហិ វសិម្ហិ បញ្ច ពលានិ សច្ឆិកតានិ មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣១៦] អារោចេយ្យាតិ អនុបសម្បន្នស្ស សត្ត ពោជ្ឈង្គេ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ សត្តន្នំ ពោជ្ឈង្គានំ លាភិម្ហិ វសិម្ហិ សត្ត ពោជ្ឈង្គា សច្ឆិកតា មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣១៧] អារោចេយ្យាតិ អនុបសម្បន្នស្ស អរិយំ អដ្ឋង្គិកំ មគ្គំ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស លាភិម្ហិ វសិម្ហិ អរិយោ អដ្ឋង្គិកោ មគ្គោ សច្ឆិកតោ មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

ឥទ្ធិបាទ ៤ អាត្មាជាអ្នកបាននូវឥទ្ធិបាទទាំង ៤ អាត្មាជាអ្នកស្ទាត់ក្នុងឥទ្ធិបាទទាំង ៤ ឥទ្ធិបាទទាំង ៤ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣១៥] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់ នូវឥន្ទ្រិយ ៥ ពលៈ ៥ អាត្មាជាអ្នកបាននូវពលៈ ៥ អាត្មាជាអ្នកស្ទាត់ក្នុងពលៈ ៥ ពលៈ ៥ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣១៦] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់ នូវពោជ្ឈង្គទាំង ៧ អាត្មាជាអ្នកបាននូវពោជ្ឈង្គទាំង ៧ អាត្មាជាអ្នកស្ទាត់ក្នុងពោជ្ឈង្គទាំង ៧ ពោជ្ឈង្គទាំង ៧ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣១៧] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់ នូវមគ្គប្រកបដោយអង្គទាំង ៨ ដ៏ប្រសើរ អាត្មាជាអ្នកបាននូវមគ្គប្រកបដោយអង្គទាំង ៨ ដ៏ប្រសើរ អាត្មាជាអ្នកស្ទាត់ក្នុងមគ្គប្រកបដោយអង្គទាំង ៨ ដ៏ប្រសើរ មគ្គប្រកបដោយអង្គទាំង ៨ ដ៏ប្រសើរ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣៥៨] អាពេចយ្យាតិ អនុបសម្បន្នស្ស សោតា-
បត្តិផលំ សកទាគាមិផលំ អនាគាមិផលំ អរហត្តផលំ[១]
សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ អរហត្តផលស្ស
លាភិម្ហិ វសិម្ហិ អរហត្តផលំ សច្ឆិកតំ មយាតិ
ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣៥៩] អាពេចយ្យាតិ អនុបសម្បន្នស្ស រាគោ មេ
ចត្តោ ទោសោ មេ ចត្តោ មោហោ មេ ចត្តោ វន្តោ មុត្តោ
បហីនោ បដិនិស្សដ្ឋោ ឧក្ខេដិតោ សមុក្ខេដិតោតិ
ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣៦០] អាពេចយ្យាតិ អនុបសម្បន្នស្ស រាគា
មេ ចិត្តំ វិនីវរណំ ទោសា មេ ចិត្តំ វិនីវរណំ មោហា
មេ ចិត្តំ វិនីវរណន្តិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣៦១] អាពេចយ្យាតិ អនុបសម្បន្នស្ស សុញ្ញា-
គារេ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ
ចតុត្ថំ ឈានំ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ

១ ឱ. ម. អរហត្តំ ។ ឯវំ សព្វត្ថ ញាតព្វំ ។

[៣១៨] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់ នូវសោតាបត្តិផល សកទាគាមិ-ផល អនាគាមិផល អរហត្តផល អាត្មាជាអ្នកបាននូវអរហត្តផល អាត្មាជាអ្នកស្ទាត់ក្នុងអរហត្តផល អរហត្តផល អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣១៩] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ដល់អនុបសម្បន្នថា រាគៈអាត្មាបានលះបង់ហើយ ទោសៈអាត្មាបានលះបង់ហើយ មោហៈអាត្មាបានលះបង់ហើយ បានខ្ជាក់ចោលហើយ បានជម្រុះចោលហើយ បានបន្សាត់ចោលហើយ បានរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣២០] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ដល់អនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាករាគៈ ចិត្តរបស់អាត្មាប្រាសចាកទោសៈ ចិត្តរបស់អាត្មាប្រាសចាកមោហៈ ត្រូវអាបត្តិបាចិត្តិយ ។

[៣២១] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ដល់អនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈាន ទុតិ-យជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ អាត្មាជាអ្នកបាន

សុញ្ញាគារេ ចតុត្ថស្ស ឈានស្ស លាភិម្ហិ វសិម្ហិ សុញ្ញាគារេ ចតុត្ថំ ឈានំ សច្ឆិកតំ មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣២២] អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ ទុតិយញ្ច ឈានំ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ បឋមស្ស ច ឈានស្ស ទុតិយស្ស ច ឈានស្ស លាភិម្ហិ វសិម្ហិ បឋមញ្ច ឈានំ ទុតិយញ្ច ឈានំ សច្ឆិកតំ មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។ អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ តតិយញ្ច ឈានំ ។ បេ ។ បឋមញ្ច ឈានំ ចតុត្ថញ្ច ឈានំ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ បឋមស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស លាភិម្ហិ វសិម្ហិ បឋមញ្ច ឈានំ ចតុត្ថញ្ច ឈានំ សច្ឆិកតំ មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣២៣] អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ សុញ្ញតញ្ច វិមោក្ខំ អនិមិត្តញ្ច វិមោក្ខំ អប្បណិហិតញ្ច វិមោក្ខំ សុញ្ញតញ្ច សមាធឹ

នូវចតុត្ថជ្ឈាន អាត្មាជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ក្នុងផ្ទះដ៏ស្ងាត់ ត្រូវអាបត្តិបាចិត្តិយ ។

[៣២២] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង ទុតិយ-ជ្ឈានផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ទុតិយជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ទុតិយជ្ឈានផង បឋមជ្ឈានផង ទុតិយជ្ឈានផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង តតិយជ្ឈានផង ។ បេ ។ បឋមជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ចតុត្ថ-ជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ចតុត្ថជ្ឈានផង បឋមជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣២៣] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង សុញ្ញត-វិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង សុញ្ញតសមាធិផង

អនិមិត្តញ្ច សមាធឹ អប្បណិហិតញ្ច សមាធឹ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ បឋមស្ស ច ឈានស្ស អប្បណិហិតស្ស ច សមាធិស្ស លាភិម្ហិ វសិម្ហិ បឋ-មញ្ច ឈានំ អប្បណិហិតោ ច សមាធិ សច្ឆិកតោ មយាតិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។

[៣២៤] អារោចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ សុញ្ញតញ្ច សមាបត្តឹ អនិមិត្តញ្ច សមាបត្តឹ អប្បណិហិតញ្ច សមាបត្តឹ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ បឋមស្ស ច ឈានស្ស អប្បណិហិតាយ ច សមាបត្តិយា លាភិម្ហិ វសិម្ហិ បឋមញ្ច ឈានំ អប្បណិហិតា ច សមាបត្តិ សច្ឆិកតា មយាតិ ភ-ណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។

[៣២៥] អារោចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ តិស្សោ ច វិជ្ជា សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ បឋមស្ស ច ឈានស្ស តិស្សន្នញ្ច វិជ្ជានំ លាភិម្ហិ វសិម្ហិ បឋមញ្ច ឈានំ តិស្សោ ច វិជ្ជា សច្ឆិកតា មយាតិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។

អនិមិត្តសមាធិផង់ អប្បណិហិតសមាធិផង់ អាត្មាជាអ្នកបាននូវបឋមជ្ឈាន ផង់ អប្បណិហិតសមាធិផង់ អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង់ អប្បណិ-ហិតសមាធិផង់ បឋមជ្ឈានផង់ អប្បណិហិតសមាធិផង់ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣២៨] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង់ សុញ្ញត-សមាបត្តិផង់ អនិមិត្តសមាបត្តិផង់ អប្បណិហិតសមាបត្តិផង់ អាត្មាជាអ្នកបាននូវបឋមជ្ឈានផង់ អប្បណិហិតសមាបត្តិផង់ អាត្មាជាអ្នកស្ទាត់ក្នុងបឋ-មជ្ឈានផង់ អប្បណិហិតសមាបត្តិផង់ បឋមជ្ឈានផង់ អប្បណិហិតសមាបត្តិផង់ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣២៩] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង់ ត្រៃ-វិជ្ជាផង់ អាត្មាជាអ្នកបាននូវបឋមជ្ឈានផង់ ត្រៃវិជ្ជាផង់ អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង់ ត្រៃវិជ្ជាផង់ បឋមជ្ឈានផង់ ត្រៃវិជ្ជាផង់ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣២៦] អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ ចត្តារោ ច សតិប្បដ្ឋានេ ចត្តារោ ច សម្មប្បធានេ ចត្តារោ ច ឥទ្ធិបាទេ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ បឋមស្ស ច ឈានស្ស ចតុន្នញ្ច ឥទ្ធិបាទានំ លាភិម្ហិ វសិម្ហិ បឋមញ្ច ឈានំ ចត្តារោ ច ឥទ្ធិបាទា សច្ឆិកតា មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣២៧] អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ បញ្ច ច ឥន្ទ្រិយានិ បញ្ច ច ពលានិ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ បឋមស្ស ច ឈានស្ស បញ្ចន្នញ្ច ពលានំ លាភិម្ហិ វសិម្ហិ បឋមញ្ច ឈានំ បញ្ច ច ពលានិ សច្ឆិកតានិ មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣២៨] អាបោចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ សត្ត ច ពោជ្ឈង្គេ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ បឋមស្ស ច ឈានស្ស សត្តន្នញ្ច ពោជ្ឈង្គា-នំ លាភិម្ហិ វសិម្ហិ បឋមញ្ច ឈានំ សត្ត ច ពោជ្ឈង្គា សច្ឆិកតា មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

បាចិត្តិយកណ្ឌ មុសាវាទវគ្គ សិក្ខាបទទី ៨ វិភង្គ

[៣២៦] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង សតិបដ្ឋាន ៤ ផង សម្មប្បធាន ៤ ផង ឥទ្ធិបាទ ៤ ផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ឥទ្ធិបាទ ៤ ផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ឥទ្ធិបាទ ៤ ផង បឋមជ្ឈានផង ឥទ្ធិបាទ ៤ ផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣២៧] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង ឥន្ទ្រិយ ៥ ផង ពលៈ ៥ ផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ពលៈ ៥ ផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ពលៈ ៥ ផង បឋមជ្ឈានផង ពលៈ ៥ ផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣២៨] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង ពោជ្ឈង្គ ៧ ផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ពោជ្ឈង្គ ៧ ផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ពោជ្ឈង្គ ៧ ផង បឋមជ្ឈានផង ពោជ្ឈង្គ ៧ ផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣២៩] អាពេចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ អរិយញ្ច អដ្ឋង្គិកំ មគ្គំ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ បឋមស្ស ច ឈានស្ស អរិយស្ស ច អដ្ឋង្គិកស្ស មគ្គស្ស លាភិម្ហិ វសិម្ហិ បឋមញ្ច ឈានំ អរិយោ ច អដ្ឋង្គិកោ មគ្គោ សច្ឆិកតោ មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣៣០] អាពេចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ សោតាបត្តិផលញ្ច សកទាគាមិផលញ្ច អនាគាមិផលញ្ច អរហត្តផលញ្ច សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ បឋមស្ស ច ឈានស្ស អរហត្តផលស្ស ច លាភិម្ហិ វសិម្ហិ បឋមញ្ច ឈានំ អរហត្តផលញ្ច សច្ឆិកតំ មយាតិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣៣១] អាពេចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ

[៣២៩] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្ន ថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង បឋមជ្ឈានផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣៣០] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្ន ថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង សោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង អរហត្តផលផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង អរហត្តផលផង បឋមជ្ឈានផង អរហត្តផលផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣៣១] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង

រាគោ ច មេ ចត្តោ ទោសោ ច មេ ចត្តោ មោហោ ច មេ ចត្តោ វន្តោ មុត្តោ បហីនោ បដិនិស្សដ្ឋោ ឧក្ខេដិ-តោ សមុក្ខេដិតោតិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។

[៣៣២] អាពេចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ រាគា ច មេ ចិត្តំ វិនីវរណំ ទោសា ច មេ ចិត្តំ វិនីវរណំ មោហា ច មេ ចិត្តំ វិនីវរណន្តិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។

[៣៣៣] អាពេចេយ្យាតិ អនុបសម្បន្នស្ស ទុតិយញ្ច ឈានំ តតិយញ្ច ឈានំ ។ បេ ។ ទុតិយញ្ច ឈានំ ចតុត្ថញ្ច ឈានំ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ ទុតិយស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស លាភិម្ហិ វសិម្ហិ ទុតិយញ្ច ឈានំ ចតុត្ថញ្ច ឈានំ សច្ឆិកតំ មយាតិ ភណន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ អាពេ-ចេយ្យាតិ អនុបសម្បន្នស្ស ទុតិយញ្ច ឈានំ ។ បេ ។

អាត្មាលះបង់រាគៈហើយផង អាត្មាលះបង់ទោសៈហើយផង អាត្មាលះបង់មោហៈហើយផង រាគៈ ទោសៈ មោហៈ អាត្មាបានខ្ជាក់ចោលហើយ បានជម្រុះចោលហើយ បានបន្សាត់ចោលហើយ បានលោស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣៣២] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង ចិត្តរបស់អាត្មាប្រាសចាករាគៈផង ចិត្តរបស់អាត្មាប្រាសចាកទោសៈផង ចិត្តរបស់អាត្មាប្រាសចាកមោហៈផង ត្រូវអាបត្តិបាចិត្តិយ ។

[៣៣៣] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល ទុតិយជ្ឈានផង តតិយជ្ឈានផង ។ បេ ។ ទុតិយជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកបាននូវទុតិយជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងទុតិយជ្ឈានផង ចតុត្ថជ្ឈានផង ទុតិយជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល

មោហា ច មេ ចិត្តំ វិនីវរណាន្តិ ភណន្តស្ស អាបត្តិ ថាចិត្តិយស្ស ។ អាពោចេយ្យាតិ អនុបសម្បន្នស្ស ទុតិ-យញ្ច ឈានំ បឋមញ្ច ឈានំ សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ ទុតិយស្ស ច ឈានស្ស បឋមស្ស ច ឈានស្ស លាភិម្ហិ វសិម្ហិ ទុតិយញ្ច ឈានំ បឋមញ្ច ឈានំ សច្ឆិកតំ មយាតិ ភណន្តស្ស អាបត្តិ ថាចិត្តិ-យស្ស ។ បេ ។ អាពោចេយ្យាតិ អនុបសម្បន្នស្ស មោហា ច មេ ចិត្តំ វិនីវរណំ បឋមញ្ច ឈានំ សមាបជ្ជឹ សមា-បជ្ជាមិ សមាបន្នោ មោហា ច មេ ចិត្តំ វិនីវរណំ បឋ-មស្ស ច ឈានស្ស លាភិម្ហិ វសិម្ហិ មោហា ច មេ ចិត្តំ វិនីវរណំ បឋមញ្ច ឈានំ សច្ឆិកតំ មយាតិ ភណន្តស្ស អាបត្តិ ថាចិត្តិយស្ស ។ បេ ។ អាពោចេយ្យាតិ អនុប-សម្បន្នស្ស មោហា ច មេ ចិត្តំ វិនីវរណំ ទោសា ច មេ ចិត្តំ វិនីវរណាន្តិ ភណន្តស្ស អាបត្តិ ថាចិត្តិយស្ស ។

[៣៣៤] អាពោចេយ្យាតិ អនុបសម្បន្នស្ស បឋ-មញ្ច ឈានំ ទុតិយញ្ច ឈានំ តតិយញ្ច ឈានំ ចតុត្ថញ្ច ឈានំ សុញ្ញតញ្ច វិមោក្ខំ អនិមិត្តញ្ច

ជាអ្នកចូលទុតិយជ្ឈានផង ។ បេ ។ ចិត្តរបស់អាត្មាប្រាសចាកមោហៈផង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រាប់ គឺ ភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលទុតិយជ្ឈានផង បឋមជ្ឈានផង អាត្មាជាអ្នកបាននូវទុតិយជ្ឈានផង បឋមជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងទុតិយជ្ឈានផង បឋមជ្ឈានផង ទុតិយជ្ឈានផង បឋមជ្ឈានផង អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាកមោហៈផង អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង ចិត្តរបស់អាត្មាប្រាសចាកមោហៈផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ចិត្តរបស់អាត្មាប្រាសចាកមោហៈផង បឋមជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់-លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ ។ បេ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាកមោហៈផង ចិត្តរបស់អាត្មាប្រាសចាកទោសៈផង ត្រូវអាបត្តិបាចិត្តិយ ។

[៣៣៤] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អាត្មាបានដល់ហើយនូវបឋមជ្ឈានផង ទុតិយជ្ឈានផង តតិយ-ជ្ឈានផង បតុត្ថជ្ឈានផង សុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង

វិមោក្ខំ អប្បណិហិតញ្ច វិមោក្ខំ សុញ្ញតញ្ច សមាធឹ អនិមិត្តញ្ច សមាធឹ អប្បណិហិតញ្ច សមាធឹ សុញ្ញតញ្ច សមាបត្តឹ អនិមិត្តញ្ច សមាបត្តឹ អប្បណិហិតញ្ច សមាបត្តឹ តិស្សោ ច វិជ្ជា ចត្តារោ ច សតិប្បដ្ឋានេ ចត្តារោ ច សម្មប្បធានេ ចត្តារោ ច ឥទ្ធិបាទេ បញ្ច ច ឥន្ទ្រិយានិ បញ្ច ច ពលានិ សត្ត ច ពោជ្ឈង្គេ អរិយញ្ច អដ្ឋង្គិកំ មគ្គំ សោតាបត្តិផលញ្ច សកទាគាមិផលញ្ច អនាគាមិផលញ្ច អរហត្តផលញ្ច សមាបជ្ជឹ ។ បេ ។ រាគោ ច មេ ចត្តោ ទោសោ ច មេ ចត្តោ មោហោ ច មេ ចត្តោ វន្តោ មុត្តោ បហីនោ បដិនិស្សដ្ឋោ ឧក្ខេដិតោ សមុក្ខេដិតោ រាគា ច មេ ចិត្តំ វិនីវរណំ ទោសា ច មេ ចិត្តំ វិនីវរណំ មោហា ច មេ ចិត្តំ វិនីវរណន្តិ ភណន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣៣៤] អារោចេយ្យាតិ អនុបសម្បន្នស្ស បឋមំ ឈានំ សមាបជ្ជិន្តិ វត្តុកាមោ ទុតិយំ ឈានំ សមាបជ្ជិន្តិ ភណន្តស្ស បដិវិជានន្តស្ស អាបត្តិ បាចិត្តិយស្ស នប្បដិវិជានន្តស្ស អាបត្តិ ទុក្កដស្ស ។ អារោចេយ្យាតិ

អប្បណិហិតវិមោក្ខផង សុញ្ញតសមាធិផង អនិមិត្តសមាធិផង អប្បណិហិតសមាធិផង សុញ្ញតសមាបត្តិផង អនិមិត្តសមាបត្តិផង អប្បណិហិតសមាបត្តិផង វិជ្ជា ៣ ផង សតិបដ្ឋាន ៤ ផង សម្មប្បធាន ៤ ផង ឥទ្ធិបាទ ៤ ផង ឥន្ទ្រិយ ៥ ផង ពលៈ ៥ ផង ពោជ្ឈង្គ ៧ ផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង សោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង ។ បេ ។ រាគៈអាត្មាបានកម្ចាត់ចេញហើយផង ទោសៈអាត្មាបានកម្ចាត់ចេញហើយផង មោហៈអាត្មាបានកម្ចាត់ចេញហើយផង រាគៈទោសៈមោហៈអាត្មាបានខ្ជាក់ចោលហើយ បានជម្រុះចោលហើយ បានបន្សាត់ចោលហើយ បានរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ចិត្តរបស់អាត្មាប្រាសចាករាគៈផង ចិត្តរបស់អាត្មាប្រាសចាកទោសៈផង ចិត្តរបស់អាត្មាប្រាសចាកមោហៈផង ត្រូវអាបត្តិបាចិត្តិយ ។

[៣៣៥] ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលបឋមជ្ឈានហើយ តែត្រឡប់ជាពោលថា អាត្មាបានចូលទុតិយជ្ឈានទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្ន មិនដឹងសេចក្តីច្បាស់ ភិក្ខុនោះ ត្រូវត្រឹម អាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុ ប្រាថ្នានឹង

អនុបសម្បន្នស្ស បឋមំ ឈានំ សមាបជ្ជិន្តិ វត្តុកាមោ តតិយំ ឈានំ ចតុត្ថំ ឈានំ សុញ្ញតំ វិមោក្ខំ អនិមិត្តំ វិមោក្ខំ អប្បណិហិតំ វិមោក្ខំ សុញ្ញតំ សមាធឹ អនិមិត្តំ សមាធឹ អប្បណិហិតំ សមាធឹ សុញ្ញតំ សមាបត្តឹ អនិមិត្តំ សមាបត្តឹ អប្បណិហិតំ សមាបត្តឹ តិស្សោ វិជ្ជា ចត្តារោ សតិប្បដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទេ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គេ អរិយំ អដ្ឋង្គិកំ មគ្គំ សោតាបត្តិផលំ សកទាគាមិផលំ អនាគាមិផលំ អរហត្តផលំ សមាបជ្ជឹ រាគោ មេ ចត្តោ ទោសោ មេ ចត្តោ មោហោ មេ ចត្តោ វន្តោ មុត្តោ បហីនោ បដិនិស្សដ្ឋោ ឧក្ខេដិតោ សមុក្ខេដិតោ រាគា មេ ចិត្តំ វិនីវរណំ ទោសា មេ ចិត្តំ វិនីវរណំ មោហា មេ ចិត្តំ វិនីវរណន្តិ ភណន្តស្ស បដិវិជានន្តស្ស អាបត្តិ បាចិត្តិយស្ស នប្បដិវិជានន្តស្ស អាបត្តិ ទុក្កដស្ស ។

[៣៣៦] អារោចេយ្យាតិ អនុបសម្បន្នស្ស ទុតិយំ ឈានំ សមាបជ្ជិន្តិ វត្តុកាមោ ។ បេ ។ មោហា មេ ចិត្តំ

និយាយប្រាប់អនុបសម្បន្នថា អាត្មាបានចូលបឋមជ្ឈានហើយ ត្រឡប់ជាពោលថា អាត្មាបានចូលតតិយជ្ឈាន ចតុត្ថជ្ឈាន សុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ សុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិត-សមាបត្តិ ត្រៃវិជ្ជា សតិបដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សោតាបត្តិផល សកទាគាមិផល អនាគាមិផល អរហត្តផល រាគៈ អាត្មាបានលះបង់ហើយ ទោសៈអាត្មាបានលះបង់ហើយ មោហៈអាត្មាបានលះបង់ហើយ រាគៈទោសៈមោហៈអាត្មាបានខ្ជាក់ចោលហើយ បានជម្រុះចោលហើយ បានបន្សាត់ចោលហើយ បានរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ចិត្តរបស់អាត្មាប្រាសចាករាគៈ ចិត្តរបស់អាត្មាប្រាសចាកទោសៈ ចិត្តរបស់អាត្មាប្រាសចាកមោហៈ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ បើអនុប-សម្បន្នមិនដឹងសេចក្តីច្បាស់ទេ ត្រូវត្រឹមអាបត្តិទុក្កដ ។

[៣៣៦] ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងនិយាយប្រាប់ ដល់អនុបសម្បន្នថា អាត្មាបានចូលទុតិយជ្ឈានហើយ ។ បេ ។ តែត្រឡប់ជាពោលថា ចិត្តរបស់អាត្មា ប្រាសចាកមោហៈទៅវិញ បើអនុបសម្បន្ន

៣៣១



វិតីវរណាន្តិ ភណន្តស្ស បដិវិជានន្តស្ស អាបត្តិ ចាចិត្តិ-យស្ស នប្បដិវិជានន្តស្ស អាបត្តិ ទុក្កដស្ស ។ អាពោ-ចេយ្យាតិ អនុបសម្បន្នស្ស ទុតិយំ ឈានំ សមាបជ្ជិន្តិ វត្ថុកាមោ បឋមំ ឈានំ សមាបជ្ជិន្តិ ភណន្តស្ស បដិវិជានន្តស្ស អាបត្តិ ចាចិត្តិយស្ស នប្បដិវិជានន្តស្ស អាបត្តិ ទុក្កដស្ស ។ បេ ។ អាពោចេយ្យាតិ អនុប-សម្បន្នស្ស មោហា មេ ចិត្តំ វិតីវរណាន្តិ វត្ថុកាមោ បឋមំ ឈានំ សមាបជ្ជិន្តិ ភណន្តស្ស បដិវិជានន្តស្ស អាបត្តិ ចាចិត្តិយស្ស នប្បដិវិជានន្តស្ស អាបត្តិ ទុក្ក-ដស្ស ។ បេ ។ អាពោចេយ្យាតិ អនុបសម្បន្នស្ស មោហា មេ ចិត្តំ វិតីវរណាន្តិ វត្ថុកាមោ ដោសា មេ ចិត្តំ វិតីវរណាន្តិ ភណន្តស្ស បដិវិជានន្តស្ស អាបត្តិ ចា-ចិត្តិយស្ស នប្បដិវិជានន្តស្ស អាបត្តិ ទុក្កដស្ស ។ អាពោចេយ្យាតិ អនុបសម្បន្នស្ស បឋមញ្ច ឈានំ ទុតិយញ្ច ឈានំ តតិយញ្ច ឈានំ ចតុត្ថញ្ច ឈានំ ។ បេ ។ ដោសា មេ ចិត្តំ វិតីវរណាន្តិ

ដឹងសេចក្តីច្បាស់ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ ត្រូវត្រឹមអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោលដល់អនុបសម្បន្នថា អាត្មាបានចូលទុតិយជ្ឈានហើយ តែត្រ-ឡប់ជាពោលថា អាត្មាបានចូលបឋមជ្ឈានទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ ត្រូវត្រឹមអាបត្តិទុក្កដ ។ បេ ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោលដល់អនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាកមោហៈ តែត្រឡប់ជាពោលថា អាត្មាបានចូលបឋមជ្ឈានហើយទៅវិញ បើអនុបសម្បន្ន ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ទេ ត្រូវត្រឹមអាបត្តិទុក្កដ ។ បេ ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោល ដល់អនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាកមោហៈ តែត្រឡប់ជាពោលថា ចិត្តរបស់អាត្មាប្រាសចាកទោសៈទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ទេ ត្រូវត្រឹមអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោល ដល់អនុបសម្បន្នថា អាត្មាបានចូលបឋមជ្ឈានផង ទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង ។ បេ ។ ចិត្តរបស់អាត្មា ប្រាសចាកទោសៈ តែត្រឡប់ជាពោលថា

វត្តុកាមោ មោហា មេ ចិត្តំ វិនីវរណាន្តិ ភណន្តស្ស បដិវិជានន្តស្ស អាបត្តិ ថាចិត្តិយស្ស នប្បដិវិជានន្តស្ស អាបត្តិ ទុក្កដស្ស ។

[៣៣៧] អាបោចេយ្យាតិ អនុបសម្បន្នស្ស ទុតិយញ្ច ឈានំ តតិយញ្ច ឈានំ ចតុត្ថញ្ច ឈានំ ។ បេ ។ មោហា ច មេ ចិត្តំ វិនីវរណាន្តិ វត្តុកាមោ បឋមំ ឈានំ សមាបជ្ជិន្តិ ភណន្តស្ស បដិវិជានន្តស្ស អាបត្តិ ថាចិត្តិយស្ស នប្បដិវិជានន្តស្ស អាបត្តិ ទុក្កដស្ស ។

[៣៣៨] អាបោចេយ្យាតិ អនុបសម្បន្នស្ស យោ តេ វិហារេ វសិ សោ ភិក្ខុ បឋមំ ឈានំ សមាបជ្ជិ សមាបជ្ជតិ សមាបន្នោ សោ ភិក្ខុ បឋមស្ស ឈានស្ស លាភី វសី តេន ភិក្ខុនា បឋមំ ឈានំ សច្ឆិកាតន្តិ ភណន្តស្ស អាបត្តិ ទុក្កដស្ស ។ អាបោចេយ្យាតិ អនុបសម្បន្នស្ស យោ តេ វិហារេ វសិ សោ ភិក្ខុ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ សមាបជ្ជិ សមាបជ្ជតិ សមាបន្នោ សោ ភិក្ខុ ចតុត្ថស្ស ឈានស្ស លាភី វសី តេន ភិក្ខុនា ចតុត្ថំ ឈានំ

ចិត្តរបស់អាត្មាប្រាសចាកមោហៈទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ ត្រូវត្រឹមអាបត្តិទុក្កដ ។

[៣៣៧] ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងនិយាយប្រាប់ ដល់អនុបសម្បន្នថា អាត្មាបានចូលទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង ។ បេ ។ ចិត្តរបស់អាត្មាប្រាសចាកមោហៈផង តែត្រឡប់ជានិយាយថា អាត្មាបានចូលបឋមជ្ឈានហើយទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ ត្រូវត្រឹមអាបត្តិទុក្កដ ។

[៣៣៨] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ដល់អនុបសម្បន្នថា ភិក្ខុអង្គណា នៅក្នុងវិហាររបស់អ្នក ភិក្ខុអង្គនោះ បានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈាន ភិក្ខុនោះជាអ្នកបាននូវបឋមជ្ឈាន ភិក្ខុនោះជាអ្នកស្ទាត់ក្នុងបឋមជ្ឈាន បឋមជ្ឈាន ភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា ភិក្ខុណា នៅក្នុងវិហាររបស់អ្នក ភិក្ខុនោះ បានចូលហើយ កំពុងចូល ជាអ្នកចូលទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ភិក្ខុនោះជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះ ជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈាន ចតុត្ថជ្ឈាន

៣៣៣



សច្ចិកតន្តិ ភណន្តស្ស អាបត្តិ ទុក្កដស្ស ។ អារោចេយ្យាតិ អនុបសម្បន្នស្ស យោ តេ វិហារេ វសិ សោ ភិក្ខុ សុញ្ញតំ វិមោក្ខំ អនិមិត្តំ វិមោក្ខំ អប្បណិហិតំ វិមោក្ខំ សុញ្ញតំ សមាធឹ អនិមិត្តំ សមាធឹ អប្បណិហិតំ សមាធឹ សមាបជ្ជិ សមាបជ្ជតិ សមាបន្នោ សោ ភិក្ខុ អប្បណិហិតស្ស សមាធិស្ស លាភី វសី តេន ភិក្ខុនា អប្បណិហិតោ សមាធិ សច្ចិកតោតិ ភណន្តស្ស អាបត្តិ ទុក្កដស្ស ។ អារោចេយ្យាតិ អនុបសម្បន្នស្ស យោ តេ វិហារេ វសិ សោ ភិក្ខុ សុញ្ញតំ សមាបត្តឹ អនិមិត្តំ សមាបត្តឹ អប្បណិហិតំ សមាបត្តឹ តិស្សោ វិជ្ជា ចត្តារោ សតិបដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទេ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គេ អរិយំ អដ្ឋង្គិកំ មគ្គំ សោតាបត្តិផលំ សកទាគាមិផលំ អនាគាមិផលំ អរហត្តផលំ សមាបជ្ជិ ។ បេ ។ តស្ស ភិក្ខុនោ រាគោ ចត្តោ ទោសោ ចត្តោ មោហោ ចត្តោ វន្តោ មុត្តោ បហីនោ បដិនិស្សដ្ឋោ

ភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះ បានដល់ហើយ កំពុងដល់ ជាអ្នកដល់នូវសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ ភិក្ខុនោះ ជាអ្នកបាននូវអប្បណិហិតសមាធិ ភិក្ខុនោះ ជាអ្នកស្ទាត់ក្នុងអប្បណិហិតសមាធិ អប្បណិហិតសមាធិ ភិក្ខុនោះ បានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា ភិក្ខុណា នៅក្នុងវិហាររបស់អ្នក ភិក្ខុនោះ បានដល់ហើយនូវសុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិ-ហិតសមាបត្តិ ត្រៃវិជ្ជា សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សោតាបត្តិផល សកទាគាមិផល អនាគាមិផល អរហត្តផល ។ បេ ។ រាគៈភិក្ខុនោះ បានលះបង់ហើយ ទោសៈភិក្ខុនោះបានលះបង់ហើយ មោហៈភិក្ខុនោះបាន លះបង់ហើយ រាគៈទោសៈមោហៈភិក្ខុនោះបានខ្ជាក់ចោលហើយ បាន ជម្រុះចោលហើយ បានបន្សាត់ចោលហើយ បានរលាស់ចោលហើយ

ឧក្ខេជិតោ សមុក្ខេជិតោ តស្ស ភិក្ខុនោ រាគា ចិត្តំ វិនីវរណំ ទោសា ចិត្តំ វិនីវរណំ មោហា ចិត្តំ វិនីវរណន្តិ ភណន្តស្ស អាបត្តិ ទុក្កដស្ស ។ អាភោ-ចេយ្យាតិ អនុបសម្បន្នស្ស យោ តេ វិហារេ វសិ សោ ភិក្ខុ សុញ្ញាគារេ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ សមាបជ្ជិ សមាបជ្ជតិ សមាបន្នោ សោ ភិក្ខុ សុញ្ញាគារេ ចតុត្ថស្ស ឈានស្ស លាភី វសី តេន ភិក្ខុនា សុញ្ញាគារេ ចតុត្ថំ ឈានំ សច្ឆិកតន្តិ ភណន្តស្ស អាបត្តិ ទុក្កដស្ស ។ អាភោចេយ្យាតិ អនុបសម្បន្នស្ស យោ តេ វិហារំ បរិ-ភុញ្ជិ យោ តេ ចីវរំ បរិភុញ្ជិ យោ តេ បិណ្ឌបាតំ បរិភុញ្ជិ យោ តេ សេនាសនំ បរិភុញ្ជិ យោ តេ គិលានប្បច្ច-យភេសជ្ជបរិក្ខារំ បរិភុញ្ជិ សោ ភិក្ខុ សុញ្ញាគារេ ចតុត្ថំ ឈានំ សមាបជ្ជិ សមាបជ្ជតិ សមាបន្នោ សោ ភិក្ខុ សុញ្ញាគារេ ចតុត្ថស្ស ឈានស្ស លាភី វសី តេន ភិក្ខុនា សុញ្ញាគារេ ចតុត្ថំ ឈានំ សច្ឆិកតន្តិ ភណន្តស្ស អាបត្តិ ទុក្កដស្ស ។

បានវើឡើងហើយ បានគាស់រំលើងហើយ ចិត្តរបស់ភិក្ខុនោះប្រាស ចាករាគៈ ចិត្តរបស់ភិក្ខុនោះប្រាសចាកទោសៈ ចិត្តរបស់ភិក្ខុនោះប្រាស ចាកមោហៈ ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះបាន ចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះជា អ្នកស្ទាត់ក្នុងចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះ បានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ប្រាប់ គឺ ភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា ភិក្ខុណានៅគ្រប់គ្រងវិហាររបស់ អ្នក ភិក្ខុណាប្រើប្រាស់ចីវររបស់អ្នក ភិក្ខុណាបរិភោគបិណ្ឌបាតរបស់ អ្នក ភិក្ខុណាប្រើប្រាស់សេនាសនៈរបស់អ្នក ភិក្ខុណាបរិភោគគិលាន-ប្បច្ចយភេសជ្ជបរិក្ខាររបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល ជាអ្នកចូល ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។

[៣៣៩] អារោចេយ្យាតិ អនុបសម្បន្នស្ស យេន តេ វិហារោ បរិភុត្តោ យេន តេ ចីវរំ បរិភុត្តំ យេន តេ បិណ្ឌបាតោ បរិភុត្តោ យេន តេ សេនាសនំ បរិភុត្តំ យេន តេ គិលានប្បច្ចយភេសជ្ជបរិក្ខារោ បរិភុត្តោ សោ ភិក្ខុ សុញ្ញាគារេ ចតុត្ថំ ឈានំ សមាបជ្ជិ សមាបជ្ជតិ សមាបន្នោ សោ ភិក្ខុ សុញ្ញាគារេ ចតុត្ថស្ស ឈានស្ស លាភី វសី តេន ភិក្ខុនា សុញ្ញាគារេ ចតុត្ថំ ឈានំ សច្ឆិកតន្តិ ភណន្តស្ស អាបត្តិ ទុក្កដស្ស ។

[៣៤០] អារោចេយ្យាតិ អនុបសម្បន្នស្ស យំ ត្វំ អាគម្ម វិហារំ អទាសិ ចីវរំ បិណ្ឌបាតំ សេនាសនំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ អទាសិ សោ ភិក្ខុ សុញ្ញា-គារេ ចតុត្ថំ ឈានំ សមាបជ្ជិ ។ បេ ។ តេន ភិក្ខុនា សុញ្ញាគារេ ចតុត្ថំ ឈានំ សច្ឆិកតន្តិ ភណន្តស្ស អាបត្តិ ទុក្កដស្ស ។

[៣៤១] អនាបត្តិ ឧបសម្បន្នស្ស ភូតំ អារោចេសិ អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។

[៣៣៩] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា វិហាររបស់អ្នក ភិក្ខុណាបាននៅគ្រប់គ្រងហើយ ចីវររបស់អ្នកភិក្ខុណាបានប្រើប្រាស់ហើយ បិណ្ឌបាតរបស់អ្នក ភិក្ខុណាបានបរិភោគហើយ សេនាសនៈរបស់អ្នក ភិក្ខុណាបានប្រើប្រាស់ហើយ គិលានប្បច្ចយភេសជ្ជបរិក្ខាររបស់អ្នក ភិក្ខុណាបានបរិភោគហើយ ភិក្ខុនោះបានចូលហើយ កំពុងចូល ជាអ្នកចូល ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។

[៣៤០] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ ចំពោះអនុបសម្បន្នថា អ្នកឯងបានឲ្យវិហារ អ្នកឯងបានឲ្យចីវរ អ្នកឯងបានឲ្យបិណ្ឌបាត អ្នកឯងបានឲ្យសេនាសនៈ អ្នកឯងបានឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ព្រោះអាស្រ័យនូវភិក្ខុណា ភិក្ខុនោះបានចូលហើយនូវចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ។ បេ ។ ចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះបានធ្វើឲ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ ។

[៣៤១] អាបត្តិមិនមានដល់ភិក្ខុ ដែលប្រាប់ឧត្តរិមនុស្សធម៌ ដែលខ្លួនបានពិតប្រាកដ ដល់ឧបសម្បន្នបុគ្គល ១ ដល់ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៨ ចប់ ។

# នវមសិក្ខាបទំ

[៣៤២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ ឆព្វគ្គិយេហិ ភិក្ខូហិ សទ្ធឹ ភណ្ឌនការកោ ហោតិ ។ សោ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អាបត្តឹ[១] អាបជ្ជិត្វា សង្ឃំ តស្សា អាបត្តិយា បរិវាសំ យាចិ ។ តស្ស សង្ឃោ តស្សា អាបត្តិយា បរិវាសំ អទាសិ ។ តេន ខោ បន សមយេន សាវត្ថិយំ អញ្ញតរស្ស បូគស្ស សង្ឃភត្តំ ហោតិ ។ សោ បរិវសន្តោ[២] ភត្តគ្គេ អាស-នបរិយន្តេ និសីទិ ។ ឆព្វគ្គិយា ភិក្ខូ តេ ឧបាសកេ ឯតទវោចុំ ឯសោ អាវុសោ អាយស្មា ឧបនន្ទោ សក្យបុត្តោ តុម្ហាកំ សម្ភាវិតោ កុលុបកោ យេ នេវ ហត្ថេន សទ្ធាទេយ្យំ ភុញ្ជតិ តេនេវ ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេសិ សោ សញ្ចេតនិកំ

១ ឱ. ម. សុក្កវិសដ្ឋិ អាបត្តឹ ។ ២ បរិវាសំ បរិវសន្តោតិបិ ទិស្សតិ ។

# សិក្ខាបទទី ៩

[៣៤២] សម័យនោះ ព្រះភគវន្តសម្ពុទ្ធ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ឧបនន្ទសក្យបុត្រដ៏មានអាយុបានឈ្មោះនឹងពួកឆព្វគ្គិយភិក្ខុ (គឺភិក្ខុមានពួក ៦) ។ ឧបនន្ទនោះ ត្រូវអាបត្តិសញ្ចេតនិកៈ (សង្ឃាទិសេស) គឺធ្វើទឹកសុក្កៈឲ្យឃ្លាតចេញ ហើយបានសូមបរិវាសអំពីជំនុំសង្ឃ ដើម្បីអាបត្តិនោះ ។ ជំនុំសង្ឃក៏បានឲ្យបរិវាសដល់ឧបនន្ទនោះ ដើម្បីអាបត្តិនោះ ។ វេលានោះឯង ក្រុងសាវត្ថីមានជនមួយពួក (គេបានចាត់ចែង) ភត្តថ្វាយសង្ឃ ។ ឯឧបនន្ទនោះ កំពុងនៅក្នុងបរិវាសបានអង្គុយចុងអាសនៈក្នុងរោងភត្ត ។ ពួកឆព្វគ្គិយភិក្ខុ ក៏បាននិយាយប្រាប់ឧបាសកទាំងនោះថា អាវុសោ ឧប-នន្ទសក្យបុត្រដ៏មានអាយុនេះជាទីសរសើរ ជាជីតុនរបស់អ្នកទាំងឡាយ តែងឆាន់ភោជនដែលគេឲ្យ ដោយសទ្ធា ដោយដៃណា យកដៃនោះឯងព្យាយាមធ្វើឲ្យទឹកអសុចិហូរចេញ ឧបនន្ទនោះត្រូវអាបត្តិសញ្ចេតនិកៈ

សុក្កវិសដ្ឋឹ អាបត្តឹ អាបជ្ជិត្វា សង្ឃំ តស្សា អាបត្តិយា បរិវាសំ យាចិ តស្ស សង្ឃោ តស្សា អាបត្តិយា បរិវាសំ អទាសិ សោ បរិវសន្តោ[១] អាសនបរិយន្តេ និសិន្នោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ភិក្ខុស្ស ទុដ្ឋុល្លំ អាបត្តឹ អនុបសម្បន្នស្ស អារោចេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខុស្ស ទុដ្ឋុល្លំ អាបត្តឹ អនុបសម្បន្នស្ស អារោចេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខុស្ស ទុដ្ឋុល្លំ អាបត្តឹ អនុបសម្បន្នស្ស អារោចេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ

១ បរិវាសំ បរិវសន្តោតិបិ ទិស្សតិ ។

ព្រោះធ្វើទឹកសុក្កៈឲ្យឃ្លាតចេញ ហើយបានសូមបរិវាសអំពីជំនុំសង្ឃ ដើម្បីអាបត្តិនោះ ជំនុំសង្ឃក៏បានឲ្យបរិវាសដល់ឧបនន្ទនោះ ដើម្បីអាបត្តិនោះ ឧបនន្ទនោះ ឥឡូវកំពុងនៅបរិវាស ហើយអង្គុយនៅក្នុងទីបំផុតអាសនៈ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនោះ ក៏ពោលទោស តិះ-ដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងហ៊ានប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុបសម្បន្នបុគ្គលសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយបានប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុបសម្បន្នបុគ្គល ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងហ៊ានប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុបសម្បន្នបុគ្គលសោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះនឹងបានដឹកនាំពួកមនុស្សដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើងក៏ទេដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើង

សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុស្ស ទុដ្ឋុល្លំ អាបត្តឹ អនុបសម្បន្នស្ស អារោចេយ្យ អញ្ញត្រ ភិក្ខុសម្មតិយា បាចិត្តិយន្តិ ។

[៣៤៣] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុស្សាតិ អញ្ញស្ស ភិក្ខុស្ស ។ ទុដ្ឋុល្លា នាម អាបត្តិ ចត្តារិ ច បារាជិកានិ តេរស ច សង្ឃាទិសេសា ។ អនុបសម្បន្នោ នាម ភិក្ខុញ្ច ភិក្ខុនិញ្ច ឋបេត្វា អវសេសោ អនុបសម្បន្នោ នាម ។ អារោចេយ្យាតិ អារោចេតិ ឥត្ថិយា វា បុរិសស្ស វា គហដ្ឋស្ស វា បព្វជិតស្ស វា ។ អញ្ញត្រ ភិក្ខុ-សម្មតិយាតិ ឋបេត្វា ភិក្ខុសម្មតឹ ។

[៣៤៤] អត្ថិ ភិក្ខុសម្មតិ អាបត្តិបរិយន្តា ន កុលបរិយន្តា អត្ថិ ភិក្ខុសម្មតិ កុលបរិយន្តា ន អាបត្តិបរិយន្តា អត្ថិ ភិក្ខុសម្មតិ អាបត្តិបរិយន្តា ច កុលបរិយន្តា ច អត្ថិ ភិក្ខុសម្មតិ នេវ អាបត្តិ-បរិយន្តា ន កុលបរិយន្តា ។ អាបត្តិបរិយន្តា នាម

នូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុបសម្បន្នបុគ្គល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសន្មតឲ្យប្រាប់ ។

[៣៤៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបារាជិកសិក្ខាបទទី ១ ។ ពាក្យថា ភិក្ខុ គឺភិក្ខុដទៃ ។ អាបត្តិបារាជិក ៤ និងអាបត្តិសង្ឃាទិសេស ១៣ ឈ្មោះថា ទុដ្ឋុល្លាបត្តិ ។ ដែលហៅថា អនុបសម្បន្ននោះ គឺលើកលែងភិក្ខុ និងភិក្ខុនីចេញ ក្រៅអំពីនោះ ហៅថា អនុបសម្បន្នទាំងអស់ ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាប់ដល់ស្រីក្តី ដល់ប្រុសក្តី ដល់គ្រហស្ថក្តី ដល់អ្នកបួសក្តី ។ ពាក្យថា វៀរលែងតែភិក្ខុដែលសង្ឃសន្មតឲ្យប្រាប់ គឺលើកលែងតែភិក្ខុដែលបានសេចក្តីសម្មតអំពីសង្ឃ ។

[៣៤៤] ឯសេចក្តីសម្មតរបស់ភិក្ខុដែលសង្ឃកំណត់ឲ្យ មាន ៤ យ៉ាង គឺសម្មតិកំណត់អាបត្តិ មិនកំណត់ត្រកូល ១ សម្មតិកំណត់ត្រកូល មិនកំណត់អាបត្តិ ១ សម្មតិកំណត់អាបត្តិ និងត្រកូល ១ សម្មតិមិនកំណត់អាបត្តិមិនកំណត់ត្រកូល ១ ។ ដែលហៅថា កំណត់អាបត្តិនោះ

អាបត្តិយោ បរិគ្គហិតាយោ ហោន្តិ ឯត្តកាហិ អាបត្តីហិ អាពោចេតព្វាតិ ។ កុលបរិយន្តា ជាម កុលានិ បរិគ្គហិតានិ ហោន្តិ ឯត្តកេសុ កុលេសុ អាពោចេតព្វាតិ ។ អាបត្តិបរិយន្តា ច កុលបរិយន្តា ច ជាម អាបត្តិយោ ច បរិគ្គហិតាយោ ហោន្តិ កុលានិ ច បរិគ្គហិតានិ ហោន្តិ ឯត្តកាហិ អាបត្តីហិ ឯត្តកេសុ កុលេសុ អាពោចេតព្វាតិ ។ នេវ អាបត្តិបរិយន្តា ន កុលបរិយន្តា ជាម អាបត្តិយោ ច អបរិគ្គហិតាយោ ហោន្តិ កុលានិ ច អបរិគ្គហិតានិ ហោន្តិ ឯត្តកាហិ អាបត្តីហិ ឯត្តកេសុ កុលេសុ អាពោចេតព្វាតិ ។

[៣៤៥] អាបត្តិបរិយន្តេ យា អាបត្តិយោ បរិគ្គហិតាយោ ហោន្តិ តា អាបត្តិយោ ឋបេត្វា អញ្ញាហិ អាបត្តីហិ អាពោចេតិ អាបត្តិ ចាចិត្តិយស្ស ។ កុលបរិយន្តេ យានិ កុលានិ បរិគ្គហិតានិ ហោន្តិ តានិ កុលានិ

គឺអាបត្តិ (ប៉ុន្មាន) ដែលសង្ឃកំណត់ឲ្យហើយ ភិក្ខុដែលសង្ឃសន្មតត្រូវប្រាប់អាបត្តិប៉ុណ្ណោះ ។ ដែលហៅថា កំណត់ត្រកូល (នោះ) គឺត្រកូល (ប៉ុន្មាន) ដែលសង្ឃកំណត់ឲ្យហើយ ភិក្ខុដែលសង្ឃសន្មត ត្រូវប្រាប់ (អាបត្តិ) ដល់ត្រកូលប៉ុណ្ណោះ ។ ដែលហៅថា កំណត់អាបត្តិ និងកំណត់ត្រកូល (នោះ) គឺអាបត្តិ (ប៉ុន្មាន) ដែលសង្ឃកំណត់ឲ្យហើយ និងត្រកូល (ប៉ុន្មាន) ដែលសង្ឃកំណត់ឲ្យហើយ ភិក្ខុដែលសង្ឃសន្មតត្រូវប្រាប់ (អាបត្តិប៉ុណ្ណោះ) ដល់ត្រកូលប៉ុណ្ណោះបាន ។ ដែលហៅថា មិនកំណត់អាបត្តិមិនកំណត់ត្រកូល (នោះ) គឺអាបត្តិ (ប៉ុន្មាន) ដែលសង្ឃមិនកំណត់ឲ្យហើយ និងត្រកូល (ប៉ុន្មាន) ដែលសង្ឃមិនកំណត់ឲ្យហើយ ភិក្ខុដែលសង្ឃសន្មតត្រូវប្រាប់អាបត្តិដែលសង្ឃមិនកំណត់ឲ្យប៉ុណ្ណោះ ដល់ត្រកូលដែលសង្ឃមិនកំណត់ឲ្យប៉ុណ្ណោះបាន ។

[៣៤៥] (ម្យ៉ាងទៀត) ត្រង់ពាក្យថា កំណត់អាបត្តិ គឺពួកអាបត្តិណាដែលសង្ឃបានកំណត់ឲ្យហើយ ភិក្ខុមិនប្រាប់អាបត្តិទាំងនោះ ទៅប្រាប់ពួកអាបត្តិដទៃវិញ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា កំណត់ត្រកូល គឺពួកត្រកូលណាដែលសង្ឃបានកំណត់ឲ្យហើយ ភិក្ខុមិន

បចេត្វា អញ្ញេសុ កុលេសុ អាហោចេតិ អាបត្តិ ចាចិត្តិយស្ស ។ អាបត្តិបរិយន្តេ ច កុលបរិយន្តេ ច យា អាបត្តិយោ បរិគ្គហិតាយោ ហោន្តិ តា អាបត្តិយោ ឋបេត្វា យានិ កុលានិ បរិគ្គហិតានិ ហោន្តិ តានិ កុលានិ ឋបេត្វា អញ្ញាហិ អាបត្តីហិ អញ្ញេសុ កុលេសុ អាហោចេតិ អាបត្តិ ចាចិត្តិយស្ស ។ នេវ អាបត្តិបរិយន្តេ ន កុលបរិយន្តេ អនាបត្តិ ។

[៣៤៦] ទុដ្ឋុល្លាយ អាបត្តិយា ទុដ្ឋុល្លាបត្តិសញ្ញី អនុបសម្បន្នស្ស អាហោចេតិ អញ្ញត្រ ភិក្ខុសម្មតិយា អាបត្តិ ចាចិត្តិយស្ស ។ ទុដ្ឋុល្លាយ អាបត្តិយា វេមតិកោ អនុបសម្បន្នស្ស អាហោចេតិ អញ្ញត្រ ភិក្ខុសម្មតិយា អាបត្តិ ចាចិត្តិយស្ស ។ ទុដ្ឋុល្លាយ អាបត្តិយា អទុដ្ឋុល្លាបត្តិសញ្ញី អនុបសម្បន្នស្ស អាហោចេតិ អញ្ញត្រ ភិក្ខុសម្មតិយា អាបត្តិ ចាចិត្តិយស្ស ។

ប្រាប់ពួកត្រកូលនោះ បែរជាប្រាប់ត្រកូលទាំងឡាយដទៃវិញ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា កំណត់អាបត្តិ និងកំណត់ត្រកូល គឺពួកអាបត្តិណាដែលសង្ឃបានកំណត់ឲ្យក្តី ពួកត្រកូលណាដែលសង្ឃបានកំណត់ឲ្យក្តី ភិក្ខុនោះមិនប្រាប់អាបត្តិទាំងនោះ មិនប្រាប់ត្រកូលទាំងនោះ ទៅប្រាប់អាបត្តិឯទៀត ត្រកូលឯទៀតវិញ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា មិនកំណត់អាបត្តិ មិនកំណត់ត្រកូល (នោះ) គឺភិក្ខុនោះប្រាប់អនុបសម្បន្នដោយអាបត្តិណា ៗ ត្រកូលណា ៗ ក៏ដោយ មិនត្រូវអាបត្តិឡើយ ។

[៣៤៦] ទុដ្ឋុល្លាបត្តិ ភិក្ខុដឹងច្បាស់ថា ទុដ្ឋុល្លាបត្តិ ហើយប្រាប់ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសន្មតឲ្យប្រាប់ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងទុដ្ឋុល្លាបត្តិ ហើយប្រាប់ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសន្មតឲ្យប្រាប់ ។ ទុដ្ឋុល្លាបត្តិ ភិក្ខុសំគាល់ថា អទុដ្ឋុល្លាបត្តិ ហើយប្រាប់ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសន្មតឲ្យប្រាប់ ។

បាចិត្តិយកណ្ឌេ មុសាវាទវគ្គស្ស នវមសិក្ខាបទស្ស អនាបត្តិវារោ

[៣៤៧] អទុដ្ឋុល្លំ អាបត្តឹ អារោចេតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នស្ស ទុដ្ឋុល្លំ វា អទុដ្ឋុល្លំ វា អជ្ឈាចារំ អារោចេតិ អាបត្តិ ទុក្កដស្ស ។ អទុដ្ឋុល្លាយ អាបត្តិយា ទុដ្ឋុល្លាបត្តិសញ្ញី អាបត្តិ ទុក្កដស្ស ។ អទុដ្ឋុល្លាយ អាបត្តិយា វេមតិកោ អាបត្តិ ទុក្កដស្ស ។ អទុដ្ឋុល្លាយ អាបត្តិយា អទុដ្ឋុល្លាបត្តិសញ្ញី អាបត្តិ ទុក្កដស្ស ។

[៣៤៨] អនាបត្តិ វត្ថុំ អារោចេតិ នោ អាបត្តឹ អាបត្តឹ អារោចេតិ នោ វត្ថុំ ភិក្ខុសម្មតិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។

[៣៤៧] ភិក្ខុប្រាប់អទុដ្ឋុល្លាបត្តិ (ដល់អនុបសម្បន្ន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រាប់អជ្ឈាចារអាក្រក់ក្តី[១] មិនសូវអាក្រក់ក្តី[២] របស់អនុបសម្បន្ន គឺសាមណេរ (ដល់អនុបសម្បន្នដទៃ) ត្រូវអាបត្តិទុក្កដ ។ អទុដ្ឋុល្លាបត្តិ ភិក្ខុសំគាល់ថា ទុដ្ឋុល្លាបត្តិវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យ ក្នុងអទុដ្ឋុល្លាបត្តិ ត្រូវអាបត្តិទុក្កដ ។ អទុដ្ឋុ-ល្លាបត្តិ ភិក្ខុសំគាល់ថា អទុដ្ឋុល្លាបត្តិ ត្រូវអាបត្តិទុក្កដ ។

[៣៤៨] អាបត្តិមិនមាន ដល់ភិក្ខុដែលប្រាប់តែវត្ថុ[៣] មិនប្រាប់អាបត្តិ ដល់ភិក្ខុដែលប្រាប់តែអាបត្តិ[៤] មិនប្រាប់វត្ថុ ដល់ភិក្ខុដែលបានសេចក្តីសន្មតអំពីសង្ឃ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់ ។

---

១ សាមណេរប្រព្រឹត្តខុសក្នុងសិក្ខាបទ ៥ ខាងដើម ឈ្មោះថាអជ្ឈាចារអាក្រក់ ។ ២ សាម-ណេរប្រព្រឹត្តខុសក្នុងសិក្ខាបទ ៥ ខាងចុងឈ្មោះថាអជ្ឈាចារមិនសូវអាក្រក់ ។ ៣ ភិក្ខុប្រាប់ថា ភិក្ខុនេះត្រូវសុក្កវិសដ្ឋិ (គឺធ្វើសុក្កៈឲ្យឃ្លាតចេញ) ជាដើម ហៅថា ប្រាប់តែវត្ថុ ។ ៤ ភិក្ខុប្រាប់ថា ភិក្ខុនេះ ត្រូវអាបត្តិបារាជិក ត្រូវអាបត្តិសង្ឃាទិសេសជាដើម ហៅថា ប្រាប់តែអាបត្តិ ។

# ទសមសិក្ខាបទំ

[៣៤៩] តេន សមយេន ពុទ្ធោ ភគវា អាឡវិយំ វិហរតិ អគ្គាឡវេ ចេតិយេ ។ តេន ខោ បន សមយេន អាឡវិកា ភិក្ខូ នវកម្មំ ករោន្តា បឋវឹ ខណន្តិបិ ខណាបេន្តិបិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា បឋវឹ ខណិ-ស្សន្តិបិ ខណាបេស្សន្តិបិ ឯកិន្ទ្រិយំ សមណា សក្យ-បុត្តិយា ជីវំ វិហេឋេន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបា-ចេន្តិ កថំ ហិ នាម អាឡវិកា ភិក្ខូ បឋវឹ ខណិស្សន្តិបិ ខណាបេស្សន្តិបីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯត-មត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ បឋវឹ ខណថបិ ខណាបេថបីតិ ។ សច្ចំ ភគវាតិ ។

# សិក្ខាបទទី ១០

[៣៤៩] សម័យនោះ ព្រះភគវន្តសម្ពុទ្ធ កាលគង់នៅអគ្គាឡវចេតិយ ក្បែរក្រុងអាឡវី ។ គ្រានោះឯង ពួកអាឡវិកភិក្ខុ កាលធ្វើនវកម្ម ក៏ជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យជីកខ្លះ នូវផែនដី ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ មិនសមបើនឹងហ៊ានជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យជីកខ្លះ នូវផែនដីសោះ ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រហ៊ានបៀតបៀនវត្ថុរស់ដែលមានឥន្ទ្រិយមួយ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកអាឡវិកភិក្ខុ មិនគួរបើនឹងហ៊ានជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យជីកខ្លះ នូវផែនដីសោះ ។ វេលានោះឯង ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យជីកខ្លះ នូវផែនដី ពិតមែនឬ ។ ភិក្ខុទាំងនោះ ក្រាបទូលតបវិញថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន ។

វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា បថវឹ ខណិស្សថបិ ខណាបេស្សថបិ ជីវសញ្ញិនោ ហិ មោឃបុរិសា មនុស្សា បថវិយា នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ បថវឹ ខណេយ្យ វា ខណាបេយ្យ វា បាចិត្តិយន្តិ ។

[៣៨០] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ បថវី នាម ទ្វេ បថវិយោ ជាតា ច បថវី អជាតា ច បថវី ។ ជាតា នាម បថវី សុទ្ធបំសុ សុទ្ធមត្តិកា អប្បបាសាណា អប្បសក្ខរា អប្បកឋលា អប្បមរុម្ពា អប្បវាលិកា យេភុយ្យេន បំសុ

ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរបើនឹងហ៊ានជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យជីកខ្លះ នូវផែនដីទេ នែមោឃបុរសទាំងឡាយ ព្រោះពួកមនុស្សមានសេចក្តីសំគាល់ថា ផែនដីជាវត្ថុមានជីវិត នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យជីកក្តី នូវផែនដី ត្រូវអាបត្តិបាចិត្តិយ ។

[៣៥០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ផែនដី បានដល់ផែនដីមានពីរយ៉ាង គឺជាតបឋវី ផែនដីមានដីច្រើនជាងវត្ថុឯទៀត ១ អជាតបឋវី ផែនដីមានដីតិចជាងវត្ថុឯទៀត ១ ។ ដែលហៅថា ជាតបឋវី (នោះ) គឺអាចម៍ដីសុទ្ធ ដីស្អិតសុទ្ធ ដីមានថ្មតិច មានក្រួសតិច មានបំណែកអម្បែងតិច មានក្រួសរវាំងតិច មានខ្សាច់តិច មានអាចម៍ដីច្រើន

យេភុយ្យេន មត្តិកា អឌឍ្ឍាបិ វុច្ចតិ ជាតា បឋវី ។ យោបិ បំសុបុញ្ជោ វា មត្តិកាបុញ្ជោ វា អតិរេកចាតុម្មាសំ ឱវដ្ឋោ អយម្បិ វុច្ចតិ ជាតា បឋវី ។ អជាតា នាម បឋវី សុទ្ធចាសាណា សុទ្ធសក្ខរា សុទ្ធកឋលា សុទ្ធមរុម្ពា សុទ្ធពាលិកា អប្បបំសុ អប្បមត្តិកា យេភុយ្យេន ចាសាណា យេភុយ្យេន សក្ខរា យេភុយ្យេន កឋលា យេភុយ្យេន មរុម្ពា យេភុយ្យេន ពាលិកា ឧឌ្ឍ្ឍាបិ វុច្ចតិ អជាតា បឋវី ។ យោបិ បំសុបុញ្ជោ វា មត្តិកាបុញ្ជោ វា ឩនកចាតុម្មាសំ[១] ឱវដ្ឋោ អយម្បិ វុច្ចតិ អជាតា បឋវី ។

[៣៤១] ខណេយ្យាតិ សយំ ខណតិ អាបត្តិ ចាចិត្តិយស្ស ។ ខណាបេយ្យាតិ អញ្ញំ ខណាបេតិ អាបត្តិ ចាចិត្តិយស្ស ។ សកឹ អាណត្តោ ពហុកំបិ ខណតិ អាបត្តិ ចាចិត្តិយស្ស ។

១ ឱ. ម. ឱមកចាតុមាសំ ។

មានដីស្អិតច្រើន ឬជាផែនដីគេមិនដែលជុត តថាគតហៅថា ជាតបឋវី ។ ម្យ៉ាងទៀត គំនរអាចម៍ដីណាក្តី គំនរដីស្អិតណាក្តី ដែលមានភ្លៀងធ្លាក់ត្រូវជាង ៤ ខែ គំនរនេះឯង តថាគតហៅថា ជាតបឋវីដែរ ។ ដែលហៅថា អជាតបឋវី (នោះ) គឺផែនដីដែលមានថ្មសុទ្ធ មានក្រួសសុទ្ធ មានបំណែកអម្បែងសុទ្ធ មានក្រួសរវាងសុទ្ធ មានខ្សាច់សុទ្ធ មានអាចម៍ដីតិច មានដីស្អិតតិច មានថ្មច្រើន មានក្រួសច្រើន មានបំណែកអម្បែងច្រើន មានក្រួសរវាងច្រើន មានខ្សាច់ច្រើន ជាផែនដីដែលគេជុតហើយ តថាគត ក៏ហៅថា អជាតបឋវី ។ ម្យ៉ាងទៀត គំនរអាចម៍ដីណាក្តី គំនរដីស្អិតណាក្តី ដែលមានភ្លៀងធ្លាក់ចុះថយពី ៤ ខែមក ផែនដីនេះ តថាគតក៏ហៅថា អជាតបឋវីដែរ ។

[៣៥១] ត្រង់ពាក្យថា ជីកដោយខ្លួនឯង គឺភិក្ខុជីកដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រើអ្នកដទៃឲ្យជីក គឺភិក្ខុបង្គាប់អ្នកដទៃឲ្យជីក ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្គាប់មនុស្សឲ្យជីកតែម្តង មនុស្សនោះ ទៅជីកច្រើនដង ត្រូវអាបត្តិបាចិត្តិយ (១) ។

[៣៤២] បឋវិយា បឋវីសញ្ញី ខណតិ វា ខណាបេតិ វា ភិន្ទតិ វា ភេទាបេតិ វា ទហតិ វា ទហាបេតិ វា អាបត្តិ ចាចិត្តិយស្ស ។ បឋវិយា វេមតិកោ ខណតិ វា ខណាបេតិ វា ភិន្ទតិ វា ភេទាបេតិ វា ទហតិ វា ទហាបេតិ វា អាបត្តិ ទុក្កដស្ស ។ បឋវិយា អបឋវីសញ្ញី ខណតិ វា ខណាបេតិ វា ភិន្ទតិ វា ភេទាបេតិ វា ទហតិ វា ទហាបេតិ វា អនាបត្តិ ។ អបឋវិយា បឋវីសញ្ញី អាបត្តិ ទុក្កដស្ស ។ អបឋវិយា វេមតិកោ អាបត្តិ ទុក្កដស្ស ។ អបឋវិយា អបឋវីសញ្ញី អនាបត្តិ ។

[៣៤៣] អនាបត្តិ ឥមំ ជាន ឥមំ ទេហិ ឥមំ អាហរ ឥមិនា អត្ថោ ឥមំ កប្បិយំ ករោហីតិ ភណតិ អសញ្ចិច្ច អសតិយា អជានន្តស្ស ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៣៥២] ផែនដីមែន ភិក្ខុសំគាល់ថា ផែនដី ហើយជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យជីកក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទម្លាយក្តី ដុតដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យដុតក្តី ត្រូវអាបត្តិបាចិត្តិយ ។ ផែនដីមែន តែភិក្ខុមានសេចក្តីសង្ស័យ ហើយជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យជីកក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទម្លាយក្តី ដុតដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យដុតក្តី ត្រូវអាបត្តិទុក្កដ ។ ផែនដីមែន ភិក្ខុមានសេចក្តីសំគាល់ថា មិនមែនផែនដី ហើយជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យជីកក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទម្លាយក្តី ដុតដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យដុតក្តី មិនត្រូវអាបត្តិឡើយ ។ ទីដែលមិនមែនជាផែនដី ភិក្ខុមានសេចក្តីសំគាល់ថា ផែនដី ត្រូវអាបត្តិទុក្កដ ។ ទីមិនមែនជាផែនដី ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ទីមិនមែនជាផែនដី ភិក្ខុសំគាល់ថាមិនមែនផែនដី មិនត្រូវអាបត្តិឡើយ ។

[៣៥៣] អាបត្តិមិនមានដល់ភិក្ខុដែលពោលថា អ្នកឯងចូរដឹងនូវវត្ថុនេះ អ្នកឯងចូរឲ្យនូវវត្ថុនេះ អ្នកឯងចូរនាំមកនូវវត្ថុនេះ អាត្មាត្រូវការដោយវត្ថុនេះ អ្នកឯងចូរធ្វើនូវវត្ថុនេះឲ្យជារបស់សមគួរ ដល់ភិក្ខុមិនបានក្តែង ដល់ភិក្ខុភ្លាត់ស្មារតី ដល់ភិក្ខុកាលមិនដឹង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

វិនយបិដកេ មហាវិភង្គោ

## តស្សុទ្ទានំ

មុសាឱមសបេសុញ្ញំ បទសេយ្យាយ វេ ទុវេ
អញ្ញត្រ វិញ្ញុជា ភូតា ទុដ្ឋុល្លាបត្តិ ខណាជាតិ[១] ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

មុសាវាទវគ្គោ បឋមោ[២] ។

---

១ ខណោនចាតិបិ បាឋោ ។ ២ ឱ. ម. បឋមោ វគ្គោ ។

ចំនួនសិក្ខាបទក្នុងមុសាវាទវគ្គនោះ គឺ

សម្បជានមុសាវាទ ១ ឱមសវាទ ១

បេសុញ្ញវាទ ១ បទសោធម្ម ១

បឋមសហសេយ្យ ១ ទុតិយសហសេយ្យ ១

ធម្មទេសនា ១ ភូតារោចនៈ ១

ទុដ្ឋុល្លាបត្តិ ១ បឋវីខណនៈ ១

សិក្ខាបទទី ១០ ចប់ ។

មុសាវាទវគ្គ ជាដំបូង ។

# ភូតគាមវគ្គស្ស បឋមសិក្ខាបទំ

[៣៨៤] តេន សមយេន ពុទ្ធោ ភគវា អាឡវិយំ វិហរតិ អគ្គាឡវេ ចេតិយេ ។ តេន ខោ បន សមយេន អាឡវិកា ភិក្ខូ នវកម្មំ ករោន្តា រុក្ខំ ឆិន្ទន្តិបិ ឆេទាបេន្តិបិ(១) ។ អញ្ញតរោបិ អាឡវិកោ ភិក្ខុ រុក្ខំ ឆិន្ទតិ ។ តស្មឹ រុក្ខេ អធិវត្ថា ទេវតា តំ ភិក្ខុំ ឯតទវោច មា ភន្តេ អត្តនោ ភវនំ កត្តុកាមោ មយ្ហំ ភវនំ ឆិន្ទាតិ(២) ។ សោ ភិក្ខុ អនាទិយន្តោ ឆិន្ទិយេវ តស្សា ច ទេវតាយ ទារកស្ស ពាហុំ អាកោដេសិ ។ អថខោ តស្សា ទេវតាយ ឯតទ-ហោសិ យន្នូនាហំ ឥមំ ភិក្ខុំ ឥធេវ ជីវិតា វោរោ-បេយ្យន្តិ ។ អថខោ តស្សា ទេវតាយ ឯតទហោសិ ន ខោ បនេតំ(៣) បតិរូបំ យាហំ ឥមំ ភិក្ខុំ ឥធេវ ជីវិតា វោរោបេយ្យំ យន្នូនាហំ ភគវតោ ឯតមត្ថំ អារោចេយ្យន្តិ ។ អថខោ សា ទេវតា យេន ភគវា

---

១ កត្ថចិ បោត្ថកេ ឆិន្ទាបេន្តិបីតិ ទិស្សតិ ។ ២ ឱ. ឆិន្ទីតិ ។ ៣ ឱ. ម. មេតំ ។

# ភូតគាមវគ្គ សិក្ខាបទទី ១

[៣៥៤] សម័យនោះ ព្រះភគវន្តសម្ពុទ្ធ កាលគង់នៅអគ្គាឡវចេតិយ ទៀបក្រុងអាឡវី ។ គ្រានោះឯង ពួកភិក្ខុនៅក្នុងក្រុងអាឡវី កាលធ្វើនវកម្ម ក៏កាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យកាប់ខ្លះ នូវដើមឈើ ។ មានភិក្ខុ ១ រូបនៅក្រុងអាឡវី កាប់ឈើមួយដើម ។ មានទេវតា ១ អង្គអាស្រ័យនៅលើដើមឈើនោះ បាននិយាយពាក្យនេះនឹងភិក្ខុនោះថា បពិត្រលោកម្ចាស់ លោកចង់ធ្វើទីនៅរបស់ខ្លួន មិនត្រូវកាប់ទីនៅរបស់ខ្ញុំទេ ។ ភិក្ខុនោះ មិនអើពើ (នឹងពាក្យទេវតានោះ) ក៏ចេះតែកាប់ឈើនោះទៅ ក៏ត្រូវដៃទារករបស់ទេវតានោះ ។ វេលានោះឯងទេវតានោះ ត្រិះរិះដូច្នេះថា បើដូច្នោះ ខ្លួនអញត្រូវសម្លាប់ភិក្ខុនេះ ក្នុងទីនេះ ។ ខណៈនោះឯង ទេវតានោះ ត្រិះរិះដូច្នេះវិញថា ខ្លួនអញសម្លាប់ភិក្ខុនេះក្នុងទីនេះ ដោយអំពើណា អំពើនេះមិនសមគួរដល់ខ្លួនអញសោះឡើយ បើដូច្នោះ អញត្រូវក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគសិន ។ គ្រានោះឯង ទេវតានោះក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ

តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ ឯតមត្ថំ អារោចេសិ ។ សាធុ សាធុ ទេវតេ សាធុ ខោ ត្វំ ទេវតេ តំ ភិក្ខុំ ន ជីវិតា វោរោបេសិ សចជ្ជ ត្វំ ទេវតេ តំ ភិក្ខុំ ជីវិតា វោរោបេយ្យាសិ ពហុំ ច ត្វំ ទេវតេ អបុញ្ញំ បសវេយ្យាសិ គច្ឆ ត្វំ ទេវតេ អមុកស្មឹ ឱកាសេ រុក្ខោ វិវិត្តោ តស្មឹ ឧបគច្ឆាតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា រុក្ខំ ឆិន្ទិស្សន្តិបិ ឆេទាបេស្សន្តិបិ[១] ឯកិន្ទ្រិយំ សមណា សក្យបុត្តិយា ជីវំ វិហេឋេន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាឡវិកា ភិក្ខូ រុក្ខំ ឆិន្ទិស្សន្តិបិ ឆេទាបេស្សន្តិបិ[២] ។

---

១-២ កត្ថចិ បោត្ថកេ ឆិន្ទាបេស្សន្តិបីតិ ទិស្សតិ ។

ត្រង់ទីដែលព្រះអង្គគង់នៅ លុះចូលទៅដល់ហើយ បានក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ (ដោយសព្វគ្រប់) ។ ព្រះសាស្ដាជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលទេវតា ពាក្យដែលអ្នកថាប្រពៃពេកណាស់ ម្នាលទេវតា អ្នកឯងមិនបានសម្លាប់ភិក្ខុនោះត្រូវពិតហើយ ម្នាលទេវតា បើអ្នកសម្លាប់ភិក្ខុនោះ ក្នុងថ្ងៃនេះហើយ ម្នាលទេវតា អ្នកឯងត្រូវបាននូវបាបជាច្រើន នែទេវតា អ្នកឯងចូរត្រឡប់ទៅវិញចុះ ក្នុងទីឯណោះមានឈើមួយដើមយ៉ាងស្ងាត់ អ្នកឯងចូរទៅនៅអាស្រ័យនូវឈើនោះចុះ ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ មិនគួរនឹងហ៊ានកាប់ដោយខ្លួនឯងផង ប្រើអ្នកដទៃឲ្យកាប់ផង នូវដើមឈើសោះ ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ រមែងបៀតបៀននូវវត្ថុដែលមានជីវិតមានឥន្ទ្រិយតែ ១ ។ ភិក្ខុទាំងឡាយបានឮពាក្យមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកភិក្ខុនៅក្នុងក្រុងអាឡវី មិនគួរនឹងហ៊ានកាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យកាប់ខ្លះ នូវដើមឈើសោះ ។

៣៤៩



អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ រុក្ខំ ឆិន្ទថបិ ឆេទាបេថបីតិ[១] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា រុក្ខំ ឆិន្ទិស្សថបិ ឆេទាបេស្ស-ថបិ[២] ជីវសញ្ញិនោ ហិ មោឃបុរិសា មនុស្សា រុក្ខស្មឹ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ប-សន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ភូតគាមបាតព្យតាយ បាចិត្តិយន្តិ ។

[៣៥៥] ភូតគាមោ នាម បញ្ច ពីជជាតានិ មូល-ពីជំ ខន្ធពីជំ ផឡុពីជំ អគ្គពីជំ ពីជពីជមេវ[៣] បញ្ចមំ ។

---

១ ឆិន្ទាបេថបីតិ ។ ២ ឆិន្ទាបេស្សថបីតិ ។ ៣ ឱ. ម. ពីជពីជញ្ចេវ ។

គ្រានោះ ភិក្ខុទាំងនោះ បានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយកាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យកាប់ខ្លះ នូវដើមឈើ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែពួកមោឃបុរស អ្នកទាំងឡាយមិនគួរបើនឹងហ៊ានកាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យកាប់ខ្លះ នូវដើមឈើទេ នែមោឃបុរសទាំងឡាយ ព្រោះពួកមនុស្សមានសេចក្ដីសំគាល់ថា ដើមឈើមានជីវិត នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះនឹងបានដឹកនាំពួកមនុស្សដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬពួកមនុស្សដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុធ្វើភូតគាម[១] មានឈើនិងស្មៅជាដើមឲ្យវិនាស ត្រូវអាបត្តិបាចិត្តិយ ។

[៣៩៥] ពូជមាន ៥ យ៉ាង គឺ ពូជកើតពីមើម ឬឫស ១ ពូជកើតពីដើម ១ ពូជកើតពីថ្នាំង ១ ពូជកើតពីចុងឬគល់ ១ ពូជកើតពីពូជ (គឺផ្លែ) ១ ពូជទាំង ៥ នេះហៅថា ភូតគាម ។ ដែលហៅថា

១ អដ្ឋកថា សំដៅយកស្មៅនិងដើមឈើស្រស់ ដែលមានពូជដុះទៅទៀតបានជាដើម ។

មូលពីជំ នាម ហលិទ្ទិំ(១) សិង្គិវេរំ វចំ វចត្តំ អតិវិសំ កដុករោហិណឹ ឧសីរំ ភទ្ទមុត្តកំ យានិ វា បនញ្ញានិបិ អត្ថិ មូលេ ជាយន្តិ មូលេ សញ្ជាយន្តិ ឯតំ មូលពីជំ នាម ។ ខន្ធពីជំ នាម អស្សត្ថោ និគ្រោធោ បិលក្ខោ ឧទុម្ពរោ កច្ឆកោ កបិបនោ យានិ វា បនញ្ញានិបិ អត្ថិ ខន្ធេ ជាយន្តិ ខន្ធេ សញ្ជាយន្តិ ឯតំ ខន្ធពីជំ នាម ។ ផឡុពីជំ នាម ឧច្ឆុ វេឡុ នឡោ យានិ វា បនញ្ញានិបិ អត្ថិ បព្វេ ជាយន្តិ បព្វេ សញ្ជាយន្តិ ឯតំ ផឡុពីជំ នាម ។ អគ្គពីជំ នាម អជ្ជុកំ ផណិជ្ជកំ ហិរិវេរំ យានិ វា បនញ្ញានិបិ អត្ថិ អគ្គេ ជាយន្តិ អគ្គេ សញ្ជាយន្តិ ឯតំ អគ្គពីជំ នាម ។

១ ឱ. ម. ពលិទ្ទិ ។

ពូជកើតពីមើម ឬឫស (នោះសំដៅយក) រមៀត ខ្ញី លំពាន់ ប្រស់ អាចម៌ត្តីស រំដេង ស្បូវភ្នាំង និងក្រវាញជ្រូក មិនតែប៉ុណ្ណោះ សូម្បីវត្ថុទាំងឡាយដទៃណា កើតពីមើមឬឫស ដុះពីមើមឬឫស វត្ថុប៉ុណ្ណោះឈ្មោះថា ពូជកើតពីមើម ឬឫស (ដូចគ្នា) ។ ដែលហៅថា ពូជកើតពីដើម (នោះសំដៅយក) ដើមពោធិ ដើមជ្រៃ ដើមល្វៀប ដើមល្វា ដើមជ្រៃក្រឹម ដើមក្រសាំង មិនតែប៉ុណ្ណោះ សូម្បីវត្ថុទាំងឡាយដទៃណាកើតពីដើម ដុះពីដើម វត្ថុប៉ុណ្ណោះហៅថា ពូជកើតពីដើម ។ ដែលហៅថា ពូជកើតពីថ្នាំង (នោះសំដៅយក) អំពៅ ឫស្សី និងបបុស មិនតែប៉ុណ្ណោះ សូម្បីវត្ថុទាំងឡាយដទៃណា កើតពីថ្នាំង ដុះពីថ្នាំង វត្ថុប៉ុណ្ណោះហៅថា ពូជកើតពីថ្នាំង ។ ដែលហៅថា ពូជកើតពីចុង ឬគល់ (នោះសំដៅយក) ជីរលីងលាក់ ស្មឹកគ្រៃ វល្លិ៍អណ្តាតត្រកួត ម្យ៉ាងទៀត សូម្បីវត្ថុទាំងឡាយណាកើតពីចុងឬគល់ ដុះពីចុងឬគល់ វត្ថុប៉ុណ្ណោះហៅថា ពូជកើតពីចុងឬគល់ (ដូចគ្នា) ។ ដែលហៅថា ពូជកើតពីពូជ (នោះសំដៅយក)

ពីជពីជំ ណាម បុព្វណ្ណំ អបរណ្ណំ យានិ វា បនញ្ញានិបិ អត្ថិ ពីជេ ជាយន្តិ ពីជេ សញ្ជាយន្តិ ឯតំ ពីជពីជំ ណាម បញ្ចមំ ។

[៣៤៦] ពីជេ ពីជសញ្ញី ឆិន្ទតិ វា ឆេទាបេតិ វា ភិន្ទតិ វា ភេទាបេតិ វា បចតិ វា បចាបេតិ វា អាបត្តិ ចាចិត្តិយស្ស ។ ពីជេ វេមតិកោ ឆិន្ទតិ វា ឆេទាបេតិ វា ភិន្ទតិ វា ភេទាបេតិ វា បចតិ វា បចាបេតិ វា អាបត្តិ ទុក្កដស្ស ។ ពីជេ អពីជសញ្ញី ឆិន្ទតិ វា ឆេទាបេតិ វា ភិន្ទតិ វា ភេទាបេតិ វា បចតិ វា បចាបេតិ វា អណាបត្តិ ។ អពីជេ ពីជសញ្ញី អាបត្តិ ទុក្កដស្ស ។ អពីជេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អពីជេ អពីជ-សញ្ញី អណាបត្តិ ។

បុព្វណ្ណជាតិ បានដល់ស្រូវ ៧ ប្រការ មានស្រូវស ស្រូវក្រហមនិង ពោតជាដើម អបរណ្ណជាតិ បានដល់សណ្តែកបាយ សណ្តែករាជមាស ជាដើម ម្យ៉ាងទៀត សូម្បីវត្ថុទាំងឡាយណាកើតពីពូជ ដុះពីពូជ វត្ថុ ប៉ុណ្ណោះហៅថា ពូជកើតពីពូជជាគម្រប់ ៥ ។

[៣៥៦] វត្ថុជាពូជមែន ភិក្ខុសំគាល់ថា ពូជ ហើយកាប់ដោយ ខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យកាប់ក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃ ឲ្យទម្លាយក្តី ចម្អិនដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យចម្អិនក្តី ត្រូវអាបត្តិ បាចិត្តិយ ។ ពូជមែន ភិក្ខុមានសេចក្តីសង្ស័យ ហើយកាប់ដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យកាប់ក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទម្លាយក្តី ចម្អិនដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យចម្អិនក្តី ត្រូវអាបត្តិទុក្កដ ។ ពូជ មែន ភិក្ខុសំគាល់ថា មិនមែនពូជ ហើយកាប់ដោយខ្លួនឯងក្តី ប្រើអ្នក ដទៃឲ្យកាប់ក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យទម្លាយក្តី ចម្អិន ដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យចម្អិនក្តី មិនត្រូវអាបត្តិឡើយ ។ វត្ថុមិន មែនពូជ ភិក្ខុសំគាល់ថា ពូជ ត្រូវអាបត្តិទុក្កដ ។ វត្ថុមិនមែនពូជ តែភិក្ខុ មានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វត្ថុមិនមែនពូជ ភិក្ខុសំគាល់ថា មិនមែនពូជ មិនត្រូវអាបត្តិឡើយ ។

[៣៩៧] អនាបត្តិ ឥមំ ជាន ឥមំ ទេហិ ឥមំ អាហរ ឥមិនា អត្ថោ ឥមំ កប្បិយំ ករោហីតិ ភណតិ អសញ្ចិច្ច អសតិយា អជានន្តស្ស ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។

[៣៥៧] អាបត្តិមិនមានដល់ភិក្ខុដែលនិយាយថា អ្នកចូរដឹងនូវវត្ថុនេះ អ្នកចូរឲ្យនូវវត្ថុនេះ អ្នកចូរនាំមកនូវវត្ថុនេះ អាត្មាត្រូវការដោយវត្ថុនេះ អ្នកចូរធ្វើនូវវត្ថុនេះឲ្យសមគួរ ដល់ភិក្ខុមិនបានក្លែង ដល់ភិក្ខុភ្លាត់ស្មារតី ដល់ភិក្ខុកាលមិនដឹង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១ ចប់ ។

# ទុតិយសិក្ខាបទំ

[៣៩៨] តេន សមយេន ពុទ្ធោ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មា ឆន្នោ សយំ អជាចារំ អាចរិត្វា សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ អញ្ញេនញ្ញំ បដិចរតិ កោ អាបន្នោ កឹ អាបន្នោ កិស្មឹ អាបន្នោ កតមំ អាបន្នោ កំ ភណថ កឹ ភណថាតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឆន្នោ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមា-នោ អញ្ញេនញ្ញំ បដិចរិស្សតិ កោ អាបន្នោ កឹ អាបន្នោ កិស្មឹ អាបន្នោ កតមំ អាបន្នោ កំ ភណថ កឹ ភណថាតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា អាយស្មន្តំ ឆន្នំ បដិបុច្ឆិ

# សិក្ខាបទទី ២

[៣៥៨] សម័យនោះ ព្រះដ៏ទ្រង់យសកាលគង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ គ្រានោះឯង ឆន្នភិក្ខុដ៏មានអាយុប្រព្រឹត្តអនាចារដោយខ្លួនឯង កាលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏ពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃ (គឺពោលពាក្យបន្ទៃបន្ទប់) ទៅវិញដោយពាក្យថា នរណាត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិព្រោះវត្ថុអ្វី ត្រូវអាបត្តិដោយប្រការដូចម្តេច លោកទាំងឡាយពោលចំពោះបុគ្គលណា លោកទាំងឡាយពោលថា អ្វី ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ហើយមិនសមបើនឹងពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃថា នរណាត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិព្រោះវត្ថុអ្វី ត្រូវអាបត្តិដោយប្រការដូចម្តេច លោកទាំងឡាយ ពោលចំពោះបុគ្គលណា លោកទាំងឡាយពោលថា អ្វី ។ គ្រានោះឯង ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់សួរបញ្ជាក់ទៅនឹងឆន្នភិក្ខុដ៏មានអាយុថា ម្នាលឆន្ន

សច្ចំ កិរ ត្វំ ឆន្ន សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយ-មានោ អញ្ញេនញ្ញំ បដិចរសិ កោ អាបន្នោ ។ បេ ។ កឹ ភណថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ អញ្ញេនញ្ញំ បដិចរិស្សសិ កោ អា-បន្នោ ។ បេ ។ កឹ ភណថាតិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ ឆន្នស្ស ភិក្ខុនោ អញ្ញវាទកំ រោបេតុ ។ ឯវញ្ច បន ភិក្ខវេ រោបេតព្វំ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឆន្នោ ភិក្ខុ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ

បានឮថាអ្នកឯងកាលដែលភិក្ខុសាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ហើយពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃវិញថា នរណាត្រូវអាបត្តិ ។ បេ ។ លោកទាំងឡាយពោលថាដូចម្តេច ពាក្យនេះពិតមែនឬ ។ ឆន្នភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពាក្យនេះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯងកាលដែលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃហើយ មិនគួរបើនឹងពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃថា នរណាត្រូវអាបត្តិ ។ បេ ។ លោកទាំងឡាយពោលដូចម្តេច នែមោឃបុរស អំពើដែលអ្នកធ្វើនេះនឹងបានដឹកនាំមនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើងក៏ទេ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់បន្ទោស រួចទ្រង់ធ្វើនូវធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះសង្ឃចូរលើកនូវអញ្ញវាទកកម្ម[១]ដល់ឆន្នភិក្ខុចុះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវលើកនូវអញ្ញវាទកកម្មយ៉ាងនេះ ភិក្ខុដែលឈ្លាសអង់អាចត្រូវប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ (ដ្បិត) ឆន្នភិក្ខុនេះ កាលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏ពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃវិញ ។

១ អំពើដែលសង្ឃត្រូវធ្វើ ដល់ភិក្ខុអ្នកពោលពាក្យដទៃ គឺពោលពាក្យបន្លែបន្លប់ ។

អញ្ញេនញ្ញំ បដិចរតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឆន្នស្ស ភិក្ខុនោ អញ្ញវាទកំ រោបេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឆន្នោ ភិក្ខុ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ អញ្ញេនញ្ញំ បដិចរតិ ។ សង្ឃោ ឆន្នស្ស ភិក្ខុនោ អញ្ញវាទកំ រោបេតិ ។ យស្សាយស្មតោ ខមតិ ឆន្នស្ស ភិក្ខុនោ អញ្ញវាទកស្ស រោបនា សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ រោបិតំ សង្ឃេន ឆន្នស្ស ភិក្ខុនោ អញ្ញវាទកំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៣៨៩] អថខោ ភគវា អាយស្មន្តំ ឆន្នំ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ អញ្ញវាទកេ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃត្រូវលើកនូវអញ្ញវាទកកម្ម ដល់ឆន្នភិក្ខុ ។ នេះជាវាចាសម្រាប់ផ្ទៀងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ (ដ្បិត) ឆន្នភិក្ខុនេះ កាលភិក្ខុសាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ក៏ពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃវិញ ។ ឥឡូវនេះ ព្រះសង្ឃលើកនូវអញ្ញវាទកកម្មដល់ឆន្នភិក្ខុ ។ ការលើកនូវអញ្ញវាទកកម្ម ដល់ឆន្នភិក្ខុ សមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគួរស្ងៀម (បើ) មិនសមគួរដល់លោកម្ចាស់អង្គណាទេ លោកម្ចាស់អង្គនោះត្រូវពោលឡើង ។ អញ្ញវាទកកម្ម សង្ឃបានលើកដល់ឆន្នភិក្ខុហើយ ។ អញ្ញវាទកកម្មសមគួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាព្រះសង្ឃស្ងៀមនៅ ។ ខ្ញុំចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។

[៣៥៩] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសឆន្នភិក្ខុដ៏មានអាយុ ដោយអនេកបរិយាយ ។ បេ ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះពោលនូវពាក្យដទៃ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ បានបញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ ។

[៣៦០] តេន ខោ បន សមយេន អាយស្មា ឆន្នោ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ អញ្ញេនញ្ញំ បដិចរន្តោ អាបត្តឹ អាបជ្ជិស្សាមីតិ តុណ្ហីភូតោ សង្ឃំ វិហេសេតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិចាចេន្តិ កថំ ហិ នាម អាយស្មា ឆន្នោ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ តុណ្ហីភូតោ សង្ឃំ វិហេសេស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អថខោ ភគវា អាយស្មន្តំ ឆន្នំ បដិបុច្ឆិ សច្ចំ កិរ ត្វំ ឆន្ន សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ តុណ្ហីភូតោ សង្ឃំ វិហេសេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ តុណ្ហីភូតោ សង្ឃំ វិហេសេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។

[៣៦០] សម័យនោះឯង ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុកំពុងសាកសួរ ដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏គិតថា អាត្មាអញកាលពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃ មុខជានឹងត្រូវអាបត្តិ (មិនខានឡើយ) ហើយក៏ស្ងៀមនៅមិនស្តី នាំឲ្យសង្ឃលំបាក ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ មិនសមបើនឹងស្ងៀមនៅមិនស្តីនាំឲ្យសង្ឃលំបាកសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរឆន្នភិក្ខុដ៏មានអាយុថា នែឆន្ន បានឮថាអ្នកឯងកាលដែលភិក្ខុសាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ហើយស្ងៀមនៅមិនស្តីនាំឲ្យសង្ឃលំបាក ពិតមែនឬ ។ ឆន្នភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការនោះ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯង កាលដែលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ មិនសមបើនឹងស្ងៀមនៅមិនស្តីនាំឲ្យសង្ឃលំបាកទេ នែមោឃបុរស អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំមនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងក៏ទេដែរ ។ បេ ។

វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ ឆន្នស្ស ភិក្ខុនោ វិហេសកំ រោបេតុ ។ ឯវញ្ច បន ភិក្ខវេ រោបេតព្វំ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឆន្នោ ភិក្ខុ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិយមានោ តុណ្ហីភូតោ សង្ឃំ វិហេសេតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឆន្នស្ស ភិក្ខុនោ វិហេសកំ រោ-បេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឆន្នោ ភិក្ខុ សង្ឃមជ្ឈេ អាបត្តិយា អនុយុញ្ជិ-យមានោ តុណ្ហីភូតោ សង្ឃំ វិហេសេតិ ។ សង្ឃោ ឆន្នស្ស ភិក្ខុនោ វិហេសកំ រោបេតិ ។ យស្សាយស្មតោ ខមតិ ឆន្នស្ស ភិក្ខុនោ វិហេសកស្ស រោបនា សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ព្រះដ៏មានព្រះភាគទ្រង់បន្ទោស រួចទ្រង់ធ្វើនូវធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរលើកនូវវិហេសកកម្ម[១] ដល់ឆន្នភិក្ខុចុះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវលើកនូវវិហេសកកម្មយ៉ាងនេះ គឺភិក្ខុដែលវាងវៃអង់អាចគួរផ្តៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ (ដ្បិត) ឆន្នភិក្ខុនេះ កាលដែលភិក្ខុសាកសួរ ដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏ស្ងៀមនៅមិនស្តី នាំឲ្យសង្ឃលំបាក ។ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវលើកនូវវិហេសកកម្មដល់ឆន្នភិក្ខុ ។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ (ដ្បិត) ឆន្នភិក្ខុនេះ កាលដែលសង្ឃសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏ស្ងៀមនៅមិនស្តី នាំឲ្យសង្ឃលំបាក ។ ឥឡូវ សង្ឃលើកនូវវិហេសកកម្មដល់ឆន្នភិក្ខុ ។ ការដែលលើកនូវវិហេសកកម្មដល់ឆន្នភិក្ខុ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀមនៅ (បើ) មិនសមគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ ត្រូវពោលឡើង ។

---

១ អំពើដែលសង្ឃត្រូវធ្វើដល់ភិក្ខុអ្នកនាំសង្ឃឲ្យបានសេចក្តីលំបាក ។

រោបិតំ សង្ឃេន ឆន្នស្ស ភិក្ខុនោ វិហេសកំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៣៦១] អថខោ ភគវា អាយស្មន្តំ ឆន្នំ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ អញ្ញវាទកេ វិហេសកេ បាចិត្តិយន្តិ ។

[៣៦២] អញ្ញវាទកោ នាម សង្ឃមជ្ឈេ វត្ថុស្មឹ វា អាបត្តិយា វា អនុយុញ្ជិយមានោ តំ ន កថេតុកាមោ តំ ន ឧគ្ឃាដេតុកាមោ អញ្ញេនញ្ញំ បដិចរតិ កោ អាបន្នោ កឹ អាបន្នោ កិស្មឹ អាបន្នោ កថំ អាបន្នោ កំ ភណថ កឹ ភណថាតិ ឯសោ អញ្ញវាទកោ នាម ។

វិហេសកកម្ម សង្ឃបានលើកដល់ឆន្នភិក្ខុរួចហើយ ។ ការដែលលើកនូវវិហេសកកម្ម សមគួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀមនៅមិនស្តី ។ ខ្ញុំចាំទុកនូវរឿងនេះ ដោយភាវៈស្ងៀមនៅយ៉ាងនេះ ។

[៣៦១] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសឆន្នភិក្ខុដ៏មានអាយុដោយអនេកបរិយាយ ។ បេ ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះពោលនូវពាក្យដទៃ (ឬ) ព្រោះធ្វើឲ្យសង្ឃបានសេចក្តីលំបាក ។

[៣៦២] ដែលហៅថា ពោលនូវពាក្យដទៃ (នោះ) គឺភិក្ខុ (ណាមួយ) ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ មិនប្រាថ្នានឹងពោលនូវវត្ថុ និងអាបត្តិនោះ មិនប្រាថ្នានឹងបង្កើបឡើងនូវវត្ថុ និងអាបត្តិនោះ ត្រឡប់ជាបិទបាំងនូវពាក្យដទៃដោយពាក្យដទៃវិញថា នរណាបានត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិព្រោះវត្ថុអ្វី ត្រូវអាបត្តិដោយប្រការដូចម្តេច លោកទាំងឡាយពោលនឹងនរណា លោកទាំងឡាយពោលដូចម្តេច ភិក្ខុនេះឈ្មោះថា ពោលនូវពាក្យដទៃ ។

[៣៦៣] វិហេសកោ ញាម សង្ឃមជ្ឈេ វត្ថុស្មឹ វា អាបត្តិយា វា អនុយុញ្ជិយមានោ តំ ន កថេតុកាមោ តំ ន ឧគ្ឃាដេតុកាមោ តុណ្ហីភូតោ សង្ឃំ វិហេសេតិ ឯសោ វិហេសកោ ញាម ។

[៣៦៤] អរោបិតេ អញ្ញវាទកេ សង្ឃមជ្ឈេ វត្ថុស្មឹ វា អាបត្តិយា វា អនុយុញ្ជិយមានោ តំ ន កថេតុ-កាមោ តំ ន ឧគ្ឃាដេតុកាមោ អញ្ញេនញ្ញំ បដិចរតិ កោ អាបន្នោ កឹ អាបន្នោ កិស្មឹ អាបន្នោ កថំ អាបន្នោ កំ ភណាថ កឹ ភណាថាតិ អាបត្តិ ទុក្កដស្ស ។ អរោបិតេ វិហេសកេ សង្ឃមជ្ឈេ វត្ថុស្មឹ វា អាបត្តិយា វា អនុយុញ្ជិយមានោ តំ ន កថេតុកាមោ តំ ន ឧគ្ឃាដេតុកាមោ តុណ្ហីភូតោ សង្ឃំ វិហេសេតិ អាបត្តិ ទុក្កដស្ស ។

[៣៦៣] *ដែលហៅថា ធ្វើឲ្យសង្ឃបានសេចក្តីលំបាក* (នោះ) *គឺ ភិក្ខុ* (ណាមួយ) *ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ មិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិនប្រាថ្នានឹងបង្អើបនូវវត្ថុនិងអាបត្តិនោះ ហើយស្ងៀមមិនស្តី នាំឲ្យសង្ឃបានសេចក្តីលំបាក ភិក្ខុនេះឈ្មោះថា ធ្វើឲ្យសង្ឃបានសេចក្តីលំបាក ។*

[៣៦៤] *កាលបើអញ្ញវាទកកម្ម សង្ឃមិនបានលើកឡើងទេ ភិក្ខុ* (ណាមួយ) *ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ ហើយមិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិនប្រាថ្នានឹងបង្អើបឡើងនូវវត្ថុនិងអាបត្តិនោះ ត្រឡប់ជាពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃវិញថា នរណាបានត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិព្រោះវត្ថុអ្វី ត្រូវអាបត្តិដោយប្រការដូចម្តេច លោកទាំងឡាយពោលនឹងនរណា លោកទាំងឡាយពោលដូចម្តេច ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ កាលបើវិហេសកកម្មដែលសង្ឃមិនបានលើកឡើងទេ ភិក្ខុណាដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ ហើយមិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិនប្រាថ្នានឹងបង្អើបឡើងនូវវត្ថុនិងអាបត្តិនោះ ស្ងៀមមិនស្តី នាំឲ្យសង្ឃបានសេចក្តីលំបាក ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។*

[៣៦៥] ពេបិតេ អញ្ញវាទកេ សង្ឃមជ្ឈេ វត្ថុស្មឹ វា អាបត្តិយា វា អនុយុញ្ជិយមានោ តំ ន កថេតុកាមោ តំ ន ឧគ្ឃាដេតុកាមោ អញ្ញេនញ្ញំ បដិចរតិ កោ អាបន្នោ ។ បេ ។ កឹ ភណថាតិ អាបត្តិ ចាចិត្តិយស្ស ។ ពេបិតេ វិហេសកេ សង្ឃមជ្ឈេ វត្ថុស្មឹ វា អាបត្តិយា វា អនុយុញ្ជិយមានោ តំ ន កថេតុកាមោ តំ ន ឧគ្ឃាដេតុកាមោ តុណ្ហីភូតោ សង្ឃំ វិហេសេតិ អាបត្តិ ចាចិត្តិយស្ស ។

[៣៦៦] ធម្មកម្មេ ធម្មកម្មសញ្ញី អញ្ញវាទកេ វិហេសកេ អាបត្តិ ចាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកោ អញ្ញវាទកេ វិហេសកេ អាបត្តិ ចាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី អញ្ញវាទកេ វិហេសកេ អាបត្តិ ចាចិត្តិយស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញី

[៣៦៥] កាលបើអញ្ញវាទកកម្មដែលសង្ឃបានលើកឡើងហើយ ភិក្ខុ (ណាមួយ) ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ ហើយមិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិនប្រាថ្នានឹងបើកឡើងនូវវត្ថុនិងអាបត្តិនោះ ត្រឡប់ជាពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃវិញថា នរណាត្រូវអាបត្តិ ។ បេ ។ លោកទាំង-ឡាយពោលដូចម្តេច ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ កាលបើវិហេសក-កម្មដែលសង្ឃបានលើកឡើងហើយ ភិក្ខុ (ណាមួយ) ដែលភិក្ខុកំពុងសាក-សួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ មិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិនប្រាថ្នានឹងបង្ហើបនូវវត្ថុនិងអាបត្តិនោះ ស្ងៀមមិនស្តី នាំឲ្យសង្ឃបានសេចក្តីលំបាក ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

[៣៦៦] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ តែពោលនូវពាក្យដទៃ នាំឲ្យសង្ឃបានសេចក្តីលំបាក ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មប្រកបដោយធម៌ ហើយពោលនូវពាក្យដទៃ នាំឲ្យសង្ឃបានសេចក្តីលំបាក ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសំគាល់ថា កម្មមិនប្រកបដោយធម៌វិញ ហើយពោលនូវពាក្យដទៃ នាំឲ្យសង្ឃបានសេចក្តីលំបាក ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសំគាល់ថា កម្ម

អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

[៣៦៧] អនាបត្តិ អជានន្តោ បុច្ឆតិ តិលាដោ ន កាថេតិ សង្ឃស្ស ភណ្ឌានំ វា កាលហោ វា វិគ្គហោ វា វិវាទោ វា ភវិស្សតីតិ ន កាថេតិ សង្ឃភេទោ វា សង្ឃរាជិ វា ភវិស្សតីតិ ន កាថេតិ អធម្មេន វគ្គេន វា ន កម្មារហស្ស វា កម្មំ ករិស្សតីតិ ន កាថេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។

ប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[៣៦៧] អាបត្តិមិនត្រូវ ដល់ភិក្ខុដែលមិនដឹងសេចក្តីហើយសួរ ដល់ភិក្ខុដែលមានជំងឺហើយមិននិយាយ ដល់ភិក្ខុដែលមិននិយាយដោយគិតថា ការបង្កហេតុប្រកួតប្រកាន់ ជម្លោះ វិវាទ នឹងនាំឲ្យរវល់ដល់សង្ឃ ដល់ភិក្ខុដែលមិននិយាយដោយគិតថា ក្រែងសង្ឃបែកគ្នា (ឬ) ក្រែងសង្ឃថ្នាំងថ្នាក់នឹងគ្នា ដល់ភិក្ខុដែលមិននិយាយដោយគិតថា សង្ឃមុខជានឹងធ្វើកម្ម មិនត្រូវតាមធម៌ផង ជាពួកផង ចំពោះភិក្ខុដែលមិនគួរដល់កម្មផង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់ ។

## តតិយសិក្ខាបទំ

[៣៦៨] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា ទព្វោ មល្លបុត្តោ សង្ឃស្ស សេនាសនញ្ច បញ្ញាបេតិ ភត្តានិ ច ឧទ្ទិសតិ ។ តេន ខោ បន សមយេន មេត្តិយភុម្មជកា ភិក្ខូ នវកា ចេវ ហោន្តិ អប្បបុញ្ញា ច យានិ សង្ឃស្ស លាមកានិ សេនាសនានិ តានិ តេសំ បាបុណន្តិ លាមកានិ ច ភត្តានិ ។ តេ អាយស្មន្តំ ទព្វំ មល្លបុត្តំ ភិក្ខូ ឧជ្ឈាបេន្តិ ឆន្ទាយ ទព្វោ មល្លបុត្តោ សេនាសនំ បញ្ញាបេតិ ឆន្ទាយ ច ភត្តានិ ឧទ្ទិសតីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម មេត្តិយភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្វំ មល្លបុត្តំ ភិក្ខូ ឧជ្ឈាបេស្សន្តីតិ ។

# សិក្ខាបទទី ៣

[៣៦៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះទព្វមល្លបុត្តដ៏មានអាយុ តែងក្រាលនូវសេនាសនៈផង តែងឧទ្ទិសនូវភត្តផង ដល់សង្ឃ ។ លំដាប់នោះ ពួកមេត្តិយភុម្មជកភិក្ខុ ទើបនឹងបួសថ្មីផង ជាមនុស្សមានបុណ្យតិចផង អស់ទាំងសេនាសនៈណា ដ៏ថោកថយរបស់សង្ឃ សេនាសនៈទាំងនោះ ត្រូវបានមកពួកភិក្ខុទាំងនោះ មួយទៀត ភត្តទាំងឡាយណាដ៏ថោកថយ ក៏ត្រូវបានមកពួកភិក្ខុទាំងនោះដែរ ។ ពួកមេត្តិយភុម្មជកភិក្ខុនោះ ក៏បង្គាប់ភិក្ខុទាំងឡាយ ឲ្យពោលទោសព្រះទព្វមល្លបុត្តដ៏មានអាយុថា ព្រះទព្វមល្លបុត្ត ក្រាលសេនាសនៈតាមសេចក្តីគាប់ចិត្តរបស់ខ្លួន ម្យ៉ាងទៀត លោកឧទ្ទិសនូវភត្តតាមសេចក្តីគាប់ចិត្តរបស់ខ្លួន ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មេត្តិយភុម្មជកភិក្ខុទាំងឡាយ មិនសមបើនឹងបង្គាប់ភិក្ខុទាំងឡាយឲ្យពោលទោសព្រះទព្វមល្លបុត្តដ៏មានអាយុសោះ ។

៣៦៣

បាចិត្តិយកណ្ឌេ ភូតគាមវគ្គស្ស តតិយសិក្ខាបទស្ស បឋមប្បញ្ញត្តិ

អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ។ បេ ។ មេត្តិយភុម្មជកេ ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ តុម្ហេ ភិក្ខវេ ទព្វំ មល្លបុត្តំ ភិក្ខូ ឧជ្ឈាបេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ទព្វំ មល្លបុត្តំ ភិក្ខូ ឧជ្ឈាបេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ឧជ្ឈាបនកេ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៣៦៩] តេន ខោ បន សមយេន មេត្តិយភុម្មជកា ភិក្ខូ ភគវតា ឧជ្ឈាបនកំ បដិក្ខិត្តន្តិ ឯត្តាវតា ភិក្ខូ សោស្សន្តីតិ ភិក្ខូនំ សាមន្តា អាយស្មន្តំ ទព្វំ មល្លបុត្តំ

គ្រានោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ។ បេ ។ ទ្រង់ត្រាស់សួរចំពោះពួកមេត្តិយភុម្មជកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បានឮថាអ្នកទាំងឡាយ បង្គាប់ភិក្ខុទាំងឡាយឲ្យពោលទោសទព្វមល្លបុត្ត ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងបង្គាប់ពួកភិក្ខុ (ដទៃ) ឲ្យពោលទោសទព្វមល្លបុត្តសោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះនឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុបង្គាប់ភិក្ខុ (ដទៃ) ឲ្យពោលទោសភិក្ខុផងគ្នា ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ បានបញ្ញត្តដល់ពួកភិក្ខុយ៉ាងនេះ ។

[៣៦៩] សម័យនោះឯង ពួកមេត្តិយភុម្មជកភិក្ខុគិតគ្នាថា ការដែលប្រើភិក្ខុ (ដទៃ) ឲ្យពោលទោស ព្រះដ៏មានព្រះភាគបានហាមរួចហើយ ព្រោះហេតុនោះ ភិក្ខុទាំងឡាយមុខជានឹងបានឮ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ហើយក៏តិះដៀលព្រះទព្វមល្លបុត្តដ៏មានអាយុជិតពួកភិក្ខុ (ដទៃ)

ទីយន្តិ ឆន្ទាយ ឥទានិ មេត្តិយភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្ពំ មល្លបុត្តំ ខីយន្តិ ឆន្ទាយ ច ភត្តានិ ឧទ្ទិសតីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម មេត្តិយភុម្មជកា ភិក្ខូ អាយស្មន្តំ ទព្ពំ មល្លបុត្តំ ខីយិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ។ បេ ។ មេត្តិយភុម្មជកេ ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ តុម្ហេ ភិក្ខវេ ទព្ពំ មល្លបុត្តំ ខីយថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃ-បុរិសា ទព្ពំ មល្លបុត្តំ ខីយិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ឧជ្ឈាបនកេ ខីយ-នកេ បាចិត្តិយន្តិ ។

ថា ព្រះទព្វមល្លបុត្តរៀបចំសេនាសនៈតាមសេចក្ដីគាប់ចិត្ត (រប់សខ្លួន) ផង ចាត់ចែងភត្តតាមសេចក្ដីគាប់ចិត្ត (របស់ខ្លួន) ផង ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកមេត្តិយភុម្មជកភិក្ខុមិនសមបើនឹងហ៊ានតិះដៀល ព្រះទព្វ-មល្លបុត្តដ៏មានអាយុសោះ ។ គ្រានោះ ភិក្ខុទាំងឡាយនោះ ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ។ បេ ។ ទ្រង់ត្រាស់សួរចំពោះនឹងពួកមេត្តិយភុម្មជកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយតិះដៀលទព្វមល្លបុត្ត ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំង-ឡាយ មិនសមបើនឹងតិះដៀលទព្វមល្លបុត្តទេ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះនឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើងក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុបង្គាប់ភិក្ខុដទៃឲ្យពោលទោស (ភិក្ខុផងគ្នា ឬ) តិះដៀល (ភិក្ខុផងគ្នា) ត្រូវអាបត្តិបាចិត្តិយ ។

[៣៧០] ឧជ្ឈាបនកំ នាម ឧបសម្បន្នំ សង្ឃេន សម្មតំ សេនាសនបញ្ញាបកំ វា ភត្តុទ្ទេសកំ វា យាគុភាជកំ វា ផលភាជកំ វា ខជ្ជភាជកំ វា អប្បមត្តកវិសជ្ជកំ វា អវណ្ណំ កត្តុកាមោ អយសំ កត្តុកាមោ មង្កុកត្តុកាមោ[១] ឧបសម្បន្នំ ឧជ្ឈាបេតិ វា ខីយតិ វា អាបត្តិ បាចិត្តិយស្ស ។

[៣៧១] ធម្មកម្មេ ធម្មកម្មសញ្ញី ឧជ្ឈាបនកេ ខីយនកេ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកោ ឧជ្ឈាបនកេ ខីយនកេ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី ឧជ្ឈាបនកេ ខីយនកេ អាបត្តិ បាចិត្តិយស្ស ។

១ ឱ. មង្កុំ កត្តុកាមោ ។

បាចិត្តិយកណ្ឌ ភូតគាមវគ្គ សិក្ខាបទទី ៣ វារៈដែលត្រូវអាបត្តិ

[៣៧០] ដែលហៅថា ភិក្ខុបង្គាប់ភិក្ខុដទៃឲ្យពោលទោស (នោះ) គឺភិក្ខុមានប្រាថ្នានឹងធ្វើនូវសេចក្តីតិះដៀល មានប្រាថ្នានឹងធ្វើនូវសេចក្តីបង្អាប់យស មានប្រាថ្នានឹងធ្វើនូវសេចក្តីបង្អាប់បង្អោន ចំពោះឧបសម្បន្នបុគ្គលដែលសង្ឃសន្មតឲ្យជាអ្នកក្រាលនូវសេនាសនៈក្តី ឲ្យជាអ្នកចាត់ចែងនូវភត្តក្តី ឲ្យជាអ្នកចែកនូវបបរក្តី ឲ្យជាអ្នកចែកនូវផ្លែឈើក្តី ឲ្យជាអ្នកចែកនូវបង្អែមក្តី ឲ្យជាអ្នកចែកចាយនូវវត្ថុមានប្រមាណតិចតួចក្តី ហើយបង្គាប់ភិក្ខុដទៃឲ្យពោលទោស ឬតិះដៀលឧបសម្បន្នបុគ្គល (នោះ) ត្រូវអាបត្តិបាចិត្តិយ ។

[៣៧១] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ ហើយបង្គាប់ភិក្ខុដទៃឲ្យពោលទោស (ឬ) តិះដៀល (ភិក្ខុផងគ្នា) ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មប្រកបដោយធម៌ ហើយបង្គាប់ភិក្ខុដទៃឲ្យពោលទោស (ឬ) តិះដៀល (ភិក្ខុផងគ្នា) ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ តែភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌វិញ ហើយបង្គាប់ភិក្ខុដទៃឲ្យពោលទោស (ឬ) តិះដៀល (ភិក្ខុផងគ្នា) ត្រូវអាបត្តិបាចិត្តិយ ។

[៣៧២] អនុបសម្បន្នំ ឧជ្ឈាបេតិ វា ខីយតិ វា អាបត្តិ ទុក្កដស្ស ។ ឧបសម្បន្នំ សង្ឃេន អសម្មតំ សេនាសនបញ្ញាបកំ វា ភត្តុទ្ទេសកំ វា យាគុភាជកំ វា ផលភាជកំ វា ខជ្ជភាជកំ វា អប្បមត្តកវិសជ្ជកំ វា អវណ្ណំ កាតុកាមោ អយសំ កាតុកាមោ មង្កុកាតុកាមោ ឧបសម្បន្នំ វា អនុបសម្បន្នំ វា ឧជ្ឈាបេតិ វា ខីយតិ វា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នំ សង្ឃេន សម្មតំ វា អសម្មតំ វា សេនាសនបញ្ញាបកំ វា ភត្តុទ្ទេសកំ វា យាគុភាជកំ វា ផលភាជកំ វា ខជ្ជភាជកំ វា អប្បមត្តកវិសជ្ជកំ វា អវណ្ណំ កាតុកាមោ អយសំ កាតុកាមោ មង្កុកាតុកាមោ ឧបសម្បន្នំ វា

[៣៧២] ភិក្ខុបង្គាប់ភិក្ខុដទៃឲ្យពោលទោសក្តី តិះដៀលដោយខ្លួនឯងក្តី នូវអនុបសម្បន្នបុគ្គល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានប្រាថ្នានឹងធ្វើនូវសេចក្តីតិះដៀល មានប្រាថ្នានឹងធ្វើនូវសេចក្តីបង្អាប់យស មានប្រាថ្នានឹងធ្វើនូវសេចក្តីបង្អាប់បង្អោន ចំពោះឧបសម្បន្នបុគ្គល ដែលសង្ឃមិនបានសន្មតឲ្យជាអ្នកក្រាលសេនាសនៈក្តី ឲ្យជាអ្នកចាត់ចែងនូវភត្តក្តី ឲ្យជាអ្នកចែកនូវបបរក្តី ឲ្យជាអ្នកចែកនូវផ្លែឈើក្តី ឲ្យជាអ្នកចែកនូវបង្អែមក្តី ឲ្យជាអ្នកចែកចាយនូវវត្ថុមានប្រមាណតិចតួចក្តី ហើយបង្គាប់ភិក្ខុដទៃឲ្យពោលទោសក្តី តិះដៀលដោយខ្លួនឯងក្តី នូវឧបសម្បន្នបុគ្គលក្តី នូវអនុបសម្បន្នបុគ្គលក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានប្រាថ្នានឹងធ្វើនូវសេចក្តីតិះដៀល មានប្រាថ្នានឹងធ្វើនូវសេចក្តីបង្អាប់យស មានប្រាថ្នានឹងធ្វើនូវសេចក្តីបង្អាប់បង្អោនចំពោះអនុបសម្បន្នបុគ្គល ដែលសង្ឃបានសន្មត ឬមិនបានសន្មត ឲ្យជាអ្នកក្រាលនូវសេនាសនៈក្តី ឲ្យជាអ្នកចាត់ចែងនូវភត្តក្តី ឲ្យជាអ្នកចែកនូវបបរក្តី ឲ្យជាអ្នកចែកផ្លែឈើក្តី ឲ្យជាអ្នកចែកនូវបង្អែមក្តី ឲ្យជាអ្នកចែកចាយនូវវត្ថុមានប្រមាណតិចតួចក្តី ហើយបង្គាប់ភិក្ខុដទៃឲ្យពោលទោស ឬតិះដៀលដោយខ្លួនឯង នូវឧបសម្បន្នបុគ្គលក្តី

អនុបសម្បន្នំ វា ឧជ្ឈាបេតិ វា ខីយតិ វា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

[៣៧៣] អនាបត្តិ បកតិយា ឆន្ទា ទោសា មោហា ភយា ករោន្តំ ឧជ្ឈាបេតិ វា ខីយតិ វា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។

អនុបសម្បន្នបុគ្គលក្តី ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសំគាល់ថា កម្មប្រកបដោយធម៌វិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យ ក្នុងកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[៣៧៣] អាបត្តិមិនមាន ដល់ភិក្ខុដែលបង្គាប់ភិក្ខុដទៃ ឲ្យពោលទោសក្តី តិះដៀលដោយខ្លួនឯងក្តី នូវភិក្ខុដែលជាអ្នកធ្វើការសង្ឃ ដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិជាប្រក្រតី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៣ ចប់ ។

# ចតុត្ថសិក្ខាបទំ

[៣៧៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខូ ហេមន្តិកេ កាលេ អជ្ឈោ-កាសេ សេនាសនំ បញ្ញាបេត្វា កាយំ ឱតាបេន្តា កាលេ អារោចិតេ តំ បក្កមន្តា នេវ ឧទ្ធរឹសុ ន ឧទ្ធ-រាបេសុំ អនាបុច្ឆា បក្កមឹសុ ។ សេនាសនំ ឱវដ្ឋំ ហោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ អជ្ឈោកាសេ សេនាសនំ បញ្ញាបេត្វា តំ បក្កមន្តា នេវ ឧទ្ធរិស្សន្តិ ន ឧទ្ធរាបេស្សន្តិ អនាបុច្ឆា បក្ក-មិស្សន្តិ សេនាសនំ ឱវដ្ឋន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ភិក្ខូ អជ្ឈោកាសេ

# សិក្ខាបទទី ៩

[៣៧៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តព្រះជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ លំដាប់នោះ ភិក្ខុទាំងឡាយបានតែងតាំងគ្រឿងសេនាសនៈ នៅទីវាលហើយកំដៅកាយ ក្នុងកាលហេមន្តរដូវ (សម័យដែលមានទឹកសន្សើម) កាលបើគេប្រាប់ភត្តកាលគឺនិមន្តឆាន់ហើយ កាលនឹងដើរចេញទៅចាកទីនោះ មិនរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវសេ-នាសនៈនោះហើយឥតទាំងបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ។ ឯគ្រឿងសេនាសនៈទទឹកដោយទឹកសន្សើមជោកអស់ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនោះ ក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនសមបើនឹងតែងតាំងគ្រឿងសេនាសនៈនៅទីវាលហើយ កាលនឹងដើរចេញទៅមិនរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវសេនាសនៈនោះ ហើយឥតទាំងបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ គ្រឿងសេនាសនៈ ក៏ជោកជាំដោយទឹកសន្សើម គ្រានោះភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់សួរនូវភិក្ខុទាំងឡាយ

បាចិត្តិយកណ្ឌោ ភូតគាមវគ្គស្ស ចតុត្ថសិក្ខាបទស្ស បញ្ញត្តិ

សេនាសនំ បញ្ញាបេត្វា តំ បក្កមន្តា នេវ ឧទ្ធរន្តិ ន ឧទ្ធរាបេន្តិ អនាបុច្ឆា បក្កមន្តិ សេនាសនំ ឱវស្សន្តិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា អជ្ឈោកាសេ សេនាសនំ បញ្ញាបេត្វា តំ បក្កមន្តា នេវ ឧទ្ធរិស្សន្តិ ន ឧទ្ធរាបេស្សន្តិ អនាបុច្ឆា បក្កមិស្សន្តិ ។ សេនាសនំ ឱវស្សំ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សង្ឃិកំ មញ្ចំ វា បីឋំ វា ភិសឹ វា កោច្ឆំ វា អជ្ឈោកាសេ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ

ថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុបានតែងតាំងគ្រឿងសេនាសនៈនៅទីវាល កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវសេនាសនៈនោះ ហើយឥតទាំងបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ គ្រឿងសេនាសនៈ ក៏ជោកជាំដោយទឹកសន្សើម ពិតមែនឬ ។ ភិក្ខុទាំងនោះ ក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគទ្រង់បន្ទោសថា ម្នាលអ្នកទាំងឡាយ មោឃបុរសទាំងនោះ មិនសមបើនឹងតែងតាំងគ្រឿងសេនាសនៈនៅទីវាល ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវសេនាសនៈនោះ ហើយឥតទាំងបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ឯគ្រឿងសេនាសនៈ ក៏ជោកជាំដោយទឹកសន្សើម ម្នាលភិក្ខុទាំងឡាយ អំពើនេះនឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើងក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយលាតឬសន្ទឹងខ្លួនឯងក្តី ឲ្យគេលាតក្តី នូវគ្រែក្តី តាំងក្តី ពូកក្តី កៅអីក្តី ដែលជារបស់សង្ឃក្នុងទីវាល ហើយកាលនឹងដើរចេញទៅ មិនបានរើយកគ្រឿងសេនាសនៈ មានគ្រែជាដើមនោះ មកទុកដាក់ឯង

អនាបុច្ឆំ វា គច្ឆេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៣៧៥] តេន ខោ បន សមយេន ភិក្ខូ អជ្ឈោកាសេ វសិត្វា កាលស្សេវ សេនាសនំ អតិហរន្តិ ។ អទ្ទសា ខោ ភគវា តេ ភិក្ខូ កាលស្សេវ សេនាសនំ អតិហរន្តេ ។ ទិស្វាន ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អដ្ឋ មាសេ អវស្សិកសង្កេតេ មណ្ឌបេ វា រុក្ខមូលេ វា យត្ថ កាកា វា កុលលា វា ន ឩហទន្តិ តត្ថេវ[1] សេនាសនំ និក្ខិបិតុន្តិ ។

[៣៧៦] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សង្ឃិកំ នាម សង្ឃស្ស ទិន្នំ ហោតិ បរិច្ចត្តំ ។ មញ្ចោ នាម ចត្តារោ មញ្ចា មសារកោ

---

១ ឱ. តត្ថ ។

មិនបានប្រើគេឲ្យរើយកមកទុកដាក់ ហើយឥតបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៣៧៥] សម័យនោះ មានភិក្ខុច្រើនរូបនៅក្នុងទីវាល លុះព្រឹកឡើងក៏នាំគ្នាជញ្ជូនយកគ្រឿងសេនាសនៈទៅ ។ ព្រះដ៏មានព្រះភាគទ្រង់បានទតឃើញភិក្ខុទាំងនោះ កំពុងតែជញ្ជូនយកគ្រឿងសេនាសនៈទៅអំពីព្រឹក ។ លុះទ្រង់បានទតហើយ ទើបទ្រង់ធ្វើនូវធម្មីកថា ព្រោះរឿងនេះ ដំណើរនេះ ហើយត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វក្អែកក្តី ពួកសត្វខ្ទែងក្តី មិនបានបន្ទោបង់នូវឧច្ចារៈដាក់ក្នុងទីណា តថាគតអនុញ្ញាតឲ្យទុកដាក់គ្រឿងសេនាសនៈក្នុងទីនោះ គឺដូចជាមណ្ឌប ឬ រុក្ខមូល (ម្លប់ឈើ) អស់កាល ៨ ខែ គឺកំណត់យកខែដែលគ្មានភ្លៀង ។

[៣៧៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ សេនាសនៈដែលគេបានប្រគេន ឬ បានលះដល់សង្ឃ ហៅថា សេនាសនៈរបស់សង្ឃ ។ ដែលហៅថា គ្រែ បានដល់គ្រែ ៤ យ៉ាង គឺគ្រែដែលគេបញ្ចូលមេទៅក្នុងដំណាប់ជើង ១

ពុន្ទិកាពទ្ធោ កុលិរចាទកោ អាហច្ចចាទកោ ។ បីឋំ ណាម ចត្តារិ បីឋានិ មសារកំ ពុន្ទិកាពទ្ធំ កុលិរចាទកំ អាហច្ចចាទកំ ។ ភិសិ ណាម បញ្ច ភិសិយោ ឧណ្ណាភិសិ វាកភិសិ ចោលភិសិ តិណាភិសិ បណ្ណាភិសិ ។ កោច្ឆំ ណាម វាកមយំ វា ឧសីរមយំ វា មុញ្ជមយំ វា បព្វជមយំ វា អន្តោ សំវេឋេត្វា ពទ្ធំ ហោតិ ។ សន្ថរិត្វាតិ សយំ សន្ថរិត្វា ។ សន្ថរាបេត្វាតិ អញ្ញំ សន្ថរាបេត្វា ។ អនុបសម្បន្នំ សន្ថរាបេតិ តស្ស បលិពោធោ ។ ឧបសម្បន្នំ សន្ថរាបេតិ សន្ថារកស្ស បលិពោធោ ។

គ្រែដែលមានមេជាប់នឹងជើង ១ គ្រែដែលមានជើងដូចជាជើងក្ដាម[១] ១ គ្រែដែលមានជើងចុច ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ ១ ។ ដែលហៅថា តាំង បានដល់តាំងមាន ៤ យ៉ាង គឺតាំងដែលគេបញ្ចូលមេទៅក្នុងដំណាប់ជើង ១ តាំងដែលមានមេគេបង្ខាំជាប់នឹងជើង ១ តាំងដែលមានជើងដូចជាជើងក្ដាម[២] ១ តាំងដែលមានជើងចុច ឬតាំងដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ ១ ។ ដែលហៅថា ពូក បានដល់ពូក ៥ យ៉ាង គឺពូកដែលគេញាត់ដោយរោមសត្វ ១ ពូកដែលគេញាត់សម្បកឈើ ១ ពូកដែលគេញាត់កំណាត់សំពត់ ១ ពូកដែលគេញាត់ស្មៅ ១ ពូកដែលគេញាត់ស្លឹកឈើ ១ ។ ដែលហៅថា កៅអី គឺកៅអីដែលគេធ្វើដោយសម្បកឈើក្ដី ធ្វើដោយស្បូវភ្លាំងក្ដី ធ្វើដោយស្មៅយ៉ាប្លងក្ដី ធ្វើដោយស្មៅដំណេកទន្សាយក្ដី ដែលគេរុំហើយចងភ្ជាប់គ្នាខាងក្នុង ។ ពាក្យថា លាត គឺតម្កល់ទុកដោយខ្លួនឯង ។ ពាក្យថា ប្រើគេឲ្យលាត គឺប្រើបុគ្គលដទៃឲ្យតម្កល់ទុក ។ ភិក្ខុប្រើអនុបសម្បន្នបុគ្គលឲ្យតម្កល់ទុក សេចក្ដីខ្វល់នឹងមានដល់ភិក្ខុអ្នកប្រើនោះ ។ ភិក្ខុប្រើឧបសម្បន្នបុគ្គលឲ្យតម្កល់ទុក សេចក្ដីខ្វល់នឹងមានដល់អ្នកតម្កល់ទុកនោះ ។

---

១-២ គ្រែដែលមានជើងដូចជាជើងសេះ ជើងពពែជាដើម ឯតាំងក៏មានជើងដូចជាគ្រែដែរ ។

តំ បក្កមន្តោ នេវ ឧទ្ធរេយ្យាតិ ន សយំ ឧទ្ធរេយ្យ ។ ន ឧទ្ធរាបេយ្យាតិ ន អញ្ញំ ឧទ្ធរាបេយ្យ ។ អជាបុច្ឆំ វា គច្ឆេយ្យាតិ ភិក្ខុំ វា សាមណេរំ វា អារាមិកំ វា អជាបុច្ឆា មជ្ឈិមស្ស បុរិសស្ស លេឌ្ឌុបាតំ អតិក្កមន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣៧៧] សង្ឃិកេ សង្ឃិកសញ្ញី អជ្ឈោកាសេ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ អជាបុច្ឆំ វា គច្ឆេយ្យ អាបត្តិ បាចិត្តិយស្ស ។ សង្ឃិកេ វេមតិកោ អជ្ឈោកាសេ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ អជាបុច្ឆំ វា គច្ឆេយ្យ អាបត្តិ បាចិត្តិយស្ស ។ សង្ឃិកេ

ពាក្យថា កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់នូវគ្រឿងសេនាសនៈនោះ គឺមិនបានរើយកមកទុកដាក់ដោយខ្លួនឯង ។ ពាក្យថា មិនបានប្រើគេឲ្យរើយកមកទុកដាក់ គឺមិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់ ។ ពាក្យថា ឥតបានប្រាប់ (អ្នកដទៃ) ហើយដើរចេញទៅ គឺកាលដែលភិក្ខុមិនបានប្រាប់ភិក្ខុផងគ្នាក្តី សាមណេរក្តី ញោមវត្តក្តី ហើយដើរកន្លង ១ លេឌ្ឌុបាត[១] របស់មជ្ឈិមបុរសទៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣៧៧] របស់សង្ឃ ភិក្ខុសំគាល់ថា របស់សង្ឃ ហើយតម្កល់ទុកដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យតម្កល់ទុកនៅក្នុងទីវាល កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង មិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់នូវគ្រឿងសេនាសនៈនោះ ឬមិនបានប្រាប់ (អ្នកដទៃ) ហើយដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងរបស់សង្ឃ ហើយតម្កល់ទុកដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យតម្កល់ទុកក្នុងទីវាល កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង មិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬមិនបានប្រាប់ (អ្នកដទៃ) ហើយចេញដើរទៅ ត្រូវអាបត្តិបាចិត្តិយ ។ របស់សង្ឃ

---

១ ចម្ងាយមួយបោះដុំដី ដែលមជ្ឈិមបុរសបោះចោលទៅ ។

បុគ្គលិកសញ្ញី អជ្ឈោកាសេ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ អនាបុច្ឆំ វា គច្ឆេយ្យ អាបត្តិ បាចិត្តិយស្ស ។ ចិមិលិកំ វា ឧត្តរត្ថរណំ វា ភុម្មត្ថរណំ វា តដ្ដិកំ វា ចម្មខណ្ឌំ វា បាទបុញ្ឆនី វា ផលកបីឋំ វា អជ្ឈោកាសេ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ អនាបុច្ឆំ វា គច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ សង្ឃិកសញ្ញី អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ បុគ្គលិកសញ្ញី អញ្ញស្ស បុគ្គលិកេ អាបត្តិ ទុក្កដស្ស ។ អត្តនោ បុគ្គលិកេ អនាបត្តិ ។

ភិក្ខុមានសេចក្ដីសំគាល់ថា ជារបស់បុគ្គលទៅវិញ ហើយតម្កល់ទុកដោយខ្លួនឯងក្ដី ប្រើអ្នកដទៃឲ្យតម្កល់ទុកក្ដី នៅក្នុងទីវាល កាលនឹងចៀសចេញទៅ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង មិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬមិនបានប្រាប់ (អ្នកដទៃ) ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុតម្កល់ទុកដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យតម្កល់ទុក នូវគ្រឿងទ្រនាប់ក្ដី គ្រឿងកម្រាលគ្រែ ឬតាំងក្ដី គ្រឿងកម្រាលផែនដីក្ដី កន្ទេលទន់ក្ដី ប្រមខណ្ឌ គឺគ្រឿងកម្រាលដែលគេធ្វើដោយស្បែកខ្លាជាដើមក្ដី គ្រឿងសម្រាប់ជូតជើងក្ដី តាំងដែលគេធ្វើដោយផែនក្ដារក្ដី នៅក្នុងទីវាល កាលនឹងចៀសចេញទៅ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង មិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈទាំងនោះ ឬមិនបានប្រាប់ (អ្នកដទៃ) ហើយចៀសចេញទៅ ត្រូវអាបត្តិទុក្កដ ។ របស់បុគ្គល ភិក្ខុមានសេចក្ដីសំគាល់ថាជារបស់សង្ឃវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្ដីសង្ស័យ ក្នុងរបស់បុគ្គល ត្រូវអាបត្តិទុក្កដ ។ របស់បុគ្គល ភិក្ខុមានសេចក្ដីសំគាល់ថាជារបស់បុគ្គល វត្ថុជារបស់បុគ្គលនៃភិក្ខុឯទៀត (ដែលមិនមែនជាវិស្សាសៈ) ត្រូវអាបត្តិទុក្កដ ។ វត្ថុជារបស់បុគ្គល ភិក្ខុកាន់យកដោយសេចក្ដី (ស្និទ្ធស្នាល) ដូចជារបស់ខ្លួន មិនត្រូវអាបត្តិឡើយ ។

[៣៧៨] អជាបត្តិ ឧទ្ធរិត្វា គច្ឆតិ ឧទ្ធរាបេត្វា គច្ឆតិ អាបុច្ឆំ គច្ឆតិ ឱតាបេន្តោ គច្ឆតិ កេនចិ បលិពុទ្ធំ ហោតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។

[៣៧៨] អាបត្តិមិនមាន ដល់ភិក្ខុដែលបានរើយកគ្រឿងសេនាសនៈមកទុកដាក់ដោយខ្លួនឯងហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រើអ្នកដទៃឲ្យរើយកគ្រឿងសេនាសនៈមកទុកដាក់ហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រាប់ (អ្នកដទៃ) ហើយដើរចេញទៅ ដល់ភិក្ខុដែលហាលគ្រឿងសេនាសនៈហើយដើរចេញទៅ (ដោយគិតថា នឹងត្រឡប់មកយកទុកវិញ) ដល់ភិក្ខុដែលមានគ្រឿងសេនាសនៈ ដែលមានបុគ្គលណាមួយមកបៀតបៀន[១] ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ[២] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់ ។

---

១ បើមានភិក្ខុចាស់បង្គាប់ភិក្ខុនោះឲ្យក្រោកចេញចាកទីសេនាសនៈ ហើយកាន់យកដោយខ្លួនលោកក្តី ឬមានយក្សក្តី ប្រេតក្តី វាមកអង្គុយនៅលើសេនាសនៈនោះឬមានជនជាធំណាមួយមកដល់ហើយកាន់យកគ្រឿងសេនាសនៈនោះ គ្រឿងសេនាសនៈនោះឈ្មោះថាមានបុគ្គលណាមួយមកបៀតបៀន ។ ម្យ៉ាងទៀត កាលបើមានពួកសត្វ មានរាជសីហ៍និងខ្លាជាដើម វាមកក្នុងប្រទេសហើយ ឈរនៅជិតគ្រឿងសេនាសនៈនោះ គ្រឿងសេនាសនៈនោះឈ្មោះថាមានបុគ្គលណាមួយមកបៀតបៀនដូចគ្នាដែរ ។ តែមានបុគ្គលណាមួយមកបៀតបៀនយ៉ាងនេះហើយ ទុកជាភិក្ខុមិនបានរើយកគ្រឿងសេនាសនៈនោះមកទុកដាក់ ក៏មិនត្រូវអាបត្តិឡើយ ។
២ គឺអន្តរាយជីវិត ឬអន្តរាយព្រហ្មចរិយធម៌ ។

# បញ្ចមសិក្ខាបទំ

[៣៧៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សត្តរសវគ្គិយា ភិក្ខូ សហាយកា ហោន្តិ ។ តេ វសន្តាបិ ឯកតោវ វសន្តិ បក្កមន្តាបិ ឯកតោ វ បក្កមន្តិ ។ តេ អញ្ញតរស្មឹ សង្ឃិកេ វិហារេ សេយ្យំ សន្ថរិត្វា តំ បក្កមន្តា នេវ ឧទ្ធរឹសុ ន ឧទ្ធរាបេសុំ អនាបុច្ឆា បក្កមឹសុ ។ សេនាសនំ ឧបចិកាហិ ខាយិតំ ហោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សត្តរសវគ្គិយា ភិក្ខូ សង្ឃិកេ វិហារេ សេយ្យំ សន្ថរិត្វា តំ បក្កមន្តា នេវ ឧទ្ធរិស្សន្តិ ន ឧទ្ធរាបេស្សន្តិ អនាបុច្ឆា បក្កមិស្សន្តិ សេនាសនំ ឧបចិកាហិ ខាយិតន្តិ ។ អថខោ

# សិក្ខាបទទី ៥

[៣៧៩] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមានពួក ១៧ ជាសំឡាញ់នឹងគ្នា ។ ភិក្ខុទាំងនោះ កាលនឹងនៅក៏នៅជាមួយគ្នា កាលនឹងដើរក៏ដើរជាមួយគ្នា ។ ភិក្ខុទាំងនោះឯង បានក្រាលគ្រឿងកម្រាលសម្រាប់ដេក ក្នុងវិហារជារបស់សង្ឃណាមួយ ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់វិញ នូវគ្រឿងកម្រាលសម្រាប់ដេកនោះ ហើយឥតទាំងប្រាប់ (អ្នកដទៃ) ឡើយ ស្រាប់តែចៀសចេញទៅ ។ ឯពួកសត្វកណ្ដៀរក៏កោរកាត់គ្រឿងសេនាសនៈខូចអស់ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា កោតតែភិក្ខុទាំង ១៧ រូបហ៊ានក្រាលគ្រឿងកម្រាលសម្រាប់ដេក ក្នុងវិហារជារបស់សង្ឃ ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវគ្រឿងកម្រាលសម្រាប់ដេកនោះ ហើយឥតទាំងប្រាប់ (អ្នកដទៃ) ឡើយ ស្រាប់តែចៀសចេញទៅ ឯពួកសត្វកណ្ដៀរក៏កោរកាត់គ្រឿងសេនាសនៈខូចអស់ ។ លំដាប់នោះ

តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ សត្តរសវគ្គិយា ភិក្ខូ សង្ឃិកេ វិហារេ សេយ្យំ សន្ថរិត្វា តំ បក្កមន្តា នេវ ឧទ្ធរឹសុ ន ឧទ្ធរាបេសុំ អនាបុច្ឆា បក្កមឹសុ សេនាសនំ ឧបចិកាហិ ខាយិតន្តិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា សង្ឃិកេ វិហារេ សេយ្យំ សន្ថរិត្វា តំ បក្កមន្តា នេវ ឧទ្ធរិស្សន្តិ ន ឧទ្ធរាបេស្សន្តិ អនាបុច្ឆា បក្កមិស្សន្តិ សេនាសនំ ឧបចិកាហិ ខាយិតំ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ

ភិក្ខុទាំងអម្បាលនោះ ក៏បានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ (ដោយសព្វគ្រប់) ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរចំពោះភិក្ខុទាំងនោះថា នៃភិក្ខុទាំងឡាយ ឮថាភិក្ខុមានពួក ១៧ រូបបានក្រាលកម្រាលសម្រាប់ដេកក្នុងវិហារជារបស់សង្ឃ ហើយកាលដែលដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់នូវកម្រាលសម្រាប់ដេកនោះ ឥតទាំងបានប្រាប់ (អ្នកដទៃ) ឡើយ ស្រាប់តែដើរចេញទៅ គ្រឿងសេនាសនៈ ពួកសត្វកណ្ដៀរវាក៏កោរកាត់ខូចអស់ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសទាំងនោះ មិនសមបើនឹងក្រាលគ្រឿងកម្រាលសម្រាប់ដេក ក្នុងវិហារជារបស់សង្ឃ ហើយកាលដែលដើរចេញទៅ ក៏មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ហើយឥតទាំងប្រាប់ (អ្នកដទៃ) សោះឡើយ ស្រាប់តែដើរចេញទៅ គ្រឿងសេនាសនៈទាំងនោះ ពួកសត្វកណ្ដៀរវាក៏កោរកាត់ខូចអស់ ម្នាលភិក្ខុទាំងឡាយ អំពើនេះនឹងបានដឹកនាំពួកមនុស្ស ដែលមិនទាន់ជ្រះថ្លាឲ្យបានជ្រះថ្លាឡើងក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ

សង្ឃិកេ វិហារេ សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ អនាបុច្ឆំ វា គច្ឆេយ្យ បាចិត្តិយន្តិ ។

[៣៨០] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សង្ឃិកោ នាម វិហារោ សង្ឃស្ស ទិន្នោ ហោតិ បរិច្ចត្តោ ។ សេយ្យំ នាម ភិសិ ចិមិលិកា ឧត្តរត្ថរណំ ភុម្មត្ថរណំ តដ្ដិកា ចម្ម-ខណ្ឌោ និសីទនំ បច្ចត្ថរណំ តិណសន្ថារោ បណ្ណ-សន្ថារោ ។ សន្ថរិត្វាតិ សយំ សន្ថរិត្វា ។ សន្ថ-រាបេត្វាតិ អញ្ញំ សន្ថរាបេត្វា ។ តំ បក្កមន្តោ នេវ ឧទ្ធរេយ្យាតិ ន សយំ ឧទ្ធរេយ្យ ។ ន ឧទ្ធរាបេយ្យាតិ ន អញ្ញំ ឧទ្ធរាបេយ្យ ។ អនាបុច្ឆំ វា គច្ឆេយ្យាតិ

ក្រាល ឬប្រើគេឲ្យក្រាលនូវកម្រាលសម្រាប់ដេក ក្នុងវិហារជារបស់សង្ឃ ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬឥតបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣៨០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិកសិក្ខាបទខាងដើមហើយ ។ វិហារដែលគេបានវេរប្រគេន ឬគេបានលះបង់ដល់សង្ឃហើយ ហៅថា វិហាររបស់សង្ឃ ។ ពូក គ្រឿងទ្រនាប់ កម្រាលគ្រែ ឬតាំង កម្រាលផែនដី កន្ទេលទន់ ច្រមខណ្ឌ (កំណាត់ស្បែក) និសីទនៈ (សំពត់សម្រាប់ទ្រាប់អង្គុយ) កម្រាលដែលគេធ្វើដោយស្មៅ កម្រាលដែលគេធ្វើដោយស្លឹក ហៅថា កម្រាលសម្រាប់ដេក ។ ពាក្យថា ក្រាល គឺក្រាលដោយខ្លួនឯង ។ ពាក្យថា ប្រើគេឲ្យក្រាល គឺប្រើអ្នកដទៃឲ្យក្រាល ។ ពាក្យថា កាលនឹងដើរចេញទៅមិនបានរើយកគ្រឿងកម្រាលនោះមកទុកដាក់ ដោយខ្លួនឯង គឺមិនបានរើយកមកទុកដាក់ដោយខ្លួនឯង ។ ពាក្យថា មិនបានប្រើគេឲ្យរើយកមកទុកដាក់ គឺមិនបានប្រើអ្នកដទៃឲ្យរើយកមកទុកដាក់ឡើយ ។ ពាក្យថា ឥតបានប្រាប់ (អ្នកដទៃ) ហើយដើរចេញទៅ គឺមិនបានប្រាប់

ភិក្ខុំ វា សាមណេរំ វា អារាមិកំ វា អនាបុច្ឆា បរិក្ខិត្តស្ស អារាមស្ស បរិក្ខេបំ អតិក្កមន្តស្ស អាបត្តិ ចាចិត្តិយស្ស ។ អបរិក្ខិត្តស្ស អារាមស្ស ឧបចារំ អតិក្កមន្តស្ស អាបត្តិ ចាចិត្តិយស្ស ។

[៣៨១] សង្ឃិកេ សង្ឃិកសញ្ញី សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ អនាបុច្ឆំ វា គច្ឆេយ្យ អាបត្តិ ចាចិត្តិយស្ស ។ សង្ឃិកេ វេមតិកោ សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ អនាបុច្ឆំ វា គច្ឆេយ្យ អាបត្តិ ចាចិត្តិយស្ស ។ សង្ឃិកេ បុគ្គលិកសញ្ញី សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ អនាបុច្ឆំ វា គច្ឆេយ្យ អាបត្តិ ចាចិត្តិយស្ស ។ វិហារស្ស ឧបចារេ វា

ភិក្ខុក្តី សាមណេរក្តី ញោមវត្តក្តី ហើយដើរទៅកន្ទង់របង់វត្ត ដែលគេបិទបាំង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុកាលបើដើរកន្ទង់ឧបចារវត្តដែលគ្មានរបង់ ត្រូវអាបត្តិបាចិត្តិយ ។

[៣៨១] វិហាររបស់សង្ឃ ភិក្ខុសំគាល់ថា ជារបស់សង្ឃ ហើយក្រាលដោយខ្លួនឯង ឬប្រើគេឲ្យក្រាលនូវកម្រាលសម្រាប់ដេក កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើឲ្យរើយកមកទុកដាក់ នូវកម្រាលសម្រាប់ដេកនោះ ឬឥតប្រាប់ (អ្នកដទៃ) ឡើយ ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងវិហារជារបស់សង្ឃ ហើយក្រាលដោយខ្លួនឯង ឬប្រើគេឲ្យក្រាលនូវកម្រាលសម្រាប់ដេក កាលដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់ នូវកម្រាលសម្រាប់ដេកនោះ ឬឥតបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុសំគាល់ថា ជារបស់បុគ្គលទៅវិញ ហើយក្រាលដោយខ្លួនឯង ឬប្រើគេឲ្យក្រាល នូវកម្រាលសម្រាប់ដេក ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនប្រាប់គេឲ្យរើយកមកទុកដាក់ នូវកម្រាលសម្រាប់ដេកនោះ ឬឥតបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រាលដោយខ្លួនឯង ឬប្រើគេឲ្យក្រាល

ឧបដ្ឋានសាលាយំ វា មណ្ឌបេ វា រុក្ខមូលេ វា សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ អនាបុច្ឆំ វា គច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។ មញ្ចំ វា បីឋំ វា វិហារេ វា វិហារស្ស ឧបចារេ វា ឧបដ្ឋានសាលាយំ វា មណ្ឌបេ វា រុក្ខមូលេ វា សន្ថរិត្វា វា សន្ថរា-បេត្វា វា តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរា-បេយ្យ អនាបុច្ឆំ វា គច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ សង្ឃិកសញ្ញី អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បុគ្គ-លិកេ បុគ្គលិកសញ្ញី អញ្ញស្ស បុគ្គលិកេ អាបត្តិ ទុក្កដស្ស ។ អត្តនោ បុគ្គលិកេ អនាបត្តិ ។

នូវកម្រាលសម្រាប់ដេក ក្នុងឧបចារវិហារក្តី ក្នុងរោងសម្រាប់ឆាន់ក្តី ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រាប់គេឲ្យរើយកមកទុកដាក់នូវកម្រាលសម្រាប់ដេកនោះ ឬឥតបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុក្រាលដោយខ្លួនឯងក្តី ប្រើគេឲ្យក្រាលក្តី នូវគ្រែ ឬតាំងក្នុងវិហារក្តី ក្នុងឧបចារវិហារក្តី ក្នុងរោងសម្រាប់ឆាន់ក្តី ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឲ្យរើយកមកទុកដាក់នូវគ្រែ និងតាំងនោះ ឬឥតបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថា ជារបស់សង្ឃទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងវិហារជារបស់បុគ្គល ត្រូវអាបត្តិទុក្កដ ។ វិហារជារបស់បុគ្គល ភិក្ខុដឹងច្បាស់ថាជារបស់បុគ្គល គឺវិហារដែលជារបស់បុគ្គលនៃភិក្ខុដទៃ (ដែលមិនមែនជាវិស្សាសៈ) ត្រូវអាបត្តិទុក្កដ ។ វិហារជារបស់បុគ្គល (ដែលជាទីស្និទ្ធស្នាលនឹងខ្លួន) មិនត្រូវអាបត្តិឡើយ ។

[៣៨២] អជាបត្តិ ឧទ្ទវិត្វា គច្ឆតិ ឧទ្ទាបេត្វា គច្ឆតិ អាបុច្ឆំ គច្ឆតិ កោេនចិ បលិពុទ្ធំ ហោតិ សាបេក្ខោ គន្ត្វា តត្ថ ឋិតោ អាបុច្ឆតិ កេនចិ បលិពុទ្ធោ ហោតិ អាបទាសុ ឧម្មត្តកស្ស អាទិ-កម្មិកស្សាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។

[៣៨២] អាបត្តិមិនមាន ដល់ភិក្ខុដែលបានរើកម្រាលយកមកទុកដាក់ដោយខ្លួនឯង រួចហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រើគេឲ្យរើយកមកទុកដាក់ហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រាប់ (អ្នកដទៃ) រួចហើយដើរចេញទៅ ដល់ភិក្ខុមានកម្រាលដែលមានបុគ្គលណាមួយចូលទៅបៀតបៀន[១] ដល់ភិក្ខុដែលមានសេចក្តីអាឡោះអាល័យ[២] បានដើរចេញទៅឈរក្នុងទីនោះប្រាប់ (បុគ្គលណាមួយ) ថា ភិក្ខុនោះមានសេចក្តីអន្តរាយនីមួយមកបៀតបៀនហើយ ដល់ភិក្ខុមានសេចក្តីអន្តរាយ[៣]កើតឡើង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់ ។

---

១-២ បានអធិប្បាយក្នុងសិក្ខាបទទី ៤ ខាងដើមរួចជាស្រេច ។ ៣ តាមន័យក្នុងអដ្ឋកថាថាភិក្ខុកាលចេញដើរទៅ គិតថាអាត្មាអញនឹងត្រឡប់មករៀបចំទុកដាក់កម្រាលវិញក្នុងថ្ងៃនេះ លុះទៅដល់ទីដែលខ្លួនប្រាថ្នានឹងទៅនៅនោះ ក៏មានសេចក្តីអន្តរាយកើតឡើងមិនអាចនឹងត្រឡប់មកវិញបាន ។

# សង្ខេបចង្អុលប្រាប់មាតិកា

និស្សគ្គិយកណ្ឌ លេខទំព័រ

## ចីវរវគ្គ សិក្ខាបទទី ១


និទានឆព្វគ្គិយភិក្ខុ............................................................................................ ១

សេចក្តីបញ្ញត្តជាដំបូង........................................................................................ ៣

សេចក្តីបញ្ញត្តជាបន្ទាប់ និងសិក្ខាបទវិភង្គ.............................................................. ៤

បទភាជនីយ និងវារៈដែលត្រូវអាបត្តិ.................................................................... ៧

វារៈដែលមិនត្រូវអាបត្តិ........................................................................................ ៨


## សិក្ខាបទទី ២


និទានភិក្ខុច្រើនរូប............................................................................................ ១០

សេចក្តីបញ្ញត្តជាដំបូង........................................................................................ ១១

សេចក្តីបញ្ញត្តជាបន្ទាប់ និងសិក្ខាបទវិភង្គ.............................................................. ១៤

បទភាជនីយ...................................................................................................... ១៥

វារៈដែលមិនត្រូវអាបត្តិ........................................................................................ ២៣


## សិក្ខាបទទី ៣


និទានភិក្ខុ ១ រូប................................................................................................ ២៤

សេចក្តីបញ្ញត្តជាដំបូង........................................................................................ ២៦

សិក្ខាបទវិភង្គ.................................................................................................... ២៧

វារៈដែលត្រូវអាបត្តិ............................................................................................ ៣១

វារៈដែលមិនត្រូវអាបត្តិ........................................................................................ ៣២

# សង្ខេបរឿងទាំងក្នុងច្បាប់មាតិកា

លេខទំព័រ

## សិក្ខាបទទី ៤

និទានស្រីបុរាណទុតិយិកា របស់ឧទាយិភិក្ខុ........................................................ ៣៣
សេចក្ដីបញ្ញត្ត........................................................................................................ ៣៥
សិក្ខាបទវិភង្គ និងបទភាជនីយ............................................................................ ៣៦
វារៈដែលត្រូវអាបត្តិ.............................................................................................. ៣៧
វារៈដែលមិនត្រូវអាបត្តិ........................................................................................ ៣៩

## សិក្ខាបទទី ៥

និទាននាងឧប្បលវណ្ណាភិក្ខុនី................................................................................ ៤០
សេចក្ដីបញ្ញត្តជាដំបូង.......................................................................................... ៤៤
សេចក្ដីបញ្ញត្តជាបន្ទាប់ និងសិក្ខាបទវិភង្គ.............................................................. ៤៥
វារៈដែលមិនត្រូវអាបត្តិ........................................................................................ ៤៧

## សិក្ខាបទទី ៦

និទានឧបនន្ទសក្យបុត្ត.......................................................................................... ៤៨
សេចក្ដីបញ្ញត្តជាដំបូង.......................................................................................... ៥២
សេចក្ដីបញ្ញត្តជាបន្ទាប់ និងសិក្ខាបទវិភង្គ.............................................................. ៥៤
វារៈដែលមិនត្រូវអាបត្តិ........................................................................................ ៥៦

## សិក្ខាបទទី ៧

និទានឆព្វគ្គិយភិក្ខុ................................................................................................ ៥៧
សេចក្ដីបញ្ញត្ត និងសិក្ខាបទវិភង្គ............................................................................ ៥៩
បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ................................................................ ៦១

# សន្ទឹកាចង្អុលប្រាប់មាតិកា

លេខទំព័រ

## សិក្ខាបទទី ៨

និទានឧបនន្ទសក្យបុត្ត........................................................................... ៦២
សេចក្តីបញ្ញត្ត................................................................................... ៦៤
សិក្ខាបទវិភង្គ និងបទភាជនីយ.................................................................. ៦៥
វារៈដែលមិនត្រូវអាបត្តិ........................................................................... ៦៧

## សិក្ខាបទទី ៩

និទានឧបនន្ទសក្យបុត្ត........................................................................... ៦៨
សេចក្តីបញ្ញត្ត................................................................................... ៧០
សិក្ខាបទវិភង្គ................................................................................... ៧១
វារៈដែលត្រូវអាបត្តិ............................................................................... ៧៣
វារៈដែលមិនត្រូវអាបត្តិ........................................................................... ៧៤

## សិក្ខាបទទី ១០

និទានឧបនន្ទសក្យបុត្ត............................................................................. ៧៥
សេចក្តីបញ្ញត្ត................................................................................... ៧៩
សិក្ខាបទវិភង្គ ................................................................................... ៨១
វារៈដែលមិនត្រូវអាបត្តិ........................................................................... ៨៥
ឧទ្ទាននៃចីវរវគ្គ................................................................................... ៨៦

## កោសិយវគ្គ សិក្ខាបទទី ១

និទានឆព្វគ្គិយភិក្ខុ................................................................................. ៨៧
សេចក្តីបញ្ញត្ត និងសិក្ខាបទវិភង្គ..................................................................... ៨៩
វារៈដែលមិនត្រូវអាបត្តិ........................................................................... ៩០

# សង្ខេបកថា/សង្កឹកចង្អុលប្រាប់មាតិកា

លេខទំព័រ

## សិក្ខាបទទី ២

និទានឆព្វគ្គិយភិក្ខុ........................................................................................ ៩១
សេចក្តីបញ្ញត្ត និងសិក្ខាបទវិភង្គ........................................................................ ៩២
វារៈដែលមិនត្រូវអាបត្តិ................................................................................... ៩៣

## សិក្ខាបទទី ៣

និទានឆព្វគ្គិយភិក្ខុ........................................................................................ ៩៤
សេចក្តីបញ្ញត្ត និងសិក្ខាបទវិភង្គ........................................................................ ៩៥
វារៈដែលមិនត្រូវអាបត្តិ................................................................................... ៩៧

## សិក្ខាបទទី ៤

និទានភិក្ខុច្រើនរូប........................................................................................ ៩៨
សេចក្តីបញ្ញត្តជាដំបូង..................................................................................... ១០០
សេចក្តីបញ្ញត្តជាបន្ទាប់ និងសិក្ខាបទវិភង្គ........................................................ ១០២
វារៈដែលមិនត្រូវអាបត្តិ................................................................................... ១០៤

## សិក្ខាបទទី ៥

និទានឧបសេនវង្គន្តបុត្តភិក្ខុ............................................................................. ១០៥
ប្រយោជន៍ ១០ យ៉ាងនៃការបញ្ញត្តិព្រះវិន័យ...................................................... ១១១
សេចក្តីបញ្ញត្ត និងសិក្ខាបទវិភង្គ........................................................................ ១១២
វារៈដែលត្រូវអាបត្តិ........................................................................................ ១១៣
វារៈដែលមិនត្រូវអាបត្តិ................................................................................... ១១៤

# សង្ខឹកចង្អុលប្រាប់មាតិកា

លេខទំព័រ

## សិក្ខាបទទី ៦


និទានភិក្ខុ ១ រូប................................................................................ ១១៥

សេចក្តីបញ្ញត្ត................................................................................ ១១៦

សិក្ខាបទវិភង្គ................................................................................ ១១៧

បទភាជនីយ................................................................................ ១១៨

វារៈដែលមិនត្រូវអាបត្តិ................................................................................ ១១៩


## សិក្ខាបទទី ៧


និទានឆព្វគ្គិយភិក្ខុ................................................................................ ១២០

សេចក្តីបញ្ញត្ត និងសិក្ខាបទវិភង្គ................................................................................ ១២២

បទភាជនីយ................................................................................ ១២៣

វារៈដែលមិនត្រូវអាបត្តិ................................................................................ ១២៥


## សិក្ខាបទទី ៨


និទានឧបនន្ទសក្យបុត្ត................................................................................ ១២៦

សេចក្តីបញ្ញត្ត................................................................................ ១២៨

សិក្ខាបទវិភង្គ................................................................................ ១២៩

បទភាជនីយ................................................................................ ១៣១

វារៈដែលមិនត្រូវអាបត្តិ................................................................................ ១៣២


## សិក្ខាបទទី ៩


និទានឆព្វគ្គិយភិក្ខុ................................................................................ ១៣៣

សេចក្តីបញ្ញត្ត និងសិក្ខាបទវិភង្គ................................................................................ ១៣៤

# សន្លឹកចង្អុលប្រាប់មាតិកា

លេខទំព័រ


បទភាជនីយ........................................................................................ ១៣៥

វារៈដែលមិនត្រូវអាបត្តិ.......................................................................... ១៣៨

## សិក្ខាបទទី ១០

និទានឧបនន្ទសក្យបុត្ត.............................................................................. ១៣៩

សេចក្ដីបញ្ញត្ត និងសិក្ខាបទវិភង្គ............................................................... ១៤១

បទភាជនីយ........................................................................................ ១៤២

វារៈដែលមិនត្រូវអាបត្តិ.......................................................................... ១៤៣

ឧទ្ទាននៃកោសិយវគ្គ.............................................................................. ១៤៤

## បត្តវគ្គ សិក្ខាបទទី ១

និទានឆព្វគ្គិយភិក្ខុ................................................................................. ១៤៥

សេចក្ដីបញ្ញត្តជាដំបូង............................................................................ ១៤៦

សេចក្ដីបញ្ញត្តជាបន្ទាប់ និងសិក្ខាបទវិភង្គ.................................................. ១៤៧

បទភាជនីយ........................................................................................ ១៤៨

វារៈដែលមិនត្រូវអាបត្តិ.......................................................................... ១៥១

## សិក្ខាបទទី ២

និទានភិក្ខុច្រើនរូប.................................................................................. ១៥៣

សេចក្ដីបញ្ញត្ត........................................................................................ ១៥៧

សិក្ខាបទវិភង្គ........................................................................................ ១៥៨

ការសន្មតភិក្ខុឲ្យជាអ្នកប្រគល់បាត្រ........................................................... ១៥៩

បទភាជនីយ........................................................................................ ១៦១

វារៈដែលមិនត្រូវអាបត្តិ.......................................................................... ១៦៦

# សន្លឹកចង្អុលប្រាប់មាតិកា

លេខទំព័រ

## សិក្ខាបទទី ៣

និទានបិលិន្ទវច្ឆត្ថេរ................................................................................................. ១៦៧
សេចក្តីបញ្ញត្ត................................................................................................................ ១៧៥
សិក្ខាបទវិភង្គ................................................................................................................ ១៧៦
វារៈដែលត្រូវអាបត្តិ........................................................................................................ ១៧៧
វារៈដែលមិនត្រូវអាបត្តិ.................................................................................................. ១៧៨

## សិក្ខាបទទី ៤

និទានឆព្វគ្គិយភិក្ខុ........................................................................................................ ១៧៩
សេចក្តីបញ្ញត្ត................................................................................................................ ១៨០
សិក្ខាបទវិភង្គ................................................................................................................ ១៨១
បទភាជនីយ.................................................................................................................. ១៨២
វារៈដែលមិនត្រូវអាបត្តិ.................................................................................................. ១៨៣

## សិក្ខាបទទី ៥

និទានឧបនន្ទសក្យបុត្ត.................................................................................................. ១៨៥
សេចក្តីបញ្ញត្ត និងសិក្ខាបទវិភង្គ........................................................................................ ១៨៧
បទភាជនីយ.................................................................................................................. ១៨៨
វារៈដែលមិនត្រូវអាបត្តិ.................................................................................................. ១៨៩

## សិក្ខាបទទី ៦

និទានឆព្វគ្គិយភិក្ខុ........................................................................................................ ១៩០
សេចក្តីបញ្ញត្ត................................................................................................................ ១៩១
សិក្ខាបទវិភង្គ និង បទភាជនីយ....................................................................................... ១៩២
វារៈដែលមិនត្រូវអាបត្តិ.................................................................................................. ១៩៣

# សន្ទឹកាចង្អុលប្រាប់មាតិកា

លេខទំព័រ

## សិក្ខាបទទី ៧

និទានឧបនន្ទសក្យបុត្ត........................................................................ ១៩៤
សេចក្តីបញ្ញត្ត........................................................................ ១៩៨
សិក្ខាបទវិភង្គ........................................................................ ១៩៩
បទភាជនីយ........................................................................ ២០១
វារៈដែលមិនត្រូវអាបត្តិ........................................................................ ២០២

## សិក្ខាបទទី ៨

និទានមហាអាមាត្យម្នាក់........................................................................ ២០៣
សេចក្តីបញ្ញត្ត........................................................................ ២០៥
សិក្ខាបទវិភង្គ........................................................................ ២០៦
បទភាជនីយ........................................................................ ២០៧
វារៈដែលមិនត្រូវអាបត្តិ........................................................................ ២០៨

## សិក្ខាបទទី ៩

និទានភិក្ខុច្រើនរូប........................................................................ ២០៩
សេចក្តីបញ្ញត្ត និងសិក្ខាបទវិភង្គ........................................................................ ២១១
បទភាជនីយ........................................................................ ២១៣
វារៈដែលមិនត្រូវអាបត្តិ........................................................................ ២១៤

## សិក្ខាបទទី ១០

និទានឆព្វគ្គិយភិក្ខុ........................................................................ ២១៥
សេចក្តីបញ្ញត្ត និង សិក្ខាបទវិភង្គ........................................................................ ២១៧
វារៈដែលមិនត្រូវអាបត្តិ........................................................................ ២១៩
ឧទ្ទាននៃបត្តវគ្គ........................................................................ ២២០

# សង្ខឹកាចង្អុលប្រាប់មាតិកា

បាចិត្តិយកណ្ឌ លេខទំព័រ

## មុសាវាទវគ្គ សិក្ខាបទទី ១


និទានហត្ថកភិក្ខុសក្យបុត្ត........................................ ២២១

សេចក្ដីបញ្ញត្ត........................................ ២២៣

សិក្ខាបទវិភង្គ........................................ ២២៤

បទភាជនីយ........................................ ២២៥

វារៈដែលមិនត្រូវអាបត្តិ........................................ ២៣៥


## សិក្ខាបទទី ២


និទានឆព្វគ្គិយភិក្ខុ........................................ ២៣៦

សេចក្ដីបញ្ញត្ត និងសិក្ខាបទវិភង្គ........................................ ២៤០

បទភាជនីយ........................................ ២៤១

វារៈដែលមិនត្រូវអាបត្តិ........................................ ២៧១


## សិក្ខាបទទី ៣


និទានឆព្វគ្គិយភិក្ខុ........................................ ២៧២

សេចក្ដីបញ្ញត្ត និងសិក្ខាបទវិភង្គ........................................ ២៧៤

បទភាជនីយ........................................ ២៧៥

វារៈដែលមិនត្រូវអាបត្តិ........................................ ២៨៤


## សិក្ខាបទទី ៤


និទានឆព្វគ្គិយភិក្ខុ........................................ ២៨៥

សេចក្ដីបញ្ញត្ត និងសិក្ខាបទវិភង្គ........................................ ២៨៦

បទភាជនីយ........................................ ២៨៧

វារៈដែលមិនត្រូវអាបត្តិ........................................ ២៨៨

# សង្ខឹកាចង្អុលប្រាប់មាតិកា

លេខទំព័រ

## សិក្ខាបទទី ៥


និទាននវកភិក្ខុច្រើនរូប.................................................. ២៨៩
សេចក្ដីបញ្ញត្ត និងសិក្ខាបទវិភង្គ.................................................. ២៩២
បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ.................................................. ២៩៣


## សិក្ខាបទទី ៦


និទានព្រះអនុរុទ្ធត្ថេរ.................................................. ២៩៥
សេចក្ដីបញ្ញត្ត និងសិក្ខាបទវិភង្គ.................................................. ៣០០
បទភាជនីយ.................................................. ៣០១
វារៈដែលមិនត្រូវអាបត្តិ.................................................. ៣០២


## សិក្ខាបទទី ៧


និទានឧទាយិភិក្ខុ.................................................. ៣០៣
សេចក្ដីបញ្ញត្តជាដំបូង.................................................. ៣០៥
សេចក្ដីបញ្ញត្តជាបន្ទាប់.................................................. ៣០៦
សិក្ខាបទវិភង្គ.................................................. ៣០៨
បទភាជនីយ.................................................. ៣០៩
វារៈដែលមិនត្រូវអាបត្តិ.................................................. ៣១០


## សិក្ខាបទទី ៨


និទានភិក្ខុច្រើនរូប.................................................. ៣១១
សេចក្ដីបញ្ញត្ត និងសិក្ខាបទវិភង្គ.................................................. ៣១៧
បទភាជនីយ.................................................. ៣១៨
វារៈដែលមិនត្រូវអាបត្តិ.................................................. ៣៣៥

# សង្ខេបរឿងពិស្ដារកាលិកា

លេខទំព័រ

## សិក្ខាបទទី ៩


និទានឧបនន្ទសក្យបុត្ត...................................................... ៣៣៦
សេចក្ដីបញ្ញត្ត និងសិក្ខាបទវិភង្គ...................................................... ៣៣៨
បទភាជនីយ...................................................... ៣៣៩
វារៈដែលមិនត្រូវអាបត្តិ...................................................... ៣៤១


## សិក្ខាបទទី ១០


និទានអាឡវិកភិក្ខុទាំងឡាយ...................................................... ៣៤២
សេចក្ដីបញ្ញត្ត និងសិក្ខាបទវិភង្គ...................................................... ៣៤៣
បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ...................................................... ៣៤៥
ឧទ្ទាននៃមុសាវាទវគ្គ...................................................... ៣៤៦


## ភូតគាមវគ្គ សិក្ខាបទទី ១


និទានអាឡវិកភិក្ខុទាំងឡាយ ...................................................... ៣៤៧
សេចក្ដីបញ្ញត្ត និងសិក្ខាបទវិភង្គ...................................................... ៣៤៩
បទភាជនីយ...................................................... ៣៥១
វារៈដែលមិនត្រូវអាបត្តិ...................................................... ៣៥២


## សិក្ខាបទទី ២


និទានឆន្នភិក្ខុ...................................................... ៣៥៣
សេចក្ដីបញ្ញត្តជាដំបូង...................................................... ៣៥៥
សេចក្ដីបញ្ញត្តជាបន្ទាប់ និងសិក្ខាបទវិភង្គ...................................................... ៣៥៨
បទភាជនីយ...................................................... ៣៥៩
វារៈដែលមិនត្រូវអាបត្តិ...................................................... ៣៦១

# សន្លឹកចង្អុលប្រាប់មាតិកា

លេខទំព័រ

## សិក្ខាបទទី ៣

និទានទព្វមល្លបុត្តភិក្ខុ........................................................................ ៣៦២
សេចក្តីបញ្ញត្តជាដំបូង........................................................................ ៣៦៣
សេចក្តីបញ្ញត្តជាបន្ទាប់........................................................................ ៣៦៤
សិក្ខាបទវិភង្គ និងបទភាជនីយ........................................................................ ៣៦៥
វារៈដែលមិនត្រូវអាបត្តិ........................................................................ ៣៦៧

## សិក្ខាបទទី ៤

និទានភិក្ខុច្រើនរូប........................................................................ ៣៦៨
សេចក្តីបញ្ញត្ត........................................................................ ៣៦៩
សិក្ខាបទវិភង្គ........................................................................ ៣៧០
បទភាជនីយ........................................................................ ៣៧២
វារៈដែលមិនត្រូវអាបត្តិ........................................................................ ៣៧៤

## សិក្ខាបទទី ៥

និទានសត្តរសវគ្គិយភិក្ខុ........................................................................ ៣៧៥
សេចក្តីបញ្ញត្ត និងសិក្ខាបទវិភង្គ........................................................................ ៣៧៧
បទភាជនីយ........................................................................ ៣៧៨
វារៈដែលមិនត្រូវអាបត្តិ........................................................................ ៣៨០

